# អដ្ឋកថា ព្រះសុត្តន្តបិដក

## បរមត្ថជោតិកា

## ខុទ្ទកបាឋៈ

## ភាគ ៥២

ពុទ្ធសករាជ ២៥៥៨

# អដ្ឋកថា ព្រះសុត្តន្តបិដក

## ខុទ្ទកនិកាយ ខុទ្ទកបាឋៈ

ឈ្មោះ

## បរមត្ថជោតិកា

## ភាគ ៥២

ពុទ្ធសករាជ ២៥៥៨

អធិប្បាយ

ខុទ្ទកបាឋៈ មាន ៩ សូត្រ

សរណៈ សិក្ខាបទ ទ្វត្តិំសាការ កុមារបញ្ហា មង្គល

រតន តិរោកុឌ្ឌ និធិកណ្ឌ និងមេត្តសូត្រ

# ព្រះសុត្តន្តបិដក

## ខុទ្ទកនិកាយ ខុទ្ទកបាឋៈ

## រួមមាន ៩ សូត្រ

## គឺ

១-អដ្ឋកថា ព្រះរតនត្រ័យ

២-អដ្ឋកថា សិក្ខាបទ

៣-អដ្ឋកថា ទ្វត្តិង្សាការ

៤-អដ្ឋកថា កុមារបញ្ហា

៥-អដ្ឋកថា មង្គលសូត្រ

៦-អដ្ឋកថា រតនសូត្រ

៧-អដ្ឋកថា តិរោកុឌ្ឌសូត្រ

៨-អដ្ឋកថា និធិកណ្ឌសូត្រ

៩-អដ្ឋកថា មេត្តសូត្រ

# ស្រៈនិងស្រ័យ

# *Signes et accents:*



# ស្រៈពេញតួ
# *Voyelles:*

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ខ្មែរ Cambodgien | អ | អា | ឥ | ឦ | ឧ | ឩ | ឯ | ឱ |
| ឡូម Romain | a | .ā | i | ī | u | ū | e | o |
| សៀម Siamois | อ | อา | อิ | อี | อุ | อู | เอ | โอ |
| លាវ Laotien | ອ | ອາ | ອິ | ອີ | ອຸ | ອູ | ເອ | ໂອ |
| លង្កា Cinghalais | අ | ආ | ඉ | ඊ | උ | ඌ | එ | ඔ |
| ភូមា Birman | အ | အာ | ဣ | ဤ | ဥ | ဦ | ဧ | ဩ |

# ព្យញ្ជនៈ

## *Consonnes:*

| | | | | | |
|---|---|---|---|---|---|
| ខ្មែរ Cambodgien | ក្ក | ខ្ខ | គ្គ | ឃ្ឃ | ង្ង |
| ឡូប Romain | k | kh | g | gh | ṅ |
| សៀម Siamois | ก | ข | ค | ฆ | ง |
| លាវ Laotien | ᨠ | ᨡ | ᨣ | ᨥ | ᨦ |
| លង្កា Cinghalais | ක | ඛ | ග | ඝ | ඞ |
| ភូមា Birman | က | ခ | ဂ | ဃ | င |

| | | | | | |
|---|---|---|---|---|---|
| ខ្មែរ Cambodgien | ច្ច | ឆ្ឆ | ជ្ជ | ឈ្ឈ | ញ្ញ |
| រ៉ូម Romain | *c* | *ch* | *j* | *jh* | *ñ* |
| សៀម Siamois | จ | ฉ | ช | ฌ | ญ |
| លាវ Laotien | ຈ | ຉ | ຊ | ຌ | ຎ |
| សិង្ហ Cinghalais | ච | ඡ | ජ | ඣ | ඤ |
| ភូមា Birman | စ | ဆ | ဇ | ဈ | ည |

| | | | | | |
|---|---|---|---|---|---|
| ខ្មែរ Cambodgien | ដ | ឋ | ឌ | ឍ | ណ |
| ឡូប Romain | *ṭ* | *ṭh* | *ḍ* | *ḍh* | *ṇ* |
| សៀម Siamois | ฏ | ฐ | ฑ | ฒ | ณ |
| លាវ Laotien | ᨭ | ᨮ | ᨯ | ᨰ | ᨱ |
| លង្កា Cinghalais | ට | ඨ | ඩ | ඪ | ණ |
| ភូមា Birman | ဋ | ဌ | ဍ | ဎ | ဏ |

| | | | | | |
|---|---|---|---|---|---|
| ខ្មែរ Cambodgien | ត | ថ | ទ | ធ | ន |
| រ៉ូម៉ាំង Romain | *t* | *th* | *d* | *dh* | *n* |
| សៀម Siamois | ต | ถ | ท | ธ | น |
| លាវ Laotien | ຕ | ຖ | ທ | ຘ | ນ |
| សឹង្ហ Cinghalais | ත | ථ | ද | ධ | න |
| ភូមា Birman | တ | ထ | ဒ | ဓ | န |

| | | | | | |
|---|---|---|---|---|---|
| ខ្មែរ Cambodgien | ប | ផ | ព | ភ | ម |
| រ៉ូម Romain | *p* | *ph* | *b* | *bh* | *m* |
| សៀម Siamois | ป | ผ | พ | ภ | ม |
| លាវ Laotien | ປ | ຜ | ພ | ຟ | ມ |
| លង្កា Cinghalais | ප | ඵ | බ | භ | ම |
| ភូមា Birman | ပ | ဖ | ဗ | ဘ | မ |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| ខ្មែរ Cambodgien | យ | រ | ល | វ | ស | ហ | ឡ | ំ | ។ |
| រូម Romain | *y* | *r* | *l* | *v* | *s* | *h* | *ḷ* | *ṃ* | ·/. |
| សៀម Siamois | ย | ร | ล | ว | ส | ห | ฬ | ํ | ฯ |
| លាវ Laotien | ຍ | ຣ | ລ | ວ | ສ | ຫ | ຬ | ໍ | ຯ |
| លង្កា Cinghalais | ය | ර | ල | ව | ස | හ | ළ | ං | ෴ |
| ភូមា Birman | ယ | ရ | လ | ဝ | သ | ဟ | ဠ | ံ | ၊ |

# ពាក្យផ្ដើម

ព្រះពុទ្ធវចនៈ គឺ ព្រះត្រៃបិដក ជាសាសនធម៌ ពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធជាម្ចាស់មានអង្គ ៩ គឺ ៖

**សុត្ត** បានដល់ ឧភតោវិភង្គ និទ្ទេសៈ ខន្ធកៈ បរិវារៈ ព្រះសូត្រផ្សេងៗ មានមង្គលសូត្រជាដើម ។

**គេយ្យ** បានដល់ ព្រះសូត្រដែលប្រកបដោយគាថាទាំងអស់ ។

**វេយ្យាករណ** គឺ ព្រះអភិធម្មបិដកទាំងអស់ ព្រះសូត្រដែលមិនមានគាថា និងពុទ្ធវចនៈដែលមិនបានចាត់ចូលក្នុងអង្គ ៨ ឈ្មោះថា វេយ្យាករណៈទាំងអស់ ។

**គាថា** គឺ ព្រះធម្មបទ ថេរគាថា ថេរីគាថា និងគាថាសុទ្ធ ៗ ដែលមិនមានឈ្មោះ ពោលដល់ ព្រះសូត្រក្នុងសុត្តនិបាត ។

**ឧទាន** គឺ ព្រះសូត្រ ៨២ សូត្រ ដែលព្រះពុទ្ធជាម្ចាស់ទ្រង់សម្ដែងដោយសោមនស្សញ្ញាណ ។

**ឥតិវុត្តក** គឺ ព្រះសូត្រ ១១០ សូត្រ ដែលផ្ដើមឡើងដោយពាក្យថា សេចក្ដី នេះ សមដូចពាក្យដែលព្រះមានព្រះភាគត្រាស់ទុក ។

**ជាតក** គឺ ជាការសម្ដែងរឿងក្នុងអតីតជាតិរបស់ព្រះពុទ្ធជាម្ចាស់ មានអបណ្ណកជាតកជាដើម មានទាំងអស់ ៥៥០ រឿង ។

**អព្ភូតធម៌** គឺ ព្រះសូត្រដែលបដិសំយុត្តដោយអច្ឆរិយព្ភូតធម៌ទាំងអស់ ។

**វេទល្ល** គឺ លំដាប់ពាក្យដែលអ្នកសួរបានយល់ច្បាស់ ព្រមទាំងបាននូវសេចក្ដី

រីកពាយ និងសួរជាបន្ត ។ ទៅ ។

ព្រះពុទ្ធវចនៈទាំងឡាយនេះ ដោយសភាវធម៌ គឺ ជាសច្ចធម៌ដែលទ្រង់ត្រាស់សម្ដែងថា ៖

ជាធម៌ដ៏ជ្រាលជ្រៅ ដឹងបានដោយលំបាក ដឹងតាម
ឃើញតាមបានដោយលំបាក ស្ងប់ ប្រណីត ល្អិត
មិនអាចដឹងបានដោយការត្រិះរិះ ប៉ុន្តែជាធម៌ដែល
បណ្ឌិតគប្បីដឹងបាន ។

ព្រោះសភាវៈនៃធម៌មានលក្ខណៈដូចពោលមកហើយនេះ ទើបត្រូវធ្វើឲ្យជាក់ច្បាស់ ឲ្យកើតការយល់ចូលចិត្តទាំងអត្ថ និងព្យញ្ជនៈ ដើម្បីញ៉ាំងការយល់ដឹងនូវធម៌ទាំងឡាយតាមសេចក្ដីពិតក្នុងរឿងនោះ ។ ។

ស្របតាមអធ្យាស្រ័យផ្សេងគ្នា របស់មនុស្សផ្សេងគ្នា ក្នុងទីកន្លែងផ្សេងៗ ដែលទ្រង់ឧបមាទុកដូចជាផ្កាឈូក ៤ ពួក ព្រះពុទ្ធជាម្ចាស់ព្រះអង្គឈ្វាសក្នុងវិធីសម្ដែងព្រះធម៌ តាមការបង្រៀនព្រះធម៌របស់ព្រះមានព្រះភាគ មាន ៣ ប្រការ គឺ ៖

១ ទ្រង់បង្រៀនឲ្យយល់ដឹងដ៏ក្រៃលែង ឃើញពិតក្នុងវត្ថុដែលគួរដឹង គួរឃើញ ។

២ ទ្រង់សម្ដែងធម៌មានហេតុផល ដែលអ្នកស្ដាប់អាចពិចារណាឃើញតាមសេចក្ដីពិតបាន ។

៣ ទ្រង់សម្តែងធម៌ដ៏អស្ចារ្យ គឺ អ្នកប្រតិបត្តិតាមនឹងបានទទួលនូវប្រយោជន៍សមគួរដល់ការប្រព្រឹត្តប្រតិបត្តិ ។

ព្រះមានព្រះភាគជាម្ចាស់ ទ្រង់ប្រកបដោយបាដិហារ្យ ទ្រង់ឆ្លាតក្នុងវោហារ ព្រោះទ្រង់ជាម្ចាស់នៃព្រះធម៌ មុននឹងទ្រង់សម្តែងនូវព្រះធម៌ដល់បុគ្គលណា ទ្រង់បានពិចារណាមើលនូវឧបនិស្ស័យរបស់បុគ្គលនោះ ដោយព្រះញាណ ទ្រង់ជ្រាបថា ការបានស្តាប់នូវពុទ្ធវាទ តែងនាំមកនូវប្រយោជន៍ ទើបទ្រង់សម្តែង ។

ក្រោយពីព្រះមានព្រះភាគជាម្ចាស់ទ្រង់បរិនិព្វានទៅ ទ្រង់បានតាំងព្រះធម៌-វិន័យទុកជាសាស្តាជំនួសព្រះអង្គ ។ តែការមិនមានសតិបញ្ញាបារមី ការយល់ខុសក្នុងធម៌របស់បុគ្គលនោះ បានធ្វើការអធិប្បាយសេចក្តីនៃព្រះធម៌វិន័យតាមការយល់ឃើញរបស់ខ្លួនឯង ជាហេតុធ្វើឲ្យមានការបដិបត្តិផ្សេង ៗ គ្នា មានសីល និងទិដ្ឋិផ្សេងៗ គ្នា រហូតមាននិកាយដល់ទៅ ១៨ ។

ព្រះអដ្ឋកថាចារ្យ ជ្រាបពុទ្ធាធិប្បាយទាំងដោយអត្ថ និងព្យញ្ជនៈនៃព្រះពុទ្ធវចនៈ ព្រោះការសិក្សាចាំស្ទាត់តគ្នាមកតាមលំដាប់ មានឆន្ទៈ និងមានឧស្សាហៈដ៏ខ្លាំងក្លា បានអធិប្បាយព្រះពុទ្ធវចនៈក្នុងព្រះត្រៃបិដក នូវសេចក្តីដែលលំបាកយល់ ឲ្យកើតការងាយយល់សម្រាប់អ្នកសិក្សា និងបដិបត្តិ ទើបសេចក្តីសំខាន់នៃគម្ពីរ ក្នុងព្រះពុទ្ធសាសនា ខាងក្រោយតគ្នារហូតមកមាន ៖

១ ព្រះសូត្រ គឺ ព្រះពុទ្ធវចនៈ ដែលហៅថា ព្រះត្រៃបិដក ទាំងព្រះវិនយ-

បិដក ព្រះសុត្តន្តបិដក និងព្រះអភិធម្មបិដក ។

២ **សុត្តានុលោម** គឺ គម្ពីរដែលព្រះអដ្ឋកថាចារ្យរចនាឡើង អធិប្បាយសេចក្តីដែលលំបាកក្នុងព្រះត្រៃបិដក ។

៣ **អាចរិយវាទ** វាទៈរបស់អាចារ្យផ្សេងៗ តាំងអំពីថ្នាក់ដីកា អនុដីកា និងបុព្វាចារ្យជំនាន់ក្រោយៗ ។

៤ **អត្តនោមតិ** ការគិតឃើញរបស់អ្នកនិយាយ អ្នកសម្តែងធម៌ក្នុងព្រះពុទ្ធសាសនា ។

ក្នុងកាលតមក មានការអធិប្បាយធម៌ប្រភេទអាចរិយវាទ គឺ កាន់តាមអាចារ្យរបស់ខ្លួន ទូន្មានទុកជាមួយអត្តនោមតិ ទៅតាមមតិរបស់ខ្លួនឯងដោយច្រើន ទាំងនេះអាចនឹងមាន ព្រោះគម្ពីរព្រះពុទ្ធសាសនា ដែលមានគោលសំខាន់ គឺ ព្រះត្រៃបិដក និងអដ្ឋកថាមិនទាន់បានប្រែ អដ្ឋកថាចំណែកច្រើននៅជាភាសាបាលី បុគ្គលដែលមានឆន្ទៈក្នុងភាសាបាលីតិចតួច សំនួនភាសាបាលីដែលប្រែចេញមកហើយ លំបាកដល់ការយល់របស់អ្នកដែលមិនបានសិក្សាភាសាបាលីជាមុន ព្រោះខ្វះកល្យាណមិត្ត ខ្វះសប្បុរស ដែលមានការចេះដឹងក្នុងព្រះពុទ្ធសាសនាជាដើម ។

ការអធិប្បាយធម៌ ដែលជាផលនៃការត្រាស់ដឹងរបស់ព្រះអរហន្តសម្មាសម្ពុទ្ធជាម្ចាស់មានអន្តរាយច្រើន ព្រោះមានឱកាសដែលយល់ខុស និយាយខុស បដិបត្តិខុស ។ ព្រះត្រៃបិដកប្រៀបដូចជារដ្ឋធម្មនុញ្ញ ច្បាប់ទូទៅនឹង

ជំទាស់ដល់ច្បាប់រដ្ឋធម្មនុញ្ញមិនបាន យ៉ាងណា ការអធិប្បាយធម៌ជំទាស់នឹងព្រះត្រៃបិដក ពុទ្ធសាសនិកជនដែលល្អប្រកាន់ថា ធ្វើមិនបានដូចគ្នា ។

សូមអានុភាពនៃព្រះរតនត្រ័យ ប្រតិស្ឋានក្នុងហឫទ័យ
របស់ពុទ្ធសាសនិកជនទាំងឡាយ សូមបានជួបប្រសព្វ
សេចក្តីចម្រើនក្នុងព្រះធម៌ ដែលព្រះមានព្រះភាគទ្រង់
ប្រកាសទុកល្អហើយបរិបូណ៌ដោយអត្ថ និងព្យញ្ជនៈ ។

ក្រុមរៀបរៀងព្រះអដ្ឋកថា

# និទានកថា

សេចក្តីសង្ខេបថា ក្នុងទីបំផុតនៃការសម្តែងយមកប្បាដិហារ្យ ព្រះមានព្រះភាគជាម្ចាស់ ស្តេចចូលចាំវស្សានៅលើផ្ទាំងបណ្ឌុកម្ពលសិលាសនៈក្រោមដើមបារិច្ឆត្តកព្រឹក្សក្នុងទេវនគរ ទ្រង់ធ្វើព្រះមាតាឲ្យជាអង្គសាក្សី ត្រាស់ព្រះអភិធម្មកថាដល់ទេវបរិស័ទ លុះទ្រង់សម្តែងបករណ៍ធម្មសង្គណីបាន ១០០ ឆ្នាំកន្លងទៅ ពួកភិក្ខុវជ្ជីបុត្រសម្តែងវត្ថុ ១០ ប្រការ ដែលប្រាសចាកព្រះធម៌-វិន័យ គឺ ៖

១ ភិក្ខុទុកដាក់អំបិលក្នុងក្លាក់សម្រាប់ឆាន់ជាមួយអាហារថា គួរ ។

២ ភិក្ខុឆាន់អាហារពេលព្រះអាទិត្យជ្រេទៅ ២ ធ្នាប់ គួរ ។

៣ ភិក្ខុហាមភត្តហើយ ចូលទៅក្នុងចន្លោះស្រុក ហើយឆាន់ភត្តដែលមិនបានធ្វើវិនយកម្មមុន មិនជាដែនរបស់ភិក្ខុឈឺ គួរ ។

៤ ភិក្ខុនៅក្នុងអាវាសជាមួយគ្នា បំបែកគ្នាធ្វើសង្ឃកម្ម គួរ ។

៥ ភិក្ខុធ្វើឧបោសថកម្មមិនរង់ចាំឆន្ទានុមតិ គួរ ។

៦ ប្រការបដិបត្តិដែលឧបជ្ឈាយ៍ អាចារ្យធ្លាប់ប្រព្រឹត្តមកខុសត្រូវយ៉ាងណា ប្រព្រឹត្តតាម គួរ ។

៧ ភិក្ខុហាមភត្តហើយ ឆាន់ទឹកដោះស្រស់ដែលមិនទាន់ប្រែជាទឹកដោះជូរ គួរ ។

៨ ភិក្ខុផឹកស្រាខ្សោយៗ គួរ ។

៩ ភិក្ខុក្រាលសំពត់និសីទនៈដែលមិនមានជាយ គួរ ។

១០ ភិក្ខុទទួល ឬត្រេកអរចំពោះមាស និងប្រាក់ ដែលគេទុកដាក់ដើម្បីខ្លួន គួរ ។

ព្រះយសត្ថេរដែលជាបុត្ររបស់ព្រាហ្មណ៍ ឈ្មោះថា កាកណ្ឌកៈ បានស្តាប់ វត្ថុ ១០ ប្រការនោះហើយ បានកាន់យកព្រះចៅអសោករាជដែលជាព្រះឱរសរបស់ព្រះចៅសុសុនាគៈធ្វើជាសម្លាញ់ ហើយជ្រើសរើសព្រះថេរៈ ៧០០ អង្គ ក្នុងចំណោម ភិក្ខុ ១.២០០.០០០ អង្គ គឺ ( ដប់ពីរសែន ) ញាំញីវត្ថុ ១០ ប្រការទាំងនោះ ហើយលើកសរីរៈ គឺ ព្រះធម៌វិន័យឡើងសង្គាយនា ។

ភិក្ខុវជ្ជីបុត្រមានប្រមាណ ១០.០០០ អង្គ ត្រូវព្រះធម្មសង្គាហកត្ថេរទាំងឡាយគ្របសង្កត់ហើយ គឺ តិះដៀលហើយ ទើបស្វែងរកពួកគណៈគ្រាបានពួកដែលជាទុព្វលៈដ៏សមគួរដល់ខ្លួន ក៏ចាត់តាំងសម្នាក់ត្រកូលអាចារ្យថ្មី ឈ្មោះថា មហាសង្ឃិកៈ និងឯកព្យោហារិកៈ ដែលបែកចេញមកពីត្រកូលអាចារ្យសង្ឃិកៈនោះ ។ ត្រកូលអាចារ្យពីរពួកដទៃទៀត គឺ បញ្ញត្តិវាទៈ និងពហុលិយៈ ដែលមានឈ្មោះ ម្យ៉ាងទៀតថា ពហុស្សុតិកៈ ដែលបែកចេញមកពីនិកាយគោកុលិកៈ ។ អាចរិយវាទដទៃទៀត ឈ្មោះថា ចេតិយវាទ កើតឡើងហើយក្នុងរវាងនិកាយពហុលិយៈនោះៗ ឯង ។ ក្នុងរយៈនៃឆ្នាំទីពីរ គឺ ក្នុងព្រះពុទ្ធសករាជ ២០០ ត្រកូលអាចារ្យទាំងប្រាំ បានកើតឡើងពីត្រកូលអាចារ្យមហាសង្ឃិកៈ ដោយប្រការដូច្នេះ ។

ត្រកូលអាចារ្យទាំងប្រាំនោះ រួមជាមួយមហាសង្ឃិកៈដើមមួយ ក៏បាន

ជាប្រាំមួយត្រកូល ។ ក្នុងពុទ្ធសករាជ ២០០ ឆ្នាំ អាចរិយវាទទាំងពីរ គឺ មហិសាសកៈ និងវជ្ជីបុត្តកៈកើតឡើង ដែលបែកចេញមកពីថេរវាទ ។ ក្នុងបណ្តា អាចរិយវាទទាំងពីរនោះ អាចរិយវាទទាំងបួន គឺ ធម្មុត្តរិយៈ ១ ភទ្រយានិកៈ ១ ឆន្នាគារិកៈ ១ សម្មិតិយៈ ១ កើតឡើង ព្រោះបែកចេញមកពីនិកាយវជ្ជីបុត្តកៈ ។ ក្នុងពុទ្ធសករាជ ២០០ ឆ្នាំ នោះឯង អាចរិយ-វាទពីរពួក គឺ សព្វត្ថិកវាទ និង ធម្មគុត្តិកៈកើតឡើង ព្រោះការបែកចេញពីត្រកូលអាចារ្យមហិសាសកៈទៀត ។ កាលនិកាយកស្សបិកៈទាំងឡាយបែកគ្នាហើយ ក៏ជាហេតុឲ្យនិកាយឈ្មោះថា សង្កន្តិកៈផ្សេងទៀតកើតឡើង កាលនិកាយសង្កន្តិកៈទាំងឡាយបែកគ្នាហើយ និកាយឈ្មោះថា សុត្តវាទក៏កើតឡើង ។ អាចរិយវាទ ១១ និកាយនេះកើតឡើងហើយ ព្រោះបែកចេញមកពីថេរវាទយ៉ាងនេះ ដោយប្រការដូច្នេះ ។ អាចរិយវាទ ១១ និកាយនេះ រួមទាំងថេរវាទដើម ក៏ជា ១២ និកាយ ។

ក្នុងពុទ្ធសករាជ ២០០ អាចរិយវាទ គឺ លទ្ធិនៃអាចារ្យទាំងអស់រួម ១៨ និកាយ គឺ ១២ និកាយបែកចេញអំពីថេរវាទនេះ និងនិកាយអាចរិយវាទ ៦ បែកចេញមកពីត្រកូលអាចារ្យមហាសង្ឃិកៈទាំងឡាយនោះដូច្នេះឯង ។

ពាក្យថា និកាយ ១៨ ក្តី ត្រកូលអាចារ្យ ១៨ ក្តី ជាឈ្មោះរបស់និកាយ ដែលពោលមកហើយនោះឯង ។ មយ៉ាងទៀត បណ្តានិកាយទាំង ១៨ នោះ បណ្ឌិតគប្បីជ្រាបថា ជានិកាយដែលបែកចេញពីគ្នា , ចំណែកថេរវាទបណ្ឌិតគប្បីជ្រាបថា ជានិកាយដែលមិនបែកគ្នា គឺ តាំងនៅដូចដើម ។

## តារាងសម្តែងនិកាយសង្ឃក្នុងសតវត្ស ទី ៣




ភិក្ខុដ៏លាមកទាំងឡាយ ដែលជាពួកវជ្ជីបុត្តជាអធម្មវាទី ត្រូវព្រះថេរៈជាធម្មវាទីទាំងឡាយបានបណ្តេញចេញហើយ បានពួកដទៃទៀត ទើបផ្តើមតាំងជាគណាចារ្យថ្មី ៗ

(ស្រង់ចេញពីអដ្ឋកថា បរមត្ថទីបនី អដ្ឋកថាអភិធម្មបិដក កថាវត្ថុ)

# ប្រវត្តិអ្នកតែងព្រះអដ្ឋកថា

ព្រះពុទ្ធឃោសត្ថេរ ដែលយើងនិយមហៅថា ព្រះពុទ្ធឃោសាចារ្យ បានប្រាប់ទុកខាងក្រោយនៃអារម្ភកថា ព្រះគម្ពីរអដ្ឋកថាអដ្ឋសាលិនីថា ភិក្ខុមាននាមថា ពុទ្ធឃោសៈដូចគ្នា បានអារាធនាលោកឲ្យតែងព្រះគម្ពីរនេះឡើង (គម្ពីរអដ្ឋសាលិនី) ។ ទាំងនេះឃើញថា នាមព្រះពុទ្ធឃោសៈមានច្រើន ដូចក្នុងសម័យនោះ ក៏នៅមានព្រះពុទ្ធឃោសៈអារាធនាឲ្យព្រះ ពុទ្ធឃោសៈតែងគម្ពីរនេះជាដើម ។

កិត្តិសព្ទរបស់ព្រះពុទ្ធឃោសៈ ជាមង្គលដ៏អង្វែង ព្រោះលោកបានធ្វើការកសាងព្រះគម្ពីរទុកយ៉ាងច្រើនសន្ធឹកសន្ធាប់ ។ ព្រះពុទ្ធឃោសាចារ្យជាអ្នកស្រុកជម្ពូទ្វីប គឺ ប្រទេសឥណ្ឌាប៉ែកខាងត្បូង មានជីវិតរស់នៅក្នុងរវាងពុទ្ធសករាជ ៩៤៥ ដល់ ១.០០០ ឆ្នាំ កើតក្នុងត្រកូលព្រាហ្មណ៍នាតំបន់ ពុទ្ធគយាដែនមគធៈ ជិតស្ថានទីត្រាស់ដឹង ។ មុនចូលមកបួសក្នុងព្រះពុទ្ធសាសនា បានសិក្សាសិល្ប៍សាស្ត្រទាំងពួង រៀនចប់ត្រៃវេទ បានត្រាច់ទៅកាន់ទីផ្សេងៗ ក្នុងជម្ពូទ្វីប បានឆ្លើយបញ្ហាជាមួយសមណៈ និងព្រាហ្មណ៍ទាំងឡាយ ប្រាកដជាអ្នកមានសតិបញ្ញាច្រើន ។ សមណព្រាហ្មណ៍ និងបណ្ឌិតដទៃៗ មិនអាចឆ្លើយដោះស្រាយបញ្ហាព្រាហ្មណ៍កំលោះនេះបាន ។ តែព្រាហ្មណ៍កំលោះនេះអាចដោះស្រាយបញ្ហា ដែលសមណព្រាហ្មណ៍ និងបណ្ឌិតសួរបាន ដូច្នោះព្រាហ្មណ៍កំលោះ ទើបមានឈ្មោះបោះសំឡេងខ្ទរខ្ទារ គ្របសង្កត់រហូតអស់

ទាំងសកលជម្ពូទ្វីប ។

គ្រាមួយ ព្រាហ្មណ៍កំលោះដើរផ្លូវ មកដល់វត្តមួយដែលជាស្ថានទី ពុទ្ធគយា បានជួបជាមួយព្រះរេវតត្ថេរ ដែលជាព្រះមហាខីណាស្រពសម្រេច បដិសម្ភិទា ៤ ។

ថ្ងៃមួយព្រាហ្មណ៍កំលោះ បានស្វាធ្យាយមន្តក្នុងគម្ពីរបតញ្ជលី យ៉ាង ត្រឹមត្រូវ ពីរោះគួរចាប់ចិត្តរហូតដល់យប់ ព្រះថេរៈបានឮសំឡេងព្រាហ្មណ៍ នោះស្វាធ្យាយហើយ ក៏ដឹងថាជាអ្នកមានសតិបញ្ញាច្រើន ទើបហៅព្រាហ្មណ៍ នោះមក ដើម្បីបានសន្ទនាគ្នា ព្រាហ្មណ៍កំលោះបានសួរបញ្ហាផ្សេងៗ ក្នុង គម្ពីរត្រៃវេទ ដែលខ្លួននៅមានការសង្ស័យមិនយល់ចំពោះព្រះថេរៈ ព្រះថេរៈ ក៏ឆ្លើយអធិប្បាយបានទាំងអស់ ក្រោយមកព្រះថេរៈទើបសួរបញ្ហាក្នុងព្រះ អភិធម្មខ្លះៗ ព្រាហ្មណ៍ កំលោះឆ្លើយមិនបាន ទើបសួរថា នេះឈ្មោះថាអ្វី ព្រះថេរៈឆ្លើយថា ឈ្មោះថា **ពុទ្ធមន្ត** ទើបសូមរៀនពុទ្ធមន្ត ហើយក៏បានបព្វជ្ជា ឧបសម្បទាក្នុងព្រះពុទ្ធសាសនា បានរៀនព្រះពុទ្ធវចនៈ គឺ ព្រះត្រៃបិដក បាន ប្រាកដឈ្មោះថា ព្រះពុទ្ធឃោសៈ ។

កាលព្រះពុទ្ធឃោសៈ គង់នៅក្នុងវត្តនាតំបន់ពុទ្ធគយានោះ បានរចនា បករណ៍ឈ្មោះ **ញាណោទ័យ** ទុកក្នុងវត្ត ហើយផ្តើមរចនាគម្ពីរអដ្ឋកថា ឈ្មោះ អដ្ឋសាលិនី ដែលជាអដ្ឋកថាព្រះគម្ពីរធម្មសង្គណីបករណ៍ និងគម្ពីរ បរិត្តដ្ឋកថា គឺ អដ្ឋកថាព្រះត្រៃបិដកច្បាប់សង្ខេប ព្រះរេវតមហាថេរៈបាន ឃើញអដ្ឋកថា ដែលលោកបានរចនាហើយ ទើបណែនាំលោកថា ក្នុង

ជម្ពូទ្វីប មានតែព្រះបាលីព្រះត្រៃបិដកប៉ុណ្ណោះ មិនមានអដ្ឋកថាបាលីព្រះត្រៃបិដកនៅឡើយ តែក្នុងលង្កាទ្វីបនៅមាន ព្រោះព្រះថេរៈទាំងឡាយមានព្រះសារីបុត្ត ( ឈ្មោះដូចអគ្គសាវ័ក ) ជាដើម បានរចនាទុក និងតមកព្រះមហិន្ទត្ថេរបានត្រួតពិនិត្យ ហើយរចនាទុកជាភាសាសីហឡៈ សូមឲ្យព្រះពុទ្ធឃោសៈទៅលង្កាទ្វីប ត្រួតពិនិត្យមើលអដ្ឋកថាទាំងនេះ ហើយប្រែមកជាភាសាមគធៈវិញ នឹងបានជាប្រយោជន៍ និងសេចក្តីចម្រើនដល់មនុស្សលោកទាំងពួង កាលព្រះថេរៈបានណែនាំយ៉ាងនេះហើយ ព្រះពុទ្ធឃោសៈក៏មានបីតិសោមនស្ស ក្រាបបង្គំលាព្រះឧបជ្ឈាយ៍ និងព្រះភិក្ខុសង្ឃ ហើយធ្វើដំណើរទៅកាន់លង្កាទ្វីបតាមទូក បានជួបព្រះពុទ្ធទត្តត្ថេរ ដែលបាននិមន្តជ្រួសផ្លូវគ្នានៅកណ្តាលសមុទ្រ បានសន្ទនាគ្នា និងប្រាស្រ័យទាក់ទងរឿងប្រែគម្ពីរជាភាសាមគធៈ ហើយធ្វើដំណើរតទៅ រហូតដល់កំពង់ផែក្រុងលង្កា សម័យនោះ គឺ ជាកាលរបស់ក្សត្រិយ៍លង្កាទ្រង់ព្រះនាមថា **មហានាម** មាននាម ដទៃទៀតថា (សិរិនិវាស) ខ្លះ (សិរិកុថៈ) ខ្លះ (សិរិកូដ្ឋៈ) ខ្លះ ក្នុងពុទ្ធសករាជ ( ៩៥២-៩៧៤ ) ។

កាលដែលព្រះពុទ្ធឃោសៈទៅដល់លង្កា បានទៅជួបព្រះភិក្ខុសង្ឃក្នុងមហាវិហារនាក្រុងអនុរាធបុរៈ ហើយបានទៅកាន់សម្នាក់របស់ព្រះសង្ឃបាលត្ថេរ ដែលជាព្រះសង្ឃរាជនៅក្នុងក្រុងអនុរាធបុរៈ នៃសម្នាក់មហាបធាន បានស្តាប់អដ្ឋកថាជាភាសាសីហឡៈ និងថេរវាទទាំងអស់ហើយ បានធ្វើទុកក្នុងចិត្តថា ជាពុទ្ធាធិប្បាយរបស់ព្រះមានព្រះភាគពិត ទើបបានសុំការអនុមតិអំពីសង្ឃ

ដើម្បីបានឱកាសរចនា អដ្ឋកថាព្រះត្រៃបិដក ជាភាសាមគធៈ ។ ដើម្បីផ្ទៀងផ្ទាត់ការចេះដឹង និងសមត្ថភាពរបស់ព្រះពុទ្ធឃោសៈ គណៈសង្ឃលង្កាដែលមានព្រះសង្ឃបាលត្ថេរជាប្រធាន បានប្រគល់ព្រះគាថា ២ ព្រះគាថា ឲ្យលោករចនាសិន ទើបអនុញ្ញាតឲ្យលោកត្រួតពិនិត្យគម្ពីរទាំងអស់ ។ ព្រះពុទ្ធឃោសៈបានរចនាបករណ៍ឈ្មោះ វិសុទ្ធិមគ្គឡើង មានសេចក្ដីយ៉ាងល្អប្រសើរ ហួតដល់ព្រះសង្ឃលង្កាទទួលស្គាល់នូវសេចក្ដីជំនាញរបស់លោក តាមប្រវត្តិបាននិយាយថា ដើម្បីនឹងប្រកាសនូវភាពជំនាញរបស់ព្រះពុទ្ធឃោសៈនោះឲ្យប្រាកដ ទេវតាបានបណ្ដាលឲ្យគម្ពីរដែលរចនាស្រេចហើយបាត់ទៅ ព្រះពុទ្ធឃោសៈក៏បានរចនាជាថ្មីម្ដងទៀត ទេវតាក៏បណ្ដាលឲ្យបាត់ទៀត លោកក៏បានរចនាឡើងម្ដងទៀតគម្រប់ ៣ ដង បន្ទាប់មក ក៏ថ្វាយគម្ពីរដែលបានរចនាទាំងពីរគម្ពីរនោះវិញ វេលានោះ ទើបបានគម្ពីរវិសុទ្ធិមគ្គ ជា ៣ ចប់ ព្រះពុទ្ធឃោសៈក៏បាននាំគម្ពីរទាំង ៣ ចប់នោះ ថ្វាយដល់ព្រះភិក្ខុសង្ឃ ព្រះភិក្ខុសង្ឃបានអានទាំងបីគម្ពីរ ប្រៀបធៀបគ្នាហើយ មិនមានការខុសគ្នា ទាំងដោយព្រះគម្ពីរ ឬអក្ខរៈ ឬដោយបទ ឬដោយព្យញ្ជនៈ ឬដោយអត្ថ ឬដោយបទដើម បទចុង ឬដោយថេរវាទ ឬដោយព្រះបាលី ទាំងឡាយក្នុងកន្លែងណានីមួយឡើយ ទាំងបីច្បាប់ដូចគ្នា ដើម្បីសម្ដែងសេចក្ដីអង់អាច យ៉ាងក្រៃលែងរបស់លោក ទេវតាទាំងឡាយបានសាធុការ ព្រះសង្ឃប្រមាណ ១.០០០ អង្គ ប្រជុំគ្នាក្នុងមហាវិហារបានឃើញសេចក្ដីអស្ចារ្យ នាំគ្នាត្រេកអរកោតសរសើរ សោមនស្ស សាធុការ បានប្រកាសថា លោកអង្គនេះ ជា

ព្រះមេត្តេយ្យពោធិសត្វពិតប្រាកដ និងបានអនុមតិឲ្យលោកប្រែគម្ពីរ ពីភាសាសីហឡ:មកជាភាសាមគធ: ។

ក្នុងគ្រានោះ ព្រះមហានាមក្សត្រិយ៍នៃលង្កា ទ្រង់បានស្តាប់កិត្តិគុណរបស់លោក ស្តេចបានចេញចាកពីព្រះនគរទៅដល់មហាវិហារ ទ្រង់នមស្ការព្រះសង្ឃ ហើយនមស្ការព្រះពុទ្ធឃោស: និមន្តឲ្យគង់នៅក្នុងប្រាសាទមួយឈ្មោះ **បធានឃរ** នាទិសទក្សិណរបស់មហាវិហារ បានប្រែអដ្ឋកថាភាសាសីហឡ: ជាអដ្ឋកថាព្រះត្រៃបិដកភាសាមគធ: ។

អដ្ឋកថាក្នុងភាសាសីហឡ:ពីបុរាណនោះមាន ៣ យ៉ាង គឺ ៖

១ មហាអដ្ឋកថា

២ បច្ចរិយអដ្ឋកថា

៣ កុរុន្ទីអដ្ឋកថា អដ្ឋកថាដែលបានលើកឡើងកាន់សង្គាយនាព្រះមហិន្ទត្ថេរនាំមកពីជម្ពូទ្វីប ហើយរចនាទុកជាភាសាសីហឡ: ឈ្មោះ **មហាអដ្ឋកថា** ។

អដ្ឋកថា ដែលព្រះភិក្ខុទាំងឡាយប្រជុំគ្នារចនានៅក្នុងផែ (ផ្ទះទឹក) ដែលក្នុងភាសាសីហឡ:ហៅថា បច្ចរិយ: ឈ្មោះថា **បច្ចរិយអដ្ឋកថា** ។

អដ្ឋកថា ដែលព្រះភិក្ខុសង្ឃទាំងឡាយប្រជុំគ្នារចនា ក្នុងកុរុន្ទីវេឡុ-វិហារ ឈ្មោះថា **កុរុន្ទីអដ្ឋកថា** ។

វាទ:ដែលអាចារ្យទាំងឡាយក្នុងកាលមុន មានព្រះអាចារ្យថ្នាក់ព្រះថេរ:ជាដើម បានរចនាទុកដោយកាន់យកន័យព្រះបាលីឈ្មោះថា **ថេរវាទ** ។

គម្ពីរអដ្ឋកថាភាសាសីហឡ: ដែលព្រះពុទ្ធឃោសៈបានប្រែមកជាអដ្ឋ-កថាព្រះត្រៃបិដកជាភាសាមគធ: មានច្រើនជាងពាក់កណ្ដាលនៃគម្ពីរអដ្ឋកថាទាំងអស់ មានរាយនាមព្រះគម្ពីរដូច្នេះ ៖

១ សមន្តបាសាទិកា អដ្ឋកថាព្រះវិន័យបិដក

២ កង្ខាវិតរណី ឬមាតិកដ្ឋកថា អដ្ឋកថាព្រះបាតិមោក្ខ

៣ សុមង្គលវិលាសនី អដ្ឋកថាទីឃនិកាយ

៤ បបញ្ចសូទនី អដ្ឋកថាមជ្ឈិមនិកាយ

៥ សារត្ថប្បកាសិនី អដ្ឋកថាសំយុត្តនិកាយ

៦ មនោរថបូរណី អដ្ឋកថាអង្គុត្តរនិកាយ

៧ បរមត្ថជោតិកា អដ្ឋកថាខុទ្ទកបាឋ: និងសុត្តនិបាត

៨ ធម្មបទដ្ឋកថា អដ្ឋកថាធម្មបទ

៩ ជាតកដ្ឋកថា អដ្ឋកថាជាតក

១០ អដ្ឋសាលិនី អដ្ឋកថាធម្មសង្គណីបករណ៍

១១ សម្មោហវិនោទនី អដ្ឋកថាវិភង្គបករណ៍

១២ បញ្ចករណដ្ឋកថា ឈ្មោះបរមត្ថទីបនី ជាព្រះអដ្ឋកថាព្រះអភិធម្មទាំងប្រាំគម្ពីរ គឺ ធាតុកថា កថាវត្ថុ បុគ្គលបញ្ញត្តិ យមក និងបដ្ឋាន ។

១៣ វិសុទ្ធិមគ្គ បករណ៍វិសេសពោលដោយ សីល សមាធិ បញ្ញា ។

១៤ ញាណោទ័យ តែងមុនកាលទៅឥណ្ឌា ច្បាប់ដើមអន្តរធានហើយ ។

១៥ បរិត្តដ្ឋកថា អដ្ឋកថាព្រះត្រៃបិដកច្បាប់សង្ខេប ច្បាប់ដើមអន្តរធាន

ហើយ ។

ព្រះគម្ពីរទាំងនេះ បានជាប្រយោជន៍ដ៏ក្រៃលែង ចំពោះមនុស្សក្នុងប្រទេសផ្សេងៗ លោកពោលទុកថា គម្ពីរទាំងអស់ប្រើពេលវេលាត្រឹមតែ ១ ឆ្នាំ ក៏បានសម្រេច បានកើតសេចក្ដីអស្ចារ្យ សូម្បីផែនដីក៏កម្រើកញាប់ញ័រ ។

លទ្ធផលការងារ វណ្ណកម្មរបស់ព្រះពុទ្ធឃោសៈ អ្នកសិក្សាភាសាបាលីទូទៅ បានសរសើរ និងរាប់អានលោកថា ជាបុរាណាចារ្យដ៏សំខាន់ក្រៃលែងរបស់លោក ។

# រាយនាមលោកអ្នកមានឧបការៈ

លោកគ្រូអគ្គបណ្ឌិតធម្មាចារ្យ ប៊ុត សាវង្ស

លោកគ្រូធម្មបណ្ឌិត រស់ សុជាត

លោកគ្រូវិនិយាចារ្យ គាំ អ៊ីវ

ឧបាសក ឈ្លាត ហ៊ាន ឧបាសក ណាក់ ម៉ៅ

ឧបាសក ធុំ ធួន ឧបាសក ហុក សីងហួត

ឧបាសក ជីម ជំនិត ឧបាសក កើត ធិត្យ

ឧបាសក សន ម៉ារឌី ឧបាសក ហាយ ចំរើន

ឧបាសក អ៊ឹម វ៉ៃយ៉ា ឧបាសក សុក្រ ហ៊ិត

ឧបាសក សោម រតនៈ ឧបាសក សំ ឆាយ

ឧបាសក ម៉ៅ ដុន ឧបាសក ជា ស៊ីថាន

ឧបាសិកា ថាប់ លឿម ឧបាសិកា ហាយ សារ៉ាត់

ឧបាសិកា ប៊ុត សុម៉ាលី ឧបាសិកា យស សម្បត្តិ

ឧបាសិកា ពូ ហ៊ាង ឧបាសិកា ប៊ុត សេដាដួង

ឧបាសិកា ប៉ែន រមណី

ព្រមទាំងពុទ្ធបរិស័ទក្នុង និងក្រៅប្រទេស

# រាយនាមអ្នកប្រែសម្រួល

ព្រះសង្ឃអាស្រមព្រះគន្ធកុដិ

| | | |
|---|---|---|
| ព្រះភិក្ខុអគ្គធិន្នោ | នូវ បូរ៉ា | ប្រធានអាស្រម |
| ព្រះភិក្ខុចិត្តរក្ខិតោ | សំ សម្បត្តិ | ធម្មាចារ្យ |
| ព្រះភិក្ខុធម្មប្បញ្ញោ | ជុំ សារឿន | ធម្មាចារ្យ |
| ព្រះភិក្ខុវរធម្មោ | ជុត តៅ | ធម្មាចារ្យ |
| ព្រះភិក្ខុតេជធរោ | ធាវ ធាន | ធម្មាចារ្យ |

សាមណេរ កោវិទោ ឡោះសូវៀត សមណសិស្សសាលាសតិប្បដ្ឋាន

ផ្នែកឧបាសក

ឧបាសក ហាយ ចំរើន

ឧបាសក ជឹម ជំនិត

# បត្តិទានកថា

ការរៀបរៀង ប្រែសម្រួលអដ្ឋកថាព្រះត្រៃបិដកជាខេមរភាសា ដើម្បី

បូជាចំពោះព្រះរតនត្រៃ ម្យ៉ាងទៀតដើម្បីតម្កល់ទុកជាសម្បត្តិវប្បធម៌ជាតិ និងជាចំណែកចូលរួមក្នុងការតាំងនៅនៃព្រះសទ្ធម្មគម្រប់៥.០០០ព្រះវស្សា ។

យើងជាក្រុមប្រែសម្រួលអដ្ឋកថា សូមលើកនូវបុណ្យកុសលដែលកើតឡើងអំពីការងារនេះៈ–

ឧទ្ទិសថ្វាយ និងគោរពជូន :

–ព្រះមហាវរក្សត្រិយ៍ និងមហាវរក្សត្រិយានី

–ព្រះមហាក្សត្រិយ៍នៃព្រះរាជាណាចក្រកម្ពុជា

–សម្តេចព្រះសង្ឃរាជទាំងពីរគណៈ

–មាតាបិតានៃយើងខ្ញុំទាំងអស់គ្នា

–លោកគ្រូអគ្គបណ្ឌិតធម្មាចារ្យ ប៊ុត សាវង្ស

–លោកគ្រូធម្មបណ្ឌិត រស់ សុជាត

–សព្វមុខមន្ត្រីរាជការ និងប្រជានុរាស្ត្រនៃកម្ពុជរដ្ឋ

–សព្វសត្វទាំងអស់ក្នុងត្រ័យភព

សូមលោកត្រេកអរ អនុមោទនានូវចំណែកបុណ្យនេះ

សូមអនុមោទនា ។.....

ក្រុមរៀបរៀង និងប្រែសម្រួល

# មាតិកាធម៌

**ឈ្មោះធម៌** **ទំព័រ**

## ខុទ្ទកនិកាយ ខុទ្ទកបាឋៈ បឋមភាគ


### អដ្ឋកថាខុទ្ទកនិកាយ ខុទ្ទកបាឋៈ

ពាក្យប្រារព្ធ ១
ការកំណត់ខុទ្ទកបាឋៈ ៣
និទានសោធនៈ ៨

### អដ្ឋកថា ព្រះរតនត្រ័យទី ១

អធិប្បាយ រឿងព្រះពុទ្ធ ១២
អធិប្បាយ សរណគមន៍ និងអ្នកដល់សរណគមន៍ ១៨
អធិប្បាយ សរណគមន៍ដាច់ មិនដាច់ និងផល ២១
អធិប្បាយ សរណៈដែលគប្បីដល់ ២៤
អធិប្បាយ សរណៈ គឺ ព្រះធម៌ និងព្រះសង្ឃ ៣១
អធិប្បាយ ហេតុក្នុងការកំណត់តាមលំដាប់ ៣៤
ប្រកាសដោយសេចក្ដីឧបមា ៣៥

### អដ្ឋកថា សិក្ខាបទ ១០ ទី ២

អដ្ឋកថា សិក្ខាបទ ៤០
វិនិច្ឆ័យសិក្ខាបទដូចគ្នា និងផ្សេងគ្នាជាដើម ៥២
ពណ៌នាសិក្ខាបទ ៥ ខាងចុង ៧៥

### អដ្ឋកថា ទ្វត្តិឹង្សាការទី ៣

ពណ៌នាការសម្ព័ន្ធនៃបទ ៨៥
អសុភភាវនា ៨៩
អធិប្បាយ សក់ ៩៦

| | | |
|---|---|---|
| អធិប្បាយ | រោម | ៩៨ |
| អធិប្បាយ | ក្រចក | ១០០ |
| អធិប្បាយ | ធ្មេញ | ១០១ |
| អធិប្បាយ | ស្បែក | ១០៣ |
| អធិប្បាយ | សាច់ | ១០៧ |
| អធិប្បាយ | សរសៃ | ១០៩ |
| អធិប្បាយ | ឆ្អឹង | ១១២ |
| អធិប្បាយ | ខួរក្នុងឆ្អឹង | ១១៩ |
| អធិប្បាយ | តម្រងបស្សាវៈ | ១២០ |
| អធិប្បាយ | បេះដូង | ១២២ |
| អធិប្បាយ | ថ្លើម | ១២៣ |
| អធិប្បាយ | ភាវ | ១២៥ |
| អធិប្បាយ | ក្រពះ | ១២៦ |
| អធិប្បាយ | សួត | ១២៧ |
| អធិប្បាយ | ពោះវៀនធំ | ១២៩ |
| អធិប្បាយ | ពោះវៀនតូច | ១៣០ |
| អធិប្បាយ | អាហារថ្មី | ១៣១ |
| អធិប្បាយ | អាហារចាស់ | ១៣៥ |
| អធិប្បាយ | ខួរក្នុងក្បាល | ១៣៦ |
| អធិប្បាយ | ប្រម៉ាត់ | ១៣៨ |
| អធិប្បាយ | ស្លេស្ម៍ | ១៣៩ |
| អធិប្បាយ | ខ្ទុះ | ១៤១ |
| អធិប្បាយ | ឈាម | ១៤២ |
| អធិប្បាយ | ញើស | ១៤៤ |
| អធិប្បាយ | ខ្លាញ់ខាប់ | ១៤៦ |
| អធិប្បាយ | ទឹកភ្នែក | ១៤៧ |
| អធិប្បាយ | ខ្លាញ់រាវ | ១៤៩ |
| អធិប្បាយ | ទឹកមាត់ | ១៥០ |

អធិប្បាយ ទឹកសំបោរ ១៥២

អធិប្បាយ ទឹកអំពិល ១៥៤

អធិប្បាយ ទឹកមូត្រ ១៥០


## បកិណ្ណកន័យ


ន័យផ្សេងៗ ១៧១


## អដ្ឋកថា កុមារបញ្ហាទី ៤


ហេតុកើតនៃរឿង ១៧១

ប្រយោជន៍នៃការតាំងបទ ១៧៧

ពណ៌នាបញ្ហា អ្វីឈ្មោះថា ១ ១៧៨

ពណ៌នាបញ្ហា អ្វីឈ្មោះថា ២ ១៨៤

ពណ៌នាបញ្ហា អ្វីឈ្មោះថា ៣ ១៨៦

ពណ៌នាបញ្ហា អ្វីឈ្មោះថា ៤ ១៨៩

ពណ៌នាបញ្ហា អ្វីឈ្មោះថា ៥ ១៩៤

ពណ៌នាបញ្ហា អ្វីឈ្មោះថា ៦ ១៩៦

ពណ៌នាបញ្ហា អ្វីឈ្មោះថា ៧ ១៩៨

ពណ៌នាបញ្ហា អ្វីឈ្មោះថា ៨ ២០៣

ពណ៌នាបញ្ហា អ្វីឈ្មោះថា ៩ ២០៦

ពណ៌នាបញ្ហា អ្វីឈ្មោះថា ១០ ២១០


## អដ្ឋកថា មង្គលសូត្រទី ៥


ប្រយោជន៍នៃការតាំងបទ ២១៣

កថាពណ៌នា បឋមសង្គាយនា ២១៤

ពណ៌នាចាប់ៈថាឯវំ ជាដើម ២៣៩

កែបទ មេ ២៤៤

កែបទ សុតំ ២៤៥

កែបទ ឯកំ និង សមយំ ២៥៣

កែបទ ភគវា ២៦០

កែបទ វិភត្តវា ២៦៧

| | | |
|---|---|---|
| កែបទ | ភត្តវា | ២៦៨ |
| កែបទ | ភវេសុ វន្តគមន | ២៦៩ |
| កែបទ | សាវត្ថិយំ វិហរតិ | ២៧០ |
| កែបទ | ជេតវនេ | ២៧៣ |
| កែបទ | អនាថបិណ្ឌិកស្ស អារាមេ | ២៧៤ |
| កែបទ | អភិកន្តៈ ស័ព្ទ | ២៨០ |
| កែបទ | កេវលកប្បំ | ២៨៣ |
| មូលហេតុកើតមង្គលបញ្ហា | | ២៩១ |
| ពណ៌នាគាថា | ពហូ ទេវា | ៣០១ |
| ពណ៌នាគាថា | អាសេវនា ច | ៣០៤ |
| ពណ៌នាគាថា | បដិរូបទេសវាសោ ច | ៣២៣ |
| ពណ៌នាគាថា | ពាហុសច្ចញ្ច | ៣២៩ |
| ពណ៌នាគាថា | មាតាបិតុឧបដ្ឋានំ | ៣៣៥ |
| ពណ៌នាគាថា | ទានញ្ច | ៣៤៣ |
| ពណ៌នាគាថា | អារតី | ៣៤៨ |
| ពណ៌នាគាថា | គារវោ ច | ៣៥៣ |
| ពណ៌នាគាថា | ខន្តិ ច | ៣៦៥ |
| ពណ៌នាគាថា | តបោ ច | ៣៧២ |
| ពណ៌នាគាថា | ផុដ្ឋស្ស លោកធម្មេហិ | ៣៧៦ |
| ពណ៌នាគាថា | ឯតាទិសានិ | ៣៨០ |


## អដ្ឋកថា រតនសូត្រទី ៦


| | | |
|---|---|---|
| ប្រយោជន៍នៃការតាំងបទ | | ៣៨៦ |
| រឿងក្រុងវេសាលី | | ៣៨៧ |
| ការអារាធនានិមន្តព្រះមានព្រះភាគ | | ៣៩៣ |
| ពណ៌នាគាថា | យានីធ | ៤០៣ |
| ពណ៌នាគាថា | តស្មា ហិ | ៤០៨ |
| ពណ៌នាគាថា | យង្កិញ្ចិ | ៤១៣ |
| ពណ៌នាគាថា | ខយំ វិរាគំ | ៤៣៨ |

ពណ៌នាគាថា យម្ពុទ្ធសេដ្ឋោ ៤៤១
ពណ៌នាគាថា យេ បុគ្គលា ៤៤៤
ពណ៌នាគាថា យេ សុប្បយុត្តា ៤៥០
ពណ៌នាគាថា យថិន្ទខីលោ ៤៥៤
ពណ៌នាគាថា យេ អរិយសច្ចានិ ៤៥៧
ពណ៌នាគាថា សហាវស្ស ៤៦០
ពណ៌នាគាថា ចតូហបាយេហិ ៤៦៤
ពណ៌នាគាថា កិញ្ចាបិ សោ ៤៦៧
ពណ៌នាគាថា វនប្បគុម្ពេ ៤៧០
ពណ៌នាគាថា វរោ វរញ្ញូ ៤៧៤
ពណ៌នាគាថា ខីណំ ៤៧៨
ពណ៌នាគាថា ៣ គាថា យានីធ ជាដើម ៤៨២

## អដ្ឋកថា តិរោកុឌ្ឌសូត្រទី ៧

ប្រយោជន៍នៃការតាំងបទ ៤៩៤
កថាអនុមោទនា ៤៩៥
ពណ៌នាគាថា ទី ១ ៥០៦
ពណ៌នាគាថា ទី ២ ៥០៨
ពណ៌នាគាថា ទី ៣ ៥១១
ពណ៌នាគាថា ទី ៤ សម្ព័ន្ធជាមួយគាថាទី ៣ ៥១៣
ពណ៌នាខាងចុងគាថាទី ៤ សម្ព័ន្ធនឹងខាងដើមគាថាទី ៥ ៥១៥
ពណ៌នាខាងចុងគាថាទី ៥ សម្ព័ន្ធនឹងខាងដើមគាថាទី ៦ ៥១៧
ពណ៌នាខាងចុងគាថាទី ៦ សម្ព័ន្ធនឹងគាថាទី ៧ ៥២៥
ពណ៌នា ២ គាថាទី ៨ និងទី ៩ ៥២៧
ពណ៌នាគាថា ទី ១០ ៥២៩
ពណ៌នាគាថា ទី ១១ ៥៣០
ពណ៌នាគាថា ទី ១២ ៥៣២
ពណ៌នាគាថា ទី ១៣ ៥៣៤

**អដ្ឋកថា និធិកណ្ឌសូត្រទី ៨**


| | |
|---|---|
| ហេតុតាំងព្រះសូត្រ | ៥៣៨ |
| ហេតុកើតព្រះសូត្រ | ៥៣៩ |
| ពណ៌នាគាថា ទី ១ | ៥៤០ |
| ពណ៌នាគាថា ទី ២ | ៥៤៣ |
| ពណ៌នាគាថា ទី ៣ | ៥៤៦ |
| ពណ៌នាគាថា ទី ៤ និងទី ៥ | ៥៤៨ |
| ពណ៌នាគាថា ទី ៦ | ៥៥០ |
| ពណ៌នាគាថា ទី ៧ | ៥៥៣ |
| ពណ៌នាគាថា ទី ៨ | ៥៥៦ |
| ពណ៌នាគាថា ទី ៩ | ៥៦០ |
| ពណ៌នាគាថា ទី ១០ | ៥៦២ |
| ពណ៌នាគាថា ទី ១១ | ៥៦៤ |
| ពណ៌នាគាថា ទី ១២ | ៥៧០ |
| ពណ៌នាគាថា ទី ១៣ | ៥៧២ |
| ពណ៌នាគាថា ទី ១៤ | ៥៧៤ |
| ពណ៌នាគាថា ទី ១៥ | ៥៧៦ |
| ពណ៌នាគាថា ទី ១៦ | ៥៧៨ |


**អដ្ឋកថា មេត្តសូត្រទី ៩**


| | |
|---|---|
| ប្រយោជន៍នៃការតាំងព្រះសូត្រ | ៥៨២ |
| ការជម្រះនិទាន | ៥៨៤ |
| ពណ៌នាគាថា ទី ១ | ៥៩២ |
| ពណ៌នាគាថា ទី ២ | ៦០៤ |
| ពណ៌នាគាថា ទី ៣ | ៦១១ |
| ពណ៌នាគាថា ទី ៤ | ៦១៤ |
| ពណ៌នាគាថា ទី ៥ | ៦២០ |
| ពណ៌នាគាថា ទី ៦ | ៦២២ |
| ពណ៌នាគាថា ទី ៧ | ៦២៤ |

ពណ្ណនាគាថា ទី ៨ ៦២៥
ពណ្ណនាគាថា ទី ៩ ៦២៩
ពណ្ណនាគាថា ទី ១០ ៦៣២
និគមគាថា ៦៣៦

# អដ្ឋកថាខុទ្ទកនិកាយ ឈ្មោះបរមត្ថជោតិកា

# ខុទ្ទកបាឋៈ

# លេខ ៥២

## ពាក្យប្រារព្ធ

*សូមនមស្ការព្រះដ៏មានព្រះភាគអរហន្តសម្មាសម្ពុទ្ធព្រះអង្គនោះ*

ពាក្យប្រារព្ធព្រះគម្ពីរ

និទ្ទេសថា ៖

*ខ្ញុំសូមដល់ព្រះពុទ្ធជាសរណៈ*

*ខ្ញុំដល់នូវព្រះធម៌ជាសរណៈ*

*ខ្ញុំដល់នូវព្រះសង្ឃជាសរណៈ*

[១] *សូម្បីវារៈទី ២ ទី ៣ ក៏ដូចគ្នា និទ្ទេសអធិប្បាយរឿងការដល់ព្រះរតនត្រ័យនេះ ជាប្រការខាងដើមរបស់គម្ពីរខុទ្ទកបាឋៈ ។*

*ឥឡូវនេះ ដើម្បីបើក បែក ធ្វើឲ្យងាយនូវសេចក្ដីនៃបាលីនេះ ខ្ញុំ*

នឹងអធិប្បាយប្រការនេះ ដោយអដ្ឋកថាខុទ្ទកបាឋៈ ឈ្មោះថា បរមត្ថជោ-តិកា ៖

ខ្ញុំម្ចាស់សូមថ្វាយបង្គំព្រះរតនត្រ័យ ដ៏ខ្ពង់ខ្ពស់ប្រសើរលើសវត្ថុទាំងឡាយដែលគួរថ្វាយបង្គំ នឹងធ្វើការពណ៌នាសេចក្តីនៃខុទ្ទកបាឋៈ ។ ការពណ៌នានេះ ដែលខ្ញុំម្ចាស់ដឹងព្រះសាសនាតិច ធ្វើបានដោយលំបាកក្រៃលែង ព្រោះខុទ្ទ-កបាឋៈមានអត្ថដ៏ជ្រាលជ្រៅមែនពិត តែព្រោះហេតុនៃការវិនិច្ឆ័យរបស់បុព្វាចារ្យនៅមានជានិរន្តដល់សព្វថ្ងៃនេះ និងនវង្គសត្ថុសាសន៍តាំងនៅដូចដើម ដូច្នោះ ខ្ញុំម្ចាស់អាស្រ័យនវង្គសត្ថុសាសន៍ និងការវិនិច្ឆ័យរបស់បុព្វាចារ្យនេះ ទើបប្រាថ្នានឹងពណ៌នាអត្ថ ដោយសេចក្តីគោរពក្នុងព្រះសទ្ធម្មមិនមែនបំណងនឹងលើកតម្កើងខ្លួន មិនបំណងនឹងសង្កត់សង្កិនអ្នកដទៃ ។ សូមលោកទាំងឡាយ ចូរតាំងចិត្តស្តាប់ការពណ៌នាសេចក្តីនោះចុះ ។

## ការកំណត់ខុទ្ទកបាឋ:

ព្រោះខ្ញុំពោលទុកក្នុងពាក្យប្រារព្ធនោះថា **និងធ្វើការពណ៌នាអត្ថនៃខុទ្ទកបាឋ:ចំណែកខ្លះ** ។ ខ្ញុំត្រូវធ្វើការកំណត់ខុទ្ទកបាឋ:ទាំងឡាយជាមុន ទើបនឹងធ្វើការពណ៌នាសេចក្តីជាខាងក្រោយ ។ ឯកទេសចំណែកមួយនៃខុទ្ទកនិកាយ ឈ្មោះថា ខុទ្ទក: ។ ឯកទេសចំណែកមួយនៃនិកាយទាំង ៥ ឈ្មោះ ខុទ្ទកនិកាយ ។ ពោលដោយធម៌ និងដោយអត្ថ គម្ពីរទាំងនោះមាន ៥ និកាយ គឺ ទីឃនិកាយ មជ្ឈិមនិកាយ សំយុត្តនិកាយ អង្គុត្តរ-និកាយ និងខុទ្ទកនិកាយ ឈ្មោះថា **និកាយ ៥** ។

បណ្តានិកាយទាំង ៥ នោះ ព្រះសូត្រ ៣៤ សូត្រ មានព្រហ្មជាលសូត្រជាដើម ឈ្មោះថា **ទីឃនិកាយ** ។ សមដូចដែលលោកពោលទុកថា ៖

និកាយដែលរួបរួមព្រះសូត្រ ៣៤ សូត្រ ៣ វគ្គ ឈ្មោះថា **ទីឃនិកាយ** អនុលោមទី ១ ។

ព្រះសូត្រ ១៥២ សូត្រ មានមូលបរិយាយសូត្រជាដើម ឈ្មោះថា **មជ្ឈិមនិកាយ** ។

ព្រះសូត្រ ៧.៧៦២ សូត្រ មានឱឃតរណសូត្រជាដើម ឈ្មោះថា **សំយុត្តនិកាយ** ។

ព្រះសូត្រ ៩.៥៥៧ សូត្រ មានចិត្តបរិយាទានសូត្រជាដើម ឈ្មោះថា **អង្គុត្តរនិកាយ** ។

ខុទ្ទកបាឋៈ ធម្មបទ ឧទាន ឥតិវុត្តកៈ សុត្តនិបាត វិមានវត្ថុ បេតវត្ថុ ថេរគាថា ថេរីគាថា ជាតក និទ្ទេស បដិសម្ភិទា អបទាន ពុទ្ធវង្ស ចរិយាបិដក ព្រះពុទ្ធវចនៈដ៏សេស វៀរវិន័យបិដក ហើយនិងអភិធម្មបិដក ឬនិកាយ ៤ ឈ្មោះថា **ខុទ្ទកនិកាយ** ។

ហេតុអ្វី និកាយនេះ លោកទើបហៅថា **ខុទ្ទកនិកាយ** ។ ហេតុជាទីរួម ជាទីនៅនៃពួកធម៌តូចៗ ចំនួនច្រើន ។ ពិតហើយ ការរួមគ្នា លោកហៅថា **និកាយ** ។ ពោលដោយសាសនា និងដោយលោក ក្នុងប្រការនេះ មានសាធកៈជាដើមយ៉ាងនេះ គឺ ម្នាលភិក្ខុទាំងឡាយ តថាគតពិចារណាមើលមិនឃើញពួកសត្វសូម្បីដទៃ ដែលវិចិត្រដូចជាពពួកសត្វតិរច្ឆានឡើយ , ពួកក្សត្រិយ៍បោណិកៈ ពួកក្សត្រិយ៍ចិក្ខល្លិកៈ ។ ឯកទេស

ចំណែកមួយរបស់ខុទ្ទកនិកាយនោះ មានដូច្នេះ ពួកធម៌ចំណែកតូចៗ ដែលរាប់ចូលក្នុងព្រះសុត្តន្តបិដកទាំងនេះ ប្រាថ្នានឹងបើក បែក ធ្វើឲ្យងាយដោយអត្ថ ខុទ្ទកបាឋ: ៩ ប្រភេទ គឺ សរណ: សិក្ខាបទ ទ្វត្តឹសាការ: កុមារបញ្ហា (សាមណេរបញ្ហា) មង្គលសូត្រ រតនសូត្រ តិរោកុឌ្ឌសូត្រ និធិកណ្ឌសូត្រ និងមេត្តសូត្រ ជាប្រការខាងដើមរបស់ពួកធម៌តូចៗ ទាំងនោះ ក្រោយមកអាចារ្យលើកឡើងកាន់ផ្លូវ ប្រាប់ បង្រៀន មិនមែនដោយពាក្យដែលព្រះដ៏មានព្រះភាគត្រាស់ទុក ។

ពិតហើយ គាថា ២ គាថានេះថា ៖

តថាគតស្វែងរកជាងអ្នកធ្វើផ្ទះ គឺ អត្តភាព កាលមិនជួប បានអន្ទោលទៅហើយក្នុងសង្សារវដ្តរាប់ដោយជាតិមិនមែនតិច ការកើតរឿយៗ ជាទុក្ខ ។

នែ៎! ជាងផ្ទះ អ្នកឯងធ្វើផ្ទះ គឺ អត្តភាព តថាគតជួបអ្នកឯងហើយ អ្នកឯងនឹងធ្វើផ្ទះរបស់តថាគតទៀតមិនបានឡើយ ឆ្អឹងជំនី គឺ កិលេសរបស់អ្នកឯង តថាគតបានកាច់

បំបាក់អស់ហើយ ដំបូលផ្ទះ គឺ អវិជ្ជា តថាគតបានរើចោល

ហើយ ចិត្តរបស់តថាគតដល់ព្រះនិព្វានហើយ ព្រោះតថាគត

បានសម្រេចធម៌ជាទីអស់ទៅនៃតណ្ហាទាំងឡាយហើយ ។

ឈ្មោះថា ជាបឋមពុទ្ធវចនៈសូម្បីទាំងអស់ ដោយព្រះតម្រាស់ដែលព្រះដ៏មានព្រះភាគត្រាស់ទុក ។ ដែលឈ្មោះថា បឋមពុទ្ធវចនៈនោះក៏ព្រោះការត្រាស់ដោយអំណាចសោមនស្ស មិនមែនទ្រង់បញ្ចេញព្រះវាចាត្រាស់ទេ ។ ចំណែកព្រះគាថានេះថា ៖

កាលណា ធម៌ទាំងឡាយប្រាកដដល់ព្រាហ្មណ៍អ្នកមាន

សេចក្តីព្យាយាមសម្លឹងពិនិត្យហើយ ក្នុងកាលនោះ សេចក្តី

សង្ស័យទាំងពួងរបស់ព្រាហ្មណ៍នោះ រមែងអស់ទៅ ព្រោះ

មកដឹងច្បាស់នូវធម៌ព្រមទាំងហេតុ ។

ឈ្មោះថា ជាបឋមពុទ្ធតម្រាស់ ជាព្រះតម្រាស់ដែលព្រះមានព្រះភាគត្រាស់ព្រះវាចា ។ ព្រោះដូច្នោះ ខុទ្ទកបាឋៈ ៩ ប្រភេទនេះ ឈ្មោះថាជាប្រការខាងដើមរបស់ពួកធម៌តូចៗ ទាំងនោះ ខ្ញុំនឹងផ្តើមពណ៌នាអត្ថនៃ

*ខ្ញុំទូកបាឋ:នោះ តាំងអំពីដើមតទៅ ។*

# និទានសោធនៈ

## ការជំរះពាក្យខាងដើម

វាចានេះថា ៖ ពុទ្ធំ សរណំ គច្ឆាមិ

ធម្មំ សរណំ គច្ឆាមិ

សង្ឃំ សរណំ គច្ឆាមិ

ជាប្រការខាងដើមនៃពាក្យផ្តើមនោះ ។ មាតិកាពណ៌នាសេចក្តីនៃពាក្យផ្តើមនោះ មានដូច្នេះ ។

ព្រះរតនត្រ័យ នរណាពោល ពោលទីណា ពោល កាលណា ពោលព្រោះហេតុអ្វី ម្យ៉ាងទៀត ដែលមិនបាន ត្រាស់ទុកមកអំពីដំបូង ព្រោះហេតុអ្វីក្នុងទីនេះទើបពោលថា ត្រាស់ទុកជាប្រការដំបូង ចាំបាច់ត្រូវជម្រះពាក្យខាងដើម ត អំពីនោះ ក្នុងពាក្យផ្តើម ក៏នឹងអធិប្បាយរឿងព្រះពុទ្ធ រឿង ការដល់សរណៈ និងរឿងបុគ្គលអ្នកដល់សរណៈ និងសំដែង ការដាច់ ការមិនដាច់នៃត្រ័យសរណគមន៍ ទាំងផល ទាំង

សរណៈដែលគួរដល់ សូម្បីក្នុង ២ សរណៈ មាន ធម្មំ សរណំ ជាដើម ក៏បានដឹងហើយថា មានន័យយ៉ាងនេះ និងអធិប្បាយហេតុក្នុងការកំណត់ដោយលំដាប់ ហើយនឹងប្រកាសព្រះរតនត្រ័យនោះ ដោយការឧបមាទាំងឡាយ ។ បណ្ដាគាថាទាំងនោះ គាថាដំបូង មានបញ្ហា ៥ ប្រការ គឺ

១.ព្រះរតនត្រ័យនេះ នរណាពោល

២.ពោលក្នុងទីណា

៣.ពោលកាលណា

៤.ពោលព្រោះហេតុអ្វី

៥.មួយ៉ាងទៀត ដែលព្រះតថាគតមិនបានត្រាស់ទុកមកអំពីដំបូង ព្រោះហេតុអ្វីក្នុងទីនេះទើបពោលថា ត្រាស់ទុកជាប្រការដំបូង ។

និងវិសជ្ជនាបញ្ហាទាំង ៥ ប្រការនោះ ។

បញ្ហាថា **នរណាពោល** វិសជ្ជនាថា ព្រះដ៏មានព្រះភាគត្រាស់ មិនមែនព្រះសាវក មិនមែនពួកឥសី មិនមែនទេវតាពោល ។

បញ្ហាថា ពោលទីណា វិសជ្ជនាថា នៅឥសិបនមិគទាយវ័ន ក្រុង ពារាណសី ។

បញ្ហាថា ពោលកាលណា វិសជ្ជនាថា កាលព្រះយសសម្រេចព្រះ អរហត្តរួមជាមួយនឹងសំឡាញ់ទាំងឡាយ កាលព្រះអរហន្ត ៦១ អង្គ បាន ត្រាស់ដឹងធម៌ក្នុងលោក ដើម្បីប្រយោជន៍សុខដល់ជនចំនួនច្រើន ។

បញ្ហាថា ពោលព្រោះហេតុអ្វី វិសជ្ជនាថា ដើម្បីបព្វជា និងដើម្បី ឧបសម្បទា ។ សមដូចព្រះមានព្រះភាគត្រាស់ទុកថា ៖

ម្នាលភិក្ខុទាំងឡាយ ក៏ឯឧបសម្បទាបេក្ខៈដែលភិក្ខុ គប្បីឲ្យបព្វជា ឧបសម្បទាយ៉ាងនេះ ។ ជាដំបូងឲ្យកោរសក់ និងពុកមាត់ ឲ្យគ្រងសំពត់កាសាយៈ ឲ្យគ្រងសំពត់ចៀង ម្ខាង ឲ្យសំពះបាទាភិក្ខុទាំងឡាយ ឲ្យអង្គុយប្រហោង ឲ្យ ផ្គងអញ្ជលី (លើកដៃប្រណម) គប្បីបង្រៀនឲ្យពោលតាម ដូច្នេះថា ពុទ្ធំ សរណំ គច្ឆាមិ , ធម្មំ សរណំ គច្ឆាមិ , សង្ឃំ សរណំ គច្ឆាមិ ។

បញ្ហាថា ព្រោះហេតុអ្វីក្នុងទីនេះទើបបានពោលថា ជាប្រការជំបូង វិសជ្ជនាថា ព្រោះហេតុដែលទេវតា និងមនុស្ស នាំគ្នាចូលកាន់ព្រះសាសនា ដោយភាពជាឧបាសកខ្លះ ជាបព្វជិតខ្លះ ដោយផ្លូវនេះ ដូច្នោះ ទើបគប្បីដឹងថា នវង្គសត្ថុសាសន៍នេះ បុព្វាចារ្យទាំងឡាយរួបរួមទុកដោយបិដកទាំង ៣ លើកឡើងកាន់ផ្លូវដើម្បីសិក្សា ។ ទើបពោលជាប្រការជំបូងក្នុងខុទ្ទកបាឋៈនេះ ព្រោះជាផ្លូវចូលទៅកាន់ព្រះសាសនា ។

និធានសោធនៈ ជម្រះហើយ

# ១ អដ្ឋកថា ព្រះរតនត្រ័យ

ឥឡូវនេះ ពាក្យណាដែលខ្ញុំបានពោលទុកថា និងអធិប្បាយរឿងព្រះពុទ្ធ រឿងការដល់សរណៈ និងរឿងបុគ្គលអ្នកដល់សរណៈ ក្នុងពាក្យនោះ សត្វពិសេស ឈ្មោះថា ពុទ្ធៈ ព្រោះបញ្ញត្តិអាស្រ័យខន្ធសន្តាន ដែលត្រូវអប់រំដោយការសម្រេចអនុត្តរវិមោក្ខ ដែលជានិមិត្តនៃព្រះញាណណាៗ ជំទាស់មិនបានក្នុងធម៌ទាំងពួង ឬព្រោះបញ្ញត្តិអាស្រ័យការត្រាស់ដឹងនូវសច្ចៈ ដែលជាបទដ្ឋាននៃព្រះសព្វញ្ញុតញ្ញាណ ។ ដូចដែលលោកពោលទុកថា ៖

ព្រះមានព្រះភាគអង្គនោះ ជាព្រះសយម្ភូ (ត្រាស់ដឹងឯង) មិនមានអាចារ្យ ត្រាស់ដឹងដោយព្រះអង្គឯងនូវសច្ចៈទាំងឡាយ ក្នុងធម៌ទាំងឡាយដែលទ្រង់មិនបានស្តាប់មកអំពីមុន ទ្រង់សម្រេចព្រះសព្វញ្ញុតញ្ញាណក្នុងធម៌ទាំងនោះ និងភាពដែលទ្រង់ជំនាញក្នុងពលៈទាំងឡាយ ព្រះមានព្រះភាគព្រះអង្គនោះ ឈ្មោះថា ពុទ្ធៈ ។

ការអធិប្បាយរឿងពុទ្ធ:ដោយអត្ថ ប៉ុណ្ណេះសិន ។

តែកាលពោលដោយព្យញ្ជនៈ គប្បីជ្រាបដោយន័យជាដើមយ៉ាង នេះថា ឈ្មោះថា ពុទ្ធ: ព្រោះទ្រង់ជាអ្នកត្រាស់ដឹង ឈ្មោះថា ពុទ្ធ: ព្រោះ ទ្រង់ជាអ្នកជាជាស់ឲ្យភ្ញាក់ ។ សមពិតដូចដែលលោកពោលទុកថា ៖

ក្នុងពាក្យថា ពុទ្ធ: ឈ្មោះថា ពុទ្ធ: ព្រោះអត្ថថាដូចម្ដេច? ឈ្មោះ ថា ពុទ្ធ: ព្រោះអត្ថថា ត្រាស់ដឹងសច្ច:ទាំងឡាយ ។ ឈ្មោះថា ពុទ្ធ: ព្រោះអត្ថថា ទ្រង់ជាស់សត្វឲ្យភ្ញាក់ឡើង ឈ្មោះថា ពុទ្ធ: ព្រោះទ្រង់ដឹង គ្រប់យ៉ាង ។ ឈ្មោះថា ពុទ្ធ: ព្រោះទ្រង់ឃើញគ្រប់យ៉ាង ឈ្មោះថា ពុទ្ធ: ព្រោះត្រាស់ដឹងឯង មិនមែនអ្នកដទៃធ្វើឲ្យត្រាស់ដឹង ឈ្មោះថា ពុទ្ធ: ព្រោះអត្ថថា ទ្រង់រីកហើយ ឈ្មោះថា ពុទ្ធ: ព្រោះរាប់បានថា ទ្រង់អស់ កិលេសហើយ ឈ្មោះថា ពុទ្ធ: ព្រោះរាប់បានថា ទ្រង់មិនមានឧបក្កិ- លេស ឈ្មោះថា ពុទ្ធ: ព្រោះអត្ថថា អស់រាគ: ឈ្មោះថា ពុទ្ធ: ព្រោះ អត្ថថា អស់ទោស: ឈ្មោះថា ពុទ្ធ: ព្រោះអត្ថថា អស់មោហ: ឈ្មោះ ថា ពុទ្ធ: ព្រោះអត្ថថា គ្មានកិលេស ឈ្មោះថា ពុទ្ធ: ព្រោះអត្ថថា ទ្រង់

ដំណើរដោយឯកាយនមគ្គ ឈ្មោះថា ពុទ្ធៈ ព្រោះអត្ថថា ត្រាស់ដឹងក្រៃ-លែងឯង នូវព្រះអនុត្តរសម្មាសម្ពោធិញ្ញាណដោយព្រះអង្គឯង ឈ្មោះថា ពុទ្ធៈ ព្រោះទ្រង់បានត្រាស់ដឹង ហេតុដែលទ្រង់កម្ចាត់ការមិនដឹងបានហើយ ។ ព្រះនាមថា ពុទ្ធៈ នេះ មិនមែនព្រះជននីដាក់ឲ្យ មិនមែនព្រះជនកដាក់ឲ្យ មិនមែនព្រះជេដ្ឋភាតាដាក់ឲ្យ មិនមែនព្រះជេដ្ឋភាគិនីដាក់ឲ្យ មិនមែនមិត្រអាមាត្យដាក់ឲ្យ មិនមែនព្រះញាតិសាលោហិតដាក់ឲ្យ មិនមែនសមណ-ព្រាហ្មណ៍ដាក់ឲ្យ មិនមែនទេវតាដាក់ឲ្យ ព្រះនាមនេះ របស់ព្រះមាន-ព្រះភាគ មានក្នុងខាងចុងនៃការរួចផុតចាកកិលេស បញ្ញត្តិគឺ ពុទ្ធៈ ទ្រង់ធ្វើឲ្យជាក់ច្បាស់ ព្រមទាំងទ្រង់បាននូវព្រះសព្វញ្ញុតញ្ញាណ ត្រង់គល់ព្រះពោធិព្រឹក្ស ។

ក្នុងពាក្យថា ពុទ្ធៈ នោះ ឈ្មោះថា ពុទ្ធៈ ព្រោះអត្ថថា ត្រាស់ដឹងសច្ចៈទាំងឡាយ ដូចអ្នកដែលចុះមកក្នុងលោក (អវតារ) ក៏ហៅថា អ្នកចុះមក (អវតារ) ។ ឈ្មោះថា ពុទ្ធៈ ព្រោះអត្ថថា ទ្រង់ដាស់ពពួកសត្វឲ្យភ្ញាក់ ដូចខ្យល់ធ្វើស្លឹកឈើឲ្យស្ងួត ក៏ហៅថា ធ្វើស្លឹកឈើឲ្យស្ងួត ។

ពាក្យថា **ឈ្មោះថា ពុទ្ធៈ ព្រោះទ្រង់ដឹងគ្រប់យ៉ាង** លោកអធិប្បាយថា ឈ្មោះថា ពុទ្ធៈ ព្រោះសេចក្ដីដឹងដែលអាចដឹងធម៌បានគ្រប់យ៉ាង ។ បទថា **ឈ្មោះថា ពុទ្ធៈ ព្រោះទ្រង់ឃើញគ្រប់យ៉ាង** លោកអធិប្បាយថា ឈ្មោះថា ពុទ្ធៈ ព្រោះត្រាស់ដឹងដែលអាចត្រាស់ដឹងធម៌បានគ្រប់យ៉ាង ។ ពាក្យថា **ឈ្មោះថា ពុទ្ធៈ ព្រោះត្រាស់ដឹងឯង មិនមែនអ្នកដទៃធ្វើត្រាស់ដឹង** លោកអធិប្បាយថា ឈ្មោះថា ពុទ្ធៈ ព្រោះត្រាស់ដឹងឯង មិនមែនអ្នកដទៃធ្វើឲ្យត្រាស់ដឹង ។ ពាក្យថា **ពុទ្ធៈ ព្រោះអត្ថថា ទ្រង់រីកហើយ** លោកអធិប្បាយថា ឈ្មោះថា ពុទ្ធៈ ព្រោះអត្ថថា ទ្រង់រីកហើយ ហេតុនៃការរីកដោយព្រះគុណច្រើនប្រការ ដូចផ្កាបទុមរីក ។ ដោយពាក្យជាដើមយ៉ាងនេះថា **ឈ្មោះថា ពុទ្ធៈ ព្រោះរាប់បានថា ទ្រង់អស់កិលេសហើយ** លោកអធិប្បាយថា ឈ្មោះថា ពុទ្ធៈ ព្រោះទ្រង់ភ្ញាក់ហើយ ហេតុអស់នូវកិលេសដូចការដេកលក់គ្រប់យ៉ាង ដូចបុរសភ្ញាក់ពីការដេកលក់ ព្រោះទ្រង់លះធម៌ដែលធ្វើឲ្យចិត្តរួញរាបាន ។ លោកពោលថា **ឈ្មោះថា ពុទ្ធៈ ព្រោះអត្ថថា ទ្រង់ដំណើរដោយឯកាយនមគ្គ** ដូច្នេះ ក៏ដើម្បីសំដែងថា

ព្រះមានព្រះភាគ លោកហៅថា **ពុទ្ធៈ** ក៏ព្រោះទ្រង់ដំណើរដោយឯកាយនមគ្គ ដូចបុរសដើរផ្លូវ គេក៏ហៅថា អ្នកដើរទៅ ព្រោះបរិយាយ (ផ្លូវ) នៃអត្ថថា ទៅកាន់ផ្លូវត្រាស់ដឹង ។ ពាក្យថា **ឈ្មោះថា ពុទ្ធៈ ព្រោះអត្ថថា ត្រាស់ដឹងដ៏ក្រៃលែងឯង នូវអនុត្តរសម្មាសម្ពោធិញាណដោយព្រះអង្គឯង** លោកអធិប្បាយថា ឈ្មោះថា **ពុទ្ធៈ** មិនមែនត្រាស់ដឹងតាមបុគ្គលដទៃការពិត ឈ្មោះថា **ពុទ្ធៈ** ព្រោះត្រាស់ដឹងក្រៃលែងនូវព្រះសម្មាសម្ពោធិដ៏កំពូលដោយព្រះអង្គឯងប៉ុណ្ណោះ ។ បទថា **អពុទ្ធិវិហតត្តា ពុទ្ធិបដិលាភា ពុទ្ធោ** ជាបទសំដែងបរិយាយថា **ពុទ្ធិ ពុទ្ធំ ពោធោ** ។ ក្នុងបទនោះគប្បីជ្រាបអត្ថដែលអាចធ្វើ **ពុទ្ធៈ** ស័ព្ទគ្រប់បទ ឲ្យសម្រេចសេចក្តី ដោយន័យយ៉ាងនេះថា លោកអធិប្បាយដើម្បីឲ្យដឹងថា **ពុទ្ធៈ** ព្រោះទ្រង់ប្រកបដោយគុណ គឺ **ពុទ្ធិ** (ការត្រាស់ដឹង) ដូចដែលគេមកដឹងថា សំពត់ខៀវសំពត់ក្រហម ក៏ព្រោះប្រកបដោយពណ៌ខៀវ ពណ៌ក្រហម តអំពីនោះពាក្យជាដើមយ៉ាងនេះថា **ព្រះនាមថា ពុទ្ធៈនេះ** លោកពោលទុកក៏ដើម្បីឲ្យដឹងថា បញ្ញត្តិនេះ ប្រព្រឹត្តទៅតាមអត្ថ ។

*ការពោលរឿងពុទ្ធសម្បីដោយព្យញ្ជនៈ មានដូចពោលមកនេះ ។*

## ពោលរឿងសរណគមន៍ និងអ្នកដល់សរណគមន៍

ឥឡូវនេះ នឹងពណ៌នារឿងការដល់សរណគមន៍ជាដើម ដូចតទៅនេះ ។

ព្រះរតនត្រ័យដែលឈ្មោះថា **សរណៈ** ព្រោះកម្ចាត់ អធិប្បាយថា បៀតបៀន កម្ចាត់ នាំចេញ រំលត់ភ័យ គឺ ការភ័យខ្លាច ការតក់ស្លុត ទុក្ខ ទុគ្គតិ សេចក្ដីសៅហ្មង ដោយការដល់សរណគមន៍នោះឯង របស់បុគ្គលទាំងឡាយដែលដល់សរណគមន៍ ។ ន័យម្យ៉ាងទៀត ព្រះពុទ្ធ ឈ្មោះថា **សរណៈ** ព្រោះកម្ចាត់ភ័យរបស់សត្វទាំងឡាយ ដោយការឲ្យដល់វត្ថុដែលជាប្រយោជន៍ និងនាំចេញនូវវត្ថុដែលមិនមែនជាប្រយោជន៍ ។ ព្រះធម៌ឈ្មោះថា **សរណៈ** ព្រោះឲ្យសត្វរួចផុតផ្លូវកន្តារ គឺ ភព និងញុំាងសេចក្ដីរីករាយចិត្ត ។ ព្រះសង្ឃ ឈ្មោះថា **សរណៈ** ព្រោះធ្វើសក្ការៈសូម្បីតិចតួច ឲ្យត្រឡប់បានផលបរិបូណ៌ ព្រោះដូច្នោះ ព្រះរតនត្រ័យនោះទើបឈ្មោះថា **សរណៈ** ដោយបរិយាយដូចដែលពោលមកនេះ ។

ចិត្តុប្បាទដែលមានសេចក្ដីជ្រះថ្លាក្នុងព្រះរតនត្រ័យនោះ និងសេចក្ដី

គោរពក្នុងព្រះរតនត្រ័យនោះ កម្ចាត់កិលេសចេញបាន ប្រព្រឹត្តទៅដោយអាការ គឺ ការមានព្រះរតនត្រ័យនោះជាខាងមុខ ឬមិនមានអ្នកដទៃជាបច្ច័យ (ដឹកនាំ) ឈ្មោះថា សរណាគមន៍ ។ សត្វអ្នកព្រមព្រៀងដោយចិត្តុប្បាទនោះ រមែងដល់ព្រះរតនត្រ័យនោះជាសរណៈ អធិប្បាយថា រមែងចូលដល់ព្រះរតនត្រ័យដោយចិត្តុប្បាទ ដែលមានប្រការដូចពោលហើយយ៉ាងថា នេះជាសរណៈរបស់ខ្ញុំ នេះជាគ្រឿងនាំមុខរបស់ខ្ញុំ ។ ក៏បុគ្គលកាលនឹងចូលដល់ រមែងចូលដល់ដោយវិធីសមាទាន ដូចនាយពាណិជ្ជ ២ នាក់ ឈ្មោះថា តបុស្សៈ និងភល្លិកៈ ជាដើមថា "បពិត្រព្រអង្គដ៏ចម្រើន ខ្ញុំព្រះអង្គទាំងពីរនាក់ សូមដល់ព្រះមានព្រះភាគ និងព្រះធម៌ ជាសរណៈ សូមព្រះមានព្រះភាគចាំទុកខ្ញុំព្រះអង្គទាំង ២ នាក់ថា ជាឧបាសក" ដូច្នេះក៏បាន ។

ចូលដល់ដោយវិធីទទួលជាសិស្ស ដូចព្រះមហាកស្សបៈជាដើមថា "បពិត្រព្រះអង្គដ៏ចម្រើន ព្រះដ៏មានព្រះភាគជាសាស្តារបស់ខ្ញុំព្រះអង្គ ខ្ញុំព្រះអង្គជាសាវក" ដូច្នេះក៏បាន ។

ចូលដល់ដោយវិធីប្រគល់ខ្លួនក្នុងព្រះរតនត្រ័យនោះ ដូចជាព្រហ្មាយុ-ព្រាហ្មណ៍ជាដើម សេចក្ដីបាលីថា "កាលព្រះមានព្រះភាគត្រាស់យ៉ាងនេះ ព្រហ្មាយុព្រាហ្មណ៍ក៏ក្រោកចាកអាសនៈ ធ្វើសំពត់ឆៀងស្មាម្ខាង លើកដៃប្រណមទៅរកព្រះមានព្រះភាគដែលទ្រង់ប្រថាប់ហើយ បន្លឺឧទាន ៣ ដងថា **នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស , នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស , នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស** ដូច្នេះ ក៏បាន ។

ចូលដល់ដោយវិធីបន្ទោនខ្លួនគោរព ដូចព្រះយោគីបុគ្គលអ្នកខ្វាយខ្វល់ក្នុងកម្មដ្ឋាន ក៏បាន ។

ចូលដល់ដោយវិស័យ និងដោយកិច្ចច្រើនវិធី ដូចជាដោយវិធីកម្ចាត់ឧបក្កិលេស ដោយការដល់សរណគមន៍ ដូចព្រះអរិយបុគ្គលទាំងឡាយ ក៏បាន ។

ពណ៌នាការដល់សរណគមន៍ និងរឿងបុគ្គលអ្នកដល់សរណគមន៍ ដូចពោលមកនេះ ។

-២១- ពោលរឿងសរណគមន៍ និងអ្នកដល់សរណគមន៍

## សម្ដែងសរណគមន៍ដាច់ មិនដាច់ និងផល

ឥឡូវនេះ នឹងសម្ដែងសរណគមន៍ដាច់ជាដើម ដែលខ្ញុំពោលថា **នឹងសម្ដែងសរណគមន៍ដាច់ និងមិនដាច់ ទាំងផល ទាំងសរណៈដែលគួរដល់** ដូចតទៅនេះ ។

ការដាច់សរណគមន៍របស់បុគ្គលអ្នកដល់សរណគមន៍យ៉ាងនេះ មាន ២ យ៉ាង គឺ មានទោស និងមិនមានទោស ។ ការដាច់សរណគមន៍ ព្រោះការស្លាប់ ឈ្មោះថា មិនមានទោស , ការដាច់សរណគមន៍ ព្រោះចូលទៅកាន់សាសនាដទៃ ហើយប្រព្រឹត្តខុសក្នុងព្រះសាស្ដា ឈ្មោះថា មានទោស ។ ការដាច់សូម្បីទាំង ២ នោះ រមែងមានដល់ពួកបុថុជ្ជនប៉ុណ្ណោះ ។ សរណៈរបស់បុថុជ្ជនទាំងនោះ រមែងឈ្មោះថា សៅហ្មង ព្រោះប្រព្រឹត្តទៅដោយការមិនដឹង សេចក្ដីសង្ស័យ និងការដឹងខុស និងព្រោះប្រព្រឹត្តមិនអើពើជាដើម ក្នុងព្រះពុទ្ធគុណទាំងឡាយ ។ ចំណែកព្រះអរិយបុគ្គល រមែងមិនដាច់សរណគមន៍ឡើយ និងសរណគមន៍ក៏មិនសៅហ្មង ។ ដូចដែលត្រាស់ទុកថា “ម្នាលភិក្ខុទាំងឡាយ ប្រការដែលបុគ្គលអ្នកដល់ព្រម

ដោយទិដ្ឋិ (សម្មាទិដ្ឋិ) នឹងគប្បីរាប់អានសាស្តាដទៃ មិនមែនជាឋាន: មិនមែនជាឱកាស" ។ ចំណែកពួកបុថុជ្ជន នៅមិនទាន់ដាច់សរណគមន៍ដ៏រាបណា ដ៏រាបនោះ ក៏នៅឈ្មោះថា ជាអ្នកមានសរណ:មិនដាច់ ។ ការដាច់សរណ:របស់បុថុជ្ជនទាំងនោះ រមែងមានទោស មានសេចក្ដីសៅហ្មង និងឲ្យផលដែលមិនគួរប្រាថ្នា ។ ការដាច់សរណ:ដែលមិនមានទោស ក៏មិនមានផល ព្រោះមិនមានជាវិបាក ។ ចំណែកការមិនដាច់សរណ: ពោលដោយផល ក៏រមែងឲ្យផលដែលគួរប្រាថ្នាតែម្យ៉ាង ។ ដូចដែលត្រាស់ទុកថា

> ជនពួកណាមួយ ដល់ព្រះពុទ្ធជាសរណ: ជនពួកនោះលះ
> កាយជាមនុស្សទៅហើយ ក៏នឹងមិនចូលដល់អបាយភូមិ
> និងធ្វើពួកទេវតាឲ្យបរិបូណ៌ ដូច្នេះ ។

ក្នុងប្រការនោះ គប្បីជ្រាបអធិប្បាយនៃគាថាយ៉ាងនេះថា ជនពួកណា ដល់សរណ:ដោយកាត់ឧបក្កិលេសបានដាច់ដោយសរណគមន៍ ជនទាំងនោះ នឹងមិនទៅអបាយ ។ ចំណែកជនក្រៅពីនោះ នឹងមិនទៅកាន់

*អបាយ ក៏ដោយការដល់សរណៈនោះឯង ។*

*សំដែងសរណៈដាច់ មិនដាច់ និងផលត្រឹមតែប៉ុណ្ណេះសិន ។*

## សម្ដែងសរណៈដែលគប្បីដល់

ក្នុងសរណៈដែលគួរដល់ បុគ្គលអ្នកជំទាស់ពោលថា ក្នុងពាក្យនេះថា ខ្ញុំសូមដល់នូវព្រះពុទ្ធជាសរណៈ ដូច្នេះ បុគ្គលណាដល់ព្រះពុទ្ធជាសរណៈ បុគ្គលនោះនឹងគប្បីព្រះពុទ្ធ ឬសរណៈសូម្បីទាំង ២ ការពោលតែមួយពាក្យ ក៏គ្មានប្រយោជន៍ ព្រោះហេតុអ្វី ។ ព្រោះមានតែកិរិយា គឺការដល់ មិនមានកម្ម ២ ។ ពិតណាស់ អ្នកគិតខាងអក្សរសាស្ត្រ មិនបំណងកម្ម ២ ក្នុងប្រការនេះ ដូចក្នុងពាក្យថា **អជំ គាមំ នេតិ** ជាដើមដូច្នោះ ។

បើអ្នកជំទាស់នោះពោលថា ការពោលសូម្បីពាក្យទាំង ២ មានប្រយោជន៍តែមួយ ដូចក្នុងពាក្យថា **គច្ឆតេវ បុព្វំ ទិសំ គច្ឆតិ បច្ឆិមំ ទិសំ** (ផ្ដោះទៅកាន់ទិសខាងកើត ទិសខាងលិច) អ្នកគិតអក្សរសាស្ត្រមិនបំណងយ៉ាងនោះ ព្រោះលោកមិនបំណងថា ព្រះពុទ្ធ និងសរណៈ ជាតួហេតុស្មើៗ គ្នា ។ ការពិត កាលបំណងថា ព្រះពុទ្ធ និងសរណៈនោះជាតួហេតុស្មើៗ គ្នាហើយ បុគ្គលសូម្បីមានចិត្តខឹង ចូលគាល់ព្រះពុទ្ធ

ក៏នឹងគប្បីឈ្មោះថា ដល់ព្រះពុទ្ធ ដល់សរណៈឬ ។ សរណៈនោះ ធ្វើឲ្យ ផ្សេងទៅថា ព្រះពុទ្ធ ។ បុគ្គលនោះក៏ឈ្មោះថា ដល់សរណៈនោះឯង ។

ប្រសិនបើមានបុគ្គលជំទាស់ពោលថា លោកបំណងយកភាពជាព្រះពុទ្ធ និងសរណៈជាតួហេតុស្មើៗ គ្នា ព្រោះបាលីថា **ឯតំ ខោ សរណំ ខេមំ ឯតំ សរណមុត្តមំ** (សរណៈនោះឯងក្សេម ប្រាសចាកភ័យ សរណៈនោះឧត្តមខ្ពង់ខ្ពស់) មិនបំណងដូច្នោះទេ ព្រោះក្នុងគាថាទាំងនោះ មានតែព្រះពុទ្ធជាសរណៈនោះឯង ។ ពិតហើយ ក្នុងគាថាទាំងនោះ លោកបំណងដល់ព្រះពុទ្ធ និងសរណៈជាតួហេតុស្មើៗ គ្នា យ៉ាងនេះថា សរណៈទាំងក្សេមទាំងឧត្តម ដូច្នេះ ព្រោះពិចារណាដល់ព្រះរតនត្រ័យ មានព្រះពុទ្ធជាដើមនោះ ក្នុងភាពជាសរណៈ ដែលរាប់បានថា កម្ចាត់ភ័យដល់អ្នកដល់សរណគមន៍ លោកក៏ មិនបំណងដល់ព្រះពុទ្ធ និងសរណៈជាតួហេតុស្មើៗ គ្នា ព្រោះមិនសម្រេចជាសរណគមន៍ ដូច្នោះ ពាក្យនេះទើបសាធកៈមិនបាន ។

ប្រសិនបើបុគ្គលជំទាស់ថា គួរនឹងបំណងយកព្រះពុទ្ធ និងសរណៈ

ជាតួហេតុស្មើៗ គ្នា ព្រោះសម្រេចជាសរណគមន៍ សូម្បីកាលមានសេចក្ដីសម្ព័ន្ធជាមួយអ្នកដល់សរណគមន៍បាន ក្នុងបាលីនេះថា **ឯតំ សរណមាគម្ម សព្វទុក្ខា បមុច្ចតិ** (បុគ្គលអាស្រ័យសរណៈនោះ រមែងរួចផុតចាកទុក្ខទាំងពួង) ដូច្នេះ ។ មិនមែនដូច្នោះទេ ព្រោះជំទាស់ប្រកបដោយទោសដូចពោលមកអំពីមុនហើយ ។ សេចក្ដីពិត សូម្បីក្នុងប្រការនោះ ក៏នឹងគប្បីជំទាស់ដោយទោសដែលពោលមកអំពីមុនយ៉ាងនេះថា កាលមានព្រះពុទ្ធ និងសរណៈជាតួហេតុស្មើៗ គ្នា បុគ្គលសូម្បីមានចិត្តវិឯ អាស្រ័យសរណៈ គឺ ព្រះពុទ្ធ ព្រះធម៌ និងព្រះសង្ឃ ក៏នឹងគប្បីរួចផុតចាកទុក្ខបានទាំងអស់ឬ តែនឹងថា មិនបានជំទាស់ដោយទោសក៏មិនមែន ដូច្នោះពាក្យនោះទើបសាធកៈមិនបាន ។ គប្បីជ្រាបក្នុងប្រការនោះ យ៉ាងនេះថា សត្វទាំងឡាយ កាលនឹងរួចផុត ដោយអនុភាពរបស់ព្រះមានព្រះភាគទ្រង់ជាកល្យាណមិត្រ លោកក៏ពោលថា អាស្រ័យកល្យាណមិត្រទើបរួចផុតបានក្នុងបាលីនេះថា ៖

ម្នាលអានន្ទ ក៏សត្វទាំងឡាយដែលមានជាតិ (ការ

កើត) ជាធម្មតាអាស្រ័យ តថាគតជាកល្យាណមិត្រ រមែង

រួចផុតចាកជាតិដូច្នេះ យ៉ាងណា សូម្បីក្នុងទីនេះ បុគ្គលកាល

នឹងរួចផុតដោយអនុភាពនៃសរណៈ គឺ ព្រះពុទ្ធ ព្រះធម៌ និង

ព្រះសង្ឃ លោកក៏ពោលថា បុគ្គលអាស្រ័យសរណៈនេះ

រមែងរួចផុតចាកទុក្ខទាំងពួង ក៏ដូច្នោះ ។

ព្រះពុទ្ធទ្រង់ជាគមនីយៈ (គួរដល់) ក៏មិនត្រូវ សរណៈ ជាគមនីយៈ ក៏មិនត្រូវ ព្រះពុទ្ធ និងសរណៈទាំងពីរ ជាគមនីយៈ ក៏មិនត្រូវ សូម្បីដោយប្រការទាំងពួងយ៉ាងនេះ គមនីយៈ (វត្ថុដែលគួរដល់) របស់អ្នកដល់សរណ-គមន៍ ដែលលោកអធិប្បាយថា "ខ្ញុំដល់វត្ថុដែលគប្បីប្រាថ្នា" គួរពោលដល់ តពីនោះ ក៏គួរពោលដោយយុតិ (គឺប្រការដែលត្រូវ) ក្នុងរឿងនេះ ។ ដូច្នោះ ខ្ញុំនឹងពោលដោយយុតិដូចតទៅនេះ ។

ក្នុងសេចក្តីយុតិនេះ ព្រះពុទ្ធប៉ុណ្ណោះជាគមនីយៈ តែដើម្បីសំដែងអាការ គឺ ការដល់ ពាក្យពោលដល់សរណៈនោះថា ខ្ញុំសូមដល់ព្រះពុទ្ធថាជាសរណៈ ព្រះពុទ្ធអង្គនោះជាសរណៈរបស់ខ្ញុំ ព្រះពុទ្ធអង្គនោះ ជា

បារាយនៈ (នាំមុខ) របស់ខ្ញុំព្រះអង្គ ទ្រង់ជាអ្នកកម្ចាត់ទុក្ខ ព្រះអង្គជាអ្នកទ្រទ្រង់ប្រយោជន៍ ខ្ញុំព្រះអង្គសូមដល់ សេព ចូលជិតព្រះពុទ្ធអង្គនោះដោយសេចក្ដីបំណងដូចពោលមកនេះ ឬថា ខ្ញុំព្រះអង្គដឹង គឺ ជ្រាបយ៉ាងនេះ ។ ពិតហើយ គតិ ជាប្រយោជន៍របស់ធាតុពួកណា សូម្បីសេចក្ដីដឹង ក៏ជាប្រយោជន៍របស់ធាតុទាំងនោះ ។

បើអ្នកជំទាស់ពោលថា ប្រការនោះមិនត្រូវ ព្រោះមិនប្រកបដោយ **ឥតិ** សព្ទ ពាក្យជំទាស់នោះក៏មិនត្រឹមត្រូវ ប្រការយុត្តិដែលត្រូវក្នុងរឿងនោះ គប្បីមានដូច្នេះ ។

ប្រសិនបើ សេចក្ដីក្នុងរឿងនោះគប្បីមានយ៉ាងនេះសោត ។ តែក៏គប្បីត្រូវប្រកប **ឥតិ** សព្ទ ដូចក្នុងប្រយោគទាំងឡាយជាដើមថា **អនិច្ចំ រូបំ អនិច្ចំ រូបន្តិ យថាភូតំ បជានាតិ** (រមែងដឹងច្បាស់រូបដែលមិនទៀងតាមសេចក្ដីពិតថា រូបមិនទៀង) ដូច្នេះ ។ តែ **ឥតិ** សព្ទ លោកមិនបានប្រកបទុក ព្រោះដូច្នោះ ការជំទាស់នោះទើបមិនត្រូវ ។ តែប្រការនោះមិនត្រូវព្រោះហេតុអ្វី ព្រោះសេចក្ដីរបស់ **ឥតិ** សព្ទ មាននៅក្នុងខ្លួននោះ

ហើយ សេចក្តីរបស់ **ឥតិ សទ្ទ** សូម្បីក្នុងទីនេះ ក៏មានព្រមហើយ ដូចក្នុងប្រយោគទាំងឡាយជាដើមយ៉ាងនេះថា **យោ ច ពុទ្ធញ្ច ធម្មញ្ច សង្ឃញ្ច សរណំ គតោ** (ក៏បុគ្គលណាដល់ព្រះពុទ្ធ ព្រះធម៌ និងព្រះសង្ឃថា ជាសរណៈ) ដូច្នេះ តែមិនមែននឹងត្រូវប្រកប **ឥតិ សទ្ទ** ទុកក្នុងទីគ្រប់កន្លែងទេ ព្រោះមាននៅព្រមក្នុងខ្លួនហើយ បណ្ឌិតគប្បីជ្រាបសេចក្តីរបស់ **ឥតិ សទ្ទ** សូម្បីមិនបានប្រកបទុក ដូចដែលប្រកបទុកក្នុងទីនោះ ទាំងក្នុងទីដទៃ ដែលមានកំណើតយ៉ាងនេះ ព្រោះដូច្នោះ **ឥតិ សទ្ទ** ទើបមិនមានទោស (មិនខុស) ។

បើមានអ្នកជំទាស់ពោលថា ពាក្យណាដែលលោកពោលទុកថា ក៏គប្បីសំដែងអាការ គឺ ដល់ ទើបត្រូវពោលបញ្ជាក់ដល់សរណៈ ដូច្នេះ ពាក្យនោះ ក៏មិនត្រូវ ព្រោះសរណៈប៉ុណ្ណោះ ជាគមនីយៈ (វត្ថុដែលគួរដល់) បានក្នុងបាលីជាដើមថា "ម្នាលភិក្ខុទាំងឡាយ តថាគត អនុញ្ញាតការបព្វជ្ជា ដោយសរណគមន៍បី" ដូច្នេះ ពាក្យដែលខ្ញុំពោលនោះ មិនមែនមិនត្រូវ ព្រោះហេតុអ្វី ។ ព្រោះពាក្យនោះ មានព្រមនៅក្នុងខ្លួន ។ ពិត

ហើយ សេចក្ដីរបស់ **ឥតិ** ស័ព្ទនោះ ក៏មាននៅព្រមក្នុងពាក្យនោះឯង ព្រោះហេតុមិនប្រកប **ឥតិ** ស័ព្ទទុកដូចពាក្យមុន ក៏គប្បីឃើញដូចប្រកប **ឥតិ** ស័ព្ទទុក ក្រៅអំពីនេះ ក៏គប្បីជំទាស់ដោយទោស ដូចពោលមកក្នុងកាលមុននោះឯង ព្រោះដូច្នោះ គប្បីកាន់យកតាមដែលលោកបង្រៀនទុកប៉ុណ្ណោះ ។

សម្ដែងវត្ថុដែលគួរដល់ ដូចពោលមកនេះ

## ពណ៌នាសរណៈ គឺ ព្រះធម៌ និងព្រះសង្ឃ

ឥឡូវនេះ នឹងពោលអធិប្បាយតទៅ ។ ក្នុងពាក្យដែលខ្ញុំពោលទុកថា **សូម្បីក្នុងសរណៈ ២ មានជាដើមថា ធម្មំ សរណំ ជាដើម ក៏បានដឹងហើយថា មានន័យយ៉ាងនេះដូចគ្នា** ។ ន័យនៃការពណ៌នានេះណាខ្ញុំពោលទុកក្នុងពាក្យនេះថា **ពុទ្ធំ សរណំ គច្ឆាមិ** ក៏គប្បីជ្រាបន័យនៃការពណ៌នាសេចក្ដីនោះ ក្នុងពីរបទនេះថា **ធម្មំ សរណំ គច្ឆាមិ សង្ឃំ សរណំ គច្ឆាមិ** ។ ពិតហើយ ក្នុងប្រការនោះ ពោលដោយអត្ថ និងព្យញ្ជនៈរបស់ព្រះធម៌ និងព្រះសង្ឃ ក៏មានត្រឹមតែការអធិប្បាយសេចក្ដីដែលមិនដូចគ្នាប៉ុណ្ណោះ ក្រៅពីនោះក៏ដូចគ្នាដូចដែលពោលមកហើយនោះឯង ព្រោះនឹងអធិប្បាយចំពោះសេចក្ដីមិនដូចគ្នា ក្នុងព្រះធម៌ និងព្រះសង្ឃ ដូច្នេះ អាចារ្យពួកមួយពោលថា មគ្គ ផល និព្វាន ឈ្មោះថា **ព្រះធម៌** ។ ខន្តិ (សេចក្ដីពេញចិត្ត ឬមតិ) របស់ពួកយើងថា មគ្គ និងវិបាកៈប៉ុណ្ណោះ ឈ្មោះថា **ព្រះធម៌** ក្នុងអត្ថនេះ ព្រោះទ្រង់ជាអ្នកចម្រើនមគ្គផល និងទ្រង់ជាអ្នកបានធ្វើឲ្យជាក់ច្បាស់ព្រះនិព្វានហើយ ព្រោះមិនឲ្យធ្លាក់ទៅក្នុងអបាយ

ទាំងឡាយ និងធ្វើឲ្យរីករាយចិត្ត សូមលើកយកអគ្គប្បសាទសូត្រនេះឯង ជាសាធកៈ ។ សមពិតដូចព្រះមានព្រះភាគត្រាស់ទុកក្នុងអគ្គប្បាសាទសូត្រ ជាដើមយ៉ាងនេះថា ៖

"ម្នាលភិក្ខុទាំងឡាយ សង្ខតធម៌មាននៅត្រឹមណា អរិយមគ្គប្រកប ដោយអង្គ ៨ លោកពោលថា ជាកំពូលនៃសង្ខតធម៌ត្រឹមនោះ" ក្រុមនៃ បុគ្គលទាំងឡាយ អ្នកព្រមព្រៀងដោយអរិយមគ្គ ៤ យ៉ាង និងអ្នកមាន ខន្ធសន្តានដែលអប់រំដោយសមាធិ (សាមញ្ញផល ៤) ឈ្មោះថា ព្រះសង្ឃ ព្រោះរួមគ្នា ដោយការរួមទិដ្ឋិ និងសីល សមពិតដូចព្រះមានព្រះភាគត្រាស់ ទុកដូច្នេះថា ៖

ម្នាលអានន្ទ អ្នកសម្គាល់សេចក្តីនោះដូចម្តេច ធម៌ ពួកណា ដែលតថាគតសម្តែងដើម្បីដឹងក្រៃលែងសម្រាប់អ្នក ទាំងឡាយ គឺ សតិប្បដ្ឋាន ៤ សម្មប្បធាន ៤ ឥទ្ធិបាទ ៤ ឥន្ទ្រិយ ៥ ពលៈ ៥ ពោជ្ឈង្គៈ ៧ អរិយមគ្គមានអង្គ ៨ ម្នាលអានន្ទ អ្នកនឹងមិនឃើញភិក្ខុសូម្បី ២ រូប មានវាទៈ

ផ្សេងគ្នាក្នុងធម៌ទាំងនេះឡើយ ។

ពិតហើយ ព្រះសង្ឃដោយបរមត្ថនេះ ដែលបុគ្គលគប្បីដល់ថាជាសរណៈ ។ ក្នុងព្រះសូត្រដែលព្រះមានព្រះភាគត្រាស់ទុកថា "ព្រះសង្ឃសាវករបស់ព្រះមានព្រះភាគ ជាអ្នកគួរទទួលរបស់ដែលគេនាំចូលមក គួរក្រាកទទួល គួរដល់ការធ្វើបុណ្យ គួរធ្វើអញ្ជលី ជាស្រែបុណ្យដ៏ប្រសើរក្នុងលោក ។ សរណគមន៍របស់អ្នកដល់សរណៈនោះ រមែងមិនដាច់ មិនសៅហ្មង ដោយការសំពះជាដើម ក្នុងភិក្ខុសង្ឃ ឬភិក្ខុនីសង្ឃសូម្បីពួកដទៃ ឬព្រះសង្ឃដែលមានព្រះពុទ្ធជាប្រធាន ឬសម្មតិសង្ឃ ផ្សេងដោយសង្ឃចតុវគ្គជាដើម ឬសូម្បីក្នុងបុគ្គលម្នាក់ ដែលបួសឧទ្ទិសចំពោះព្រះ-មានព្រះភាគ សេចក្តីផ្សេងគ្នាក្នុងសង្ឃសរណៈមានប៉ុណ្ណេះ ។ ចំណែកការដាច់ និងមិនដាច់ជាដើមនៃសរណគមន៍នេះ និងចំណែកក្រៅពីដូចដែលពោលហើយ គប្បីជ្រាបតាមន័យដូចពោលមកហើយក្នុងកាលមុន ។ ការពណ៌នាសេចក្តីប្រការនេះថា សូម្បីក្នុង ២ សរណៈថា ធម្មំ សរណំ ជាដើម ក៏បានដឹងហើយថា ន័យនេះដូចគ្នា ដូច្នេះ មានប៉ុណ្ណេះសិន ។

## អធិប្បាយហេតុក្នុងការកំណត់តាមលំដាប់

ក្នុងពាក្យនេះថា **និងអធិប្បាយហេតុក្នុងការកំណត់តាមលំដាប់** ឥឡូវនេះ នឹងអធិប្បាយហេតុក្នុងការកំណត់តាមលំដាប់យ៉ាងនេះថា ក្នុងពាក្យដល់សរណៈទាំងបីនោះ លោកប្រកាសព្រះពុទ្ធជាលំដាប់ដំបូង ព្រោះជាបុគ្គលប្រសើរលើសសត្វទាំងពួង ប្រកាសព្រះធម៌តាមលំដាប់តមក ព្រោះជាដែនកើតរបស់ព្រះពុទ្ធនោះ និងព្រោះជាធម៌ដែលព្រះពុទ្ធអង្គនោះទ្រង់ទូន្មានហើយ ប្រកាសព្រះសង្ឃជាលំដាប់ចុងក្រោយ ព្រោះជាអ្នកទ្រទ្រង់ទុកនូវព្រះធម៌នោះ និងព្រោះសេពព្រះធម៌នោះ ។ ន័យម្យ៉ាងទៀត លោកប្រកាសព្រះពុទ្ធជាលំដាប់ដំបូង ព្រោះទ្រង់ប្រកបសត្វទាំងពួងទុកក្នុងហិត-ប្រយោជន៍ ប្រកាសព្រះធម៌ជាលំដាប់តមក ព្រោះជាដែនកើតនៃព្រះពុទ្ធអង្គនោះ និងព្រោះជាធម៌ ជាហិតប្រយោជន៍ដល់សត្វទាំងពួង ប្រកាសព្រះសង្ឃជាលំដាប់ចុងក្រោយ ព្រោះព្រះសង្ឃជាអ្នកប្រតិបត្តិដើម្បីសម្រេចហិតប្រយោជន៍ និងមានហិតប្រយោជន៍ដែលសម្រេចហើយ កំណត់ដោយភាពជាសរណៈ ។

# ប្រកាសដោយសេចក្តីឧបមា

ឥឡូវនេះ និងអធិប្បាយពាក្យថា **នឹងប្រកាសព្រះរតនត្រ័យនោះដោយការឧបមាទាំងឡាយ** ក្នុងពាក្យនោះ ព្រះពុទ្ធប្រៀបដូចព្រះច័ន្ទពេញបូរមី ព្រះធម៌ប្រៀបដូចរស្មីរបស់ព្រះច័ន្ទ ព្រះសង្ឃប្រៀបដូចលោកដែលរីករាយដោយរស្មីរបស់ព្រះច័ន្ទពេញបូរមីដែលធ្វើឲ្យកើតឡើង ។ ព្រះពុទ្ធប្រៀបដូចព្រះអាទិត្យបញ្ចេញពន្លឺដ៏ស្រទន់ ព្រះធម៌ប្រៀបដូចសំណាញ់នៃរស្មីរបស់ព្រះអាទិត្យនោះ ព្រះសង្ឃប្រៀបដូចលោកដែលព្រះអាទិត្យនោះកម្ចាត់ងងឹតហើយ ។ ព្រះពុទ្ធប្រៀបដូចមនុស្សដុតព្រៃ ព្រះធម៌ជាគ្រឿងដុតព្រៃ គឺ កិលេស ប្រៀបដូចជាភ្លើងឆេះព្រៃ ព្រះសង្ឃជាបុញ្ញខេត្ត ព្រោះដុតកិលេសបានហើយ ប្រៀបដូចជាភូមិភាគដែលជាស្រែ ព្រោះដុតព្រៃអស់ហើយ ។ ព្រះពុទ្ធប្រៀបដូចភ្លៀងធំ ព្រះធម៌ប្រៀបដូចទឹកភ្លៀង ព្រះសង្ឃអ្នកស្ងប់រម្ងាប់កិលេស ប្រៀបដូចជនបទដែលស្ងប់ធូលី ព្រោះត្រូវទឹកភ្លៀង ។ ព្រះពុទ្ធប្រៀបដូចសារថីដ៏ល្អ ព្រះធម៌ប្រៀបដូចឧបាយហ្វឹកហាត់សេះអាជានេយ្យ ព្រះសង្ឃប្រៀបដូចហ្វូងសេះអាជានេយ្យដែល

ហ្វឹកហាត់មកល្អហើយ ។ ព្រះពុទ្ធប្រៀបដូចជាពេទ្យ ព្រោះទ្រង់ដកកូនសរ គឺ ទិដ្ឋិ បានអស់ហើយ ព្រះធម៌ប្រៀបដូចឧបាយដែលដកកូនសរចេញបាន ព្រះសង្ឃប្រៀបដូចអ្នកដកកូនសរ គឺ ទិដ្ឋិចេញហើយ ប្រៀបដូចជនដែលត្រូវដកកូនសរចេញហើយ ។ ន័យម្យ៉ាងទៀត ព្រះពុទ្ធប្រៀបដូចចក្ខុពេទ្យ ព្រោះទ្រង់បកផ្ទាំងមោហៈចេញបានហើយ ព្រះធម៌ប្រៀបដូចឧបាយគ្រឿងបកភ្នែក ព្រះសង្ឃអ្នកមានភ្នែកដែលត្រូវបកហើយ អ្នកមានកែវភ្នែក គឺ ញាណដ៏បរិសុទ្ធ ប្រៀបដូចជនដែលបកភ្នែកហើយ មានកែវភ្នែកស្រស់ថ្លា ។ ន័យម្យ៉ាងទៀត ព្រះពុទ្ធប្រៀបដូចពេទ្យដ៏ឆ្លាត ព្រោះអាចកម្ចាត់ព្យាធិ គឺ កិលេសព្រមទាំងអនុស័យចេញបាន ព្រះធម៌ប្រៀបដូចភេសជ្ជៈ (ថ្នាំ) ដែលព្យាបាលត្រឹមត្រូវហើយ ព្រះសង្ឃអ្នកមានព្យាធិ គឺ កិលេស និងអនុស័យ ដែលស្ងប់រម្ងាប់ហើយ ប្រៀបដូចពួកជនដែលព្យាធិស្ងប់ហើយព្រោះថ្នាំ ។

ន័យម្យ៉ាងទៀត ព្រះពុទ្ធប្រៀបដូចអ្នកប្រាប់ផ្លូវល្អ ព្រះធម៌ប្រៀបដូចផ្លូវល្អ ឬទីដែលផុតចាកភ័យ ព្រះសង្ឃប្រៀបដូចអ្នកដើរផ្លូវ ដល់ទីដែល

ផុតភ័យ ។ ព្រះពុទ្ធប្រៀបដូចម្ចាស់ទូកដ៏ល្អ ព្រះធម៌ប្រៀបដូចជាទូក ព្រះសង្ឃប្រៀបដូចជនអ្នកធ្វើដំណើរដល់ត្រើយ ។ ព្រះពុទ្ធប្រៀបដូចជាព្រៃហិមពាន្ត ព្រះធម៌ប្រៀបដូចជាឱសថ ដែលកើតអំពីព្រៃហិមពាន្តនោះ ព្រះសង្ឃប្រៀបដូចជនអ្នកមិនមានរោគព្រោះប្រើថ្នាំ ។ ព្រះពុទ្ធប្រៀបដូចអ្នកប្រទានទ្រព្យ ព្រះធម៌ប្រៀបដូចជាទ្រព្យ ព្រះសង្ឃអ្នកបានអរិយទ្រព្យមកដោយប្រពៃ ប្រៀបដូចជាជនអ្នកបានទ្រព្យតាមប្រាថ្នា ។ ព្រះពុទ្ធប្រៀបដូចអ្នកបង្ហាញកំណប់ទ្រព្យ ព្រះធម៌ប្រៀបដូចកំណប់ទ្រព្យ ព្រះសង្ឃប្រៀបដូចជាអ្នកបានកំណប់ទ្រព្យ ។

ន័យម្យ៉ាងទៀត ព្រះពុទ្ធជាវីរៈបុរស ប្រៀបដូចអ្នកប្រទានសេចក្តីមិនមានភ័យ ព្រះធម៌ប្រៀបដូចការមិនមានភ័យ ព្រះសង្ឃអ្នកផុតចាកភ័យគ្រប់យ៉ាង ប្រៀបដូចជនអ្នកដល់នូវការមិនមានភ័យ ។ ព្រះពុទ្ធប្រៀបដូចអ្នកលួងលោម ព្រះធម៌ប្រៀបដូចជាការលួងលោម ព្រះសង្ឃប្រៀបដូចជាជនដែលត្រូវលួងលោម ។ ព្រះពុទ្ធប្រៀបដូចជាមិត្រល្អ ព្រះធម៌ប្រៀបដូចអ្នកទូន្មានដែលជាហិតប្រយោជន៍ ព្រះសង្ឃប្រៀបដូចជាជនអ្នកបាននូវ

ប្រយោជន៍ខ្លួន ព្រោះប្រកបដោយហិតប្រយោជន៍ ។ ព្រះពុទ្ធប្រៀបដូចជាអ្នកបង្កើតទ្រព្យ ព្រះធម៌ប្រៀបដូចជាទ្រព្យដែលជាសារៈ ព្រះសង្ឃប្រៀបដូចជនអ្នកប្រើប្រាស់ទ្រព្យដែលជាសារៈ ។ ព្រះពុទ្ធប្រៀបដូចជាអ្នកផ្ងូតទឹកឲ្យរាជកុមារ ព្រះធម៌ប្រៀបដូចជាទឹកដែលផ្ងូតដល់រាជកុមារ ព្រះសង្ឃអ្នកផ្ងូតទឹកដោយល្អហើយ គឺ ព្រះសទ្ធម្ម ប្រៀបដូចជាពួករាជកុមារដែលស្រង់ទឹកល្អហើយ ។ ព្រះពុទ្ធប្រៀបដូចជាងអ្នកធ្វើគ្រឿងប្រដាប់ ព្រះធម៌ប្រៀបដូចជាគ្រឿងប្រដាប់ ព្រះសង្ឃអ្នកប្រដាប់ដោយព្រះសទ្ធម្ម ប្រៀបដូចជារាជឱរសដែលទ្រង់ប្រដាប់ហើយ ។ ព្រះពុទ្ធប្រៀបដូចខ្លឹមច័ន្ទ ព្រះធម៌ប្រៀបដូចក្លិនដែលកើតអំពីខ្លឹមច័ន្ទនោះ ព្រះសង្ឃអ្នកស្ងប់រម្ងាប់សេចក្ដីក្ដៅក្រហាយបានអស់ហើយ ព្រោះឧបភោគព្រះសទ្ធម្ម ប្រៀបដូចជនអ្នកស្ងប់រម្ងាប់សេចក្ដីក្ដៅក្រហាយ ព្រោះប្រើខ្លឹមច័ន្ទ ។ ព្រះពុទ្ធប្រៀបដូចបិតាប្រគល់មត៌កដោយធម៌ ព្រះធម៌ប្រៀបដូចជាមត៌ក ព្រះសង្ឃអ្នកទទួលមត៌ក គឺ ព្រះសទ្ធម្ម ប្រៀបដូចជាបុត្រអ្នកទទួលមត៌ក ។ ព្រះពុទ្ធប្រៀបដូចជាផ្កាបទុមដែលរីក ព្រះធម៌ប្រៀបដូចជាទឹកដមដែលកើតអំពីផ្កាបទុម

ដែលរីកនោះ ព្រះសង្ឃប្រៀបដូចជាពួកភមរៈដែលក្រេបនូវទឹកដមនោះ ។ គប្បីប្រកាសព្រះរតនត្រ័យនោះ ដោយឧបាយទាំងឡាយ ដូចដែលពោលមកដូច្នេះ ។

មាតិកា នៃកថាពណ៌នាសេចក្តីដែលតាំងទុកក្នុងខាងដើម ដោយ ៤ គាថាថា **ព្រះរតនត្រ័យ នរណាពោល ពោលទីណា ពោលកាលណា ពោលព្រោះហេតុអ្វី** ជាដើម ក៏ជាការប្រកាសហើយដោយអត្ថ ដោយកថាមានប្រមាណត្រឹមតែប៉ុណ្ណោះឯង ។

ចប់អដ្ឋកថា ព្រះរតនត្រ័យ

# សិក្ខាបទ ១០ ក្នុងខុទ្ទកបាឋៈ

## អដ្ឋកថា សិក្ខាបទសូត្រ ២

### មាតិកាបាឋៈពោលដោយសិក្ខាបទ

*គប្បីជ្រាបវិនិច្ឆ័យក្នុង សិក្ខាបទសូត្រទី ២ ដូចតទៅនេះ ៖*

[២] *លុះសម្ដែងការចូលកាន់ព្រះសាសនា ដោយការដល់សរណគមន៍ យ៉ាងនេះហើយ ដើម្បីនឹងពណ៌នាបាឋៈដែលពោលដោយសិក្ខាបទដែលតាំងជានិក្ខេបបទទុក ដើម្បីសំដែងសិក្ខាបទទាំងឡាយ ដែលឧបាសកឬបព្វជិតអ្នកចូលមកកាន់ព្រះសាសនា គប្បីសិក្សាជាលំដាប់ដំបូង ឥឡូវនេះ ខ្ញុំនឹងពោលមាតិកាដូចតទៅនេះ ៖*

*សិក្ខាបទទាំងនេះ នរណាពោល ពោលទីណា*

*ពោលកាលណា ពោលព្រោះហេតុអ្វី ចាំបាច់កំណត់*

*ពោលន័យនោះ ដោយសេចក្ដីប្លែកគ្នានៃសិក្ខាបទទូទៅ*

*ត្រូវកំណត់ទោស ទាំងដែលជាបកតិវជ្ជៈ និងបណ្ណត្តិវជ្ជៈ*

*ធ្វើការបង្ហាញន័យទូទៅ គ្រប់សិក្ខាបទ ដោយព្យញ្ជនៈ*

និងអត្ថនៃបទទាំងឡាយ ។

តែក្នុង ៥ សិក្ខាបទខាងដើម គប្បីជ្រាបវិនិច្ឆ័យ ដោយប្រកាសសេចក្ដីប្លែកគ្នារបស់សិក្ខាបទទូទៅ ដោយតែម្យ៉ាង និងសេចក្ដីផ្សេងគ្នាមានជាអាទិ៍ តាំងអំពីបាណាតិបាតជាដើមទៅ ដោយអារម្មណ៍ ការសមាទាន និងការដាច់ ដោយមានទោសច្រើន ដោយប្រយោគ អង្គ និងសមុដ្ឋាន ដោយវេទនា មូល និងកម្ម ដោយការវៀរ និងផល ។

យុត្តិ គឺ សេចក្ដីត្រឹមត្រូវចាកពីការពណ៌នា ៥ សិក្ខាបទខាងដើម គប្បីនាំមកប្រើក្នុង ៥ សិក្ខាបទខាងក្រោយ គប្បីពោលសិក្ខាបទជាចំណែកៗ គប្បីជ្រាបថា សិក្ខាបទ មានអាក្រក់ជាដើមទុកផងចុះ ។

ក្នុងមាតិកាទាំង ១០ សិក្ខាបទ មានបាណាតិបាតវេរមណីជាដើម នោះ ព្រះមានព្រះភាគ ព្រះអង្គត្រាស់ទុកតែម្យ៉ាង មិនមែនព្រះសាវកជា

ដើមទេ (ពោលទុក) ។ ពិតហើយ ព្រះមានព្រះភាគស្តេចចេញចាកក្រុង កបិលវត្ថុ ដល់ក្រុងសាវត្ថី ទ្រង់ឲ្យព្រះរាហុលបព្វជ្ជាហើយ នៅវត្តជេតពន អារាមរបស់អនាថបិណ្ឌិក: ក្រុងសាវត្ថី ត្រាស់សិក្ខាបទ ១០ នោះ ដើម្បី ទ្រង់កំណត់សិក្ខាបទសម្រាប់សាមណេរទាំងឡាយ ។ សមពិតដូចដែល លោកពោលពាក្យនេះទុកថា ៖

គ្រានោះ ព្រះមានព្រះភាគប្រថាប់សម្រាកតាមព្រះពុទ្ធអធ្យាស្រ័យ នៅក្នុងកបិលវត្ថុហើយ ស្តេចចារិកទៅកាន់ក្រុងសាវត្ថី កាលស្តេចចារិក មកតាមលំដាប់ ក៏ដល់ក្រុងសាវត្ថី ។ នៅក្នុងទីនោះ ព្រះមានព្រះភាគ ប្រថាប់នៅក្នុងវត្តជេតពន អារាមរបស់អនាថបិណ្ឌិក: ក្រុងសាវត្ថី ។ សម័យ នោះ ។ល។ សាមណេរទាំងឡាយមានការត្រិះរិះថា សិក្ខាបទទាំងឡាយ សម្រាប់ពួកយើងមានប៉ុន្មានទៅហ្ន៎ ពួកយើងនឹងគប្បីសិក្សាក្នុងសិក្ខាបទ ចំនួនប៉ុន្មាន ។ ភិក្ខុទាំងឡាយ ទើបនាំសេចក្តីនោះក្រាបទូលចំពោះព្រះ- មានព្រះភាគ ។ ព្រះមានព្រះភាគទ្រង់ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតិសិក្ខាបទ ១០ សម្រាប់សាមណេរទាំងឡាយ ដើម្បីសាម-

ណោះទាំងឡាយសិក្សាក្នុងសិក្ខាបទ ១០ នោះ គឺ **បាណាតិបាតា វេរមណី** ។ល។ **ជាតរូបរជតបដិគ្គហណា វេរមណី** ដូច្នេះ ។

សិក្ខាបទទាំង ១០ នោះ គប្បីជ្រាបថា លោកលើកឡើងទុកដោយលំនាំព្រះសូត្រថា **សមាទាយ សិក្ខតិ សិក្ខាបទេសុ** (សមាទានសិក្សាក្នុងសិក្ខាបទទាំងឡាយ) និងដោយលំនាំបាឋៈដែលលោកសម្តែងទុកក្នុងសរណគមន៍យ៉ាងនេះថា **បាណាតិបាតា វេរមណីសិក្ខាបទំ សមាទិយាមិ** (ខ្ញុំសមាទានសិក្ខាបទ គឺ ចេតនាវៀរចាកបាណាតិបាត) ជាដើម គប្បីជ្រាបន័យដែលថា សិក្ខាបទទាំងនេះ នរណាពោល ពោលក្នុងកាលណា ពោលព្រោះហេតុអ្វី ទីងពោលន័យនោះ ដូច្នេះមុន ។

## កំណត់សេចក្ដីផ្សេងគ្នានៃសិក្ខាបទទូទៅ

ក៏បណ្ដាសិក្ខាបទទាំងនោះ ពីរសិក្ខាបទខាងដើម និងសិក្ខាបទទី ៤-៥ ទូទៅទាំងឧបាសកទាំងសាមណេរដោយភាពជានិច្ចសីល ។ តែថាដោយភាពជាឧបោសថសីលរបស់ពួកឧបាសក វៀរប្រការចុងក្រោយរបស់សិក្ខាបទទាំងអស់ រួមសិក្ខាបទទី ៧ និងទី ៨ ចូលជាអង្គតែមួយ សូម្បី

សិក្ខាបទទាំងអស់ ក៏ទូទៅដល់សាមណេរទាំងឡាយ ចំណែកសិក្ខាបទក្រោយជាពិសេសសម្រាប់សាមណេរប៉ុណ្ណោះ គប្បីជ្រាបការកំណត់ដោយភាពផ្សេងគ្នានៃសិក្ខាបទទូទៅដូចពោលមកនេះ ដូច្នេះ ។ គប្បីកំណត់បកតិវជ្ជ: និងបណ្ណត្តិវជ្ជ: យ៉ាងនេះ គឺ បណ្ដាសិក្ខាបទទាំង ៥ នោះ សិក្ខាបទខាងដើម កំណត់ដោយចេតនាវៀរចាកបកតិវជ្ជ:របស់បាណាតិបាតជាដើម ព្រោះមានអកុសលចិត្តជាសមុដ្ឋានតែម្យ៉ាង សិក្ខាបទក្រៅអំពីនេះ កំណត់ដោយចេតនាវៀរចាកបណ្ណត្តិវជ្ជ: ។

## អធិប្បាយបទទូទៅ

ក៏ព្រោះហេតុក្នុងបណ្ដាបទទាំងនោះ បទទាំងនេះថា (**វេរមណី សិក្ខាបទំ សមាទិយាមិ** (ខ្ញុំសូមសមាទានសិក្ខាបទ គឺ ចេតនាវៀរចាក) ជាបទទូទៅទាំងអស់ ដូច្នោះ គប្បីជ្រាបការអធិប្បាយបទទាំងនោះទូទៅ ទាំងដោយព្យញ្ជន: ទាំងដោយអត្ថដូចតទៅនេះ ៖

ក្នុងបទទាំងនោះ គប្បីជ្រាបដោយពាក្យព្យញ្ជន: ឈ្មោះថា **វេរមណី** ព្រោះវៀរចាក អធិប្បាយថា លះ បន្ទោបង់ពៀរ គឺ ធ្វើឲ្យដល់ទីបំផុត

ឲ្យដល់ការមិនមានតទៅទៀត ។ ន័យម្យ៉ាងទៀត បុគ្គលរមែងវៀរចាកពៀរ ដោយចេតនាជាតួកម្មនោះ ហេតុនោះ ចេតនានោះ ទើបឈ្មោះថា **វេរមណី** ព្រោះយក **វិ** អក្សរជា **វេ** អក្សរ ។ ដោយហេតុនោះឯង ក្នុងបទនេះ ពុទ្ធបរិស័ទទើបសូត្រជា ២ យ៉ាងថា **វេរមណីសិក្ខាបទំ វិរមណីសិក្ខាបទំ** ។ ឈ្មោះថា **សិក្ខា** ព្រោះបុគ្គលគប្បីសិក្សា ។ ឈ្មោះថា **បទ** ព្រោះជាគ្រឿងដល់ ។ ន័យម្យ៉ាងទៀត លោកអធិប្បាយថា ជាមូល ជាទីអាស្រ័យ ជាទីតាំង ។ សិក្ខាបទ គឺ ចេតនាជាគ្រឿងវៀរចាក ឈ្មោះថា **វេរមណីសិក្ខាបទ** ឬ **វិរមណីសិក្ខាបទ** តាមន័យទី ២ ។ ខ្ញុំកាន់យកដោយល្អ ឈ្មោះថា **សមាទិយាមិ** លោកអធិប្បាយថា ខ្ញុំកាន់យកដោយបំណងនឹងមិនកន្លងល្មើស ព្រោះជាអ្នកធ្វើសិក្ខាបទឲ្យរឹងមាំ មិនឲ្យដាច់ មិនឲ្យធ្លុះធ្លាយ ។

តែកាលពោលដោយអត្ថ បទថា **វេរមណី** បានដល់ វិរតិ ចេតនាវៀរចាកប្រកបដោយចិត្តដែលជាកាមាវចរកុសល ។ វិរតិរបស់បុគ្គលអ្នកវៀរចាកបាណាតិបាត លោកពោលទុកក្នុងវិភង្គ ដោយន័យជាដើមយ៉ាង

នេះថា បេតនាលះ បេតនាវៀរ វៀរដាច់ខាត លះបង់ចោល មិនធ្វើ មិនប្រទូស្ត មិនកន្លង មិនល្មើសខេត្ត ការផ្តាច់ស្ពានចេញដោយអរិយមគ្គ ឈ្មោះថា **សេតុ** ចាកបាណាតិបាត ក្នុងសម័យនោះ ឯណា ។ ធម្មតាថា វេរមណីនោះសូម្បីជាលោកុត្តរៈ មានហើយក៏ពិត តែក្នុងទីនេះ ក៏គួរជា វេរមណីដែលប្រព្រឹត្តទៅដោយការសមាទាន ព្រោះអ្នកសមាទានពោលថា **សមាទិយាមិ** ព្រោះដូច្នោះ វេរមណីដែលជាលោកុត្តរៈនោះ ទើបមិនមាន ខ្ញុំពោលថា **វិរតិ** (បេតនាវៀរ) ប្រកបដោយចិត្តដែលកាមាវចរកុសល ។

បទថា **សិក្ខា** (**សិក្ខា**) បានដល់ សិក្ខា ៣ គឺ អធិសីលសិក្ខា អធិចិត្តសិក្ខាបទ អធិប្បញ្ញាសិក្ខា ។ តែក្នុងទីនេះ សីល គឺ សម្បត្តិ-វិរតិ វិបស្សនាដែលជាលោកិយៈ រូបឈាន និងអរូបឈាន និងអរិយមគ្គ លោកបំណងថា **សិក្ខា** ក្នុងបទថាសិក្ខានេះ ដូចដែលលោកពោលទុកថា

ធម៌ពួកណា ឈ្មោះថា សិក្ខា សម័យណា ចិត្ត ជាកុសលជាកាមាវចរកើតឡើង សហគតជាមួយសោ-មនស្ស សម្បយុត្តដោយញាណ ។ល។ ក្នុងសម័យនោះ

ផស្សៈក៏មាន ។បេ។ ការមិនរាយមាយក៏មាន ធម៌ទាំង នេះ ឈ្មោះថា សិក្ខា ។

ធម៌ពួកណា ឈ្មោះថា សិក្ខា សម័យណាដែល ព្រះយោគាវចរចម្រើនអរិយមគ្គ ដោយការចូលដល់រូប-ឈាន ស្ងាត់ចាកកាមទាំងឡាយ ស្ងាត់ចាកអកុសលធម៌ ទាំងឡាយ ។បេ។ ចូលដល់បឋមឈាន ។បេ។ ចូលដល់ បញ្ចមឈាន ។បេ។ ការមិនរាយមាយក៏មាន ធម៌ទាំងនេះ ឈ្មោះថា សិក្ខា ។

ធម៌ពួកណា ឈ្មោះថា សិក្ខា ក្នុងសម័យណា ព្រះយោគាវចរចម្រើនមគ្គ ដោយការចូលដល់អរូបឈាន ។បេ។ សហគតជាមួយនេវសញ្ញានាសញ្ញាយតនឈាន ។បេ។ ការមិនរាយមាយក៏មាន ធម៌ទាំងនេះ ឈ្មោះថា សិក្ខា ។

ធម៌ពួកណា ឈ្មោះថា សិក្ខា ក្នុងសម័យណា

ព្រះយោគាវចរចម្រើនលោកុត្តរឈាន ជាធម៌នាំសត្វ

ចេញចាកទុក្ខ ។ល។ សេចក្ដីមិនរាយមាយក៏មាន ធម៌

ទាំងនេះ ឈ្មោះថា សិក្ខា ។

បទ គឺ ឧបាយជាគ្រឿងដល់ ម្យ៉ាងទៀត ជាមូល ជាទីអាស្រ័យ ជាទីតាំង នៃសិក្ខាណាមួយក្នុងបណ្ដាសិក្ខាទាំងនោះ ហេតុនោះ ទើបឈ្មោះថា សិក្ខាបទ ។ សមដូចដែលលោកពោលទុកដូច្នេះថា ព្រះយោគាវចរអាស្រ័យសីល តាំងនៅក្នុងសីល កាលចម្រើន គឺ ធ្វើឲ្យច្រើននូវពោជ្ឈង្គ ៧ យ៉ាងនេះជាដើម ។ គប្បីធ្វើការអធិប្បាយដោយព្យញ្ជនៈ ដោយអត្ថទូទៅដល់បទទាំងឡាយទូទៅ ក្នុងបទទាំងនោះ ដោយប្រការដូច្នេះ ។

## ពណ៌នា ៥ សិក្ខាបទខាងដើម

ពាក្យណាខ្ញុំពោលទុកថា តែក្នុង ៥ សិក្ខាបទខាងដើម គប្បីជ្រាបវិនិច្ឆ័យដោយប្រកាសសេចក្ដីផ្សេងគ្នា ក្នុងពាក្យនោះ ឥឡូវនេះ ខ្ញុំនឹងពោលអធិប្បាយដូច្នេះ ជាដំបូង ក្នុងបទថា **បាណាតិបាតោ** (ញុំាងសត្វមានជីវិតឲ្យធ្លាក់ចុះ) នេះ បទថា **បាណោ** បានដល់ ការបន្តនៃខន្ធដែល

ដាច់ដោយជីវិតិន្ទ្រីយ៍ ។ ន័យម្យ៉ាងទៀត បានដល់ សត្វ ដែលបណ្ឌិតអាស្រ័យការបន្តនៃខន្ធនោះបញ្ញត្តិទុក ។ ក៏វធកចេតនា (ចេតនាគិតនឹងសម្លាប់) របស់បុគ្គលអ្នកមានសេចក្តីសំគាល់ក្នុងសត្វមានជីវិតនោះថា ជាសត្វមានជីវិត ជាសមុដ្ឋាននៃសេចក្តីព្យាយាមដែលនឹងត្រូវផ្តាច់ជីវិតិន្ទ្រីយ៍របស់សត្វមានជីវិតនោះ ប្រព្រឹត្តទៅតាមកាយទ្វារ និងវចីទ្វារ ទ្វារណាមួយ ឈ្មោះថា **បាណាតិបាត** ។

ក្នុងបទថា **អទិន្នាទានំ (កាន់យករបស់ដែលម្ចាស់របស់គេមិនបានឲ្យ)** បានដល់ ទ្រព្យរបស់របរដែលម្ចាស់គេហួងហែង ។ ដែលម្ចាស់របស់កាលនឹងធ្វើតាមដែលត្រូវការ ក៏មិនត្រូវទោស មិនត្រូវតិះដៀល ថេយ្យ-ចេតនា (ចេតនាគិតនឹងលួច) របស់បុគ្គលអ្នកមានសេចក្តីសំគាល់ក្នុងទ្រព្យរបស់ដែលម្ចាស់របស់គេហួងហែងថា ជាទ្រព្យរបស់ដែលម្ចាស់គេហួងហែងជាសមុដ្ឋាននៃសេចក្តីព្យាយាមនឹងលួចទ្រព្យរបស់នោះ ប្រព្រឹត្តទៅតាមកាយទ្វារ និងវចីទ្វារ ទ្វារណាមួយ ឈ្មោះថា **អទិន្នាទាន** ។

បទថា **អព្រហ្មចរិយំ (ការប្រព្រឹត្តមិនមែនជាព្រហ្មចារ្យ)** បានដល់

ការប្រព្រឹត្តមិនប្រសើរ ចេតនាជាហេតុលះល្មើសក្នុងឋានៈ គឺ ការសេព អសទ្ធម្ម ដែលប្រព្រឹត្តទៅតាមកាយទ្វារដោយការសេពមេថុន ឈ្មោះថា អព្រហ្មចារ្យ ។

បទថា **មុសាវាទោ** (ការពោលកុហក) នេះ បទថា **មុសា** (កុហក) បានដល់ វចីបយោគ ឬកាយបយោគដែលកាត់ប្រយោជន៍របស់បុគ្គលដែលបំណងនឹងឲ្យឃ្លៀងឃ្លាតពីសេចក្ដីពិតជាខាងមុខ មិច្ឆាចេតនា (ចេតនាដែលនិយាយខុស ធ្វើខុស) របស់បុគ្គលនោះ ដោយប្រាថ្នានឹងឲ្យអ្នកដទៃយល់ខុស ជាសមុដ្ឋាននៃកាយបយោគ និងវចីបយោគ ដែលធ្វើឲ្យអ្នកដទៃយល់ខុស ប្រព្រឹត្តទៅផ្លូវកាយទ្វារ និងវចីទ្វារ ទ្វារណាមួយ ឈ្មោះថា **មុសាវាទ** ។

ក្នុងបទថា **សុរាមេរយមជ្ជប្បមាទដ្ឋាន** (ការសេពគ្រឿងស្រវឹង គឺ សុរា និងមេរ័យ ដែលជាទីតាំងនៃសេចក្ដីប្រមាទ) នេះ ពាក្យថា **សុរា** (ស្រា) បានដល់ សុរា ៥ យ៉ាង គឺ សុរាធ្វើដោយម្សៅ សុរាធ្វើដោយនំ សុរាធ្វើដោយបាយ សុរាផ្សំដោយឈើ សុរាដែលគេផ្សំដោយគ្រឿង

ផ្សំផ្សេងៗ ។

សុរា **មេរ័យ** ក៏មាន ៥ យ៉ាង គឺ មេរ័យដែលធ្វើដោយផ្កាឈើ មេរ័យធ្វើដោយផ្លែឈើ មេរ័យធ្វើដោយទឹកអំពៅ មេរ័យធ្វើដោយទឹកឃ្មុំ មេរ័យដែលផ្សំដោយគ្រឿងផ្សំ ។ បទថា **មជ្ជំ (របស់ស្រវឹង)** បានដល់ទាំង ២ យ៉ាងនោះឯង ឈ្មោះថា **របស់ស្រវឹង** ព្រោះអត្ថថា ជាទីតាំងនៃសេចក្ដីស្រវឹង ។ ឬក៏វត្ថុណា មិនថាជាអ្វី ជាទីតាំងនៃសេចក្ដីស្រវឹង បុគ្គលស្រវឹងប្រមាទដោយវត្ថុណាដែលផឹកហើយ វត្ថុនេះក៏ហៅថា **មជ្ជៈ** ។ បទថា **បមាទដ្ឋានំ (ជាទីតាំងនៃសេចក្ដីប្រមាទ)** បានដល់ ចេតនាដែលផឹកគ្រឿងស្រវឹងនោះ លោកហៅថា **ជាទីតាំងនៃសេចក្ដីប្រមាទ** ព្រោះជាហេតុនៃសេចក្ដីស្រវឹង និងសេចក្ដីប្រមាទ ចេតនាផឹកនូវទឹកស្រវឹង គឺសុរា និងមេរ័យ ប្រព្រឹត្តតាមកាយទ្វារ ដោយបំណងនឹងផឹក គប្បីជ្រាបថា **សុរាមេរយមជ្ជប្បមាទដ្ឋាន** ដោយប្រការណា គប្បីជ្រាបវិនិច្ឆ័យក្នុងសិក្ខាបទទាំងនោះមុន រាប់តាំងអំពីបាណាតិបាតជាដើម ដោយប្រការដូច្នេះ ។

## វិនិច្ឆ័យសិក្ខាបទដូចគ្នា និងផ្សេងគ្នាជាដើម

ក្នុងបទថា **ឯកតានានតាទិតោ (ដោយសិក្ខាបទដែលដូចគ្នា និងផ្សេងគ្នាជាដើម)** នេះ អ្នកជំទាស់ពោលថា "បាណាតិបាត ឬសិក្ខាបទដទៃ មានអទិន្នាទានជាដើមដូចគ្នា ព្រោះបុគ្គលនឹងត្រូវសម្លាប់ បុគ្គលអ្នកសម្លាប់ ប្រយោគ (សេចក្តីព្យាយាម) និងចេតនាជាដើមដូចគ្នា ឬបាណាតិបាត ឬ សិក្ខាបទដទៃ មានអទិន្នាទានជាដើមផ្សេងគ្នា ព្រោះមានអ្នកត្រូវសម្លាប់ ជាដើមផ្សេងគ្នា ឬថា មិនមែនទាំង ២ យ៉ាង" ។ ក៏ព្រោះហេតុអ្វី អ្នក ដែលជំទាស់ទើបពោលពាក្យនេះ ប្រសិនបើសិក្ខាបទដូចគ្នា ព្រោះអ្នកនឹង ត្រូវសម្លាប់ជាដើមជាមនុស្សតែម្នាក់សោត បើដូច្នោះ កាលណា អ្នកសម្លាប់ ច្រើននាក់ សម្លាប់អ្នកដែលនឹងត្រូវសម្លាប់តែម្នាក់ ឬអ្នកសម្លាប់ម្នាក់ សម្លាប់ មនុស្សដែលគប្បីសម្លាប់ច្រើននាក់ ក៏នឹងត្រូវសម្លាប់ឲ្យស្លាប់ដោយប្រយោគ តែមួយ មានសាហត្ថិកប្បយោគជាដើម ។ ឬចេតនាតែមួយ ក៏នឹងញុំាង ប្រយោគរបស់អ្នកចូលទៅផ្តាច់ជីវិតិន្ទ្រីយ៍ របស់អ្នកដែលនឹងត្រូវសម្លាប់ច្រើន នាក់ ឲ្យតាំងឡើង (កើត) កាលនោះ បាណាតិបាតក៏គប្បីមានតែម្យ៉ាង ។

ប៉ុន្តែថា សិក្ខាបទនឹងផ្សេងគ្នា ព្រោះអ្នកដែលនឹងត្រូវសម្លាប់ជាដើមផ្សេង គ្នា ដូច្នោះ កាលណាអ្នកសម្លាប់ម្នាក់ កាលធ្វើប្រយោគតែមួយ ដើម្បីមនុស្ស ម្នាក់ៗ ក៏រមែងសម្លាប់មនុស្សដែលគប្បីសម្លាប់ច្រើននាក់ ឬសម្លាប់មនុស្ស ច្រើននាក់ កាលធ្វើច្រើនប្រយោគដើម្បីមនុស្សច្រើននាក់ មានទេវទត្ត យញ្ញ-ទត្ត និងសោមទត្តជាដើម ក៏រមែងសម្លាប់បានចំពោះ ទេវទត្ត យញ្ញទត្ត និងសោមទត្តតែម្នាក់ប៉ុណ្ណោះ ឬអ្នកដែលនឹងត្រូវសម្លាប់ម្នាក់ ត្រូវអ្នកសម្លាប់ សម្លាប់ច្រើនប្រយោគ មានសាហត្ថិកប្បយោគជាដើម ។ មួយវិញទៀត បេតនាច្រើន ក៏នឹងញុំាងប្រយោគរបស់អ្នកចូលទៅផ្តាច់ជីវិតិន្ទ្រិយ៍របស់អ្នក ដែលនឹងត្រូវសម្លាប់តែម្នាក់ប៉ុណ្ណោះឲ្យកើតឡើង កាលនោះ បាណាតិបាត ក៏នឹងគប្បីមានច្រើនយ៉ាង ។ សូម្បីពាក្យទាំងពីរនោះ ក៏មិនត្រូវ ។ សិក្ខាបទ នឹងឈ្មោះថា ដូចគ្នា ព្រោះអ្នកដែលនឹងត្រូវសម្លាប់ជាដើមទាំងនោះ មាន តែម្នាក់ ក៏មិនមែន ។ សិក្ខាបទឈ្មោះថា ផ្សេងគ្នា ព្រោះអ្នកដែលនឹង ត្រូវសម្លាប់ទាំងនោះផ្សេងគ្នា ក៏មិនមែន ការពិត សិក្ខាបទដូចគ្នា និងផ្សេង គ្នា ក៏ដោយហេតុយ៉ាងដទៃ ពាក្យនោះគប្បីប្រើដល់បាណាតិបាត សូម្បី

សិក្ខាបទក្រៅពីនោះ ក៏គប្បីប្រើដូច្នោះ ។

ខ្ញុំសូមអធិប្បាយតទៅនេះ ៖ ជាដំបូង បាណាតិបាតនោះឈ្មោះថា ដូចគ្នា ព្រោះអ្នកដែលនឹងត្រូវសម្លាប់ និងអ្នកស្លាប់ជាដើមដូចគ្នា ឈ្មោះថា ផ្សេងគ្នា ព្រោះអ្នកដែលនឹងត្រូវសម្លាប់ជាដើមផ្សេងគ្នា ក៏មិនមែន ការពិត បាណាតិបាតឈ្មោះថា ដូចគ្នា ព្រោះអ្នកដែលត្រូវសម្លាប់ និងអ្នកស្លាប់ ជាដើមតែមួយ ដោយចាត់ជាគូៗ គ្នា ។ ទាំងឈ្មោះថា តែមួយដូចគ្នា ព្រោះអ្នកនឹងត្រូវសម្លាប់ និងអ្នកស្លាប់ជាដើមទាំងពីរនោះ តែមួយដូចគ្នា ដោយចាត់ជាគូៗ គ្នា ឬឈ្មោះថា ផ្សេងគ្នា ព្រោះអ្នកដែលនឹងត្រូវសម្លាប់ និងអ្នកស្លាប់ជាដើមនោះ ជាមនុស្សដទៃក្រៅពីមនុស្សទាំងពីរនាក់នោះ ។

ពិតយ៉ាងនោះ កាលអ្នកសម្លាប់ច្រើននាក់ សូម្បីសម្លាប់អ្នកដែល ត្រូវសម្លាប់ច្រើននាក់ ដោយប្រយោគច្រើន មានសរក្ខេបប្រយោគ (ការ ជីកស្រះ) ជាដើម ឬដោយប្រយោគមួយៗ មានឱបាតខណនប្រយោគ (ការ ជីកអណ្តូង) ជាដើម ក៏ជាបាណាតិបាតច្រើន ។ កាលអ្នកសម្លាប់តែម្នាក់ សូម្បីសម្លាប់មនុស្សដែលត្រូវសម្លាប់ច្រើននាក់ ដោយប្រយោគតែមួយ ឬ

ច្រើនប្រយោគ ដោយចេតនាតែមួយ ញ៉ាំងប្រយោគនោះឲ្យតាំងឡើង ឬដោយច្រើនចេតនា ក៏ជាបាណាតិបាតច្រើន ។ មួយទៀត កាលអ្នកសម្លាប់ច្រើននាក់ សូម្បីសម្លាប់មនុស្សដែលត្រូវសម្លាប់តែម្នាក់ ដោយច្រើនប្រយោគតាមដែលពោលហើយ ឬដោយប្រយោគតែមួយ ក៏ជាបាណាតិបាតច្រើន ។ សូម្បីក្នុងសិក្ខាបទ មានអទិន្នាទានជាដើម ក៏ន័យនេះ ។ ក្នុងរឿងនេះគប្បីជ្រាបវិនិច្ឆ័យដោយសិក្ខាបទដូចគ្នា និងផ្សេងគ្នាជាដើម ដោយប្រការដូចពោលមក ដូច្នេះ ។

*កាលពោលដោយអារម្មណ៍* ក្នុងសេចក្តីនេះ បាណាតិបាត មានជីវិតិន្ទ្រិយ៍ជាអារម្មណ៍ ។ អទិន្នាទាន អព្រហ្មចរិយៈ និងសុរាមេរយមជ្ជប្បមាទដ្ឋាន មានសង្ខារ គឺ បណ្តារូបធម៌ មានរូបាយតនៈជាដើមណាមួយជាអារម្មណ៍ ។ មុសាវាទ មានសត្វជាអារម្មណ៍ ព្រោះប្រារព្ធអ្នកដែលត្រូវនិយាយមុសាឲ្យប្រព្រឹត្តទៅ ។ អាចារ្យពួកមួយពោលថា "សូម្បីអព្រហ្មចរិយៈ ក៏មានសត្វជាអារម្មណ៍" ។ មា៉្យងទៀត អទិន្នាទាន មានសត្វជាអារម្មណ៍ ក្នុងវេលាដែលនឹងគប្បីត្រូវលួចយកទៅ ។ ប្រការមួយ

ទៀត អទិន្នាទាន មានសត្វជាអារម្មណ៍ ក៏ដោយអំណាចសង្ខារ មិនមែនដោយអំណាចបញ្ញត្តិ ។ ក្នុងសេចក្ដីនេះ គប្បីជ្រាបវិនិច្ឆ័យដោយអារម្មណ៍ដូចពោលមកនេះ ។

**ពោលដោយសមាទាន** ក៏សិក្ខាបទទាំងនេះ មាន បាណាតិបាតាវេរមណីសិក្ខាបទ ជាដើម សាមណេរសមាទានក្នុងសម្នាក់ភិក្ខុប៉ុណ្ណោះ ទើបជាការសមាទាន ចំណែកឧបាសកសមាទានខ្លួនឯងក្ដី សមាទានក្នុងសម្នាក់របស់អ្នកដទៃក្ដី ក៏ជាការសមាទានហើយ ។ សមាទានរួមគ្នាក្ដី សមាទានដោយឡែកពីគ្នាក្ដី ក៏ជាការសមាទានហើយដូចគ្នា ។ តែផ្សេងគ្នាយ៉ាងណា ។ បុគ្គលសមាទានរួម ក៏មានវិរតិតែមួយ មានចេតនាតែមួយប៉ុណ្ណោះ តែប្រាកដថា វិរតិ និងចេតនានោះ មាន ៥ ដោយអំណាចកិច្ច (គឺនាទី) ។ ចំណែកបុគ្គលដែលសមាទានផ្សេងគ្នា ក៏គប្បីជ្រាបថា មានវិរតិ ៥ ចេតនាក៏ ៥ ។ ក្នុងប្រការនេះ គប្បីជ្រាបវិនិច្ឆ័យដោយការសមាទាន ដោយប្រការដូច្នេះ ។

**ពោលដោយការដាច់** ក្នុងសេចក្ដីនេះ ចំពោះសាមណេរទាំងឡាយ

កាលសិក្ខាបទមួយដាច់ គ្រប់សិក្ខាបទក៏ជាការដាច់ ។ ព្រោះថា សិក្ខាបទទាំងនោះ ជាទីតាំងនៃបារាជិករបស់សាមណេរទាំងនោះ ។ ព្រោះសិក្ខាបទដែលសាមណេរកន្លងល្មើសនោះឯង ក៏មានកម្មជាប់តាមមក ។

តែចំពោះគ្រហស្ថ កាលសីលប្រការណាមួយដាច់ ក៏ដាច់ត្រឹមតែមួយប៉ុណ្ណោះ ព្រោះសីលរបស់គ្រហស្ថទាំងនោះ មានអង្គ ៥ រមែងបរិបូណ៌ដោយការសមាទានសីលនោះឯង ។ តែអាចារ្យពួកមួយពោលថា "បណ្ដាសីលដែលគ្រហស្ថសមាទានមួយៗ កាលសីលណាមួយដាច់ ក៏ជាការដាច់តែមួយប៉ុណ្ណោះ" តែបណ្ដាសីលដែលគ្រហស្ថសមាទានរួមគ្នាយ៉ាងនេះថា "ខ្ញុំសូមសមាទានសីលដែលប្រកបដោយអង្គ ៥" ដូច្នេះ កាលសីលណាមួយដាច់ សីលសម្បជ៏សេសក៏ជាការដាច់ទាំងអស់ ។ ព្រោះហេតុអ្វី ។ ព្រោះការសមាទានរួមគ្នា ។ សីលដែលគ្រហស្ថគន្លងល្មើសនោះឯង ក៏មានការបង់ដោយកម្ម ។ ក្នុងសេចក្ដីនេះ គប្បីជ្រាបវិនិច្ឆ័យសូម្បីដោយការដាច់ដោយប្រការដូច្នេះ ។

ពោលដោយទោសច្រើន បណ្ដាសត្វមានជីវិត ដែលវៀរចាកគុណ

មានសត្វតិរច្ឆានជាដើម បាណាតិបាតឈ្មោះថា មានទោសតិច ក៏ព្រោះសត្វមានខ្លួនតូច ។ ឈ្មោះថា មានទោសច្រើន ក៏ព្រោះសត្វមានខ្លួនធំ ។ ព្រោះហេតុអ្វី ។ ព្រោះប្រយោគធំ (សេចក្តីព្យាយាមច្រើន) ។ សូម្បីមានប្រយោគស្មើគ្នា ឈ្មោះថា មានទោសច្រើន ព្រោះវត្ថុធំ ។ ចំណែកបណ្តាសត្វមានជីវិត ដែលមានគុណ មានមនុស្សជាដើម បាណាតិបាតឈ្មោះថា មានទោសតិច ក៏ព្រោះមនុស្សមានគុណតិច ។ ឈ្មោះថា មានទោសច្រើន ក៏ព្រោះមនុស្សមានគុណច្រើន ។ តែកាលមានខ្លួន និងគុណស្មើគ្នា ក៏គប្បីជ្រាបថា មានទោសតិច ព្រោះកិលេស និងសេចក្តីព្យាយាមតិច និងមានទោសច្រើន ព្រោះកិលេស និងសេចក្តីព្យាយាមខ្លាំងក្លា ។ សូម្បីក្នុងសិក្ខាបទដ៏សេស ក៏ន័យនេះដូចគ្នា ។ មួយទៀត ក្នុងសេចក្តីនេះ សុរាមេរយមជ្ជប្បមាទដ្ឋានប៉ុណ្ណោះ ឈ្មោះថា មានទោសច្រើន បាណាតិបាតជាដើម ឈ្មោះថា មានទោសតិច ព្រោះហេតុអ្វី ។ ព្រោះធ្វើអន្តរាយដល់អរិយធម៌ ហេតុធ្វើមនុស្សដែលកើតមកឲ្យក្លាយជាមនុស្សឆ្កួត ។ ក្នុងប្រការនេះ គប្បីជ្រាបវិនិច្ឆ័យការមានទោសច្រើន ដោយប្រការដូច្នេះ ។

ពោលដោយប្រយោគ ក្នុងសេចក្តីនេះ បាណាតិបាតមាន ៦ ប្រយោគ គឺ សាហត្ថិកប្បយោគ អាណត្តិកប្បយោគ និស្សគ្គិយប្បយោគ ថាវរប្បយោគ វិជ្ជាមយប្បយោគ ឥទ្ធិមយប្បយោគ ។

បណ្តាប្រយោគទាំងនោះ ការប្រហារដោយកាយ ឬវត្ថុដែលជាប់ដោយកាយ ឈ្មោះថា **សាហត្ថិកប្បយោគ** សាហត្ថកប្បយោគនោះ ចែកជា ២ គឺ សាហត្ថិកប្បយោគចំពោះ និងសាហត្ថិកប្បយោគមិនចំពោះ ។ ក្នុងសាហត្ថិកប្បយោគទាំងពីរនោះ បុគ្គលរមែងត្រូវចងដោយកម្ម ព្រោះការស្លាប់របស់មនុស្សដែលគេប្រហារដោយចំពោះប៉ុណ្ណោះ ។ ក្នុងសាហត្ថិកប្បយោគមិនចំពោះ យ៉ាងនេះថា នរណាមួយចូរស្លាប់ទៅចុះ ដូច្នេះ បុគ្គលរមែងត្រូវចំណងដោយកម្ម ព្រោះសេចក្តីស្លាប់របស់មនុស្សណាមួយហេតុព្រោះការប្រហារជាបច្ច័យ ។ មួយទៀត សូម្បីដោយសាហត្ថិកប្បយោគទាំងពីរ ពេលគេត្រូវប្រហារក៏ស្លាប់ ឬស្លាប់ដោយរោគនោះក្នុងកាលជាខាងក្រោយ បុគ្គលក៏រមែងត្រូវចងដោយកម្ម ខណៈដែលគេត្រូវប្រហារប៉ុណ្ណោះ ។ តែកាលបុគ្គលប្រហារដោយបំណងនឹងឲ្យគេស្លាប់ តែគេមិន

ស្លាប់ដោយការប្រហារនោះ ត្រឡប់គិតប្រហារម្តងទៀត ប្រសិនបើសូម្បី ក្នុងខាងក្រោយ គេស្លាប់ដោយការប្រហារគ្រាដំបូង បុគ្គលនោះ ក៏រមែង ត្រូវជាប់ដោយកម្មក្នុងវេលានោះប៉ុណ្ណោះ ។ ប្រសិនបើ គេស្លាប់ដោយការ ប្រហារលើកទី ២ ក៏មិនជាបាណាតិបាត ។ សូម្បីកាលគេស្លាប់ដោយ សាហត្ថិកប្បយោគទាំង ២ បុគ្គលក៏រមែងជាប់កម្ម ដោយការប្រហារគ្រា ដំបូងប៉ុណ្ណោះ កាលគេមិនស្លាប់ សូម្បីដោយសាហត្ថិកប្បយោគទាំង ២ ក៏មិនជាបាណាតិបាតឡើយ ។ ក្នុងប្រការដែលមានមនុស្សច្រើននាក់ ប្រហារ មនុស្សម្នាក់ ក៏ន័យនេះ ។ ក្នុងសេចក្តីនោះ ការដែលត្រូវជាប់ដោយកម្ម រមែងមានដល់អ្នកដែលប្រហារគេឲ្យស្លាប់ប៉ុណ្ណោះ ។

ការតាំងចិត្តបញ្ជាឲ្យគេធ្វើ ឈ្មោះថា **អាណត្តិកប្បយោគ** សូម្បី ក្នុងអាណត្តិកប្បយោគនោះ ក៏គប្បីជ្រាបការចងដោយកម្ម ដោយន័យដែល ពោលទុកក្នុងសាហត្ថិកប្បយោគនោះឯង ។ ក៏ក្នុងអាណត្តិកប្បយោគនោះ គប្បីជ្រាបថា មានកំណត់ទុក ៦ យ៉ាង ៖

អាណត្តិកប្រយោគកំណត់ទុក ៦ យ៉ាងទាំងនេះ គឺ

***វត្ថុ ១ កាល ១ ឱកាស ១ អាវុធ ១ ឥរិយាបថ ១ កិរិយាវិសេស ១ ។***

*ក្នុងការកំណត់ ៦ នោះ សត្វមានជីវិត គប្បីចាំទុកថា **វត្ថុ** ។ វេលាព្រឹក វេលាល្ងាចជាដើម និងវេលាកម្លោះ ក្រមុំ វេលាចំទ្បើង ជាដើម ក៏គប្បីចាំទុកថា **កាល** ។ គាម និគម ព្រៃ ប្រកចូល ឬផ្លូវបែក ដូចពោលមកនេះជាដើម គប្បីចាំទុកថា **ឱកាស** ។ គ្រឿងប្រហារជាដើម យ៉ាងនេះ គឺ ដាវ ធ្នូ ឬលំពែង គប្បីចាំទុកថា **អាវុធ** ។ កិរិយាឈរ ឬអង្គុយរបស់អ្នកដែលត្រូវសម្លាប់ និងអ្នកស្លាប់ ដូចពោលមកនេះជាដើម គប្បីចាំទុកថា **ឥរិយាបថ** ។ ការចាក់ ការកាត់ ការធ្វើឲ្យដាច់ ឬការដកសក់ ដូចដែលពោលមកនេះជាដើម គប្បីចាំទុកថា **កិរិយាវិសេស** ។ ប្រសិនបើអ្នកដែលត្រូវគេបញ្ជាឲ្យសម្លាប់អ្នកណា ធ្វើវត្ថុនោះឲ្យឃ្លៀងឃ្លាត (សម្លាប់មនុស្សខុស) ទៅសម្លាប់មនុស្សដទៃក្រៅអំពីអ្នកនោះ អ្នកបញ្ជាក៏មិនត្រូវជាប់ដោយកម្ម ។ បើគេមិនធ្វើវត្ថុឲ្យឃ្លៀងឃ្លាត (សម្លាប់មិនខុសមនុស្ស) សូម្បីទាំង ២ នាក់ ក៏ត្រូវជាប់ដោយកម្ម គឺ អ្នកបញ្ជាក្នុង*

ខណៈបញ្ហា អ្នកទទួលបញ្ហាក្នុងខណៈសម្លាប់ ។ សូម្បីក្នុងការកំណត់ដទៃៗ មានកាលជាដើម ក៏ន័យនេះ ។

ក៏ការពួយគ្រឿងប្រហារដោយកាយ ឬរបស់ដែលជាប់ដោយកាយ ដើម្បីធ្វើឲ្យគេស្លាប់ ឈ្មោះថា **និស្សគ្គិយប្បយោគ** ។ សូម្បីនិស្សគ្គិយ-ប្បយោគនោះ ក៏ចែកជា ២ ដូចគ្នា គឺ និស្សគ្គិយប្បយោគចំពោះ និង និស្សគ្គិយប្បយោគមិនចំពោះ ក្នុងសេចក្ដីនេះ ការជាប់ដោយកម្ម ក៏គប្បីជ្រាបតាមន័យដែលពោលមកហើយក្នុងប្រការខាងដើមៗ នោះឯង ។

ការជីកអន្លង់ ការដាក់អន្ទាក់ ការដាក់ថ្នាំពិស និងការប្រើគ្រឿងយន្តជាដើម ដើម្បីធ្វើឲ្យគេស្លាប់ ឈ្មោះថា **ថាវរប្បយោគ** ។ សូម្បីថាវរប្បយោគនោះ ក៏ចែកជា ២ គឺ ថាវរប្បយោគចំពោះ និងថាវរប្ប-យោគមិនចំពោះ ។ ក៏ក្នុងសេចក្ដីនេះ ការត្រូវចងដោយកម្ម គប្បីជ្រាបតាមន័យដែលពោលមកហើយក្នុងប្រការដើមៗ ។ តែសេចក្ដីប្លែកគ្នា មានដូច្នេះ កាលអ្នកស្វែងរកមើមជំឡូង ធ្វើអន្លង់ជាដើមរាក់ៗ ឬធ្វើអន្លង់ទទេក្ដីរបស់អ្នកដទៃៗ បើថា គេស្លាប់ព្រោះអន្លង់ជាដើមនោះ ជាបច្ច័យ ការ

ជាប់ដោយកម្ម ក៏មានដល់អ្នករកមើមដំឡូងនោះ ។ មួយទៀត កាលអ្នកនោះ ឬអ្នកដទៃលប់អន្លង់នេះចេញហើយ ធ្វើផ្ទៃឲ្យរាប អ្នកបោសធូលីបោសទៅ ឬអ្នកជីកដំឡូង ជីកដំឡូងធ្វើឲ្យជ្រៅ ឬកាលភ្លៀងធ្លាក់ចុះមកកើតជារណ្ដៅភក់ មនុស្សធ្លាក់ចុះទៅជាប់ស្លាប់ក្នុងរណ្ដៅភក់នោះ ការជាប់ដោយកម្ម ក៏មានដល់អ្នករកដំឡូងនោះឯង ។ ក៏បើថា អ្នកដែលរកដំឡូង ឬអ្នកដទៃ ធ្វើអន្លង់នោះឲ្យធំ ឬជ្រៅជាដើម អ្នកធ្លាក់ចុះទៅស្លាប់ព្រោះរណ្ដៅធំ ឬជ្រៅនោះ ការជាប់ដោយកម្ម ក៏មានដល់អ្នកទាំងពីរ ។ ដូចយ៉ាងថា មូលហេតុទាំងឡាយ រមែងប្រៀបធៀបគ្នាបានជាមួយការជីកដំឡូងយ៉ាងណា កាលមនុស្សលប់អន្លង់ឲ្យរាបស្មើក្នុងទីនោះ ។ មនុស្សក៏ផុតពីការធ្លាក់អន្លង់ ក៏ដូច្នោះ ។ សូម្បីក្នុងថាវរប្បយោគ មានការដាក់ក្ដារបន្ទះជាដើម ក៏ដូច្នោះដូចគ្នា ការជាប់ដោយកម្ម តាមហេតុដែលកើត ក៏គប្បីជ្រាបដរាបស្មើនឹងថាវរប្បយោគទាំងនោះនៅប្រព្រឹត្តទៅ ។

ការរាយវិជ្ជាគមដើម្បីធ្វើឲ្យស្លាប់ ឈ្មោះថា **វិជ្ជាមយប្បយោគ** ។

ការធ្វើឫទ្ធិផ្សេងៗ ដែលកើតអំពីវិបាកកម្ម ដើម្បីឲ្យគេស្លាប់ ដូច

ប្រើអាវុធ គឺ ចង្កូមជាដើម ខាំដោយចង្កូមជាដើម ឈ្មោះថា **ឥទ្ធិមយប្បយោគ** ។ ចំណែកអទិន្នាទានក៏មានប្រយោគ គឺ សាហត្ថិកប្បយោគ និងអាណត្តិកប្បយោគជាដើម ដែលប្រព្រឹត្តទៅដោយអំណាច ថេយ្យាវហារ បសយ្ហាវហារ បដិច្ឆន្នាវហារ បរិកប្បាវហារ និងកុសាវហារ ប្រភេទនៃប្រយោគសូម្បីទាំងនោះ ក៏គប្បីជ្រាបដោយទំនងដែលពោលមកហើយនោះឯង ។ សិក្ខាបទសូម្បីទាំង ៣ មានអព្រហ្មចរិយៈជាដើម ក៏បានចំពោះតែសាហត្ថិកប្បយោគតែម្យ៉ាង ។ ក្នុងសេចក្តីនេះ គប្បីជ្រាបវិនិច្ឆ័យសូម្បីដោយប្រយោគ ដោយប្រការដូចពោលមកនេះ ។

ពោលដោយអង្គ ក្នុងសេចក្តីនេះថា ៖

បាណាតិបាត មានអង្គ ៥ គឺ ៖

១.បាណោ សត្វមានជីវិត

២.បាណសញ្ញី សំគាល់ថាសត្វមានជីវិត

៣.វធកចិត្តំ ចិត្តគិតនឹងសម្លាប់

៤.វាយមតិ ព្យាយាម

៥.តេន មរតិ          សត្វស្លាប់ដោយសេចក្តីព្យាយាមនោះ

សុរាបានក្នុងអទិន្នាទាន ក៏មានអង្គ ៥ ដូចគ្នា គឺ ៖

១.បរិបរិគ្គហិតំ          របស់មានម្ចាស់គេហួងហែង

២.បរបរិគ្គហិតសញ្ញី   សម្គាល់ថារបស់មានម្ចាស់គេហួងហែង

៣.ថេយ្យចិត្តំ          មានចិត្តគិតនឹងលួច

៤.វាយមតិ          ព្យាយាម

៥.តេន អាទាតព្វំ អាទានំ គច្ឆតិ លួចរបស់បានមកដោយសេចក្តីព្យាយាមនោះ ។

ចំណែកអព្រហ្មចរិយៈ មានអង្គ ៤ គឺ ៖

១.អជ្ឈាចរិយវត្ថុ          វត្ថុដែលគប្បីគន្ធងល្មើស

២.សេវនចិត្តំ          ចិត្តគិតនឹងសេព

៣.បយោគំ សមាបជ្ជតិ ព្យាយាមចូលដល់

៤.សាទិយតិ          ត្រេកអរ ។

មុសាវាទ ក៏មានអង្គ ៤ ដូចគ្នា គឺ ៖

១.មុសា កុហក

២.វិសំវាទនចិត្តំ ចិត្តគិតនឹងនិយាយកុហក

៣.វាយាមោ ព្យាយាម

៤.បរវិសំវាទនំ និយាយកុហកចំពោះអ្នកដទៃ និងគេដឹងរឿង កុហក ។

សុរាមេរយមជ្ជប្បមាទដ្ឋាន ក៏មានអង្គ ៤ គឺ ៖

១.សុរាទីនំ អញ្ញតរំ របស់ស្រវឹងមានសុរាជាដើមណាមួយ

២.មទនីយបាតុកម្យតាចិត្តំ ចិត្តគិតប្រាថ្នានឹងផឹករបស់ស្រវឹង

៣.តជ្ជំ វាយាមំ អាបជ្ជតិ សេចក្តីព្យាយាមកើតដល់ចិត្តនោះ

៤.បីតេ ច បវិសតិ ផឹកចូលទៅក្នុងបំពង់ក ។

ក្នុងសេចក្តីនេះ គប្បីជ្រាបវិនិច្ឆ័យដោយអង្គ ដោយប្រការដូចបាន ពោលមកដូច្នេះ ។

ពោលដោយសមុដ្ឋាន បាណាតិបាត អទិន្នាទាន និងមុសាវាទ មាន សមុដ្ឋាន ៣ គឺ ១-កាយនឹងចិត្ត ២.វាចានឹងចិត្ត ៣.កាយវាចានឹងចិត្ត ។

អព្រហ្មចរិយៈ មានសមុដ្ឋាន ១ គឺ កាយជាមួយចិត្ត ។ សុរាមេរយ-មជ្ជប្បមាទដ្ឋាន មានសមុដ្ឋាន ២ គឺ កាយ និងកាយនឹងចិត្ត ។ ក្នុងសេចក្តីនេះ គប្បីជ្រាបវិនិច្ឆ័យដោយសមុដ្ឋាន ដោយប្រការដូចពោលមកដូច្នេះ ។

*ពោលដោយវេទនា* បាណាតិបាត ប្រកបដោយទុក្ខវេទនា ។ អទិន្នាទាន ប្រកបដោយវេទនា ៣ យ៉ាងណាមួយ មុសាវាទក៏ដូចគ្នា ។ ២ សិក្ខាបទទៀតក្រៅពីនេះ ប្រកបដោយសុខវេទនា និងអទុក្ខមសុខវេទនា ។ គប្បីជ្រាបវិនិច្ឆ័យសូម្បីដោយវេទនា ដោយប្រការដូចពោលមកដូច្នេះ ។

*ពោលដោយមូល* បាណាតិបាត មានទោសៈ និងមោហៈជាមូល ។ អទិន្នាទាន និងមុសាវាទ មានលោភៈ និងមោហៈជាមូលខ្លះ មានទោសៈ និងមោហៈជាមូលខ្លះ ។ ២ សិក្ខាបទទៀតក្រៅពីនេះ មានលោភៈ និងមោហៈជាមូល ។ គប្បីជ្រាបវិនិច្ឆ័យដោយមូល ដោយប្រការដូចដែលពោលមកដូច្នេះ ។

*ពោលដោយកម្ម* បាណាតិបាត អទិន្នាទាន និងអព្រហ្មចរិយៈ ជា

កាយកម្ម និងជាកម្មបថ ។ មុសាវាទ ជាវចីកម្មតែម្យ៉ាង ។ (មុសាវាទ) ជាឫសគល់នៃប្រយោជន៍ ក៏ជាកម្មបថ មុសាវាទក្រៅពីនេះជាកម្មតែម្យ៉ាង ។ សុរាមេរយមជ្ជប្បមាទដ្ឋាន ជាកាយកម្មតែម្យ៉ាង ។ គប្បីជ្រាបវិនិច្ឆ័យសូម្បីដោយកម្ម ដោយប្រការដូចពោលមកដូច្នេះ ។

**ពោលវិរតិ** ក្នុងសេចក្តីនេះ អាចារ្យអ្នកជំទាស់ខ្លះពោលថា "បុគ្គលវៀរចាកបាណាតិបាតជាដើម វៀរចាកពេលណា" ។ នឹងអធិប្បាយដូច្នេះជាដំបូង បុគ្គលកាលវៀរចាកដោយសមាទានវិរតិ រមែងវៀរចាកអកុសល-កម្ម មានបាណាតិបាតជាដើមរបស់ខ្លួនឯង ឬរបស់អ្នកដទៃៗ ។ ប្រារព្ធអ្វី ។ ក៏ប្រារព្ធអារម្មណ៍នៃអកុសលកម្ម មានបាណាតិបាតជាដើម តាមដែលបានពោលហើយ ។ តែអាចារ្យពួកខ្លះពោលថា "បុគ្គលប្រារព្ធសង្ខារទាំងឡាយ ដែលរាប់បានថា ទឹកស្រវឹង គឺ សុរា និងមេរ័យ ទើបវៀរចាកទីតាំងនៃសេចក្តីប្រមាទ គឺ ការផឹកទឹកស្រវឹង គឺ សុរា និងមេរ័យ បុគ្គលប្រារព្ធបណ្តាសត្វ និងសង្ខារ ចំពោះដែលខ្លួនគប្បីលួច និងដកឫសគល់ ទើបវៀរចាកអទិន្នាទាន និងមុសាវាទ ប្រារព្ធសត្វតែម្យ៉ាង ទើបវៀរ

ចាកបាណាតិបាត និងអព្រហ្មចរិយៈ” ។ អាចារ្យក្រៅពីនោះ មានការ
ឃើញយ៉ាងនេះថា បើដូច្នោះ បុគ្គលកាលគិតយ៉ាង ក៏ធ្វើយ៉ាង លះបង់
វត្ថុណា ក៏មិនដឹងវត្ថុនោះ ដូច្នេះ កាលមិនត្រូវការ (យ៉ាងនោះ) ទើប
ពោលថា បុគ្គលលះបង់វត្ថុណា ក៏ប្រារព្ធវត្ថុនោះ គឺ អកុសលកម្ម មាន
បាណាតិបាតជាដើម របស់ខ្លួននោះឯង ទើបវៀរ” ។ ពាក្យនោះមិនត្រឹម
ត្រូវ ។ ព្រោះហេតុអ្វី ។ ព្រោះវត្ថុនោះ មិនមានអារម្មណ៍បច្ចុប្បន្ន និង
មិនមានអារម្មណ៍ខាងក្រៅ ។ ពិតហើយ ក្នុងបាលីវិភង្គនៃសិក្ខាបទទាំង
ឡាយ លោកសួរថា សិក្ខាបទទាំង ៥ ជា កុសលប៉ុន្មាន ។ល។ ជា
អរណៈ (សត្រូវ) ប៉ុន្មាន ។ ក្នុងការឆ្លើយបញ្ហាដែលប្រព្រឹត្តទៅយ៉ាងនេះ
ថា កុសលទាំងឡាយ ប្រកបដោយសុខវេទនាក៏មាន ដូច្នេះ ទើបពោល
ដល់សភាពនៃធម៌មានអារម្មណ៍ជាបច្ចុប្បន្ន និងមានអារម្មណ៍ខាងក្រៅយ៉ាង
នេះថា “មានអារម្មណ៍ជាបច្ចុប្បន្ន មានអារម្មណ៍ខាងក្រៅ” ។ ពាក្យនោះ
រមែងមិនត្រឹមត្រូវសម្រាប់បុគ្គលដែលប្រារព្ធអកុសលធម៌ មានបាណាតិបាត
ជាដើមរបស់ខ្លួនហើយវៀរ ។ ក្នុងពាក្យដែលថា បុគ្គលគិតយ៉ាង ធ្វើយ៉ាង

និងលះបង់វត្ថុណា ក៏មិនដឹងវត្ថុនោះ សូមអធិប្បាយដូច្នេះ បុគ្គលកំពុងបដិបត្តិដោយធ្វើកិច្ចឲ្យសម្រេច នរណានឹងពោលថា គិតម្យ៉ាង ធ្វើម្យ៉ាង ឬថា លះបង់វត្ថុណា មិនដឹងវត្ថុនោះ ដូច្នេះ រមែងមិនមាន ។

ព្រះអរិយបុគ្គលដែលតាំងនៅមគ្គ ប្រារព្ធអមតធម៌ ក៏លះបាបធម៌បានអស់ ជាឧទាហរណ៍ក្នុងសេចក្តីនេះ ។

គប្បីវិនិច្ឆ័យសូម្បីដោយវិរតិ ដោយប្រការដូចពោលមកនេះ ។

ពោលដោយផល បាបធម៌ មានបាណាតិបាតជាដើមទាំងអស់នេះ រមែងឲ្យកើតផល គឺ ទុគ្គតិ និងឲ្យកើតវិបាកដែលមិនគួរប្រាថ្នា មិនគួររីករាយ មិនគួរពេញចិត្ត ក្នុងសុគតិ ទាំងឲ្យកើតផលមានសេចក្តីមិនក្សៀវ-ក្សាជាដើម ក្នុងចំណែកខាងមុខ និងបច្ចុប្បន្ន ។ ម្យ៉ាងទៀត ក្នុងសេចក្តីនេះ គប្បីជ្រាបវិនិច្ឆ័យសូម្បីដោយផល តាមន័យជាដើមយ៉ាងនេះថា វិបាករបស់បាណាតិបាតយ៉ាងស្រាលបំផុត កាលកើតមកជាមនុស្ស ក៏ធ្វើឲ្យមានអាយុខ្លី ។

ន័យម្យ៉ាងទៀត ក្នុងសេចក្តីនេះ ក៏គប្បីជ្រាបវិនិច្ឆ័យសូម្បីដោយ

សមុដ្ឋាន វេទនា មូល កម្ម និងផល របស់ចេតនាវៀរចាកបាណាតិបាត ជាដើម ។ ក្នុងចេតនាវៀរនោះ គប្បីយល់ដូច្នេះ ។ វេរមណី (ចេតនាវៀរចាក) ទាំងអស់នេះ តាំងឡើងដោយសមុដ្ឋាន ៤ គឺ កាយ , កាយនិងចិត្ត , វាចា និងចិត្ត , កាយវាចា និងចិត្ត ។ ទាំងអស់នោះឯង ប្រកបដោយសុខវេទនាក៏មាន ប្រកបដោយអទុក្ខមសុខវេទនាក៏មាន មានអលោភៈ អទោសៈក៏មាន មានអលោភៈ អទោសៈ និងអមោហៈក៏មាន ក្នុងប្រការនេះ វេរមណីសូម្បីទាំង ៤ ជាកាយកម្ម មុសាវាទវេរមណីជាវចីកម្ម តែក៏កើតឡើងអំពីចិត្ត ។ ក្នុងខណៈមគ្គចិត្ត សូម្បីវេរមណីទាំងពួង ក៏ជាមនោកម្ម ។

*ចេតនាវៀរចាកការសម្លាប់សត្វ* មានផលជាដើមយ៉ាងនេះ គឺ ការមានអវយវៈតូចធំបរិបូណ៌ សម្បត្តិ គឺ កាពខ្ពង់ខ្ពស់ សម្បត្តិ គឺ បញ្ញាវាងវៃ មានបាតជើងតាំងនៅស៊ប់ល្អ មានកាពស្រស់ល្អ ទន់ភ្លន់ ស្អាតក្លាហាន មានកម្លាំងខ្លាំង មានវាចាពីរោះ ជាទីស្រឡាញ់របស់ពពួកជនមានវាចាមិនមានទោស មានបរិស័ទមិនបែកគ្នា មានសេចក្តីអង់អាច មាន

ការដល់ព្រមដោយរូប ភាពជាអ្នកមិនស្ដាប់ព្រោះសត្រូវ ភាពជាអ្នកមានបរិវារច្រើន ភាពជាអ្នកមានរូបស្រស់ស្អាត ភាពជាអ្នកមានទ្រង់ទ្រាយល្អ មានរោគតិច មិនសៅហ្មង មិនព្រាត់ប្រាសចាកសត្វសង្ខារដែលជាទីស្រឡាញ់ពេញចិត្ត មានអាយុវែង ។

ចេតនាវៀរចាកការកាន់យករបស់ដែលម្ចាស់គេមិនបានឲ្យ មានផលជាដើមយ៉ាងនេះ គឺ ស្ដុកស្ដមដោយសម្បត្តិទ្រព្យ ស្ដុកស្ដមដោយធញ្ញ-ទ្រព្យ ស្ដុកស្ដមដោយភោគទ្រព្យ កើតឡើងនៅភោគទ្រព្យដែលមិននៅមិនទាន់កើតឡើង មានថាវរៈស្ថិតស្ថេរនៃភោគទ្រព្យដែលកើតឡើងហើយបានភោគទ្រព្យយ៉ាងឆាប់រហ័សតាមសេចក្ដីប្រាថ្នា មានភោគទ្រព្យមិនត្រូវបែងចែកដោយភ័យ គឺ ព្រះរាជា ចោរ ទឹក ភ្លើង ទាយាទដែលមិនជាទីស្រឡាញ់ បានធនទ្រព្យដែលមិនជាសាធារណៈ ការបានលោកុត្តរទ្រព្យការមិនដឹងរម៉ែងមិនមាន ភាពនៅជាសុខ ។

ចេតនាវៀរចាកការប្រព្រឹត្តដែលមិនមែនជាព្រហ្មចរិយៈ មានផលជាដើមដូច្នេះ គឺ ការមិនមានសត្រូវ ជាទីស្រឡាញ់របស់មនុស្សគ្រប់រូប

ភាពជាអ្នកបានបាយទឹកសំពត់ទីដេកជាដើម ការដេកជាសុខ ការភ្ញាក់ឡើងក៏ជាសុខ ការផុតភ័យក្នុងអបាយ ជាអ្នកមិនកើតជាស្ត្រី ឬកើតជាមនុស្សមិនមានភេទ មិនក្រោធ ការធ្វើដោយសេចក្តីគោរព ធ្វើដោយរៀបរយមានភាពសង្ហារ មានអំណាច ជាទីស្រឡាញ់គ្រប់គ្នានៃស្ត្រី និងបុរសមានឥន្ទ្រីយ៍បរិបូណ៌ មានលក្ខណៈបរិបូណ៌ មិនមានសេចក្តីសង្ស័យ ភាពជាអ្នកខ្វល់ខ្វាយតិច ភាពនៅជាសុខ ការមិនមានភ័យក្នុងទីណា ការមិនមានសេចក្តីព្រាត់ប្រាសចាកសត្វសង្ខារដែលជាទីស្រឡាញ់ពេញចិត្ត ។

ចេតនាវៀរចាកការពោលកុហក មានផលជាដើមយ៉ាងនេះ គឺ មានឥន្ទ្រីយ៍ផូរផង់ ជាអ្នកមានវាចាពីរោះទន់ភ្លន់ មានធ្មេញរាបស្មើ និងស្អាតមានរូបរាងមិនធាត់ពេក មិនស្គមពេក ការមិនទាបពេក មិនខ្ពស់ពេកមានសម្ផស្សស្រួលបាយ មាត់មានក្លិនដូចផ្កាឧប្បល មានមនុស្សជិតស្និទ្ធជឿស្តាប់បង្គាប់ មានវាចាដែលជឿកាន់យកបាន មានអណ្តាតទន់ក្រហមដូចជាផ្កាកោមុត និងឧប្បលខ្វះ មិនរាយមាយ មិនរសាប់រសល់ ។

ចេតនាវៀរចាកការសេពគ្រឿងស្រវឹង គឺ សុរាមេរ័យដែលជាទីតាំង

នៃសេចក្តីប្រមាទ មានផលជាដើមយ៉ាងនេះ គឺ ការប្តេជ្ញាបានចាប់រហ័ស ក្នុងករណីកិច្ចទាំងពួង ទាំងអតីត អនាគត និងបច្ចុប្បន្ន មានសតិតាំងមាំគ្រប់កាល មិនមែនជាមនុស្សឆ្កួត មានបញ្ញា មិនខ្ជិលច្រអូស មិនល្ងង់ខ្លៅ មិនជាអ្នកជាមនុស្សគ មិនស្រវឹង មិនប្រមាទ ការមិនវង្វេង មិនភ័យខ្លាច មិនប្រណាំងប្រជែង មិនមានសេចក្តីសង្ស័យ មិនមានសេចក្តីងឿងឆ្ងល់ ជាអ្នកនិយាយសច្ចៈ ជាអ្នកនិយាយតែវាចាមិនសឹកសៀត មិនពោលត្រគោះបោះបោក ឥតប្រយោជន៍ (រោយរាយ) ជាបុគ្គលមិនខ្ជិលច្រអូសទាំងថ្ងៃទាំងយប់ ជាអ្នកមានកតញ្ញូ មានកតវេទី មិនកំណាញ់ មានការលះបង់ មានសីល ភាពជាមនុស្សត្រង់ មិនមានសេចក្តីក្រោធ មានហិរិ មានឱត្តប្បៈ មានបញ្ញាច្រើន មានការចេះដឹង ភាពជាបណ្ឌិត ជាអ្នកឆ្លាតក្នុងវត្ថុដែលជាប្រយោជន៍ និងមិនជាប្រយោជន៍ ។ គប្បីជ្រាបវិនិច្ឆ័យ សូម្បីដោយសមុដ្ឋាន វេទនា មូល កម្ម និងផល នៃចេតនាជាគ្រឿងវៀរចាកបាណាតិបាតជាដើម ដោយប្រការដូចពោលមកនេះ ។

# ពណ៌នា ៥ សិក្ខាបទខាងក្រោយ

*ពាក្យដែលខ្ញុំពោលទុកថា ប្រការយុត្តិចាកពាក្យ*

*ពណ៌នា ៥ សិក្ខាបទខាងដើមនោះ គួរនាំមកប្រើក្នុង ៥*

*សិក្ខាបទក្រោយ គួរពោលជាចំណែកៗ គប្បីជ្រាបថា*

*សិក្ខាបទដែលមិនល្អជាដើម ទុកផង ។*

ឥឡូវនេះ នឹងពណ៌នាអត្ថដូចតទៅនេះ ។ បទណាក្នុងការពណ៌នា ៥ សិក្ខាបទខាងដើម រមែងយុត្តិ (ត្រឹមត្រូវ) ពាក្យនោះ គួរកាន់យកអំពីការពណ៌នានោះមកប្រកបក្នុង ៥ សិក្ខាបទខាងក្រោយ ។ ក្នុងប្រការនេះ ប្រកបសេចក្តីដូច្នេះ ។ ដូចមានសេចក្តីថា ៖

**ពោលដោយអារម្មណ៍** ក្នុងសិក្ខាបទមុនៗ សុរាមេរយមជ្ជប្បមាទដ្ឋាន មានសង្ខារ មានរូបាយតនៈជាដើមណាមួយជាអារម្មណ៍ យ៉ាងណា ក្នុងទីនេះ **វិកាលភោជនៈ** ក៏ដូច្នោះ ។ គប្បីជ្រាបការផ្សេងគ្នានៃអារម្មណ៍របស់ ៥ សិក្ខាបទខាងក្រោយគ្រប់ៗ សិក្ខាបទ ដោយន័យនេះ ។

**ពោលដោយសមាទាន** សិក្ខាបទ ៥ ខាងដើម ដែលសាមណេរ ឬ

ឧបាសកសមាទាន រមែងជាការសមាទានហើយ យ៉ាងណា ៥ សិក្ខាបទ ក្រោយនេះ ក៏ដូច្នោះ ។

សូម្បីកាលពោលដោយអង្គ សេចក្តីផ្សេងគ្នានៃអង្គរបស់សិក្ខាបទ ៥ ខាងដើម មានបាណាតិបាតជាដើម ពោលទុកហើយក្នុងទីនោះ យ៉ាងណា សូម្បីក្នុងទីនេះក៏ដូច្នេះ ។

**វិកាលភោជនៈ មានអង្គ ៤** ១.វិកាល ២.របស់ជាយាវកាលិកៈ ៣.ការបរិភោគ ៤.ភាពមិនមែនជាមនុស្សឆ្កួត ។ គប្បីជ្រាបការចែកអង្គ របស់សិក្ខាបទសូម្បីដ៏សេស ដោយទំនងនេះចុះ ។

ម្យ៉ាងទៀត **កាលពោលដោយសមុដ្ឋាន** ក្នុងទីនេះ សុរាមេរយ-មជ្ជប្បមាទដ្ឋាន មាន ២ សមុដ្ឋាន គឺ កាយ និងកាយជាមួយចិត្ត យ៉ាង ណា ក្នុងទីនេះ វិកាលវិភោជនៈ ក៏ដូច្នោះ ។ គប្បីជ្រាបសមុដ្ឋានរបស់ សិក្ខាបទគ្រប់សិក្ខាបទ ដោយន័យនេះ ។

**កាលពោលដោយវេទនា** ក្នុងទីនេះ អទិន្នាទាន ប្រកបដោយវេទនា ៣ ណាមួយ យ៉ាងណា ក្នុងទីនេះ វិកាលភោជនៈក៏ដូច្នោះ ។ គប្បីជ្រាប

ការប្រកបព្រមដោយវេទនា របស់សិក្ខាបទគ្រប់សិក្ខាបទ ដោយន័យនេះ ។

ម្យ៉ាងទៀត (កាលពោលដោយមូល) ក្នុងទីនោះ អព្រហ្មចរិយៈ មានលោភៈ និងមោហៈជាមូល យ៉ាងណា សូម្បីក្នុងទីនេះ វិកាលភោជនៈ និង ២ សិក្ខាបទទៀត ក៏ដូច្នោះ ។ គប្បីជ្រាបសេចក្ដីផ្សេងគ្នានៃមូល របស់សិក្ខាគ្រប់សិក្ខាបទ ដោយន័យនេះ ។

ម្យ៉ាងទៀត ក្នុងទីនោះ (កាលពោលដោយកម្ម) បាណាតិបាត ជាដើម ជាកាយកម្ម យ៉ាងណា សូម្បីក្នុងទីនេះ វិកាលភោជនៈជាដើម ក៏ដូច្នោះ ។

ម្យ៉ាងទៀត ជាតរូបរជតបដិគ្គហណៈ ជាកាយកម្មក៏មាន ជាវចីកម្ម ក៏មាន ដោយបរិយាយនៃការប្រព្រឹត្តទៅ និងការកើតតាមកាយទ្វារជាដើម មិនមែនជាកម្មបថ ។

ម្យ៉ាងទៀត **កាលពោលដោយវិរតិ** ក្នុងទីនោះ បុគ្គលកាលវៀរចាក រមែងវៀរចាកអកុសល មានបាណាតិបាតជាដើមរបស់ខ្លួន ឬរបស់អ្នកដទៃ យ៉ាងណា សូម្បីក្នុងទីនេះ ក៏រមែងវៀរចាកអកុសល មានវិកាលភោជនៈ ជាដើម ក៏ដូច្នោះ ។

មយ៉ាងទៀត កាលពោលដោយភាពជាកុសល ក៏ដូចគ្នា ។ ក៏វេរមណី ៥ ខាងដើម មាន ៤ សមុដ្ឋាន គឺ កាយ កាយនិងចិត្ត វាចានិងចិត្ត និងកាយវាចានិងចិត្ត គ្រប់វេរមណីប្រកបដោយសុខវេទនាក៏មាន ប្រកបដោយអទុក្ខមសុខវេទនាក៏មាន មានអលោភៈ អទោសៈជាមូលក៏មាន មានអលោភៈ អទោសៈ អមោហៈជាមូលក៏មាន ។ ហើយគ្រប់វេរមណីឲ្យកើតផលដែលគួរប្រាថ្នាមានប្រការផ្សេងៗ យ៉ាងណា សូម្បីក្នុងទីនេះក៏ដូច្នោះ ខ្ញុំទើបពោលថា ៖

ប្រការយុត្តិចាកពណ៌នា ៥ សិក្ខាបទខាងដើមនោះ គួរនាំ
មកប្រើក្នុង ៥ សិក្ខាបទខាងក្រោយ គួរពោលសិក្ខាបទ
ជាចំណែកៗ គប្បីជ្រាបថា សិក្ខាបទដែលមិនល្អជាដើម
ទុកផង ។

គប្បីជ្រាបវិនិច្ឆ័យក្នុង ៥ សិក្ខាបទខាងក្រោយនោះ ។ ពាក្យថា វិកាលភោជនំ (ការបរិភោគអាហារក្នុងវេលាវិកាល) បានដល់ ការបរិភោគអាហារក្នុងកាលកន្លងវេលាថ្ងៃត្រង់ ។ ពិតហើយ ការបរិភោគអាហារ

កន្លងវេលាថ្ងៃត្រង់នោះ ក៏គឺ ការបរិភោគអាហារកន្លងកាលដែលព្រះមាន-ព្រះភាគទ្រង់អនុញ្ញាត ព្រោះដូច្នោះ លោកទើបពោលថា វិកាលភោជនៈ ចេតនាវៀរចាកការបរិភោគអាហារក្នុងវេលាវិកាលនោះ ។ ក្នុងពាក្យថា **នច្ចគីតវាទិតវិសូកទស្សនំ** នេះ ការរាំច្រៀងណាមួយ ឈ្មោះថា **នច្ចៈ** ។ ការច្រៀងណាមួយ ឈ្មោះថា **គីតៈ** ។ ការប្រគុំណាមួយ ឈ្មោះថា **វាទិតៈ** ។ ការមើលវត្ថុដែលជាសត្រូវ ព្រោះទម្លាយធម៌ចំណែកកុសល ដោយភាពជាបច្ច័យធ្វើឲ្យកើតកិលេស ឈ្មោះថា **វិសូកទស្សនៈ** ។ ឬការមើល ការឃើញវត្ថុដែលជាសត្រូវ ក៏ឈ្មោះថា **វិសូកទស្សនៈ** ។ ការរាំផង ការច្រៀងផង ការប្រគំផង ការមើលវត្ថុដែលជាសត្រូវផង ឈ្មោះថា **នច្ចគីតវាទិតវិសូកទស្សនៈ** ។ ក៏វិសូកទស្សនៈ ក្នុងទីនេះ គប្បីកាន់យកតាមន័យដែលត្រាស់ទុកក្នុងព្រហ្មជាលសូត្រ ។ ពិតហើយ ក្នុងព្រហ្មជាលសូត្រនោះ ព្រះមានព្រះភាគត្រាស់ទុកថា ៖

សមណព្រាហ្មណ៍ពួកមួយ បរិភោគភោជនៈ ដែលគេឲ្យ
ដោយសទ្ធា ពេញចិត្តមើលការលេងដែលជាសត្រូវបែប

នេះ គឺ រាំ ច្រៀង ប្រគំ លេងមហោស្រព ស្តាប់រឿង និទាន លេងទះដៃ លេងគោះត្រឡោក លេងវាយស្គរ លេងរបស់ស្អាតៗ ធ្វើរបស់ស្អាតៗ លេង ធ្វើគ្រាប់តាម មនុស្សចណ្ឌាល លេងឈើខ្ពស់ លេងមុខខ្មោច លេង ជល់ដំរី លេងជល់សេះ លេងជល់ក្របី លេងជល់គោ លេងជល់ពពែ លេងជល់កេះ លេងជល់មាន់ លេងជល់ សត្វទា លេងដាវដំបង លេងប្រកួតសុនខ លេងប្រដាល់ លេងចំបាប់ លេងច្បាំងគ្នា លេងសមរភូមិ លេងត្រួត ពល លេងចាត់ក្បួនទ័ព មើលកងទ័ព ដូច្នេះណាមួយ ព្រះសមណគោតម វៀរស្រឡះចាកការមើល ការលេង បែបនេះ ដូចពោលមកដូច្នេះ ។

ន័យម្យ៉ាងទៀត ការរាំ ការច្រៀង និងការប្រគំ តាមសេចក្តី ដែលពោលមកហើយប៉ុណ្ណោះ ជាសត្រូវ ឈ្មោះថា នច្ចគីតវាទិតវិសូក: ការមើលការរាំច្រៀង និងការប្រគំដែលជាសត្រូវទាំងនោះ ឈ្មោះថា នច្-

គឺតវាទិតវិសូកទស្សនៈ ចេតនាវៀរចាកការរាំ ច្រៀង និងការប្រគំដែល ជាសត្រូវនោះ ។ គួរនឹងពោលថា **ទស្សនសវនា** សូម្បីការស្តាប់ លោក ក៏ហៅថា ទស្សនៈ ដូចគ្នា ដូចការចាប់អារម្មណ៍ សូម្បីមិនមែនប្រព្រឹត្ត ទៅតាមចក្ខុទ្វារ លោកក៏ហៅថា ទស្សនៈ ក្នុងប្រយោគជាដើមយ៉ាងនេះ ថា **សោ ច ហោតិ មិច្ឆាទិដ្ឋិកោ វិបរីតទស្សនោ** (បុគ្គលនោះ រមែង ជាមិច្ឆាទិដ្ឋិ មានការឃើញវិបរិត) ។ ឯការកន្លងល្មើសក្នុងសិក្ខាបទនេះ រមែងមានដល់អ្នកដែលចូលទៅមើល ព្រោះប្រាថ្នានឹងមើលប៉ុណ្ណោះ ។ ចំណែកអ្នកដើរទៅជួប ឬឃើញចំពោះដែលមកប្រាកដ ក្នុងឱកាសដែល ឈរ អង្គុយ ដេក ក៏មានតែសេចក្តីសៅហ្មង មិនមែនកន្លងល្មើស ។ ក្នុងសិក្ខាបទនេះ ការច្រៀង សូម្បីអាស្រ័យធម៌ ក៏មិនគួរ តែធម៌ដែល អាស្រ័យការច្រៀង គប្បីជ្រាបថា គួរ ។

ផ្កាឈើជាដើម គប្បីប្រកបដោយការសៀតជាដើម តាមសមគួរ ក្នុងសិក្ខាបទនោះ ។ បទថា **មាលា** (ផ្កាឈើ) បានដល់ ផ្កាឈើប្រភេទ ណាមួយ ។ បទថា **វិលេបនៈ** (គ្រឿងលាប) បានដល់ របស់ណាមួយ

ដែលគេដាក់ទុកដើម្បីលាប ។ ក្រៅអំពីនោះ របស់ក្រអូប មានម្សៅទឹកអប់ជាដើមគ្រប់យ៉ាង ឈ្មោះថា **របស់ក្រអូប** ។ របស់ក្រអូបនោះគ្រប់យ៉ាងប្រើប្រដាប់តាក់តែង មិនគួរ តែប្រើជាថ្នាំ ក៏គួរ ។ តែរបស់ក្រអូបដែលគេនាំមកដើម្បីបូជា សម្រាប់អ្នកទទួលទុក រមែងមិនគួរដោយបរិយាយណាៗ រមែងមិនមាន (គួរទទួលដើម្បីបូជា) ។ ទីដេកដែលខុសខ្នាត លោកហៅថា **ទីដេកខ្ពស់** ។ ទីដេកជាអកប្បិយៈ និងគ្រឿងក្រាលទីដេកដែលជាអកប្បិយៈ លោកហៅថា **ទីដេកធំ** ។ ទីដេកសូម្បីទាំង ២ យ៉ាងនោះ អ្នកទទួលទុករមែងមិនគួរ មិនថាដោយបរិយាយណាៗ ។

បទថា **ជាតរូបៈ (មាស)** បានដល់ មាស ។ បទថា **រជតៈ (ប្រាក់)** បានដល់ កហាបណៈ គឺ របស់ណាៗ ដែលជាមាសកលោហៈ មាសកឈើ និងមាសកជ័រជាដើម ដែលគេប្រើផ្លាស់ប្តូរគ្នាក្នុងប្រទេសនោះៗ ។ មាស និងប្រាក់សូម្បីទាំង ២ នោះ ឈ្មោះថា **ជាតរូបរជតៈ** ។ ការទទួលយកមាស និងប្រាក់នោះ ឈ្មោះថា **បដិគ្គហៈ** ។ ការទទួលនោះ រមែងមិនគួរ មិនថាដោយបរិយាយណាៗ ។

គប្បីជ្រាបសិក្ខាបទប្រការខាងលើ ដូចពោលមកដូច្នេះចុះ ។

ទាំង ១០ សិក្ខាបទនេះ បុគ្គលសមាទានដោយឆន្ទៈ វិរិយៈ ចិត្តៈ វិមង្សាដ៏អាក្រក់ ក៏ឈ្មោះថា ហីនៈ (យ៉ាងអាក្រក់) ។ ដោយឆន្ទៈ វិរិយៈ ចិត្តៈ វិមង្សាយ៉ាងកណ្ដាល ឈ្មោះថា មជ្ឈិមៈ (កណ្ដាល) ។ ដោយឆន្ទៈ វិរិយៈ ចិត្តៈ វិមង្សាយ៉ាងប្រណីត ឈ្មោះថា បណីតៈ (យ៉ាងល្អ) ។ ន័យម្យ៉ាងទៀត សិក្ខាបទទាំង ១០ នេះ សៅហ្មង ដោយតណ្ហា ទិដ្ឋិ និងមានះ ឈ្មោះថា អាក្រក់ ។ ដែលមិនសៅហ្មង ឈ្មោះថា កណ្ដាល ។ ដែលមានបញ្ញាក្នុងសិក្ខាបទនោះៗ ឈ្មោះថា ប្រណីត ។ ន័យម្យ៉ាងទៀត សិក្ខាបទទាំងនោះ ដែលសមាទានដោយកុសលចិត្តជាញាណវិប្បយុត្ត ឈ្មោះថា អាក្រក់ ។ ដែលសមាទានដោយកុសលចិត្តដែលជាញាណសម្បយុត្ត ជាសសង្ខារិកៈ ឈ្មោះថា កណ្ដាល ។ ដែលសមាទានដោយកុសល-ចិត្តដែលជាញាណសម្បយុត្ត ជាអសង្ខារិកៈ ឈ្មោះថា ប្រណីត ។ គប្បីជ្រាបថា សិក្ខាបទមានអាក្រក់ជាដើម ដូចពោលមកដូច្នេះ ។

មាតិកាណា ខ្ញុំលើកឡើងជាបទតាំង ដើម្បីពណ៌នាបាឋៈនៃសិក្ខាបទ

ដោយគាថា ៦ គាថា ថា សិក្ខាបទនេះ នរណាពោល ពោលទុកក្នុងទីណា ពោលកាលណា ពោលព្រោះហេតុអ្វី ដូច្នេះជាដើម មាតិកានោះ ដែលខ្ញុំប្រកាសដោយអត្ថ ដោយពាក្យមានប្រមាណត្រឹមតែប៉ុណ្ណេះ ដោយប្រការដូច្នេះឯង ។

ចប់អដ្ឋកថា សិក្ខាបទ

# អដ្ឋកថា ទុត្តិសាការទី ៣

## (ពណ៌នាការសម្ព័ន្ធនៃបទ)

*គប្បីជ្រាបវិនិច្ឆ័យក្នុង ទុត្តិសាការទី ៣ ដូចតទៅនេះ ៖*

*[៣] កម្មដ្ឋាន គឺ កាយគតាសតិនេះ ដែលពួកតិរ្ថិយ៍ទាំងពួង មិនធ្លាប់ឲ្យប្រព្រឹត្តទៅហើយ វៀរការកើតឡើងនៃព្រះពុទ្ធ ដើម្បីសេចក្តីបរិសុទ្ធនៃអាសយញ្ញាណ និងដើម្បីចិត្តភាវនារបស់កុលបុត្រអ្នកមានប្រយោគដែលបរិសុទ្ធដោយសិក្ខាបទ ១០ យ៉ាងនេះ អ្នកតាំងនៅក្នុងសីល ព្រះមានព្រះភាគទ្រង់សរសើរហើយ ដោយអាការដ៏ច្រើនក្នុងព្រះសូត្រនោះៗ យ៉ាងនេះថា ៖*

*ម្នាលភិក្ខុទាំងឡាយ ធម៌មួយ ភិក្ខុចម្រើន ធ្វើឲ្យច្រើនហើយ ប្រព្រឹត្តទៅដើម្បីសង្វេគ (ការស្លុតចិត្ត) ធំ ប្រព្រឹត្តទៅដើម្បីអត្ថ (ប្រយោជន៍) ធំ ប្រព្រឹត្តទៅដើម្បីយោគក្ខេមៈ (សេចក្តីក្សេមចាកយោគៈ) ធំ ប្រព្រឹត្តទៅដើម្បីសតិសម្បជញ្ញៈ (ការរលឹកដឹងខ្លួន) ធំ ប្រព្រឹត្តទៅដើម្បីបានញាណទស្សនៈ (ការឃើញ) ប្រព្រឹត្តទៅដើម្បីទិដ្ឋធម្មសុខវិហារ (នៅជាសុខក្នុង*

បច្ចុប្បន្ន) ប្រព្រឹត្តទៅដើម្បីធ្វើឲ្យជាក់ច្បាស់វិជ្ជា វិមុត្តិ និងផល ។ ធម៌មួយ គឺ កាយគតាសតិ ដូចម្ដេច ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនបរិភោគកាយគតាសតិ ភិក្ខុទាំងនោះ ឈ្មោះថា មិនបានបរិភោគអមតៈ ភិក្ខុពួកណាបរិភោគកាយគតាសតិ ភិក្ខុពួកនោះ ឈ្មោះថា បរិភោគអមតៈ ភិក្ខុពួកណាមិនបរិភោគកាយគតាសតិ ឈ្មោះថា មិនបានបរិភោគអមតៈ ភិក្ខុដែលបរិភោគកាយគតាសតិ ឈ្មោះថា បានបរិភោគអមតៈ ភិក្ខុដែលវិនាសចាកកាយគតាសតិ ឈ្មោះថា វិនាសចាកអមតៈ ភិក្ខុដែលមិនវិនាសចាកកាយគតាសតិ ឈ្មោះថា មិនវិនាសចាកអមតៈ ភិក្ខុដែលប្រាសចាកកាយ-គតាសតិ ឈ្មោះថា ប្រាសចាកអមតៈ ភិក្ខុមិនប្រាសចាកកាយគតាសតិ ឈ្មោះថា មិនប្រាសចាកអមតៈ ។

ដូច្នេះហើយ ទ្រង់សម្ដែងកាយគតាសតិកម្មដ្ឋានទុកជាបព្វៈ ១៤ បព្វៈ គឺ អានាបានបព្វៈ ឥរិយាបថបព្វៈ ចតុសម្បជញ្ញបព្វៈ បដិកូលមនសិ-ការបព្វៈ ធាតុមនសិការបព្វៈ សីវថិកាបព្វៈ ៩ បព្វៈ ដោយន័យនេះថា

ម្នាលភិក្ខុទាំងឡាយ កាយគតាសតិ ដែលភិក្ខុចម្រើនដូចម្ដេច ធ្វើ

ឲ្យច្រើនដូចម្តេច ទើបមានផលច្រើន មានអានិសង្សច្រើន ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងធម្មវិន័យនេះ នៅព្រៃក្តី ដូច្នេះជាដើម ។

ឥឡូវនេះ និទ្ទេសនៃការចម្រើនកាយគតាសតិកម្មដ្ឋាននោះ មកដល់តាមលំដាប់ហើយ ។ ក្នុងនិទ្ទេសនោះ ខ្ញុំពោលជាវិបស្សនាទុក ៣ បព្វៈនេះ គឺ ឥរិយាបថបព្វៈ ចតុសម្បជញ្ញបព្វៈ ធាតុមនសិការបព្វៈ ពោលសីវថិកាបព្វៈទាំង ៩ ជាអាទីនវានុបស្សនា ទុកក្នុងវិបស្សនាញាណ ។ ចំណែកសមាធិភាវនាក្នុងឧទ្ធុមាតកអសុភៈជាដើម ក្នុងនិទ្ទេសនោះ ដែលគប្បីប្រាថ្នា ខ្ញុំក៏ប្រកាសទុកពិស្តារហើយក្នុងអសុភភាវនានិទ្ទេស ឯគម្ពីរវិសុទ្ធិមគ្គនោះឯង ។ ២ បព្វៈនេះ គឺ អានាបានបព្វៈ និងបដិកូលមនសិការបព្វៈ ក៏ពោលជាសមាធិទុកហើយក្នុងនិទ្ទេសនោះ ។ ក្នុង ២ បព្វៈនោះ អានាបានបព្វៈ ជាកម្មដ្ឋានមួយផ្នែកដោយពិត ជាអានាបានស្សតិ ។ ចំណែកកម្មដ្ឋាន គឺ ទ្វត្តឹសាការៈនោះ ជាបរិយាយនៃភាវនាមួយចំណែករបស់កាយគតាសតិ ដែលព្រះមានព្រះភាគទ្រង់សំដែងសង្គ្រោះខួរក្បាលទុកដោយខួរក្នុងឆ្អឹងក្នុងបាលីប្រទេសនោះៗ យ៉ាងនេះថា ៖

ម្នាលភិក្ខុទាំងឡាយ ន័យម្យ៉ាងទៀត ភិក្ខុពិចារណាឃើញកាយនេះ តាំងអំពីបាតជើងឡើងទៅ ចុះសក់ចុះមក មានស្បែកហ៊ុំព័ទ្ធដោយជុំវិញ ពេញទៅដោយរបស់មិនស្អាត មានប្រការផ្សេងៗ ថា ក្នុងកាយនេះមាន សក់ រោម ។ល។ មូត្រ ដូច្នេះ ។ ខ្ញុំផ្ដើមទុកហើយ កម្មដ្ឋាន គឺ ទ្វត្តិ-សាការៈនោះ នឹងពណ៌នាសេចក្ដីដូចតទៅនេះ ៖

បណ្ដាបទទាំងនោះ បទថា **អត្ថិ** ប្រែថា មាន ។ បទថា **ឥមស្មឹ** (នេះ) សេចក្ដីថា ដែលពោលថា តាំងអំពីបាតជើងឡើងទៅ ចុះសក់ចុះមក មានស្បែកហ៊ុំព័ទ្ធដោយជុំវិញ ពេញទៅដោយរបស់មិនស្អាត មានប្រការផ្សេងៗ ។ បទថា **កាយេ** (ក្នុងកាយ) បានដល់ ក្នុងសរីរៈ ។ ពិតហើយ សរីរៈ ហៅថា កាយ ព្រោះសន្សំរបស់មិនស្អាត ឬព្រោះជាទីចម្រើនធំ ធាត់ មានសក់ជាដើមដែលគួរខ្ពើមរអើម ហើយរោគមានជាច្រើនរយ មាន រោគភ្នែកជាដើម ។ បទថា **កេសា** ។បេ។ **មុត្តំ** (សក់ ។ល។ ទឹកមូត្រ) គឺ អាការ ៣២ មានសក់ជាដើមទាំងនេះ ក្នុងទ្វត្តិសាការៈនេះ គប្បីជ្រាប សេចក្ដីសម្ពន្ធ (ភ្ជាប់សេចក្ដី) យ៉ាងនេះថា សក់មាននៅក្នុងកាយនេះ រោម

មាននៅក្នុងកាយនេះជាដើម ។ ទ្រង់ត្រាស់អ្វីទុក ដោយទ្វត្តឹសាការកម្ម-ដ្ឋាននោះ គឺ ទ្រង់ត្រាស់ទុកថា "នរណាៗ កាលពិចារណា សូម្បីដោយអាការគ្រប់យ៉ាងក្នុងកឡេវរៈ (រាងកាយ) ទំហំមួយព្យាមនេះ គឺ មានប្រមាណប៉ុណ្ណេះ គឺ ខាងលើតាំងអំពីបាតជើងឡើងទៅ ខាងក្រោមតាំងអំពីចុងសក់ចុះមក ជណ្តប់ដោយស្បែកជុំវិញ រមែងនឹងមិនឃើញអ្វី មិនថា កែវមុក្តា កែវមណី កែវពិទូរ្យ ក្រឹស្នា ចាន់ ស្បូវក្លាំង ការបូរ ឬទឹកអប់ជាដើមសូម្បីតូចជាស្អាត ដោយពិត រមែងនឹងឃើញកាយ មានតែសក់រោមជាដើម ដែលមានក្លិនស្អុយគួរខ្ពើមរអើមក្រៃលែង មិនមានសិរីដែលគួរមើលឡើយ មានប្រការផ្សេងៗ ថា មិនស្អាតតែម្យ៉ាង ។

ពណ៌នា ដោយការសម្ព័ន្ធនៃបទក្នុងទ្វត្តឹសាការកម្មដ្ឋាននេះប៉ុណ្ណេះមុន ។

## អសុភភាវនា

គប្បីជ្រាបការពណ៌នាទ្វត្តឹសាការកម្មដ្ឋាននោះ ជាអសុភភាវនាដូចតទៅនេះ ។

ជាដំបូង កុលបុត្រអ្នកផ្ដើមបំពេញកម្មដ្ឋាន ជាអ្នកតាំងនៅក្នុងសីល មានបាណាតិបាតវេរមណីជាដើម យ៉ាងនេះហើយ មានប្រយោគដ៏បរិសុទ្ធ បំណងនឹងប្រកបរឿយៗ នៅអនុយោគ: គឺ ការបំពេញកម្មដ្ឋានចំណែក ទុត្តិសាការ: ដើម្បីសម្រេចសេចក្ដីបរិសុទ្ធិនៃអាសយញ្ញាណ កុលបុត្រនោះ រមែងមានកង្វល់ ១០ ប្រការ គឺ កង្វល់ដោយទីនៅ ដោយត្រកូល ដោយលាភ ដោយគណ: ដោយការងារ ដោយការដើរផ្លូវ ដោយញាតិ ដោយការរៀនគម្ពីរ ដោយរោគ និងដោយឫទ្ធិ ឬកង្វល់ដោយកេរ្តិ៍ឈ្មោះ កាលដូច្នោះ កុលបុត្រនេះត្រូវកាត់កង្វល់ទាំង ១០ នោះចេញ ដោយវិធីយ៉ាងនេះ គឺ ដោយការលះសេចក្ដីកង្វល់ក្នុងអាវាស ត្រកូល លាភ គណ: ញាតិ និងកេរ្តិ៍ឈ្មោះចេញ ដោយការមិនខ្វល់ខ្វាយក្នុងការងារ ការដើរផ្លូវ និងការរៀនគម្ពីរចេញ ដោយការព្យាបាលរោគ កាលកុលបុត្រនេះកាត់កង្វល់បានហើយ មិនលះបង់សេចក្ដីត្រេកអរក្នុងនេក្ខម្ម: កំណត់ការបដិបត្តិដុសខាត់រហូតដល់ទីបំផុត មិនលះអាចារ:ផ្លូវវិន័យសូម្បីតិចតួច ក៏គប្បីចូលទៅរកអាចារ្យអ្នកឲ្យកម្មដ្ឋាន ដែលជាអ្នកប្រកបដោយអាគម (បរិយត្តិ)

និងអធិគម (បដិវេធ) ឬប្រកបដោយគុណសម្បត្តិយ៉ាងណាមួយអំពីអាគម និងអធិគមនោះ ដោយវិធីដែលសមគួរដល់វិន័យ ហើយគប្បីប្រាប់សេចក្តីប្រាថ្នារបស់ខ្លួនដល់ព្រះអាចារ្យនោះ ដែលខ្លួនធ្វើឲ្យលោកមានចិត្តត្រេកអរ ដោយវត្តសម្បទា ។ ព្រះអាចារ្យនោះ គប្បីដឹងសេចក្តីផ្សេងគ្នានៃនិមិត្ត អធ្យាស្រ័យ ចរិយា និងអធិមុត្តិ របស់កុលបុត្រនោះ បើថា កម្មដ្ឋាននោះជារបស់សមគួរ ដូច្នោះ កុលបុត្រនោះបំណងនឹងនៅក្នុងវិហារដែលខ្លួននៅដែរ តអំពីនោះ ក៏គប្បីឲ្យកម្មដ្ឋានដោយសង្ខេប ។ បើកុលបុត្រនោះបំណងនឹងនៅក្នុងវិហារដទៃ ក៏គប្បីប្រាប់កម្មដ្ឋានដោយពិស្តារ ព្រមទាំងប្រការដែលគួរធ្វើមុន ដោយប្រាប់ប្រការដែលគួរលះ និងប្រការដែលគួរកំណត់ដឹងជាដើម ព្រមទាំងប្រភេទចរិត ដោយប្រាប់កម្មដ្ឋានដែលសមគួរដល់ចរិតជាដើម ។ កុលបុត្រនោះ កាលរៀនកម្មដ្ឋាន ព្រមទាំងប្រការដែលគួរធ្វើមុន ទាំងប្រភេទនោះ ហើយប្រាប់លាអាចារ្យ វៀរចាកសេនាសនៈ ១៨ ប្រភេទ ដែលលោកពោលថា គួរវៀរ យ៉ាងនេះថា ៖

អាវាសធំ អាវាសថ្មី អាវាសចាស់ អាវាសជិតផ្លូវ អាវាស

ជិតអណ្ដូងទឹក អាវាសមានស្លឹកឈើ អាវាសមានផ្កាឈើ អាវាសមានផ្លែឈើ អាវាសដែលមនុស្សប្រាថ្នា អាវាសដែលជិតនគរ អាវាសដែលជិតមនុស្សចូលទៅកាប់ឈើ អាវាសដែលជិតវាលស្រែ អាវាសដែលមានអារម្មណ៍ជាសត្រូវ អាវាសជិតកំពង់ទូក អាវាសជិតតំបន់លក់ដូរ អាវាសមានសីមា អាវាសដែលជាអសប្បាយៈ អាវាសដែលមិនបានកល្យាណមិត្ត បណ្ឌិតយល់ស្ថានទី ១៨ នេះ ដូច្នេះហើយ គប្បីវៀរចេញឲ្យឆ្ងាយ ដូចអ្នកដើរផ្លូវ វៀរផ្លូវដែលមានភ័យចំពោះមុខ ដូច្នោះ ។

ហើយចូលកាន់សេនាសនៈដែលប្រកបដោយអង្គ ៥ ដែលព្រះមានព្រះភាគត្រាស់យ៉ាងនេះថា ៖

ម្នាលភិក្ខុទាំងឡាយ សេនាសនៈប្រកបដោយអង្គ ៥ ដូចម្ដេច ម្នាលភិក្ខុទាំងឡាយ សេនាសនៈក្នុងព្រះធម្មវិន័យនេះ ជាសេនាសនៈដែលមិនឆ្ងាយពេក ដែលមិនជិតពេក

ព្រមដោយគមនាគម ពេលថ្ងៃមនុស្សមិនកុះករ ពេលយប់ស្ងប់ស្ងាត់សំឡេង មិនគឹកកង មិនមានរបោម មូស ខ្យល់កំដៅថ្ងៃ ពស់ រំខាន កាលភិក្ខុនៅក្នុងសេនាសនៈនោះ ចីវរ បិណ្ឌបាត សេនាសនៈ គិលានប្បច្ច័យភេសជ្ជៈបរិក្ខារនៃអ្នកជំងឺ កើតឡើងមិនលំបាក ក្នុងសេនាសនៈនោះឯង មានភិក្ខុជាថេរៈអ្នកជាពហុស្សូត្រ អ្នកចប់អាគម ទ្រទ្រង់ធម៌ ទ្រទ្រង់ព្រះវិន័យ ទ្រទ្រង់មាតិកា ភិក្ខុចូលទៅរកភិក្ខុជាថេរៈទាំងនោះ តាមសមគួរដល់កាល សាកសួរសេចក្តីងឿងឆ្ងល់ថា លោកម្ចាស់ ប្រការនេះយ៉ាងណា ប្រការនេះមានសេចក្តីយ៉ាងណា លោកទាំងនោះ រមែងនឹងបើកបង្ហាញប្រការដែលនៅមិនទាន់បានបើកបង្ហាញដល់ភិក្ខុនោះ ធ្វើប្រការដែលលំបាកឲ្យងាយស្រួល បន្ទោបង់សេចក្តីសង្ស័យក្នុងធម៌ទាំងឡាយ ដែលជាទីតាំងនៃសេចក្តីសង្ស័យផ្សេង ៗ ចេញបាន ម្នាលភិក្ខុទាំងឡាយ សេនាសនៈប្រកបដោយ

អង្គ ៥ យ៉ាងនេះឯង ។

ដូច្នេះ ធ្វើកិច្ចគ្រប់យ៉ាងឲ្យសម្រេចហើយ ពិចារណាទោសក្នុងកាមទាំងឡាយ និងអានិសង្សក្នុងនេក្ខម្មៈ ធ្វើចិត្តឲ្យជ្រះថ្លាដោយការរឭកដល់ (ព្រះរតនត្រ័យ) ថា ព្រះមានព្រះភាគព្រះអង្គត្រាស់ដឹងល្អហើយ ព្រះធម៌ជាធម៌ដ៏ល្អ ព្រះសង្ឃជាអ្នកបដិបត្តិល្អហើយ មិនលះការឈ្លាសវៃក្នុងផ្លូវត្រាស់ដឹង ៧ ប្រការ ដែលលោកពោលទុកយ៉ាងនេះថា ៖

អ្នកប្រាជ្ញដឹងផ្លូវបដិបត្តិ ៧ ប្រការ គឺ ដោយវាចា
ដោយចិត្ត ដោយវណ្ណៈ ដោយសណ្ឋាន ដោយទិស
ដោយឱកាស និងដោយបរិច្ឆេទ ។

និងការឆ្លាតឈ្លាសធ្វើទុកក្នុងចិត្ត ១០ យ៉ាង ដែលលោកពោលទុកយ៉ាងនេះ គឺ ដោយលំដាប់ ដោយមិនរហ័សពេក ដោយមិនយឺតពេក ដោយរារាំងសេចក្តីរាយមាយ ដោយកន្លងបញ្ញត្តិ ដោយលំដាប់លំដោយ ដោយអប្បនា ដោយសូត្រ ៣ សូត្រ ទើបគួរចម្រើនទ្វត្តឹសាការ ។ ពិតហើយ ការចម្រើនទ្វត្តឹសាការៈដោយអាការគ្រប់យ៉ាង រមែងសម្រេចដល់

អ្នកចាប់ផ្តើម ដូចពោលមកនេះ សម្រេចដោយប្រការដទៃមិនមាន ។

ក្នុងការចម្រើនទ្វត្តិំសាការៈនោះ ភិក្ខុទទួលតចបញ្ចកកម្មដ្ឋានជាមុន ពោលដោយព្រះត្រៃបិដក កាលតចបញ្ចកកម្មដ្ឋានជំនាញដោយអនុលោម តាមន័យថា **កេសា លោមា** ជាដើម ជំនាញដោយបដិលោម តាមន័យថា **តចោ ទន្តា** ជាដើម គប្បីចម្រើនរហូតកន្លះខែ តាមផ្លូវវាចា ដើម្បីកាត់សេចក្តីត្រិះរិះ ដែលរាយមាយចេញទៅខាងក្រៅដោយអនុលោម និងបដិលោម តាមន័យទាំង ២ នោះឯង ដើម្បីឲ្យជំនាញបាលី និងតាមផ្លូវចិត្ត ដើម្បីកំណត់សភាវៈនៃចំណែករាងកាយជាអារម្មណ៍ ។ ពិតណាស់ ការចម្រើនផ្លូវវាចា នូវតចបញ្ចកកម្មដ្ឋាននោះ កាត់វិតក្កៈដែលរាយមាយទៅខាងក្រៅបានហើយ រមែងជាបច្ច័យដល់ការចម្រើនផ្លូវចិត្ត ព្រោះជំនាញបាលីហើយ ការចម្រើនផ្លូវចិត្ត រមែងជាបច្ច័យដល់ការកំណត់អសុភៈ វណ្ណៈ និងលក្ខណៈចំណែកណាមួយ ដោយន័យនោះ ក៏គប្បីចម្រើនវក្កបញ្ចក-កម្មដ្ឋាន (ពួកដែលមានវក្កៈជាទី ៥) រហូតកន្លះខែតអំពីនោះ ទើបចម្រើនតចបញ្ចកកម្មដ្ឋាន និងវក្កបញ្ចកកម្មដ្ឋានទាំងពីរនោះរហូតខ្លះខែ តអំពីនោះ

ទើបបច្ឆាសបញ្ចកកម្មដ្ឋានរហូតកន្លះខែ តអំពីនោះ ក៏ចម្រើនទាំង ៣ បញ្ចកៈនោះរហូតកន្លះខែ ដូច្នោះឯង ក៏គប្បីបន្ថែមមត្ថលុង្គ ដែលមិនបានត្រាស់ទុកក្នុងខាងក្រោយក្នុង ៣ ពួកនេះ ហើយចម្រើនរួមគ្នាជាមួយអាការនៃបឋវីធាតុទាំងឡាយ ហើយចម្រើនមត្ថលុង្គ រហូតកន្លះខែ តអំពីនោះ ក៏ចម្រើនបញ្ចកៈ និងចតុក្កៈរហូតកន្លះខែ មេទឆក្កៈកន្លះខែ តពីនោះ ក៏ចម្រើនបញ្ចកៈ និងចតុក្កៈ រួមជាមួយមេទឆក្កៈកន្លះខែ មុត្តឆក្កៈកន្លះខែ តពីនោះ ក៏ចម្រើនទ្វត្តឹសាការៈទាំងអស់រហូតកន្លះខែ គប្បីចម្រើនកំណត់ដោយវណ្ណៈ សណ្ឋាន ទិស ឱកាស និងបរិច្ឆេទ ៦ ខែ ដូចពោលមកនេះ ។ សេចក្តីនេះ លោកពោលសំដៅដល់បុគ្គលដែលមានបញ្ញាជាកណ្តាល ។ ចំណែកអ្នកដែលមានបញ្ញាខ្សោយ គប្បីចម្រើនរហូតអស់ជីវិត អ្នកមានបញ្ញាមុតស្រួច ការចម្រើន រមែងសម្រេចបានយ៉ាងឆាប់រហ័ស ។

### កេសា (សក់)

ក្នុងសេចក្តីនេះ អាចារ្យពួកខ្លះ (អ្នកជំទាស់) ពោលថា ភិក្ខុអ្នកចម្រើនកម្មដ្ឋាននេះ កំណត់ទ្វត្តឹសាការនេះ ដោយវណ្ណៈជាដើមយ៉ាងណា

សេចក្ដីពិត ភិក្ខុអ្នកផ្ដើមកម្មដ្ឋាននេះ កាលចម្រើនទ្វត្តឹសាការៈដោយចែក តចបញ្ចកៈជាដើម ដោយន័យថា សក់មាននៅក្នុងកាយនេះ ដូច្នេះជាដើម រមែងកំណត់សក់ ជារបស់ដែលភិក្ខុនេះឃើញហើយអំពីមុនដោយវណ្ណៈថា មានពណ៌ខ្មៅ ។ កំណត់សក់ដែលវែងដោយសណ្ឋានថា ដូចជាដងជញ្ជីង ។ តែព្រោះហេតុក្នុងកាយនេះ ខាងលើផ្ទៃ (ពោះ) ឡើងទៅ ហៅថា ទិសខាងលើ ខាងក្រោមផ្ទៃចុះមក ហៅថា ទិសខាងក្រោម ដូច្នោះ ទើបកំណត់ ដោយទិសថា កើតក្នុងទិសខាងលើនៃកាយនេះ ។ កំណត់ដោយឱកាស (ទីតាំង) ថា កើតត្រង់ស្បែកក្បាល កំណត់យកទីបំផុតត្រឹមថ្ងាស់ ជុំវិញ គល់ត្រចៀក និងដើម.ក ។ កំណត់ក្នុងកេសានោះថា សក់មិនដឹងថា យើង កើតត្រង់ស្បែកក្បាល សូម្បីស្បែកក្បាលក៏មិនដឹងថា សក់កើតត្រង់យើង ប្រៀបដូចជាស្មៅកុណ្ឌៈ ដែលដុះលើដំបូកកណ្ដៀរ មិនដឹងថា យើងដុះ លើដំបូកកណ្ដៀរ សូម្បីដំបូកក៏មិនដឹងថា ស្មៅកុណ្ឌៈដុះលើយើង ដូច្នោះ ។ កំណត់ថា ដែលពិត សក់ទាំងនេះ វៀរចាកការគិត និងការពិចារណា ជាធម៌ មិនមានចេតនា (ចិត្ត) ជាអព្យាកតៈ ជារបស់សោះសូន្យ បដិកូល

ដោយក្លិន គួរខ្ពើមយ៉ាងក្រៃលែង មិនមែនសត្វ មិនមែនបុគ្គល ។ កាលពោលដោយបរិច្ឆេទ (ចំណែក) ការកំណត់ចំណែក មាន ២ យ៉ាង គឺដោយសភាគ: (ចំណែកត្រូវគ្នា) ដោយវិសភាគ: (ចំណែកខុសគ្នា) ។ ក្នុងចំណែក ២ យ៉ាងនោះ កំណត់ចំណែកដោយសភាគ:យ៉ាងនេះថា សក់ចំណែកក្រោម (គល់សក់) ត្រឹមស្បែក និងគល់របស់ខ្លួន ដែលដុះចូលទៅក្នុងស្បែកនោះប្រមាណមួយចុងគ្រាប់ស្រូវ ចំណែកខាងលើដោយអាកាស ខាងទទឹងដោយសក់ផងគ្នា និងកំណត់ដោយចំណែកវិសភាគ: យ៉ាងនេះថា សក់មិនមែនអាការ ៣១ ដ៏សេស , អាការ ៣១ ដ៏សេសក៏មិនមែនសក់ កំណត់សក់ដោយវណ្ណ:ជាដើម មានប្រការដូចពោលមកយ៉ាងនេះមុន ។

## លោមា (រោម)

ក្នុងអាការ ៣១ ដ៏សេស ក៏កំណត់រោម ដែលភិក្ខុនេះឃើញហើយដោយវណ្ណ: ចំណែកច្រើន មានពណ៌ខ្មៅ ដោយសណ្ឋានថា មានសណ្ឋានដូចជងធ្នូ ឬមានសណ្ឋានដូចដើមត្នោតកោង កំណត់ដោយទិសទាំង ២ កំណត់ដោយឱកាស (ទីតាំង) ថា កើតត្រង់ស្បែកនៃសរីរ:ដ៏សេសដោយ

ច្រើន វៀរបាតដៃបាតជើង ។

ក្នុងអាការ ៣០ ដ៏សេស កំណត់ថា រោមរមែងមិនដឹងថា យើងកើតត្រង់ស្បែកនៃសរីរៈ សូម្បីស្បែកនៃសរីរៈក៏មិនដឹងថា រោមកើតត្រង់យើង ប្រៀបដូចស្មៅទព្វៈដែលកើតត្រង់ទីផ្ទះចាស់ រមែងមិនដឹងថា យើងកើតត្រង់ទីផ្ទះចាស់ សូម្បីទីផ្ទះចាស់ ក៏មិនដឹងថា ស្មៅទព្វៈកើតត្រង់យើងដូច្នោះ ។ ព្រោះថា រោមទាំងនេះ វៀរចាកការគិត និងការពិចារណា ជាធម៌មិនមានចេតនា (ចិត្ត) ជាអព្យាកត សោះសូន្យ បដិកូលដោយក្លិនគួរឲ្យខ្ពើមរអើមក្រៃលែង មិនមែនសត្វ មិនមែនបុគ្គល ។ កំណត់ដោយបរិច្ឆេទ (ដោយចំណែក) ថា ចំណែកខាងក្រោម កំណត់ដោយផ្ទៃស្បែកដែលតាំងនៅ ដោយគល់របស់ខ្លួនដែលចូលទៅក្នុងផ្ទៃស្បែកនោះ ប្រមាណប៉ុនក្បាលចៃ ខាងលើកំណត់ដោយចំណែកអាកាស រោមខាងទទឹង កំណត់ដោយរោមគ្នាឯង ។ នេះជាការកំណត់រោមទាំងនោះ ដោយសភាគៈ ចំណែកការកំណត់ដោយវិសភាគៈ ក៏ដូចគ្នានឹងសក់នោះឯង កំណត់រោមដោយវណ្ណៈជាដើម មានប្រការដូចពោលមកដូច្នេះ ។

នខា (ក្រចក)

ក្នុងក្រចកនោះ កំណត់ថា អ្នកមានក្រចកគ្រប់ ក៏មាន ២០ ក្រចក ។ ក្រចកទាំងអស់នោះ ដោយវណ្ណៈ មានពណ៌ស ក្នុងឱកាសជាប់ដោយសាច់ មានពណ៌ក្រហម ក្នុងឱកាសដែលជាប់ជាមួយសាច់ ដោយសណ្ឋាន មានសណ្ឋានដូចឱកាសតាមទីកើតដោយច្រើន មានសណ្ឋានដូចគ្រាប់ស្រគុំ ឬមានសណ្ឋានដូចស្រកាត្រី ។ ដោយទិស កើតនៅក្នុងទិសទាំង ២ ។ ដោយឱកាស តាំងនៅចុងម្រាមដៃ ។

ក្នុងក្រចកនោះ កំណត់ថា ក្រចករមែងមិនដឹងថា យើងតាំងនៅចុងម្រាមដៃ សូម្បីម្រាមដៃក៏មិនដឹងថា ក្រចកតាំងនៅត្រង់ខាងចុងនៃយើង ប្រៀបដូចគ្រាប់ស្រគុំ ដែលពួកក្មេងអ្នកស្រុកដោតទុកត្រង់ចុងឈើ មិនដឹងថា យើងត្រូវដោតទុកត្រង់ចុងឈើ សូម្បីឈើក៏មិនដឹងថា គ្រាប់ស្រគុំត្រូវដោតទុកត្រង់យើង ដូច្នោះ ។ ព្រោះថា ក្រចកទាំងនេះ វៀរចាកការនឹកគិត និងការពិចារណា ជាធម៌ មិនមានចេតនា ។ល។ មិនមែនបុគ្គល ។ កំណត់ដោយបរិច្ឆេទថា ក្រចកត្រូវកំណត់ដោយសាច់ម្រាមដៃត្រង់គាល់ ឬ

ដោយផ្ទៃទីតាំងនៅត្រង់គល់នោះ និងក្រចកខាងលើកំណត់ដោយអាកាស ត្រង់ចុង ដោយស្បែកចុងម្រាមទាំងពីរចំណែក ។ នេះជាការកំណត់ក្រចកទាំងនោះដោយសភាគៈ ឯការកំណត់ដោយវិសភាគៈ ក៏ដូចគ្នានឹងសក់នោះឯង កំណត់ក្រចកដោយពណ៌ជាដើម មានប្រការដូចពោលមកដូច្នេះ ។

## ទន្តា (ធ្មេញ)

តអំពីនោះ ក៏កំណត់ថា អ្នកមានធ្មេញគ្រប់ ក៏មានធ្មេញ ៣២ ។ ធ្មេញទាំងអស់នោះ ដោយវណ្ណៈ ក៏មានពណ៌ស ។ ដោយសណ្ឋាន ធ្មេញរបស់អ្នកមានធ្មេញរាបស្មើ នឹងប្រាកដដូចផ្ទៃស័ង្ខដ៏រីង និងដូចពួកផ្កាឈើសក្កោបដែលក្រងទុកដោយល្អ ។ ធ្មេញរបស់បុគ្គលមានធ្មេញមិនរាបស្មើ មានសណ្ឋានផ្សេងៗ គ្នា ដូចលំដាប់តាំងលើពេងចាស់ ។ ក៏ក្នុងចុងជួរធ្មេញទាំងពីរខាងនៃធ្មេញនោះ ធ្មេញ ៨ គ្រាប់ ខាងក្រោម ២ ខាងលើ ២ គ្រាប់ (តែម្ខាងៗ) មានចុង ៤ មានឫស ៤ មានសណ្ឋានដូចអាសន្ទិ (កៅអីជើងវែង) ។ ធ្មេញ ៨ គ្រាប់ ដែលតាំងនៅតាមលំដាប់នោះ ក្នុងធ្មេញទាំងនោះ មានចុង ៣ មានឫស ៣ មានសណ្ឋានដូចផ្លូវបែកជា ៣

ធ្មេញ ៤ គ្រាប់ ខាងក្រោម ១ ខាងលើ ១ តាមលំដាប់នោះ ក្នុងធ្មេញទាំងនោះ មានចុង ២ មានឫស ២ មានសណ្ឋានដូចឈើទ្រយាន (ជន្ទុលរទេះ) ។ ធ្មេញចង្កូម ៤ គ្រាប់ ដែលតាំងនៅតាមលំដាប់នោះ ធ្មេញក្រោម ១ លើ ១ មានចុងមួយ មានឫសមួយ មានសណ្ឋានដូចផ្កាម្លិះក្តាប ។ បន្ទាប់ពីនោះ ធ្មេញ ៨ គ្រាប់ ខាងក្រោម ៤ ខាងលើ ៤ ត្រង់កណ្តាលជួរធ្មេញទាំង ២ ខាង មានចុងតែមួយ ឫសតែមួយ មានសណ្ឋានដូចគ្រាប់ឃ្លោក ។ ដោយទិស កើតក្នុងទិសខាងលើ ដោយឱកាស ធ្មេញខាងលើតាំងនៅក្នុងឆ្អឹងថ្គាមលើ មានចុងចុះក្រោម ធ្មេញក្រោម តាំងនៅក្នុងឆ្អឹងថ្គាមក្រោម មានចុងឡើងលើ ។

ក្នុងធ្មេញនោះ ក៏កំណត់ថា ធ្មេញមិនដឹងថា យើងតាំងនៅក្នុងឆ្អឹងថ្គាមក្រោម តាំងជ្រៀតនៅក្នុងឆ្អឹងថ្គាមខាងលើ សូម្បីឆ្អឹងថ្គាមក្រោម ក៏មិនដឹងថា ធ្មេញតាំងនៅក្នុងយើង ប្រៀបដូចសសរដែលបុរសកសាង ដាំចុះទុកក្នុងផ្ទៃថ្មខាងក្រោម បញ្ចុះទៅក្នុងផ្ទៃថ្មខាងលើ រមែងមិនដឹងថា យើងត្រូវគេដាំទុកក្នុងផ្ទៃថ្មខាងក្រោម ត្រូវបញ្ចុះទៅក្នុងផ្ទៃថ្មខាងលើ ផ្ទៃថ្មខាង

ក្រោមក៏មិនដឹងថា សសរត្រូវគេដាំទុកក្នុងយើង ផ្ទៃថ្មខាងលើក៏មិនដឹងថា សសរត្រូវគេបញ្ចុះក្នុងយើង ដូច្នោះ ។ ព្រោះថា ធ្មេញទាំងនេះវៀរចាក ការគិត និងការពិចារណា ជាធម៌ ។ល។ មិនមែនបុគ្គល ។ កំណត់ដោយ បរិច្ឆេទថា ធ្មេញក្រោមកំណត់ដោយរណ្តៅឆ្អឹងថ្គាម ដុះចេញពីឆ្អឹងថ្គាម តាំងនៅ និងដោយឫសរបស់ខ្លួន ធ្មេញលើ កំណត់ដោយអាកាស ខាងទទឹង កំណត់ដោយធ្មេញផងគ្នា ។ នេះជាការកំណត់ធ្មេញទាំងនោះដោយសភាគៈ ចំណែកកំណត់ដោយវិសភាគៈ ក៏ដូចគ្នានឹងសក់នោះឯង ។ កំណត់ធ្មេញ ដោយពណ៌ជាដើម មានប្រការដូចពោលមកនោះឯង ។

## តចោ (ស្បែក)

តអំពីនោះ វត្ថុដែលបិទបាំងគំនរសាកសពផ្សេងៗ ក្នុងខាងក្នុងសរីរៈ ឈ្មោះថា ស្បែក ។ កាលកំណត់ដោយវណ្ណៈ ស្បែកមានពណ៌ស ។ ប្រសិនបើស្បែកនោះ ប្រាកដដូចមានពណ៌ផ្សេងៗ ដោយពណ៌ខ្មៅ ពណ៌ស ជាដើម ក៏ព្រោះត្រូវជ្រលក់ដោយគ្រឿងជ្រលក់ពណ៌ ទើបបានជាពណ៌ស នោះឯង ដោយវណ្ណៈដែលជាសភាគៈគ្នា ។ ក៏ភាពដែលស្បែកមានពណ៌

សនោះ រមែងប្រាកដដោយសម្បុរត្រូវលោកភ្លើង និងត្រូវប្រហារដោយគ្រឿងប្រហារជាដើម ។ កំណត់ដោយសណ្ឋាន ដោយសង្ខេបថា មានសណ្ឋានដូចអាវ ដោយពិស្តារថា មានសណ្ឋានផ្សេងៗ ។ ពិតណាស់ស្បែកម្រាមជើង មានសណ្ឋានដូចសំបុកដង្កូវនាង ឯស្បែកខ្នងជើងមានសណ្ឋានដូចស្បែកជើងដែលខ្ចប់ទុក ស្បែកស្មងជើង មានសណ្ឋានដូចស្លឹកត្នោតខ្ចប់បាយ ស្បែកជើង មានសណ្ឋានដូចថង់យូរដែលពេញដោយស្រូវ ស្បែកត្រគាក មានសណ្ឋានដូចសំពត់ត្រងទឹកមានទឹកពេញ ស្បែកផ្អឹងខ្នង មានសណ្ឋានដូចស្បែកស្រោបខែល ស្បែកពោះ មានសណ្ឋានដូចស្បែកស្រោបពិណ ស្បែកដើមទ្រូងដោយច្រើន មានសណ្ឋាន ៤ ជ្រុង ស្បែកដៃទាំងពីរ មានសណ្ឋានដូចស្បែកស្រោបបំពង់ធ្នូ ស្បែកខ្នងដៃ មានសណ្ឋានដូចស្រោមកំបិតកោរ ឬមានសណ្ឋានដូចស្រោមស្និត ស្បែកម្រាមដៃ មានសណ្ឋានដូចស្រោមសោរ ស្បែក.ក មានសណ្ឋានដូចអាវមាន.ក ស្បែកមុខ មានសណ្ឋានដូចសំបុកដង្កូវ ដែលមានរន្ធតូចៗ ស្បែកសីសៈ មានសណ្ឋានដូចស្លោកបាត្រ ។

ក៏ព្រះយោគាវចរ ដែលកំណត់ស្បែកជាអារម្មណ៍ បញ្ជូនចិត្តទៅរវាងស្បែក និងសាច់ តាំងអំពីបបូរមាត់ខាងលើ កំណត់ស្បែកមុខមុនជាលំដាប់ដំបូង តពីនោះ ក៏ស្បែកសីសៈ ស្បែក.កផ្នែកខាងក្រៅ បន្ទាប់ពីនោះ ក៏គប្បីកំណត់ស្បែកដៃស្តាំ ទាំងអនុលោម និងបដិលោម ដោយលំដាប់តមក ក៏គប្បីកំណត់ស្បែកដៃខាងឆ្វេង ស្បែកខ្នង ស្បែកត្រគាកតអំពីនោះ ក៏ស្បែកខ្នងជើងស្តាំ ទាំងអនុលោម និងបដិលោម ស្បែកខ្នងជើងឆ្វេង ស្បែកក្រពះបស្សាវៈ ពោះតូច បេះដូង ក.ខាងក្នុង តពីនោះ ក៏ស្បែកចង្កាក្រោម ស្បែកបបូរមាត់កណ្តាល កំណត់យ៉ាងនេះទៀតរហូតដល់បបូរមាត់ខាងលើ ។ កំណត់ដោយទិសថា កើតក្នុងទិសទាំង ២ ។ កំណត់ដោយឱកាសថា រុំខ្ចប់ទូទៅសរីរៈហើយតាំងនៅ ។

ក្នុងស្បែកនោះ ព្រះយោគាវចរកំណត់ថា ស្បែករមែងមិនដឹងថា យើងរុំខ្ចប់សរីរៈដែលប្រកបដោយមហាភូតរូបទាំង ៤ នេះ សូម្បីសរីរៈដែលប្រកបដោយមហាភូតរូបទាំង ៤ នេះ ក៏មិនដឹងថា យើងត្រូវស្បែករុំខ្ចប់ទុក ប្រៀបដូចហិបរុំដោយស្បែក រមែងមិនដឹងថា យើងរុំហិប សូម្បី

ហិបក៏មិនដឹងថា យើងត្រូវស្បែករុំ ដូច្នោះ ព្រោះថា ស្បែកទាំងនេះវៀរ

ចាកការគិត និងការពិចារណា ជាធម៌ ។ល។ មិនមែនបុគ្គល ។ លោក

ពោលទុកដោយអស់ជើងថា ៖

អល្លចម្មបដិច្ឆន្នោ  នវទ្វារោ មហាវណោ

សមន្តតោ បគ្ឃរតិ  អសុចិបូតិគន្ធិយោ ។

រាងកាយនេះ បិទបាំងដោយស្បែក មានទ្វារ ៩

មានដំបៅច្រើន មិនស្អាត មានក្លិនស្អុយ រមែង

ហូរចេញដោយជុំវិញ ។

កំណត់ដោយបរិច្ឆេទ (កំណត់) ថា ស្បែកខាងក្រោម កំណត់ដោយ សាច់ ឬទីតាំងនៃសាច់នោះ ស្បែកខាងលើ កំណត់ដោយសម្បុរ នេះ ជាការកំណត់ស្បែកនោះដោយសភាគៈ ។ ការកំណត់ដោយវិសភាគៈ ក៏ ដូចគ្នានឹងសក់នោះឯង ។ កំណត់ស្បែកដោយវណ្ណៈជាដើម មានប្រការ ដូចពោលមកនោះឯង ។

## មំសំ (សាច់)

តអំពីនោះទៅ កំណត់សាច់ ដែលផ្សេងដោយសាច់ ៩០០ ដុំ ក្នុងសរីរៈ ដោយវណ្ណៈថា មានពណ៌ក្រហមស្រដៀងនឹងផ្កាចារ ។ ដោយសណ្ឋានថា មានសណ្ឋានផ្សេងៗ គ្នា ។ ពិតហើយ សាច់កំភួនជើងនៃសរីរៈនោះ មានសណ្ឋានដូចបាយខ្ចប់ស្លឹកត្នោត អាចារ្យពួកខ្លះពោលថា “មានសណ្ឋានដូចផ្កាវំពេកក្ដោប ដែលនៅមិនទាន់រីក” ដូច្នេះក៏មាន ។ សាច់ជើងមានសណ្ឋានដូចកូនដុំកំបោរស សាច់ត្រគាក មានសណ្ឋានដូចចុងសសរ សាច់ខ្នង មានសណ្ឋានដូចជាផែននៃស្ករត្នោត សាច់ឆ្អឹងជំនីទាំងសងខាង មានសណ្ឋានដូចដីស្អិតក្នុងទីជម្រុកស្រូវដែលធ្វើដោយឫស្សី សាច់ដោះ មានសណ្ឋានដូចដុំដីជ្រាយ ដែលធ្វើឲ្យមូលហើយបោះទៅ សាច់ដៃទាំងពីរខាង មានសណ្ឋានដូចកណ្ដុរធំដែលគេកាត់ក្បាល និងជើងពន្លាត់ស្បែកហើយ ។ អាចារ្យពួកមួយពោលថា “មានសណ្ឋានដូចចង្កោមដុំសាច់” ដូច្នេះក៏មាន ។ សាច់ថ្ពាល់ មានសណ្ឋានដូចផ្លែថ្ងាន់ ដែលគេដាក់ទុកត្រង់ថ្ពាល់ ។ អាចារ្យមួយពួកទៀតពោលថា “មានសណ្ឋានដូចសត្វ

កន្ត្រៃ” ដូច្នេះក៏មាន ។ សាច់អណ្តាត មានសណ្ឋានដូចត្របកផ្កាឈូក សាច់ប្រមុះ មានសណ្ឋានដូចទូដាក់សៀវភៅ សាច់ភ្នែក មានសណ្ឋានដូចផ្លែល្វាទុំពាក់កណ្តាល សាច់ក្បាល មានសណ្ឋាន ដូចប្រេងលាបខ្ទះស្តើងៗ ជុំវិញបាត ។ ក៏ព្រះយោគាវចរ ដែលកំណត់សាច់ជាអារម្មណ៍ គប្បីកំណត់សាច់ចំណែកគ្រោតគ្រាតទាំងនោះឯង ដោយសណ្ឋាន ។ ព្រោះថា ព្រះយោគាវចរកំណត់យ៉ាងនេះ សាច់ចំណែកល្អិត ក៏នឹងប្រាកដដល់ញាណ ។ កំណត់ដោយទិស សាច់កើតនៅក្នុងទិសទាំងពីរ ។ កំណត់ដោយឱកាស សាច់បូកលាបតាមឆ្អឹង ៣០០ កំណាត់ ដែលគ្រាន់ឆ្អឹងនោះហើយតាំងនៅ ។

ក្នុងសាច់នោះ ក៏កំណត់ថា សាច់ ៩០០ ដុំ រមែងមិនដឹងថា យើងបូកលាបឆ្អឹង ៣០០ កំណាត់ សូម្បីឆ្អឹង ៣០០ កំណាត់ ក៏មិនដឹងថា យើងត្រូវសាច់ ៩០០ ដុំ បូកលាបទុក ប្រៀបដូចជញ្ជាំងផ្ទះដែលត្រូវបូកលាបដោយដី ដីរមែងមិនដឹងថា យើងបូកលាបជញ្ជាំងផ្ទះ សូម្បីជញ្ជាំងផ្ទះក៏មិនដឹងថា យើងត្រូវបូកលាបដោយដី ។ សេចក្តីថា សាច់ទាំងនេះ

វៀរចាកការគិត និងការពិចារណា ជាធម៌ ។ល។ មិនមែនបុគ្គល ។

លោកពោលទុកថា ៖

នវ បេសិសតា មំសា អនុលិត្តា កឡេវរំ

នានាកិមិកុលាកិណ្ណំ មិឡ្ហដ្ឋានំវ បូតិកំ ។

សាច់ ៩០០ ដុំ បូកលាបដោយកឡេវរៈរាងកាយ ដែល

ជ្រៀតជ្រៀតដោយពួកជន្តុវប្រភេទផ្សេងៗ ស្អុយដូចលាមក ។

កំណត់ដោយបរិច្ឆេទថា សាច់ខាងក្រោម កំណត់ដោយរាងឆ្អឹង ឬ ទីតាំងនៃរាងឆ្អឹងនោះ សាច់ខាងលើ កំណត់ដោយស្បែក សាច់ខាងទទឹង កំណត់ដោយសាច់គ្នាឯង ។ នេះជាការកំណត់សាច់នោះ ដោយសភាគៈ ចំណែកការកំណត់ដោយវិសភាគៈ ក៏ដូចគ្នានឹងសក់នោះឯង ។ កំណត់សាច់ដោយវណ្ណៈជាដើម មានប្រការដូចពោលមកនោះឯង ។

ន្ហារុ (សរសៃ)

តអំពីនោះទៅ ការកំណត់ថា សរសៃ ៩០០ ក្នុងសរីរៈ ដោយ វណ្ណៈថា មានពណ៌ស ។ អាចារ្យពួកមួយពោលថា មានពណ៌ដូចទឹកឃ្មុំ ។

ដោយសណ្ឋាន មានសណ្ឋានផ្សេងៗ ។ ពិតហើយ បណ្ដាសរសៃ ៩០០ នោះ សរសៃធំៗ មានសណ្ឋានដូចផ្កាកន្ទួលៈក្រពុំ ដ៏ល្អិតជាងនោះ ក៏មានសណ្ឋានដូចខ្សែសំណាញ់ទាក់ជ្រូក ដែលតូចក្រៃលែងជាងនោះ ក៏មានសណ្ឋានដូចវល្លិ៍ផោម ដែលតូចក្រៃលែងជាងនោះទៅទៀត ក៏មានសណ្ឋានដូចខ្សែពិណធំរបស់ជនជាតិសីហឡៈ ដែលតូចក្រៃលែងជាងនោះទៅទៀត ក៏មានសណ្ឋានដូចអំបោះគគ្រាត សរសៃខ្នងដៃខ្នងជើង មានសណ្ឋានដូចជើងបក្សី សរសៃក្បាល មានសណ្ឋានដូចសំពត់ស្តើងៗ ដែលគេដាក់លើក្បាលរបស់ក្មេងអ្នកស្រុក សរសៃខ្នង មានសណ្ឋានដូចសំណាញ់ចាប់ត្រីដែលសើមដោយទឹកហើយលាតហាលថ្ងៃ សរសៃតាមអវយវៈតូចធំនោះៗក្នុងសរីរៈនេះដ៏សេស មានសណ្ឋានដូចអាវសំណាញ់ដែលពាក់លើសរីរៈ ។ ដោយពិស្ដារ សរសៃកើតនៅក្នុងទិសទាំងពីរ ។ បណ្ដាសរសៃទាំងនោះ សរសៃធំ មានឈ្មោះថា កណ្ឌរៈ មាន ៥ ចងតាំងពីគុម្ពត្រចៀកខាងស្ដាំមកខាងមុខ និងខាងក្រោយរហូតដល់ខាងឆ្វេង ចងតាំងពីគុម្ពត្រចៀកខាងឆ្វេងមកខាងមុខរហូតដល់ត្រចៀកខាងស្ដាំ ចងតាំងពី.កខាងស្ដាំមកខាងមុខ

និងខាងក្រោយរហូតដល់ខាងឆ្វេង ចង់តាំងពីកខាងឆ្វេងមកខាងមុខ និងខាងក្រោយរហូតដល់ខាងស្តាំ ចងដៃខាងស្តាំមកខាងមុខ ៥ ខាងក្រោយ ៥ រួមសរសៃធំ ដែលឈ្មោះថា កណ្ឌរៈជា ១០ សរសៃ ៗ ដៃខាងឆ្វេង ជើងខាងស្តាំ និងជើងខាងឆ្វេង ក៏ដូច្នោះ ៗ រួមមក សរសៃធំមាន ៦០ ដូចពោលមកនោះ ក៏កំណត់ថា ជាគ្រឿងជួយទ្រទ្រង់សរីរៈទុក ជួយរក្សាសរីរៈក៏មាន ។ កំណត់ដោយឱកាស សរសៃចងឆ្អឹងខាងក្នុង ឆ្អឹងនឹងស្បែក និងឆ្អឹងជាមួយសាច់ តាំងនៅទូទៅសរីរៈ ។

ក្នុងសរសៃនោះ កំណត់ថា សរសៃ រមែងមិនដឹងថា ឆ្អឹង ៣០០ កំណាត់ ត្រូវយើងចងទុក សូម្បីឆ្អឹង ៣០០ កំណាត់ ក៏មិនដឹងថា យើងត្រូវសរសៃចងទុក ប្រៀបដូចឈើកោង ដែលត្រូវវល្លិ៍រុំព័ន្ធ វល្លិ៍រមែងមិនដឹងថា ឈើកោងត្រូវយើងចងទុក សូម្បីឈើកោងក៏មិនដឹងថា យើងត្រូវវល្លិ៍រុំព័ន្ធ ដូច្នោះ ។ ព្រោះថា សរសៃទាំងនេះ វៀរចាកការនឹកគិត និងការពិចារណា ជាធម៌ ។ល។ មិនមែនបុគ្គល ។ លោកពោលសរុបទុកថា

នវន្ហារុសតា ហោន្តិ ព្យាមមត្តេ កឡេវរេ

ពន្ធន្តិ អដ្ឋិសង្ឃាដំ អគារមិវ វល្លិយោ ។
សរសៃ ៩០០ រមែងចងភ្ជាប់ឆ្អឹង ក្នុងផ្ទះ គឺ រាងកាយ
ប្រមាណមួយព្យាម ដូចវល្លិ៍ចងផ្ទះ ដូច្នោះ ។

ដោយបរិច្ឆេទ សរសៃខាងក្រោម កំណត់ដោយឆ្អឹង ៣០០ កំណាត់ ឬទីតាំងឆ្អឹងនោះ សរសៃខាងលើ កំណត់ដោយស្បែក និងសាច់ ខាងទទឹង កំណត់សរសៃផងគ្នានោះឯង ។ នេះជាការកំណត់សរសៃទាំងនោះ ដោយសភាគៈ ចំណែកការកំណត់ដោយវិសភាគៈ ក៏ដូចគ្នានឹងសក់នោះឯង ។ កំណត់សរសៃដោយវណ្ណៈជាដើម មានប្រការដូចពោលមកដូច្នេះ ។

## អដ្ឋិ (ឆ្អឹង)

តពីនោះទៅ កំណត់ដោយវណ្ណៈថា ឆ្អឹង មានប្រភេទដែលលោកពោលទុក ដោយន័យជាដើមយ៉ាងនេះថា ព្រោះលោកកាន់យកឆ្អឹងធ្មេញ ៣២ គ្រាប់ បែកទុកផ្សេងគ្នា ឆ្អឹងដ៏សេសក្នុងសរីរៈ គឺ ឆ្អឹងប្រអប់ដៃ ៦៤ ឆ្អឹងប្រអប់ជើង ៦៤ ឆ្អឹងខ្ចីដែលជាប់សាច់ ៦៤ ឆ្អឹងកែងជើង ២ ឆ្អឹង.កជើង (ក្អែកគោ) ៤ ឆ្អឹងស្មង ៤ ឆ្អឹងជង្គង់ ២ ឆ្អឹងភ្លៅ ២ ឆ្អឹងចង្កេះ ២

ឆ្អឹងខ្នង ១៨ ឆ្អឹងជំនី ២៤ ឆ្អឹងទ្រូង ១៤ ឆ្អឹងបាំងបេះដូង ១ ឆ្អឹងដង
កាំបិត ២ ឆ្អឹងស្មាបប្រចៀវ ២ ឆ្អឹងដើមដៃ ២ ឆ្អឹងកំភួនដៃ ៤ ឆ្អឹង.ក
៧ ឆ្អឹងចង្កា ២ ឆ្អឹងប្រមុះ ១ ឆ្អឹងប្រឡង់ភ្នែក ២ ឆ្អឹងត្រចៀក ២ ឆ្អឹង
ថ្ងាស ១ ឆ្អឹងក្បាល (បង្ហើយ) ១ ឆ្អឹងលលាដ៍ក្បាល ៩ ឆ្អឹងទាំងនោះ
៦៥ មានពណ៌ស ។

កំណត់ដោយសណ្ឋាន ឆ្អឹងមានសណ្ឋានផ្សេងៗ គ្នា ។ ពិតហើយ
បណ្ដាឆ្អឹងទាំងនោះ ឆ្អឹងចុងម្រាមជើង មានសណ្ឋានដូចគ្រាប់ដីប៉ី តពី
នោះ ឆ្អឹងកណ្ដាល មានសណ្ឋានដូចគ្រាប់ខ្នុរដែលមិនពេញ ឆ្អឹងខាងគល់
មានសណ្ឋានដូចស្គរ អាចារ្យពួកខ្លះពោលថា "មានសណ្ឋានដូចស្រកាជើង
ក្ងោក" ដូច្នេះក៏មាន ។ ឆ្អឹងខ្នងជើង មានសណ្ឋាន ដូចបាច់នៃគល់វល្លិ៍
ដែលគេដំហើយ ឆ្អឹងកែងជើង មានសណ្ឋានដូចគ្រាប់ផ្លែត្នោត ដែលមាន
គ្រាប់មួយ ឆ្អឹង.កជើង មានសណ្ឋានដូចគ្រាប់អង្កាញ់ចងផ្គោបគ្នា ឆ្អឹងស្មង
កំណាត់តូច មានសណ្ឋានដូចដងធ្នូ ឆ្អឹងស្មងកំណាត់ធំ មានសណ្ឋានដូច
ខ្នងពស់ដែលស្គួតព្រោះសេចក្ដីស្រេកឃ្លាន ឆ្អឹងជង្គង់ មានសណ្ឋានដូចជា

ដុំពពុះទឹកដែលផុតម្ខាង ឆ្អឹងស្មងដែលទល់នឹងជង្គង់ មានសណ្ឋានដូចស្នែងគោដែលមានចុងទាល ឆ្អឹងភ្លៅ មានសណ្ឋានដូចដងកាំបិតព្រា ឬដងពូថៅដែលគគ្រាត ឆ្អឹងភ្លៅដែលទល់នឹងឆ្អឹងចង្កេះ មានសណ្ឋានដូចផ្លែអង្គញ់ ឆ្អឹងចង្កេះដែលទល់នឹងឆ្អឹងភ្លៅ មានសណ្ឋានដូចផ្លែបុស្សនាគធំ មានចុងស្រួច ឆ្អឹងចង្កេះទាំងពីរ តែជាប់គ្នា មានសណ្ឋានដូចចង្ក្រានរបស់ជាងឆ្នាំងបើបែកមួយៗ មានសណ្ឋានដូចដង្កាប់របស់ជាងមាស ឆ្អឹងត្រគាកផ្នែកខាងចុង មានសណ្ឋានដូចពពារពស់ ដែលគេចាប់ឲ្យផ្កាប់ មានប្រហោងតូចធំ ៧-៨ កន្លែង ឆ្អឹងខ្នងខាងក្នុង មានសណ្ឋានដូចក្រវិលសំណដែលដាក់តម្រួតគ្នា ឆ្អឹងខ្នងខាងក្រៅ មានសណ្ឋានដូចគ្រាប់អង្កាំ ក្នុងចន្លោះនៃឆ្អឹងខ្នងនោះៗ មានបន្ទួញ ២-៣ ដូចជាធ្មេញរណា ។ បណ្តាឆ្អឹងជំនី ២៤ កំណាត់ ចំណែកដែលបរិបូរណ៍ មានសណ្ឋានដូចផ្លែកណ្តៀវអ្នកស្រុកសីហឡៈដែលបរិបូណ៌ (កណ្តៀវត្រកង) ចំណែកដែលមិនបរិបូណ៌ មានសណ្ឋានដូចកណ្តៀវអ្នកស្រុកសីហឡៈដែលមិនបរិបូណ៌ (កណ្តៀវត្រកាត់) អាចារ្យពួកខ្លះពោលថា "ទាំងអស់នោះឯង មានសណ្ឋានដូចស្លាបទាំងពីររបស់

មាន់សំឡីដែលគេដាងចេញ” ដូច្នេះក៏មាន ។ ឆ្អឹងទ្រូង ១៤ កំណាត់ មានសណ្ឋានដូចរបាំក្រែស្នែងដែលចាស់ ឆ្អឹងបាំងបេះដូង មានសណ្ឋានដូចវែក ឆ្អឹងជងកាំបិត មានសណ្ឋានដូចជងកាំបិតលោហៈតូចៗ បណ្តាឆ្អឹងជងកាំបិតទាំងនោះ ឆ្អឹងខាងក្រោម មានសណ្ឋានដូចព្រះច័ន្ទមួយចំណិត ឆ្អឹងខ្នងដៃ មានសណ្ឋានដូចផ្លែពូថៅ អាចារ្យពួកខ្លះពោលថា “មានសណ្ឋានដូចចបអ្នកស្រុកសីហឡៈកាត់ពាក់កណ្តាល” ដូច្នេះក៏មាន ។ ឆ្អឹងដើមដៃ មានសណ្ឋានដូចជងវែនតា ឆ្អឹង.កដៃ មានសណ្ឋានដូចផ្ទៃសំពត់គ្របក្បាលដែលគេដាក់ភ្ជាប់គ្នា ឆ្អឹងខ្នងដៃ មានសណ្ឋានដូចបាច់នៃគល់វល្លិ៍ដែលគេដំហើយ ឆ្អឹងម្រាមដៃត្រង់គល់ មានសណ្ឋានដូចស្គរ ឆ្អឹងម្រាមកណ្តាល មានសណ្ឋានដូចគ្រាប់ខ្នុរមិនពេញ ឆ្អឹងម្រាមខាងចុង មានសណ្ឋានដូចគ្រាប់ផ្លែជីប៉ូ ឆ្អឹង.ក ៧ កំណាត់ មានសណ្ឋានដូចកំណាត់ទំពាំង ដែលគេប្រើឈើដោតជាចង្កាក់ ឆ្អឹងថ្គាមក្រោម មានសណ្ឋានដូចដង្កាប់ដែករបស់ជាងមាស ឆ្អឹងថ្គាមលើ មានសណ្ឋានដូចឈើជម្រះ ៧ ឆ្អឹងប្រឡង់ភ្នែក និងឆ្អឹងរន្ធច្រមុះ មានសណ្ឋានដូចប្រឡង់គ្រាប់ត្នោតខ្ចីដែលខ្វេះយកសាច់ចេញ

ឆ្អឹងថ្ពាស មានសណ្ឋានដូចសំបកស័ន្ធបែកដែលគេដាក់ផ្កាប់ ឆ្អឹងត្រចៀក មានសណ្ឋានដូចស្រោមកាំបិតកោរបស់ជាងកាត់សក់ បណ្តាឆ្អឹងថ្ពាស និង ឆ្អឹងត្រចៀក ឆ្អឹងក្នុងឱកាសដែលជាប់គ្នាផ្នែកខាងលើ មានសណ្ឋានដូចជា ចំរៀកសំពត់ចាស់បិទមាត់ក្អមពេញដោយទឹក ឆ្អឹងបង្ហើយ មានសណ្ឋាន ដូចបំណែកត្រឡោកដូងដែលគេកាត់ទទឹង ឆ្អឹងលលាដ៍ក្បាល មានសណ្ឋាន ដូចត្រឡោកឃ្លោកចាស់ដែលគេដេរភ្ជាប់គ្នា ។ ដោយទិស ឆ្អឹងទាំងឡាយ កើតក្នុងទិសទាំង ២ ។

ដោយឱកាស ឆ្អឹងទាំងឡាយតាំងនៅទូទាំងសរីរៈ មិនមានចំណែក សល់ ប៉ុន្តែពោលដោយពិសេស ឆ្អឹងសីសៈតាំងនៅលើឆ្អឹង.ក ឆ្អឹង.កតាំង នៅលើឆ្អឹងខ្នង ឆ្អឹងខ្នងតាំងនៅលើឆ្អឹងចង្កេះ ឆ្អឹងចង្កេះតាំងនៅលើឆ្អឹងភ្លៅ ឆ្អឹងភ្លៅតាំងនៅលើឆ្អឹងក្បាលជង្គង់ ឆ្អឹងក្បាលជង្គង់តាំងនៅលើឆ្អឹងស្មង ឆ្អឹង ស្មងតាំងនៅលើឆ្អឹង.កជើង ឆ្អឹង.កជើងតាំងនៅលើឆ្អឹងខ្នងជើង ឆ្អឹងខ្នងជើង ក៏លើកឆ្អឹង.កជើងឡើង ឆ្អឹង.កជើងក៏លើកឆ្អឹងជើងឡើង ។ល។ ឆ្អឹង.កក៏ លើកឆ្អឹងក្បាលឡើង ។ គប្បីជ្រាបឆ្អឹងដ៏សេស ដោយទំនងដូចពោលមក

ដូច្នោះ ។

ក្នុងឆ្អឹងទាំងនោះ កំណត់ថា ឆ្អឹងក្បាលមិនដឹងថា វាតាំងនៅលើឆ្អឹង.ក ។ល។ ឆ្អឹង.កជើង រមែងមិនដឹងថា តាំងនៅលើឆ្អឹងខ្នងជើង សូម្បីឆ្អឹងខ្នងជើង ក៏មិនដឹងថា តាំងនៅលើឆ្អឹង.កជើង ប្រៀបដូចបណ្ដាទព្វសម្ភារៈ មានឥដ្ឋ និងឈើរនុកជាដើម ឥដ្ឋជាដើមផ្នែកខាងលើរមែងមិនដឹងថា យើងតាំងនៅលើឥដ្ឋផ្នែកក្រោម ឥដ្ឋផ្នែកក្រោមជាដើម ក៏មិនដឹងថា យើងលើកឥដ្ឋផ្នែកខាងលើតាំងឡើង ដូច្នោះ ។ ព្រោះថា ឆ្អឹងទាំងនោះ វៀរចាកការត្រិះរិះ និងការពិចារណា ជាធម៌ ។ល។ មិនមែនបុគ្គល ។ ឆ្អឹង ៣០០ កំណាត់ ដែលសាងឡើងទាំងនេះ ដែលសរសៃ ៩០០ សរសៃ និងសាច់ ៩០០ ដុំ ចង និងបូកលាប បិទបាំងដោយស្បែកជាដុំតែមួយ បូកលាបដោយជ័រស្អិត ទៅតាមប្រសាទទទួលរស ៧.០០០ មានតំណក់ញើស ព្រមដោយរណ្ដៅរោម ៩៩.០០០ មានត្រកូលដង្កូវ ៨០ ត្រកូល រាប់បានថា **កាយ** ដែលព្រះយោគាវចរ កាលពិចារណាដោយសភាវៈ រមែងមិនឃើញវត្ថុអ្វីៗ ដែលគួរចូលទៅប្រកាន់យក ប៉ុន្តែនឹងឃើញគ្រោងឆ្អឹង

តែម្យ៉ាង ដែលចងរឹតដោយសរសៃ ប្រៀបដូចសាកសពផ្សេងៗ លុះឃើញហើយ រមែងចូលដល់ភាពជាឱរសរបស់ព្រះទសពល ។ ដូចដែលត្រាស់ទុកថា ៖

ឆ្អឹងទាំងឡាយតាំងចុងរៀងគ្នា ក្នុងទី.តកាគច្រើនពីកាយ
នេះ ដែលវត្ថុអ្វីៗ មិនបានចងទុក កាយនេះ សរសៃទាំងឡាយ
ចងរឹតទុក ដែលជកជាស់តឿនហើយ មិនមានចេតនា (ចិត្ត)
ឧបមាដូចកំណាត់ឈើ ។

សាកសពកើតក្នុងសាកសព របស់ស្អុយកើតក្នុងរបស់មិន
ស្អាត របស់ស្អុយកើតក្នុងរបស់ស្អុយ របស់ដែលសូន្យទៅ
កើតក្នុងរបស់ដែលបែកធ្លាយទៅ គំនរឆ្អឹងកើតក្នុងគំនរឆ្អឹង
របស់ស្អុយកើតក្នុងកាយស្អុយ អ្នកទាំងឡាយ ចូលកម្ចាត់
សេចក្តីពេញចិត្តក្នុងកាយស្អុយនោះចេញ នឹងជាបុត្ររបស់
ព្រះទសពល ។

ដោយបរិច្ឆេទ ក៏កំណត់ថា ខាងក្នុងឆ្អឹងកំណត់ដោយខួរក្នុងឆ្អឹង ខាង

ក្រៅកំណត់ដោយសាច់ ចុង និងគល់កំណត់ដោយឆ្អឹងគ្នាឯង នេះជាការកំណត់ដោយឆ្អឹងទាំងនោះដោយសភាគៈ ចំណែកការកំណត់ដោយវិសភាគៈ ក៏ដូចគ្នានឹងសក់នោះឯង ។ កំណត់ឆ្អឹងដោយវណ្ណៈជាដើម មានប្រការដូចពោលមកហើយនោះឯង ។

## អដ្ឋិមិញ្ជំ (ខួរក្នុងឆ្អឹង)

តអំពីនោះទៅ ក៏កំណត់ថា ខួរក្នុងឆ្អឹង នៅខាងក្នុងឆ្អឹងទាំងឡាយមានប្រភេទតាមដែលពោលហើយក្នុងសរីរៈ ដោយវណ្ណៈថា មានពណ៌ស ។ ដោយសណ្ឋានដូចឱកាសរបស់ខ្លួន គឺ ខួរឆ្អឹងដែលនៅខាងក្នុងឆ្អឹងទាំងឡាយខ្នាតធំៗ មានសណ្ឋានដូចពន្លកស្ពៅ ដែលគេស៊កទុកក្នុងបំពង់ឫស្សី និងដើមបបុសខ្នាតធំ ។ ខួរឆ្អឹងដែលនៅក្នុងឆ្អឹងខ្នាតតូចៗ មានសណ្ឋានដូចពន្លកស្ពៅតូចៗ ដែលគេស៊កទុកក្នុងបំពង់ឫស្សី និងដើមបបុសតូចៗ ។ ដោយទិស កើតនៅក្នុងទិសទាំងពីរ ។ ដោយឱកាស តាំងនៅខាងក្នុងឆ្អឹងទាំងឡាយ ។

ខួរឆ្អឹងនោះកំណត់ថា ខួរឆ្អឹងរមែងមិនដឹងថា យើងតាំងនៅក្នុងឆ្អឹង

សូម្បីឆ្អឹងក៏មិនដឹងថា ខួរឆ្អឹងនៅក្នុងយើង ប្រៀបដូចទឹកដោះ និងទឹកអំពៅ នៅក្នុងបំពង់ឫស្សី និងដើមបបុសជាដើម រមែងមិនដឹងថា យើងនៅក្នុង បំពង់ឫស្សី និងដើមបបុសជាដើម សូម្បីដើមឫស្សី និងដើមបបុសជាដើម ក៏មិនដឹងថា ទឹកដោះ និងទឹកអំពៅនៅខាងក្នុងយើង ដូច្នោះ ។ ពិតហើយ ធម៌ទាំងនេះ វៀរចាកការត្រិះរិះ និងការពិចារណា ជាធម៌ ។ល។ មិន មែនបុគ្គល ។ ដោយបរិច្ឆេទ ខួរក្នុងឆ្អឹង គប្បីកំណត់ដោយចំណែកខាង ក្នុងឆ្អឹងទាំងឡាយ នៃខួរក្នុងឆ្អឹង នេះជាការកំណត់ខួរក្នុងឆ្អឹងនោះ ។ នេះ ជាការកំណត់ខួរក្នុងឆ្អឹងនោះ ដោយសភាគ: , ចំណែកការកំណត់ដោយ វិសភាគ: ក៏ដូចគ្នានឹងសក់នោះឯង ។ កំណត់ខួរក្នុងឆ្អឹងដោយវណ្ណ:ជា ដើម មានប្រការដូចពោលមកហើយ ។

## វក្កំ (តម្រងបស្សាវៈ)

តពីនោះទៅ កំណត់ថា វក្កំ បានដល់ ដុំសាច់ ២ ដុំ មានទងតែ មួយ នៅខាងក្នុងសរីរៈ ។ ដោយវណ្ណ: មានពណ៌ក្រហមព្រឿងៗ ដូច ពណ៌គ្រាប់រលួសបាយ ។ ដោយសណ្ឋាន មានសណ្ឋានដូចកូនប៊ូលរបស់

ក្មេងអ្នកស្រុក ដែលដោតដោយអំបោះបោះលេង អាចារ្យពួកខ្លះពោលថា មានសណ្ឋានដូចស្វាយ ២ ផ្លែ ទងតែមួយ ដូច្នេះក៏មាន ។ ដោយទិស តម្រងបស្សាវៈ កើតក្នុងទិសខាងលើ ។ ដោយឱកាស តម្រងបស្សាវៈ នោះ ជាប់នឹងសរសៃធំ មានគល់សរសៃតែមួយ បែកចេញមកពីបំពង់ក ទៅបន្តិច ក៏បែកចេញជា ២ រុំព័ទ្ធបេះដូង ហើយតាំងនៅ ។

បណ្តាតម្រងបស្សាវៈទាំងនោះ ក៏កំណត់ថា តម្រងបស្សាវៈរមែង មិនដឹងថា យើងត្រូវសរសៃធំចង សូម្បីសរសៃធំក៏មិនដឹងថា យើងជា អ្នកចង ប្រៀបដូចស្វាយ ២ ផ្លែ មានទងតែមួយ រមែងមិនដឹងថា យើង ត្រូវជាប់ដោយទង សូម្បីទងក៏មិនដឹងថា យើងជាប់ដោយស្វាយ ២ ផ្លែ ដូច្នោះ ។ ព្រោះថា ធម៌ទាំងនោះវៀរចាកការនឹកគិត និងពិចារណា ជា ធម៌ ។ល។ មិនមែនបុគ្គល ។ ដោយបរិច្ឆេទថា តម្រងបស្សាវៈ កំណត់ ដោយចំណែកនៃតម្រងបស្សាវៈ នេះជាការកំណត់តម្រងបស្សាវៈនោះ ដោយ សភាគៈ ចំណែកការកំណត់ដោយវិសភាគៈ ក៏ដូចគ្នានឹងសក់នោះឯង ។ កំណត់ដោយវណ្ណៈជាដើម មានប្រការដូចពោលមកដូច្នេះ ។

## ហទយំ (បេះដូង)

តពីនោះទៅ ក៏កំណត់ថា បេះដូងមាននៅក្នុងសរីរៈ ដោយវណ្ណៈ បេះដូងមានពណ៌ក្រហម ដូចស្រទាប់នៃផ្កាឈូកក្រហម ។ ដោយសណ្ឋាន បេះដូង មានសណ្ឋានដូចផ្កាឈូកក្រពុំបកស្រទាប់ក្រៅចេញហើយ ដាក់សំយ៉ុងចុះ ។ ក៏បេះដូងនោះ ម្ខាងដូចផ្លែបុស្សនាគកាត់ចុង ខាងក្រៅរលីង ខាងក្នុងដូចផ្លែននោព្រៃ ។ បេះដូងរបស់អ្នកមានបញ្ញាច្រើន រីកធំបន្តិច របស់អ្នកមានបញ្ញាតិច ក្រពុំធម្មតា ។ មនោធាតុ និងមនោវិញ្ញាណធាតុ អាស្រ័យរូបណាប្រព្រឹត្តទៅ រូបនោះហៅថា បេះដូង ឈាមដែលដក់នៅប្រមាណកន្ទះទូកដៃខាងក្នុងបេះដូង ពោលគឺ ជុំសាច់ដ៏សេស ឈាមនោះ របស់បុគ្គលរាគចរិត ពណ៌ក្រហម , របស់បុគ្គលទោសចរិត ពណ៌ខ្មៅ , របស់បុគ្គលមោហចរិត មានពណ៌ដូចទឹកលាងសាច់ , របស់បុគ្គលវិតក្កចរិត មានពណ៌ដូចទឹកសណ្តែក , របស់បុគ្គលសទ្ធាចរិត មានពណ៌ដូចផ្កាកណ្ណិកា , របស់បុគ្គលបញ្ញាចរិត ស្រស់ថ្លាមិនល្អក់កករ ដូចកែវមណីដ៏រុងរឿងពីកំណើតដែលជម្រះហើយ ។ ដោយទិស បេះដូងកើតក្នុងទិស

ខាងលើ ។ ដោយឱកាស បេះដូង តាំងនៅត្រង់កណ្ដាល (ចន្លោះ) ដោះទាំង ២ ខាងក្នុងសរីរៈ ។

ក្នុងបេះដូងនោះ កំណត់ថា បេះដូងរមែងមិនដឹងថា យើងតាំងនៅកណ្ដាលដោះទាំង ២ សូម្បីដោះក៏មិនដឹងថា បេះដូងតាំងនៅត្រង់កណ្ដាលយើង ប្រៀបដូចជាគន្លឹះតាំងនៅកណ្ដាលនៃមេបង្អួច និងទ្វារទាំង ២ សូម្បីបង្អួច និងទ្វារក៏មិនដឹងថា គន្លឹះស៊កនៅត្រង់កណ្ដាលយើង ដូច្នោះ ។ ព្រោះថា ធម៌ទាំងនោះវៀរចាកការត្រិះរិះ ការពិចារណា ជាធម៌ ។ល។ មិនមែនបុគ្គល ។ ដោយបរិច្ឆេទ ក៏កំណត់ថា បេះដូង កំណត់ដោយចំណែកនៃបេះដូង នេះជាការកំណត់បេះដូងនោះដោយសភាគៈ ចំណែកការកំណត់ដោយវិសភាគៈ ក៏ដូចគ្នានឹងសក់នោះឯង ។ កំណត់បេះដូងដោយវណ្ណៈជាដើម មានប្រការដូចពោលមកហើយនោះឯង ។

## យកនំ (ថ្លើម)

តពីនោះទៅ ក៏កំណត់ថា ចំរៀកដុំសាច់មួយគូ ដែលគេសម្គាល់ថា **យកនៈ** (ថ្លើម) មានក្នុងសរីរៈ ។ ដោយវណ្ណៈ ថ្លើមមានពណ៌ក្រហម ដូច

ពណ៌ស្រទាប់ខាងក្រៅផ្កាកុមុទក្រហម ។ ដោយសណ្ឋាន មានគល់មួយ មានសណ្ឋាន ចុងពីរ មានសណ្ឋានដូចស្លឹករលួសផ្អុង ។ ក៏ថ្លើមរបស់មនុស្សអ្នកមានបញ្ញាទន់ខ្សោយ មានផែកមួយប៉ុន្តែធំ ថ្លើមរបស់មនុស្សអ្នកមានបញ្ញា មានផែក ២ ឬ ៣ ប៉ុន្តែតូចៗ ។ ដោយទិស ថ្លើមកើតក្នុងទិសខាងលើ ។ ដោយឱកាស ថ្លើមអាស្រ័យនៅត្រង់ចន្លោះនៃដោះទាំង ២ ផ្អៀងទៅខាងស្តាំ ។

ក្នុងថ្លើមនោះ កំណត់ថា ថ្លើមរមែងមិនដឹងថា យើងអាស្រ័យនៅផ្នែកខាងស្តាំ ត្រង់ចន្លោះនៃដោះទាំង ២ សូម្បីផ្នែកខាងស្តាំត្រង់ចន្លោះនៃដោះទាំង ២ នោះ ក៏មិនដឹងថា ថ្លើមអាស្រ័យយើងហើយតាំងនៅ ប្រៀបដូចចំរៀកសាច់ដែលចងព្យួរនៅជិតឆ្នាំង រមែងមិនដឹងថា យើងព្យួរនៅជិតឆ្នាំង សូម្បីឆ្នាំងក៏មិនដឹងថា មានចំរៀកសាច់ព្យួរនៅជិតយើង ដូច្នោះ ។ ព្រោះថា ធម៌ទាំងនេះ វៀរចាកការគិត និងការពិចារណា ជាធម៌ ។ល។ មិនមែនបុគ្គល ។ ដោយបរិច្ឆេទ កំណត់ថា ថ្លើមកំណត់ដោយចំណែកនៃថ្លើមនោះឯង នេះជាការកំណត់ថ្លើមនោះដោយសភាគៈ ចំណែកការកំណត់

ដោយវិសភាគៈ ក៏ដូចគ្នានឹងសក់នោះឯង ។ កំណត់ថ្ងើមដោយវណ្ណៈជាដើម មានប្រការដូចពោលមកដូច្នេះ ។

## កិលោមកំ (វាវ)

តពីនោះទៅ កំណត់ថា **កិលោមកំ** មានក្នុងសរីរៈនេះ ដោយវណ្ណៈ វាវមាន ២ ប្រភេទ គឺ ប្រភេទមិនប្រាកដឲ្យឃើញ និងប្រភេទប្រាកដឲ្យឃើញ មានពណ៌ស ដូចសំពត់ទុកូលចាស់ ។ ដោយសណ្ឋាន មានសណ្ឋានដូចឱកាសរបស់ខ្លួន ។ ដោយទិស កើតក្នុងទិសទាំង ២ ។ ដោយឱកាស វាវប្រភេទមិនប្រាកដ រុំព័ទ្ធបេះដូងផង និងតម្រងបស្សាវៈផង ហើយតាំងនៅ ។ វាវប្រភេទប្រាកដ ពាសនៅលើសាច់ក្រោមស្បែកទូទាំងសរីរៈ ហើយតាំងនៅ ។

បណ្ដាវាវទាំងនោះ កំណត់ថា វាវរមែងមិនដឹងថា យើងត្រូវរុំព័ទ្ធបេះដូង និងតម្រងបស្សាវៈ និងស្ថិតនៅលើសាច់ក្រោមស្បែកទូទាំងសរីរៈ សូម្បីបេះដូង និងតម្រងបស្សាវៈ និងសាច់ទូទាំងសរីរៈ ក៏រមែងមិនដឹងថា យើងត្រូវវាវរុំព័ទ្ធដែរ ប្រៀបដូចជាសាច់ដែលត្រូវសំពត់ទុកូលចាស់រុំព័ទ្ធ

សំពត់ទុកូលចាស់ ក៏រមែងមិនដឹងថា យើងរុំព័ទ្ធសាច់ សូម្បីសាច់ក៏រមែង មិនដឹងថា យើងត្រូវសំពត់ទុកូលចាស់រុំព័ទ្ធ ដូច្នោះ ។ ព្រោះថា ធម៌ទាំង នោះ វៀរចាកការគិត និងការពិចារណា ជាធម៌ ។ល។ មិនមែនបុគ្គល ។ ដោយបរិច្ឆេទ ក៏កំណត់ថា វាវ ចំណែកខាងក្រោមកំណត់ដោយសាច់ ខាងលើកំណត់ដោយស្បែក ខាងទទឹងកំណត់ដោយចំណែកនៃវាវ នេះជា ការកំណត់វាវទាំងនោះដោយសភាគ: ចំណែកការកំណត់ដោយវិសភាគ: ក៏ដូចគ្នានឹងសក់នោះឯង ។ ការកំណត់វាវដោយវណ្ណ:ជាដើម មានប្រការ ដូចពោលមកហើយ ដូច្នេះ ។

## បិហកំ (ក្រពះ)

តពីនោះទៅ ក៏កំណត់ថា ខាងក្នុងសរីរ: ក្រពះ ដោយវណ្ណ:មាន ពណ៌ខៀវ មានពណ៌ដូចផ្កាគន្ធីសក្រៀម ។ ដោយសណ្ឋាន ភាគច្រើន មានសណ្ឋានដូចអណ្តាតកូនគោខ្មៅមិនព័ន្ធគ្នា មានប្រមាណ ៧ ធ្នាប់ ។ ដោយទិស កើតនៅក្នុងទិសខាងលើ ។ ដោយឱកាស ក្រពះតាំងនៅខាង ឆ្វេងនៃបេះដូង ផ្នែកខាងលើផ្ទៃពោះ ។ កាលចេញមកខាងក្រៅ ព្រោះ

ត្រូវប្រហារដោយគ្រឿងប្រហារ សត្វក៏អស់ជីវិត ។

ក្នុងក្រពះនោះ ក៏កំណត់ថា ក្រពះរមែងមិនដឹងថា យើងអាស្រ័យនៅខាងលើផ្ទៃពោះ សូម្បីចំណែកខាងលើផ្ទៃពោះ ក៏រមែងមិនដឹងថា ក្រពះអាស្រ័យយើងហើយតាំងនៅ ប្រៀបដូចដុំអាចម៍គោ អាស្រ័យនៅខាងលើពោះហើយតាំងនៅ រមែងមិនដឹងថា យើងអាស្រ័យនៅលើពោះហើយតាំងនៅ សូម្បីចំណែកខាងលើនៃពោះ ក៏មិនដឹងថា ដុំអាចម៍គោអាស្រ័យនៅលើយើង ដូច្នោះ ព្រោះថា ធម៌ទាំងនោះ វៀរចាកការគិត និងការពិចារណា ជាធម៌ ។ល។ មិនមែនបុគ្គល ។ ដោយបរិច្ឆេទ កំណត់ថា ក្រពះកំណត់ដោយចំណែកនៃក្រពះ នេះជាការកំណត់ក្រពះនោះ ដោយសភាគៈ ចំណែកការកំណត់ដោយវិសភាគៈ ក៏ដូចគ្នានឹងសក់នោះឯង ។ ការកំណត់ដោយវណ្ណៈជាដើម មានប្រការដូចពោលមកហើយ ។

### បប្ផាសំ (សួត)

តពីនោះទៅ ក៏កំណត់ថា ខាងក្នុងសរីរៈ សួត ជាប្រភេទដុំសាច់តូចៗ ៣២ ចំរៀក ដោយវណ្ណៈថា មានពណ៌ក្រហមដូចផ្លែកល្ហាស្រគាល ។

ដោយសណ្ឋាន មានសណ្ឋានដូចនំដែលកាត់មិនស្មើ អាចារ្យពួកខ្លះពោលថា "មានសណ្ឋានដូចគំនរផេ្ទសម្រាប់រៀបកំពែង" ដូច្នេះក៏មាន ។ ស្អូតនោះ មិនមានរស មិនមានឱជា ដូចចំបើងដែលសត្វទំពាស៊ីហើយ ព្រោះត្រូវប៉ះខ្ទប់នឹងចំហាយក្តៅដែលកើតពីកម្មផ្សាយឡើង ព្រោះមិនមានអាហារដែលទំពារ និងផឹកចូលទៅ ។ ដោយទិស ស្អូតកើតក្នុងទិសខាងលើ ។ ដោយឱកាស ស្អូតតាំងសំយុងចុះក្រោម ក្រសោបបេះដូង និងថ្លើម ចន្លោះដោះទាំង ២ ខាងក្នុងសរីរៈ ។

បណ្តាស្អូតទាំងនោះ ក៏កំណត់ថា ស្អូតរមែងមិនដឹងថា យើងព្យួរត្រង់ចន្លោះដោះទាំង ២ ខាងក្នុងសរីរៈ សូម្បីដោះទាំង ២ ក្នុងសរីរៈ ក៏មិនដឹងថា ស្អូតតាំងព្យួរក្នុងយើង ប្រៀបដូចសំបុកសត្វតាំងព្យួរខាងក្នុងជម្រុកចាស់ រមែងមិនដឹងថា យើងព្យួរខាងក្នុងជម្រុកចាស់ សូម្បីជម្រុកចាស់ ក៏មិនដឹងថា សំបុកសត្វតាំងព្យួរខាងក្នុងយើង ដូច្នោះ ។ ព្រោះថាធម៌ទាំងនោះ វៀរចាកការគិត និងការពិចារណា ជាធម៌ៗលៗ មិនមែនបុគ្គល ។ នេះជាការកំណត់ស្អូតនោះ ដោយសភាគៈ ចំណែកការកំណត់

ដោយវិសភាគៈ ក៏ដូចគ្នានឹងសក់នោះឯង ។ ការកំណត់សួតដោយវណ្ណៈជាដើម មានប្រការដូចពោលមកហើយ ។

## អន្តំ (ពោះវៀនធំ)

តពីនោះទៅ ក៏កំណត់ថា ខាងក្នុងសរីរៈ ដោយវណ្ណៈ ពោះវៀនធំបត់ជា ២១ ផ្នត់ មានប្រវែង ៣២ ហត្ថ សម្រាប់បុរស ប្រវែង ២៨ ហត្ថ សម្រាប់ស្ត្រី មានពណ៌ស ដូចពណ៌ស្ករស ឬកំបោរស ។ ដោយសណ្ឋាន ពោះវៀនធំ មានសណ្ឋានដូចពស់ដែលគេកាត់ក្បាលដាក់ធ្លាយទុកក្នុងថ្លុកឈាម ។ ដោយទិស កើតក្នុងទិសទាំង ២ ។ ដោយឱកាស ពោះវៀនធំ តាំងនៅខាងក្នុងសរីរៈ តាំងអំពីក រហូតដល់ផ្លូវចេញករីសៈ (ឧច្ចារៈ) ជាទីបំផុត ព្រោះជាប់នឹងបំពង់កខាងលើ និងខាងក្រោមដល់ផ្លូវដើរករីសៈ ។

ក្នុងពោះវៀនធំនោះ ក៏កំណត់ថា ពោះវៀនធំរមែងមិនដឹងថា យើងតាំងនៅខាងក្នុងសរីរៈ សូម្បីសរីរៈក៏មិនដឹងថា ពោះវៀនធំតាំងនៅក្នុងយើង ប្រៀបដូចរាងកាយសត្វពស់ដាច់ក្បាល ដែលតាំងនៅក្នុងថ្លុកឈាម រមែង

មិនដឹងថា យើងតាំងនៅក្នុងថ្កុកឈាម សូម្បីថ្កុកឈាម ក៏មិនដឹងថា រាង កាយសត្វពស់ជាប់ក្បាល តាំងនៅក្នុងយើង ។ ព្រោះថា ធម៌ទាំងនោះ វៀរចាកការនឹកគិត និងការពិចារណា ជាធម៌ ។ល។ មិនមែនបុគ្គល ។ ដោយបរិច្ឆេទ ក៏កំណត់ថា ពោះវៀនធំកំណត់ដោយចំណែកនៃពោះវៀន ធំ នេះជាការកំណត់ពោះវៀនធំដោយសភាគៈ ចំណែកការកំណត់ដោយ វិសភាគៈ ក៏ដូចគ្នានឹងសក់នោះឯង ។

## អន្តគុណំ (ពោះវៀនតូច)

តពីនោះទៅ ក៏កំណត់ថា ខាងក្នុងសរីរៈ ដោយវណ្ណៈ ពោះវៀនតូច នៅក្នុងចន្លោះពោះវៀនធំ មានពណ៌ស ដូចក្រអៅឈូក ។ ដោយសណ្ឋាន ពោះវៀនតូច មានសណ្ឋានដូចក្រអៅឈូកនោះឯង អាចារ្យពួកខ្លះពោលថា "មានសណ្ឋាន ដូចទឹកនោមគោ" ដូច្នេះ ក៏មាន ។ ដោយទិស ពោះវៀន តូច កើតក្នុងទិសទាំង ២ ។ ដោយឱកាស ពោះវៀនតូចតោងជាប់ពោះ-វៀនធំ ដូចខ្សែដែលរុំនឹងកង់រុំរបស់ជាងធ្វើការងារផ្សេងៗ មានការបោះ នឹងការចាំងជាដើម តាំងនៅចន្លោះពោះវៀនធំ ២១ ផ្នត់ ដូចខ្សែដែលក្រង

សម្រាប់ជូតជើង តាំងនៅចន្លោះខ្សែសម្រាប់ជូតជើងនោះឯង ។

ក្នុងពោះវៀនតូចនោះ ក៏កំណត់ថា ពោះវៀនតូចរមែងមិនដឹងថា យើងតោងពោះវៀនធំ ខាងក្នុងពោះវៀនធំ ២១ ផ្នត់ សូម្បីពោះវៀនធំ ក៏មិនដឹងថា ពោះវៀនតូចតោងយើង ប្រៀបដូចខ្សែ (តូចៗ) ជោតក្រង ខ្សែសម្រាប់ជូតជើង (ខ្សែធំ) រមែងមិនដឹងថា យើងចងខ្សែជូតជើង សូម្បី ខ្សែជូតជើង ក៏មិនដឹងថា ខ្សែតូចៗ ចងយើង ដូច្នេះ ។ ព្រោះថា ពោះ-វៀនតូចនេះ វៀរចាកការគិត និងការពិចារណា ជាធម៌ ។ល។ មិនមែន បុគ្គល ។ ដោយបរិច្ឆេទ ក៏កំណត់ថា ពោះវៀនតូច កំណត់ដោយចំណែក នៃពោះវៀនតូច នេះជាការកំណត់ពោះវៀនតូចដោយសភាគៈ ចំណែកការ កំណត់ដោយវិសភាគៈ ក៏ដូចគ្នានឹងសក់នោះឯង ។ ការកំណត់ពោះវៀនតូច ដោយវណ្ណៈជាដើម មានប្រការដូចពោលមកហើយ ។

## ឧទរិយំ (អាហារថ្មី)

តពីនោះទៅ ក៏កំណត់ថា ក្នុងសរីរៈ ដោយវណ្ណៈ អាហារថ្មី មាន ពណ៌ដូចអាហារដែលលេបចូលទៅ ។ ដោយសណ្ឋាន មានសណ្ឋានដូច

អន្ទរដែលបន្ដូរៗ ក្នុងសំពត់តម្រងទឹក ។ ដោយទិស អាហារថ្មីកើត នៅក្នុងទិសខាងលើ ។ ដោយឱកាស អាហារថ្មីតាំងនៅក្នុងពោះ (ក្រពះអាហារ) ។ ធម្មតា ពោះ ជាថង់របស់ពោះវៀនធំ ប៉ោងដោយខ្យល់កើតឯងត្រង់កណ្ដាល ដូចសំពត់សើមដែលត្រូវបន្ដុងសងខាង ចំណែកខាងក្រៅរលោង ខាងក្នុងដូចជាសំពត់ជូតឈាមរដូវ ហើយគេយកខ្ចប់សាច់ អាចារ្យពួកខ្លះពោលថា "ដូចខាងក្នុងផ្លែខ្នុរស្អោរ" ដូច្នេះក៏មាន ។ ក្នុងពោះនោះ មានដង្កូវផ្សេងៗ ៣២ ត្រកូល គឺ ត្រកូលតក្កោដកៈ (ព្រូនទំពក់) គណ្ឌុប្បាទកៈ (ដូចជន្លេន) តាលហិរកៈ (ព្រូនចង្កឹះ) សូចិមុខៈ (ព្រូនមាត់ស្រួច) កាបដៈ (ព្រូនសំប៉ែត) តន្តុ (តេនញ៉ា) សុត្តកៈ (ព្រូនអំបោះ-អៀន) ជាដើម ប្រជ្រៀតជេញគ្នាដណ្ដើមចំណី អាស្រ័យជាប្រចាំ កាលមិនបានអាហារ មានទឹក និងបាយជាដើម ក៏ធ្វេធ្វាខាំសាច់បេះដូង និងវេលាដែលមនុស្សលេបអាហារចូលទៅ មានទឹក និងបាយជាដើម ក៏បែរមុខមកដណ្ដើមអាហារ ២-៣ ដុំ ដែលមនុស្សលេបចូលទៅគ្រាដំបូង (ពោះ) ទើបក្លាយជាផ្ទះដង្កូវ ជាបង្គន់ ជារោងព្យាបាល និងជាព្រៃស្មសាន

របស់ជន្តុវទាំងនោះ ប្រៀបដូចនៅក្នុងសារទរដូវ ភ្លៀងគ្រាប់ថ្លោសៗ បង្អុរចុះមកក្នុងស្រះស្មោកគ្រោក ជិតទ្វារស្រុកនៃមនុស្សចណ្ឌាល សំណល់ផ្សេងៗមានឧច្ចារៈ បស្សាវៈ ចំរៀកស្បែក ឆ្អឹង សរសៃ ទឹកមាត់ ទឹកសំបោរនិងឈាមជាដើម ត្រូវទឹកនាំមក រួមប្រមូលប្របល់គ្នា ក៏មានត្រកូលជន្តុវតូចធំកើតឯង កន្លងទៅ ២-៣ ថ្ងៃ ក៏ក្តៅដោយពន្លឺថ្ងៃ កកើតមានពពុះខាងលើ មានពណ៌ខៀវ មានក្លិនស្អុយ និងគួរខ្ពើមក្រៃលែង មិនសមគួរនឹងចូលទៅជិត ឬមើល មិនចាំបាច់ពោលទៅថ្វីដល់ការ ស្រូបក្លិន ឬលិទ្ធរស មានឧបមាយ៉ាងណា ទឹក និងបាយជាដើម មានប្រការផ្សេងៗ ក៏ដូច្នោះដូចគ្នា ដែលអង្រែ គឺ ធ្មេញបុកល្អិតហើយ ដៃ គឺ អណ្តាតគ្រវីត្រឡប់ទៅមកហើយ ប្របល់ដោយទឹកមាត់ មានការប្រាកដព្រមដោយពណ៌ក្លិន រស ក្នុងខណៈនោះជាដើម ដូចកំអួតក្នុងរាងកាយរបស់សុនខ ប្រមូលប្របល់ដោយស្លេស្ម ក្តៅដោយកំដៅភ្លើងក្នុងពោះ មានត្រកូលជន្តុវតូចធំបណ្តែតពងឡើងលើ ក៏ក្លាយទៅជាគំនរសម្រាម មានក្លិនស្អុយ គួរខ្ពើមយ៉ាងក្រៃលែង ដែលបានឮហើយធ្វើឲ្យមិនចង់ផឹក បរិភោគបាយជាដើម

មិនបាច់ពោលថ្វីដល់បញ្ញាចក្ខុនោះ ព្រោះជាទីកន្លែងនៃទឹក និងបាយជាដើម ធ្លាក់ចុះទៅហើយ និងបែងចែកជា ៥ ចំណែក គឺ ១.សម្រាប់សត្វក្នុងពោះស៊ី ២.សម្រាប់ភ្លើងក្នុងពោះដុត ៣.ក្លាយទៅជាបស្សាវ: ៤.ក្លាយទៅជាឧច្ចារ: ៥.ក្លាយទៅជារស (ឱជ:) ដែលទំនុកបម្រុងដល់រាងកាយ មានឈាម និងសាច់ជាដើម ។

ក្នុងអាហារថ្មីនោះ ក៏កំណត់ថា អាហារថ្មីរមែងមិនដឹងថា យើងនៅក្នុងពោះដែលមានក្លិនស្អុយ គួរខ្ពើមយ៉ាងក្រៃលែង សូម្បីពោះក៏មិនដឹងថា អាហារថ្មីនៅខាងក្នុងយើង ប្រៀបដូចកំអួតសុនខ ដែលនៅក្នុងពោះសុនខ គួរខ្ពើមយ៉ាងក្រៃលែង សូម្បីពោះសុនខ ក៏មិនដឹងថា កំអួតនៅក្នុងពោះយើង ដូច្នេះ ។ ព្រោះថា ធម៌ទាំងនោះវៀរចាកការត្រិះរិះ ការពិចារណា ជាធម៌ ។ល។ មិនមែនបុគ្គល ។ ដោយបរិច្ឆេទ ក៏កំណត់ថា អាហារថ្មី កំណត់ដោយចំណែកអាហារថ្មី នេះជាការកំណត់អាហារថ្មីនោះដោយសភាគ: ចំណែកការកំណត់ដោយវិសភាគ: ក៏ដូចគ្នានឹងសក់នោះឯង ។ ការកំណត់អាហារថ្មី ដោយវណ្ណ:ជាដើម មានប្រការដូចពោលហើយ

នោះឯង ។

## ករីសំ (អាហារចាស់)

តអំពីនោះទៅ ក៏កំណត់ថា ក្នុងសរីរៈ ដោយច្រើន ដោយវណ្ណៈ អាហារចាស់ ក៏មានពណ៌ដូចអាហារដែលលេបចូលទៅ ។ ដោយសណ្ឋាន ក៏មានសណ្ឋានដូចឱកាស ។ ដោយទិស កើតក្នុងទិសខាងក្រោម ដោយឱកាស តាំងនៅត្រង់អាហារដែលរលួយហើយ ។ ធម្មតា ប្រទេសដែលអាហាររលួយហើយនៅអាស្រ័យ ក៏ជាប្រទេសដូចខាងក្នុងបំពង់ឫស្សី និងដើមបបុស មានកម្ពស់ប្រមាណ ៨ ធ្នាប់ នៅចុងពោះវៀនធំ រវាងគល់ពោះវៀនតូច និងឆ្អឹងខ្នងខាងក្រោម ប្រៀបដូចទឹកភ្លៀងធ្លាក់អំពីទីខ្ពស់ ក៏ហូរចុះធ្វើទីខាងក្រោម (ទាប) ឲ្យពេញ យ៉ាងណា ទឹក និងបាយជាដើមណាមួយ ដែលធ្លាក់ទៅកាន់ទីនៅរបស់អាហារថ្មី ដែលភ្លើងក្នុងពោះដុតឲ្យឆ្អិន ឲ្យល្អិតដូចម្សៅ ព្រោះភ្លើងធាតុធ្វើឲ្យល្អិតហើយ ក៏ហូរទៅតាមពោះ-វៀនធំ រឹតប្រចាប់សន្សំទុក ដូចដីឥដ្ឋ ដែលគេដាក់ក្នុងបំពង់ឫស្សី និងដើមបបុស ក៏យ៉ាងនោះ ។

ក្នុងអាហារចាស់នោះ ក៏កំណត់ថា អាហារចាស់រមែងមិនដឹងថា យើងនៅក្នុងទីនៅនៃអាហារដែលរលួយហើយ សូម្បីទីនៅនៃអាហារចាស់ដែលរលួយហើយ ក៏មិនដឹងថា អាហារចាស់នៅក្នុងយើង ប្រៀបដូចដីឥដ្ឋ ដែលគេច្រកក្នុងបំពង់ឫស្សី ឬក្នុងដើមបបុស រមែងមិនដឹងថា យើងនៅក្នុងបំពង់ឫស្សី ឬដើមបបុស សូម្បីបំពង់ឫស្សី និងដើមបបុស ក៏មិនដឹងថា ដីឥដ្ឋនៅក្នុងយើង ដូច្នោះ ។ ព្រោះថា ធម៌ទាំងនោះ វៀរចាកការត្រិះរិះ ការពិចារណា ជាធម៌ ។ល។ មិនមែនបុគ្គល ។ ដោយបរិច្ឆេទ ក៏កំណត់ថា អាហាចាស់ កំណត់ដោយចំណែកនៃអាហារចាស់ នេះជាការកំណត់អាហារចាស់នោះដោយសភាគៈ ចំណែកការកំណត់ដោយវិសភាគៈ ក៏ដូចគ្នានឹងសក់នោះឯង ។ ការកំណត់អាហារចាស់ ដោយវណ្ណៈជាដើម មានប្រការដូចពោលមកហើយ ដូច្នេះឯង ។

## មត្ថលុង្គំ (ខួរក្នុងក្បាល)

តពីនោះទៅ ក៏កំណត់ថា ក្នុងសរីរៈ ដោយវណ្ណៈ ខួរក្បាលនៅក្នុងលលាដ៍ក្បាល មានពណ៌សដូចផ្សិត ។ អាចារ្យពួកខ្លះពោលថា "មាន

ពណ៌ដូចទឹកដោះជាំពុះ” ដូច្នេះក៏មាន ។ ដោយសណ្ឋាន មានសណ្ឋាន ដូចឱកាស ។ ដោយទិស កើតក្នុងទិសខាងលើ ។ ដោយឱកាស ជាប្រភេទដុំខួរ ៤ ដុំ ដែលតម្រៀបលើក្រោមគ្នា ជា ៤ សំណុំ ខាងក្នុងលលាដ៍ក្បាល តាំងនៅដូចដុំម្សៅ ៤ ដុំ ដែលគេតម្រៀបទុក ។

ខួរក្នុងក្បាលនោះ ក៏កំណត់ថា ខួរក្នុងក្បាលរមែងមិនដឹងថា យើងតាំងនៅក្នុងលលាដ៍ក្បាល សូម្បីលលាដ៍ក្បាល ក៏មិនដឹងថា ខួរក្បាលនៅតាំងនៅក្នុងយើង ប្រៀបដូចដុំម្សៅ ដែលគេដាក់ទុកក្នុងត្រឡោកឃ្លោកចាស់ ឬទឹកដោះជាំពុះ រមែងមិនដឹងថា យើងតាំងនៅក្នុងត្រឡោកឃ្លោកចាស់ សូម្បីត្រឡោកឃ្លោកចាស់ ក៏មិនដឹងថា ដុំម្សៅ ឬទឹកដោះជាំពុះនៅក្នុងយើង ដូច្នោះ ។ ព្រោះថា ធម៌ទាំងនោះ វៀរចាកការគិត និងការពិចារណា ជាធម៌ ។ល។ មិនមែនបុគ្គល ។ ដោយបរិច្ឆេទកំណត់ថា ខួរក្នុងក្បាលកំណត់ដោយចំណែកនៃខួរក្នុងក្បាល នេះជាការកំណត់ខួរក្បាលនោះដោយសភាគៈ ចំណែកការកំណត់ដោយវិសភាគៈ ក៏ដូចគ្នានឹងសក់នោះឯង ។ ការកំណត់ខួរក្នុងក្បាល ដោយវណ្ណៈជាដើម មានប្រការដូច

ពោលមកហើយនោះឯង ។

## បិត្តំ (ប្រមាត់)

តពីនោះ ក៏កំណត់ថា ប្រមាត់មាន ២ ប្រភេទ គឺ ប្រមាត់ក្រៅស្រោម និងប្រមាត់ក្នុងស្រោម មានពណ៌ដូចប្រេងស្រគំចាស់ ។ អាចារ្យពួកខ្លះពោលថា "ប្រមាត់ក្រៅស្រោម មានសណ្ឋានដូចផ្កាថ្កុលក្រៀម" ដូច្នេះក៏មាន ។ ដោយសណ្ឋាន មានសណ្ឋានដូចឱកាស ។ ដោយទិស កើតក្នុងទិសទាំង ២ ។ ដោយឱកាស ប្រមាត់ក្រៅស្រោម វៀរត្រង់ក្រចក រោម សក់ និងធ្មេញ ដែលដុះផុតពីសាច់ និងស្បែកក្រិនចេញ ជ្រាបពេញក្នុងសរីរៈ ចំណែកដ៏សេស ដូចដំណក់ប្រេងជ្រាបទឹក កាលកម្រើកហើយភ្នែកនឹងមានពណ៌លឿង វិលមុខ ញ័រខ្លួន និងរមាស់ ។ ប្រមាត់ក្នុងថង់តាំងនៅក្នុងថង់ទឹកប្រមាត់ ដូចសំបកននោងព្រៃធំ (ក្រហម) អាស្រ័យសាច់ថ្លើមតាំងនៅក្នុងចន្លោះបេះដូង និងសួត កាលកម្រើកហើយ សត្វទាំងឡាយនឹងឆ្កួត មានចិត្តវិបល្លាស លះបង់ហិរិឱត្តប្បៈ ធ្វើការដែលមិនគួរធ្វើ និយាយពាក្យដែលមិនគួរនិយាយ គិតសេចក្តីដែលមិនគួរគិត ។

ក្នុងប្រមាត់នោះ ក៏កំណត់ថា ប្រមាត់ក្រៅចង រមែងមិនដឹងថា យើងជ្រាបគ្រប់សរីរៈ សូម្បីសរីរៈ ក៏មិនដឹងថា ប្រមាត់ក្រៅចងជ្រាបលើយើង ប្រៀបដូចប្រេងជ្រាបក្នុងទឹក រមែងមិនដឹងថា យើងជ្រាបក្នុងទឹក សូម្បីទឹកក៏មិនដឹងថា ប្រេងជ្រាបក្នុងយើង ដូច្នោះ ។ ប្រមាត់ក្នុងចង ក៏រមែងមិនដឹងថា យើងនៅក្នុងចងប្រមាត់ សូម្បីចងប្រមាត់ក៏មិនដឹងថា ប្រមាត់ក្នុងចងនៅក្នុងយើង ប្រៀបដូចទឹកភ្លៀង ដែលនៅក្នុងននោងព្រៃ ក៏មិនដឹងថា ទឹកភ្លៀងនៅក្នុងយើង សូម្បីននោងព្រៃ ក៏មិនដឹងថា ទឹកភ្លៀងនៅក្នុងយើង ដូច្នោះ ។ ព្រោះថា ធម៌ទាំងនោះ វៀរចាកការត្រិះរិះ និងការពិចារណា ជាធម៌ ។ល។ មិនមែនបុគ្គល ។ ដោយបរិច្ឆេទ ក៏កំណត់ថា ប្រមាត់កំណត់ដោយចំណែកនៃប្រមាត់ នេះជាការកំណត់ប្រមាត់នោះដោយសភាគៈ ឯការកំណត់ដោយវិសភាគៈ ក៏ដូចគ្នានឹងសក់នោះឯង ។ ការកំណត់ប្រមាត់ដោយវណ្ណៈជាដើម មានប្រការដូចពោលមកដូច្នេះឯង ។

## សេម្ហំ (ស្លេស្ម៍)

តពីនោះទៅ ក៏កំណត់ថា ដោយវណ្ណៈ ស្លេស្ម៍មានប្រមាណ ១ បាត្រ

ក្នុងសរីរៈ មានពណ៌ស ដូចពណ៌ទឹកក្នុងស្លឹកខ្ទុង ។ ដោយសណ្ឋាន មានសណ្ឋានដូចឱកាស ។ ដោយទិស កើតក្នុងទិសខាងលើ ។ ដោយឱកាស តាំងនៅក្នុងផ្ទៃពោះ ។ ក្នុងវេលាបរិភោគទឹក និងភោជនជាដើម កាលទឹក និងភោជនជាដើមធ្លាក់ចុះក្នុងពោះ ក៏បែកជា ២ ចំណែក ហើយត្រឡប់មកគ្របវិញ កាលមានតិច ផ្ទៃពោះក៏មានក្លិនដូចសាកសព គួរខ្ពើមយ៉ាងក្រៃលែង ដូចបូសទុំ ដូចពងមាន់ស្អុយ ប្រៀបដូចសារាយក្នុងទឹក កាលចំរៀកឈើ ឬក៏ក្បឿងធ្លាក់ ក៏ដាច់ជា ២ ចំណែក ហើយក៏ត្រឡប់ក្រសោបវិញ ដូច្នោះ ។ ការភើក្តី និយាយក្តី ក៏មានក្លិនស្អុយ ដូចសាក-សពស្អុយ ដោយក្លិនដែលភាយឡើងពីពោះនោះ ទើងបុគ្គលនោះក៏ត្រូវគេដេញថា ចេញទៅអ្នកមានក្លិនមិនល្អ និងកាលស្លេស្មក៏ពូនក្រាស់ឡើង ក៏ជួយរម្ងាប់ក្លិនស្អុយ តាំងនៅក្នុងពោះនោះឯង ដូចក្តារបិទបង្គន់ ។

ក្នុងស្លេស្មនោះ ក៏កំណត់ថា ស្លេស្មរមែងមិនដឹងថា យើងនៅក្នុងពោះ សូម្បីពោះក៏មិនដឹងថា ស្លេស្មនៅក្នុងយើង ប្រៀបដូចដុំពពុះទឹកនៅលើអណ្តូងស្មោកគ្រោក រមែងមិនដឹងថា យើងនៅលើអណ្តូងស្មោកគ្រោក

សួម្បីអណ្តូងស្មោកគ្រោក ក៏មិនដឹងថា ដុំពពុះនៅលើយើង ដូច្នោះ ។ ព្រោះថា ធម៌ទាំងនេះ វៀរចាកការនឹកគិត និងការពិចារណា ជាធម៌ ។ល។ មិនមែនបុគ្គល ។ ដោយបរិច្ឆេទ ក៏កំណត់ថា ស្លេស្មកំណត់ដោយចំណែកនៃស្លេស្ម នេះជាការកំណត់ស្លេស្មនោះដោយសភាគៈ ចំណែកការកំណត់ដោយវិសភាគៈ ក៏ដូចគ្នានឹងសក់នោះឯង ។ ការកំណត់ស្លេស្មដោយវណ្ណៈជាដើម មានប្រការដូចពោលមកហើយ ។

## បុព្វោ (ខ្ទុះ)

តពីនោះទៅ ក៏កំណត់ថា ដោយវណ្ណៈ ខ្ទុះមានពណ៌ដូចស្លឹកឈើលឿង ។ ដោយសណ្ឋាន មានសណ្ឋានដូចឱកាស ។ ដោយទិស កើតក្នុងទិសទាំង ២ ។ ដោយឱកាស ធម្មតាឱកាសរបស់ខ្ទុះតាំងនៅប្រចាំមិនបាន ។ ខ្ទុះតាំងនៅក្នុងសរីរៈ កាលត្រូវដង្គត់ បន្លា គ្រឿងប្រហារ ឬអណ្តាតភ្លើងជាដើម ពាល់ត្រូវហើយ ក៏ចេញឈាម ឬកើតបូស និងដុំពកជាដើម ខ្ទុះក៏មាននៅក្នុងទីនោះៗ ។

ក្នុងខ្ទុះនោះ ក៏កំណត់ថា ខ្ទុះរមែងមិនដឹងថា យើងតាំងនៅក្នុងកន្លែង

ដែលត្រូវជន្គត់ឈើ ឬបន្ទាជាដើមពាល់ត្រូវ ឬក្នុងកន្ទែងដែលកើតបូស និងដុំពកជាដើម ក្នុងទីនោះៗ នៃសរីរៈ សូម្បីកន្ទែងសរីរៈ ក៏មិនដឹងថា ខ្ទុះនៅក្នុងយើង ប្រៀបដូចជ័រឈើដែលហូរចេញ តាំងនៅក្នុងទីដែលត្រូវមុតពូថៅជាដើម ក្នុងទីនោះៗ របស់ដើមឈើ រមែងមិនដឹងថា យើងតាំងនៅក្នុងទីដែលត្រូវមុតនៃដើមឈើ សូម្បីទីត្រូវមុតនៃដើមឈើ ក៏មិនដឹងថា ជ័រតាំងនៅក្នុងយើង ដូច្នោះ ។ ព្រោះថា ធម៌ទាំងនោះវៀរចាកការនឹកគិត និងការពិចារណា ជាធម៌ ។ល។ មិនមែនបុគ្គល ។ ដោយបរិច្ឆេទ ក៏កំណត់ថា ខ្ទុះកំណត់ដោយចំណែកនៃខ្ទុះ នេះជាការកំណត់ខ្ទុះនោះដោយសភាគៈ ចំណែកការកំណត់ដោយវិសភាគៈ ក៏ដូចគ្នានឹងសក់នោះឯង ។ ការកំណត់ខ្ទុះដោយវណ្ណៈជាដើម មានប្រការដូចពោលមក ដូច្នេះ ។

## លោហិតំ (ឈាម)

តពីនោះទៅ ឈាមមាន ២ យ៉ាង គឺ សន្និចិតលោហិត (ឈាមខាប់) និងសសរណលោហិត (ឈាមរាវ) ។ ក៏កំណត់ឈាមខាប់មុន ដោយវណ្ណៈ មានពណ៌ដូចអាចម៍ល័ក្ខខាប់ដែលចាស់ភ្លើង (ក្រហមក្រមៅ) ឈាម

ភាវ មានពណ៌ដូចជាអាចម៍ល័ក្ខជ្ជា (ក្រហមស្រស់) ។ ដោយសណ្ឋាន ឈាមគ្រប់យ៉ាង មានសណ្ឋានដូចឱកាសរបស់ខ្លួន ។ ដោយទិស ឈាមខាប់ ស្ថិតនៅទិសខាងលើ ឈាមរាវកើតក្នុងទិសទាំងពីរ ។ ដោយឱកាស ឈាមរាវផ្សាយទៅទូទាំងសរីរៈនៃឧបាទិន្នកសត្វ តាមលំអានសរសៃឈាម វៀរលែងតែសក់ រោម និងធ្មេញដែលផុតចាកសាច់ និងស្បែកក្រិន ។ ឈាមខាប់ ធ្វើចំណែកខាងក្រោមរបស់ថ្លើមឲ្យពេញ ហើយធ្វើដំណក់ឈាមឲ្យធ្លាក់ទៅបន្តិចៗ ម្តង ទៅលើបេះដូង តម្រងបស្សាវៈ និងសួត ប្រមាណពេញមួយទូកដៃ ធ្វើបេះដូង តម្រងបស្សាវៈ និងសួតឲ្យសើម កាលមិនធ្វើបេះដូង និងតម្រងបស្សាវៈ ថ្លើមជាដើមឲ្យសើមទេ សត្វទាំងឡាយនឹងស្រេកទឹក ។

ក្នុងឈាម ក៏កំណត់ថា ឈាមរមែងមិនដឹងថា យើងធ្វើបេះដូង និងតម្រងបស្សាវៈជាដើមឲ្យសើម ហើយតាំងនៅត្រង់ចំណែកខាងក្រោមនៃថ្លើម សូម្បីបេះដូង និងតម្រងបស្សាវៈជាដើម ក៏មិនដឹងថា ឈាមតាំងនៅក្នុងយើង ឬធ្វើយើងឲ្យសើមឡើយ ប្រៀបដូចទឹកក្នុងកាជនៈចាស់

ធ្វើដុំដីជាដើមខាងក្រោមឲ្យសើមហើយ ក៏មិនដឹងថា យើងតាំងនៅក្នុងភាជនៈចាស់ ធ្វើដុំដីខាងក្រោមជាដើមឲ្យសើម សូម្បីភាជនៈចាស់ ឬដុំដីខាងក្រោម ក៏មិនដឹងថា ទឹកតាំងនៅក្នុងយើង ឬធ្វើយើងឲ្យសើមឡើយដូច្នោះ ។ ព្រោះថា ធម៌ទាំងនេះវៀរចាកការនឹកគិត និងការពិចារណាជាធម៌ ។ល។ មិនមែនបុគ្គល ។ ដោយបរិច្ឆេទ ក៏កំណត់ថា ឈាមកំណត់ដោយចំណែកនៃឈាម នេះជាការកំណត់ឈាមដោយសភាគៈ ចំណែកការកំណត់ឈាមដោយវិសភាគៈ ក៏ដូចគ្នានឹងសក់នោះឯង ។ ការកំណត់ឈាមដោយវណ្ណៈជាដើម មានប្រការដូចពោលហើយ ។

## សេទោ (ញើស)

តពីនោះទៅ ក៏កំណត់ថា ដោយវណ្ណៈ ញើសក្នុងសរីរៈ មានពណ៌ដូចប្រេងល្ងថ្លា ។ ដោយសណ្ឋាន មានសណ្ឋានដូចឱកាស ។ ដោយទិស កើតក្នុងទិសទាំង ២ ។ ដោយឱកាស ធម្មតាញើសមិនហូរចេញគ្រប់កាលទេ ។ ប៉ុន្តែប្រសិនបើ ញើសហូរចេញគ្រប់កាល ឬព្រោះពេលណាដែលសរីរៈក្តៅ ដោយកំដៅភ្លើង ពន្លឺថ្ងៃ និងរដូវវិបរិតជាដើម វេលា

នោះ ញើសហូរចេញចាកគ្របរណ្ដៅសក់ និងរន្ធរោម ដូចទឹកក្នុងក្រអៅ ឈូក និងជាងឈូកដែលកាត់ លើកឡើងផុតពីទឹក ដូច្នោះ ។ ហេតុនោះ ព្រះយោគាវចរទើបកំណត់ញើសនោះ ដោយសណ្ឋាន ដោយរន្ធសក់ និង រន្ធរោមនោះឯង ។ បុព្វាចារ្យទាំងឡាយពោលទុកថា “ដែលព្រះយោគា-វចរកំណត់យកញើសជាអារម្មណ៍ គប្បីធ្វើទុកក្នុងចិត្តនូវញើស ដោយញើស ដែលហូរតាមរន្ធសក់ និងរន្ធរោមនោះឯង” ។

ក្នុងញើសនោះ កំណត់ថា ញើសរមែងមិនដឹងថា យើងហូរចេញ អំពីរន្ធសក់ និងរន្ធរោម សូម្បីរន្ធសក់ និងរន្ធរោម ក៏មិនដឹងថា ញើស ហូរចេញពីយើង ប្រៀបដូចទឹកដែលហូរចេញពីរន្ធក្រអៅឈូក និងជាង ឈូក សូម្បីក្រអៅឈូក និងជាងឈូក ក៏មិនដឹងថា ទឹកហូរចេញពីយើង ដូច្នោះ ។ ព្រោះថា ធម៌ទាំងនេះ វៀរចាកការនឹកគិត និងការពិចារណា ជាធម៌ ។ល។ មិនមែនបុគ្គល ។ ដោយបរិច្ឆេទ កំណត់ថា ញើសកំណត់ ដោយចំណែកញើស នេះជាការកំណត់ញើសនោះដោយសភាគៈ ចំណែក ការកំណត់ដោយវិសភាគៈ ក៏ដូចគ្នានឹងសក់នោះឯង ។ ការកំណត់ញើស

ដោយវណ្ណៈជាដើម មានប្រការដូចពោលមក ដូច្នេះ ។

មេទោ (ខ្លាញ់ខាប់)

តពីនោះទៅ ក៏កំណត់ថា ដោយវណ្ណៈ ខ្លាញ់ខាប់នៅចន្លោះស្បែក និងសាច់ក្នុងសរីរៈ មានពណ៌ដូចល្មៀត ។ ដោយសណ្ឋាន មានសណ្ឋានដូចឱកាស ។ ពិតហើយ សម្រាប់មនុស្សធាត់ មានខ្លាញ់ខាប់ផ្សាយទៅចន្លោះស្បែក និងសាច់ មានសណ្ឋានដូចសំពត់សំបកឈើចាស់ជ្រលក់ល្មៀត សម្រាប់មនុស្សស្គម ខ្លាញ់ខាប់អាស្រ័យសាច់ស្មង សាច់ជើង សាច់ឆ្អឹងខ្នង និងសាច់ខ្នង និងសាច់ពោះ មានសណ្ឋានដូចសំពត់សំបកឈើចាស់ជ្រលក់ល្មៀតដែលគេពូត ។ ដោយទិស កើតក្នុងទិសទាំង ២ ។ ដោយឱកាស ខ្លាញ់ខាប់សម្រាប់មនុស្សធាត់ផ្សាយទៅទូទាំងសរីរៈ សម្រាប់ស្គមអាស្រ័យសាច់កំភួនជើងជាដើម សូម្បីចាត់ថាជាប្រេង ក៏មិនមែនជាប្រេងលាបក្បាល មិនមែនជាប្រេងដើម្បីដុំបាយ មិនមែនដើម្បីប្រទីប ព្រោះជារបស់គួរខ្ពើមយ៉ាងក្រៃលែង ។

ក្នុងខ្លាញ់ខាប់នោះ កំណត់ថា ខ្លាញ់ខាប់នោះរមែងមិនដឹងថា យើង

អាស្រ័យនៅទូទាំងក្នុងសរីរៈ ឬសាច់ស្ទួនជាដើម ប្រៀបដូចសំពត់សំបក ឈើចាស់ជ្រលក់ល្មៀត ដែលទុកលើគំនរសាច់ រមែងមិនដឹងថា យើងនៅ លើគំនរសាច់ សូម្បីគំនរសាច់ក៏មិនដឹងថា សំពត់សំបកឈើចាស់ជ្រលក់ ល្មៀត ទុកនៅលើយើង ដូច្នោះ ។ ព្រោះថា ធម៌ទាំងនោះវៀរចាកការ នឹកគិត និងការពិចារណា ជាធម៌ ។ល។ មិនមែនបុគ្គល ។ ដោយបរិច្ឆេទ ក៏កំណត់ថា ខ្លាញ់ខាប់ ខាងក្រោមកំណត់ដោយសាច់ ខាងលើកំណត់ដោយ ស្បែក ដោយជុំវិញកំណត់ដោយចំណែកនៃខ្លាញ់ខាប់ នេះជាការកំណត់ ខ្លាញ់ខាប់នោះដោយសភាគៈ ចំណែកការកំណត់ដោយវិសភាគៈ ក៏ដូចគ្នា នឹងសក់នោះឯង ។ ការកំណត់ខ្លាញ់ខាប់ ដោយវណ្ណៈជាដើមមានប្រការ ដូចពោលមកហើយនោះឯង ។

## អស្សុ (ទឹកភ្នែក)

តពីនោះទៅ កំណត់ថា ទឹកភ្នែកមានពណ៌ដូចប្រេងល្ងថ្លា ដោយ សណ្ឋាន មានសណ្ឋានដូចឱកាស ។ ដោយទិស កើតក្នុងទិសខាងលើ ។ ដោយឱកាស តាំងនៅក្នុងរន្ធភ្នែក ។ ក៏ទឹកភ្នែកនោះ មិនកកនៅក្នុងរន្ធ

ក្អែកគ្រប់កាលទេ ដូចទឹកប្រមាត់នៅក្នុងថង់ប្រមាត់ទេ ។ មានដូចម្ដេច ។ កាលណាសត្វទាំងឡាយ កើតសោមនស្ស សប្បាយចិត្ត ក៏សើចខ្លាំង កើតទោមនស្ស តូចចិត្ត ក៏យំត្អូញត្អែរ ឬបរិភោគអាហារហឹរក៏ដូចគ្នា នឹងកាលណាក្អែកទាំងពីររបស់សត្វទាំងនោះត្រូវផ្សែង និងលំអងធូលីជាដើមប៉ះត្រូវ កាលនោះទឹកក្អែកកើតឡើង ព្រោះសោមនស្សខ្លះ ទោមនស្សខ្លះ អាហារហឹរជាដើម ក៏ញាំងទឹកក្អែកឲ្យពេញតាមរណ្ដៅក្អែក បុរាណាចារ្យទាំងឡាយពោលថា "ព្រះយោគាវចរកំណត់យកទឹកក្អែកជាអារម្មណ៍ គប្បីមនសិការក្នុងទឹកក្អែកនោះ គឺ ទឹកក្អែកក្នុងរណ្ដៅក្អែកនោះឯង ។

ក្នុងទឹកក្អែកនោះ ក៏កំណត់ថា ទឹកក្អែករមែងមិនដឹងថា យើងតាំងនៅក្នុងប្រហោងក្អែក សូម្បីប្រហោងក្អែក ក៏មិនដឹងថា ទឹកក្អែកនៅក្នុងយើង ប្រៀបដូចទឹកដែលនៅក្នុងគ្រាប់ត្នោតខ្ចីដែលកាត់ រមែងមិនដឹងថា យើងតាំងនៅក្នុងគ្រាប់ត្នោតខ្ចីដែលកាត់ សូម្បីប្រហោងគ្រាប់ត្នោតខ្ចីដែលកាត់ ក៏មិនដឹងថា ទឹកនៅក្នុងយើង ដូច្នោះ ។ ព្រោះថា ធម៌ទាំងនោះវៀរចាកការនឹកគិត និងការពិចារណា ជាធម៌ ។ល។ មិនមែនបុគ្គល ។

ដោយបរិច្ឆេទ ក៏កំណត់ថា ទឹកភ្នែក កំណត់ដោយចំណែកនៃទឹកភ្នែក នេះជាការកំណត់ទឹកភ្នែកនោះដោយសភាគៈ ចំណែកកំណត់ដោយវិសភាគៈ ក៏ដូចគ្នានឹងសក់នោះឯង ។ ការកំណត់ទឹកភ្នែកដោយវណ្ណៈជាដើម មានប្រការដូចពោលមកហើយ ដូច្នេះ ។

## វសា (ខ្លាញ់រាវ)

តពីនោះ ក៏កំណត់ថា ដោយវណ្ណៈ ខ្លាញ់រាវ គឺ ខ្លាញ់ដែលរាវមានក្នុងសរីរៈ មានពណ៌ដូចប្រេងដែលចាក់ក្នុងបាយក្តាំង ។ ដោយសណ្ឋានមានសណ្ឋានដូចឱកាស ។ ដោយទិស កើតក្នុងទិសទាំង ២ ។ ដោយឱកាស តាំងនៅត្រង់បាតដៃ ខ្នងដៃ បាតជើង ខ្នងជើង ខ្នង់ច្រមុះ ថ្ងាស និងចង្កួយស្មា ។ ប៉ុន្តែខ្លាញ់រាវនោះ មិនតាំងនៅក្នុងឱកាសទាំងនោះគ្រប់ពេលទេ ។ ព្រោះអ្វី ។ កាលណាប្រទេសទាំងនោះមានកំដៅ ព្រោះវិសភាគៈនឹងកំដៅភ្លើង កំដៅថ្ងៃ រដូវ និងធាតុ កាលនោះខ្លាញ់រាវក៏នឹងរលាយជ្រាបទៅក្នុងប្រទេសទាំងនោះ ដូចចំហាយទឹកក្នុងអណ្តូងដែលមានទឹកថ្លា ។

ក្នុងខ្វាញ់ពរនោះ កំណត់ថា ខ្វាញ់ពរមែងមិនដឹងថា យើងជប់នៅតាមបាតដៃជាដើម សូម្បីបាតដៃជាដើមក៏មិនដឹងថា ខ្វាញ់ពរជប់នៅក្នុងយើង ប្រៀបដូចចំហាយទឹកដែលអណ្តែតលើអណ្តូងទឹក រមែងមិនដឹងថាយើងអណ្តែតលើអណ្តូងទឹក សូម្បីអណ្តូងទឹកក៏មិនដឹងថា មានចំហាយទឹកអណ្តែតនៅលើយើង ដូច្នោះ ។ ព្រោះថា ធម៌ទាំងនោះ វៀរចាកការគិតនិងការពិចារណា ជាធម៌ ។ល។ មិនមែនបុគ្គល ។ ដោយបរិច្ឆេទ កំណត់ថា ខ្វាញ់ពរកំណត់ដោយចំណែកនៃខ្វាញ់ពរ នេះជាការកំណត់ខ្វាញ់ពរនោះដោយសភាគ: ចំណែកការកំណត់ដោយវិសភាគ: ក៏ដូចគ្នានឹងសក់នោះឯង ។ ការកំណត់ខ្វាញ់ពរ ដោយវណ្ណ:ជាដើម មានប្រការដូចពោលមកហើយនោះឯង ។

## ខេឡោ (ទឹកមាត់)

តពីនោះ កំណត់ថា ក្នុងសរីរ: ដោយវណ្ណ: ទឹកមាត់ខាងក្នុងមាត់មានពណ៌ស មានពណ៌ដូចពពុះទឹក ។ ដោយសណ្ឋាន មានសណ្ឋានដូចឱកាស ។ អាចារ្យពួកខ្លះពោលថា "មានសណ្ឋានដូចពពុះទឹកសមុទ្រ" ដូច្នេះ

ក៏មាន ។ ដោយទិស កើតក្នុងទិសខាងលើ ។ ដោយឱកាស ហូរចុះចាក ថ្គាល់ទាំងសងខាង តាំងនៅត្រង់អណ្តាត ។ ប៉ុន្តែទឹកមាត់នោះ មិនសន្សំ តាំងនៅត្រង់ថ្គាល់នោះគ្រប់ពេលវេលាទេ ។ ព្រោះហេតុអ្វី ។ ព្រោះ កាលណាសត្វទាំងឡាយឃើញ ឬឮពួកដល់អាហារ ឬដាក់របស់ក្តៅ របស់ ល្វីង ហឹរ ប្រៃ និងជូរអ្វីម្យ៉ាងក្នុងមាត់ និងកាលណាបេះដូងរបស់សត្វ ទាំងនោះមិនសប្បាយ ឬកើតការស្រេកឃ្លានឡើងក្នុងគ្រាខ្លះ ក្នុងកាលនោះ កាលនោះ ទឹកមាត់ក៏កើតឡើង ហូរចាកថ្គាល់ទាំងសងខាង តាំងនៅត្រង់ អណ្តាត ។ ប៉ុន្តែចុងអណ្តាតទឹកមាត់តិច ត្រង់គល់អណ្តាតច្រើន ។ កាល គេដាក់របស់ទំពារចូលក្នុងមាត់ ដូចជាត្រប៉ែ បាយ ឬរបស់ទំពារដទៃផ្សេង ទៀត ទឹកមាត់រមែងចេញមកមិនអស់ ដូចទឹកក្នុងអណ្តូង ដែលជីកលើដី ខ្សាច់ក្បែរមាត់ទន្លេ កាលនោះ ទឹកមាត់ក៏ធ្វើរបស់ទំពារឲ្យសើមជានិច្ច ។

ក្នុងទឹកមាត់នោះ ក៏កំណត់ថា ទឹកមាត់រមែងមិនដឹងថា យើងហូរ ចេញអំពីថ្គាល់ទាំងសងខាង ហើយតាំងនៅត្រង់ផ្ទៃអណ្តាត សូម្បីអណ្តាត ក៏មិនដឹងថា ទឹកមាត់ហូរចេញអំពីថ្គាល់សងខាងតាំងនៅក្នុងយើង ប្រៀប

ដូចទឹកនៅក្នុងអណ្តូងដែលគេជីកខ្សាច់ក្បែរទន្លេ រមែងមិនដឹងថា យើងនៅក្នុងអណ្តូង សូម្បីអណ្តូងក៏មិនដឹងថា ទឹកនៅក្នុងយើង ដូច្នោះ ។ ព្រោះថា ធម៌ទាំងនោះវៀរចាកការគិត និងការពិចារណា ជាធម៌ ។ល។ មិនមែនបុគ្គល ។ ដោយបរិច្ឆេទក៏កំណត់ថា ទឹកមាត់ កំណត់ដោយចំណែកនៃទឹកមាត់ នេះជាការកំណត់ទឹកមាត់នោះដោយសភាគៈ ចំណែកការកំណត់ដោយចំណែកវិសភាគៈ ក៏ដូចគ្នានឹងសក់នោះឯង ។ ការកំណត់ទឹកមាត់ដោយវណ្ណៈជាដើម មានប្រការដូចពោលមកហើយ ដូច្នេះឯង ។

## សិង្ឃាណិកា (ទឹកសំបោរ)

តពីនោះ កំណត់ថា ខាងក្នុងសរីរៈ ដោយវណ្ណៈ ទឹកសំបោរ មានពណ៌ស ដូចពណ៌ទឹកក្នុងគ្រាប់ត្នោតខ្ចី ។ ដោយសណ្ឋាន មានសណ្ឋានដូចឱកាសនៃខ្លួន ។ អាចារ្យពួកខ្លះពោលថា "មានសណ្ឋានដូចពន្លកផ្តៅដែលគេដាក់បន្តគ្នាចូលទៅក្នុងរន្ធច្រមុះ" ដូច្នេះក៏មាន ។ ដោយទិស កើតក្នុងទិសខាងលើ ។ ដោយឱកាស ដក់នៅពេញរន្ធច្រមុះ ។ ប៉ុន្តែថា ទឹកសំបោរនោះ មិនដក់នៅក្នុងរន្ធច្រមុះគ្រប់កាលទេ ។ ដូចអ្វី ។ ដូចជា

បុរសខ្ចប់ទឹកដោះជូរទុកក្នុងស្លឹកឈូក យកបន្ទាចាក់ស្លឹកឈូកខាងក្រោម ភ្លាមនោះ ទឹកដោះជូរក៏នឹងហូរចេញចាករន្ធនោះ ធ្លាក់ចុះមកក្រៅ យ៉ាងណា កាលណាសត្វទាំងឡាយយំ ឬកើតធាតុកម្រើកដោយអាហារ និងរដូវ ដែលវិសភាគៈគ្នា កាលនោះ សំបោរដែលតាំងនៅជិតខួរក្បាល ក៏ក្លាយទៅជាស្លេស្ម៍ ហូរចេញពីក្បាលតាមផ្លូវលើពិតានមាត់ ដក់នៅពេញរន្ធច្រមុះ ។

ក្នុងទឹកសំបោរនោះ កំណត់ថា ទឹកសំបោររមែងមិនដឹងថា យើងនៅក្នុងប្រហោងច្រមុះ សូម្បីប្រហោងច្រមុះក៏មិនដឹងថា ទឹកសំបោរនៅក្នុងយើង ប្រៀបដូចទឹកដោះជូរ ដែលគេដាក់ក្នុងសំបកខ្យង រមែងមិនដឹងថា យើងនៅក្នុងសំបកខ្យង សូម្បីសំបកខ្យងក៏មិនដឹងថា ទឹកដោះជូរនៅក្នុងយើង ដូច្នោះ ។ ព្រោះថា ធម៌ទាំងនោះវៀរចាកការត្រិះរិះ ការពិចារណា ជាធម៌ ។ល។ មិនមែនបុគ្គល ។ ដោយបរិច្ឆេទ កំណត់ថា ទឹកសំបោរ កំណត់ដោយចំណែកនៃទឹកសំបោរ នេះជាការកំណត់ទឹកសំបោរនោះដោយសភាគៈ ចំណែកការកំណត់ដោយវិសភាគៈ ក៏ដូចគ្នានឹងសក់នោះឯង ។ ការកំណត់ទឹកសំបោរដោយវណ្ណៈជាដើម ដូចពោលមកហើយនោះឯង ។

## លសិកា (ទឹករំអិល)

តពីនោះទៅ ក៏កំណត់ថា ខាងក្នុងសរីរៈ មានទឹករំអិលកើតខាងក្នុងទី.តនៃសរីរៈ ឈ្មោះថា ទឹករំអិល ។ ដោយវណ្ណៈ ទឹករំអិលនោះមានពណ៌ដូចជ័រដើមផ្កាកណិការ ។ ដោយសណ្ឋាន មានសណ្ឋានដូចឱកាស ។ ដោយទិស កើតក្នុងទិសទាំង ២ ។ ដោយឱកាស ឲ្យសម្រេចកិច្ច គឺនាទីជាជំណក់ប្រេង ត្រង់ទី.តនៃឆ្អឹងទាំងឡាយ តាំងនៅខាងក្នុងទី.ត ១៨០ កន្លែង ។ ទឹករំអិលនោះ របស់បុគ្គលណាមានតិច បុគ្គលនោះក្រោកឡើង អង្គុយចុះ ឈានដើរទៅខាងមុខ ថយក្រោយ ផ្ងារដៃ លាតដៃ ឆ្អឹងទាំងឡាយក៏លាន់ឮ ដើរទៅក៏ធ្វើសំឡេងដូចផ្ទាត់ម្រាមដៃ ដើរផ្លូវឆ្ងាយបានសូម្បី ១ យោជន៍ ២ យោជន៍ វាយោធាតុក៏កម្រើក ខ្លួនក៏លំបាក ចំណែកទឹករំអិលរបស់បុគ្គលណាមានច្រើន បុគ្គលនោះ ឆ្អឹងទាំងឡាយក៏មិនលាន់ឮក្នុងខណៈក្រោកឡើង និងអង្គុយចុះជាដើម សូម្បីដើរផ្លូវយូរ វាយោធាតុក៏មិនកម្រើក ខ្លួនក៏មិនលំបាក ។

ក្នុងទឹករំអិលនោះ កំណត់ថា ទឹករំអិលរមែងមិនដឹងថា យើងបន្តក់

ត្រង់ទី.ត ១៨០ កន្លែង សូម្បីទី.ត ១៨០ កន្លែង ក៏មិនដឹងថា ដំណក់ទឹករំអិលបន្តក់លើយើង ប្រៀបដូចប្រេងបន្តក់ក្លៀវថ រមែងមិនដឹងថា យើងបន្តក់ត្រង់ក្លៀវថ សូម្បីក្លៀវថក៏មិនដឹងថា ដំណក់ប្រេងនោះបន្តក់លើយើង ដូច្នោះ ។ ព្រោះថា ធម៌ទាំងនោះ វៀរចាកការនឹកគិត និងការពិចារណា ជាធម៌ ។ល។ មិនមែនបុគ្គល ។ ដោយបរិច្ឆេទ ក៏កំណត់ថា ទឹករំអិលកំណត់ដោយចំណែកនៃទឹករំអិល នេះជាការកំណត់ទឹករំអិលនោះ ដោយសភាគៈ ចំណែកការកំណត់ដោយវិសភាគៈ ក៏ដូចគ្នានឹងសក់នោះឯង ។ ការកំណត់ទឹករំអិលដោយវណ្ណៈជាដើម មានប្រការដូចពោលហើយ ។

## មុត្តំ (ទឹកមូត្រ)

តពីនោះ កំណត់ថា ខាងក្នុងសរីរៈ ដោយវណ្ណៈ ទឹកមូត្រមានពណ៌ដូចទឹកក្បុងសណ្តែករាជមាស ។ ដោយសណ្ឋាន មានសណ្ឋានដូចទឹកដែលនៅក្នុងផ្ទាំងពេញដោយទឹក ដែលគេដាក់ផ្កាប់មាត់ ។ ដោយទិសកើតក្នុងទិសខាងក្រោម ។ ដោយឱកាស តាំងនៅក្នុងតម្រងបស្សាវៈ ។ ថង់បស្សាវៈ លោកហៅថា តម្រងបស្សាវៈ ប្រៀបដូចរសទឹកកខ្វក់ រមែង

ហូរចូលទៅក្នុងឆ្នាំដែលមិនមានគម្រប ដែលគេដាក់ក្នុងស្រះកខ្វក់ ផ្លូវចូលនៃរសទឹកកខ្វក់នោះមិនប្រាកដ យ៉ាងណា ទឹកមូត្រជ្រាបចេញចាកសរីរៈរមែងចូលទៅ តាមផ្លូវជ្រាបរបស់ទឹកមូត្រនោះមិនប្រាកដ ចំណែកផ្លូវចេញប៉ុណ្ណោះប្រាកដ យ៉ាងណា កាលតម្រងបស្សាវៈពេញដោយទឹកមូត្រ សត្វទាំងឡាយក៏នឹងព្យាយាមថា ពួកយើងនឹងបន្ទោបង់បស្សាវៈ ។

ក្នុងទឹកមូត្រនោះ កំណត់ថា ទឹកមូត្ររមែងមិនដឹងថា យើងតាំងនៅក្នុងតម្រងបស្សាវៈ សូម្បីតម្រងបស្សាវៈក៏មិនដឹងថា ទឹកមូត្រតាំងនៅក្នុងយើង ប្រៀបដូចរសទឹកកខ្វក់ក្នុងឆ្នាំងមិនមានគម្របគេដាក់ក្នុងស្រះកខ្វក់រមែងមិនដឹងថា យើងនៅក្នុងឆ្នាំងមិនមានគម្រប សូម្បីឆ្នាំង ក៏មិនដឹងថារសទឹកកខ្វក់នៅក្នុងយើង ដូច្នោះ ។ ព្រោះថា ធម៌ទាំងនេះ វៀរចាកការនឹកគិត និងការពិចារណា ជាធម៌ ។ល។ មិនមែនបុគ្គល ។ ដោយបរិច្ឆេទកំណត់ថា ទឹកមូត្រកំណត់ដោយចំណែកតម្រងបស្សាវៈ ព្រោះជាចំណែកនៃទឹកមូត្រ នេះជាការកំណត់ទឹកមូត្រនោះដោយសភាគៈ ឯការកំណត់ដោយវិសភាគៈ ក៏ដូចគ្នានឹងសក់នោះឯង ។ ការកំណត់ទឹកមូត្រ ដោយវណ្ណៈ

ជាដើម មានប្រការដូចពោលមកនោះឯង ។ ព្រះយោគាវចរកំណត់អាការ ៣២ ប្រការ ដោយពណ៌ជាដើម ដោយប្រការដូច្នេះ ។

ព្រោះអាស្រ័យការប្រកបរឿយៗ នូវការចម្រើនទ្វត្តឹសាការនោះៗ ទ្វត្តឹសាការមានសក់ជាដើម ក៏រមែងស្ទាត់ជំនាញ ប្រាកដច្បាស់ជាចំណែកៗ ដល់ព្រះយោគាវចរនោះ ដែលកំណត់ទ្វត្តិង្សាការនេះ ដោយវណ្ណៈជាដើម ដោយប្រការដូច្នេះ ។ តអំពីនោះទៅ បុរសដែលមានភ្នែក ពិនិត្យមើលកម្រងនៃផ្កាទាំងឡាយ ដែលមាន ៣២ ពណ៌ ដែលក្រងដោយអំបោះតែមួយសរសៃ ផ្កាគ្រប់ប្រភេទក៏រមែងប្រាកដមិនមុនមិនក្រោយ យ៉ាងណា កាលព្រះយោគាវចរក្រឡេកមើលនូវកាយនេះ ដោយសតិថា ក្នុងកាយនេះមានសក់ជាដើម ធម៌ពួកទាំងអស់នោះ រមែងជាការប្រាកដមិនមុនមិនក្រោយ ក៏យ៉ាងនោះដែរ ។ សតិដែលតាំងឡើងក្នុងសក់ទាំងឡាយ ដែលទឹកដល់រមែងប្រព្រឹត្តទៅរហូតដល់ទឹកមូត្រ ។ តាំងពីនោះទៅ មនុស្ស និងសត្វតិរិច្ឆានជាដើម ដែលដើរទៅមក នឹងលះអាការថាសត្វ ប្រាកដច្បាស់តែគំនរនៃកោដ្ឋាសៈប៉ុណ្ណោះដល់ព្រះយោគាវចរៈនោះ ឯទឹក និងភោជនជាដើម

ដែលសត្វទាំងនោះបរិភោគ ក៏ប្រាកដច្បាស់ដូចជាក់ចុះទៅក្នុងគំនរនៃកោដ្ឋាសៈ ។

ក្នុងសេចក្តីនេះ អាចារ្យវិទណ្ឌវាទីពោលថា "បើដូច្នោះ ព្រះយោគាវចរនេះគប្បីធ្វើអ្វី តពីនោះទៅ" ។ សូមពោលប្រាប់ដូច្នេះ និមិត្តនោះៗ ឯង ដែលព្រះយោគាវចរ គប្បីសេព គប្បីចម្រើន គប្បីធ្វើឲ្យច្រើន គប្បីកំណត់ ឲ្យជាការកំណត់ដោយល្អ ។ សួរថា ព្រះយោគាវចរនេះ សេព ចម្រើន ធ្វើឲ្យច្រើន កំណត់ឲ្យជាការកំណត់ដោយល្អនូវនិមិត្តដូចម្តេច ។ ឆ្លើយថា តាមពិត ព្រះយោគាវចរនេះ សេពនិមិត្ត គឺ ទ្វត្តិំសាការៈ មានសក់ជាដើម ប្រាកដជាចំណែកៗ នោះ រមែងចង សេព ចូលទៅជិតដោយសតិ ឲ្យតាំងនៅ គឺ សតិ ឬធ្វើសតិដែលបានក្នុងនិមិត្តនោះ ឲ្យចម្រើន លោកហៅថា ចម្រើននិមិត្តនោះ ។ បទថា ធ្វើឲ្យច្រើន បានដល់ ធ្វើនិមិត្តនោះឲ្យរឿយៗ ប្រកបដោយសតិ ដែលវិតក្កៈ និងវិចារៈ ចូលទៅពាល់ត្រូវហើយ ។ បទថា កំណត់ ឲ្យជាការកំណត់ដោយល្អ បានដល់ និមិត្តដែលជាការកំណត់ដោយល្អ មិនវិនាសទៅដោយប្រការណា ព្រះយោ-

គាវចរមែងកំណត់ក្នុងការទទួល ចូលទៅចងនិមិត្តនោះដោយសតិ ដោយប្រការដូច្នេះ ។

ម្យ៉ាងទៀត មនសិការកោសល្យ (ការឆ្លាតក្នុងមនសិការ) ណាដែលពោលទុកពីមុន ១០ យ៉ាង គឺ ១ ដោយលំដាប់ ២ ដោយមិនលឿនពេក ៣ មិនយឺតពេក ៤ ដោយការពារកាពរាយមាយ ៥ ដោយការកន្លងបញ្ញត្ត ៦ ដោយលំដាប់ ៧ ដោយលក្ខណៈ និងដោយសូត្រទាំង ៣ ។ ក្នុងមនសិការកោសល្យនោះ គប្បីជ្រាបថា ព្រះយោគាវចរធ្វើទុកក្នុងចិត្តដោយលំដាប់ ឈ្មោះថា **សេព** ។ មនសិការដោយមិនលឿនពេក និងដោយមិនយឺតពេក ឈ្មោះថា **ចម្រើន** ។ មនសិការ ដោយការការពារសេចក្តីរាយមាយ ឈ្មោះថា **ធ្វើឲ្យច្រើន** ។ មនសិការដោយកន្លងបញ្ញត្តជាដើម ឈ្មោះថា **កំណត់ឲ្យជាការកំណត់ដោយល្អ** ។

ក្នុងសេចក្តីនេះ អាចារ្យវិទណ្ឌវាទីពោលថា ព្រះយោគាវចរនេះមនសិការក្នុងធម៌ទាំងនេះ ដោយមនសិការកោសល្យ មានតាមលំដាប់ដូចម្តេច ។ សូមឆ្លើយដូច្នេះ តាមពិត ព្រះយោគាវចរនេះ លុះមនសិការក្នុង

សក់ហើយ លំដាប់ពីនោះ ក៏មនសិការក្នុងរោម មិនមនសិការក្នុងក្រចកទេ ។ កាលមនសិការក្នុងរោមហើយ លំដាប់តពីនោះ ក៏មនសិការក្នុងក្រចក មិនមនសិការក្នុងធ្មេញទេ ។ ក្នុងអាការគ្រប់យ៉ាង ក៏ន័យនេះ ។ ព្រោះហេតុអ្វី ។ ព្រោះថា ព្រះយោគាវចរ កាលមនសិការខុសលំដាប់ ក៏មានចិត្តលំបាក ឃ្លាតចាកទ្វត្តិំសាការភាវនា ចម្រើនភាវនាមិនសម្រេច ព្រោះមិនបានអស្សាទៈ (សេចក្តីរីករាយ) ដែលគួរបានដោយភាវនាសម្បត្តិ ប្រៀបដូចបុរសមិនធ្លាតឡើងកាំជណ្តើរ ៣២ កាំ ខុសលំដាប់ ក៏លំបាកកាយ រមែងធ្លាក់ពីកាំជណ្តើរដែលខ្លួនឡើង មិនសម្រេចការឡើងដូច្នេះ ។

ម្យ៉ាងទៀត ព្រះយោគាវចរ សូម្បីធ្វើទុកក្នុងចិត្តតាមលំដាប់ ក៏ការធ្វើទុកក្នុងចិត្ត **មិនលឿនពេកថា** កេសា លោមា ។ ព្រោះថា ព្រះយោគាវចរ កាលមនសិការលឿនពេក ក៏មិនអាចកំណត់និមិត្តនៃអាការ ៣២ មានវណ្ណៈ និងសណ្ឋានជាដើម ព្រោះមិនឈ្លាសក្នុងទ្វត្តិំសាការ និងកម្មដ្ឋានក៏វិនាសទៅ ប្រៀបដូចបុរសកំពុងធ្វើដំណើរផ្លូវឆ្ងាយ មិនអាចកំណត់លក្ខណៈរបស់ផ្លូវថា ផ្លូវរាប ផ្លូវរលាក់ ដើមឈើ ទីទួល ទីក្រឡុក ផ្លូវបែកជាពីរ

ជាដើម ព្រោះមិនឈ្លាសក្នុងផ្លូវ ការដើរផ្លូវឆ្ងាយក៏នឹងវិនាសទៅ ដូច្នោះ ។

មួយវិញទៀត ព្រះយោគាវចរ មនសិការដោយមិនរហ័សពេក យ៉ាងណា ក៏មនសិការ សូម្បី **មិនរហ័សពេក** ក៏ដូច្នោះ ។ ព្រោះថា ព្រះយោគាវចរ កាលមនសិការយឺតពេក ក៏មិនដល់ការសម្រេចទុត្តិយាការការនា តែនឹងដល់ការលំបាកព្រោះកាមវិតក្កៈជាដើម ក្នុងរវាងនោះ ព្រោះការនាជាច់ ប្រៀបដូចបុរសដើរផ្លូវឆ្ងាយ ត្រូវស្នាក់ស្មើរនៅត្រង់ដើមឈើ ភ្នំ និងត្រពាំងទឹកជាដើម ក្នុងរវាងផ្លូវ ក៏មិនទៅដល់កន្លែងតាមបំណង តែនឹងដល់ការវិនាសដោយរាជសីហ៍ និងខ្លាធំជាដើម ក្នុងរវាងផ្លូវនោះឯង ។

មួយវិញទៀត ព្រះយោគាវចរ សូម្បីមនសិការមិនយឺតពេក ក៏មនសិការ សូម្បី **ព្រោះការពារសេចក្តីរាយមាយ** ។ ឈ្មោះថា ដែលមនសិការដើម្បីការពារសេចក្តីរាយមាយ ព្រះយោគាវចររមែងមនសិការ ដោយប្រការដែលចិត្តមិនរាយមាយព្រោះការងារដទៃៗ មានការងារនវកម្ម (ការកសាង) ជាដើម ។ ព្រះយោគាវចរអ្នកមានចិត្តរាយមាយទៅខាងក្រៅ មានការត្រិះរិះនៃចិត្ត មិនតាំងមាំក្នុងទុតិយាការ មានសក់ជាដើម ក៏នឹងមិនសម្រេច

នូវការនា ទើងដល់នូវកាពលំបាកក្នុងរវាងផ្លូវនោះឯង ដូចសម្លាញ់របស់ព្រះពោធិសត្វ រមែងដល់នូវសេចក្ដីវិនាសក្នុងដំណើរផ្លូវទៅក្រុងតក្កសិលា ចំណែកព្រះយោគាវចរអ្នកមានចិត្តមិនរាយមាយ មានសេចក្ដីត្រិះរិះនៃចិត្ត តាំងមាំក្នុងវត្តិងព្វាការ មានសក់ជាដើម ក៏ដល់នូវការសម្រេចការនា ដូចព្រះពោធិសត្វដល់នូវការសម្រេចនៃរាជសម្បត្តិក្នុងក្រុងតក្កសិលា ។ ធម៌ទាំងនោះ រមែងសម្រេចដោយអសុភៈ ដោយពណ៌ ឬដោយភាពសូន្យទទេ ដោយអំណាចបារមី ចរិយា និងការបង្អោនចិត្តជឿ របស់ព្រះយោគាវចរអ្នកមនសិការ ដោយការការពារសេចក្ដីរាយមាយ ដោយប្រការដូច្នេះ ។

ម្យ៉ាងទៀត ព្រះយោគាវចរមនសិការធម៌ទាំងនោះ **ដោយកន្លងបញ្ញត្តិ** ។ បទថា ដោយកន្លងបញ្ញត្តិ បានដល់ មនសិការដោយការលះបង់នូវវោហារជាដើម យ៉ាងនេះថា **កេសា លោមា** ដោយជាអសុភៈជាដើម តាមដែលប្រាកដហើយ ។ មនសិការយ៉ាងណា ។ ប្រៀបដូចមនុស្សទាំងឡាយ ដែលចូលទៅអាស្រ័យក្នុងព្រៃធ្វើគ្រឿងសម្គាល់ ដោយកាប់មែកឈើជាដើម ដើម្បីសម្គាល់ទីដែលមានទឹក ព្រោះជាភូមិភាគដែលមិន

ធ្លាប់ស្គាល់មកពីមុន តាមគ្រឿងសម្គាល់នោះ រមែងបរិភោគទឹកបាន តែកាលបើបានស្គាល់ភូមិភាគនោះហើយ ក៏មិនចាំបាច់ទៅតាមគ្រឿងសម្គាល់នោះ រមែងចូលទៅកាន់ទីដែលមានទឹក ហើយបរិភោគទឹកបាន យ៉ាងណា ព្រះយោគាវចរនោះ ក៏ដូច្នោះដូចគ្នា មនសិការធម៌ទាំងនោះ ដោយវោហារនោះៗ មាន **កេសា លោមា** ជាដើមជាមុន កាលធម៌ទាំងនោះប្រាកដច្បាស់ដោយអារម្មណ៍ មានអសុភៈជាដើមណាមួយ ក៏គប្បីលះបង់វោហារនោះ មនសិការអារម្មណ៍ មានអសុភៈជាដើមនោះឯង ។

ក្នុងសេចក្តីនេះ អាចារ្យវិទណ្ឌវាទីពោលថា ធម៌ទាំងនោះ ប្រាកដដោយភាពជាអសុភៈជាដើម ដល់ព្រះយោគាវចរនោះយ៉ាងណា ដោយវណ្ណៈយ៉ាងណា ឬដោយភាវៈជារបស់សូន្យទទេយ៉ាងណា ។ មយ៉ាងទៀត ព្រះយោគាវចរនេះ មនសិការធម៌ទាំងនេះ ដោយអសុភៈយ៉ាងណា ដោយវណ្ណៈយ៉ាងណា ឬដោយភាវៈទទេយ៉ាងណា ។ ជាដំបូង សក់ទាំងឡាយ រមែងប្រាកដដល់ព្រះយោគាវចរនោះ ដោយអសុភៈមាន ៥ ចំណែក គឺ វណ្ណៈ (ពណ៌) សណ្ឋាន (ទ្រង់ទ្រាយ) គន្ធៈ (ក្លិន) អាសយៈ (ទីនៅ) និង

ឱកាស (ទីកើត) ព្រះយោគាវចរនេះ ក៏មនសិការក្នុងធម៌ទាំងនេះ ជា ៥ ចំណែកនោះឯង ដោយអសុភៈ ។ ដូចម្ដេច ។ ធម្មតាសក់ទាំងនេះ ដោយវណ្ណៈ មិនស្អាត ជារបស់បដិកូល គួរខ្ពើមយ៉ាងក្រៃលែង ។ ពិតហើយ មនុស្សទាំងឡាយឃើញសំបកឈើ ឬសរសៃអំបោះ មានពណ៌ដូចសក់ ដែលធ្លាក់ទៅក្នុងទឹក ឬក្នុងបាយវេលាថ្ងៃ រមែងលះបង់ ឬខ្ពើមទឹក និងបាយសូម្បីជារបស់ពេញចិត្ត ដោយសម្គាល់ថា សក់ ។ សូម្បីដោយសណ្ឋាន ក៏មិនស្អាត ។ ពិតណាស់ មនុស្សទាំងឡាយប៉ះពាល់សំបកឈើ ប៉ះពាល់សរសៃអំបោះ ដែលមានសណ្ឋានដូចសក់ ដែលធ្លាក់ចុះទៅក្នុងទឹក និងបាយ ក្នុងវេលាយប់ រមែងលះបង់ចោល ឬខ្ពើមទឹក និងបាយសូម្បីជារបស់ពេញចិត្ត ដោយសម្គាល់ថា សក់ ។ សូម្បីដោយក្លិន ក៏មិនស្អាត ។ ពិតហើយ សក់ទាំងឡាយ ដែលវៀរចាកការតុបតែង មានលាបប្រេង ចងផ្កាឈើ អប់ផ្សែងភ្លើងជាដើម ក៏មានក្លិនស្អុយ គួរឆ្អើសយ៉ាងក្រៃលែង មនុស្ស (សត្វទាំងឡាយ) ស្រូបក្លិនសក់ដែលបោះចូលក្នុងភ្លើង ត្រូវបិទប្រមុះ គេចចេញពីក្លិនអាក្រក់ ។ សូម្បីដោយទីនៅ ក៏

មិនស្អាត ។ ពិតណាស់ សក់ទាំងនោះ ដែលដល់នូវការសន្សំហើយ ក៏កពូនធ្វើការរារាំងការហូរមកនៃទឹកប្រមាត់ ស្លេស្ម ខ្ទុះ និងឈាម ដូចដើមម្រះព្រៅជាដើមក្នុងគំនរសម្រាម ដោយការហូរមកកកនូវវត្ថុមិនស្អាតរបស់មនុស្សផ្សេងៗ ។ សូម្បីដោយឱកាស ក៏មិនស្អាត ។ ពិតហើយ សក់ទាំងនោះ កើតក្នុងស្បែកខ្ចី ដែលបិទបាំងសីសៈរបស់មនុស្សទាំងឡាយលើកំពូលគំនរសាកសព ៣១ មានរោមជាដើម ដែលគួរខ្ពើមដ៏ក្រៃលែងដូចដើមម្រះព្រៅជាដើម ក្នុងគំនរសម្រាម ។ ក្នុងសាកសព ៣១ មានរោមជាដើម ក៏ន័យនេះ ។ ព្រះយោគាវចរនេះ មនសិការធម៌ទាំងនេះដែលប្រាកដដោយអសុភៈ ជារបស់មិនស្អាត ដោយប្រការយ៉ាងនេះ ។

ប្រសិនបើថា ធម៌ទាំងនេះប្រាកដដល់ព្រះយោគាវចរនោះ ដោយវណ្ណៈ បើដូច្នោះ សក់ទាំងឡាយក៏ប្រាកដដោយអំណាចនីលកសិណ ។ រោមធ្មេញ ក៏ដូច្នោះ រមែងប្រាកដដោយអំណាចឱទាតកសិណ ។ ក្នុងទុត្តិ-ស្សាការគ្រប់ប្រការ ក៏ដូចគ្នានឹងន័យនេះ ។ ព្រះយោគាវចរនេះ រមែងមនសិការក្នុងធម៌ទាំងនេះ ដោយអំណាចកសិណនោះៗ ឯង ។ ធម៌ដែល

ប្រាកដដោយវណ្ណៈយ៉ាងនេះ ព្រះយោគាវចរក៏មនសិការដោយវណ្ណៈ ។

ប្រសិនបើធម៌ទាំងនោះ ប្រាកដដល់ព្រះយោគាវចរនោះ ដោយភាពជារបស់សូន្យ ដូច្នោះ សក់ទាំងឡាយរមែងប្រាកដដោយការប្រជុំនៃវិនិព្ភោគរូបដែលមានឱជាគម្រប់ ៨ ដោយការកំណត់ចែកជាកលាបៈ ។ រោមជាដើម ក៏ប្រាកដដូចសក់ប្រាកដ ។ ព្រះយោគាវចរនេះ រមែងមនសិការក្នុងធម៌ទាំងនោះយ៉ាងនោះដូចគ្នា ។ ធម៌ដែល ប្រាកដដោយភាពជារបស់សូន្យទទេនេះ ក៏មនសិការដោយភាពជារបស់សូន្យទទេ ។

ព្រះយោគាវចរនេះ មនសិការយ៉ាងនេះ ឈ្មោះថា មនសិការក្នុងធម៌ទាំងនោះតាមលំដាប់ ។ បទថា **ដោយតាមលំដាប់** អធិប្បាយថា ព្រះយោគាវចរ បណ្តាយតាមសក់ដែលប្រាកដដោយអសុភៈជាដើមណាមួយ ហើយមនសិការនូវរោម ជាអ្នកព្រងើយក្នុងសក់ទាំងឡាយ ហើយមនសិការចំពោះរោមទាំងឡាយ កាលមនសិការក្នុងរោមទាំងឡាយ ក៏ឈ្មោះថា រមែងព្រលែងអំពីសក់ ប្រៀបដូចជាឈ្លើងព្រងើយត្រង់ប្រទេស ដែលតោងដោយកន្ទុយ តោងត្រង់ប្រទេសដទៃដោយមាត់ កាលតោងប្រទេសនោះឯង ក៏

ឈ្មោះថា បោះបង់ប្រទេសដទៃៗ ចេញ ដូច្នោះ ។ ក្នុងទ្វត្តិង្សាការគ្រប់យ៉ាង ក៏ន័យនេះ ។ ធម៌ទាំងនោះ កាលប្រាកដដល់ព្រះយោគាវចរនោះ ដែលមនសិការដោយតាមលំដាប់យ៉ាងនេះ រមែងប្រាកដមិនសេសសល់ គឺប្រាកដកាន់តែច្បាស់ជាង ។

កាលបើដូច្នោះ ធម៌ពួកណា ប្រាកដ **ដោយភាពជារបស់មិនស្អាត** ដល់ព្រះយោគាវចរណា ទាំងប្រាកដច្បាស់ជាង ប្រៀបដូចស្វាត្រូវព្រានដេញទៅក្នុងព្រៃត្នោត ៣២ ដើម រមែងលោតពីដើមមួយទៅដើមមួយ កាលលោតត្រឡប់មកវិញក៏ហត់ ។ កាលនោះ ទើបឈប់ត្រង់ដើមត្នោតល្អមួយដើម ដែលមានស្លឹកក្រាស់ប៉ុណ្ណោះ យ៉ាងណា ស្វា គឺ ចិត្តរបស់ព្រះយោគាវចរនោះ ក៏ដូច្នោះ ដែលព្រះយោគាវចរនោះៗ ឯង ពិចារណាក្នុងកាយនេះ ដែលមាន ៣២ ចំណែក មិនបញ្ឈប់សូម្បីតែមួយចំណែក រមែងស្ទុះទៅ កាលត្រឡប់ ព្រោះមិនមានសេចក្តីប្រាថ្នាក្នុងការស្ទុះទៅក្នុងអារម្មណ៍ដ៏ច្រើន ក៏នឿយហត់ ។ លំដាប់នោះ ធម៌ណារបស់ព្រះយោគាវចរនោះស្ទាត់ជំនាញ ឬសមគួរដល់ចរិតជាង ក្នុងអាការ ៣២ មានសក់ជាដើម ឬ

ជាអ្នកបំពេញបារមីទុកអំពីមុនក្នុងធម៌ណា ក៏អាស្រ័យធម៌នោះ ហើយស្ថិតនៅដោយអំណាចឧបចារសមាធិ ។ កាលបើដូច្នោះ ព្រះយោគាវចរធ្វើនូវនិមិត្តនោះៗ ឯង ឲ្យដល់វិត្តកៈ វិត្តកៈត្រិះរិះរឿយៗ ក៏ធ្វើបឋមជ្ឈានឲ្យកើតឡើងតាមលំដាប់ តាំងនៅក្នុងបឋមជ្ឈាននោះហើយ ផ្ដើមវិបស្សនា រមែងសម្រេចអរិយភូមិបាន ។

ម្យ៉ាងទៀត ធម៌ទាំងនោះ រមែងប្រាកដ **ដោយវណ្ណៈ** ដល់ព្រះយោគាវចរណា ប្រៀបដូចស្វាត្រូវព្រានដេញនៅក្នុងព្រៃត្នោត ៣២ ដើម មិនហ៊ានឈប់សូម្បីមួយដើម កាលណាត្រឡប់ក៏នឿយហត់ ។ កាលនោះ ទើបឈប់ត្រង់ត្នោតល្អមួយដើម ដែលមានស្លឹកក្រាស់ប៉ុណ្ណោះ យ៉ាងណា ស្វា គឺ ចិត្តរបស់ព្រះយោគាវចរនោះ ក៏ដូច្នោះដែរ ព្រះយោគាវចរនោះៗ ឯង ពិចារណាក្នុងកាយនេះ ដែលមានអាការ ៣២ គឺ មិនឲ្យឈប់សូម្បីតែក្នុងអាការ ១ ហើយស្ទុះទៅ កាលណាត្រឡប់ ព្រោះមិនមានការប្រាថ្នាស្ទុះទៅកាន់អារម្មណ៍ដ៏ច្រើន ក៏នឿយហត់ កាលនោះ ធម៌ណារបស់ព្រះយោគាវចរនោះ ស្ទាត់ជំនាញ ឬសមគួរដល់ចរិតជាង ក្នុងអាការ ៣២

មានសក់ជាដើម ឬជាអ្នកបំពេញបារមីមកអំពីមុនក្នុងធម៌ណា ក៏អាស្រ័យធម៌នោះ ឲ្យតាំងនៅដោយអំណាចឧបចារសមាធិ ។ កាលនោះ ព្រះយោគាវចរធ្វើនូវនិមិត្តនោះៗ ឯង ឲ្យដល់វិត្តក: កាលត្រូវវិត្តក:ត្រិះរិះរឿយៗ ក៏នឹងធ្វើឲ្យកើតរូបាវចរឈានសូម្បីទាំង ៥ ដោយនីលកសិណ ឬដោយបិតកសិណ តាមលំដាប់ និងតាំងនៅក្នុងរូបាវចរឈាននោះណាមួយ ផ្តើមចម្រើនវិបស្សនា ក៏នឹងសម្រេចអរិយភូមិបាន ។

ម្យ៉ាងទៀត ធម៌ទាំងនោះ ប្រាកដ ដោយជារបស់ទទេ ដល់ព្រះយោគាវចរណា ព្រះយោគាវចនោះ រមែងមនសិការដោយលក្ខណ: កាលមនសិការដោយលក្ខណ: រមែងលុះឧបចារឈាន ដោយកំណត់ធាតុ ៤ ក្នុងធម៌ទាំងនោះ ដូច្នោះ កាលមនសិការ ក៏មនសិការក្នុងធម៌ទាំងនោះដោយសូត្រទាំង ៣ គឺ មិនទៀង ជាទុក្ខ ជាអនត្តា ។ នេះជាវិបស្សនាន័យរបស់ព្រះយោគាវចរនោះ ។ ព្រះយោគាវចរផ្តើមចម្រើនវិបស្សនានេះនិងបដិបត្តិទៅតាមលំដាប់ ក៏រមែងសម្រេចអរិយភូមិបាន ។

ក៏ពាក្យណាដែលខ្ញុំពោលទុកថា ព្រះយោគាវចរនេះ មនសិការក្នុង

ធម៌ទាំងនោះ ដោយអំណាចនៃអនុបុព្វៈជាដើមណា ពាក្យនោះ ក៏ជាការដែលខ្ញុំព្យាករណ៍ហើយដោយកថាមានប្រមាណប៉ុណ្ណេះ ។ មួយវិញទៀត ពាក្យណាដែលខ្ញុំពោលទុកថា គប្បីជ្រាបការពណ៌នាបាឋៈនោះយ៉ាងនេះ ដោយការនៃ ។ អត្ថរបស់ពាក្យនោះ ក៏ខ្ញុំប្រកាសហើយនោះឯង ។

# បកិណ្ណកន័យ

## (ន័យបន្ថែម)

ឥឡូវនេះ គប្បីជ្រាបបកិណ្ណកន័យនេះ ដើម្បីសេចក្តីជំនាញ និងការឈ្លាសក្នុងទុក្ខនិង្យាការនេះថា ៖

និមិត្តតោ លក្ខណតោ ធាតុតោ សុញ្ញតោបិ ច

ខន្ធាទិតោ ច វិញ្ញេយ្យោ ទុក្ខសាការនិច្ឆយោ ។

គប្បីជ្រាបការវិនិច្ឆ័យទុក្ខនិង្យាការ ដោយនិមិត្ត ដោយលក្ខណៈ ដោយធាតុ ដោយភាពសូន្យទទេ និងដោយខន្ធជាដើម ។

បណ្តាបកិណ្ណកៈនោះ បទថា ដោយនិមិត្ត សេចក្តីថា ក្នុងទុក្ខនិង្យាការនេះ មានប្រការដូចពោលមកហើយនេះ មាននិមិត្ត ១៦០ ដែលព្រះយោគាវចរអាចកំណត់ទុក្ខនិង្យាការបានដោយកោដ្ឋាសៈ គឺ ជាចំណែកៗ គឺ សក់មាននិមិត្ត ៥ គឺ វណ្ណៈ (ពណ៌) សណ្ឋាន (ទ្រង់ទ្រាយ) ទិសា (ទិស) ឱកាស (ទីកើត) បរិច្ឆេទ (ការកំណត់) ក្នុងរោមជាដើម ក៏ន័យនេះ ។

បទថា ដោយលក្ខណៈ ក្នុងទុក្ខនិង្យាការ មានលក្ខណៈ ១២៨ ដែល

ព្រះយោគាវចរអាចមនសិការទ្វត្តិង្សាការបានដោយលក្ខណៈ គឺ សក់មាន ៤ លក្ខណៈ គឺ លក្ខណៈរឹង លក្ខណៈកកផ្ញុំ លក្ខណៈក្តៅ លក្ខណៈកម្រើក ។ ក្នុងពោមជាដើម ក៏ន័យនេះ ។

បទថា **ដោយធាតុ** ក្នុងទ្វត្តិង្សាការ ក្នុងធាតុទាំងឡាយដែលព្រះមានព្រះភាគត្រាស់ទុកក្នុងបាលីនេះថា "ម្នាលភិក្ខុទាំងឡាយ បុរសនេះមានធាតុ ៤" ដូច្នេះ មានធាតុ ១២៨ ដែលព្រះយោគាវចរអាចកំណត់ទ្វត្តិង្សាការបានដោយធាតុ គឺ ក្នុងសក់មានធាតុ ៤ គឺ ចំណែករឹង ជាបឋវីធាតុ ។ ចំណែកសើមជ្រួតជ្រាប ជាអាបោធាតុ ។ ចំណែកដែលក្តៅ ជាតេជោធាតុ ។ ចំណែកកម្រើក ជាវាយោធាតុ ។ ក្នុងពោមជាដើម ក៏មានន័យនេះ ។

បទថា **ដោយភាពសូន្យទទេ** ក្នុងទ្វត្តិង្សាការ មានសុញ្ញតា ១២៨ ដែលព្រះយោគាវចរអាចពិចារណាឃើញទ្វត្តិង្សាការ ដោយភាពសូន្យទទេ គឺ ក្នុងសក់ មានសុញ្ញតា ៤ គឺ បឋវីធាតុ សូន្យចាកអាបោធាតុជាដើម អាបោធាតុជាដើមក៏យ៉ាងនោះ សូន្យចាកបឋវីធាតុជាដើម ។ ក្នុងពោមជាដើម

ក៏យ៉ាងនោះ ។

បទថា **ដោយខន្ធជាដើម** ក្នុងទូត្តិន្យាការ ក្នុងសក់ជាដើម លោកសង្រ្គោះដោយខន្ធជាដើម គប្បីជ្រាបវិនិច្ឆ័យដោយន័យជាដើមយ៉ាងនេះថា សក់ទាំងឡាយមានខន្ធប៉ុន្មាន មានអាយតនៈប៉ុន្មាន មានធាតុប៉ុន្មាន មានសច្ចៈប៉ុន្មាន មានសតិប្បដ្ឋានប៉ុន្មាន ។ កាយរមែងប្រាកដដូចគំនរស្មៅនិងឈើ ដល់ព្រះយោគាវចរនោះ ដែលពិចារណាឃើញយ៉ាងនេះ ដូចលោកពោលទុកថា ៖

នត្ថិ សត្តោ នរោ បោសោ បុគ្គលោ នូបលព្ភតិ
សុញ្ញភូតោ អយំ កាយោ តិណកដ្ឋសមូបមោ ។

មិនមានសត្វ នរៈ បុរស មិនមានបុគ្គល កាយនេះ
មានសភាពសូន្យទទេ ប្រៀបដូចជាស្មៅ និងឈើ ។

ម្យ៉ាងទៀត ការត្រេកអរនោះឯណា ដែលមិនមែនជារបស់មនុស្ស ដែលលោកពោលទុកយ៉ាងនេះថា ៖

សុញ្ញាគារំ បវិដ្ឋស្ស សន្តចិត្តស្ស តាទិនោ

អមានុសី រតិ ហោតិ សម្មា ធម្មំ វិបស្សតោ ។

លោកចូលទៅកាន់ផ្ទះស្ងាត់ មានចិត្តស្ងប់ គង់ពិចារណា

ឃើញធម៌ដោយប្រពៃ រមែងមានការត្រេកអរ ដែលមិន

មែនជារបស់មនុស្ស ។

សេចក្តីត្រេកអរនោះនៅមិនឆ្ងាយឡើយ ។ តពីនោះ អមត: គឺ បីតិ និងបាមោជ្ជ:នោះឯណា ដែលសម្រេចមកពីវិបស្សនា ដែលព្រះមាន-ព្រះភាគត្រាស់ទុកយ៉ាងនេះថា ៖

យតោ យតោ សម្មសតិ ខន្ធានំ ឧទយព្វយំ

លភតិ បីតិបាមោជ្ជំ អមតំ តំ វិជានតំ ។

បុគ្គលពិចារណាឃើញការកើត និងការរលត់នៃខន្ធ

ទាំងឡាយដោយប្រការណាៗ បីតិ និងបាមោជ្ជ: ដែល

ជាអមត: រមែងបានដល់បុគ្គលអ្នកពិចារណា ឃើញការ

កើតរលត់នោះ ដោយប្រការនោះៗ ។

ព្រះយោគាវចរ កាលសោយបីតិ និងបាមោជ្ជ: ដែលជាអមត:នោះ

មិនយូរឡើយ ក៏នឹងធ្វើឲ្យជាក់ច្បាស់អមតៈ គឺ ព្រះនិព្វានដែលមិនចាស់ មិនស្លាប់ ដែលអរិយជនសេពហើយនោះឯង ។

បរមត្ថជោតិកាយ ខុទ្ទកាចាឋដ្ឋកថាយ

ទិត្តិសាការវណ្ណនា និដ្ឋិតា

ចប់អដ្ឋកថា អាការ ៣២ ប្រការ

នៃអដ្ឋកថាខុទ្ទកចាឋៈ ឈ្មោះ បរមត្ថជោតិកា ។

# អដ្ឋកថា កុមារបញ្ហា

## (វត្ថុប្បត្តិ ហេតុកើតរឿង)

[៤] ឥឡូវនេះ តាមលំដាប់ពណ៌នាអត្ថនៃកុមារបញ្ហា (សាមណេរ-បញ្ហា) ជាដើមយ៉ាងនេះថា **ឯកំ នាម កឹ (អ្វីឈ្មោះថា ១)** ។ ខ្ញុំនឹងពោលហេតុកើតរឿងរបស់កុមារបញ្ហាទាំងនោះ និងប្រយោជន៍នៃការដាក់បទតាំងក្នុងទីនេះហើយ ទើបនឹងពោលការពណ៌នាសេចក្តី ។

នឹងពោលហេតុកើតរឿងរបស់កុមារបញ្ហាទាំងនោះមុន ។ ឈ្មោះថា **សោបាកៈ** ជាព្រះមហាសាវករបស់ព្រះមានព្រះភាគ ។ ព្រះសោបាកៈនោះសម្រេចព្រះអរហត្តកាលអាយុបាន ៧ ខួបដោយកំណើត ។ ព្រះមានព្រះ-ភាគ ទ្រង់មានពុទ្ធបំណងអនុញ្ញាតការឧបសម្បទា ដោយការព្យាករណ៍បញ្ហាដល់លោក ទ្រង់ឃើញថា លោកជាអ្នកអាចព្យាករណ៍បញ្ហាទាំងឡាយដែលមានអត្ថតាមព្រះពុទ្ធបំណងហើយ ទើបត្រាស់សួរបញ្ហា ដោយន័យជាដើមយ៉ាងនេះថា **ធម្មជាតអ្វី ឈ្មោះថា ១** ។ លោកក៏ព្យាករណ៍ហើយធ្វើព្រះទ័យរបស់ព្រះមានព្រះភាគ ឲ្យទ្រង់រីករាយដោយការព្យាករណ៍នោះ ។

ដោយបញ្ហានោះឯង ទើបបានជាឧបសម្បទារបស់ព្រះសោបាកៈនោះ ។

នេះជាហេតុកើតរឿងរបស់សាមណេរបញ្ហាទាំងនោះ ។

## ប្រយោជន៍នៃការតាំងបទ

ក៏ព្រោះហេតុដែលប្រកាសចិត្តការនា ដោយឮកដល់ព្រះពុទ្ធ ព្រះធម៌ និងព្រះសង្ឃដោយសរណគមន៍ ប្រកាសសីលការនាដោយសិក្ខាបទ និង ប្រកាសកាយការនាដោយទ្វត្តិង្សាការ ដូច្នោះ ឥឡូវនេះ ទើបដាក់ការព្យា-ករណ៍បញ្ហាទាំងនេះជាបទតាំងក្នុងទីនេះ ដើម្បីសំដែងមុខ គឺ បញ្ញាការនា ដោយប្រការផ្សេងៗ ។ ឬព្រោះហេតុដែលសមាធិ មានសីលជាបទដ្ឋាន និងបញ្ញា មានសមាធិជាបទដ្ឋាន ដូចព្រះមានព្រះភាគត្រាស់ទុកថា "នរជន អ្នកមានបញ្ញា តាំងនូវក្នុងសីល ចម្រើនចិត្ត និងបញ្ញា" ដូច្នេះ ។ ដូច្នោះ ទើបគួរជ្រាបថា គ្រាខ្ញុំសំដែងសីលដោយសិក្ខាបទទាំងឡាយ និងសមាធិ ដែលមានសីលនោះជាគោចរ ដោយទ្វត្តិង្សាការហើយ ទើបដាក់បញ្ហាព្យាករ

ជាបទតាំងទុកក្នុងទីនេះ ដើម្បីសំដែងប្រភេទនៃបញ្ហាដែលជាគ្រឿងពិចារណាធម៌ផ្សេងៗ សម្រាប់បុគ្គលអ្នកមានចិត្តតាំងមាំហើយ ។

នេះជាប្រយោជន៍នៃការដាក់បញ្ហាទាំងនោះជាបទតាំងក្នុងទីនេះ ។

## ពណ៌នាបញ្ហាថា អ្វីឈ្មោះថា ១

ឥឡូវនេះ នឹងពណ៌នាអត្ថនៃបញ្ហាទាំងនោះ ។ ភិក្ខុកាលនឿយណាយដោយល្អក្នុងធម៌ណាមួយ រមែងធ្វើទីបំផុតទុក្ខបានដោយលំដាប់ ម្យ៉ាងទៀត ព្រះសោបាកៈនេះ កាលនឿយណាយក្នុងធម៌មួយ បានធ្វើទីបំផុតទុក្ខហើយដោយលំដាប់ ព្រះមានព្រះភាគទ្រង់សំដៅដល់ធម៌នោះ ទើបត្រាស់សួរបញ្ហាថា ឯកំ នាម កឹ (អ្វីឈ្មោះថា ១) ។ ព្រះថេរៈទូលឆ្លើយដោយទេសនាជាបុគ្គលាធិដ្ឋានថា **សព្វេ សត្តា អាហារដ្ឋិតិកា (សត្វទាំងពួង តាំងនៅបានដោយអាហារ)** ។ ក្នុងបទនេះ ព្រះសូត្រទាំងឡាយមានជាដើមយ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ សម្មាសតិ ដូចម្តេច ។ ភិក្ខុក្នុងធម្មវិន័យនេះ

ពិចារណាឃើញកាយក្នុងកាយ ដូច្នេះ ជាគ្រឿងសាធកៈក្នុងបទយុត្តិនៃការឆ្លើយតបយ៉ាងនេះ ។ ក្នុងប្រការនេះ សត្វទាំងពួងលោកពោលថា "តាំងនៅបានដោយអាហារ ដោយអាហារណា" អាហារនោះ ឬដែលសត្វទាំងនោះតាំងនៅបានដោយអាហារ គប្បីជ្រាបថា ព្រះថេរៈដែលត្រូវត្រាស់សួរថា អ្វីហ្ន៎ ឈ្មោះថា ១ ទូលតបហើយ ។ ពិតណាស់ បទនោះ ព្រះមានព្រះភាគទ្រង់បំណងថា ឈ្មោះថា ១ ក្នុងទីនេះ តែមិនមែនត្រាស់ដើម្បីឲ្យដឹងថា ឈ្មោះថា ១ យ៉ាងដទៃ ក្នុងព្រះសាសនា ឬក្នុងលោក មិនមានឡើយ ។ សេចក្តីពិត ព្រះមានព្រះភាគត្រាស់ទុកថា ៖

ម្នាលភិក្ខុទាំងឡាយ ក្នុងធម៌មួយ ភិក្ខុកាលនឿយណាយដោយប្រពៃ កាលប្រាសចាកដោយប្រពៃ កាលរួចផុតដោយប្រពៃ ឃើញទីបំផុតដោយប្រពៃ ត្រាស់ដឹងធម៌ដោយប្រពៃ រមែងជាអ្នកធ្វើទីបំផុតទុក្ខបានក្នុងទិដ្ឋធម៌ (បច្ចុប្បន្ន) ក្នុងធម៌មួយដូចម្តេច គឺ ក្នុងធម៌មួយថា សត្វទាំងពួងតាំងនៅបានដោយអាហារ ។

ម្នាលភិក្ខុទាំងឡាយ ក្នុងធម៌មួយនេះឯង ភិក្ខុកាល
នឿយណាយដោយប្រពៃ កាលប្រាសចាកដោយប្រពៃ
កាលរួចផុតដោយប្រពៃ ឃើញទីបំផុតដោយប្រពៃ ត្រាស់
ដឹងធម៌ដោយប្រពៃ រមែងជាអ្នកធ្វើទីបំផុតទុក្ខបានក្នុង
ទិដ្ឋធម៌ ពាក្យនោះណា តថាគតពោលថា ជាបញ្ហា ១
ឧទ្ទេស ១ វេយ្យាករណ៍ ១ ដូច្នេះ ពាក្យនេះ តថាគត
អាស្រ័យបទនោះពោលហើយ ។

ក្នុងបទថា (អាហារដ្ឋិតិកា) តាំងនៅបានដោយអាហារ នេះ ព្រះថេរៈ កាន់យកបច្ច័យ ដោយអាហារស័ព្ទ ហៅសត្វទាំងពួងដែលតាំងនៅបានដោយបច្ច័យថា តាំងនៅបានដោយអាហារ ដូចបច្ច័យ លោកហៅថា អាហារ ក្នុងព្រះបាលីមានជាដើមយ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ សុភនិមិត្ត មានហើយ ការធ្វើឲ្យច្រើនដោយការមនសិការមិនប្រពៃក្នុងសុភនិមិត្តនោះ មានហើយ នេះជាអាហារដើម្បីការកើតកាមច្ឆន្ទៈ ដែលនៅមិនទាន់កើតឡើង ដូច្នោះ ។ តែកាលលោកសំដៅយកអាហារ ៤ ពោលថា “តាំងនៅបាន

ដោយអាហារ” ដូច្នេះ ។ បទថា ទាំងពួង ក៏មិនទាន់ត្រឹមត្រូវនៅឡើយ ព្រោះព្រះបាលីថា ទេវតាជាអសញ្ញីសត្វ មិនមានហេតុ មិនមានអាហារ មិនមានផស្សៈ មិនមានវេទនា ។

ក្នុងបទនោះ គប្បីមានពាក្យបញ្ជាក់ដូច្នេះ សូម្បីកាលត្រូវពោល យ៉ាងនេះ ការដែលខន្ធទាំងឡាយប៉ុណ្ណោះ តាំងនៅបានដោយបច្ច័យ ក៏ត្រូវ ព្រោះព្រះបាលីថា ធម៌ពួកណាមានបច្ច័យ ។ បញ្ចក្ខន្ធ គឺ រូបក្ខន្ធ ។ល។ វិញ្ញាណក្ខន្ធ តែសត្វទាំងឡាយតាំងនៅបានដោយបច្ច័យ ។ ពាក្យនេះនឹង ឃើញថាមិនត្រូវ ។ បទនេះ មិនគួរពោលយ៉ាងនេះ ។ ព្រោះហេតុអ្វី ។ ព្រោះពោលរួមទុកដល់ខន្ធក្នុងសត្វទាំងឡាយ ។ ពិតហើយ លោកពោល រួមទុកដល់ខន្ធក្នុងសត្វទាំងឡាយហើយ ។ ព្រោះហេតុអ្វី ។ ព្រោះលោក អាស្រ័យខន្ធទាំងឡាយហើយ ទើបបញ្ញត្តិទុក ។ ដូចម្តេច ។ ដូចឧបចារៈ ផ្ទះ គឺ កាលផ្ទះមួយខ្នង ឬពីរខ្នង សូម្បីបីខ្នង ត្រូវភ្លើងឆេះ ក៏ពោលរួម ទុកដល់ផ្ទះក្នុងស្រុកយ៉ាងនេះថា “ផ្ទះត្រូវភ្លើងឆេះ” ព្រោះអាស្រ័យផ្ទះច្រើន ខ្នង ទើបបញ្ញត្តិ យ៉ាងណា គប្បីជ្រាបថា ក៏ជាការពោលរួមសេចក្តីទុកថា

សត្វទាំងឡាយ តាំងនៅបានដោយអាហារ ដូច្នេះ ក្នុងសត្វទាំងឡាយដែលតាំងនៅបានព្រោះអាហារ ព្រោះអត្ថថា ជាបច្ច័យក្នុងខន្ធទាំងឡាយ ក៏ដូច្នោះដូចគ្នា ។ តែកាលពោលដោយបរមត្ថ គប្បីជ្រាបថា កាលខន្ធទាំងឡាយកើត ចាស់ និងស្លាប់ ព្រះមានព្រះភាគកាលត្រាស់ថា ម្នាលភិក្ខុ អ្នកកើត ចាស់ និងស្លាប់គ្រប់ខណៈ ដូច្នេះ គឺ ទ្រង់សំដែងថា ត្រាស់រួមដល់ខន្ធទុកជាស្រេចក្នុងសត្វទាំងនោះ ។ កាលណា សត្វទាំងពួងតាំងនៅបានដោយអាហារ គឺ បច្ច័យយ៉ាងណា អាហារនោះ ឬការដែលសត្វតាំងនៅបានដោយអាហារ គប្បីជ្រាបថា មាន ។ ព្រោះថា អាហារ ឬការដែលសត្វតាំងនៅបានដោយអាហារ រមែងជាឋានទីតាំងនៃនិព្វិទា (សេចក្តីនឿយណាយ) ព្រោះជាហេតុនៃអនិច្ចតា (ភាពជារបស់មិនទៀង) ។ ដូច្នោះភិក្ខុកាលនឿយណាយ ព្រោះឃើញអនិច្ចតាក្នុងសង្ខារទាំងឡាយ ដែលគេសម្គាល់ថា ជាសត្វទាំងឡាយនោះ រមែងជាអ្នកធ្វើទីបំផុតទុក្ខបានដោយលំដាប់ រមែងសម្រេចបរមត្ថវិសុទ្ធិ (សេចក្តីបរិសុទ្ធដោយបរមត្ថ) ។ ដូចដែលត្រាស់ទុកថា ៖

សព្វេ សង្ខារា អនិច្ចាតិ   យទា បញ្ញាយ បស្សតិ
អថ និព្វិន្ទតិ ទុក្ខេ   ឯស មគ្គោ វិសុទ្ធិយា ។

កាលណាឃើញដោយបញ្ញាថា សង្ខារទាំងពួងមិនទៀង
កាលនោះ រមែងនឿយណាយក្នុងទុក្ខ នោះជាផ្លូវនៃ
សេចក្ដីបរិសុទ្ធិ ។

ក៏ក្នុងបញ្ហាដំបូងនេះ មានបាឋៈ ២ យ៉ាងថា ឯកំ នាម កឹ និង (ឯកំ នាម) កិហ ។ ក្នុងបាឋៈទាំង ២ នោះ បាឋៈអ្នកសីហឡៈថា កិហៈ ព្រោះថា ជនជាតិសីហឡៈទាំងនោះ ពោលជំនួសថា កឹ ក៏ពោលថា កិហ ។ អាចារ្យជនជាតិសីហឡៈពួកខ្លះពោលថា ពាក្យថា ហ ជានិបាត បាឋៈ សូម្បីរបស់ពួកអ្នកកាន់លទ្ធិចំណែកថេរវាទ ក៏យ៉ាងនេះដូចគ្នា ។ តែទាំង ២ បាឋៈ សេចក្ដីដូចគ្នា ។ ពេញចិត្តយ៉ាងណា គប្បីសូត្រ គប្បីពោល យ៉ាងនោះចុះ ។ ឧបមាថា បុគ្គលខ្លះក៏ពោលថា ទុខំ និងខ្លះទៀតក៏ពោលថា ទុក្ខំ ក្នុងបាលីទាំងឡាយជាដើមយ៉ាងថា ទុខេន ផុដ្ឋា អថ វា ទុខេន ទុក្ខំ ទោមនស្សំ បដិសំវេទេតិ យ៉ាងណា កន្លែងខ្លះក៏ពោលថា ឯកំ កន្លែង

ខ្វះក៏ពោលថា ឯក្កំ ក៏ដូច្នោះ ។ តែក្នុងទីនេះ មានបាឋៈនេះតែម្យ៉ាងថា **ឯកំ នាម** ។

## ពណ៌នាបញ្ហាថា អ្វី ឈ្មោះថា ២

ព្រះសាស្ដា ទ្រង់មានព្រះទ័យដែលព្រះថេរៈធ្វើឲ្យរីករាយដោយការព្យាករណ៍បញ្ហានេះហើយ ទើបត្រាស់សួរបញ្ហាតទៅទៀត ដូចន័យដំបូងថា **ទ្វេ នាម កឹ (អ្វី ឈ្មោះថា ២)** ។ ព្រះថេរៈពោលដដែលថា **២** ទូលឆ្លើយដោយទេសនាជាធម្មាធិដ្ឋានថា គឺ **នាម និងរូប** ។ បណ្ដានាម និងរូបនោះ ធម្មជាតិដែលមិនមែនជារូបទាំងអស់ លោកហៅថា **នាម** ព្រោះបង្អោនទៅកាន់អារម្មណ៍ ព្រោះជាហេតុបង្អោនចិត្តទៅ ។ តែក្នុងទីនេះ លោកបំណងយកធម៌ដែលប្រកបដោយអាសវៈប៉ុណ្ណោះ ព្រោះជាហេតុនៃនិព្វិទា (សេចក្ដីនឿយណាយ) ។ ចំណែកមហាភូតរូបទាំង ៤ និងរូបទាំងអស់អាស្រ័យមហាភូតរូបនោះប្រព្រឹត្តទៅ លោកហៅថា **រូប** ព្រោះអត្ថថា បែកធ្លាយ ។ រូបនោះ ក្នុងទីនេះ លោកបំណងយកទាំងអស់ ។ តែព្រះថេរៈពោលទុកក្នុងទីនេះថា ឈ្មោះថា ២ គឺ នាម និងរូប ក៏ដោយ

បំណងនេះឯង មិនមែនពោលព្រោះធម៌ ២ ដទៃ ។ ដូចទ្រង់ត្រាស់ទុកថា ៖

ម្នាលភិក្ខុទាំងឡាយ ក្នុងធម៌ ២ យ៉ាង កាលភិក្ខុ នឿយណាយដោយប្រពៃ ។ល។ រមែងជាអ្នកធ្វើទីបំផុតទុក្ខបាន ។ ក្នុងធម៌ ២ យ៉ាងដូចម្តេច ធម៌ ២ ប្រការ គឺ នាម និងរូប ។

ម្នាលភិក្ខុទាំងឡាយ ក្នុងធម៌ ២ យ៉ាងនេះឯង ភិក្ខុ នឿយណាយដោយប្រពៃ ។ល។ រមែងជាអ្នកធ្វើទីបំផុតទុក្ខបាន ។ ពាក្យនោះ តថាគតពោលថា បញ្ហា ២ ឧទ្ទេស ២ វេយ្យាករណ៍ ២ ដូច្នេះ ពាក្យនេះ តថាគតអាស្រ័យប្រការនោះ ពោលហើយ ។

ក៏ក្នុងបញ្ហាប្រការនេះ គប្បីជ្រាបថា ភិក្ខុលះអត្តទិដ្ឋិ (ការឃើញថាជាខ្លួន) ដោយការឃើញត្រឹមនាមរូបហើយ កាលនឿយណាយដោយការពិចារណាឃើញ (នាមរូប) ជាអនត្តាជាខាងមុខ រមែងជាអ្នកធ្វើទីបំផុតទុក្ខបានដោយលំដាប់ គឺ រមែងលុះបរមត្ថវិសុទ្ធិបាន ដូចទ្រង់ត្រាស់ទុកថា ៖

*សព្វេ ធម្មា អនត្តាតិ យទា បញ្ញាយ បស្សតិ*

*អថ និព្វិន្ទតិ ទុក្ខេ ឯស មគ្គោ វិសុទ្ធិយា ។*

*កាលណា ឃើញដោយបញ្ញាថា ធម៌ទាំងពួងជាអនត្តា*

*កាលនោះ រមែងនឿយណាយក្នុងទុក្ខ នេះជាផ្លូវនៃវិសុទ្ធិ*

*ដូច្នេះ ។*

ពណ៌នាបញ្ហាថា អ្វី ឈ្មោះថា ៣

*ឥឡូវនេះ ព្រះសាស្តាទ្រង់មានព្រះទ័យ ដែលព្រះថេរៈធ្វើឲ្យទ្រង់ត្រេកអរដោយការព្យាករណ៍បញ្ហានេះហើយ ទើបត្រាស់សួរបញ្ហាតទៅទៀតដូចន័យមុនៗ ថា* ***តីណិ នាម កឹ*** *(ធម្មជាតអ្វី ឈ្មោះថា ៣) ។ ព្រះថេរៈពោលថា* ***តីណិ*** *៣ កាលសំដែងសំខ្យា (រាប់) ចំនួនដែលសមគួរដល់លិង្គ (ភេទស័ព្ទ) នៃសេចក្ដីដែលគប្បីព្យាករណ៍ទៀត ទើបទូលឆ្លើយថា* ***តិស្សោ វេទនា*** *គឺ វេទនា ៣ ។ ន័យម្យ៉ាងទៀត ព្រះថេរៈគិតថា ចាំយើងនឹងត្រឡប់ពាក្យថា* ***តីណិ*** *អត្ថរបស់វេទនា ដែលព្រះមានព្រះភាគ*

ត្រាស់ទុកថា **តិស្សោ វេទនា** កាលទីងសំដែង ទើបទូលឆ្លើយ ។ បណ្ឌិត គប្បីជ្រាបសេចក្តីក្នុងប្រការនេះ ដូចពោលមកដូច្នេះ ។ ព្រោះថា ទេសនា របស់បុគ្គលអ្នកសម្រេចទេសនាដ៏វិលាស ព្រោះការបែកធ្លាយបដិសម្ភិទា មានកថាមុខដ៏ច្រើន ។ តែអាចារ្យពួកខ្លះពោលថា ពាក្យថា **តីណិ** នេះ ជាបទលើស ។ តែព្រះថេរៈពោលក្នុងទីនេះថា "វេទនា ៣" ក៏តាមន័យ មុនៗ នោះឯង មិនមែនពោលព្រោះមិនមានធម៌ ៣ យ៉ាងដទៃទេ ។ ដូច ដែលត្រាស់ទុកថា ៖

ម្នាលភិក្ខុទាំងឡាយ ក្នុងធម៌ ៣ ទាំងនេះ ភិក្ខុកាល នឿយណាយដោយប្រពៃ ។ល។ រមែងជាអ្នកធ្វើនូវ ទីបំផុតទុក្ខបាន ។ ក្នុងធម៌ ៣ ដូចម្តេច ធម៌ ៣ ប្រការ គឺ វេទនា ៣ ។ ម្នាលភិក្ខុទាំងឡាយ ក្នុង ធម៌ ៣ នេះឯង ភិក្ខុកាលនឿយណាយដោយប្រពៃ ។ល។ រមែងជាអ្នកធ្វើទីបំផុតទុក្ខបាន ។ ពាក្យណា តថាគតពោលថា បញ្ហា ៣ ឧទ្ទេស ៣ វេយ្យាករណ៍

៣ ដូច្នេះ ពាក្យនេះ គឺថាគតអាស្រ័យសេចក្តីនោះ

ពោលហើយ ដូច្នេះ ។

ក្នុងបញ្ហានេះ គប្បីជ្រាបថា ភិក្ខុលះសុខសញ្ញា (សេចក្តីសំគាល់ថាសុខ) ដោយការឃើញវេទនាទាំង ៣ ជាទុក្ខ ហើយនឿយណាយដោយការពិចារណាឃើញទុក្ខជាខាងមុខ តាមព្រះសូត្រដែលត្រាស់ទុកថា វេទនាការសោយអារម្មណ៍ណាមួយ ទាំងអស់នោះ គឺថាគតពោលថាជាទុក្ខ ឬសភាពជាទុក្ខ ព្រោះទុក្ខជាទុក្ខ ព្រោះប្រែប្រួល និងជាទុក្ខព្រោះគ្រូវបច្ច័យតាក់តែងយ៉ាងនេះថា ៖

យោ សុខំ ទុក្ខតោ អទ្ទ ទុក្ខមទ្ទក្ខិ សល្លតោ
អទុក្ខមសុខំ សន្តំ អទ្ទក្ខិ នំ អនិច្ចតោ ។

បុគ្គលណាឃើញសុខជាទុក្ខ ឃើញទុក្ខដូចជាកូនសរ
ឃើញអទុក្ខមសុខមានហើយ បុគ្គលនោះ ឈ្មោះថា
ឃើញវេទនានោះ ជារបស់មិនទៀង ដូច្នេះ ។

រមែងជាអ្នកធ្វើទីបំផុតទុក្ខបានដោយលំដាប់ គឺ រមែងលុះបរមត្ថ-

វិសុទ្ធិបាន ។ ដូចដែលត្រាស់ទុកថា ៖

សព្វេ សង្ខារា ទុក្ខាតិ យទា បញ្ញាយ បស្សតិ

អថ និព្វិន្ទតិ ទុក្ខេ ឯស មគ្គោ វិសុទ្ធិយា ។

កាលណាឃើញដោយបញ្ញាថា សង្ខារទាំងពួងជាទុក្ខ កាល

នោះ រមែងនឿយណាយក្នុងទុក្ខ នោះជាផ្លូវនៃវិសុទ្ធិ ដូច្នេះ ។

## ពណ៌នាបញ្ហាថា អ្វី ឈ្មោះថា ៤

ព្រះសាស្តាទ្រង់មានព្រះទ័យ ដែលព្រះថេរៈធ្វើឲ្យទ្រង់ត្រេកអរដោយការព្យាករណ៍បញ្ហានេះយ៉ាងនេះហើយ ទើបត្រាស់សួរបញ្ហាបន្តទៀត ដូចន័យមុនៗ ថា ចត្តារិ នាម កឹ (អ្វី ឈ្មោះថា ៤) ។ ក្នុងបញ្ហានេះ ក្នុងការព្យាករណ៍បញ្ហានេះ កន្លែងខ្លះ លោកបំណងយកអាហារ ៤ តាមន័យមុនៗ ។

ដូចដែលត្រាស់ទុកថា ៖

ម្នាលភិក្ខុទាំងឡាយ ក្នុងធម៌ ៤ ភិក្ខុកាលនឿយណាយ

ដោយប្រពៃ ។ល។ ជាអ្នកធ្វើនូវទីបំផុតទុក្ខបាន ។ ក្នុង

ធម៌ ៤ ដូចម្តេច ធម៌ ៤ ប្រការ គឺ អាហារ ៤ ។ ម្នាល

ភិក្ខុទាំងឡាយ ក្នុងធម៌ ៤ ទាំងនេះឯង ភិក្ខុកាលនឿយ

ណាយដោយប្រពៃ ។ល។ ជាអ្នកធ្វើនូវទីបំផុតទុក្ខបាន ។

ពាក្យណា ដែលតថាគតពោលថា បញ្ហា ៤ ឧទ្ទេស ៤

វេយ្យាករណ៍ ៤ ដូច្នេះ ពាក្យនេះ តថាគតអាស្រ័យសេចក្តី

នោះពោលហើយ ដូច្នេះ ។

ភិក្ខុអ្នកមានចិត្តអប់រំល្អហើយក្នុងគុណធម៌ណា រមែងជាអ្នកធ្វើទី បំផុតទុក្ខបានតាមលំដាប់ គុណធម៌ទាំងនោះ ក៏គឺ សតិបដ្ឋាន ៤ ។ ដូច ព្រះកជង្គលាភិក្ខុនីពោលទុកថា ៖

អ្នកមានអាយុ ក្នុងធម៌ ៤ ភិក្ខុមានចិត្តអប់រំល្អហើយ

ដោយប្រពៃ ឃើញទីបំផុតទុក្ខដោយប្រពៃ ត្រាស់ដឹងធម៌

ដោយប្រពៃ រមែងជាអ្នកធ្វើទីបំផុតទុក្ខបានក្នុងបច្ចុប្បន្ន ។

ក្នុងធម៌ ៤ ដូចម្តេច ធម៌ ៤ ប្រការ គឺ សតិបដ្ឋាន ៤ ។

អ្នកមានអាយុ ក្នុងធម៌ ៤ ទាំងនេះឯង ភិក្ខុ មានចិត្ត
អប់រំល្អហើយដោយប្រពៃ ។ល។ រមែងជាអ្នកធ្វើទីបំផុត
ទុក្ខបាន ។ ពាក្យណា ដែលព្រះមានព្រះភាគត្រាស់ទុកថា
បញ្ហា ៤ ឧទ្ទេស ៤ វេយ្យាករណ៍ ៤ ពាក្យនេះឯង ខ្ញុំ
អាស្រ័យសេចក្តីនោះពោលហើយ ដូច្នេះ ។

តែក្នុងទីនេះ ការកាត់កវតណ្ហាបាន ព្រោះត្រាស់ដឹងតាម និងចាក់ធ្លុះអរិយសច្ចៈ ៤ ណា ព្រោះហេតុនៃអរិយសច្ចៈទាំង ៤ នោះ លោកបំណងយកហើយ ។ ឬព្រោះហេតុបញ្ហាកម្ម ដែលលោកព្យាករណ៍ដោយបរិយាយនេះ ជាការព្យាករណ៍ល្អហើយនោះឯង ដូច្នោះ ព្រះថេរៈពោលដដែលថា ៤ ទើបទូលឆ្លើយថា **អរិយសច្ចៈ** ។ ក្នុងពាក្យនោះ ពាក្យថា ៤ ជាការកំណត់ដោយចំនួន ។ ពាក្យថា **អរិយសច្ចៈ** បានដល់ សច្ចៈដែលជាអរិយៈ អធិប្បាយថា មិនខុស មិនឃ្លៀងឃ្លាត ។ ដូចដែលត្រាស់ទុកថា ៖

ម្នាលភិក្ខុទាំងឡាយ អរិយសច្ចៈទាំង ៤ នេះឯង ដែល

ជារបស់ពិត មិនខុស មិនប្រែប្រួលទៅជាដទៃ ព្រោះ

ដូច្នោះ លោកទើបហៅថា អរិយសច្ចៈ ។

ម្យ៉ាងទៀត ព្រោះហេតុណា លោកអធិប្បាយថា ព្រោះជាសច្ចៈ ដែលលោកព្រមទាំងទេវលោកគប្បីប្រព្រឹត្ត គប្បីសម្រេច ។ ព្រោះដំណើរប្រព្រឹត្តទៅក្នុងផ្លូវចម្រើន ដែលគេដឹងថា ឋានដែលគួរព្យាយាមខ្វះ ព្រោះមិនប្រព្រឹត្តទៅក្នុងផ្លូវមិនចម្រើន ដែលព្រះពុទ្ធ ព្រះបច្ចេកពុទ្ធ និងព្រះសាវកពុទ្ធទាំងឡាយ ដែលបានដឹងហើយថា ជាព្រះអរិយៈ ព្រោះប្រកបដោយអរិយធម៌ គឺ ពោធិបក្ខិយធម៌ ៣៧ ប្រការ រមែងចាក់ធ្លុះអរិយសច្ចៈទាំងនេះ សូម្បីព្រោះហេតុនោះ លោកទើបពោលថា ៖

ម្នាលភិក្ខុទាំងឡាយ អរិយសច្ចៈ ៤ ទាំងនេះ ។ល។

អរិយសច្ចៈ ៤ ទាំងនេះឯង ព្រះអរិយៈទាំងឡាយ

រមែងចាក់ធ្លុះអរិយសច្ចៈ ៤ ទាំងនេះ ព្រោះដូច្នោះ

លោកទើបហៅថា អរិយសច្ចៈ ។

ន័យម្យ៉ាងទៀត ឈ្មោះថា អរិយសច្ចៈ ព្រោះជាសច្ចៈរបស់ព្រះ-

មានព្រះភាគដែលទ្រង់ជាអរិយៈ ។ ដូចដែលត្រាស់ទុកថា ៖

ម្នាលភិក្ខុទាំងឡាយ តថាគតជាអរិយៈក្នុងលោក ព្រម

ទាំងទេវលោក ។ល។ ទាំងទេវតា និងមនុស្ស ព្រោះ

ដូច្នោះ ទើបលោកហៅថា អរិយសច្ចៈ ។

ន័យម្យ៉ាងទៀត ឈ្មោះថា សច្ចៈ សូម្បីព្រោះធ្វើឲ្យសម្រេចភាព

ជាអរិយៈ ព្រោះអរិយសច្ចៈទាំងនោះ ដែលព្រះពុទ្ធជាដើម ទ្រង់ដឹងដ៏ក្រៃ

លែងដោយព្រះអង្គឯង ។ ដូចដែលត្រាស់ទុកថា ៖

ម្នាលភិក្ខុទាំងឡាយ ព្រោះអរិយសច្ចៈ ៤ នេះឯង

តថាគតត្រាស់ដឹងឯងតាមសេចក្តីពិត តថាគតទើប

ត្រូវហៅថា ព្រះអរហន្តសម្មាសម្ពុទ្ធ ។

សេចក្តីនៃបទរបស់អរិយសច្ចៈទាំងនេះមានដូច្នេះ ។ ការកាត់ផ្តាច់

ភវតណ្ហារមែងមាន ព្រោះការត្រាស់ដឹងតាម និងការចាក់ធ្លុះអរិយសច្ចៈ

ទាំងនោះ ។ ដូចដែលត្រាស់ទុកថា ៖

ម្នាលភិក្ខុទាំងឡាយ ទុក្ខអរិយសច្ចៈទាំងនោះ ដែល

តថាគតត្រាស់ដឹងហើយ ចាក់ធ្លុះហើយ ។ល។ ទុក្ខ-
និរោធគាមិនីបដិបទាអរិយសច្ច: ដែលតថាគតត្រាស់
ដឹងហើយ ចាក់ធ្លុះហើយ ។ ភវតណ្ហា តថាគតក៏ដក
បានហើយ តណ្ហាដែលនាំទៅកាន់ភព ក៏អស់ហើយ
ឥឡូវនេះ ការកើតថ្មីទៀតរមែងមិនមាន ដូច្នេះ ។

## ពណ៌នាបញ្ហាថា អ្វី ឈ្មោះថា ៥

ព្រះសាស្តា ទ្រង់មានព្រះទ័យដែលព្រះថេរៈធ្វើឲ្យទ្រង់រីករាយហើយ ដោយការព្យាករណ៍បញ្ហានេះ ទើបត្រាស់សួរបញ្ហាបន្តទៀត តាមន័យមុនៗ ថា បញ្ច នាម កឹ (ធម្មជាត ឈ្មោះថា ៥ គឺអ្វី) ។ ព្រះថេរៈពោលតប ថា ៥ ទើបទូលឆ្លើយថា **ឧបាទានក្ខន្ធ** ។ ក្នុងពាក្យទាំងនោះ ពាក្យថា ៥ ជាការកំណត់ចំនួន ។ ខន្ធទាំងឡាយ ដែលត្រូវឧបាទានឲ្យកើតមក ឬដែលធ្វើឧបាទានឲ្យកើត ឈ្មោះថា ឧបាទានក្ខន្ធ ។ រូប វេទនា សញ្ញា សង្ខារ និងវិញ្ញាណ ណាមួយ មានអាសវ: ដែលបុគ្គលគប្បីប្រកាន់យក

ពាក្យនេះ ជាឈ្មោះរបស់ឧបាទានក្ខន្ធនោះឯង ។ ក៏ក្នុងទីនេះ ព្រះថេរៈ

ពោលថា "ឧបាទានក្ខន្ធ ៥" តាមន័យមុននោះឯង ។ មិនមែនពោលព្រោះ

មិនមានធម៌ ៥ យ៉ាងដទៃទេ ។ ដូចដែលត្រាស់ទុកថា ៖

ម្នាលភិក្ខុទាំងឡាយ ក្នុងធម៌ ៥ ភិក្ខុកាលនឿយណាយ

ដោយប្រពៃ ។ល។ រមែងជាអ្នកធ្វើនូវទីបំផុតទុក្ខបាន ។

ក្នុងធម៌ ៥ ដូចម្ដេច ធម៌ ៥ ប្រការ គឺ ឧបាទានក្ខន្ធ

៥ ។ ម្នាលភិក្ខុទាំងឡាយ ក្នុងធម៌ ៥ ទាំងនេះឯង ភិក្ខុ

កាលនឿយណាយដោយប្រពៃ ។ល។ រមែងជាអ្នកធ្វើនូវ

ទីបំផុតបាន ។ ពាក្យណា តថាគតពោលថា បញ្ហា ៥

ឧទ្ទេស ៥ វេយ្យាករណ៍ ៥ ពាក្យនេះ តថាគតអាស្រ័យ

សេចក្ដីនោះទើបពោលហើយ ដូច្នេះ ។

ក៏ក្នុងបញ្ហានេះ ភិក្ខុកាលពិចារណាខន្ធ ៥ ដោយការកើត និងការ

រលត់ជាអារម្មណ៍ បានអមតៈដោយវិបស្សនាហើយ រមែងធ្វើឲ្យជាក់ច្បាស់

អមតៈ គឺ ព្រះនិព្វានដោយលំដាប់ ។ ដូចដែលត្រាស់ទុកថា ៖

យតោ យតោ សម្មសតិ ខន្ធានំ ឧទយព្វយំ

លភតី បីតិបាមោជ្ជំ  អមតំ តំ វិជានតំ ។

ពិចារណាការកើត និងការរលត់នៃខន្ធទាំងឡាយ ដោយ

ប្រការណាៗ បីតិ និងបាមោជ្ជៈដែលជាអមតៈ រមែងមាន

ដល់បុគ្គលអ្នកដឹងច្បាស់នូវការកើត និងការរលត់នោះ ។

ដោយប្រការនោះៗ ដូច្នេះ ។

ពណ៌នាបញ្ហាថា អ្វី ឈ្មោះថា ៦

ព្រះសាស្តា ទ្រង់មានព្រះទ័យដែលព្រះថេរៈធ្វើឲ្យទ្រង់រីករាយហើយ ដោយការព្យាករណ៍បញ្ហានេះ ទើបត្រាស់សួរបញ្ហាបន្តទៀត តាមន័យមុនៗ ថា ឆ នាម កឹ (ធម្មជាត ឈ្មោះថា ៦ គឺអ្វី) ។ ព្រះថេរៈពោលដដែល ថា ៦ ទើបក្រាបទូលថា **អាយតនៈក្នុង** ។ ក្នុងបទទាំងនោះ បទថា ៦ ជាការកំណត់ចំនួន ។ អាយតនៈទាំងឡាយដែលប្រកបខាងក្នុង ឬធ្វើខ្លួន ឲ្យជាទីអាស្រ័យប្រព្រឹត្តទៅ ឈ្មោះថា **អជ្ឈត្តិកៈ** ។ ឈ្មោះថា **អាយតនៈ** ព្រោះ.ត ឬព្រោះឲ្យកើតសេចក្តីចម្រើន ឬព្រោះនាំសង្សារទុក្ខមកដ៏វែង

ធ្វាយ ។ ពាក្យនេះ ជាឈ្មោះរបស់ចក្ខុ សោតៈ ឃានៈ ជិវ្ហា កាយ មនៈ ។ ក៏ក្នុងទីនេះ ព្រះថេរៈពោលថា "អាយតនៈក្នុង ៦" តាមន័យមុននោះឯង មិនមែនពោលព្រោះមិនមានធម៌ ៦ យ៉ាងដទៃទេ ។ ដូចដែលត្រាស់ទុកថា ៖

ម្នាលភិក្ខុទាំងឡាយ ក្នុងធម៌ ៦ ភិក្ខុកាលនឿយណាយដោយប្រពៃ ។ល។ រមែងជាអ្នកធ្វើទីបំផុតទុក្ខបាន ។ ក្នុងធម៌ ៦ ដូចម្តេច ធម៌ ៦ ប្រការ គឺ អាយតនៈក្នុង ៦ ។ ម្នាលភិក្ខុទាំងឡាយ ក្នុងធម៌ ៦ នេះឯង ភិក្ខុកាលនឿយណាយដោយប្រពៃ ។ល។ រមែងជាអ្នកធ្វើទីបំផុតទុក្ខបាន ពាក្យនោះ តថាគតពោលថា បញ្ហា ៦ ឧទ្ទេស ៦ វេយ្យាករណ៍ ៦ ពាក្យនេះ តថាគតអាស្រ័យសេចក្តីនោះពោលហើយ ។

ក៏ក្នុងបញ្ហានេះ ភិក្ខុពិចារណាអាយតនៈក្នុង ៦ ថាជារបស់ស្ងាត់ តាមព្រះបាលីថា ម្នាលភិក្ខុទាំងឡាយ ពាក្យថា ស្រុកស្ងាត់នេះ ជាឈ្មោះ

*របស់អាយតនៈខាងក្នុង ៦ ដូច្នេះ ព្រោះជារបស់ទទេ និងព្រោះជារបស់កុហក ព្រោះតាំងនៅបានមិនយូរ ដូចពពុះទឹក និងថ្ងៃបណ្ដើរកូន ដូច្នោះ ក៏ទៀយណាយ ធ្វើទីបំផុតទុក្ខបានដោយលំដាប់ រមែងចូលដល់ទីដែលមច្ចុរាជមើលមិនឃើញ ដូចដែលត្រាស់ថា ៖*

*យថា បុព្វុឡកំ បស្សេ យថា បស្សេ មរីចិកំ*
*ឯវំ លោកំ អវេក្ខន្តំ មច្ចុរាជា ន បស្សតិ ។*

*មច្ចុរាជរមែងមើលមិនឃើញ បុគ្គលដែលមើល*
*ឃើញលោកដូចឃើញពពុះទឹក ដូចឃើញថ្ងៃបណ្ដើរ*
*កូន ដូច្នោះ ។*

ពណ៌នាបញ្ហាថា អ្វី ឈ្មោះថា ៧

*ព្រះសាស្ដា ទ្រង់មានព្រះទ័យដែលព្រះថេរៈធ្វើឲ្យទ្រង់រីករាយដោយការព្យាករណ៍បញ្ហានេះហើយ ទើបត្រាស់សួរបញ្ហាបន្តទៅទៀត (តាមន័យមុនៗ) ថា **សត្ត នាម កឹ** (ធម្មជាតឈ្មោះថា ៧ គឺអ្វី) ។ វិញ្ញាណដ្ឋិតិ*

៧ ដែលព្រះថេរៈពោលក្នុងការព្យាករណ៍បញ្ហាធំ ក៏ពិត តែភិក្ខុអ្នកមានចិត្តអប់រំល្អហើយក្នុងធម៌ពួកណា រមែងជាអ្នកធ្វើទីបំផុតទុក្ខបាន ព្រះថេរៈកាលសំដែងធម៌ពួកនោះ ទើបទូលឆ្លើយថា ពោជ្ឈង្គ ៧ ។ ម្យ៉ាងទៀតសេចក្តីប្រការនេះ ព្រះមានព្រះភាគទ្រង់អនុមតិហើយ ។ ដូចដែលត្រាស់ទុកថា ៖

ម្នាលគហបតីទាំងឡាយ កជង្គលាភិក្ខុនី ជាបណ្ឌិត
ម្នាលគហបតីទាំងឡាយ កជង្គលាភិក្ខុនី មានបញ្ញា
ច្រើន សូម្បីបើពួកលោកចូលមករកតថាគត ហើយ
សាកសួរសេចក្តីនេះ តថាគតក៏គប្បីព្យាករណ៍សេចក្តី
នោះដូចកជង្គលាភិក្ខុនីព្យាករណ៍ហើយ ដូច្នោះ ។

កជង្គលាភិក្ខុនីនោះព្យារកណ៍ទុកយ៉ាងនេះថា ៖

អ្នកមានអាយុ ក្នុងធម៌ ៧ ភិក្ខុមានចិត្តអប់រំល្អហើយ
ដោយប្រពៃ ។ល។ រមែងជាអ្នកធ្វើទីបំផុតបាន ។ ក្នុង
ធម៌ ៧ ដូចម្តេច ធម៌ ៧ ប្រការ គឺ ពោជ្ឈង្គ ៧ ។

អ្នកមានអាយុ ក្នុងធម៌ ៧ ទាំងនេះឯង ភិក្ខុអ្នកមាន
ចិត្តអប់រំល្អហើយដោយប្រពៃ ។ល។ រមែងជាអ្នកធ្វើ
បំផុតបានដោយប្រពៃ ។ ពាក្យណា ព្រះមានព្រះភាគ
ត្រាស់ទុកថា បញ្ហា ៧ ឧទ្ទេស ៧ វេយ្យាករណ៍ ៧
ពាក្យនេះ តថាគតអាស្រ័យសេចក្តីនោះពោលហើយ
ដូច្នេះ ។

សេចក្តីនេះ គប្បីជ្រាបថា ព្រះមានព្រះភាគទ្រង់អនុមតិហើយ ដោយប្រការដូច្នេះ ។

ក្នុងពាក្យទាំងនោះ ពាក្យថា ៧ សេចក្តីថា ជាការកំណត់ចំនួនដាច់ខាត មិនលើសមិនខ្វះអំពីនោះ ។ ពាក្យថា ពោជ្ឈង្គ នេះ ជាឈ្មោះរបស់ធម៌ មានសតិជាដើម ។ អត្ថនៃបទក្នុងពោជ្ឈង្គ: ៧ នោះ មានដូច្នេះ ឈ្មោះថា ពោធិ ព្រោះវិគ្រោះថា ព្រះអរិយសាវករមែងត្រាស់ដឹងដោយធម្មសាមគ្គី ពោលគឺ សតិ ធម្មវិចយ: វីរិយ: បីតិ បស្សទ្ធិ សមាធិ និងឧបេក្ខា ដែលជាបដិបក្ខចំពោះឧបទ្វវ:ជាច្រើន ការខ្ជិលច្រអូស

សេចក្តីរាយមាយ ការឈប់ព្យាយាម កាមសុខល្លិកានុយោគ អត្តកិលមថានុយោគ និងសេចក្តីប្រកាន់ដោយឧច្ឆេទទិដ្ឋិ និងសស្សតទិដ្ឋិជាដើម ដែលកើតឡើងក្នុងខណៈនៃមគ្គចិត្ត ទាំងចំណែកលោកិយៈ និងលោកុត្តរៈ នោះ លោកអធិប្បាយថា ក្រោកឡើងអំពីការលក់ គឺ សន្តានដែលមានកិលេស ឬត្រាស់ដឹងអរិយសច្ចៈ ៤ ឬធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វាន នោះឯង ។ ដូចដែលលោកពោលទុកថា "ទ្រង់ចម្រើនពោជ្ឈង្គៈ ៧ ត្រាស់ដឹងក្រៃលែងនូវអនុត្តរសម្មាសម្ពោធិ ។

ម្យ៉ាងទៀត សូម្បីអរិយសាវក ឈ្មោះថា ពោធិ ព្រោះវិគ្រោះថា ត្រាស់ដឹងនូវធម្មសាមគ្គីនោះ មានប្រការតាមដែលពោលហើយ ។ ដូច្នោះ ឈ្មោះថា ពោជ្ឈង្គៈ ព្រោះជាអង្គ (គឺចំណែក) នៃពោធិ ពោលគឺ ធម្មសាមគ្គីនោះ ដូចអង្គនៃឈាន និងអង្គនៃមគ្គនោះ ម្យ៉ាងទៀត ឈ្មោះថា ពោជ្ឈង្គៈ សូម្បីព្រោះជាអង្គរបស់ព្រះអរិយសាវកដែលបានវោហារថា "ពោធិ" នោះ ដូចអង្គ គឺ ចំណែករបស់កងទ័ព និងអង្គ គឺ ចំណែករបស់រថជាដើម ដូច្នេះ ។

ន័យម្យ៉ាងទៀត គប្បីជ្រាបអត្ថនៃពោជ្ឈង្គៈរបស់ពោជ្ឈង្គទាំងឡាយ តាមវិធីដែលពោលទុកក្នុងគម្ពីរបដិសម្ភិទាយ៉ាងនេះថា ក្នុងពាក្យថា ពោជ្ឈង្គ ឈ្មោះថា ពោជ្ឈង្គៈ ព្រោះអត្ថថាអ្វី ឈ្មោះថា ពោជ្ឈង្គៈ ព្រោះប្រព្រឹត្តិទៅដើម្បីការត្រាស់ដឹង ឈ្មោះថា ពោជ្ឈង្គៈ ព្រោះត្រាស់ដឹង ឈ្មោះថា ពោជ្ឈង្គៈ ព្រោះត្រាស់ដឹងតាម ឈ្មោះថា ពោជ្ឈង្គៈ ព្រោះចាក់ធ្លុះ ឈ្មោះថា ពោជ្ឈង្គៈ ព្រោះត្រាស់ដឹងព្រម ។ ព្រះយោគាវចរកាលចម្រើន ធ្វើឲ្យច្រើននូវពោជ្ឈង្គៈ ៧ ទាំងនេះ យ៉ាងនេះ មិនយូរប៉ុន្មាន ក៏នឹងជាអ្នកបានគុណ មានការនឿយណាយតែម្យ៉ាង ព្រោះហេតុនោះ ទើបត្រាស់ថា "រមែងជាអ្នកធ្វើនូវទីបំផុតទុក្ខបានក្នុងបច្ចុប្បន្ន" ។ សមដូចដែលព្រះមាន-ព្រះភាគទ្រង់ត្រាស់ទុកថា ៖

> ម្នាលភិក្ខុទាំងឡាយ ពោជ្ឈង្គៈ ៧ ទាំងនេះ ដែលបុគ្គលចម្រើនហើយ ធ្វើឲ្យច្រើនហើយ រមែងប្រព្រឹត្តទៅដើម្បីសេចក្ដីនឿយណាយតែម្យ៉ាង ដើម្បីការប្រាសចាកតម្រេក ដើម្បីការរលត់ ដើម្បីសេចក្ដីស្ងប់ ដើម្បី

*ការដឹងកែ្រលែង ដើម្បីការដឹងព្រម ដើម្បីនិព្វាន*

*ដូច្នេះ ។*

## ពណ៌នាបញ្ហាថា អ្វី ឈ្មោះថា ៨

*ព្រះសាស្តា ទ្រង់មានព្រះទ័យដែលព្រះថេរៈធ្វើឲ្យទ្រង់រីករាយដោយការព្យាករណ៍បញ្ហានេះ យ៉ាងនេះហើយ ទើបត្រាស់សួរបញ្ហាតទៅទៀតថា* ***អដ្ឋ នាម កឹ (ធម្មជាតិឈ្មោះថា ៨ គឺអ្វី)*** *។ លោកធម៌ ៨ ដែលព្រះថេរៈពោលទុកក្នុងការព្យាករណ៍ច្រើនបញ្ហា ក៏ពិតហើយ តែភិក្ខុអ្នកមានចិត្តអប់រំល្អហើយក្នុងធម៌ពួកណា រមែងជាអ្នកធ្វើនូវទីបំផុតនៃទុក្ខបាន ព្រះថេរៈកាលសំដែងធម៌ទាំងនោះ មិនពោលថា "អង្គនៃមគ្គ ៨ ជាអរិយៈ" ព្រោះធម្មតាមគ្គដែលផុតចាកអង្គ ៨ រមែងមិនមាន តែថា មគ្គមានត្រឹមតែអង្គ ៨ ប៉ុណ្ណោះ ដូច្នោះ កាលនឹងឲ្យសម្រេចសេចក្តីនោះ ទើបទូលឆ្លើយដោយវិលាសនៃទេសនាថា* ***អរិយមគ្គមានអង្គ ៨*** *។ អត្ថ និងទេសនាប្រការនេះ សូម្បីព្រះមានព្រះភាគ ទ្រង់អនុមតិហើយ ។ ដូចដែលត្រាស់*

ទុកថា ៖

ម្នាលគហបតីទាំងឡាយ កជង្គលាភិក្ខុនី ជាបណ្ឌិត

។លៈ។ សូម្បីតថាគត ក៏គប្បីព្យាករណ៍ដូចកជង្គលា-

ភិក្ខុនីព្យាករណ៍ ដូច្នោះ ។

កជង្គលាភិក្ខុនីនោះ ព្យាករណ៍ទុកយ៉ាងនេះថា ៖

អ្នកមានអាយុ ក្នុងធម៌ ៨ ភិក្ខុអ្នកមានចិត្តអប់រំល្អ

ហើយដោយប្រពៃ ។លៈ។ រមែងជាអ្នកធ្វើនូវទីបំផុត

ទុក្ខបាន ។ ពាក្យណា ដែលព្រះមានព្រះភាគត្រាស់

ទុកថា បញ្ហា ៨ ឧទ្ទេស ៨ វេយ្យាករណ៍ ៨ ពាក្យ

នេះ តថាគតអាស្រ័យសេចក្តីនោះទើបពោល ដូច្នេះ ។

អត្ថ និងទេសនានៃយនេះ គប្បីជ្រាបថា ព្រះមានព្រះភាគទ្រង់អនុ-

មតិហើយ ដោយប្រការដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អរិយះ** បានដល់ ដែលអ្នកត្រូវការ

ព្រះនិព្វានគប្បីសម្រេច ។ ម្យ៉ាងទៀត មគ្គ គប្បីជ្រាបថា **អរិយះ** ព្រោះ

ប្រព្រឹត្តទៅឆ្ងាយចាកកិលេសទាំងឡាយ ព្រោះធ្វើភាពជាព្រះអរិយៈ និង សម្បីព្រោះបានអរិយផល ។ អង្គរបស់មគ្គនោះ មាន ៨ ព្រោះហេតុនោះ មគ្គនោះ ទើបឈ្មោះថា **មានអង្គ ៨** ។ មគ្គនោះ គប្បីជ្រាបថា មានត្រឹមតែអង្គប៉ុណ្ណោះ ព្រោះមគ្គមានសភាពដែលបុគ្គលនឹងមិនគប្បីបាន ដោយប្រាសចាកអង្គ ដូចកងទ័ពមានអង្គ ៤ និងតន្ត្រីមានអង្គ ៥ ។ បុគ្គលរមែងស្វែងរកព្រះនិព្វានដោយផ្លូវនេះ ឬស្វែងរកឯង ឬសម្លាប់កិលេស ហេតុនោះ ផ្លូវនេះ ទើបឈ្មោះថា **មគ្គ** ។

ភិក្ខុកាលចម្រើនមគ្គមានប្រភេទ ៨ និងមានអង្គ ៨ នេះ យ៉ាងនេះ រមែងកម្ចាត់បង់អវិជ្ជា ធ្វើវិជ្ជាឲ្យកើតឡើង ធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វាន ព្រោះហេតុនោះ លោកទើបពោលថា "ជាអ្នកធ្វើនូវទីបំផុតទុក្ខបានក្នុងបច្ចុប្បន្ន" ។ សមពិតដូចដែលត្រាស់ទុកយ៉ាងនេះថា ៖

> ម្នាលភិក្ខុទាំងឡាយ ចុងគ្រាប់ស្រូវខ្សាយក្តី ចុងគ្រាប់
> ស្រូវជំណើបក្តី ដែលបុគ្គលរៀបចំត្រូវទំនង គឺ ធ្វើឲ្យ
> មានចុងឡើងលើ បុគ្គលសង្កត់ដោយដៃ ឬជាន់ដោយ

*ជើង នឹងមុតដៃ ឬជើង នឹងធ្វើឈាមឲ្យផុលឡើងបាន ហេតុនេះ ទើបមានរឿងនោះ ព្រោះហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយ ព្រោះចុងគ្រាប់ស្រូវ បុគ្គលរៀបចំត្រូវទំនងដូចម្តេចមិញ ម្នាលភិក្ខុទាំងឡាយ ភិក្ខុមានចិត្តតម្កល់ត្រូវនឹងទម្លាយអវិជ្ជា នឹងធ្វើវិជ្ជាឲ្យកើតឡើង នឹងធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វាន ហេតុនេះ ទើបមានរឿងនោះ ។*

## ពណ៌នាបញ្ហាថា អ្វី ឈ្មោះថា ៩

*ព្រះសាស្តា ទ្រង់មានព្រះទ័យដែលព្រះថេរៈធ្វើឲ្យទ្រង់រីករាយដោយការព្យាករណ៍បញ្ហានេះ ទើបសួរបញ្ហានេះតទៅទៀតថា* ***នវ នាម កឹ*** *(អ្វីឈ្មោះថា ៩) ព្រះថេរៈពោលដដែលថា ៩ ទើបទូលតបថា* ***សត្តាវាស*** *។*

*ក្នុងបទនោះ បទថា ៩ បានដល់ ការកំណត់ចំនួន ។ បទថា* ***សត្វ*** *បានដល់ សត្វមានជីវិត ដែលលោកបញ្ញត្តិអាស្រ័យខន្ធដែលជាប់ទាក់ទងដោយឥន្ទ្រិយ៍ ។ បទថា* ***អាវាស*** *បានដល់ ឈ្មោះថា អាវាស ព្រោះជា*

ទីនៅអាស្រ័យ ។ ទីនៅអាស្រ័យរបស់សត្វទាំងឡាយ ឈ្មោះថា សត្តា-វាស ។ នោះជាផ្លូវនៃទេសនា ។ តែកាលពោលដោយអត្ថ (សេចក្តី) បទនេះ ជាឈ្មោះរបស់សត្វ ៩ ប្រភេទ។ ដូចដែលលោកពោលទុកថា ៖

អ្នកមានអាយុ ពួកសត្វមានកាយផ្សេងគ្នា មានសញ្ញាផ្សេងគ្នាក៏មាន ដូចមនុស្សពួកខ្លះ ទេវតាពួកខ្លះ និងវិនិបាតិកៈពួកខ្លះ នេះជាសត្តាវាស ទី ១ ។ ពួកសត្វមានកាយផ្សេងគ្នា មានសញ្ញាដូចគ្នាក៏មាន ដូចពួកទេវតាដែលនៅក្នុងពួកព្រហ្មអ្នកកើតគ្រាដំបូង (បឋម-ជ្ឈានភូមិ) នេះជាសត្តាវាសទី ២ ។ ពួកសត្វអ្នកមានកាយដូចគ្នា មានសញ្ញាផ្សេងគ្នាក៏មាន ដូចពួកទេវតាជាន់អាភស្សរៈ នេះជាសត្តាវាសទី ៣ ។ ពួកសត្វអ្នកមានកាយដូចគ្នា មានសញ្ញាដូចគ្នាក៏មាន ដូចពួកទេវតាជាន់សុភកិណ្ហៈ នេះជាសត្តាវាសទី ៤ ។ ពួកសត្វដែលមិនមានសញ្ញា មិនសោយអារម្មណ៍ក៏មាន ដូចពួកទេវតា

ជាន់អសញ្ញសត្វ នេះជាសត្តាវាសទី ៥ ។ ពួកទេវតា ដែលកន្លងរូបសញ្ញា ។ល។ ដែលចូលដល់អាកាសានញ្ចាយតនៈ នេះជាសត្តាវាសទី ៦ ។ ពួកសត្វ ។ល។ ដែលចូលដល់វិញ្ញាណញ្ចាយតនៈ នេះជាសត្តាវាសទី ៧ ។ ពួកសត្វ ។ល។ ដែលចូលដល់អាកិញ្ចញ្ញាយតនៈ នេះជាសត្តាវាសទី ៨ ។ ពួកសត្វ ។ល។ ដែលចូលដល់នេវសញ្ញានាសញ្ញាយតនៈ នេះជាសត្តាវាសទី ៩ ។

ក៏ក្នុងទីនេះ ព្រះថេរៈពោលថា "សត្តាវាស ៩" ក៏តាមន័យមុនៗ នោះឯង មិនមែនពោលព្រោះមិនមានធម៌ ៩ យ៉ាងដទៃទេ ។ ដូចដែលត្រាស់ទុកថា ៖

ម្នាលភិក្ខុទាំងឡាយ ក្នុងធម៌ ៩ ភិក្ខុកាលនឿយណាយដោយប្រពៃ ។ល។ រមែងជាអ្នកធ្វើនូវទីបំផុតបាន ។ ក្នុងធម៌ ៩ ដូចម្តេច ធម៌ ៩ ប្រការ គឺ សត្តាវាស ៩ ។ ម្នាលភិក្ខុទាំងឡាយ ក្នុងធម៌ ៩ ទាំងនេះឯង ភិក្ខុកាល

*នឿយណាយដោយប្រពៃ ។ល។ រមែងជាអ្នកធ្វើនូវទីបំផុត ទុក្ខបាន ។ ពាក្យណា ដែលតថាគតពោលថា បញ្ហា ៩ ឧទ្ទេស ៩ វេយ្យាករណ៍ ៩ ពាក្យនេះ តថាគតអាស្រ័យ សេចក្តីនោះ ទើបពោល ។*

*ក៏ក្នុងទីបញ្ហានេះ ភិក្ខុលះសេចក្តីឃើញនូវអត្តភាពនេះថា ទៀង ថា ស្អាត មានសេចក្តីសុខ ដោយញាតបរិញ្ញា (កំណត់ដឹងដោយបញ្ញា) ក្នុងសត្តាវាស ព្រោះបាលីថា ធម៌ ៩ គួរកំណត់ដឹង ។ ធម៌ ៩ ប្រការដូចម្តេច គឺ សត្តាវាស ៩ ។ នឿយណាយដោយការឃើញត្រឹមតែគំនរសង្ខារសុទ្ធៗ ប្រាសចាកតម្រេក ព្រោះការឃើញអនិច្ចលក្ខណៈ ដោយតីរណបរិញ្ញា (កំណត់ដឹងដោយការពិចារណា) រួចផុតដោយការឃើញទុក្ខលក្ខណៈ ឃើញទីបំផុតដោយប្រពៃ ដោយការឃើញអនត្តលក្ខណៈ ត្រាស់ដឹងធម៌ដោយប្រពៃ ដោយបហានបរិញ្ញា រមែងជាអ្នកធ្វើនូវទីបំផុតទុក្ខបានក្នុងទិដ្ឋធម៌ គឺ បច្ចុប្បន្ន ។ ព្រោះហេតុនោះ ព្រះមានព្រះភាគទើបមានព្រះតម្រាស់ថា ៖*

*ម្នាលភិក្ខុទាំងឡាយ ក្នុងធម៌ ៩ ភិក្ខុកាលនឿយណាយ*

ដោយប្រពៃ ។ល។ រមែងជាអ្នកធ្វើនូវទីបំផុតទុក្ខបាន ។
ក្នុងធម៌ ៩ ដូចម្តេច ធម៌ ៩ ប្រការ គឺ សត្តាវាស ៩
ដូច្នេះ ។

ពណ៌នាបញ្ហាថា អ្វី ឈ្មោះថា ១០

ព្រះសាស្តា ទ្រង់មានព្រះទ័យដែលព្រះថេរៈធ្វើឲ្យទ្រង់រីករាយដោយការព្យាករណ៍នេះ យ៉ាងនេះហើយ ទើបត្រាស់សួរបញ្ហាតទៅទៀតថា ទសនាម កឹ (អ្វីឈ្មោះថា ១០) ។ ក្នុងបញ្ហានោះ ព្រះមានព្រះភាគត្រាស់អកុសលកម្មបថ ១០ ទុកក្នុងវេយ្យាករណ៍ទាំងឡាយ ក្រៅពីការព្យាករណ៍បញ្ហានេះ ។ ដូចដែលត្រាស់ទុកថា ៖

ម្នាលភិក្ខុទាំងឡាយ ក្នុងធម៌ ១០ ភិក្ខុកាលនឿយណាយ
ដោយប្រពៃ ។ល។ រមែងជាអ្នកទីបំផុតទុក្ខបាន ។ ក្នុងធម៌
១០ ដូចម្តេច ធម៌ ១០ ប្រការ គឺ អកុសលកម្មបថ ១០ ។
ម្នាលភិក្ខុទាំងឡាយ ក្នុងធម៌ ១០ ភិក្ខុកាលនឿយណាយ

ដោយប្រពៃ ។ល។ រមែងជាអ្នកទីបំផុតបាន ។ ពាក្យណា ដែលតថាគតពោលថា បញ្ហា ១០ ឧទ្ទេស ១០ វេយ្យា-ករណ៍ ១០ ពាក្យនេះ តថាគតអាស្រ័យសេចក្តីនេះ ទើបពោល ដូច្នេះ ។

ពិតហើយ សូម្បីយ៉ាងនោះ ក្នុងទីនេះ ព្រោះហេតុដែលព្រះថេរៈមិននាំដោយខ្លួនឯងចូលទៅ បំណាងនឹងព្យាករណ៍ព្រះអរហត្ត ឬព្រោះហេតុដែលបញ្ហាកម្ម ដែលព្រះថេរៈព្យាករណ៍ដោយបរិយាយនេះ ជាការព្យា-ករណ៍ល្អហើយ ដូច្នោះ ដែលលោកប្រកបដោយអង្គ ១០ ពួកណា លោកហៅថា "ព្រះអរហន្ត" ព្រះថេរៈកាលសំដែងការសម្រេចអង្គ ១០ ទាំងនោះ ទើបទូលឆ្លើយ ដោយទេសនាជាបុគ្គលាធិដ្ឋានថា **បុគ្គលប្រកបដោយអង្គ ១០ លោកហៅថា ព្រះអរហន្ត** ។ ព្រោះក្នុងសេចក្តីនេះ បុគ្គលដែលប្រកបព្រមដោយអង្គ ១០ ពួកណា លោកហៅថា ព្រះអរហន្ត គប្បីជ្រាបថា អង្គ ១០ ទាំងនោះ ព្រះថេរៈត្រូវត្រាស់សួរថា អ្វីហ្ន៎ ឈ្មោះថា ១០ ទើបទូលបញ្ជាក់ ។ ក៏អង្គ ១០ ទាំងនោះ គប្បីជ្រាបដោយន័យដែលត្រាស់

ទុកក្នុងព្រះសូត្រទាំងឡាយជាដើម យ៉ាងនេះថា ៖

ភិក្ខុទូលសួរថា បពិត្រព្រះអង្គដ៏ចម្រើន ដែលហៅថា អសេក្ខៈ អសេក្ខៈ ភិក្ខុជាអសេក្ខៈ ដោយហេតុត្រឹមណា ព្រះអង្គ ។ ត្រាស់ឆ្លើយថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងធម៌វិន័យនេះ ប្រកបដោយសម្មាទិដ្ឋិជាអសេក្ខៈ សម្មាសង្កប្បៈជាអសេក្ខៈ សម្មាវាចាជាអសេក្ខៈ សម្មា-កម្មន្តៈជាអសេក្ខៈ សម្មាអាជីវៈជាអសេក្ខៈ សម្មាយាមៈជាអសេក្ខៈ សម្មាសតិជាអសេក្ខៈ សម្មាសមាធិជាអសេក្ខៈ សម្មាញាណៈជាអសេក្ខៈ និងសម្មាវិមុត្តិជាអសេក្ខៈ ។ ម្នាលភិក្ខុទាំងឡាយ យ៉ាងនេះឯង ភិក្ខុឈ្មោះថា ជាអសេក្ខៈ ។

ចប់អដ្ឋកថា កុមារបញ្ហាសូត្រទី ៤

# អដ្ឋកថា មង្គលសូត្រទី ៥

*(ប្រយោជន៍នៃបទតាំង)*

[៥] *ឥឡូវនេះ ជាលំដាប់ការពណ៌នាសេចក្តីនៃមង្គលសូត្រដែលលើកជាបទតាំង តអំពីកុមារបញ្ហា ។ ក្នុងទីនេះ ខ្ញុំនឹងពោលប្រយោជន៍នៃបទតាំងហើយ នឹងពណ៌នាសេចក្តីនៃមង្គលសូត្រនោះ ។ យ៉ាងណា ។ ពិតហើយ ព្រះសូត្រនេះ ព្រះមានព្រះភាគសម្បីមិនបានត្រាស់តាមលំដាប់ តែខ្ញុំពោលដើម្បីសំដែងនូវការរាប់អានព្រះសាសនា ដោយការដល់សរណៈ និងន័យតាមប្រភេទសីល សមាធិ បញ្ញា ដែលទ្រង់សំដែងទុកដោយសិក្ខាបទ ទ្វត្តិង្សាការៈ និងកុមារបញ្ហាណា សូម្បីទាំងអស់នោះ ក៏ជាមង្គលដ៏ក្រៃលែង ព្រោះបុគ្គលត្រូវការមង្គល ចាំបាច់ត្រូវធ្វើសេចក្តីព្យាយាមដ៏ក្រៃលែងក្នុងមង្គលនោះឯង ។ ចំណែកការដែលរាប់អានព្រះសាសនាជាដើមនោះ ជាមង្គលនោះ បណ្ឌិតគប្បីជ្រាបតាមព្រះសូត្រនេះ ។*

*នេះជាប្រយោជន៍នៃបទតាំងក្នុងមង្គលសូត្រនោះ ក្នុងទីនេះ ។*

## កថាពណ៌នា បឋមសង្គាយនា

ក៏ដើម្បីពណ៌នាអត្ថនៃមង្គលសូត្រនោះ ដែលលើកជាបទតាំងទុកយ៉ាងនេះ មានមាតិកា ដូច្នេះ ។

ខ្ញុំនឹងពោលវិធីនេះយ៉ាងនេះថា ពាក្យនេះ អ្នកណាពោល
ពោលកាលណា ពោលព្រោះហេតុអ្វី កាលនឹងពណ៌នា
សេចក្តីនៃបាឋ: មាន ឯវំ ជាដើម ដោយប្រការផ្សេងៗ
ក៏នឹងពោលសមុដ្ឋានដែលកើតមង្គល កំណត់មង្គលនោះ
ហើយ នឹងអធិប្បាយអត្ថនៃមង្គលសូត្រនោះ ។

ក្នុងមាតិកានោះ ជាដំបូង កន្លះគាថានេះថា វុត្តំ យេន យទា យស្មា ចេតំ វត្វា ឥមំ វិធឹ ។ លោកពោលសំដៅដល់ពាក្យ គឺ ឯវំ មេ សុតំ ឯកំ សមយំ ភគវា ។បេ។ ភគវន្តំ គាថាយ អជ្ឈភាសិ ។ ពិតហើយ ព្រះសូត្រនេះ លោកពោលដោយស្តាប់តៗ គ្នាមក ក៏ព្រះមាន-ព្រះភាគអង្គនោះ ជាសយម្ភូ (ទ្រង់ត្រាស់ដឹងឯង) មិនមានអាចារ្យ ព្រោះដូច្នោះ ពាក្យនេះ (និទានវចនៈ) ទើបមិនមែនព្រះតម្រាស់របស់ព្រះមាន-

ព្រះភាគ អរហន្តសម្មាសម្ពុទ្ធអង្គនោះ ។ ព្រោះហេតុដែលមានពាក្យពោលថា ពាក្យនេះ នរណាពោល ពោលកាលណា និងពោលព្រោះហេតុអ្វី ដូច្នោះ ទើបសូម្បីពោលអធិប្បាយដូច្នេះ ពាក្យនេះ ព្រះអានន្ទពោល និងពោលក្នុងវេលាធ្វើមហាសង្គាយនាគ្រាដំបូង ។

សេចក្តីពិត ការធ្វើសង្គាយនាគ្រាដំបូងនេះ គួរជ្រាបមកតាំងអំពីដើម ដើម្បីឈ្លាសក្នុងនិទានវចនៈ (ពាក្យខាងដើម) របស់ព្រះសូត្រទាំងពួងដូចតទៅនេះ ។

កាលព្រះមានព្រះភាគ ទ្រង់ជានាថៈ (ទីពឹង) របស់លោក ទ្រង់បំពេញពុទ្ធកិច្ច ផ្តើមតាំងពីទ្រង់ប្រកាសព្រះធម្មចក្ក រហូតដល់ទ្រង់ប្រោសសុភទ្ទបរិព្វាជក ហើយស្តេចបរិនិព្វានដោយអនុបាទិសេសនិព្វានធាតុ វេលាទៀបភ្លឺថ្ងៃពេញបូរមីខែវិសាខ ចន្លោះដើមសាលព្រឹក្សទាំងគូ ក្នុងសាលវនោទ្យានដែលជាទីលំហែរបស់មល្លក្សត្រជិតក្រុងកុសិនារា ព្រះមហាកស្សបៈជាសង្ឃថេរៈរបស់ភិក្ខុប្រមាណ ៧០០.០០០ រូប ដែលប្រជុំគ្នាក្នុងថ្ងៃបែងចែកព្រះបរមសារីរិកធាតុរបស់ព្រះមានព្រះភាគ មករឭកដល់ពាក្យរបស់

សុភទ្ទៈ ពោលកាលព្រះមានព្រះភាគស្តេចបរិនិព្វានបាន ៧ ថ្ងៃ ថា "ណ្ហើយចុះ អ្នកមានអាយុ លោកទាំងឡាយកុំសោកសៅឡើយ កុំអាឡោះអាល័យឡើយ ពួកយើងរួចហើយអំពីព្រះសមណៈនោះ អំពីមុនពួកយើងត្រូវព្រះមហាសមណៈនោះ បង្គាប់ពួកយើងថា វត្ថុនេះគួរដល់ពួកអ្នកខ្លះ វត្ថុនេះមិនគួរដល់ពួកអ្នកខ្លះ វត្ថុនេះគួរលះ វត្ថុនេះមិនគួរលះ តែឥឡូវនេះ ពួកយើងប្រាថ្នាវត្ថុណា ក៏នឹងធ្វើវត្ថុនោះ មិនប្រាថ្នាវត្ថុណា ក៏នឹងមិនធ្វើវត្ថុនោះ" លោកត្រិះរិះថា ពួកភិក្ខុអាក្រក់ យល់ថា បាវចនៈ (ព្រះធម្មវិន័យ) មានព្រះសាស្តាកន្លងទៅហើយ បានបក្សពួក ក៏នឹងនាំគ្នាញាំញីព្រះសទ្ធម្មឲ្យអន្តរធានទៅមិនយូរឡើយ ប្រការនេះរមែងប្រព្រឹត្តទៅបាន ។ ដរាបណាព្រះធម្មវិន័យតាំងនៅ ដរាបនោះ បាវចនៈក៏ឈ្មោះថា ព្រះសាស្តាមិនទាន់កន្លងទៅឡើយ ។ សមដូចដែលព្រះមានព្រះភាគត្រាស់ទុកថា ៖

ម្នាលអានន្ទ ធម៌ និងវិន័យណា ដែលតថាគតសំដែង
ហើយ បញ្ញត្តិហើយដល់អ្នកទាំងឡាយ ធម៌និងវិន័យ
នោះ នឹងជាសាស្តារបស់អ្នកទាំងឡាយ កាលតថាគត

បរិនិព្វានទៅ ដូច្នេះ ។

កុំធ្វើដូច្នោះ យើងនឹងជួយគ្នាសង្គាយនាព្រះធម្មវិន័យ ដោយវិធីដែលព្រះសាសនានេះ នឹងគប្បីតាំងនៅអស់កាលយូរអង្វែង ។

ម្យ៉ាងទៀត យើងកស្សបៈ ដែលព្រះដ៏មានព្រះភាគទ្រង់អនុគ្រោះដោយសាធារណបរិភោគក្នុងចីវរ ត្រាស់ថា ៖

កស្សបៈ អ្នកនឹងគ្រងសំពត់បង្សុកូលដែលប្រើហើយរបស់តថាគតបានឬ និងទ្រង់អនុគ្រោះដោយទ្រង់ស្ថាបនាយើងទុកស្មើៗ នឹងព្រះអង្គក្នុងឧត្តរិមនុស្សធម៌ (ធម៌ដ៏ក្រៃលែងជាងរបស់មនុស្ស) មានអនុបុព្វវិហារ ៩ និងអភិញ្ញា ៦ ដោយន័យជាដើមយ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ តថា-គតត្រូវការស្ងាត់ចាកកាមទាំងឡាយ ស្ងាត់ចាកអកុសលធម៌ទាំងឡាយ ចូលដល់បឋមឈានត្រឹមណា សូម្បីកស្សបៈ ក៏ត្រូវការស្ងាត់ចាកកាមទាំងឡាយ ស្ងាត់ចាកអកុសលធម៌ទាំងឡាយ ។ល។ ចូរដល់បឋមឈានត្រឹម

នោះ ដូច្នេះ ។

យើងនឹងមានបំណុលអ្វី ព្រះមានព្រះភាគទ្រង់ជ្រាបថា កស្សបៈនេះ នឹងជាអ្នកតាំងវង្សព្រះសទ្ធម្មរបស់តថាគត ទើបទ្រង់អនុគ្រោះយើង ដោយការអនុគ្រោះដែលមិនទូទៅនេះ ដូចព្រះរាជា ទ្រង់អនុគ្រោះព្រះរាជឱរសអ្នកតាំងវង្សត្រកូលរបស់ខ្លួន ដោយទ្រង់ប្រទានអាវគ្រោះ និងព្រះរាជឥស្សរិយយស មិនមែនឬ ទើបធ្វើសេចក្តីឧស្សាហ៍ឲ្យកើតដល់ភិក្ខុទាំងឡាយ ដើម្បីជួយគ្នាសង្គាយនាព្រះធម្មវិន័យ ។ ដូចដែលព្រះអានន្ទពោលទុកថា

គ្រានោះឯង ព្រះមហាកស្សបៈពោលនឹងភិក្ខុទាំងឡាយថា អ្នកមានអាយុទាំងឡាយ គ្រាមួយ យើងដើរផ្លូវឆ្ងាយចាក នគរបាវា មកកាន់នគរកុសិនារា ព្រមជាមួយនឹងភិក្ខុពួកធំ ប្រមាណ ៥០០ រូប ដូច្នេះ ។

សុភទ្ទកណ្ឌៈ គួរពោលឲ្យពិស្តារទាំងអស់ ។ តពីនោះ ព្រះមហាកស្សបៈពោលថា ៖

អ្នកមានអាយុទាំងឡាយ ណ្ហើយចុះ មកយើងជួយគ្នា

សង្គាយនាព្រះធម្មវិន័យ តទៅខាងមុខអធម៌នឹងរុងរឿង ធម៌នឹងសាបសូន្យ ។ អវិន័យនឹងរុងរឿង វិន័យនឹងសាបសូន្យ កាលខាងមុខអធម្មវាទីនឹងមានកម្លាំង ធម្មវាទីនឹងខ្សោយកម្លាំង អវិនយវាទីនឹងមានកម្លាំង វិនយវាទីនឹងខ្សោយកម្លាំង ។

ភិក្ខុទាំងឡាយពោលថា "បពិត្រលោកដ៏ចម្រើន បើដូច្នោះ សូមព្រះថេរៈប្រោសជ្រើសរើសភិក្ខុទាំងឡាយចុះ ។ ព្រះថេរៈវៀរភិក្ខុដែលជាបុថុជ្ជន សោតាបន្ន សកទាគាមី អនាគាមី និងព្រះខីណាស្រពជាសុក្ខវិបស្សកៈ អ្នកទ្រទ្រង់ព្រះបរិយត្តិ គឺ នវង្គសត្ថុសាសន៍ទាំងអស់ មានចំនួនច្រើនរយច្រើនពាន់រូប ជ្រើសរើសយកចំពោះភិក្ខុដែលជាព្រះអរហន្តខីណាស្រព ៤៩៩ អង្គ ប្រភេទតេវិជ្ជាជាដើម អ្នកទ្រទ្រង់ព្រះបរិយត្តិ គឺព្រះត្រៃបិដកទាំងអស់ សម្រេចបដិសម្ភិទា មានអានុភាពធំ ដោយច្រើនដែលព្រះមានព្រះភាគទ្រង់លើកសរសើរជាឯតទគ្គៈ ដែលព្រះសង្គីតិកាចារ្យលើកឡើងពោលទុកថា គ្រានោះឯងព្រះមហាកស្សបៈជ្រើសរើសព្រះ

អរហន្ត ៥០០ រូប នៅខ្វះមួយរូប ដូច្នេះ ។

សួរថា ដូចម្ដេច ព្រះថេរៈទើបធ្វើឲ្យខ្វះមួយរូប (វៀរទុកមួយរូប) ឆ្លើយថា ដើម្បីបើកឱកាសដល់ព្រះអានន្ទត្ថេរ ។ ព្រោះថា រួមទាំងព្រះអានន្ទ បើវៀរព្រះអានន្ទចេញមិនអាចសង្គាយនាធម៌បានឡើយ ព្រោះព្រះអានន្ទ នោះ នៅជាព្រះសេក្ខៈមានកិច្ចដែលត្រូវធ្វើ ដូច្នោះ ទើបមិនអាចរួមបាន តែព្រោះហេតុដែលនវង្គសត្ថុសាសន៍ មានសុត្តៈ និងគេយ្យៈជាដើមណា មួយ ដែលព្រះទសពលទ្រង់សំដែងហើយ ដែលឈ្មោះថា ព្រះអានន្ទមិន បានទទួលចំពោះព្រះភក្ត្ររបស់ព្រះមានព្រះភាគ រមែងមិនមាន ដូច្នោះ ទើប មិនអាចវៀរចេញបាន ។ ប្រសិនបើ ព្រះអានន្ទសូម្បីជាសេក្ខៈ ក៏គួរតែ ព្រះថេរៈគប្បីជ្រើសរើស ព្រោះជាអ្នកមានឧបការៈច្រើនដល់ការធ្វើសង្គាយនា ធម៌ តែព្រោះហេតុអ្វី ព្រះថេរៈទើបមិនជ្រើសរើស ។ ព្រោះចៀសវាង ការតិះដៀល ។ ពិតណាស់ ព្រះថេរៈមានសេចក្ដីស្និទ្ធស្នាលជាមួយ ព្រះអានន្ទដ៏ក្រៃលែង ។ ពិតហើយ សូម្បីព្រះអានន្ទមានសីសៈស្កូវហើយ ព្រះថេរៈក៏នៅតែប្រៀនប្រដៅលោក ដោយវាទៈថាក្មេងថា "ក្មេងម្នាក់នេះ

មិនស្គាល់ប្រមាណឡើយ” ។ មយ៉ាងទៀត ព្រះអានន្ទនេះកើតនៅក្នុងត្រកូលសក្យៈ ជាព្រះអនុជរបស់ព្រះតថាគត ជាឱរសរបស់ស្តេចតូ ។ ក្នុងការជ្រើសរើសព្រះអានន្ទ ភិក្ខុទាំងឡាយនឹងសំគាល់ថាលោកលំអៀង ព្រោះស្រឡាញ់ នឹងគប្បីតិះដៀលថា “ព្រះថេរៈវៀរពួកភិក្ខុអ្នកសម្រេចអសេក្ខប្បដិសម្ភិទាចេញ ទៅជ្រើសរើសយកព្រះអានន្ទដែលសម្រេចសេក្ខប្បដិសម្ភិទា ។ ព្រះថេរៈកាលនឹងចៀសវាងពីពាក្យតិះដៀលនោះ គិតថា វៀរព្រះអានន្ទចេញ ក៏មិនអាចនឹងធ្វើសង្គាយនាបានឡើយ យើងនឹងជ្រើសរើសក៏ស្រេចតែភិក្ខុទាំងឡាយអនុមតិប៉ុណ្ណោះ ដូច្នេះ ទើបមិនជ្រើសរើសខ្លួនឯង ។

គ្រានោះ ភិក្ខុទាំងឡាយនាំគ្នា សូមអង្វរព្រះថេរៈដើម្បីជ្រើសរើសព្រះអានន្ទ ។ ដូចដែលព្រះអានន្ទពោលទុកថា ៖

ភិក្ខុទាំងឡាយ បានពោលចំពោះព្រះមហាកស្សបៈយ៉ាងនេះថា បពិត្រលោកម្ចាស់ដ៏ចម្រើន ព្រះអានន្ទនេះ សូម្បីនឹងជាព្រះសេក្ខៈ តែក៏មិនគួរលំអៀងព្រោះតែស្រឡាញ់

ព្រោះស្អប់ ព្រោះវង្វេង ព្រោះខ្លាច ក៏ព្រះអានន្ទនេះ បាន
រៀនព្រះធម្មវិន័យក្នុងសំណាក់ព្រះមានព្រះភាគដ៏ច្រើន បើ
ដូច្នោះ សូមព្រះថេរៈប្រោសជ្រើសរើសព្រះអានន្ទផងចុះ ។
គ្រានោះឯង ព្រះមហាកស្សបៈ ទើបបានជ្រើសរើសព្រះ
អានន្ទផង ។

ព្រះថេរៈទើបមានចំនួនគ្រប់ ៥០០ រូប រួមទាំងព្រះអានន្ទ ដែលព្រះថេរៈជ្រើសរើសដោយអនុមតិរបស់ភិក្ខុទាំងឡាយ ដោយប្រការដូច្នេះ ។

លំដាប់នោះ ភិក្ខុថេរៈទាំងឡាយបានប្រឹក្សាគ្នាថា យើងនឹងជួយគ្នាសង្គាយនាព្រះធម្មវិន័យ ទីណាហ្ន៎ ។ បានសន្មតិគ្នាថា ក្រុងរាជគ្រឹះមានទីគោចរច្រើន មានសេនាសនៈសមល្មម ប្រសិនបើយើងនឹងនៅចាំវស្សាជួយគ្នាធ្វើសង្គាយនាព្រះធម្មវិន័យ នៅក្នុងក្រុងរាជគ្រឹះ ភិក្ខុពួកដទៃ (ដែលមិនបានទទួលការជ្រើសរើស) មិនគប្បីចាំវស្សាក្នុងក្រុងរាជគ្រឹះ ។ ព្រោះហេតុអ្វី ភិក្ខុជាថេរៈទាំងនោះទើបបានសម្មតិគ្នាដូច្នោះ ។ ព្រោះលោកត្រិះរិះថា ការធ្វើសង្គាយនានេះ បើជាវរកម្មរបស់យើង បុគ្គលដែលជា

វិសភាគៈ (មិនត្រូវគ្នា) នឹងគប្បីចូលមកកណ្តាលសង្ឃ នឹងធ្វើថាវកម្មនោះវិនាស ។ គ្រានោះ ព្រះមហាកស្សបៈទើបប្រកាសដោយញត្តិទុតិយកម្ម ។ ពាក្យប្រកាសនោះ គប្បីជ្រាបតាមន័យដែលលោកពោលទុកហើយ ក្នុងសង្គីតិខន្ធកៈនោះឯង ។

គ្រានោះ រាប់តាំងពីព្រះមានព្រះភាគទ្រង់ចូលបរិនិព្វាន កាលការលេងសាធុកីឡា (ការរីករាយផ្លូវសាសនា) កន្លងទៅ ៧ ថ្ងៃ ការបូជាព្រះធាតុកន្លងទៅ ៧ ថ្ងៃទៀត ព្រះមហាកស្សបៈដឹងថា វេលាកន្លងទៅកន្លះខែហើយ នៅសល់តែវេលាកន្លះខែនៃគិម្ហន្តរដូវ ក៏កាន់តែចូលមកជិតតិថីចូលចាំវស្សា ទើបពោលថា "អ្នកមានអាយុទាំងឡាយ យើងនឹងនាំគ្នាទៅក្រុងរាជគ្រឹះ" ក៏នាំពួកភិក្ខុពាក់កណ្តាលបំបែកផ្លូវគ្នាដើរទៅ ។ សូម្បីព្រះអនុរុទ្ធត្ថេរៈ ក៏នាំពួកភិក្ខុពាក់កណ្តាលដើរទៅមួយផ្លូវទៀត ។ ចំណែកព្រះអានន្ទត្ថេរៈកាន់បាត្រ ចីវររបស់ព្រះមានព្រះភាគ មានពួកភិក្ខុហែហមប្រាថ្នានឹងទៅក្រុងសាវត្ថី (មុន) ហើយទើបនឹងទៅក្រុងរាជគ្រឹះ ក៏បំបែកផ្លូវគ្នាដើរទៅក្រុងសាវត្ថី ។ ក្នុងស្ថានទីដែលព្រះអានន្ទថេរៈដល់ ក៏បាន

ឮសំឡេងយំរៀបរាប់យ៉ាងធំថា "បពិត្រព្រះអានន្ទ លោកទុកសាស្ដានៅទីណា ហើយមក" ។ កាលព្រះថេរៈដល់ក្រុងសាវត្ថីតាមលំដាប់ បានឮសំឡេងយំរៀបរាប់យ៉ាងធំ ដូចក្នុងសម័យដែលព្រះមានព្រះភាគស្ដេចទ្រង់បរិនិព្វាន ។

បានឮថា ក្នុងទីនោះ ព្រះអានន្ទបានលួងលោមមហាជននោះដោយធម៌ មានកថាដែលប្រកបដោយអនិច្ចតា (សេចក្ដីមិនទៀង) ជាដើម ហើយទើបចូលទៅកាន់ព្រះវិហារជេតពន បើកទ្វារនៃព្រះគន្ធកុដិដែលព្រះទសពលធ្លាប់ប្រថាប់ ហើយនាំគ្រែ តាំងចេញមកគោះ បោសសំអាតព្រះគន្ធកុដិ បោលសំរាម គឺ ផ្កាឈើស្ងួត (ស្វិត) នាំគ្រែ តាំងចូលទៅតាំងទុកកន្លែងដើមវិញ បានធ្វើវត្តបដិបត្តិគ្រប់យ៉ាងដែលគួរធ្វើ ដូចក្នុងកាលដែលព្រះមានព្រះភាគនៅមានព្រះជន្ម ។

គ្រានោះ ព្រះថេរៈឆាន់ថ្នាំលាយដោយទឹកដោះ ក្នុងថ្ងៃទី ២ ដើម្បីកំចាត់បង់នូវធាតុធ្ងន់ឲ្យស្រាល ព្រោះតាំងពីព្រះមានព្រះភាគស្ដេចទ្រង់ចូលបរិនិព្វាន លោកត្រូវឈរច្រើន អង្គុយច្រើន ទើបអង្គុយនៅក្នុងតែវិហារ

ប៉ុណ្ណោះ សមពិតដូចដែលព្រះសង្គីតិកាចារ្យពោលទុកថា ពោលសំដៅដល់ក្មេងកំលោះ ដែលសុភមាណពប្រើឲ្យទៅនិមន្ត ដូច្នេះថា “ម្នាលកុមារ ថ្ងៃនេះមិនទាន់គួរទេ ព្រោះយើងផឹកថ្នាំបញ្ចុះ តែព្រឹកស្អែក ទើបយើងទៅ ។ ថ្ងៃទី ២ ព្រះថេរៈមានព្រះចេតកត្ថេរជាបច្ឆាសមណៈ (អ្នកជាប់តាម) ទើបចូលទៅ ត្រូវសុភមាណពសាកសួរបញ្ហាហើយ បានពោលសូត្រទី ១០ ឈ្មោះសុភសូត្រ ក្នុងទីឃនិកាយ ។

គ្រានោះ ព្រះថេរៈសូមឲ្យសុភមាណពជួយបដិសង្ខរណវត្ថុ “វត្ថុដែលទ្រុឌទ្រោម” ក្នុងវត្តជេតពនវិហារ លុះជិតចូលវស្សា ទើបទៅកាន់ក្រុងរាជគ្រឹះ ។ ព្រះមហាកស្សបៈ និងព្រះអនុរុទ្ធក៏យ៉ាងនោះ នាំពួកភិក្ខុទាំងអស់ទៅកាន់ក្រុងរាជគ្រឹះដូចគ្នា ។

សម័យនោះ ក្នុងក្រុងរាជគ្រឹះមានវត្តធំ ១៨ វត្ត គ្រប់វត្តមានសុទ្ធតែសម្រាមដែលគេបោះចោល ខ្ចាត់ខ្ចាយទៅក្នុងទីនោះ ។ ព្រោះក្នុងវេលាដែលព្រះមានព្រះភាគស្ដេចបរិនិព្វាន ភិក្ខុទាំងឡាយកាន់បាត្រចីវររបស់ខ្លួនបោះបង់វត្តចោល និងបរិវេណនាំគ្នាទៅអស់ ។ គ្រានោះ ព្រះថេរៈទាំង

ឡាយគិតគ្នាថា យើងនឹងជួយគ្នាបដិសង្ខរណាវិហារដែលទ្រុឌទ្រោម ក្នុងខែដំបូងនៃវស្សា ដើម្បីបូជាពុទ្ធតម្រាស់ និងចៀសវាងពាក្យតិះដៀលរបស់ពួកតិរ្ថិយ៍ ។ សេចក្តីថា ពួកតិរ្ថិយ៍នាំគ្នាតិះដៀលថា ពួកសាវករបស់ព្រះសមណគោតម កាលសាស្តានៅមានជីវិត ក៏នាំគ្នាទំនុកបំរុងវត្ត លុះសាស្តាបរិនិព្វានហើយ ក៏នាំគ្នាបោះបង់ចោលវត្ត ។ លោកអធិប្បាយថា ព្រះថេរៈទាំងឡាយគិតគ្នាដូច្នោះ ក៏ដើម្បីចៀសវាងពីពាក្យតិះដៀលរបស់ពួកតិរ្ថិយ៍ទាំងនោះ ។ សមពិតដូចលោកពោលទុកថា ៖

គ្រានោះឯង ភិក្ខុជាថេរៈទាំងឡាយ ប្រឹក្សាគ្នាដូច្នេះថា អ្នកមានអាយុទាំងឡាយ ការបដិសង្ខរណាវិហារដែលទ្រុឌទ្រោម ព្រះមានព្រះភាគទ្រង់សរសើរហើយ មកអ្នកមានអាយុទាំងឡាយ យើងនាំគ្នាបដិសង្ខរណាវិហារដែលខូចទ្រុឌទ្រោមរហូតខែដំបូង ខែកណ្តាលសីមយើងប្រជុំគ្នាសង្គាយនាព្រះធម៌វិន័យ ។

ថ្ងៃទី ២ ព្រះថេរៈទាំងនោះ នាំគ្នាទៅឈរជិតទ្វារព្រះរាជនិវេសន៍ ។

ព្រះបាទអជាតសត្រូវស្តេចមក ទ្រង់ថ្វាយបង្គំហើយបវារណាថា "លោកម្ចាស់ តើញោមអាចជួយអ្វីបានខ្លះ លោកម្ចាស់ត្រូវការអ្វី" ។ ព្រះថេរៈទាំងឡាយថ្វាយព្រះពរឲ្យទ្រង់ជ្រាបនូវហត្ថកម្ម ដើម្បីត្រូវការបដិសង្ខារណាវត្តធំទាំង ១៨ វត្ត ។ ព្រះរាជាទ្រង់ទទួលថា "សាធុលោកម្ចាស់" ហើយព្រះរាជទានជាងដែលមានស្នាដៃល្អ ។ ព្រះថេរៈទាំងឡាយឲ្យបដិសង្ខរណាវត្តទាំងអស់រហូតខែដំបូង ។ តមក ទើបទូលព្រះរាជាថា "សូមថ្វាយព្រះពរ ការងារបដិសង្ខរណាវិហារស្រេចហើយ ឥឡូវនេះ អាត្មាភាពទាំងឡាយនឹងនាំគ្នាសង្គាយនាធម៌វិន័យ" ។ ព្រះរាជាទ្រង់មានព្រះតម្រាស់ថា "សាធុៗ លោកម្ចាស់ សូមលោកម្ចាស់ប្រោសធ្វើដោយសប្បាយចុះ ការងារខាងអាណាចក្រទុកជាធុរៈរបស់ញោម ចំណែកខាងធម្មចក្រជាធុរៈរបស់លោកម្ចាស់ ប្រោសប្រាប់មកចុះ លោកម្ចាស់ នឹងឲ្យញោមជួយអ្វីខ្លះ" ។ ព្រះថេរៈទាំងឡាយថ្វាយព្រះពរទូលថា "ថ្វាយព្រះពរ ប្រោសឲ្យសាងទីអង្គុយប្រជុំសម្រាប់ភិក្ខុទាំងឡាយដែលគង់សង្គាយនាធម៌" ។ ត្រាស់សួរថា "នឹងធ្វើត្រង់ណា លោកម្ចាស់" ។ ទូលថា "ថ្វាយព្រះពរ ធ្វើជិតទ្វារល្អាងក្នុំសត្ត-

បពិត នាក្នុំវេភារ: គួរ ថ្វាយព្រះពរមហាបពិត្រ ។ ព្រះបាទអជាតសត្រូវទទួលថា “ប្រពៃហើយលោកម្ចាស់” ហើយប្រោសឲ្យសាងមណ្ឌលធំ មានជញ្ជាំង សសរ និងជណ្ដើរ ដែលចាត់ចែងទុកយ៉ាងល្អ វិចិត្រដោយក្បាច់ផ្កាឈើ និងក្បាច់វល្លិ៍ច្រើនប្រភេទ ហាក់ដូចជាវិស្សុកម្មទេវបុត្រនិមិត្តទុក តាក់តែងមណ្ឌលធំនោះឲ្យមានពិតានមាស លាយឡំជាមួយកម្រងផ្កាឈើប្រភេទផ្សេងៗ រយេងរយោង ការងារលើផែនដីក៏ធ្វើស្រេចយ៉ាងល្អ លំអរដោយផ្កាឈើច្រើនពណ៌នាំមកបំពេញ ចំណែកផ្ទៃផ្លូវដើរក៏បានលំអរដោយកូនរាំងមណីរតនៈដ៏វិចិត្រ ដូចវិមានព្រហ្ម ប្រោសឲ្យក្រាលអាសនៈដែលជាកប្បិយ: ៥០០ កន្លែង បែរមុខទៅទិសខាងជើង ខ្នងបែរទៅទិសខាងត្បូង ឲ្យក្រាលធម្មាសនៈដែលគួរ ជាអាសនៈសម្រាប់ព្រះមានព្រះភាគ បែរមុខទៅទិសខាងកើត ត្រង់កណ្ដាលមណ្ឌប ដាក់ផ្ចិតដែលធ្វើដោយភ្លុកដំរីទុកលើធម្មាសនៈនោះ ហើយត្រាស់បង្គាប់ឲ្យប្រាប់ដល់ភិក្ខុសង្ឃថា “កិច្ចកម្មរួចហើយ លោកម្ចាស់” ។

ភិក្ខុទាំងឡាយពោលចំពោះព្រះអានន្ទថា “អានន្ទ ព្រឹកស្អែក ជាថ្ងៃ

ប្រជុំសង្ឃ ចំណែកខ្ញុំនលោកជាសេក្ខៈ នៅមានកិច្ចដែលត្រូវធ្វើ ព្រោះហេតុនោះ លោកទើបមិនគួរទៅប្រជុំ សូមលោកចូរកុំប្រមាទឡើយ" ។ គ្រានោះ ព្រះអានន្ទត្រិះរិះថា ព្រឹកស្អែកនេះជាថ្ងៃប្រជុំ ការដែលយើងនៅជាសេក្ខៈ ទៅប្រជុំមិនសមគួរឡើយ ដូច្នេះ ទើបនៅដោយកាយគតាសតិអស់រាត្រី វេលាជិតភ្លឺទើបចុះចាកទីចង្រ្កមចូលទៅកាន់វិហារ នឹកដល់កាយបំណងនឹងដេក ។ ជើងទាំងពីរផុតផ្ទៃដី និងសីសៈនៅមិនទាន់ដល់ខ្នើយក្នុងរវាងនោះ ចិត្តក៏មិនប្រកាន់មាំ និងផុតចាកអាសវៈទាំងឡាយ ។

ពិតហើយ ព្រះអានន្ទនេះនៅខាងក្រៅដោយការចង្រ្កម មិនអាចធ្វើគុណវិសេសឲ្យកើតឡើងបាន ទើបត្រិះរិះថា ព្រះមានព្រះភាគបានត្រាស់ចំពោះយើងទុកមិនមែនឬថា អានន្ទ អ្នកបានធ្វើបុណ្យទុកហើយ ចូរប្រកបសេចក្តីព្យាយាមឲ្យរឿយៗ ក៏នឹងជាអ្នកមិនមានអាសវៈបានដោយឆាប់រហ័ស ក៏ធម្មតាថា ព្រះពុទ្ធទាំងឡាយត្រាស់ទុកមិនខុស យើងគង់ប្រារព្ធសេចក្តីព្យាយាមហួសពេក ព្រោះហេតុនោះ ចិត្តរបស់យើងទើបប្រព្រឹត្តទៅក្នុងផ្លូវរាយមាយ ណ្ហើយចុះ យើងនឹងប្រកបសេចក្តីព្យាយាមតែល្មម ដូច្នេះ

ទើបចុះចាកទីចង្រ្កម ឈរត្រង់កន្លែងមួយលាងជើង លាងជើងហើយក៏ចូល ទៅកាន់វិហារ អង្គុយលើគ្រែ គិតនឹងសម្រាកមួយស្របក់ ក៏ទម្រេតកាយ លើគ្រែ ជើងទាំងពីរផុតពីដី និងសីសៈនៅមិនទាន់ដល់ខ្នើយ ក្នុងចន្លោះ នោះ ចិត្តក៏មិនប្រកាន់មាំ និងរួចចាកអាសវៈទាំងឡាយ ។ ព្រះអរហត្ត របស់ព្រះថេរៈ វៀរចាកឥរិយាបថ ៤ ។ ព្រោះហេតុនោះ កាលបើគេ សួរថា ក្នុងព្រះសាសនានេះ ភិក្ខុរូបណា មិនអង្គុយ មិនដេក មិនឈរ មិនដើរ សម្រេចព្រះអរហត្ត ក៏គួរនឹងឆ្លើយថា ព្រះអានន្ទត្ថេរៈ ។

ក្នុងថ្ងៃទី ២ ភិក្ខុជាថេរៈទាំងឡាយឆាន់ភត្តាហារ ទុកដាក់បាត្រចីវរ ហើយ ក៏ប្រជុំគ្នាក្នុងធម្មសភា ។ ចំណែកព្រះអានន្ទ បំណងនឹងសម្ដែង ដឹងការសម្រេចព្រះអរហត្តរបស់ខ្លួន ទើបមិនទៅជាមួយភិក្ខុទាំងឡាយ ។ ភិក្ខុទាំងឡាយ កាលអង្គុយលើអាសនៈរៀងៗ ខ្លួន តាមសមគួរ ក៏អង្គុយ វៀរអាសនៈរបស់អានន្ទ ។ ក្នុងពេលនោះ កាលមានព្រះថេរៈខ្លះសួរថា នោះជាអាសនៈរបស់នរណា? ក៏មានសំឡេងឆ្លើយថា របស់ព្រះអានន្ទ ។ សួរថា ក៏ព្រះអានន្ទទៅណាហ្ន៎? សម័យនោះ ព្រះថេរៈត្រិះរិះថា ឥឡូវនេះ

ជាវេលាដែលយើងទៅបានហើយ ។ ដូច្នោះ កាលសំដែងអានុភាពរបស់ខ្លួន ទើបមុជចុះផែនដីទៅសំដែងខ្លួនខាងលើអាសនៈរបស់ខ្លួន ។ អាចារ្យពួកខ្លះពោលថា "ហោះមកអង្គុយក៏មាន" ។

កាលព្រះអានន្ទអង្គុយរៀបរយហើយ ព្រះមហាកស្សបៈទើបប្រឹក្សានឹងភិក្ខុទាំងឡាយថា អ្នកមានអាយុទាំងឡាយ យើងនឹងសង្គាយនាអ្វីមុន ធម៌ ឬវិន័យ ។

ភិក្ខុទាំងឡាយទើបឆ្លើយថា "បពិត្រមហាកស្សបៈ ធម្មតាថា វិន័យជាអាយុរបស់ព្រះពុទ្ធសាសនា កាលវិន័យតាំងនៅ ព្រះសាសនាក៏ឈ្មោះថា តាំងនៅដូចគ្នា ព្រោះដូច្នោះ យើងនឹងសង្គាយនាវិន័យមុន" ។ ព្រះថេរៈសួរថា "នឹងប្រគល់ឲ្យនរណាជាធុរៈសង្គាយនាវិន័យហ្ន៎?" ភិក្ខុទាំងឡាយឆ្លើយថា "ព្រះឧបាលិ លោកម្ចាស់" ។ ព្រះថេរៈសួរបញ្ជាក់ថា ព្រះអានន្ទមិនអាចឬ? ភិក្ខុទាំងឡាយឆ្លើយថា មិនមែនមិនអាចទេលោកម្ចាស់ តែថា ព្រះសម្មាសម្ពុទ្ធកាលមានព្រះជន្មគង់នៅ ទ្រង់អាស្រ័យការបង្រៀនព្រះបរិយត្តិ (របស់លោក) ទើបទ្រង់ស្ថាបនាព្រះឧបាលិទុកក្នុងតំណែងជា

ឯតទគ្គៈថា ម្នាលភិក្ខុទាំងឡាយ ឧបាលិប្រសើរលើសភិក្ខុជាសាវ័ករបស់តថាគតអ្នកទ្រទ្រង់វិន័យ ដូច្នេះ ព្រោះហេតុនោះ យើងនឹងសួរព្រះឧបាលិ ហើយនាំគ្នាសង្គាយនាព្រះវិន័យ ។ តពីនោះ ព្រះថេរៈទើបសម្មតិដោយខ្លួនឯង ដើម្បីសួរវិន័យ ចំណែកព្រះឧបាលិត្ថេរៈក៏សម្មតិខ្លួន ដើម្បីឆ្លើយវិន័យ ។ ក្នុងសេចក្តីនោះ មានបាលីដូច្នេះ ៈ-

គ្រានោះ ព្រះមហាកស្សបៈ ប្រកាសសង្ឃថា

សុណាតុ មេ អាវុសោ សង្ឃោ , យទិ សង្ឃស្ស

បត្តកល្លំ អហំ ឧបាលឹ វិនយំ បុច្ឆេយ្យំ ។

លោកទាំងឡាយ សូមសង្ឃស្តាប់ខ្ញុំ ប្រសិនបើសង្ឃព្រមព្រៀងហើយ ខ្ញុំនឹងសួរវិន័យដល់ព្រះឧបាលិ ។

សូម្បីព្រះឧបាលិ ក៏ប្រកាសសង្ឃថា

សុណាតុ មេ ភន្តេ សង្ឃោ , យទិ សង្ឃស្ស បត្តកល្លំ អហំ

អាយស្មតា មហាកស្សបេន វិនយំ បុដ្ឋោ វិស្សជ្ជេយ្យំ ។

បពិត្រលោកទាំងឡាយ សូមសង្ឃស្តាប់ខ្ញុំ ប្រសិនបើសង្ឃព្រមព្រៀង

ហើយ ខ្ញុំដែលព្រះមហាកស្សបៈសួរហើយ នឹងឆ្លើយព្រះវិន័យ ។

ព្រះឧបាលិ គ្រាសម្មតិខ្លួនដោយខ្លួនឯងយ៉ាងនេះហើយ ក៏ក្រោកចាកអាសនៈ គ្រងចីវរឆៀងស្មាម្ខាង សំពះភិក្ខុជាថេរៈហើយ អង្គុយលើធម្មាសនៈ ចាប់ផ្លិតធ្វើដោយភ្លុកដំរី តពីនោះ ព្រះមហាកស្សបត្ថេរទើបសួរព្រះវិន័យទាំងអស់ តាំងពីបឋមបារាជិកជាដើមទៅ ចំពោះព្រះឧបាលិ-ត្ថេរ ។ ព្រះឧបាលិត្ថេរក៏ឆ្លើយ ភិក្ខុទាំងអស់ ៥០០ រូប ក៏សូត្រព្រមៗ គ្នាតាំងពីបឋមបារាជិកសិក្ខាបទ ព្រមទាំងនិទានជាដើមទៅ សូម្បីសិក្ខាបទក្រៅពីនោះ ក៏សូត្រយ៉ាងនោះ ព្រោះហេតុនោះ គប្បីលើកយករឿងទាំងអស់តាមអដ្ឋកថាវិន័យ ។ ព្រះឧបាលិត្ថេរ គ្រាសង្គាយនាវិន័យបិដកទាំងអស់ ព្រមទាំងវិភង្គទាំង ២ (ភិក្ខុវិភង្គ ភិក្ខុនីវិភង្គ) គម្ពីរខន្ធកៈ និងបរិវារៈ ដោយន័យនេះហើយ ក៏ដាក់ផ្លិតភ្លុកដំរី ចុះចាកធម្មាសនៈ សំពះភិក្ខុដែលជាថេរៈហើយ ក៏អង្គុយលើអាសនៈរបស់ខ្លួនវិញ ។

ព្រះមហាកស្សបត្ថេរ លុះសង្គាយនាព្រះវិន័យហើយ បំណងនឹងសង្គាយនាព្រះធម៌ ទើបសួរភិក្ខុទាំងឡាយថា លោកទាំងឡាយកាលនឹង

សង្គាយនាព្រះធម៌ នឹងប្រគល់ដល់បុគ្គលណាជាធុរៈ សង្គាយនាព្រះធម៌? ភិក្ខុទាំងឡាយ ទើបឆ្លើយថា ប្រគល់ដល់ព្រះអានន្ទត្ថេរឲ្យជាធុរៈ ។

គ្រានោះ ព្រះមហាកស្សបៈ ទើបប្រកាសសង្ឃថា

សុណាតុ មេ អាវុសោ សង្ឃោ , យទិ សង្ឃស្ស
បត្តកល្លំ អហំ អានន្ទំ ធម្មំ បុច្ឆេយ្យំ ។

លោកទាំងឡាយ សូមសង្ឃស្តាប់ខ្ញុំ ប្រសិនបើសង្ឃព្រមព្រៀងគ្នាហើយ ខ្ញុំនឹងសួរព្រះធម៌ចំពោះព្រះអានន្ទ ។

គ្រានោះ ព្រះអានន្ទ ក៏ប្រកាសសង្ឃថា

សុណាតុ មេ ភន្តេ សង្ឃោ , យទិ សង្ឃស្ស បត្តកល្លំ អហំ
អាយស្មតា មហាកស្សបេន ធម្មំ បុដ្ឋោ វិស្សជ្ជេយ្យំ ។

បពិត្រលោកទាំងឡាយ សូមសង្ឃស្តាប់ខ្ញុំ ប្រសិនបើសង្ឃព្រមព្រៀងគ្នាហើយ ខ្ញុំដែលព្រះមហាកស្សបៈសួរហើយ នឹងឆ្លើយព្រះធម៌ ដូច្នេះ ។

គ្រានោះ ព្រះអានន្ទចុះចាកអាសនៈ គ្រងចីវរឆៀងស្មាម្ខាង ថ្វាយបង្គំភិក្ខុជាថេរៈហើយ ក៏អង្គុយលើធម្មាសនៈ កាន់ផ្លិត (ដែលធ្វើដោយភ្លុក

ជ័រ) ។ លំដាប់នោះ ព្រះមហាកស្សបៈ សួរព្រះធម៌ចំពោះព្រះអានន្ទថា អានន្ទ ព្រហ្មជាលសូត្រ ព្រះមានព្រះភាគត្រាស់ក្នុងទីណា? ឆ្លើយថា ក្នុងព្រះដំណាក់ព្រះរាជឧទ្យានឈ្មោះអម្ពលដ្ឋិកា ដែលនៅចន្លោះក្រុងរាជគ្រឹះ និងក្រុងនាលន្ទា ។ សួរថា ទ្រង់ប្រារព្ធនរណា? ឆ្លើយថា ទ្រង់ប្រារព្ធសុប្បិយបរិព្វាជកជាមួយព្រហ្មទត្តមាណព ។ លំដាប់នោះ ព្រះមហា-កស្សបៈ សួរព្រះអានន្ទដល់និទាននៃព្រហ្មជាលសូត្រ សួរទាំងបុគ្គល ។ សួរថា អានន្ទ ក៏សាមញ្ញផលសូត្រ ត្រាស់ត្រង់ទីណា? ឆ្លើយថា ត្រង់ចំការស្វាយរបស់ពេទ្យជីវក នាក្រុងរាជគ្រឹះ លោកម្ចាស់ ។ សួរថា ត្រាស់ជាមួយនរណា? ឆ្លើយថា ជាមួយព្រះបាទអជាសត្រូវវេទេហិបុត្រ ឱរសព្រះនាងវេទេហិ លោកម្ចាស់ ។ លំដាប់នោះ ព្រះមហាកស្សបៈទើបសួរព្រះអានន្ទ ដល់និទាននៃសាមញ្ញផលសូត្រ សួរទាំងបុគ្គល ។ ព្រះមហាកស្សបៈសួរ សូម្បីទាំង ៥ និកាយដោយឧបាយនេះឯង ព្រះអានន្ទ ត្រូវសួរហើយសួរទៀត ក៏ឆ្លើយបានទាំងអស់ ។ **បឋមមហាសង្គីតិ** (សង្គា-យនាធំគ្រាដំបូង) នេះ ព្រះថេរៈ ៥០០ រូបបាននាំគ្នាធ្វើហើយ ។

*បឋមមហាសង្គីតិ ដែលព្រះថេរៈ ៥០០ រូប នាំគ្នាធ្វើ ព្រោះហេតុនោះ លោកទើបហៅថា បញ្ចសត្តា និងព្រោះភិក្ខុទាំងនោះសុទ្ធតែជាព្រះថេរៈទាំងអស់ ទើបហៅថា ថេរិកា (ថេរវាទ) ។*

កាលបឋមសង្គីតិនេះកំពុងប្រព្រឹត្តទៅ ព្រះមហាកស្សបៈ គ្រាសួរគម្ពីរទីឃនិកាយ និងគម្ពីរមជ្ឈិមនិកាយជាដើមអស់ហើយ កាលនឹងសួរគម្ពីរខុទ្ទកនិកាយតទៅតាមលំដាប់ ទើបសួរដល់និទានក្នុងពាក្យនេះថា សួរទាំងនិទាន សួរទាំងបុគ្គល ខាងចុងពាក្យសួរ ដែលលោកបានសួរជាដើមយ៉ាងនេះថា អានន្ទ មង្គលសូត្រ ព្រះមានព្រះភាគទ្រង់ត្រាស់ក្នុងទីណា? ដូច្នេះ ។ ព្រះអានន្ទបំណាងនឹងពោលនិទាននោះឲ្យពិស្តារថា ត្រាស់យ៉ាងណា អ្នកណាស្តាប់មក ស្តាប់កាលណា និងអ្នកណាពោល ពោលទីណា ពោលដល់អ្នកណា នឹងពោលសេចក្តីនោះឲ្យអស់ កាលនឹងសំដែងសេចក្តីនោះថា ត្រាស់ទុកយ៉ាងនេះ ។ ខ្ញុំបានស្តាប់មក ។ ស្តាប់មកសម័យមួយ ។ ព្រះមានព្រះភាគត្រាស់ ។ ត្រាស់ក្នុងក្រុងសាវត្ថី ។ ត្រាស់ដល់

ទេវតា ដូច្នេះ ទើបពោលថា ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយព្រះមានព្រះភាគទ្រង់គង់នៅក្នុងវត្តជេតពន ជាអារាមរបស់អនាថបិណ្ឌិកសេដ្ឋីក្នុងក្រុងសាវត្ថី ។ល។ បានក្រាបទូលព្រះមានព្រះភាគដោយគាថា ពាក្យនេះ ព្រះអានន្ទពោលទុកយ៉ាងនេះ ។ ក៏ឯពាក្យនោះគប្បីជ្រាបថា ពោលទុកក្នុងវេលាធ្វើបឋមមហាសង្គីតិ ។

ឥឡូវនេះ នឹងអធិប្បាយក្នុងសេចក្តីនេះថា ត្រាស់ព្រោះហេតុអ្វី ។ ព្រោះហេតុដែលព្រះអានន្ទ ត្រូវព្រះមហាកស្សបៈសួរដល់និទាន លោកទើបពោលនិទាននោះទុកពិស្តារតាំងអំពីដើម ។ម្យ៉ាងទៀត ព្រោះហេតុដែលទេវតាពួកខ្លះឃើញព្រះអានន្ទអង្គុយលើធម្មាសនៈ ចោមរោមដោយគណៈអ្នកជំនាញ ទើបកើតចិត្តគិតថា ព្រះអានន្ទនេះ ជាវេទេហមុនី (មុនីអ្នកគួរដល់ការរៀន) សូម្បីដោយប្រក្រតី ក៏ជាប់នៅក្នុងសក្យត្រកូល ជាទាយាទរបស់ព្រះមានព្រះភាគ សូម្បីព្រះមានព្រះភាគ ក៏ទ្រង់សរសើរទុកក្នុងតំណែងឯតគ្គៈដល់ ៥ ស្ថាន ជាអ្នកប្រកបដោយអច្ឆរិយអព្ភូតធម៌ ៤ប្រការ ជាទីស្រឡាញ់ពេញចិត្តរបស់បរិស័ទ ៤ ឥឡូវនេះ ឃើញកន្លែង

ដែលជារជ្ជទាយាទដោយធម៌របស់ព្រះដ៏មានព្រះភាគ កើតជាពុទ្ធ: (ជាបណ្ឌិត) ។

ដូច្នោះ ព្រះអានន្ទ បានដឹងទូទៅដល់បរិវិតក្ក:របស់ទេវតាទាំងនោះដោយចិត្តខ្លួនឯង អត់ធន់នឹងការសរសើរគុណដែលមិនមានពិតនោះ មិនបាន ដើម្បីសំដែងការ:ដែលខ្លួនត្រឹមតែជាសាវក ទើបពោលថា ខ្ញុំបានស្តាប់មកហើយយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ។ល។ បានក្រាបទូល ។ ក្នុងវាំងនេះព្រះអរហន្ត ៥០០ រូប និងទេវតាច្រើនពាន់ ក៏ឲ្យសព្ទសាធុការព្រះអានន្ទថា សាធុ សាធុ ផែនមហាប្រឹថពីក៏ញាប់ញ័រ ភ្លៀងផ្កាឈើច្រើនប្រភេទក៏ធ្លាក់ចុះមកអំពីអាកាស សេចក្តីអស្ចារ្យយ៉ាងដទៃក៏ប្រាកដ និងទេវតាជាច្រើនក៏កើតសេចក្តីសង្វេគថា ពាក្យណាយើងស្តាប់មកចំពោះព្រះភ័ក្ត្រព្រះមានព្រះភាគ ពាក្យនោះ សូម្បីហេតុការណ៍កន្លងផុតខ្សែក្នុកមកហើយ ក៏នឹងកើតបានទៀត ។ ពាក្យនេះ ព្រះអានន្ទ សូម្បីនឹងពោលទុកវេលាធ្វើបឋមមហាសង្គីតិ ក៏គប្បីជ្រាបថា លោកពោលព្រោះហេតុនេះ ដោយប្រការដូច្នេះ ។ ដោយការពណ៌នាត្រឹមប៉ុណ្ណេះ ក៏ជាការ

ដែលប្រកាសសេចក្ដីនៃកន្ទះគាថានេះថា វុត្តំ យេន យទា យស្មា ចេតំ វត្វា ឥមំ វិធី (ទីនពោលវិធីនេះយ៉ាងនេះថា ពាក្យនេះ នរណាពោល ពោលកាលណា ពោលព្រោះហេតុអ្វី) ។

## ពណ៌នាបាឋៈថា ឯវំ ជាដើម

ដើម្បីប្រកាសសេចក្ដីរួបរួមទុកដោយមាតិការជាដើម យ៉ាងនេះថា ឯវមិច្ចាបាឋស្ស អត្ថំ នានប្បការតោ (សេចក្ដីនៃបាឋៈថា ឯវំ ជាដើម ដោយប្រការផ្សេងៗ) ឥឡូវនេះ សូមអធិប្បាយដូច្នេះ ស័ព្ទថា ឯវំ នេះ គប្បីឃើញថា ប្រើក្នុងអត្ថទាំងឡាយមានជាដើមថា សេចក្ដីប្រៀបធៀប សេចក្ដីណែនាំ សេចក្ដីសរសើរ ការតិះដៀល ការទទួលពាក្យ អាការ ការពន្យល់ ការហាមសេចក្ដីដទៃ ។ ពិតដូច្នោះ ឯវំ ស័ព្ទនេះ ។ ប្រើក្នុងសេចក្ដីប្រៀបធៀប បានក្នុងប្រយោគជាដើមយ៉ាងនេះថា ឯវំ ជាតេន មច្ចេន កត្តព្វំ កុសលំ ពហុំ សត្វកើតមកហើយ គួរបំពេញកុសលឲ្យបានច្រើន ដូច្នោះ ។

ប្រើក្នុងសេចក្ដីណែនាំ បានក្នុងប្រយោគជាដើមយ៉ាងនេះថា ឯវំ តេ

អភិក្កមិតព្វំ ឯវំ តេ បដិក្កមិតព្វំ លោកគប្បីឈានទៅយ៉ាងនេះ គប្បី ថយត្រឡប់យ៉ាងនេះ ។

ប្រើក្នុងសេចក្តីសរសើរ បានក្នុងប្រយោគជាដើមយ៉ាងនេះថា ឯវ-មេតំ ភគវា ឯវមេតំ សុគត សេចក្តីនោះយ៉ាងនេះឯង ព្រះមានព្រះភាគ ប្រការនោះយ៉ាងនេះឯង ព្រះសុគត ។

ប្រើក្នុងការតិះដៀល បានក្នុងប្រយោគជាដើមយ៉ាងនេះថា ឯវមេវំ បនាយំ វសលី យស្មឹ វា តស្មឹ វា តស្ស មុណ្ឌកស្ស សមណកស្ស វណ្ណំ ភាសតិ ក៏ស្ត្រីទន់ខ្សោយម្នាក់នេះពោលសរសើរ សមណៈក្បាល ត្រងោលនោះ យ៉ាងនេះ យ៉ាងនេះ គ្រប់ទីកន្លែង ។

ប្រើក្នុងការទទួលពាក្យ បានក្នុងប្រយោគជាដើមយ៉ាងនេះថា ឯវំ ភន្តេតិ ខោ តេ ភិក្ខូ ភគវតោ បច្ចស្សោសុំ ភិក្ខុទាំងនោះ ទូលទទួល ព្រះតម្រាស់របស់ព្រះមានព្រះភាគថា យ៉ាងនោះឯង ព្រះអង្គ ។

ប្រើក្នុងអាការ បានក្នុងប្រយោគជាដើមយ៉ាងនេះថា ឯវំ ព្យា ខោ អហំ ភន្តេ ភគវតា ធម្មំ ទេសិតំ អាជានាមិ បពិត្រលោកដ៏ចម្រើន ខ្ញុំ

រមែងដឹងនូវទៅដល់ធម៌ដែលព្រះមានព្រះភាគទ្រង់សំដែងហើយ យ៉ាងនេះ ។

ប្រើក្នុងការពន្យល់ បានក្នុងប្រយោគជាដើមយ៉ាងនេះថា ឯហិ ត្វំ មាណវក យេន សមណោ អានន្ទោ តេនុបសង្កម ។ ឧបសង្កមិត្វា មម វចនេន សមណំ អានន្ទំ អប្បាពាធំ អប្បាតង្កំ លហុដ្ឋានំ ពលំ ផាសុវិហារំ បុច្ឆ សុភោ មាណវោ តោទេយ្យបុត្តោ ភវន្តំ អានន្ទំ អប្បាពាធំ អប្បាតង្កំ លហុដ្ឋានំ ពលំ ផាសុវិហារំ បុច្ឆតីតិ ឯវញ្ច វទេហិ សាធុ កិរ ភវំ អានន្ទោ យេន សុភស្ស មាណវស្ស តោទេយ្យបុត្តស្ស និវេសនំ តេនុបសង្កមតុ អនុកម្បំ ឧបាទាយ ។ មកនេះ ក្មេងកំលោះ អ្នកចូរទៅរកព្រះអានន្ទ ហើយអ្នកសួរព្រះអានន្ទដល់ការមិនមានអាពាធ ការមិនមានរោគ ការរហ័សរហួន ការមានកម្លាំង ការនៅសប្បាយ ហើយចូរនិយាយយ៉ាងនេះថា សុភមាណពតោទេយ្យបុត្រ សូមសាកសួរដល់ព្រះអានន្ទ ដល់ការមិនមានអាពាធ ការមិនមានរោគ ការរហ័សរហួន ការមានកម្លាំង ការនៅជាសុខ ហើយចូរពោលយ៉ាងនេះថា សាធុ សូមព្រះអានន្ទមេត្តា អនុគ្រោះចូលទៅកាន់និវេសន៍របស់សុភមា-

ណាពតោទេយ្យបុត្រផងចុះ ។

ប្រើក្នុងការហាមសេចក្ដីដទៃ បានក្នុងប្រយោគជាដើមថា តំ កឹ មញ្ញថ កាលាមា ឥមេ ធម្មា កុសលា វា អកុសលា វាតិ ។ អកុសលា ភន្តេតិ ។ សាវជ្ជា វា អនវជ្ជា វាតិ ។ សាវជ្ជា ភន្តេតិ ។ វិញ្ញុគរហិតា វា វិញ្ញុប្បសត្ថា វាតិ ។ វិញ្ញុគរហិតា ភន្តេតិ ។ សមត្តា សមាទិន្នា អហិតាយ ទុក្ខាយ សំវត្តន្តិ នោ វា កថំ វោ ឯត្ថ ហោតីតិ ។ សមត្តា ភន្តេ សមាទិន្នា បហិតាយ ទុក្ខាយ សំវត្តន្តិ ឯវំ នោ ឯត្ថ ហោតីតិ ។ ត្រាស់សួរថា ម្នាលកាលាមៈទាំងឡាយ អ្នកនឹងសំគាល់សេចក្ដីនោះដូចម្ដេច ធម៌ទាំងនេះជាកុសល ឬជាអកុសល ។ ទូលឆ្លើយថា ជាអកុសល ព្រះអង្គ ។ ត្រាស់សួរថា មានទោស ឬមិនមានទោស ។ ទូលឆ្លើយថា មានទោស ព្រះអង្គ ។ ត្រាស់សួរថា វិញ្ញូជនតិះដៀល ឬសរសើរ ។ ទូលឆ្លើយថា តិះដៀល ព្រះអង្គ ។ ត្រាស់សួរថា បុគ្គលសមាទានបរិបូណ៌ហើយ ប្រព្រឹត្តទៅដើម្បីមិនមែនជាប្រយោជន៍ ដើម្បីសេចក្ដីទុក្ខមិនមែនឬ ក្នុងប្រការនេះ អ្នកមានការឃើញដូចម្ដេច ។

ទូលឆ្លើយថា បុគ្គលសមាទានបរិបូណ៌ហើយ រមែងប្រព្រឹត្តទៅដើម្បីមិនជាប្រយោជន៍ ដើម្បីសេចក្តីទុក្ខ ខ្ញុំព្រះអង្គមានការឃើញក្នុងប្រការនេះ យ៉ាងនេះ ព្រះអង្គ ។

តែក្នុងទីនេះ គប្បីឃើញថា ឯវំ ស័ព្ទ ប្រើក្នុងអត្ថ គឺ អាការការពន្យល់ និងការហាមសេចក្តីដទៃទៀត ។

ក្នុងអត្ថទាំង ៣ នោះ ព្រះថេរៈសំដែងអត្ថនេះដោយ ឯវំ ស័ព្ទ ដែលមានអត្ថជាអាការថា ព្រះតម្រាស់របស់ព្រះមានព្រះភាគអង្គនោះ ល្អិតដោយន័យផ្សេងៗ កើតឡើងដោយច្រើនអធ្យាស្រ័យ សម្បូរដោយអត្ថ និងព្យញ្ជនៈ មានបាដិហារ្យផ្សេងៗ ច្រើនយ៉ាង ជ្រាលជ្រៅដោយធម៌ អត្ថ ទេសនា និងបដិវេធ មកប៉ះខ្ទប់សោតៈ សមគួរដល់ភាសារៀងៗ ខ្លួនរបស់សព្វសត្វទាំងឡាយ នរណានឹងអាចដឹងបានដោយប្រការទាំងពួង តែខ្ញុំសូម្បីចេះតិចតួចក៏ឲ្យកើតសេចក្តីប្រាថ្នាចង់ស្តាប់ ក៏បានស្តាប់មកយ៉ាងនេះ គឺ សូម្បីខ្ញុំក៏បានស្តាប់មកហើយ ដោយអាការយ៉ាងនេះឯង ។

ដោយ ឯវំ ស័ព្ទ ដែលមានអត្ថដល់ការចង្អុលបង្ហាញ ព្រះថេរៈ

កាលទីងដោះខ្លួនថា ខ្ញុំមិនមែនសយម្ភូ ព្រះសូត្រនេះ ខ្ញុំមិនបានធ្វើឲ្យជាក់ច្បាស់ ទើបសំដែងព្រះសូត្រទាំងអស់ដែលគួរពោលក្នុងកាលឥឡូវនេះថា **ឯវមេ សុតំ មយាបិ ឯវំ សុតំ** ខ្ញុំស្តាប់មកហើយយ៉ាងនេះ គឺ សូម្បីខ្ញុំក៏បានឮមកយ៉ាងនេះ ។

ដោយ **ឯវំ** សព្ទ ដែលមានសព្ទជាការហាមសេចក្តីដទៃ ព្រះថេរៈកាលសំដែងនូវការទ្រទ្រង់ចាំរបស់ខ្លួន ដែលគួរដល់ការៈដែលព្រះដ៏មាន-ព្រះភាគទ្រង់សរសើរទុកយ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ អានន្ទជាកំពូលនៃភិក្ខុសាវករបស់តថាគត ដែលជាពហូសូត មានគតិ មានសតិ មានធិតិ ជាពុទ្ធុបដ្ឋាក ដូច្នេះ រមែងឲ្យកើតសេចក្តីប្រាថ្នាចង់ស្តាប់ដល់សត្វទាំងឡាយ ដោយពោលថា ខ្ញុំបានស្តាប់មកហើយនេះ ពាក្យនោះ មិនខ្វះមិនលើស មិនថាដោយអត្ថ ឬដោយព្យញ្ជនៈ បណ្ឌិតគប្បីឃើញយ៉ាងនេះប៉ុណ្ណោះ មិនគប្បីឃើញយ៉ាងដទៃឡើយ ។

## កែបទ មេ

មេ សព្ទ រួមគ្នានៅក្នុងសេចក្តី ៣ យ៉ាង ។ ពិតហើយ មេ សព្ទ

មានសេចក្តីថា មយា (យើង) បានក្នុងប្រយោគជាដើមយ៉ាងនេះថា គា-ថាភិគីតំ មេ អភោជនេយ្យំ (ភោជនដែលបានមកដោយការច្រៀង ដែលយើងមិនគួរបរិភោគ) ។

មានសេចក្តីថា មយ្ហំ ដល់យើង បានក្នុងប្រយោគជាដើមយ៉ាងនេះថា សាធុ មេ ភន្តេ ភគវា សង្ខិត្តេន ធម្មំ ទេសេតុ បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគ មេត្តាទ្រង់សំដែងធម៌ដោយសង្ខេបដល់ខ្ញុំព្រះអង្គផងចុះ ។

មានសេចក្តីថា មម របស់យើង បានក្នុងប្រយោគជាដើមយ៉ាងនេះថា ធម្មទាយាទា មេ ភិក្ខវេ ភវថ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយចូលជាធម្មទាយាទរបស់តថាគតចុះ ។

តែក្នុងទីនេះ មេ ស័ព្ទ រមែងត្រូវក្នុងសេចក្តីទាំងពីរ គឺ មយា សុតំ ដែលខ្ញុំបានស្តាប់មក មម សុតំ ការស្តាប់របស់ខ្ញុំ ។

## កែបទ សុតំ

សុត ស័ព្ទនេះ មានឧបសគ្គ និងមិនមានឧបសគ្គ ផ្សេងគ្នាដោយ

អត្ថច្រើនយ៉ាង ដូចមានអត្ថថា ទៅ ប្រាកដ តម្រេក សន្សំ ខ្វល់ខ្វាយ សំឡេងដែលដឹងដោយសោត: និងដឹងតាមផ្លូវសោតទ្វារជាដើម ។ ពិតហើយ សុត ស័ព្ទនោះ មានអត្ថថា **ទៅ** បានក្នុងប្រយោគជាដើមយ៉ាងនេះថា **សេនាយ បសុតោ** (ទ័ពចេញដំណើរទៅ) ។

មានអត្ថថា **ប្រាកដ** បានក្នុងប្រយោគជាដើមយ៉ាងនេះថា **សុត-ធម្មស្ស បស្សតោ** អ្នកមានធម៌ប្រាកដហើយ ឃើញហើយ ។

មានអត្ថថា **តម្រេក** បានក្នុងប្រយោគជាដើមយ៉ាងនេះថា **អវស្សុតា អវស្សុតស្ស** ភិក្ខុនីមានតម្រេក ត្រេកអរកាលដែលបុរសមានតម្រេកមកស្ទាបអង្អែលកាយ ។

មានអត្ថថា **សន្សំ** បានក្នុងប្រយោគជាដើមយ៉ាងនេះថា **តុម្ហេហិ បុញ្ញំ បសុតំ អនប្បកំ** អ្នកទាំងឡាយសន្សំបុណ្យដ៏ច្រើន ។

មានអត្ថថា **ខ្វល់ខ្វាល** បានក្នុងប្រយោគជាដើមយ៉ាងនេះថា **យេ ឈានបសុតាធីរា** អ្នកប្រាជ្ញពួកណាខ្វល់ខ្វាយក្នុងឈាន ។

មានអត្ថថា **សំឡេងដែលដឹងតាមសោត:** បានក្នុងប្រយោគជាដើម

យ៉ាងនេះថា **ទិដ្ឋំ សុតំ មុតំ** រូបដែលបានឃើញ សំឡេងដែលបានឮ អារម្មណ៍ដែលបានជ្រាប ។

មានអត្ថថា **ដឹងតាមផ្លូវសោតទ្វារ** បានក្នុងប្រយោគជាដើមយ៉ាងនេះថា **សុតធរោ សុតសន្និចយោ** ទ្រទ្រង់សុតៈ សន្សំសុតៈ ។

តែក្នុងទីនេះ ពាក្យថា **សុតៈ** មានអត្ថថា ចូលទៅទ្រទ្រង់ទុក ឬការទ្រទ្រង់ចាំទុកដោយវិញ្ញាណវិថី ដែលមានសោតវិញ្ញាណជាប្រធាន ។ ក្នុងពាក្យនោះ កាលណា **មេ** ស័ព្ទ មានអត្ថថា **មយា** ដែលខ្ញុំ កាលនោះ ក៏ប្រកបសេចក្តីថា ដែលខ្ញុំម្ចាស់បានស្តាប់មកហើយ គឺ ទ្រទ្រង់ចាំទុកហើយ ដោយវិញ្ញាណវិថី ដែលមានសោតវិញ្ញាណជាប្រធាន ។ កាលណា **មេ** ស័ព្ទ មានសេចក្តីថា **មម** របស់ខ្ញុំ កាលនោះ ក៏ប្រកបសេចក្តីថា ការស្តាប់របស់ខ្ញុំ គឺ ការទ្រទ្រង់ចាំទុកដោយវិញ្ញាណវិថី ដែលមានសោតវិញ្ញាណជាប្រធាន ។

បណ្តាពាក្យទាំង ៣ នោះ ដូចពណ៌នាមកនេះ ពាក្យថា **ឯវំ** ជាពាក្យបង្ហាញដល់កិច្ច គឺ នាទីរបស់សោតវិញ្ញាណ ។ ពាក្យថា **មេ** ជា

ពាក្យបង្ហាញដល់បុគ្គលអ្នកប្រកបដោយសោតវិញ្ញាណ ដែលមានសោត-វិញ្ញាណដូចពោលហើយ ។ ពាក្យថា **សុតំ** ជាពាក្យបង្ហាញដល់ការកាន់យកមិនលើសមិនខ្វះ និងមិនវិបរិត ព្រោះបដិសេធភាវ: គឺ ការមិនបានស្តាប់ ។

ន័យម្យ៉ាងទៀត ពាក្យថា **ឯវំ** ជាបទសំដែងដល់ភាវ:នៃចិត្ត មានការគិតនឹងស្តាប់ជាដើម ប្រព្រឹត្តទៅក្នុងអារម្មណ៍ ដោយប្រការផ្សេងៗ ។ ពាក្យថា **មេ** ជាពាក្យសំដែងដល់ខ្លួន ។ ពាក្យថា **សុតំ** ជាពាក្យសំដែងដល់ធម៌ ។

ន័យម្យ៉ាងទៀត ពាក្យថា **ឯវំ** ជាពាក្យបង្ហាញធម៌ដែលគួរប្រាប់ ។ ពាក្យថា **មេ** ជាពាក្យបង្ហាញដល់បុគ្គល ។ ពាក្យថា **សុតំ** ជាពាក្យបង្ហាញកិច្ច គឺ នាទីរបស់បុគ្គល ។

ន័យម្យ៉ាងទៀត ពាក្យថា **ឯវំ** អធិប្បាយដល់ប្រការផ្សេងៗ របស់វិថីចិត្តទាំងឡាយ ជាអាការបញ្ញត្តិ ។ ពាក្យថា **មេ** អធិប្បាយដល់អ្នកធ្វើ ។ ពាក្យថា **សុតំ** អធិប្បាយដល់វិស័យ ។

ន័យម្យ៉ាងទៀត ពាក្យថា **ឯវំ** អធិប្បាយដល់កិច្ចនាទីរបស់បុគ្គល ។ ពាក្យថា **សុតំ** អធិប្បាយដល់កិច្ចនាទីរបស់វិញ្ញាណ ។ ពាក្យថា **មេ** អធិប្បាយដល់បុគ្គលអ្នកប្រកបដោយកិច្ចទាំង ២ ។

ន័យម្យ៉ាងទៀត ពាក្យថា **ឯវំ** សំដែងដល់ការៈ ។ ពាក្យថា **មេ** សំដែងដល់បុគ្គល ។ ពាក្យថា **សុតំ** សំដែងដល់កិច្ចរបស់បុគ្គលនោះ ។

ក្នុងពាក្យទាំងនោះ ពាក្យថា **ឯវំ** និង **មេ** ជាអវិជ្ជមានបញ្ញត្តិ ដោយជាសច្ចិកត្ថបរមត្ថ ។ ពាក្យថា **សុតំ** ជាវិជ្ជមានបញ្ញត្តិ ។

ន័យម្យ៉ាងទៀត ពាក្យថា **ឯវំ** និង **មេ** ឈ្មោះថា ឧបាទាយ-បញ្ញត្តិ ព្រោះពោលអាស្រ័យអារម្មណ៍នោះៗ ។ ពាក្យថា **សុតំ** ឈ្មោះថា ឧបនិធាយបញ្ញត្តិ ព្រោះពោលអាងអារម្មណ៍ មានអារម្មណ៍ដែលបានឃើញហើយជាដើម ។

ក៏ក្នុងពាក្យទាំង ៣ នោះ ព្រះថេរៈសំដែងការមិនវង្វេង ដោយពាក្យថា **ឯវំ** ។ ការមិនប្រឡំក្នុងរឿងដែលស្តាប់មក ដោយពាក្យថា **សុតំ** ។ ម្យ៉ាងទៀត ព្រះថេរៈសំដែងការធ្វើទុកក្នុងចិត្តដោយឧបាយ ដោយពាក្យថា

ឯវំ ព្រោះមិនមានការចាក់ដុះដោយប្រការផ្សេងៗ ចំពោះអ្នកមិនធ្វើទុកក្នុងចិត្តដោយឧបាយត្រូវទំនង ។ សំដែងការមិនរាយមាយដោយពាក្យថា សុតំ ព្រោះមិនមានការស្តាប់ ចំពោះអ្នកមានចិត្តរាយមាយ ។ ពិតហើយ បុគ្គលអ្នកមានចិត្តរាយមាយ សូម្បីលោកនឹងពោលគ្រប់សព្វ យ៉ាងណា ក៏នឹងពោលថា ខ្ញុំមិនបានឮ មេត្តានិយាយម្តងទៀត ។ ក៏ក្នុងប្រការនេះ បុគ្គលនឹងឲ្យសម្រេចការតាំងខ្លួនទុកដោយប្រពៃ និងភាពជាអ្នកធ្វើបុណ្យទុកមកអំពីមុន ក៏ដោយការធ្វើទុកក្នុងចិត្តដោយឧបាយត្រឹមត្រូវ នឹងឲ្យសម្រេចការស្តាប់ធម៌របស់សប្បុរស និងការពឹងពាក់អាស្រ័យសប្បុរស ក៏ព្រោះសេចក្តីមិនរាយមាយ ។ ក៏ព្រះថេរៈសំដែងការដល់ព្រមដោយចក្កធម៌ ២ ប្រការក្រោយរបស់ខ្លួន ដោយអាការស្អាតល្អ ដោយពាក្យថា ឯវំ នេះ ។ សំដែងការដល់ព្រមដោយចក្កធម៌ ២ ខាងដើម ដោយការព្យាយាមស្តាប់ ដោយពាក្យថា សុតំ ។ ម្យ៉ាងទៀត ព្រះថេរៈសំដែងសេចក្តីបរិសុទ្ធនៃអជ្ឈាស្រ័យ និងសេចក្តីបរិសុទ្ធនៃសេចក្តីព្យាយាមនោះ គឺ សំដែងការឈ្លាសវៃក្នុងអធិគម ដោយសេចក្តីបរិសុទ្ធនៃអជ្ឈាស្រ័យ ទាំងសំដែងការ

ឈ្លាសវៃក្នុងបរិយត្តិ ដោយសេចក្ដីបរិសុទ្ធិនៃសេចក្ដីព្យាយាម ។

ម្យ៉ាងទៀត ព្រះថេរៈសំដែងការដល់ព្រមដោយអត្ថប្បដិសម្ភិទា និងបដិភាណប្បដិសម្ភិទារបស់ខ្លួន ដោយពាក្យដែលសំដែងបដិវេធមានប្រការផ្សេងៗ ដោយពាក្យថា **ឯវំ** នេះ ។ សំដែងការដល់ព្រមដោយធម្មប្បដិ-សម្ភិទា និងនិរុត្តិប្បដិសម្ភិទា ដោយពាក្យដែលសំដែងបដិវេធ ដែលផ្សេងដោយប្រការដែលគួរស្ដាប់ដោយពាក្យថា **សុតំ** នេះ ។ ម្យ៉ាងទៀត ព្រះថេរៈកាលពោលពាក្យដែលសំដែងដល់ការធ្វើទុកក្នុងចិត្ត ដោយឲ្យបាយយ៉ាងនេះ ក៏ប្រកាសឲ្យគេដឹងថា ធម៌ទាំងនេះ ខ្ញុំពិចារណាដោយចិត្ត ចាក់ធ្លុះហើយដោយទិដ្ឋិ ដោយពាក្យថា **ឯវំ** ។ កាលពោលពាក្យសំដែងដល់សេចក្ដីព្យាយាមស្ដាប់នេះ ក៏ប្រកាសឲ្យគេដឹងថា ធម៌ដ៏ច្រើន ខ្ញុំបានស្ដាប់មកហើយ ទ្រទ្រង់ចាំហើយ ទន្ទេញរត់មាត់ហើយ ដោយពាក្យថា **សុតំ** ។ កាលសេចក្ដីបរិបូណ៌នៃអត្ថ និងព្យញ្ជនៈ ឲ្យកើតសេចក្ដីអើពើនឹងស្ដាប់ សូម្បីដោយពាក្យទាំង ២ នេះ ។

ម្យ៉ាងទៀត ព្រះអានន្ទមិនតាំងធម៌ដែលព្រះតថាគតទ្រង់ប្រកាសហើយ

ដើម្បីខ្លួន ឲ្យធ្លាក់ចុះនៅក្នុងភូមិនៃអសប្បុរស កាលប្រាថ្នាភាពជាសាវក ទើបឈានចុះកាន់ភូមិរបស់សប្បុរស ដោយពាក្យសូម្បីទាំងអស់ថា **ឯវំ មេ សុតំ** នេះ ។ ម្យ៉ាងទៀត ព្រះថេរៈឈ្មោះថា លើកចិត្តចេញចាកអសទ្ធម្ម តាំងចិត្តទុកក្នុងព្រះសទ្ធម្ម ។ ម្យ៉ាងទៀត កាលសំដែងថា ព្រះតម្រាស់របស់ព្រះមានព្រះភាគអរហន្តសម្មាសម្ពុទ្ធអង្គនោះ ខ្ញុំបានស្តាប់មកហើយទាំងអស់ ឈ្មោះថា ដោះខ្លួន អាងព្រះសាស្តា នៃបទិត្យជាមួយព្រះពុទ្ធតម្រាស់ តាំងបែបផែនធម៌ទុក ។

ម្យ៉ាងទៀត ព្រះថេរៈមិនព្រមទទួលពាក្យថា **ឯវំ មេ សុតំ** ថា ខ្លួនធ្វើឲ្យកើតឡើង កាលបើកបង្ហាញការស្តាប់មកពីមុន ទើបគួរជ្រាបថា លោកឈ្មោះថា ទម្លាយការមិនជឿ (ក្នុងខណៈតែមួយ) ធ្វើឲ្យកើតសទ្ធាសម្បទា (ការដល់ព្រមដោយការជឿ) ក្នុងព្រះសទ្ធម្មនេះ ដល់ពួកទេវតាទាំងឡាយ និងមនុស្សថា ព្រះតម្រាស់នេះ ខ្ញុំទទួលមកអំពីព្រះភ័ក្ត្ររបស់ព្រះមានព្រះភាគអង្គនោះ ទ្រង់ជាអ្នកក្លៀវក្លាដោយចតុវេសារជ្ជញ្ញាណ ទ្រង់ជាអ្នកទ្រទ្រង់ទសពលញ្ញាណ ទ្រង់តាំងនៅក្នុងតំណែងដ៏ខ្ពង់ខ្ពស់ ទ្រង់បន្លឺ

សីហនាទ ទ្រង់ជាកំពូលរបស់សព្វសត្វ ទ្រង់ជាធំក្នុងធម៌ ទ្រង់ជារាជានៃធម៌ អធិបតីនៃធម៌ ទ្រង់មានធម៌ជាទីពឹង ទ្រង់បង្វិលចក្រដ៏ប្រសើរ គឺព្រះសទ្ធម្ម ទ្រង់ជាព្រះសម្មាសម្ពុទ្ធ ត្រាស់ដឹងដោយប្រពៃដោយព្រះអង្គឯងក្នុងបទតម្រាស់នោះ មិនគួរធ្វើសេចក្ដីសង្ស័យក្នុងអត្ថ ឬធម៌ បទ ឬព្យញ្ជនៈនេះឡើយ ។ ក៏ក្នុងសេចក្ដីនេះ មានពាក្យពោលថា ៖-

ព្រះអានន្ទ សាវករបស់ព្រះគោតមសម្ពុទ្ធ កាលពោល
ពាក្យថា ឯវំមេ្ម សុតំ នេះ ឈ្មោះថា ទម្លាយអសទ្ធិយៈ
(ការមិនជឿ) កពូននូវសទ្ធាក្នុងព្រះសាសនា ។

កែអត្ថ ឯកំ និង សមយំ

ពាក្យថា ឯកំ សំដែងការកំណត់ចំនួន ។ ពាក្យថា **សមយំ** សំដែងកាលដែលកំណត់ ។ ពីរបទថា **ឯកំ សមយំ** សំដែងកាលមិនពិតប្រាកដ ។ ក្នុងពាក្យនោះ **សមយ** ស័ព្ទ មានសេចក្ដីថា ព្រមព្រៀង ខណៈ កាល ប្រជុំ ហេតុ លទ្ធិ បានចំពោះ លះ និង ចាក់ធ្លុះ ។

ពិតយ៉ាងនេះ **សមយ** ស័ព្ទនោះ មានសេចក្ដីថា ព្រមព្រៀង បាន

ក្នុងព្រះយោគមានជាដើមយ៉ាងនេះថា **អប្បេវ នាម ស្វេបិ ឧបសង្កមេយ្យាម កាលញ្ច សមយញ្ច ឧបាទាយ** ប្រសិនបើ យើងទាំងឡាយកំណត់កាល និង សេចក្តីព្រមព្រៀង គប្បីចូលទៅរកសូម្បីក្នុងថ្ងៃស្អែកនេះ ។

សេចក្តីថា **ខណៈ** បានក្នុងប្រយោគជាដើមយ៉ាងនេះថា **ឯកោ វ ខោ ភិក្ខវេ ខណោ ច សមយោ ច ព្រហ្មចរិយវាសាយ** ម្នាលភិក្ខុទាំងឡាយ ឱកាស និង **ខណៈ** ដើម្បីការនៅប្រព្រឹត្តព្រហ្មចារ្យ មានតែម្យ៉ាងនេះឯង ។

មានសេចក្តីថា **កាល** បានក្នុងប្រយោគជាដើមថា **ឧណ្ហសមយោ បរិឡាហសមយោ** កាល ក្តៅ កាល ក្រវល់ក្រវាយ ។

មានអត្ថថា **ប្រជុំ** បានក្នុងប្រយោគជាដើមថា **មហាសមយោ បវនស្មិំ** ការប្រជុំធំក្នុងព្រៃធំ ។

មានអត្ថថា **ហេតុ** បានក្នុងប្រយោគជាដើមយ៉ាងនេះថា **សមយោបិ ខោ តេ ភទ្ទាលិ អប្បដិវិទ្ធោ អហោសិ , ភគវា ខោ សាវត្ថិយំ វិហរតិ , សោបិ មំ ជានិស្សតិ ភទ្ទាលិ នាម ភិក្ខុ សត្ថុសាសនេ**

សិក្ខាយ អបរិបូរការីតិ អយម្បិ ខោ តេ ភទ្ទាលិ សមយោ អប្បដិវិទ្ធោ អហោសិ ។ ម្នាលភទ្ទាលិ លោកក៏មិនដឹងសូម្បីដល់ហេតុថា ព្រះមាន-ព្រះភាគប្រថាប់នៅក្នុងក្រុងសាវត្ថី សូម្បីព្រះអង្គក៏នឹងទ្រង់ជ្រាបដល់ខ្លួនយើងថា ភិក្ខុឈ្មោះ ភទ្ទាលិ មិនធ្វើសិក្ខាឲ្យបរិបូណ៌ក្នុងពាក្យទូន្មានរបស់ព្រះសាស្តា ភទ្ទាលិ លោកមិនដឹងដល់ ហេតុ សូម្បីនេះ ។

មានសេចក្តីថា លទ្ធិ បានក្នុងប្រយោគជាដើមយ៉ាងនេះថា តេន ខោ បន សមយេន ឧគ្គហមានោ បរិព្វាជកោ សមណមុណ្ឌិកាបុត្តោ សមយប្បវាទកេ តិន្ទុកាចីរេ ឯកសាលកេ មល្លិកាយ អារាមេ បដិវសតិ ។ សម័យនោះ បរិព្វាជកឈ្មោះ ឧគ្គហមានះ បុត្ររបស់នាងសមណមុណ្ឌិកា អាស្រ័យនៅក្នុងអារាមរបស់ព្រះនាងមល្លិកា ដែលមានសាលាមួយខ្នង មានដើមទម្លាប់ព័ទ្ធជុំវិញ ជាទីបង្រៀន លទ្ធិ ។

មានអត្ថថា បានចំពោះ បានក្នុងប្រយោគជាដើមយ៉ាងនេះថា

ទិដ្ឋេ ធម្មេ ច យោ អត្ថោ យោ ចត្ថោ សម្បរាយិកោ
អត្ថាភិសមយា ធីរោ បណ្ឌិតោតិ បវុច្ចតិ ។

អ្នកមានបញ្ញា លោកហៅថា បណ្ឌិត ព្រោះបានចំពោះ

នូវប្រយោជន៍ក្នុងបច្ចុប្បន្ន និងប្រយោជន៍បរលោក ។

មានអត្ថថា លះ បានក្នុងប្រយោគជាដើមយ៉ាងនេះថា សម្មា មានាភិសមយា អន្តមកាសិ ទុក្ខស្ស ធ្វើទីបំផុតនៃទុក្ខ ព្រោះ លះ មានះបានដោយប្រពៃ ។

មានអត្ថថា ចាក់ដោះ បានក្នុងប្រយោគជាដើមយ៉ាងនេះថា ទុក្ខស្ស បីឡនដ្ឋោ សង្ខតដ្ឋោ សន្តាបដ្ឋោ វិបរិណាមដ្ឋោ អភិសមយដ្ឋោ បៀតបៀន តាក់តែង ដុតកោល ប្រែប្រួល ចាក់ដោះ ទុក្ខ ។

តែក្នុងទីនេះ សមយ សព្ទនោះ មានអត្ថថា កាល ។ ព្រោះហេតុនោះ ព្រះថេរៈទើបសំដែងថា ពាក្យថា ឯកំ សមយំ បានដល់សម័យមួយ បណ្តាសម័យទាំងឡាយ ដែលហៅថា កាល ជាដើមថា ឆ្នាំ រដូវ ខែ កន្លះខែ យប់ ថ្ងៃ ព្រឹក ថ្ងៃ ល្ងាច យាមដើម យាមកណ្តាល យាមខាងចុង និងគ្រា ។

លោកអធិប្បាយថា សម័យរបស់ព្រះដ៏មានព្រះភាគនេះណា ដែល

ហៅថា កាលមានច្រើន ដែលប្រាកដដ៏ក្រៃលែងក្នុងពួកទេវតា និងមនុស្ស ជាដើម យ៉ាងនេះគឺ សម័យស្ដេចចុះកាន់ព្រះគភ៌ សម័យប្រសូតិ សម័យទ្រង់សង្វេគ សម័យស្ដេចចេញបួស សម័យទ្រង់ធ្វើទុក្ករកិរិយា សម័យទ្រង់ឈ្នះមារ សម័យទ្រង់ត្រាស់ដឹង សម័យប្រថាប់នៅជាសុខក្នុងបច្ចុប្បន្ន សម័យទេសនា សម័យបរិនិព្វាន បណ្ដាសម័យទាំងនោះ ព្រះថេរៈសំដែង សម័យមួយ ពោលគឺ **សម័យទេសនា** ។

លោកអធិប្បាយថា ព្រះថេរៈសំដែងថា **ឯកំ សមយំ** សម័យមួយ សំដៅដល់ សម័យណាមួយ គឺ សម័យដែលទ្រង់ធ្វើកិច្ចដោយព្រះករុណា ក្នុងសម័យទ្រង់ធ្វើកិច្ចដោយព្រះញាណ និងព្រះករុណា សម័យទ្រង់បដិ-បត្តិដើម្បីប្រយោជន៍ដល់អ្នកដទៃ ក្នុងសម័យដែលទ្រង់បដិបត្តិដើម្បីប្រយោជន៍ខ្លួន និងប្រយោជន៍អ្នកដទៃ សម័យទ្រង់ពោលធម៌ សម័យទេសនា ក្នុងសម័យទ្រង់ទេសនា និងបដិបត្តិ ។

ក្នុងសេចក្ដីនេះ មានអ្នកជំទាស់ពោលថា ក៏ព្រោះហេតុអ្វី ក្នុងព្រះសូត្រនេះ លោកទើបធ្វើនិទ្ទេសជាទុតិយាវិភត្តិថា **ឯកំ សមយំ** មិនធ្វើដូច

ក្នុងព្រះអភិធម្ម ដែលធ្វើនិទ្ទេសជាសត្តមីវិភត្តិថា **យស្មឹ សមយេ កាមាវចរំ** និងក្នុងសុត្តបទដទៃក្រៅពីអភិធម្មនេះថា **យស្មឹ សមយេ ភិក្ខវេ ភិក្ខុ វិវិច្ចេវ កាមេហិ** និងដូចក្នុងវិន័យ ដែលធ្វើនិទ្ទេសជាតតិយាវិភត្តិថា **តេន សមយេន ពុទ្ធោ ភគវា** ។ សូមពោលបញ្ជាក់ដូច្នេះ ព្រោះក្នុងអភិធម្ម និងព្រះវិន័យ **សមយ** ស័ព្ទ មានអត្ថដូច្នោះ ចំណែកក្នុងព្រះសូត្រនេះ មានអត្ថយ៉ាងដទៃ ។ ពិតណាស់ បណ្ដាបិដកទាំង ៣ នោះ ក្នុងអភិធម្មបិដក **សមយ** ស័ព្ទ មានអត្ថថា អធិករណៈ ក្នុងសុត្តបទដទៃក្រៅពីអភិធម្មនេះ និងមានអត្ថថា កំណត់លក្ខណៈនៃការៈ ។ ពិតហើយ អធិករណៈ ក៏គឺ **សមយ** ស័ព្ទ ដែលមានសេចក្ដីថា **កាល** និងមានសេចក្ដីថា **ប្រជុំ** និងការៈនៃធម៌មានផស្សៈជាដើមនោះ កំណត់បានដោយការៈនៃសម័យ គឺ ខណៈ ការព្រមព្រៀង និងហេតុ នៃធម៌ទាំងឡាយ មានផស្សៈជាដើម ដែលពោលហើយក្នុងអភិធម្មបិដក និងសុត្តបទដទៃនោះ ព្រោះហេតុនោះ លោកទើបធ្វើនិទ្ទេសជាសត្តមីវិភត្តិក្នុងអភិធម្មបិដកនោះ ដើម្បីបញ្ជាក់សេចក្ដីនោះ ។

ចំណែកក្នុងវិន័យបិដក **សមយ** ស័ព្ទ មានសេចក្ដីថា ហេតុ និង មានសេចក្ដីថា ករណៈ ។ ពិតណាស់ សម័យទ្រង់បញ្ញត្តិសិក្ខាបទណា សូម្បីព្រះថេរៈមានព្រះសារីបុត្តជាដើម ដែលដឹងបានដោយលំបាក ដោយសម័យនោះ ដែលជាហេតុ និងជាករណៈ ព្រះមានព្រះភាគកាលទ្រង់បញ្ញត្តិសិក្ខាបទទាំងឡាយ ក៏ទ្រង់សម្លឹងដល់ហេតុនៃការបញ្ញត្តិសិក្ខាបទ ទើបប្រថាប់នៅក្នុងស្ថានទីនោះៗ ព្រោះដូច្នោះ លោកទើបធ្វើនិទ្ទេសជាតតិយាវិភត្តិទុកក្នុងវិន័យបិដកនោះ ដើម្បីបញ្ជាក់សេចក្ដីនោះ ។

ចំណែកក្នុងសូត្រនេះ និងបាឋៈនៃសុត្តន្តបិដក ដែលមានកំណើតយ៉ាងដទៃៗ **សមយ** ស័ព្ទ មានអត្ថថា អច្ចន្តសំយោគ (គឺទុតិយាវិភត្តិដែលប្រែថា រហូត) ។ ពិតហើយ ព្រះមានព្រះភាគទ្រង់សំដែងសូត្រនេះ ឬសូត្រដទៃ រហូតអស់សម័យណា ក៏ប្រថាប់នៅដោយព្រះករុណាវិហាររហូតទៅ គឺ រហូតសម័យនោះ ។ ព្រោះដូច្នោះ **សមយ** ស័ព្ទ ទើបគួរជ្រាបថា លោកធ្វើនិទ្ទេសជាទុតិយាវិភត្តិទុកក្នុងសូត្រនេះ ក៏ដើម្បីបញ្ជាក់សេចក្ដីនោះ ។ ក្នុងសេចក្ដីនេះ មានពាក្យពោលថា ៈ-

តំ តំ អត្ថមបេក្ខិត្វា កុម្មេន ករណេន ច

អញ្ញត្រ សមយោ វុត្តោ ឧបយោគេន សោ ឥធ ។

លោកពិចារណាអត្ថនោះៗ ពោល សមយ ស័ព្ទក្នុងបិដក

ដទៃដោយសត្តមីវិភត្តិ និងដោយតតិយាវិភត្តិ តែក្នុងសុត្ត-

ន្តបិដកនេះ សមយ ស័ព្ទនោះ លោកពោលដោយទុតិ-

យាវិភត្តិ ។

## កែអត្ថ ភគវា

បទថា ភគវា នេះ ជាពាក្យហៅព្រះមានព្រះភាគអង្គនោះ ដែល ទ្រង់វិសេសដោយគុណ ជាកំពូលរបស់សត្វ ជាគ្រូ និងគួរគោរព ដូចដែល លោកពោលទុកថា ៈ-

ភគវាតិ វចនំ សេដ្ឋំ ភគវាតិ វចនមុត្តមំ

គរុ គារវយុត្តោ សោ ភគវា តេន វុច្ចតិ

ពាក្យថា ភគវា ជាពាក្យប្រសើរបំផុត ពាក្យថា ភគវា

ជាពាក្យខ្ពស់បំផុត ព្រះអង្គទ្រង់ជាគ្រូ និងគួរដល់ការ

គោរព ព្រោះហេតុនោះ បណ្ឌិតទើបពោលថា ភគវា ។

សេចក្តីពិត នាម (គឺឈ្មោះ) មាន ៤ គឺ អាវត្ថិក: (ឈ្មោះតាមជំនាន់) លិង្គិក: (ឈ្មោះតាមភេទ) នេមិត្តក: (ឈ្មោះតាមគុណ) អធិច្ច-សមុប្បន្ន: (ឈ្មោះតាំងតៗ) ។ ឈ្មោះថា អធិច្ចសមុប្បន្ននាម លោកអធិប្បាយថា ជានាមដែលតាំងតាមសេចក្តីពេញចិត្ត ។ ក្នុងនាមទាំង ៤ នោះ នាមជាដើមយ៉ាងនេះថា កូនគោ គោហ្វឹកហាត់ គោការង្វារ ឈ្មោះថា **អាវត្ថិកនាម** ។ នាមជាដើមយ៉ាងនេះថា អ្នកមានវិជ្ជា ៣ អ្នកមានអភិញ្ញា ៦ ឈ្មោះថា **នេមិត្តកនាម** ។ នាមជាដើមយ៉ាងនេះថា អ្នកចម្រើនដោយសិរី អ្នកចម្រើនដោយទ្រព្យ ដែលប្រព្រឹត្តទៅមិនសម្លឹងដល់អត្ថរបស់ពាក្យ ឈ្មោះថា **អធិច្ចសមុប្បន្ននាម** ។ ឯព្រះនាមថា **ភគវា** នេះ ជា**នេមិត្តកនាម** ដោយព្រះគុណ មិនមែនព្រះនាងមហាមាយាពុទ្ធមាតាដាក់ឲ្យ មិនមែនព្រះបាទសុទ្ធោទនមហារាជ ពុទ្ធបិតាដាក់ឲ្យ មិនមែនជនជាព្រះញាតិ ៨៤.០០០ អង្គដាក់ឲ្យ មិនមែនទេវតា ពិសេសមានស្តេចសក្ក: និងស្តេចសន្តុសិតជាដើមដាក់ឲ្យ ដូចព្រះសារីបុត្រពោលទុកថា ព្រះនាមថា

ភគវា នេះ ព្រះពុទ្ធមាតាមិនបានដាក់ឲ្យ ។បេ។ ព្រះនាម គឺ ភគវា ជា សច្ឆិកាបញ្ញត្តិ ។

ដើម្បីប្រកាសគុណទាំងឡាយ ដែលជាគុណនេមិត្តកនាម ព្រះសង្គីតិកាចារ្យទាំងឡាយពោលគាថានេះថា ៖-

ភគី ភជី ភាគី វិភត្តវា ឥតិ
អកាសិ ភគ្គន្តិ គរូតិ ភាគ្យវា
ពហូហិ ញាយេហិ សុភាវិតត្តនោ
ភវន្តគោ សោ ភគវាតិ វុច្ចតិ

ព្រះមានព្រះភាគអង្គនោះ ទ្រង់ព្រះនាមថា ភគវា ព្រោះ ទ្រង់ជាអ្នកមាន ភគៈ គឺ ជោគ ព្រោះទ្រង់ជាអ្នកសេព (ទីស្ងាត់) ព្រោះទ្រង់មានភាគៈ (ចំណែកដែលគួរបាន ទទួលបច្ចុប្បច្ច័យ ឬមានចំណែកនៃធម៌) ព្រោះទ្រង់ជា អ្នកចែកធម៌ ព្រោះទ្រង់បានធ្វើការកាច់បំបាក់បាបធម៌ ព្រោះទ្រង់ជាគ្រូ ព្រោះទ្រង់មានភាគ្យៈ គឺ បុណ្យ

ព្រោះទ្រង់អប់រំព្រះអង្គល្អហើយ ដោយញៀយធម៌ដ៏

ច្រើន ព្រោះជាអ្នកដល់ទីបំផុតនៃភព ។

ក៏ភាពនៃគុណ ពាក្យថា ភគវា នោះ គប្បីឃើញតាមន័យ ដែល

ពោលទុកហើយក្នុងនិទ្ទេសជាដើមយ៉ាងនេះឯង ។

មួយទៀត បរិយាយដទៃទៀត មានដូច្នេះ

ភាគ្យវា ភគ្គវា យុត្តោ ភគេហិ ច វិភត្តវា

ភត្តវា វន្តគមនោ ភវេសុ ភគវា តតោ ។

ព្រះអង្គទ្រង់មានបុណ្យ ទ្រង់កាច់បំបាក់កិលេស ទ្រង់ប្រកប

ដោយភគធម៌ ទ្រង់ចែកនូវធម៌ ទ្រង់សេពធម៌ ទ្រង់ខ្ជាក់ចេញ

កិលេសជាហេតុនាំទៅកាន់ភពទាំងឡាយបានហើយ ព្រោះ

ដូច្នោះ ទើបទ្រង់ព្រះនាមថា ភគវា ។

ក្នុងពាក្យទាំងនោះ គប្បីជ្រាបថា លោកកាន់យកលក្ខណៈនៃនិរុត្តិ-

សាស្ត្រយ៉ាងនេះថា ចុះអក្សរថ្មី ផ្លាស់អក្សរ ជាដើម ឬយកលក្ខណៈការ

រួមចូលក្នុងជុតសព្ទមាន បិសោទរ សព្ទ ជាដើម តាមន័យនៃសព្ទសាស្ត្រ

កាលគួរនឹងហៅថា *ភាគ្យវា* ព្រោះព្រះអង្គមានភាគ្យ: គឺ បុណ្យបារមី មាន ទាន និងសីលជាដើមដ៏ប្រសើរ ដែលឲ្យកើតសេចក្ដីសុខទាំងលោកិយ: និង លោកុត្តរ: ក៏ហៅថា *ភគវា* ។

ម្យ៉ាងទៀត ព្រោះហេតុដែលព្រះអង្គទ្រង់កាច់បំបាក់នូវឫសគល់នៃ កិលេសដែលធ្វើសេចក្ដីខ្វល់ខ្វាយក្ដៅក្រហាយរាប់សែនប្រភេទ គឺ ប្រភេទ លោភ: ទោស: មោហ: ប្រភេទវិបរិតមនសិការ ប្រភេទអហិរិក: អនោ- ត្តប្ប: ប្រភេទកោធ: ឧបនាហ: ប្រភេទមក្ខ: បលាស: ប្រភេទឥស្សា មច្ឆរិយ: ប្រភេទមាយា សាឋេយ្យ: ប្រភេទថម្ភ: សារម្ភ: ប្រភេទមានះ អតិមានះ ប្រភេទមទ: បមាទ: ប្រភេទតណ្ហា អវិជ្ជា , ប្រភេទអកុសល មូល ៣ ទុច្ចរិត ៣ សង្កិលេស ៣ មល: ៣ វិសម: សញ្ញា ៣ វិតក្ក: ៣ បបញ្ចធម៌ ៣ , ប្រភេទវិបរិយេស: ៤ អាសវ: ៤ គន្ថ: ៤ ឱឃ: ៤ យោគ: ៤ អគតិ ៤ តណ្ហុប្បាទ: ៤ , ប្រភេទចេតោខិល: ៥ វិនិ- ពន្ធ: ៥ នីវរណ: ៥ អភិនន្ទន: ៥ , ប្រភេទវិវាទមូល ៦ តណ្ហាកាយ: ៦ , ប្រភេទអនុស័យ ៧ ប្រភេទមិច្ឆត្ត: ៨ ប្រភេទតណ្ហាមូលក: ៩

ប្រភេទអកុសលកម្មបថ ១០ ប្រភេទទិដ្ឋិគតៈ ៦២ ប្រភេទតណ្ហាវិចរិត ១០៨ ឬពោលដោយសង្ខេប គឺ មារ ៥ គឺ កិលេសមារ ខន្ធមារ អភិសង្ខារ-មារ មច្ចុមារ និងទេវបុត្តមារ ដូច្នោះ កាលនឹងហៅថា ភគ្គវា ក៏ហៅថា ភគវា ព្រោះទ្រង់កាច់បំបាក់ឬសគល់អន្តរាយនោះចេញបាន ។ ក្នុងសេចក្តីនេះ លោកពោលទុកថា ៖-

ភគ្គរាគោ ភគ្គទោសោ ភគ្គមោហោ អនាសវោ
ភគ្គាស្ស បាបកា ធម្មា ភគវា តេន វុច្ចតិ ។

ទ្រង់កាច់បំបាក់រាគៈ កាច់បំបាក់ទោសៈ កាច់បំបាក់មោហៈ
មិនមានអាសវៈ ទ្រង់កាច់បំបាក់បាបធម៌បានហើយ ព្រោះ
ហេតុនោះ លោកទើបហៅថា ភគវា ។

ក៏ឯ ការដល់ព្រមនៃព្រះរូបកាយរបស់ព្រះអង្គដែលទ្រទ្រង់ទុកនៅព្រះបុញ្ញលក្ខណៈរាប់រយ ដែលលោកសំដែងដោយភាពដែលទ្រង់មានភាគ្យៈ គឺ បុណ្យ ការដល់ព្រមនៃព្រះធម្មកាយ ដែលទ្រង់សំដែងដោយភាពដែលទ្រង់កាច់បំបាក់ទោសៈបានហើយ ។ ភាពជាអ្នកដែលមនុស្សលោក និង

មនុស្សលោក និងអ្នកជិតខាងរាប់អានក្តី ភាពជាអ្នកដែលគ្រហស្ថ និង បព្វជិតទាំងឡាយទៅមករកក្តី ។ ភាពជាអ្នកអាចជួយកម្ចាត់ទុក្ខកាយ និងទុក្ខចិត្តដល់អ្នកទៅមករកក្តី ភាពជាអ្នកធ្វើឧបការៈដល់គេ ដោយអា-មិសទាន និងធម្មទានក្តី ។ ភាពជាអ្នកអាចក្នុងការប្រកបទុកដោយលោ-កិយៈ និងលោកុត្តរៈក្តី គឺ លោកសំដែងដោយគុណទាំងពីរយ៉ាងនោះ ។

មួយទៀត ព្រោះហេតុដែល ភគ ស័ព្ទ ក្នុងលោក ប្រព្រឹត្តទៅក្នុងធម៌ ៦ គឺ ឥស្សរិយៈ ធម្មៈ សិរិ កាមៈ បយត្តៈ ក៏ព្រះមានព្រះភាគអង្គនោះ ទ្រង់មានឥស្សរិយៈ (ភាពជាធំ) ក្នុងចិត្តរបស់ព្រះអង្គឯងដ៏ប្រសើរ ឬទ្រង់មានឥស្សរិយៈបរិបូណ៌ដោយអាការគ្រប់យ៉ាង ដែលសម្មតិថា ជាលោកិយៈ មានអណិមា (ធ្វើខ្លួនឲ្យតូច) លឃិមា (ធ្វើខ្លួនឲ្យស្រាល) ទ្រង់មានលោកុត្តរធម៌ក៏ដូចគ្នា ទ្រង់មានយសបរិសុទ្ធក្រៃលែង ដែលទ្រង់បានមកដោយព្រះគុណតាមពិតទូទៅក្នុងលោកទាំងបី ទ្រង់មានព្រះសិរីស្រស់ស្អាតទូទាំងព្រះសរពាង្គកាយ បរិបូណ៌ដោយអាការគ្រប់យ៉ាង ទ្រង់អាចធ្វើឲ្យកើតសេចក្តីរីករាយទាំងផ្លូវភ្នែក ទាំងផ្លូវចិត្ត ដល់អ្នកដែលខ្វល់ខ្វាយ

បាននូវសេចក្តីរីករាយក្នុងព្រះរូបព្រះគោម ទ្រង់មានព្រះកាមៈ ដែលសំដៅ ដល់សេចក្តីសម្រេចនៃប្រយោជន៍ ដែលទ្រង់ប្រាថ្នា ព្រោះប្រយោជន៍ណាៗ ដែលទ្រង់បំណងហើយ ប្រាថ្នាហើយ នឹងជាប្រយោជន៍ខ្លួនក្តី ប្រយោជន៍ អ្នកដទៃក្តី ប្រយោជន៍នោះៗ ក៏សម្រេចតាមប្រាថ្នាទាំងអស់នោះឯង និង ទ្រង់មានព្រះបយត្តៈ ពោលគឺ សម្មាវាយាមៈ ដែលជាហេតុនៃគ្រូរបស់ លោកទាំងពួង ដូច្នោះ លោកទើបហៅថា **ភគវា** ដោយអត្ថយ៉ាងនេះថា **ទ្រង់មានភគធម៌** ព្រោះទ្រង់ប្រកបដោយភគធម៌នោះឯង ។

## កែបទ វិភត្តវា

ម្យ៉ាងទៀត ព្រោះហេតុដែលព្រះមានព្រះភាគទ្រង់ជាអ្នកចែកធម៌ លោកអធិប្បាយថា ទ្រង់ចែក បែងចែក បើកបង្ហាញ សំដែង នូវធម៌ ទាំងពួងដោយប្រភេទ មានប្រភេទកុសលជាដើម ឬនូវធម៌ មានកុសលធម៌ ជាដើម ដោយប្រភេទ មានខន្ធ អាយតនៈ ធាតុ សច្ចៈ ឥន្ទ្រិយ៍ និង បដិច្ចសមុប្បាទជាដើម ឬនូវទុក្ខអរិយសច្ចៈ ដោយអត្ថ គឺ បីឡូនៈ (បៀត បៀន) សង្ខតៈ (ដែលបច្ច័យតាក់តែង) សន្តាបៈ (ដុតរោល) វិបរិណាមៈ

(ប្រែប្រួល) ឬនូវសមុទយអរិយសច្ច: ដោយអត្ថ គឺ អាយូហន: (ប្រមូលទុក្ខមក) និទាន: (ហេតុនៃទុក្ខ) សំយោគ: (ចងទុក្ខទុក) បលិពោធ: (រាំងមិនឲ្យដល់មគ្គ) នូវនិរោធអរិយសច្ច: ដោយអត្ថ គឺ និស្សរណ: (ចេញចាកទុក្ខ) វិវេក: (ស្ងប់ចាកទុក្ខ) អសង្ខត: (ដែលបច្ច័យតាក់តែងមិនបាន) អមត: (ជាសភាពមិនស្លាប់) នូវមគ្គអរិយសច្ច: ដោយអត្ថ គឺ និយ្យានិក: (នាំចេញចាកទុក្ខ) ហេតុ (ហេតុនៃនិរោធ) ទស្សន: (ឃើញព្រះនិព្វាន) អធិបតេយ្យ (ធំក្នុងការឃើញព្រះនិព្វាន) ដូច្នោះ កាលគួរនឹងហៅ **វិភត្តវា** តែក៏ហៅថា **ភគវា** ។

## កែបទ ភត្តវា

ម្យ៉ាងទៀត ព្រោះព្រះមានព្រះភាគអង្គនោះ ទ្រង់គប់ ទ្រង់សេព ទ្រង់ធ្វើឲ្យច្រើន នូវធម៌ដែលជាទិព្វវិហារ ព្រហ្មវិហារ និងអរិយវិហារ នូវកាយវិវេក ចិត្តវិវេក និងឧបធិវិវេក នូវសុញ្ញតវិមោក្ខ អប្បណិហិតវិមោក្ខ និងអនិមិត្តវិមោក្ខ និងនូវឧត្តរិមនុស្សធម៌ទាំងជាលោកិយ: និងលោកុត្តរៈដទៃៗ ដូច្នោះ កាលគួរនឹងហៅថា **ភត្តវា** តែក៏ហៅថា **ភគវា** ។

## តៃបទ ភវេសុ វន្តគមន

មួយទៀត ព្រោះហេតុនៃការទៅ ពោលគឺ តណ្ហាក្នុងភពទាំង ៣ ដែលព្រះអង្គទ្រង់ខ្ជាក់ចេញហើយ ដូច្នោះ កាលគួរនឹងហៅថា **ភវេសុ វន្តគមន** តែលោកយក **ភ** អក្សរពី **ភវ** ស័ព្ទ , **គ** អក្សរពី **គមន** ស័ព្ទ និង **វ** អក្សរពី **វន្ត** ស័ព្ទ ហើយធ្វើជាទីឃៈ (សំឡេងវែង) ហៅថា **ភគវា** ដូចក្នុងផ្លូវលោក កាលនឹងហៅពេញៗ ថា **មេហនស្ស ខស្ស មាលា** តែអ្នកប្រាជ្ញ លោក (កាន់យក **មេ** ពី **មេហនស្ស** , **ខ** ពី **ខស្ស** , **លា** ពី **មាលា**) ក៏ហៅថា **មេខលា** ដូច្នោះឯង ។

ក៏ព្រះអានន្ទត្ថេរៈកាលសំដែងធម៌តាមដែលបានស្តាប់មក រៀនមក ទើបប្រកាសព្រះសរីរធម៌ (តួធម៌) របស់ព្រះមានព្រះភាគឲ្យប្រច័ក្ស ដោយពាក្យថា **ឯវំ មេ សុតំ** ក្នុងព្រះសូត្រនេះ ដោយពាក្យត្រឹមប៉ុណ្ណោះ ព្រោះហេតុនោះ ព្រះថេរៈទើបលួងលោមជនអ្នកមានចិត្តរាយមាយ ព្រោះមិនជួបព្រះមានព្រះភាគថា បាវចនៈ (ធម៌វិន័យ) នេះ ឈ្មោះថា មានសាស្តាកន្លងក៏មិនមែន ធម៌វិន័យនេះ ជាសាស្តារបស់លោកទាំងឡាយ ។

ដោយពាក្យថា **ឯកំ សមយំ ភគវា** ព្រះថេរៈកាលសំដែងសេចក្តីដែលព្រះមានព្រះភាគមិនមាននៅក្នុងសម័យនោះ ឈ្មោះថា សំដែងការបរិនិព្វាននៃព្រះរូបកាយ ។ ដោយពាក្យនោះ ព្រះថេរៈញ៉ាំងជនអ្នកស្រវឹងព្រោះស្រវឹងក្នុងជីវិតឲ្យតក់ស្លុត ហើយញ៉ាំងឧស្សាហៈក្នុងព្រះសទ្ធម្មឲ្យកើតដល់ជននោះថា ព្រះមានព្រះភាគអង្គនោះ ទ្រង់សំដែងអរិយសច្ចនេះ យ៉ាងនោះ ទ្រង់ជាទសពល មានព្រះកាយដូចជាពេជ្រ ក៏ស្តេចបរិនិព្វាន ក្នុងសេចក្តីនោះ បុគ្គលដទៃណាហ្ន៎ និងគប្បីឲ្យកើតសេចក្តីសង្ឃឹមក្នុងជីវិតបាន ។

ក៏ព្រះថេរៈកាលពោលថា **ឯវំ** ឈ្មោះថា សំដែងទេសនាសម្បត្តិ (ការដល់ព្រមនៃទេសនា) កាលពោលពាក្យថា **មេ សុតំ** ឈ្មោះថា សំដែងសាវកសម្បត្តិ (ការដល់ព្រមនៃសាវក) កាលពោលពាក្យថា **ឯកំ សមយំ** ឈ្មោះថា សំដែងកាលសម្បត្តិ (ការដល់ព្រមនៃកាល) កាលពោលពាក្យថា **ភគវា** ឈ្មោះថា ទេសកសម្បត្តិ (ការដល់ព្រមនៃអ្នកសំដែង) ។

## កែបទ សាវត្ថិយំ វិហរតិ

ពាក្យថា **សាវត្ថី** (ក្រុងសាវត្ថី) ក្នុងបទថា **សាវត្ថិយំ វិហរតិ** (ប្រថាប់នៅក្នុងក្រុងសាវត្ថី) នេះ បានដល់ នគរដែលជាស្ថានទីនៅប្រចាំរបស់ឥសីឈ្មោះថា សាវត្ថៈ ដូចពាក្យថា **កាកន្ទី មាកន្ទី** ដូច្នោះ ដូច្នោះ លោកទើបហៅថា សាវត្ថី ជាស័ព្ទឥត្ថីលិង្គ អ្នកប្រាជ្ញផ្នែកអក្សរសាស្ត្រពោលយ៉ាងនេះ ចំណែកព្រះអដ្ឋកថាចារ្យទាំងឡាយពោលថា "គ្រឿងឧបភោគបរិភោគសម្រាប់មនុស្ស មានគ្រប់យ៉ាងក្នុងនគរនោះ ព្រោះហេតុនោះ នគរនោះទើបឈ្មោះថា សាវត្ថី ។ តែក្នុងការប្រកបស័ព្ទ កាលត្រូវសួរថា មានវត្ថុអ្វី ទើបអាស្រ័យពាក្យថា មានគ្រប់យ៉ាង ឆ្លើយថា សាវត្ថី (មានរបស់គ្រប់យ៉ាង) ។

គ្រឿងឧបករណ៍គ្រប់យ៉ាង មានព្រមក្នុងក្រុងសាវត្ថី
គ្រប់កាល ព្រោះដូច្នោះ សំដៅដល់របស់គ្រប់យ៉ាង ទើប
ហៅថា សាវត្ថី ។

រាជធានីនៃដែនកោសល គួររីករាយ គួរត្រេកអរ គួរ
ពេញចិត្ត មិនវៀរចាកសំឡេងទាំង ១០ ដល់ព្រមដោយ

បាយទឹក ។

ក្រុងសាវត្ថីរាជធានី ដល់នូវសេចក្តីចម្រើនបរិបូណ៌
ស្តុកស្តម្ភ រុងរឿង គួររីករាយចិត្ត ដូចក្រុងអាឡកមន្ទា
ទេពធានីរបស់ពួកទេវតា ដូច្នេះ ។

តស្សំ សាវត្ថិយំ (ជិតក្រុងសាវត្ថីនោះ) ពាក្យនេះ ជាសត្តមីវិភត្តិចុះក្នុងអត្ថថា ជិត ។

ពាក្យថា **វិហរតិ** (នៅ) នេះ ជាពាក្យសំដែងការដល់ព្រមដោយវិហារ (ការនៅ) បណ្តាឥរិយាបថវិហារ ទិព្វវិហារ ព្រហ្មវិហារ និងអរិយវិហារ បែបណាមួយ ដោយមិនប្លែកគ្នា តែក្នុងព្រះសូត្រនេះ សំដែងការប្រកបព្រមដោយឥរិយាបថវិហារ ក្នុងបណ្តាឥរិយាបថផ្សេងៗ ដោយការឈរ ដើរ អង្គុយ ដេក ឥរិយាបថណាមួយ ។ ព្រោះហេតុនោះ ព្រះមានព្រះភាគប្រថាប់ឈរក្តី ទ្រង់យាងក្តី ប្រថាប់អង្គុយក្តី ផ្ទំក្តី ក៏គប្បីជ្រាបថា **វិហរតិ** (នៅ) នោះឯង ។ ពិតហើយ ព្រះមានព្រះភាគអង្គនោះទ្រង់កម្ចាត់សេចក្តីលំបាកនៃឥរិយាបថមួយដោយឥរិយាបថមួយទៀត (ប្តូរ

ឥរិយាបថ) ត្រង់បរិហារអត្តភាពឲ្យប្រព្រឹត្តទៅមិនលំបាក ។ ព្រោះដូច្នោះទើបហៅថា **វិហរតិ** (ប្រថាប់នៅ) ។

## កែបទ ជេតវនេ

គប្បីជ្រាបវិនិច្ឆ័យក្នុងបទថា **ជេតវនេ** នេះ ដូច្នេះ ។ ព្រះរាជកុមារឈ្មោះថា **ជេតៈ** ព្រោះឈ្នះជនអ្នកជាសត្រូវរបស់ព្រះអង្គ ឬថាឈ្មោះថា **ជេតៈ** ព្រោះប្រសូតិកាលព្រះរាជាទ្រង់ឈ្នះជនជាសត្រូវរបស់ព្រះអង្គ ឬថា ឈ្មោះថា **ជេតៈ** សូម្បីព្រោះព្រះរាជាទ្រង់ដាក់ព្រះនាមយ៉ាងនេះដល់ព្រះរាជកុមារ ព្រោះមានព្រះរាជបំណងឲ្យជាមង្គល ។ ដែលឈ្មោះថា **វនៈ** ព្រោះឲ្យគប់រក អធិប្បាយថា ធ្វើឲ្យកើតភក្តីភាពដល់ខ្លួន ព្រោះការដល់ព្រមនៃខ្លួន គឺ ឲ្យកើតសេចក្តីស្រឡាញ់ដល់ខ្លួន ។ ន័យម្យ៉ាងទៀតឈ្មោះថា **វនៈ** ព្រោះហៅរក អធិប្បាយថា ប្រៀបដូចជាសូមអង្វរសត្វទាំងឡាយថា អញ្ជើញមកប្រើប្រាស់យើងចុះ ដោយសំឡេងស្រែកហៅនៃវិហគៈ មានសត្វតាវ៉ៅជាដើម ដែលស្រវឹងក្នុងក្លិនផ្កាឈើច្រើនពណ៌ និងមានដើម មែក បន្លៀប ផ្កាឈើ ផ្លែឈើ ស្លឹកខ្ចី ស្លឹកចាស់ សប្បាយ

ដោយខ្យល់បក់មករំភើយៗ ។ វនៈរបស់ជេតរាជកុមារ ឈ្មោះថា **ជេតវន** ។ ពិតណាស់ **ជេតវន** នោះ ដែលព្រះរាជកុមារព្រះនាមថា **ជេតៈ** ដាំដុះរក្សាទុក ។ ជេតរាជកុមារនោះ ជាម្ចាស់របស់ជេតវននោះ ព្រោះដូច្នោះទើបហៅថា **ជេតវន** ។ ក្នុងព្រះជេតវននោះ ។

## កែអត្ថបទ អនាថបិណ្ឌិកស្ស អារាមេ

គប្បីជ្រាបវិនិច្ឆ័យក្នុងបទថា **អនាថបិណ្ឌិកស្ស អារាមេ** នេះ ដូច្នេះ គហបតីនោះ ឈ្មោះសុទត្តៈ ដោយមាតាបិតាដាក់ឈ្មោះឲ្យ ម្យ៉ាងទៀត លោកបានឲ្យដុំបាយជាទានដល់មនុស្សអនាថាជាប្រចាំ ព្រោះលោកជាអ្នកប្រាសចាកមន្ទិល គឺ សេចក្ដីកំណាញ់ និងជាអ្នកដល់ព្រមដោយគុណ មានករុណាជាដើម ហេតុជាអ្នកស្ដុកស្ដម្ភដោយសម្បត្តិដែលគួរប្រាថ្នាគ្រប់យ៉ាង ព្រោះហេតុនោះ លោកទើបបានទទួលនាមថា **អនាថបិណ្ឌិកៈ** ។ ប្រទេសដែលឈ្មោះថា **អារាម** ព្រោះជាកន្លែងដែលសត្វទាំងឡាយ ឬដោយចំពោះក្រៃលែងដោយបព្វជិតទាំងឡាយ នាំគ្នាមកអភិរម្យ អធិប្បាយថា បព្វជិតទាំងឡាយនាំគ្នាមកអំពីទីនោះៗ ត្រេកអរអភិរម្យហើយ ដោយមិនទើ្បយ-

ណាយ ព្រោះជេតវ័ននោះ ស្រស់ស្អាតដោយផ្កាឈើ ផ្លែឈើ ស្លឹកឈើ ទ្វីជាដើម និងព្រោះដល់ព្រមដោយអង្គរបស់សេនាសនៈ ៥ ប្រការ មិនឆ្ងាយពេក មិនជិតពេកជាដើម ។ ម្យ៉ាងទៀត ឈ្មោះថា អារាម ព្រោះកាលសត្វ និងបព្វជិតដែលទៅក្នុងទីនោះៗ (ត្រឡប់) មកទីនៅរបស់ខ្លួនហើយត្រេកអរ ព្រោះសម្បត្តិដូចពោលមកហើយ ។ ពិតហើយ អារាមនោះ ដែលអនាថបិណ្ឌិកគហបតី ទិញអំពីព្រះហត្ថរបស់ព្រះរាជកុមារព្រះនាមថា ជេតៈ ដោយក្រាលប្រាក់ ១៨ កោដិ ឲ្យសាងសេនាសនៈជាប្រាក់ ១៨ កោដិ ហើយឲ្យធ្លងវិហារជាប្រាក់ ១៨ កោដិ បង្គ្រានថ្វាយព្រះភិក្ខុ-សង្ឃ មានព្រះពុទ្ធជាប្រធាន ដោយបរិច្ចាគប្រាក់ ៥៤ កោដិ យ៉ាងនេះ ព្រោះដូច្នោះ ទើបគេហៅថា ***អារាមរបស់អនាថបិណ្ឌិកៈ*** ។ ក្នុងអារាមរបស់អនាថបិណ្ឌិកៈនោះ ។

ក្នុងបទទាំងនោះ បទថា ***ជេតវនេ (ជេតវ័ន)*** បញ្ជាក់ដល់ម្ចាស់ដើម ។ បទថា ***អនាថបិណ្ឌិកស្ស អារាមេ (អារាមរបស់អនាថបិណ្ឌិកៈ)*** បញ្ជាក់ដល់ម្ចាស់ក្រោយ ។ មានពាក្យជំទាស់ថា ក្នុងការបញ្ជាក់ដល់ព្រះ

ជេតវ័ន និងអារាមទាំងនោះ មានប្រយោជន៍អ្វី ។ សូមពន្យល់ដូច្នេះ ។ ពោលដោយអធិការមុន ប្រយោជន៍ គឺ ជាការកំណត់ (ធ្វើយ) ពាក្យសួរ ដែលថា ត្រាស់ទុកទីណា មព្រាំងជាការប្រកប (បបួល) អ្នកដែលត្រូវការ បុណ្យដទៃៗ ទុក ក្នុងការដល់ (កាន់យក) បែបណាមួយ ។ ពិតណាស់ ក្នុងប្រយោជន៍ ២ យ៉ាងនោះ ទ្រព្យ ១៨ កោដិ ដែលបានពីការលក់ដី ក្នុងការកសាងប្រាសាទ ដែលមានខ្លោងទ្វារ និងទ្វារ និងដើមឈើទាំងឡាយ ដែលមានតំលៃច្រើនកោដិ ជាការបរិច្ចាគរបស់ព្រះជេតរាជកុមារ ។ ទ្រព្យ ៥៤ កោដិ ជាការបរិច្ចាគរបស់អនាថបិណ្ឌិកគហបតី ។ ដោយការបញ្ជាក់ ដល់ព្រះជេតវ័ន និងអារាមនោះ ព្រះអានន្ទកាលសំដែងថា អ្នកត្រូវការ បុណ្យ រមែងធ្វើបុណ្យទាំងឡាយយ៉ាងនេះ ក៏រមែងប្រកប (បបួល) អ្នក ត្រូវការបុណ្យដទៃៗ ទុកក្នុងការកាន់យកជាបែបផែនដោយប្រការណា ។ ការប្រកប (បបួល) អ្នកត្រូវការបុណ្យទុកក្នុងការកាន់យកបែបផែន ក៏គប្បី ជ្រាបថា ជាប្រយោជន៍ក្នុងសេចក្តីនេះ ដោយប្រការដូច្នោះ ។

ក្នុងសេចក្តីនេះ អាចារ្យពួកខ្លះពោលថា "ប្រសិនបើ ព្រះមានព្រះ-

ភាគ ប្រថាប់នៅក្នុងក្រុងសាវត្ថីមុន ព្រះអានន្ទក៏មិនគួរពោលថា ក្នុងវត្ត ជេតពន អារាមរបស់អនាថបិណ្ឌិកៈ តែបើប្រថាប់នៅក្នុងវត្តជេតពននោះ ក៏មិនគួរពោលថា ជិតក្រុងសាវត្ថី ។ ព្រោះថា ព្រះមានព្រះភាគ មិនអាច ប្រថាប់នៅក្នុងទី ២ កន្លែង ក្នុងវេលាតែមួយបាន" ។ សូមប្រាប់ដូច្នេះ ខ្ញុំ ពោលមកហើយមិនមែនឬថា "បទថា **សាវត្ថិយំ** ជាសត្តមីវិភត្តិចុះក្នុងអត្ថ ថា ជិត" ព្រោះថា ប្រៀបដូចហ្វូងគោដើរចូលទៅជិតស្ទឹងគង្គា និងយមុនា ជាដើម គេក៏ហៅថា ដើរទៅជិតស្ទឹងគង្គា ដើរទៅជិតស្ទឹងយមុនា យ៉ាង ណា ព្រះមានព្រះភាគកាលប្រថាប់នៅក្នុងវត្តជេតពន អារាមរបស់អនាថ-បិណ្ឌិកៈ ជិតក្រុងសាវត្ថី ក៏គប្បីជ្រាបថា គេក៏ពោលថា ព្រះមានព្រះភាគ ប្រថាប់នៅក្នុងវត្តជេតពន អារាមរបស់អនាថបិណ្ឌិកៈ ជិតក្រុងសាវត្ថី ដូច្នេះ សូម្បីក្នុងព្រះសូត្រនេះ ក៏ដូច្នោះ ។ ពិតណាស់ បទថា **សាវត្ថី** របស់ ព្រះថេរៈ ក៏ដើម្បីសំដែងគោចរគ្រាម ។ ពាក្យដ៏សេស ក៏ដើម្បីសំដែង ទីនៅប្រថាំដែលសមគួរដល់បព្វជិត ។

ក្នុងពាក្យទាំងពីរនោះ ព្រះថេរៈ (ព្រះអានន្ទ) សំដែងការអនុគ្រោះ

គ្រហស្ថរបស់ព្រះមានព្រះភាគ ដោយការបញ្ជាក់ដល់ក្រុងសាវត្ថី សំដែងការអនុគ្រោះបព្វជិត ដោយការបញ្ជាក់វត្តជេតពនជាដើម ។ ន័យម្យ៉ាងទៀត សំដែងការវៀរអត្តកិលមថានុយោគ ព្រោះកាន់យកបច្ច័យ ដោយពាក្យខាងដើម សំដែងឧបាយវៀរចាកកាមសុខល្ហិកានុយោគ ព្រោះលះវត្ថុកាម ដោយពាក្យខាងក្រោយ ។ មួយទៀត សំដែងសេចក្តីព្យាយាមក្នុងទេសនា ដោយពាក្យដើម សំដែងការបង្អោនទៅក្នុងវិវេកដោយខាងក្រោយ ។ សំដែងការចូលទៅដោយករុណា ដោយពាក្យដើម និងសំដែងការចូលទៅដោយបញ្ញា ដោយពាក្យខាងក្រោយ ។ សំដែងដល់ព្រះមាន-ព្រះភាគ ទ្រង់បង្អោនទៅក្នុងការឲ្យសម្រេចហិតសុខ ដល់សត្វទាំងឡាយ ដោយពាក្យខាងដើម សំដែងការដែលទ្រង់មិនជាប់នៅក្នុងការបំពេញហិត-សុខដល់អ្នកដទៃ ដោយពាក្យខាងក្រោយ ។ សំដែងការនៅជាសុខ ដែលទ្រង់លះសេចក្តីសុខប្រកបដោយធម៌ជានិមិត្ត ដោយពាក្យខាងដើម សំដែងការនៅជាសុខដែលមានការប្រកបរឿយៗ នូវឧត្តរិមនុស្សធម្មជានិមិត្ត ដោយពាក្យខាងក្រោយ សំដែងការដែលទ្រង់មានឧបការៈច្រើនដល់មនុស្សទាំង

ឡាយ ដោយពាក្យខាងដើម ។ សំដែងភាពដែលទ្រង់មានឧបការៈដល់ទេវតាទាំងឡាយ ដោយពាក្យខាងក្រោយ ។ សំដែងការដែលព្រះមាន-ព្រះភាគស្តេចឧបត្តិក្នុងលោក ចម្រើនជំធាត់ក្នុងលោក ដោយពាក្យដំបូង ។ សំដែងការដែលលោកលាបព្រះអង្គមិនបាន ដោយពាក្យខាងក្រោយ មានដូចពោលមកនេះជាដើម ។

សព្ទថា **អថ** ប្រើក្នុងអត្ថថាមិនដាច់ខ្សែ សព្ទថា **ខោ** ជានិបាតចុះក្នុងអត្ថថា សំដែងរឿងដទៃៗ ។ ដោយ ២ បទនោះ ព្រះថេរៈសំដែងថា រឿងដទៃៗ នេះ កើតឡើងក្នុងព្រះវិហាររបស់ព្រះមានព្រះភាគមិនដាច់ខ្សែឡើយ ។ រឿងនោះដូចម្តេច? គឺ រឿងទេវតាមួយអង្គជាដើម ។ បទថា **អញ្ញត្រា (មួយអង្គ)** ក្នុងបទថា ទេវតាអង្គមួយនោះ សំដែងសេចក្តីមិនពិតប្រាកដ ។ ពិតហើយ ទេវតានោះ មិនប្រាកដនាម និងគោត្រព្រោះដូច្នោះ លោកទើបពោលថា "មួយអង្គ" ។ ទេវតា គឺ ក៏ទេពនោះឯង ។ បទថា **អញ្ញត្រា (មួយអង្គ)** នេះ ជាសាធារណៈ ទូទៅដល់ស្ត្រីនិងបុរស ។ តែក្នុងទីនេះ បុរសប៉ុណ្ណោះ ហៅថាទេវបុត្រ ។ ក៏ពាក្យអ្វី

ហ្ន៎? ទេវបុត្រ លោកពោលថា "ទេវតា" ព្រោះជាសាធារណនាម ។

## កៃ អភិក្កន្ត សព្ទ

ក្នុងបទថា **អភិក្កន្តាយ រត្តិយា** នេះ មានពាក្យអធិប្បាយដូច្នេះ **អភិក្កន្ត** សព្ទ ប្រើក្នុងសេចក្តីទាំងឡាយមាន **អស់ទៅ ល្អ ស្អាត គួរ** រីករាយក្រៃលែង ជាដើម ។

ក្នុងសេចក្តីទាំងនោះ ប្រើក្នុងអត្ថថា **អស់ទៅ** បានក្នុងប្រយោគជាដើមយ៉ាងនេះថា **អភិក្កន្តា ភន្តេ រត្តិ , និក្ខន្តោ បឋមោ យាមោ ចិរនិសិន្នោ ភិក្ខុសង្ឃោ ឧទ្ទិសតុ ភន្តេ ភគវា ភិក្ខូនំ បាដិមោក្ខំ** ។ បពិត្រព្រះអង្គដ៏ចម្រើន រាត្រី **អស់ទៅ** ហើយ បឋមយាមកន្លងទៅហើយ ភិក្ខុសង្ឃអង្គុយយូរហើយ សូមព្រះមានព្រះភាគ ទ្រង់មេត្តាសំដែងបាតិមោក្ខដល់ភិក្ខុទាំងឡាយចុះ ព្រះអង្គ ។

ប្រើក្នុងសេចក្តីថា **ល្អ** បានក្នុងប្រយោគជាដើមយ៉ាងនេះថា **អយំ ឥមេសំ ចតុន្នំ បុគ្គលានំ អភិក្កន្តតរោ ច បណីតតរោ ច** បុគ្គលនេះ **ល្អ** ជាង ប្រណីតជាង បុគ្គល ៤ ជំពូកនេះ ។

ប្រើក្នុងសេចក្ដីថា ស្អាត បានក្នុងប្រយោគជាដើមយ៉ាងនេះថា

កោ មេ វន្ទតិ បាទានិ ឥទ្ធិយា យសសា ជលំ
អភិក្កន្តេន វណ្ណេន សព្វា ឱភាសយំ ទិសា

នរណាហ្ន៎ រុងរឿងដោយរិទ្ធិ ដោយយស មានវណ្ណៈស្អាត
បញ្ចេញរស្មីភ្លឺសព្វទិស មកថ្វាយបង្គំជើងតថាគត ។

ប្រើក្នុងសេចក្ដីថា គួរពីករាយក្រៃលែង បានក្នុងប្រយោគជាដើមយ៉ាងនេះថា អភិក្កន្តំ ភោ គោតម អភិក្កន្តំ ភោ គោតម (ភាសិតរបស់ព្រះអង្គ) គួរពីករាយក្រៃលែង បពិត្រព្រះគោតម (ភាសិតរបស់ព្រះអង្គ) គួរពីករាយក្រៃលែង បពិត្រព្រះគោតម ។

តែក្នុងព្រះសូត្រនេះ ប្រើក្នុងសេចក្ដីថា អស់ទៅ ព្រោះហេតុនោះ លោកអធិប្បាយថា បទថា អភិក្កន្តាយ រត្តិយា ប្រែថា រាត្រីកាលអស់ទៅហើយ ។

ក្នុងបទថា អភិក្កន្តវណ្ណា នេះ អភិក្កន្ត ស័ព្ទ ប្រើក្នុងសេចក្ដីថា ស្អាត ។ វណ្ណ ស័ព្ទ ប្រើក្នុងសេចក្ដីថា សម្បុរ សរសើរ ពួកត្រកូល

ហេតុ ទ្រង់ទ្រាយ ខ្នាត រូបាយតនះ ជាដើម ។

ប្រើក្នុងអត្ថថា សម្បុរ បានក្នុងប្រយោគជាដើមថា សុវណ្ណវណ្ណោ ភគវា ព្រះមានព្រះភាគ មាន ព្រះឆវី ដូចមាស ។

ប្រើក្នុងសេចក្តីថា សរសើរ បានក្នុងប្រយោគជាដើមយ៉ាងនេះថា គហបតីពាក្យ សរសើរ ព្រះសមណគោតមអង្គនោះ លោករួបរួមទុកកាលណា ។

ប្រើក្នុងសេចក្តីថា ពួកត្រកូល បានក្នុងប្រយោគជាដើមយ៉ាងនេះថា ព្រះគោតម ត្រកូល (វណ្ណ:) ៤ ទាំងនេះ ។

ប្រើក្នុងសេចក្តីថា ហេតុ បានក្នុងប្រយោគជាដើមយ៉ាងនេះថា អថ កេន នុ វណ្ណេន គន្ធថេនោតិ វុច្ចតិ បើដូច្នោះ ព្រោះ ហេតុ អ្វីហ្ន៎ ទើបពោលថាយើងជាអ្នកលួចក្លិន ។

ប្រើក្នុងអត្ថថា ទ្រង់ទ្រាយ បានក្នុងប្រយោគជាដើមយ៉ាងនេះថា មហន្តំ ហត្ថិរាជវណ្ណំ អភិនិម្មិត្វា និម្មិត ទ្រង់ទ្រាយ ជាស្តេចដំរី ។

ប្រើក្នុងសេចក្តីថា ខ្នាត បានក្នុងប្រយោគជាដើមយ៉ាងនេះថា តយោ

*បត្តស្ស វណ្ណោ* ខ្នាត របស់បាត្រ ៣ ខ្នាត ។

ប្រើក្នុងសេចក្តីថា *រូបាយតនៈ* បានក្នុងប្រយោគជាដើមយ៉ាងនេះថា *វណ្ណោ គន្ធោ រសោ ឱជា , រូបំ គន្ធោ រសោ ឱជា* ។

*វណ្ណៈ* ស័ព្ទនោះ ក្នុងសូត្រនេះ គប្បីឃើញថា ប្រើក្នុងសេចក្តីថា *សម្បុរ* ។ ព្រោះហេតុនោះ លោកទើបអធិប្បាយថា បទថា *អភិក្កន្តវណ្ណា* ប្រែថា មានពណ៌សម្បុរគួរស្រឡាញ់ ។

## កែអត្ថបទ កេវលកប្បំ

ក្នុងពាក្យថា *កេវលកប្បំ* នេះ មានពាក្យអធិប្បាយដូច្នេះ *កេវល* ស័ព្ទ មានសេចក្តីជាអនេក ដូច **មិនមានចំណែកសល់ ដោយច្រើន មិនប្រឡូកប្រឡំ** (សុទ្ធៗ) **មិនច្រើនពេក ឋិតនៅ មិនជាប់** ។ ពិតហើយ *កេវល* ស័ព្ទនោះ មានអត្ថថា **មិនមានចំណែកសល់** បានក្នុងប្រយោគជាដើមថា *កេវលបរិបុណ្ណំ បរិសុទ្ធំ ព្រហ្មចរិយំ* ព្រហ្មចារ្យបរិសុទ្ធិបរិបូណ៌ **មិនមានចំណែកសល់** ។

មានអត្ថថា **ដោយច្រើន** បានក្នុងប្រយោគយ៉ាងនេះថា *កេវលកប្បា*

ច អង្គមាគធា បហូតំ ខាទនីយំ ភោជនីយំ អាទាយ ឧបសង្កមិស្សន្តិ អ្នកស្រុកអង្គៈ និងអ្នកស្រុកមគធៈចំណែកច្រើន កាន់យករបស់ទំពារស៊ី ដ៏ ច្រើន ចូលទៅគាល់ ។

មានអត្ថថា មិនប្រឡូកប្រឡំ (សុទ្ធៗ) បានក្នុងប្រយោគជាដើម យ៉ាងនេះថា កេវលស្ស ទុក្ខក្ខន្ធស្ស សមុទយោ ហោតិ ការកើតនៃ ទុក្ខក្ខន្ធមិនប្រឡូកប្រឡំគ្នា (សុទ្ធៗ) មានហើយ ។

មានអត្ថថា មិនច្រើនពេក បានក្នុងប្រយោគជាដើមយ៉ាងនេះថា កេវលំ សទ្ធាមត្តកំ នូន អយមាយស្មា អ្នកមានត្រឹមតែសទ្ធា មិនច្រើន ទេ ។

មានសេចក្តីថា មាំមួន បានក្នុងប្រយោគជាដើមយ៉ាងនេះថា អយ-ស្មតោ ភន្តេ អនុរុទ្ធស្ស ពាហិយោ នាម សទ្ធិវិហារិកោ កេវលកប្បំ សង្ឃភេទាយ ឋិតោ បពិត្រព្រះអង្គដ៏ចម្រើន សទ្ធិវិហារិករបស់ព្រះអនុរុទ្ធៈ ឈ្មោះថា ពាហិយៈតាំងនៅក្នុងសង្ឃភេទ (ការធ្វើសង្ឃឲ្យបែកគ្នា) ឋិត នៅ រហូតអស់កប្ប ។

មានសេចក្ដីថា **មិនជាប់** បានក្នុងប្រយោគជាដើមយ៉ាងនេះថា **កេវលី វុសិត្វា ឧត្តមបុរិសោតិ វុច្ចតិ អ្នក មិនជាប់** នៅចប់ព្រហ្មចរិយៈហើយ លោកហៅថា បុរសខ្ពង់ខ្ពស់ ។

តែក្នុងសូត្រនេះ **កេវល** ស័ព្ទនោះ លោកបំណងយកសេចក្ដីថា **មិនមានចំណែកសល់** ។

ចំណែក **កប្ប** ស័ព្ទ មានអត្ថច្រើន មានជាដើមថា **ការជឿជាក់ វោហារ កាល បញ្ញត្តិ កាត់តែង វិកប្ប លេស និងដោយជុំវិញ** ។

ពិតយ៉ាងនោះ **កប្ប** ស័ព្ទនោះ មានសេចក្ដីថា **ជឿជាក់** បានក្នុងប្រយោគជាដើមយ៉ាងនេះថា **ឱកប្បនីយមេតំ ភោតោ គោតមស្ស យថា តំ អរហតោ សម្មាសម្ពុទ្ធស្ស** នោះជាការ **ជឿជាក់** ចំពោះព្រះគោតម ដូចជាជឿជាក់ចំពោះព្រះអរហន្តសម្មាសម្ពុទ្ធ ។

មានសេចក្ដីថា **វោហារ** បានក្នុងប្រយោគជាដើមយ៉ាងនេះថា **អនុ-ជានាមិ ភិក្ខវេ បញ្ចហិ សមណកប្បេហិ ផលំ បរិភុញ្ជិតុំ ម្នាលភិក្ខុ**ទាំងឡាយតថាគតអនុញ្ញាតឲ្យឆាន់ផ្លែឈើដោយសមណ **វោហារ** ៤ ប្រការ ។

មានសេចក្តីថា កាល បានក្នុងប្រយោគជាដើមយ៉ាងនេះថា យេន សុទំ និច្ចកប្បំ វិហរាមិ បានឮថា តថាគតនឹងនៅរហូតអស់ កាល ជានិច្ច ដោយធម៌ណា ។

មានសេចក្តីថា បញ្ញត្តិ បានក្នុងប្រយោគជាដើមយ៉ាងនេះថា ឥច្ចា-យស្មា កប្បោ លោក កប្បៈ យ៉ាងនេះ ។

មានអត្ថថា តាក់តែង បានក្នុងប្រយោគយ៉ាងនេះថា អលង្កតោ កប្បិតកេសមស្សុ តែងខ្លួន តែងសក់ និងពុកមាត់ ។

មានសេចក្តីថា គួរ បានក្នុងប្រយោគជាដើមយ៉ាងនេះថា កប្បតិ ទ្វង្គុលកប្បោ កិក្ខុទុកសក់ ២ អង្គុលី រមែង គួរ ។

មានសេចក្តីថា លេស បានក្នុងប្រយោគជាដើមយ៉ាងនេះថា អត្ថិ កប្បោ និបជ្ជិតុំ ធ្វើ លេស ដើម្បីនឹងដេក ។

មានសេចក្តីថា ដោយជុំវិញ បានក្នុងប្រយោគជាដើមយ៉ាងនេះថា កេវលកប្បំ វេឡុវនំ ឱភាសេត្វា បញ្ចេញរស្មីទូទៅព្រះវេឡុវ័ន ដោយ ជុំវិញ មិនសេសសល់ ។

តែក្នុងសូត្រនេះ **កប្ប** សព្ទនោះ លោកបំណងយកសេចក្តីថា **ដោយជុំវិញ** ដោយក្នុងបទថា **កេវលកប្បំ ជេតវនំ** នេះ គប្បីជ្រាបសេចក្តីយ៉ាងនេះថា ទូទៅក្នុងវត្តជេតពន **ដោយជុំវិញ** មិនមានសល់ ។

បទថា **ឱភាសេត្វា (បញ្ចេញរស្មី)** បានដល់ ផ្សាយដោយរស្មី ។ អធិប្បាយថា ធ្វើរស្មីឲ្យតែមួយ រុងរឿង ដូចព្រះចន្ទ និងព្រះអាទិត្យ ។

បទថា **យេន ភគវា តេនុបសង្កមិ** ជាតតិយាវិភត្តិចុះក្នុងអត្ថនៃសត្តមីវិភត្តិ ដោយប្រការដែលគប្បីឃើញអត្ថក្នុងពាក្យនេះ យ៉ាងនេះថា ព្រះមានព្រះភាគប្រថាប់នៅក្នុងទីណា ទេវបុត្រក៏ចូលទៅគាល់ក្នុងទីនោះ ។ ឬគប្បីឃើញអត្ថក្នុងពាក្យនេះ យ៉ាងនេះថា ព្រះមានព្រះភាគ ដែលទេវតានិងមនុស្សគប្បីចូលទៅគាល់ដោយហេតុណា ទេវបុត្រក៏ចូលទៅគាល់ដោយហេតុនោះឯង ។ ព្រះមានព្រះភាគ ដែលទេវបុត្រ និងមនុស្សនាំគ្នាចូលទៅគាល់ដោយហេតុណា ។ ដោយបំណងនឹងសម្រេចគុណវិសេស មានប្រការផ្សេងៗ ដូចដើមឈើធំដែលចេញផ្លែជានិច្ច ដែលហ្វូងបក្សីនាំគ្នាចូលទៅ ក៏ដោយបំណងនឹងស៊ីផ្លែឈើដែលមានរសផ្អែម ដូច្នោះ ។ លោកអធិ-

ប្បាយថា បទថា **ឧបសង្កមិ** ប្រែថា ចូលទៅគាល់ ។ បទថា **ឧបសង្កមិត្វា** (គ្រាចូលទៅគាល់) ជាពាក្យពោលដល់ចុងក្រោយនៃការចូលទៅគាល់ ។ ម្យ៉ាងទៀត លោកអធិប្បាយថា ទេវតាទៅយ៉ាងនោះហើយ បន្ទាប់ពីនោះក៏ទៅកាន់ស្ថានទីដែលតពីអាសនៈ ពោលគឺ ទីជិតព្រះមានព្រះភាគ ។ បទថា **ភគវន្តំ អភិវាទេត្វា** (ថ្វាយបង្គំព្រះមានព្រះភាគ) បានដល់ ថ្វាយបង្គំ បង្អោនទមស្ការចំពោះព្រះមានព្រះភាគ ។

សព្ទថា **ឯកមន្តំ** ជាសព្ទនិទ្ទេស ធ្វើឲ្យជា **ភាវនបុំសកលិង្គ** ។ លោកអធិប្បាយថា ឱកាសមួយ ចំណែកម្ខាង ។ ន័យម្យ៉ាងទៀត ពាក្យនេះជាទុតិយាវិភត្តិចុះក្នុងអត្ថសត្តមីវិភត្តិ ។ សព្ទថា **អដ្ឋាសិ** បដិសេធឥរិយាបថអន្ទុយជាដើម អធិប្បាយថា សម្រេចការឈរ គឺ បានឈរហើយ ។

សួរថា ក៏ទេវតានោះឈរដូចម្តេច ទើបឈ្មោះថា បានជាអ្នកឈរចំណែកម្ខាង ។

ឆ្លើយថា បុរាណាចារ្យពោលថា ៖-

ន បច្ឆតោ ន បុរតោ នាបិ អាសន្នទូរតោ
ន កច្ឆេ នោបិ បដិវាតេ ន ចាបិ ឱណតុណ្ណតេ
ឥមេ ទោសេ វិវជ្ជេត្វា ឯកមន្តំ ឋិតា អហុ ។

មិនឈរខាងក្រោយ មិនឈរខាងមុខ មិនឈរជិត និង
មិនឈរឆ្ងាយ មិនឈរទីចំពោះមុខ មិនឈរលើខ្យល់
មិនឈរទីទាប និងទីខ្ពស់ ឈរវៀរចាកទោសទាំងនេះ
ឈ្មោះថា ឈរនៅក្នុងចំណែកម្ខាង ។

សួរថា ព្រោះហេតុអ្វី ទេវតាអង្គនេះ ទើបឈរចំណែកម្ខាង មិនអង្គុយ? ឆ្លើយថា ព្រោះទេវតាបំណងនឹងត្រឡប់ទៅវិញយ៉ាងរហ័ស ។ ពិតហើយ ទេវតាទាំងឡាយ អាស្រ័យប្រយោជន៍ខ្លះ ទើបមកកាន់មនុស្សលោក ដូចបុរសដែលស្អាត ចូលក្នុងបង្គន់ ។ ក៏ដោយប្រក្រតី មនុស្សលោកជារបស់បដិកូល ព្រោះជារបស់ក្លិនស្អុយសម្រាប់ទេវតាទាំងនោះ រាប់តាំងអំពី ១០០ យោជន៍ ទេវតាទាំងឡាយមិនអភិរម្យក្នុងមនុស្សលោកនោះឡើយ ព្រោះហេតុនោះ ទេវតានោះ ទើបមិនអង្គុយ ព្រោះបំណងនឹងធ្វើកិច្ចដែល

មកហើយ ប្រញាប់ត្រឡប់ទៅវិញ ។ ក៏មនុស្សទាំងឡាយ រមែងអង្គុយ ក៏ដើម្បីបន្ទោបង់សេចក្ដីលំបាកនៃឥរិយាបថ មានដើរជាដើម យ៉ាងណា សេចក្ដីលំបាកនោះសម្រាប់ទេវតាមិនមាន ព្រោះដូច្នោះ ទេវតាទើបមិនអង្គុយ ។

មួយទៀត ព្រះមហាសាវកពួកណា ឈរហែរហមព្រះមានព្រះភាគ ព្រះមានព្រះភាគ ក៏ទ្រង់រាប់អានតបព្រះមហាសាវកទាំងនោះ (គឺប្រថាប់ឈរ) សូម្បីព្រោះហេតុនោះ ទេវតាទើបមិនអង្គុយ ។

មួយទៀត ទេវតាមិនអង្គុយ ក៏ព្រោះគោរពក្នុងព្រះមានព្រះភាគ ។ ពិតហើយ ទីអង្គុយរមែងកើតដល់ទេវតាទាំងឡាយដែលបំណងនឹងអង្គុយ តែទេវតាអង្គនេះ មិនបំណងទីអង្គុយនោះ មិនគិតសូម្បីតែនឹងអង្គុយ ទើបឈរក្នុងទីដ៏សមគួរមួយ ។

បទថា **ឯកមន្តំ ឋិតា ខោ សា ទេវតា** (ទេវតាអង្គនោះឈរនៅក្នុងទីដ៏សមគួរមួយ) សេចក្ដីថា ទេវតាអង្គនោះ ឈរនៅក្នុងចំណែកម្ខាងដោយហេតុទាំងនេះ យ៉ាងនេះ ។ បទថា **ភគវន្តំ គាថាយ អជ្ឈភាសិ**

(បានទូលព្រះមានព្រះភាគដោយគាថា) សេចក្ដីថា បានទូលព្រះមានព្រះ-ភាគដោយពាក្យកាព្យ ដែលកំណត់ដោយអក្ខរបទ ។ បានក្រាបទូលដូចម្ដេច? បានក្រាបទូលយ៉ាងនេះថា **ពហូ ទេវា មនុស្សា ច ។បេ។ ព្រូហិ មង្គលមុត្តមំ** (ទេវតា និងមនុស្សទាំងជាច្រើន ។បេ។ សូមព្រះអង្គត្រាស់ប្រាប់មង្គលដ៏ឧត្ដម) ។

## មូលហេតុកើតមង្គលបញ្ហា

ក្នុងការពណ៌នាមង្គលសូត្រនោះ ព្រោះហេតុដែលខ្ញុំតាំងមាតិកាទុកថា កាលនឹងពណ៌នាសេចក្ដីនៃបាឋៈមានជាអាទិ៍ថា **ឯវំ** ដោយប្រការផ្សេងៗ និងពោលដល់សមុដ្ឋាន (មូលហេតុ) ដូច្នេះ នេះជាឱកាសដែលនឹងគប្បីពោលដល់សមុដ្ឋាននោះ ដូច្នោះ នឹងពោលដល់សមុដ្ឋានរបស់មង្គលបញ្ហាមុន ខាងក្រោយទើបនឹងពណ៌នាសេចក្ដីនៃបទគាថាទាំងនេះ ។ អ្វីជាមូល-ហេតុកើតមង្គលបញ្ហា ។

បានឮមកថា ក្នុងជម្ពូទ្វីប មហាជនជួបជុំគ្នាក្នុងទីនោះៗ ជិតទ្វារក្រុង សភានៃទីរាជការជាដើម ប្រគល់ទ្រព្យរបស់ មាស ប្រាក់ឲ្យគេនិយាយរឿង

ផ្សេងៗ ដូចរឿងនាំនាងសិតាមកជាដើម ។ រឿងមួយៗ និយាយរហូត ៤ ខែទើបចប់ ក្នុងស្ថានទីនោះ ។ ថ្ងៃមួយ រឿងមង្គលបញ្ហាក៏កើតឡើងថា អ្វីហ្ន៎ ជាមង្គល ។ វត្ថុដែលឃើញឬជាមង្គល រឿងដែលបានឮឬជាមង្គល ឬរឿងដែលបានជ្រាបជាមង្គល នរណាស្គាល់ដឹងមង្គល ដូច្នេះ ។

គ្រានោះ បុរសម្នាក់ឈ្មោះ **ទិដ្ឋមង្គលិក:** (រាប់អានវត្ថុដែលឃើញថាជាមង្គល) ពោលថា ខ្ញុំដឹងមង្គល ។ វត្ថុដែលឃើញជាមង្គលក្នុងលោក រូបដែលសម្មតិគ្នាថា ជាមង្គល ឈ្មោះថា ទិដ្ឋ: ។ យ៉ាងណា ។ បុគ្គលខ្លះក្នុងលោកនេះ ក្រោកពីព្រឹកឃើញសត្វហើរទទះស្លាបខ្លះ ឃើញដើមព្នៅជំទង់ខ្លះ ឃើញស្ត្រីមានគភ៌ខ្លះ ឃើញក្មេងកំលោះប្រដាប់តាក់តែងកាយ ទូលថ្នាំងដាក់ទឹកពេញខ្លះ ត្រីឆ្អិនក្រហមខ្លះ សេះអាជានេយ្យខ្លះ រថទឹមដោយសេះខ្លះ គោឈ្មោលខ្លះ គោញីខ្លះ គោក្រហមខ្លះ ឬថា ឃើញរូបសូម្បីដទៃណា ឃើញបែបនោះ ដែលសម្មតិគ្នាថា ជាមង្គល រូបដែលឃើញនេះ ហៅថា **ទិដ្ឋមង្គល** ។ បុគ្គលពួកខ្លះក៏យល់ព្រមទទួលពាក្យរបស់គេ ពួកខ្លះក៏មិនយល់ព្រមទទួល ពួកដែលមិនយល់ព្រមក៏បែកចេញពីគេ ។

គ្រានោះ បុរសម្នាក់ឈ្មោះ **សុតមង្គលិកៈ** ក៏ពោលថា លោកអើយ ដែលឈ្មោះថា ភ្នែក រមែងឃើញរបស់ស្អាតខ្លះ របស់មិនស្អាតខ្លះ របស់ល្អខ្លះ របស់មិនល្អខ្លះ របស់ពេញចិត្តខ្លះ របស់មិនពេញចិត្តខ្លះ ប្រសិនបើរូបដែលអ្នកឃើញនោះ គប្បីជាមង្គលសោត ក៏នឹងគប្បីជាមង្គលទាំងអស់ ព្រោះដូច្នោះ រូបដែលឃើញ មិនមែនជាមង្គល ។ តែថា សំឡេងដែលបានឮផ្លូវត្រចៀកជាមង្គល ។ សំឡេងដែលសម្មតិថា ជាមង្គល ឈ្មោះថា សុតៈ ។ យ៉ាងណា ។ បុគ្គលខ្លះក្នុងលោកនេះ ក្រោកឡើងអំពីព្រឹក បានឮសំឡេងដូច្នេះថា ចម្រើនហើយ ចម្រើនហើយ ពេញ បាយ ចិត្តល្អ សិរី ចម្រើនដោយសិរី ថ្ងៃនេះ ឫក្សល្អ យាមល្អ ថ្ងៃល្អ មង្គលល្អ ឬស្តាប់សំឡេងដែលសម្មតិថា មង្គល យ៉ាងណាមួយ ។ សំឡេងដែលបានឮនេះ ហៅថា សុតមង្គល ។ ពួកខ្លះក៏យល់ព្រមទទួលពាក្យរបស់គេ ពួកខ្លះក៏មិនយល់ព្រម ពួកដែលមិនព្រមទទួល ក៏បែកចេញពីគេ ។

គ្រានោះ បុរសម្នាក់ឈ្មោះ **មុតមង្គលិកៈ** ពោលថា លោកអើយ ដែលពិត ដែលឈ្មោះថា ត្រចៀក រមែងបានឮសំឡេងល្អខ្លះ មិនល្អខ្លះ

ពេញចិត្តខ្លះ មិនពេញចិត្តខ្លះ ប្រសិនបើសំឡេងដែលអ្នកបានឮនោះ ជាមង្គលសោត ក៏នឹងជាមង្គលទាំងអស់ ។ ព្រោះដូច្នោះ សំឡេងដែលបានឮ ទើបមិនជាមង្គល ។ តែថា វត្ថុដែលប្រាបហើយ ជាមង្គល ។ ក្លិនរស និងផោដ្ឋព្វ: (វត្ថុដែលគប្បីពាល់ត្រូវ) ដែលសម្មតិថា ជាមង្គល ឈ្មោះថា មុត: ។ យ៉ាងណា ។ បុគ្គលខ្លះក្រោកពីព្រឹក ស្រូបក្លិនផ្កាឈើ មានក្លិនផ្កាបទុមជាដើមខ្លះ ទំពារឈើស្ងួនខ្លះ ពាល់ត្រូវផែនដីខ្លះ ពាល់ត្រូវសន្ទូងខ្លះ អាចម៍គោស្រស់ខ្លះ ផេះខ្លះ ល្ងខ្លះ ផ្កាឈើខ្លះ ផ្លែឈើខ្លះ លាបដោយដីសខ្លះ ស្លៀកដណ្ដប់សំពត់សខ្លះ ជួតក្បាលកំណាត់សខ្លះ ឬក៏ថា ស្រូបក្លិន លិទ្ធរស ឬពាល់ត្រូវផោដ្ឋព្វ: ដែលសម្មតិថា ជាមង្គលយ៉ាងដទៃណា ឃើញបែបនោះ វត្ថុដូចពោលមកនេះ ហៅថា **មុតមង្គល** ។ ពួកខ្លះក៏ព្រមទទួលពាក្យរបស់គេ ពួកខ្លះក៏មិនព្រមទទួល ។

ក្នុង ៣ ពួកនោះ ទិដ្ឋមង្គលិកបុរស ក៏មិនអាចធ្វើឲ្យសុតមង្គលិកបុរស និងមុតមង្គលិកបុរសត្រេកអរទទួលយកបាន ទាំង ៣ ចំណែកនោះ មួយចំណែក ក៏ធ្វើឲ្យជា ២ ចំណែក ឲ្យរីករាយទទួលមិនបាន ។ បណ្ដា

បុគ្គលទាំងនោះ ពួកណាយល់ព្រមទទួលពាក្យរបស់ទិដ្ឋមង្គលិកបុរស ពួកនោះក៏កាន់យកថា រូបដែលឃើញហើយប៉ុណ្ណោះ ជាមង្គល ។ ពួកណាទទួលពាក្យរបស់សុតមង្គលិកបុរស និងមុតមង្គលិកបុរស ពួកនោះក៏ប្រកាន់ថា សំឡេងដែលបានឮប៉ុណ្ណោះ ជាមង្គល វត្ថុដែលបានជ្រាបប៉ុណ្ណោះ ជាមង្គល ។ រឿងមង្គលបញ្ហានេះ បានប្រាកដទូទៅក្នុងជម្ពូទ្វីប ដោយប្រការដូច្នេះ ។

គ្រានោះ មនុស្សទូទាំងជម្ពូទ្វីប ប្រកាន់គ្នាជាពួកៗ នាំគ្នាគិតមង្គលទាំងឡាយថា អ្វីហ្ន៎ ជាមង្គល ។ អារក្ខទេវតារបស់មនុស្ស ពួកនោះស្ដាប់រឿងនោះហើយ ក៏នាំគ្នាគិតមង្គលទាំងឡាយដូចគ្នា ។ ពួកភុម្មទេវតា ជាមិត្ររបស់ទេវតាទាំងនោះ ស្ដាប់រឿងពីអារក្ខទេវតានោះហើយ ក៏នាំគ្នាគិតមង្គលយ៉ាងនោះដូចគ្នា ។ អាកាសដ្ឋកទេវតា ជាមិត្ររបស់ទេវតាទាំងនោះ ចាតុមហារាជទេវតា ជាមិត្ររបស់អាកាសដ្ឋកទេវតាទាំងនោះ ដោយឧបាយយ៉ាងនេះ ដរាបដល់អកនិដ្ឋទេវតា ស្ដាប់រឿងពីសុទស្សីទេវតានោះហើយ ក៏កាន់យកគ្នាជាពួកៗ នាំគ្នាគិតមង្គលទាំងឡាយ ដោយឧបាយយ៉ាងនេះ ។

ការគិតមង្គល បានកើតឡើងក្នុងទីគ្រប់កន្លែង រហូត ១០.០០០ ចក្រវាឡ ។ ក៏ការគិតមង្គលកើតឡើងហើយ សូម្បីវិនិច្ឆ័យថា នេះជាមង្គល នេះជាមង្គល តែក៏មិនដាច់ស្រេចរហូតដល់ ១២ ឆ្នាំ ។ ទាំងមនុស្ស ទាំងទេវតា ទាំងព្រហ្មក៏ដូចគ្នា វៀរព្រះអរិយសាវក បែកជា ៣ ពួក គឺ ទិដ្ឋមង្គលិក: សុតមង្គលិក: និងមុតមង្គលិក: សូម្បីតែមួយពួក ក៏សម្រេចតាមសេចក្ដីពិតមិនបានថា នេះប៉ុណ្ណោះជាមង្គល មង្គលកោលាហល (ការភ័យរឿងមង្គល) កើតឡើងហើយក្នុងលោក ។

ដែលឈ្មោះថា កោលាហល មាន ៥ គឺ កប្បកោលាហល ចក្កវត្តិកោលាហល ពុទ្ធកោលាហល មង្គលកោលាហល មោនេយ្យកោលាហល ។ បណ្ដាលកោលាហលទាំង ៥ នោះ ពួកទេវតាជាន់កាមាវចរ អន្រ្ទនសីស: រំសាយសក់ ស្រែកយំ យកដៃជូតទឹកភ្នែក ស្លៀកសំពត់ពណ៌ក្រហម មានភេទប្លែកៗ ត្រាច់ទៅក្នុងកន្លែងមនុស្ស ស្រែកប្រាប់ថា កន្លងទៅ ១០០.០០០ ឆ្នាំ កប្បនឹងប្រាកដ លោកនេះនឹងវិនាស មហាសមុទ្រនឹងរីងស្ងួត មហាបឋវីនេះ នឹងភ្នំសិនេរុ នឹងត្រូវភ្លើងឆេះ នឹងវិនាស

លោកវិនាសនឹងមានរហូតដល់ព្រហ្មលោក អ្នកនិរទុក្ខ សូមលោកទាំងឡាយចូរនាំគ្នាចម្រើនមេត្តាចុះ ចូរនាំគ្នាចម្រើនករុណា មុទិតា ឧបេក្ខាចុះ លោកអ្នកនិរទុក្ខ ចូរទំនុកបម្រុងមាតាបិតា ចូរកោតក្រែងអ្នកជាធំក្នុងត្រកូលជាស់តឿនគ្នា កុំជាអ្នកប្រមាទឡើយ ។ នេះឈ្មោះថា **កប្បកោលាហល** ។

ទេវតាជាន់កាមាវចរនោះឯង ត្រាច់ទៅក្នុងឋានមនុស្សពោលប្រាប់ថា កន្លងទៅ ១០០ ឆ្នាំ ស្តេចចក្រពត្តិនឹងកើតឡើងក្នុងលោក នេះឈ្មោះថា **ចក្កវត្តិកោលាហល** ។

ចំណែកទេវតាជាន់សុទ្ធាវាស ប្រដាប់អង្គដោយអាភរណ៍ព្រហ្ម យកសំពត់ជូតក្បាលរបស់ព្រហ្មជូតលើសីសៈ កើតបីតិបាមោជ្ជៈ ពោលព្រះពុទ្ធគុណ យាងទៅក្នុងឋានមនុស្សនៅ ពោលថា កន្លងទៅ ១.០០០ ឆ្នាំ ព្រះពុទ្ធនឹងឧប្បត្តិ ។ នេះឈ្មោះថា **ពុទ្ធកោលាហល** ។

ទេវតាជាន់សុទ្ធាវាសនោះឯង ដឹងចិត្តរបស់ពួកទេវតា និងមនុស្សត្រាច់ទៅក្នុងឋានមនុស្ស ពោលថា កន្លងទៅ ១២ ឆ្នាំ ព្រះសម្មាសម្ពុទ្ធនឹងត្រាស់មង្គល ។ នេះឈ្មោះថា **មង្គលកោលាហល** ។

ទេវតាជាន់សុទ្ធាវាសនោះឯង ត្រាច់ទៅក្នុងឋានមនុស្ស ពោលថា កន្លងទៅ ៧ ឆ្នាំ ភិក្ខុមួយរូបសមាគមជាមួយព្រះសម្មាសម្ពុទ្ធ នឹងទូលសួរមោនេយ្យប្បដិបទា ។ នេះឈ្មោះថា **មោនេយ្យកោលាហល** ។ បណ្តាកោលាហលទាំង ៥ នេះ មង្គលកោលាហលរបស់ទេវតា និងមនុស្សទាំងឡាយ កើតឡើងហើយក្នុងលោក ។

គ្រានោះ កាលទេវតា និងមនុស្សទាំងឡាយនាំគ្នាពិចារណា ក៏នៅមិនបានមង្គលទាំងឡាយ កន្លងទៅ ១២ ឆ្នាំ ទេវតាជាន់តាវតឹង្សគប់រកសមាគមគ្នា ក៏ជួយគ្នាគិតយ៉ាងនេះថា ម្ចាស់របស់ផ្ទះក៏ជាប្រធានរបស់ខ្លួនខាងក្នុងផ្ទះ ម្ចាស់របស់ស្រុកក៏ជាប្រធានរបស់ជនក្នុងស្រុក ព្រះរាជាក៏ជាប្រធានរបស់មនុស្សទាំងឡាយ យ៉ាងណា ស្តេចសក្កៈជាស្តេចទេវតាអង្គនេះ ក៏ជាអ្នកប្រសើរបំផុតរបស់ពួកយើង គឺ ជាអធិបតីរបស់ទេវលោកទាំងពីរ (ជាន់ចាតុមហារាជកា និងតាវតឹង្ស) ដោយបុណ្យ តេជៈ ឥស្សរិយៈ បញ្ញា ដូច្នោះ យើងគប្បីនាំគ្នាទៅទូលសួរសេចក្តីនេះចំពោះស្តេចសក្កៈទេវរាជចុះ ។ ទេវតាទាំងនោះ ក៏នាំគ្នាទៅកាន់សំណាក់ស្តេចសក្កៈ

ថ្វាយបង្គំសក្កទេវរាជ ដែលមានព្រះសរីរៈ មានសិរីដោយអាភរណៈប្រចាំកាយរបស់ព្រះអង្គ ដែលសមគួរដល់ខណៈនោះ មានពួកទេពអប្សរ ២៥០ កោដិហែហម ប្រថាប់អង្គុយលើមណ្ឌលកម្ពលសិលាសនៈដ៏ប្រសើរ ខាងក្រោមដើមបារិច្ឆត្រ ហើយឈរនៅក្នុងទីដ៏សមគួរមួយ ទូលថា សូមប្រទានព្រះវរោកាស ព្រះអង្គអ្នកនិរទុក្ខ ប្រោសមេត្តាជ្រាបចុះ ឥឡូវនេះ មង្គលបញ្ហាកើតឡើងហើយ មួយពួកពោលថា "រូបដែលឃើញជាមង្គល" ពួកមួយពោលថា "សំឡេងដែលបានឮជាមង្គល" ពួកមួយពោលថា "វត្ថុដែលជ្រាបហើយជាមង្គល" បណ្តាលោកទាំងនោះ ពួកខ្ញុំព្រះអង្គ និងពួកដទៃទៀត នៅមិនទាន់បានជាក់ច្បាស់នៅឡើយ សូមព្រះអង្គទ្រង់មេត្តាប្រោសព្យាករណ៍តាមពិត ដល់ពួកខ្ញុំព្រះអង្គផងចុះ ។ ស្តេចសក្កទេវរាជ ដោយប្រក្រតីទ្រង់មានបញ្ញា ទើបត្រាស់ថា រឿងមង្គលនេះកើតឡើងអំពីទីណាមុនគេ ទូលថា បពិត្រទេវរាជ ពួកខ្ញុំស្តាប់ពាក្យរបស់ពួកទេវតាចាតុមហារាជ ។ តពីនោះ ពួកទេវតាជាន់ចាតុមហារាជ ក៏ស្តាប់ពាក្យរបស់អាកាសដ្ឋទេវតា ពួកអាកាសដ្ឋទេវតាស្តាប់ពាក្យរបស់ភុម្មទេវតា ពួកភុម្មទេវតា

បានស្តាប់ពាក្យរបស់ទេវតាអ្នករក្សាមនុស្ស ដែលពួកទេវតាអ្នករក្សាមនុស្ស បានពោលថា "រឿងមង្គលកើតឡើងក្នុងមនុស្សលោក" ។

លំដាប់នោះ សក្កទេវរាជត្រាស់សួរទេវតាទាំងនោះថា ព្រះសម្មាសម្ពុទ្ធ ប្រថាប់នៅក្នុងទីណា? ទេវតាទាំងឡាយទូលថា ប្រថាប់នៅក្នុងមនុស្សលោក ព្រះអង្គ ។ ត្រាស់សួរថា នរណាបានទូលសួរព្រះមានព្រះភាគ ព្រះអង្គនោះដែរឬ? ទូលថា មិនមាននរណាទូលសួរទេ ព្រះអង្គ ។ ត្រាស់ថា អ្នកនិរទុក្ខ ហេតុអ្វី លោកទាំងឡាយទើបមក លះបង់គំនរភ្លើង ហើយមកតាមពន្លឺសត្វអំពិលអំពែក ព្រោះហេតុអ្វី លោកទាំងឡាយទើបមក លះបង់ព្រះមានព្រះភាគដែលទ្រង់សំដែងមង្គលទុកមិនមានសេសសល់ ហើយយល់ថា គួរនឹងសួរយើង មកលោកអ្នកនិរទុក្ខទាំងឡាយ យើងនឹងទូលសួរព្រះមានព្រះភាគអង្គនោះ ពួកយើងគង់នឹងបានការព្យាករណ៍បញ្ហា ដែលមានសិរីដោយពិត ទើបមានទេវឱង្ការប្រើទេវបុត្រមួយអង្គថា លោកចូរទៅទូលសួរព្រះមានព្រះភាគចុះ ។ ទេវបុត្រអង្គនោះ តាក់តែងកាយដោយគ្រឿងអលង្ការ ដែលសមគួរដល់ខណៈនោះ រុងរឿងដូចផ្លេកបន្ទោរ

មានពួកទេវតាហែហម ទៅកាន់វត្តជេតពនមហាវិហារ ថ្វាយបង្គំព្រះមានព្រះ-ភាគ ហើយឈរនៅក្នុងទីដ៏សមគួរមួយ កាលទូលសួរមង្គលបញ្ហា ទើបពោលជាគាថាថា **ពហូ ទេវា មនុស្សា ច** (ទេវតា និងមនុស្សជាច្រើន) ជាដើម ។

(នេះជាមូលហេតុកើតមង្គលបញ្ហា)

## ពណ៌នាគាថាថា ពហូ ទេវា

[៦] ឥឡូវនេះ នឹងពណ៌នាសេចក្តីនៃបទក្នុងគាថា ។ សព្ទថា **ពហូ** គឺ សំដែងចំនួនមិនពិតប្រាកដ ព្រោះហេតុនោះ លោកទើបអធិប្បាយថា ច្រើនរយ ច្រើនពាន់ ច្រើនសែន ។ ឈ្មោះថា **ទេព** ព្រោះលេង អធិប្បាយថា លេងជាមួយនឹងកាមគុណ ៥ ឬរុងរឿងដោយសិរីរបស់ខ្លួន ។ ន័យម្យ៉ាងទៀត បទថា **ទេវា (ទេព)** បានដល់ ទេពទាំង ៣ គឺ សម្មតិទេព ឧបបត្តិទេព និងវិសុទ្ធិទេព ដូចដែលលោកពោលទុកថា ៖

**បទថា ទេព បានដល់ ទេព ៣ គឺ សម្មតិទេព ឧបបត្តិទេព**

វិសុទ្ធិទេព ។ បណ្តាទេពទាំង ៣ នោះ ព្រះរាជា ព្រះរាជ-
ទេវី ព្រះរាជកុមារ ឈ្មោះថា សម្មតិទេព ។ ទេពតាំងពី
ជាន់ចាតុមហារាជិកា និងខ្ពស់ឡើងទៅអំពីនោះ ឈ្មោះថា
ឧប្បត្តិទេព ។ ដែលគេដឹងថា ព្រះអរហន្ត ឈ្មោះថា វិសុទ្ធិ-
ទេព ។

ក្នុងទេពទាំង ៣ នោះ ក្នុងសូត្រនេះ លោកបំណងយកឧប្បត្តិ-
ទេព ។ ឈ្មោះថា **មនុស្ស** ព្រោះជាការកកើតរបស់ព្រះមនូ ។ តែ
បុរាណាចារ្យពោលថា ឈ្មោះថា **មនុស្ស** ព្រោះជាអ្នកមានចិត្តខ្ពស់ ។
មនុស្សទាំងនោះមាន ៤ ប្រភេទ គឺ មនុស្សជម្ពូទ្វីប មនុស្សអបរគោយាន-
ទ្វីប មនុស្សឧត្តរកុរុទ្វីប មនុស្សបុព្វវិទេហទ្វីប ។ ក្នុងសូត្រនេះ លោក
បំណងយកមនុស្សជម្ពូទ្វីប ។ ឈ្មោះថា **មង្គល** ព្រោះសត្វចម្រើនរុងរឿង
ដោយគុណទាំងនេះ អធិប្បាយ សត្វដល់នូវសេចក្តីសម្រេច និងសេចក្តី
ចម្រើន ។ បទថា **អចិន្តយុំ** ប្រែថា គិតគ្នាហើយ ។ បទថា **អាកង្ខមានា**
(ប្រាថ្នា) បានដល់ បំណង ត្រូវការ សង្ឃឹម ។ បទថា **សោត្ថានំ** ប្រែថា

សួស្តី លោកអធិប្បាយថា ដែលធម៌ទាំងឡាយប្រព្រឹត្តទៅក្នុងបច្ចុប្បន្ន និង កាលខាងមុខគ្រប់យ៉ាង ស្រស់ ល្អ ស្អាត ។ បទថា **ព្រូហិ (មេត្តាត្រាស់ ប្រាប់)** បានដល់ សំដែង ប្រកាស ប្រាប់ បើកបង្ហាញ ចែក ធ្វើឲ្យងាយ ។ បទថា **មង្គលំ (មង្គល)** បានដល់ ហេតុនៃការសម្រេច ហេតុនៃសេចក្តី ចម្រើន ហេតុនៃសម្បត្តិគ្រប់យ៉ាង ។ ពាក្យថា **ឧត្តមំ (ដ៏ឧត្តុង្គឧត្តម)** បានដល់ វិសេស ប្រសើរ នាំប្រយោជន៍សុខមកឲ្យលោកទាំងពួង ដូច ពោលមកនេះ ជាការពណ៌នាតាមលំដាប់បទនៃគាថា ។

ចំណែកសេចក្តីរួមមានដូច្នេះ ទេវបុត្រនោះឯង ឃើញទេវតាក្នុងម៉ឺន ចក្រវាឡ ជួបជុំគ្នាក្នុងចក្រវាឡនេះ ព្រោះប្រាថ្នានឹងស្តាប់មង្គលបញ្ហា នាំ គ្នានិម្មិតអត្តភាពតូចៗ ១០ អង្គខ្លះ ២០ អង្គខ្លះ ៣០ អង្គខ្លះ ៤០ អង្គខ្លះ ៥០ អង្គខ្លះ ៦០ អង្គខ្លះ ៧០ អង្គខ្លះ ៨០ អង្គខ្លះ ទំហំប៉ុនចុងរោមកន្ទុយ សត្វទ្រាយ ឈរហែហមព្រះមានព្រះភាគ ដែលប្រថាប់គង់លើពុទ្ធាសនៈ ដ៏ប្រសើរដែលគេចាត់ចែងទុក បញ្ចេញពន្លឺរស្មីគ្របដណ្តប់ទេវតា មារ ព្រហ្ម ទាំងនោះ ដោយព្រះសិរី និងព្រះតេជៈ និងដឹងបរិវិតក្កៈរបស់ពួកមនុស្ស

ជម្ពូទ្វីប ដែលមិនបានមកប្រជុំក្នុងសម័យនោះ ដោយចិត្តព្រះអង្គឯង ទើបត្រាស់គាថា ដើម្បីដក់កូនសរ គឺ សេចក្ដីសង្ស័យរបស់ទេវតា និងមនុស្សទាំងឡាយថា ៖

ទេវតា និងមនុស្សដ៏ច្រើន ប្រាថ្នាសេចក្ដីសួស្ដី ទើបនាំគ្នា

គិតរកមង្គលទាំងឡាយ សូមព្រះអង្គមេត្តាត្រាស់សំដែង

មង្គលផងចុះ ព្រះអង្គ ។

បពិត្រព្រះដ៏មានព្រះភាគ ព្រះអង្គ ដែលខ្ញុំព្រះអង្គទូលសួរហើយ ដោយអនុមតិរបស់ទេវតាទាំងនោះ និងដោយអនុគ្រោះមនុស្សទាំងឡាយ មង្គលណា ដែលឧត្ដមខ្ពង់ខ្ពស់ ព្រោះនាំមកនូវប្រយោជន៍សុខដល់ខ្ញុំព្រះអង្គទាំងឡាយដោយចំណែកមួយ ប្រោសអាស្រ័យព្រះករុណាត្រាស់ប្រាប់មង្គលនោះ ដល់ខ្ញុំព្រះអង្គទាំងឡាយផង ។

## ពណ៌នាគាថាថា អសេវនា ច

ព្រះមានព្រះភាគ ទ្រង់ស្ដាប់ពាក្យរបស់ទេវបុត្រនោះ យ៉ាងនេះហើយ ទើបត្រាស់ព្រះគាថាថា **អសេវនា ច ពាលានំ** (ការមិនសេពគប់បុគ្គល

ពាល) ជាដើម ។ ក្នុងព្រះគាថានោះ បទថា **អសេវនា** (ការមិនសេពគប់) បានដល់ ការមិនគប់រក មិនចូលទៅជិត ។

បទថា **ពាលានំ** (បុគ្គលពាល) សេចក្តីថា ឈ្មោះថា ពាល ព្រោះជាអ្នករស់នៅត្រឹមតែដកដង្ហើម អធិប្បាយថា ជាអ្នករស់នៅត្រឹមដកដង្ហើមចូលដកដង្ហើមចេញ មិនរស់នៅដោយភាពជាអ្នកនៅដោយបញ្ញា ។

បទថា **បណ្ឌិតានំ** (បណ្ឌិត) សេចក្តីថា ឈ្មោះថា បណ្ឌិត ព្រោះប្រព្រឹត្តទៅ អធិប្បាយថា ប្រព្រឹត្តទៅដោយគតិ គឺ ការដឹងក្នុងប្រយោជន៍ដែលជាបច្ចុប្បន្ន និងអនាគត ។

បទថា **សេវនា** (ការគប់) បានដល់ ការគប់រក ការចូលជិត ការមានបណ្ឌិតទាំងនោះជាសំឡាញ់ មានបណ្ឌិតនោះជាមិត្រ ការប្រកបដោយបណ្ឌិតនោះ ។

បទថា **បូជា** (បូជា) បានដល់ ការសក្ការៈ គោរព រាប់អានថ្វាយបង្គំ ។

បទថា **បូជនេយ្យានំ** ប្រែថា អ្នកដែលគួរបូជា ។

បទថា **ឯតំ មង្គលមុត្តមំ (នេះជាមង្គលដ៏ឧត្តម)** សេចក្ដីថា ព្រះមានព្រះភាគទ្រង់ប្រមូលការមិនសេពគប់បុគ្គលពាល ១ ការសេពគប់រកបណ្ឌិត ១ ការបូជាបុគ្គលដែលគួរបូជា ១ ទាំងអស់ ទើបត្រាស់ថា "នេះជាមង្គលដ៏ឧត្តម" ។ លោកអធិប្បាយថា "ពាក្យណា លោកសួរថា មេត្តាត្រាស់ប្រាប់មង្គលដ៏ឧត្តមចុះ លោកចូរកាន់យកពាក្យនោះថា មង្គលដ៏ឧត្តមក្នុងប្រការនោះចុះ" ។ នេះជាការពណ៌នាបទនៃគាថានេះ ។

ចំណែកការពណ៌នាសេចក្ដីនៃបទនោះ គប្បីជ្រាបដូច្នេះ ព្រះមាន-ព្រះភាគ ទ្រង់ស្ដាប់ពាក្យរបស់ទេវបុត្រនោះយ៉ាងនេះហើយ ទើបត្រាស់ព្រះគាថានេះថា **អសេវនា ច ពាលានំ (ការមិនសេពគប់បុគ្គលពាល)** ជាដើម ។

ក្នុងគាថានោះ គាថាមាន ៤ គឺ **បុច្ឆិតគាថា អបុច្ឆិតគាថា សានុ-សន្ធិកគាថា អននុសន្ធិកគាថា** ។

បណ្ដាគាថាទាំង ៤ នោះ គាថាដែលទ្រង់ត្រូវអ្នកសួរ សួរហើយទើបត្រាស់ ឈ្មោះថា **បុច្ឆិតគាថា** បានក្នុងប្រយោគជាដើមយ៉ាងនេះថា

**បុច្ឆាមិ តំ គោតម ភូរិបញ្ញ កថំករោ សាវកោ សាធុ ហោតិ** បពិត្រព្រះគោតម ទ្រង់មានបញ្ញាធំទូលាយដូចផែនដី ខ្ញុំម្ចាស់សូមសួរព្រះអង្គ សាវកធ្វើយ៉ាងណា ទើបជាមនុស្សល្អ និងប្រយោគថា **កថំ នុ ត្វំ មារិស ឱឃមតរិ** ម្នាលអ្នកនិរទុក្ខ លោកឆ្លងឱឃៈបានយ៉ាងណា ។

គាថាដែលព្រះអង្គមិនត្រូវបានសួរ តែត្រាស់ដោយព្រះអជ្ឈាស្រ័យរបស់ព្រះអង្គឯង ឈ្មោះថា **អបុច្ឆិតគាថា** បានក្នុងប្រយោគជាដើមយ៉ាងនេះថា **យំ បរេ សុខតោ អាហុ តទរិយា អាហុ ទុក្ខតោ** អ្នកដទៃៗពោលវត្ថុណាថាជាសុខ ព្រះអរិយៈទាំងឡាយពោលវត្ថុនោះថាជាទុក្ខ ។ គាថារបស់ព្រះពុទ្ធទាំងឡាយសូម្បីទាំងអស់ ឈ្មោះថា **សានុសន្ធិកគាថា** ព្រោះព្រះបាលីថា **សនិទានាហំ ភិក្ខវេ ធម្មំ ទេសេស្សាមិ** ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសំដែងធម៌មាននិទាន គឺ ហេតុ ដូច្នេះ ។ ដែលឈ្មោះថា **អននុសន្ធិកគាថា** (គាថាមិនមានហេតុ) មិនមានក្នុងសាសនានេះ ។ ក៏បណ្ដាគាថាដូចពោលមកនេះ គាថាមានឈ្មោះថា **បុច្ឆិតគាថា** ព្រោះជាគាថា ដែលព្រះមានព្រះភាគត្រូវទេវតាទូលសួរហើយ ទើបត្រាស់

តប ។ ក៏គាថានេះ ប្រាប់បុគ្គលដែលមិនគួរគប់រក ក្នុងបុគ្គលដែលគួរគប់រក និងមិនគួរគប់រក ហើយទើបប្រាប់បុគ្គលដែលគួរគប់រក ប្រៀបដូចបុរសអ្នកឆ្លាត ដឹងផ្លូវ ដឹងទីដែលមិនមែនផ្លូវ ត្រូវសួរដល់ផ្លូវ ទើបប្រាប់ផ្លូវដែលគួរវៀរជាមុន ជាខាងក្រោយទើបប្រាប់ផ្លូវដែលគួរកាន់យកថា ក្នុងទីត្រង់នោះមានផ្លូវបំបែក ២ ។ ក្នុងផ្លូវបំបែក ២ នោះ ពួកលោកចូរវៀរផ្លូវខុសចេញ ហើយកាន់យកផ្លូវខាងស្តាំ ដូច្នោះ ។ ក៏ព្រះមានព្រះភាគទ្រង់ជាបុរសឆ្លាតក្នុងផ្លូវ ដូចដែលត្រាស់ទុកថា ៖

តិស្សៈ ពាក្យថា បុរសអ្នកឆ្លាតក្នុងផ្លូវ នេះ ជាឈ្មោះរបស់តថាគតអរហន្តសម្មាសម្ពុទ្ធ ។ ពិតហើយ តថាគតអរហន្តសម្មាសម្ពុទ្ធនោះ ត្រាស់ដឹងលោកនេះ ត្រាស់ដឹងលោកដទៃ ត្រាស់ដឹងប្រយោជន៍ក្នុងបច្ចុប្បន្ន ត្រាស់ដឹងប្រយោជន៍ក្នុងបរលោក ត្រាស់ដឹងដែនដីរបស់មច្ចុ ទាំងត្រាស់ដឹងទីមិនមែនដែនដីរបស់មច្ចុ ត្រាស់ដឹងអន្ទាក់របស់មារ ទាំងត្រាស់ដឹងទីមិនមែនអន្ទាក់របស់មារ ។

ព្រោះហេតុនោះ ព្រះមានព្រះភាគត្រាស់ប្រាប់ដល់បុគ្គលដែលមិនគួរគប់រកមុន ទើបត្រាស់ថា ការមិនសេពគប់បុគ្គលពាល និងការសេពគប់បុគ្គលជាបណ្ឌិត ។ ពិតណាស់ បុគ្គលពាលទាំងឡាយ មិនគួរសេពគប់ មិនគួរចូលជិត ដូចផ្លូវដែលត្រូវលះបង់ តពីនោះ ក៏គួរសេពគប់ គួរចូលជិតបណ្ឌិត ដូចផ្លូវដែលគួរកាន់យក ។ អ្នកពោលជំទាស់ពោលថា ក៏ព្រោះហេតុអ្វី ព្រះមានព្រះភាគ កាលត្រាស់មង្គល ទើបត្រាស់ការមិនសេពគប់បុគ្គលពាល និងការសេពគប់បណ្ឌិតមុន ។ សូមប្រាប់ដូច្នេះ ។ ព្រោះហេតុដែលពួកទេវតា និងមនុស្សប្រកាន់ការឃើញ ថាជាមង្គល ក្នុងវត្ថុដែលឃើញហើយជាដើមនេះ ដោយការសេពគប់បុគ្គលពាល ទាំងការសេពគប់បុគ្គលពាលនោះក៏មិនជាមង្គល ដូច្នោះ ព្រះមានព្រះភាគ កាលទ្រង់តិះដៀលការសេពគប់ជាមួយបុគ្គលដែលមិនមែនជាកល្យាណមិត្រ ដែលកាត់ប្រយោជន៍ទាំងលោកនេះ និងលោកខាងមុខ ហើយទ្រង់សរសើរការសមាគមជាមួយកល្យាណមិត្រ ដែលឲ្យសម្រេចប្រយោជន៍ក្នុងលោកទាំងពីរ ទើបត្រាស់ការមិនសេពគប់បុគ្គលពាល និងសេពគប់បណ្ឌិតជាមុន ដល់

ទេវតា និងមនុស្សទាំងនោះ ។

សត្វទាំងឡាយគ្រប់ប្រភេទ អ្នកប្រកបដោយអកុសលកម្មបថ មានបាណាតិបាតជាដើម ឈ្មោះថា **ពាល** ក្នុងចំនួនពាល និងបណ្ឌិតនោះ ។ បុគ្គលពាលទាំងនោះ ដឹងបានក៏ដោយអាការទាំង ៣ ដូចដែលព្រះមានព្រះភាគត្រាស់ទុក ។ ក្នុងព្រះសូត្រថា "ម្នាលភិក្ខុទាំងឡាយ ពាលលក្ខណៈរបស់បុគ្គលពាល ៣ ទាំងនេះ" ។ ម្យ៉ាងទៀត គ្រូទាំង ៦ មានបូរណកស្សបៈជាដើម និងសត្វដទៃៗ ទាំងនេះ គឺ **ទេវទត្ត កោកាលិកៈ កដមោទកៈ តិស្សខណ្ឌាទេវីបុត្រ សមុទ្ទទត្តៈ នាងចិញ្ចមាណវិកា** ជាដើម និង **បងប្រុសរបស់ទីឃវិទៈ** ក្នុងគ្រាអតីត គប្បីជ្រាបថា **ពាល** ។

ពាលទាំងនោះ រមែងញុំាងខ្លួនឯង និងពួកអ្នកដែលធ្វើតាមពាក្យរបស់ខ្លួនឲ្យវិនាស ដោយការឃើញដែលខ្លួនកាន់យកមិនល្អ ដូចផ្ទះដែលត្រូវភ្លើងឆេះ ។ ដូចបងប្រុសរបស់ទីឃវិទៈ ធ្លាក់ចុះទៅក្នុងនរក ដោយអត្តភាពប្រមាណ ៦០ យោជន៍ ភ្លើងឆេះនៅក្នុងមហានរក រហូតអស់ ៤ ពុទ្ធន្តរ និងដូចត្រកូល ៥០០ ត្រកូល ដែលពេញចិត្តក្នុងទិដ្ឋិ (ការឃើញ)

របស់បងប្រុសរបស់ទីឃៈវិទៈនោះ គេនៅរួមជាសំឡាញ់របស់បងប្រុសរបស់ទីឃៈវិទៈនោះឯង ក៏ឆេះនៅក្នុងមហានរក ដូច្នោះ ។ សមដូចដែលព្រះមានព្រះភាគត្រាស់ទុកដូច្នេះថា ៖

ម្នាលភិក្ខុទាំងឡាយ ភ្លើងឆេះរាលពីផ្ទះបបុស ឬផ្ទះស្មៅ រមែងឆេះសូម្បីផ្ទះកំពូល នូវជញ្ជាំងទាំងខាងក្រៅ និងខាងក្នុងដែលការពារខ្យល់ ជាប់ដោយគន្លឹះ បិទបង្អួចបាន យ៉ាងណា ម្នាលភិក្ខុទាំងឡាយ ភ័យគ្រប់ប្រភេទ រមែងកើតឡើងដូច្នោះដូចគ្នា ភ័យទាំងអស់នោះកើតពីបុគ្គលពាល មិនកើតពីបណ្ឌិត ។ ឧបទ្រវៈគ្រប់យ៉ាងរមែងកើត ។ល។ ឧបសគ្គគ្រប់យ៉ាងរមែងកើត ។ល។ មិនកើតពីបណ្ឌិត ។ ម្នាលភិក្ខុទាំងឡាយ ដូច្នោះឯង បុគ្គលពាលជាភ័យ បណ្ឌិតមិនជាភ័យ បុគ្គលពាលជាឧបទ្រវៈ បណ្ឌិតមិនជាឧបទ្រវៈ បុគ្គលពាលជាឧបសគ្គ បណ្ឌិតមិនជាឧបសគ្គ ដូច្នេះ ។

មយ៉ាងទៀត បុគ្គលពាលដូចត្រីស្អុយ អ្នកសេពគប់បុគ្គលពាលនោះ

ក៏ដូចស្លឹកឈើដែលខ្ចប់ត្រីស្អុយ រមែងប្រសព្វភាវៈដែលវិញ្ញូជនលះបង់ បោល និងវៀរវៀស ។ សមដូចដែលព្រះមានព្រះភាគត្រាស់ទុកថា ៖

នរជនណាខ្ចប់ត្រីស្អុយដោយស្បូវ ស្លឹកស្បូវរបស់នរជន
នោះ ក៏មានក្លិនស្អុយជាប់ទៅផង ការសេពគប់បុគ្គលពាល
ក៏ដូច្នោះ ។

ម្យ៉ាងទៀត កាលស្តេចសក្កៈទេវរាជទ្រង់ប្រទានពរ អកិត្តិបណ្ឌិត ក៏ពោលយ៉ាងនេះថា ៖

បុគ្គលមិនគួរសេពគប់បុគ្គលពាល មិនគួរស្តាប់ មិនគួរ
នៅរួមជាមួយបុគ្គលពាល មិនគប្បីធ្វើការចរចារប្រាស្រ័យ
ជាមួយបុគ្គលពាល និងមិនគួរពេញចិត្ត (ក្នុងបុគ្គលពាល
នោះ) ។

សក្កទេវរាជត្រាស់សួរថា

បពិត្រកស្សបៈ បុគ្គលពាលបានធ្វើអ្វីឲ្យដល់លោកឬ សូម
លោកចូរប្រាប់ហេតុនោះដល់ខ្ញុំ ព្រោះហេតុអ្វី លោកទើប

មិនប្រាថ្នាឃើញ បុគ្គលពាល ។

អកិត្តិបណ្ឌិតឆ្លើយថា

បុគ្គលពាលមានបញ្ញាអន់ រមែងណែនាំវត្ថុដែលមិនគួរណែនាំ រមែងបបួលក្នុងវត្ថុដែលមិនមែនជាធុរៈ ការណែនាំអាក្រក់ ជាការល្អសម្រាប់បុគ្គលពាល គេពោលប្រាប់ដោយល្អ ក៏ក្រោធ បុគ្គលពាលនោះ មិនដឹងវិន័យ ការមិនបានឃើញគេក៏ជាល្អ ។

ព្រះមានព្រះភាគ កាលទ្រង់តិះដៀលការសេពគប់បុគ្គលពាលដោយអាការទាំងពួងយ៉ាងនេះ ទើបត្រាស់ថា **ការមិនសេពគប់បុគ្គលពាល ជាមង្គល** ឥឡូវនេះ កាលទ្រង់សរសើរការសេពគប់បណ្ឌិត ទើបត្រាស់ថា **ការសេពគប់បណ្ឌិត ជាមង្គល** ។ សត្វគ្រប់ប្រភេទ អ្នកប្រកបដោយកុសលកម្មបថ ១០ មានចេតនាវៀរចាកបាណាតិបាតជាដើម ឈ្មោះថា **បណ្ឌិត** ក្នុងពួកបុគ្គលពាល និងបណ្ឌិតនោះ ។

បណ្ឌិតទាំងនោះនឹងគប្បីដឹងបាន ក៏ដោយអាការទាំង ៣ ដូចដែល

ព្រះមានព្រះភាគត្រាស់ទុក ។ ក្នុងព្រះសូត្រថា ម្នាលភិក្ខុទាំងឡាយ ៣ ប្រការទាំងនេះ ជាបណ្ឌិតលក្ខណៈរបស់បណ្ឌិត ។ ម្យ៉ាងទៀត ព្រះពុទ្ធ ព្រះបច្ចេកពុទ្ធ ព្រះអសីតិមហាសាវក ព្រះសាវកដទៃរបស់តថាគត និង បណ្ឌិត មានគ្រូសុនេត្តៈ គ្រូមហាគោវិន្ទៈ វិធុរបណ្ឌិត សរភង្គតាបស មហោសថ សុតសោមបណ្ឌិត ព្រះបាទនិមិរាជ អយោឃរកុមារ និង អកិត្តិបណ្ឌិតជាដើម គប្បីជ្រាបថា **បណ្ឌិត** ។

បណ្ឌិតទាំងនោះ ជាអ្នកកម្ចាត់ភ័យ ឧបទ្រវៈ និងឧបសគ្គបានគ្រប់យ៉ាង ដល់ពួកអ្នកធ្វើតាមពាក្យរបស់ខ្លួន ដូចជាការពារគ្នាបានក្នុងវេលាមានភ័យ ដូចជាដួងប្រទីបក្នុងវេលាងងឹត ដូចជាបានបាយទឹកជាដើម ក្នុងវេលាត្រូវទុក្ខ មានសេចក្ដីស្រេកឃ្លានជាដើមគ្របសង្កត់ ។ ពិតហើយ អាស្រ័យតថាគត ពួកទេវតា និងមនុស្សរាប់ប្រមាណមិនបាន នាំគ្នាសម្រេចធម៌ជាទីអស់អាសវៈ តាំងនៅក្នុងព្រហ្មលោក តាំងនៅក្នុងទេវលោក កើតក្នុងសុគតិ ត្រកូល ៨០.០០០ ត្រកូល ធ្វើចិត្តឲ្យជ្រះថ្លាក្នុងព្រះសារីបុត្តត្ថេរៈ និងទំនុកបម្រុងព្រះថេរៈដោយបច្ច័យ ៤ ក៏បានកើតក្នុង

ទេវលោក ។ ត្រកូលទាំងឡាយ ធ្វើចិត្តឲ្យជ្រះថ្លាក្នុងព្រះមហាសាវកទាំងឡាយ រាប់តាំងអំពីព្រះមហាមោគ្គល្លាន ព្រះមហាកស្សបៈជាដើម ក៏ដូច្នោះដូចគ្នា ។ សាវកទាំងឡាយរបស់គ្រូសុនេត្តៈ ពួកខ្លះក៏កើតក្នុងព្រហ្មលោក ពួកខ្លះក៏ចូលជាសំឡាញ់របស់ពួកទេវតាជាន់បរនិម្មិតវសវត្តី ។ល។ ពួកខ្លះក៏ចូលដល់ភាពជាសំឡាញ់របស់គហបតីមហាសាល ។ សូម្បីព្រះមានព្រះភាគ ក៏បានត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ ភ័យមិនមានអំពីបណ្ឌិត មិនមានឧបទ្រវៈពីបណ្ឌិត មិនមានឧបសគ្គពីបណ្ឌិត ។

មួយទៀត បណ្ឌិតដូចជាក្លិនក្រអូប មានក្រឹស្នា និងផ្កាឈើជាដើម បុគ្គលសេពគប់ជាមួយបុគ្គលបណ្ឌិត ក៏ដូចជាស្លឹកឈើដែលខ្ចប់របស់ក្រអូប មានក្រឹស្នា និងផ្កាឈើជាដើម នៅប្រសព្វនឹងភាវៈដែលវិញ្ញូជនសរសើរ និងពេញចិត្ត ។ សូម្បីព្រះមានព្រះភាគ ក៏បានត្រាស់ទុកដូច្នេះថា ៖

នរជនណាខ្ចប់ក្រឹស្នាដោយស្លឹកឈើ ស្លឹកឈើរបស់នរជន
នោះក៏ចោលក្លិនក្រអូបផ្សាយទៅ ការគប់រកបណ្ឌិតក៏ដូច្នោះ
ដូចគ្នា ។

មួយទៀត កាលសក្កទេវរាជប្រទានពរ អកិត្តិបណ្ឌិត ក៏ពោលយ៉ាង នេះថា ៖

បុគ្គលគប្បីសេពគប់បណ្ឌិត គួរស្តាប់បណ្ឌិត គួរនៅរួម ជាមួយបណ្ឌិត គួរធ្វើការសន្ទនាប្រាស្រ័យជាមួយបណ្ឌិត និងគួរពេញចិត្តក្នុងបណ្ឌិតនោះ ។

សក្កទេវរាជត្រាស់សួរថា ៖

បពិត្រកស្សបៈ បណ្ឌិតបានធ្វើអ្វីឲ្យដល់លោកឬ សូម លោកចូរប្រាប់ហេតុនោះដល់ខ្ញុំ ព្រោះហេតុអ្វី លោកទើប ប្រាថ្នាជួបបណ្ឌិត។

អកិត្តិបណ្ឌិតឆ្លើយថា ៖

បណ្ឌិតរមែងណែនាំវត្ថុដែលគួរណែនាំ មិនបបួលទៅក្នុង វត្ថុដែលមិនមែនជាធុរៈ ការណែនាំល្អ ជាសេចក្តីល្អរបស់ បណ្ឌិត គេត្រូវពោលដោយល្អ ក៏មិនក្រោធ បណ្ឌិតនោះ ដឹងវិន័យ សមាគមជាមួយបណ្ឌិតនោះបាន ជាការល្អ ។

ព្រះមានព្រះភាគ កាលទ្រង់សរសើរការសេពគប់បណ្ឌិត ដោយអាការទាំងពួងយ៉ាងនេះ ទើបត្រាស់ថា **ការសេពគប់បណ្ឌិតជាមង្គល** ។ ឥឡូវនេះ កាលនឹងទ្រង់សរសើរការបូជាបុគ្គលអ្នកចូលដល់ភាពជាអ្នកគួរបូជា ដោយលំដាប់ ដោយការមិនសេពគប់ជាមួយបុគ្គលពាល និងការសេពគប់បណ្ឌិតនោះ ទើបត្រាស់ថា **ការបូជាអ្នកដែលគួរបូជា ជាមង្គល** ។ ព្រះមានព្រះភាគ ឈ្មោះថា **អ្នកដែលគួរបូជា** ព្រោះទ្រង់វៀរចាកទោសគ្រប់យ៉ាង និងព្រោះទ្រង់ប្រកបដោយគុណគ្រប់យ៉ាង និងបន្ទាប់អំពីនោះ ក៏ព្រះបច្ចេកពុទ្ធ ព្រះអរិយសាវកទាំងឡាយ ឈ្មោះថា អ្នកដែលគួរបូជា ក្នុងពាក្យថា **បូជនេយ្យានំ (បុគ្គលគួរបូជា)** នោះ ។ ពិតហើយ ការបូជាបូជនេយ្យបុគ្គលទាំងនោះ សូម្បីតិចតួច ក៏ជាប្រយោជន៍សុខអស់កាលដ៏យូរ ។ ក្នុងសេចក្តីនេះ មានរឿងនាយសុមនមាលាការ និងព្រះនាងមល្លិកាជាដើម ជាគ្រឿងឧបមា ។ ក្នុង ២ រឿងនោះ និងពោលតែរឿងមួយ ល្មមជាគ្រឿងសាធក: ។

សេចក្តីថា ព្រឹកថ្ងៃមួយ ព្រះមានព្រះភាគទ្រង់អន្តរាវាសក:ហើយ

ទ្រង់កាន់បាត្រចីវរ ស្តេចចូលទៅបិណ្ឌបាតក្នុងក្រុងរាជគ្រឹះ ខណៈនោះ នាយក្រងផ្កាឈើឈ្មោះសុមនមាលាការ កំពុងដើរកាន់ផ្កាឈើដើម្បីថ្វាយ ព្រះបាទពិម្ពិសាររសេនីយ៍ក្នុងដែនមគធៈ បានឃើញព្រះមានព្រះភាគស្តេច ចូលដល់ទ្វារព្រះនគរ ទ្រង់ផូរផង់ គួរជ្រះថ្លា ប្រដាប់ដោយព្រះមហាបុរិស លក្ខណៈ ៣២ ប្រការ និងអនុព្យញ្ជនៈ ៨០ ប្រការ រុងរឿងដោយព្រះពុទ្ធ សិរី លុះឃើញហើយ គេក៏គិតថា ព្រះរាជាទ្រង់ទទួលផ្កាឈើហើយ ក៏នឹង គប្បីប្រទានទ្រព្យ ១០០ ឬ ១.០០០ ក៏ការនោះ នឹងជាសេចក្តីសុខត្រឹម តែលោកនេះប៉ុណ្ណោះ ។ តែការបូជាព្រះមានព្រះភាគ រមែងនឹងមានផល ប្រមាណមិនបាន រាប់មិនបាន នឹងនាំប្រយោជន៍សុខមកឲ្យអស់កាលយូរ ណេ្ហីយចុះ យើងនឹងបូជាព្រះមានព្រះភាគ ដោយផ្កាឈើទាំងនេះ ដូច្នោះ គេមានចិត្តជ្រះថ្លា ចាប់ផ្កាឈើមួយក្តាប់បាចទៅចំពោះព្រះភក្ត្រព្រះមាន-ព្រះភាគ ។ ផ្កាឈើទាំងឡាយអណ្តែតតាមអាកាស ប្រតិស្ឋានជាពិតាន ផ្កានៅខាងលើព្រះមានព្រះភាគ ។ នាយមាលាការឃើញអានុភាពនោះ ក៏ មានចិត្តជ្រះថ្លា ទើបបាចផ្កាមួយក្តាប់ទៀត សូម្បីផ្កាទាំងនោះក៏ទៅប្រតិស្ឋាន

ជាក្រោះផ្កាឈើ ។ នាយមាលាការបាចផ្កាយ៉ាងនេះអស់ ៨ ក្ដាប់ ផ្កាឈើទាំងនោះ ក៏ទៅប្រតិស្ឋានជាផ្ទះកំពូលផ្កាឈើ ។

ព្រះមានព្រះភាគ ប្រថាប់នៅក្នុងផ្ទះកំពូល មហាជនក៏ប្រជុំគ្នា ។ ព្រះមានព្រះភាគទតឃើញនាយមាលាការ ក៏ទ្រង់ធ្វើអាការញញឹមឲ្យប្រាកដ ព្រះអានន្ទត្ថេរក៏ទូលសួរដល់ហេតុដែលទ្រង់ញញឹម ដោយគិតថា ព្រះពុទ្ធទាំងឡាយ មិនមានហេតុ មិនមានបច្ច័យ នឹងមិនទ្រង់ញញឹមឲ្យប្រាកដ ។ ព្រះមានព្រះភាគត្រាស់ថា អានន្ទ នាយមាលាការនេះ នឹងត្រាច់ទៅក្នុងទេវតា និងមនុស្ស ១០០.០០០ កប្ប ដោយអនុភាពនៃការបូជានេះ ក្នុងទីបំផុត ក៏នឹងបានជាព្រះបច្ចេកពុទ្ធ នាមថា **សុមនិស្សរៈ** ត្រាស់ចប់ ក៏បានត្រាស់ព្រះគាថានេះ ដើម្បីទ្រង់សំដែងធម៌ថា ៖

បុគ្គលធ្វើកម្មណាហើយ មិនក្ដៅក្រហាយក្នុងកាលជាខាង
ក្រោយ បុគ្គលមានចិត្តរីករាយហើយសោយផលនៃកម្មណា
កម្មនោះ បានធ្វើហើយល្អ ។

ចប់គាថា សត្វ ៨៤.០០០ បានសម្រេចធម៌ ។ ការបូជាបូជានេយ្យ-

បុគ្គលទាំងនោះសូម្បីតិចតួច គប្បីជ្រាបថា មានប្រយោជន៍សុខអស់កាលយូរ ដោយប្រការដូច្នេះ ។

ក៏ការបូជានោះ ជាអាមិសបូជា និងពោលទៅថ្វីក្នុងបដិបត្តិបូជា ។ ព្រោះកុលបុត្រពួកណា បូជាព្រះមានព្រះភាគ ដោយការទទួលសរណគមន៍ និងសិក្ខាបទ ដោយការសមាទានអដ្ឋឧបោសថ និងដោយគុណទាំងឡាយរបស់ខ្លួន មានចតុប្បារិសុទ្ធិសីលជាដើម ។ នរណានឹងពណ៌នាផលនៃការបូជារបស់កុលបុត្រទាំងនោះបាន ។ ព្រោះថា កុលបុត្រទាំងនោះ លោកពោលថា "បូជាព្រះតថាគតដោយការបូជាដ៏ឧត្តុង្គឧត្តម" ។ ដូចដែលព្រះមានព្រះភាគត្រាស់ទុកថា ៖

ម្នាលអានន្ទ អ្នកណា មិនថាជាភិក្ខុ ភិក្ខុនី ឧបាសក
ឬឧបាសិកា ជាអ្នកបដិបត្តិធម៌សមគួរដល់ធម៌ បដិបត្តិ
ដោយពេញចិត្ត ប្រព្រឹត្តតាមធម៌ បុគ្គលនោះ ឈ្មោះ
ថា សក្ការៈ គោរព រាប់អាន បូជា កោតក្រែង ថ្វាយ
បង្គំ តថាគតដោយការបូជាដ៏ខ្ពង់ខ្ពស់ ។

ការបូជាសូម្បីព្រះបច្ចេកពុទ្ធ និងព្រះអរិយសាវក ក៏នាំមកនូវប្រយោជន៍សុខ គប្បីជ្រាបតាមន័យនេះ ។

មួយទៀត សម្រាប់គ្រហស្ថ គប្បីជ្រាប បូជនេយ្យបុគ្គល ក្នុងប្រការនេះយ៉ាងនេះ គឺ បុគ្គលដែលចម្រើន ទាំងបងប្រុស ទាំងបងស្រី ឈ្មោះថា បូជនេយ្យបុគ្គលរបស់ប្អូន មាតាបិតា ជាបូជនេយ្យបុគ្គលរបស់បុត្រ ស្វាមី ឪពុកក្មេក ម្តាយក្មេក ជាបូជនេយ្យបុគ្គលរបស់កុលធីតាទាំងឡាយ ព្រោះថា ការបូជាបូជនេយ្យបុគ្គលសូម្បីទាំងនោះ ជាមង្គលនោះឯង ព្រោះរាប់ថា ជាកុសលធម៌ និងព្រោះជាហេតុចម្រើនអាយុជាដើម ។ ព្រះមានព្រះភាគ មានព្រះពុទ្ធតម្រាស់ទុកដូច្នេះថា “ជនទាំងនោះ នឹងជាអ្នកឧបត្ថម្ភមាតា ឧបត្ថម្ភបិតា ឧបត្ថម្ភសមណៈ ឧបត្ថម្ភព្រាហ្មណ៍ ជាអ្នកបូជាអ្នកធំក្នុងត្រកូល និងកាន់យកកុសលធម៌នេះបដិបត្តិ ក៏នឹងចម្រើនទាំងអាយុ និងចម្រើនទាំងវណ្ណៈ ព្រោះហេតុសមាទានកុសលធម៌ទាំងនេះ” ជាដើម ។

ឥឡូវនេះ ព្រោះហេតុដែលខ្ញុំតាំងមាតិកាទុកថា ពោលពីសមុដ្ឋាន

*(ហេតុដែលកើតមង្គល) ហើយកំណត់មង្គលនោះ និងបង្ហាញការបូជានោះ ជាមង្គល ដូច្នោះ ទើបសូមបញ្ជាក់ដូច្នេះ ។ ព្រះមានព្រះភាគត្រាស់មង្គលនៃគាថានេះទុក ៣ មង្គល គឺ **ការមិនសេពគប់បុគ្គលពាល , ការសេពគប់បុគ្គលជាបណ្ឌិត និងការបូជាបុគ្គលដែលគួរបូជា** ។ ដោយប្រការដូច្នេះ ។ ក្នុងមង្គលទាំង ៣ នោះ គប្បីជ្រាបថា ការមិនសេពគប់បុគ្គលពាល ឈ្មោះថា ជាមង្គល ព្រោះជាហេតុនៃប្រយោជន៍ក្នុងលោកទាំងពីរ ហេតុការពារភ័យ មានភ័យកើតអំពីបុគ្គលពាលជាបច្ច័យជាដើម ការសេពគប់បណ្ឌិត និងការបូជាបុគ្គលដែលគួរបូជា ឈ្មោះថា ជាមង្គល ព្រោះជាហេតុនៃនិព្វាន និងសុគតិ ដោយន័យដូចពោលទុកហើយក្នុងការពណ៌នាសេចក្តីបន្ថែមនៃផលក្នុងការសេពគប់បណ្ឌិត និងការបូជាបុគ្គលដែលគួរបូជានោះឯង ។ តែខ្ញុំមិនទាន់បានសំដែងមាតិកាតពីនោះទៅ នឹងកំណត់សេចក្តីដែលជាមង្គលយ៉ាងនេះ ទើបបង្ហាញសេចក្តីប្រការនោះជាមង្គល ។*

ចប់សេចក្តីពណ៌នាគាថានេះថា អសេវនា ច ពាលានំ

## ពណ៌នាគាថាថា បដិរូបទេសវាសោ ច

ព្រះមានព្រះភាគ សូម្បីត្រូវទេវបុត្រទូលសូមមង្គលតែមួយថា ព្រូហិ **មង្គលមុត្តមំ** សូមទ្រង់មេត្តាប្រោសត្រាស់ប្រាប់មង្គលដ៏ឧត្តម តែក៏ត្រាស់ដល់ ៣ មង្គល ដោយគាថាមួយ ប្រៀបដូចបុរសចិត្តទូលាយ ត្រូវសូមតិចតែឲ្យច្រើន ក្រៃលែងជាងនោះ ក៏ទ្រង់ផ្ដើមនឹងត្រាស់មង្គលដ៏ច្រើនទៀតដោយគាថាទាំងឡាយថា **បដិរូបទេសវាសោ ច** ជាដើម ក៏ព្រោះទេវតាទាំងឡាយប្រាថ្នាស្ដាប់ ព្រោះមង្គលទាំងឡាយមានហើយ និងព្រោះមង្គលណាៗ ជាគុណដល់សត្វណាៗ ទ្រង់មានពុទ្ធបំណងនឹងទ្រង់ប្រកបសត្វនោះៗទុកក្នុងមង្គលនោះៗ ។ បណ្ដាគាថាទាំងនោះ នឹងពោលក្នុងគាថាដំបូងមុន ។ បទថា **បដិរូបោ** ប្រែថា សមគួរ ។ ឱកាសជាទីនៅអាស្រ័យរបស់សត្វទាំងឡាយគ្រប់កន្លែង មិនថាស្រុកក្ដី និគមក្ដី នគរក្ដី ជនបទក្ដី ឈ្មោះថា **ទេសៈ** ។ ការនៅអាស្រ័យក្នុងទេសៈនោះ ឈ្មោះថា **វាសៈ** ។ បទថា **បុព្វេ** ប្រែថា អំពីមុន គឺ ក្នុងជាតិដែលកន្លងមកហើយ ។ ភាពជាអ្នកមានកុសលដែលសន្សំហើយ ឈ្មោះថា **ភាពជាអ្នកមានបុណ្យដែល**

ធ្វើទុកហើយ ។ ចិត្ត ឬអត្តភាពទាំងអស់ ហៅថា អត្តៈ ការតាំង គឺ ការប្រកបខ្លួនទុកដោយប្រពៃ ឈ្មោះថា សម្មាបណិធិ អធិប្បាយថា ការតាំងទុក ។ បទក្រៅពីនោះ មានន័យដូចពោលទុកហើយនោះឯង ។ នេះជាការពណ៌នាបទក្នុងគាថាជំបូងនោះ ។

ចំណែកការពណ៌នាសេចក្តី គប្បីជ្រាបដូច្នេះ ។ ក្នុងប្រទេសណា បរិស័ទ ៤ ចារិកហើយ នៅបំពេញបុញ្ញកិរិយាវត្ថុ មានទានជាដើម នវង្គ-សត្ថុសាសន៍នៅរុងរឿង ។ ប្រទេសនោះ ឈ្មោះថា បដិរូបទេស ការនៅអាស្រ័យក្នុងបដិរូបទេសៈនោះ ត្រាស់ថា "ជាមង្គល" ។ ព្រោះជាបច្ច័យដល់ការធ្វើបុណ្យរបស់សត្វទាំងឡាយ ។ ក្នុងប្រការនេះ មានអ្នកនេសាទដែលចូលទៅកាន់កោះសីហឡៈជាដើម ជាតួយ៉ាង ។

ន័យមួយទៀត ប្រទេសជាទីត្រាស់ដឹងព្រះពោធិញ្ញាណ (ទីត្រាស់ដឹងជាព្រះពុទ្ធ ហៅពោធិមណ្ឌលស្ថាន) ប្រទេសដែលទ្រង់ប្រកាសព្រះ-ធម្មចក្ករបស់ព្រះមានព្រះភាគ ប្រទេស គឺ គល់ស្វាយរបស់នាយគណ្ឌៈដែលទ្រង់សំដែងយមកប្បាដិហារ្យ កម្ចាត់នូវសេចក្តីស្រវឹងរបស់ពួកតិរ្ថិយ៍

ទាំងពួង ក្នុងកណ្តាលបរិស័ទប្រមាណ ១២ យោជន៍ ប្រទេសដែលស្តេច ចុះចាកទេវលោក ឬក៏ប្រទេសដទៃណា ដែលជាទីប្រថាប់នៅរបស់ព្រះពុទ្ធ មានក្រុងសាវត្ថី ក្រុងរាជគ្រឹះជាដើម ប្រទេសនោះឈ្មោះថា **បដិរូបទេស** ការនៅអាស្រ័យក្នុងបដិរូបទេសៈនោះ ត្រាស់ថា "ជាមង្គល" ព្រោះជាបច្ច័យដល់ការបានអនុត្តរិយៈ ៦ របស់សត្វទាំងឡាយ ។

ន័យម្យ៉ាងទៀត ទិសបូព៌ តាំងអំពីកជង្គលនិគមចុះមកដល់មហាសាលា ជុំវិញខាងក្រៅជាបច្ចន្តិមជនបទ ជុំវិញខាងក្នុងជាមជ្ឈិមជនបទ ។ ទិសអាគ្នេយ៍ តាំងពីស្ទឹងសល្លវតីចុះមក ខាងក្រៅជុំវិញជាបច្ចន្តិមជនបទ ជុំវិញខាងក្នុងជាមជ្ឈិមជនបទ ។ ទិសទក្សិណ តាំងពីសេតកណ្ណិកនិគមចុះមក ជុំវិញខាងក្រៅជាបច្ចន្តិមជនបទ ជុំវិញខាងក្នុងជាមជ្ឈិមជនបទ ។ ទិសខាងលិច តាំងពីស្រុកព្រាហ្មណ៍ ឈ្មោះថូណៈ ជុំវិញខាងក្រៅជាបច្ចន្តិមជនបទ ជុំវិញខាងក្នុងជាមជ្ឈិមជនបទ ។ ទិសឧត្តរ តាំងពីភ្នំឧសីរធជៈចុះមក ជុំវិញខាងក្រៅជាបច្ចន្តិមជនបទ ជុំវិញខាងក្នុងជាមជ្ឈិមជនបទ ។ នេះជាមជ្ឈិមប្រទេស បណ្តោយ ៣០០ យោជន៍ ទទឹង ២៥០

យោជន៍ ដោយជុំវិញ ៩០០ យោជន៍ ។ មជ្ឈិមប្រទេសនេះ ឈ្មោះថា បដិរូបទេស ។

ស្តេចចក្រពត្តិទាំងឡាយ អ្នកគ្រប់គ្រងឥស្សរិយាធិបតេយ្យនៃទ្វីបធំទាំង ៤ ទ្វីបតូច ២.០០០ ទ្វីប ទ្រង់ឧប្បត្តិឡើងក្នុងបដិរូបទេសៈនោះ ព្រះមហាសាវកទាំងឡាយ មានព្រះសារីបុត្រ និងព្រះមោគ្គល្លានជាដើម បំពេញបារមីមក ១ អសង្ខេយ្យ ១០០.០០០ កប្ប ក៏កើតក្នុងបដិរូប-ទេសៈ ព្រះបច្ចេកពុទ្ធទាំងឡាយ បំពេញបារមីមក ២ អសង្ខេយ្យ និង ១០០.០០០ កប្ប ក៏កើតក្នុងបដិរូបទេសៈនោះ ព្រះសម្មាសម្ពុទ្ធទាំងឡាយ បំពេញបារមី ៤ អសង្ខេយ្យនិង ១០០.០០០ កប្បខ្លះ ៨ អសេង្ខយ្យនិង ១០០.០០០ កប្បខ្លះ ១៦ អសង្ខេយ្យនិង ១០០.០០០ កប្បខ្លះ ក៏ស្តេចឧប្បត្តិក្នុងបដិរូបទេសៈនោះ ។ បណ្តាលោកទាំងនោះ សត្វទាំងឡាយទទួលឱវាទរបស់ស្តេចចក្រពត្តិ តាំងនៅក្នុងសីល ៥ ហើយ ក៏មានសួគ៌ជាទីទៅខាងមុខ ។ តាំងនៅក្នុងឱវាទរបស់ព្រះបច្ចេកពុទ្ធ ក៏ដូចគ្នា ចំណែកសត្វទាំងឡាយតាំងនៅក្នុងឱវាទរបស់ព្រះសម្មាសម្ពុទ្ធ និងរបស់សាវករបស់

ព្រះពុទ្ធ រមែងមានសួគ៌ជាទីប្រព្រឹត្តទៅខាងមុខ និងមានព្រះនិព្វានជាទីទៅខាងមុខ ។ ព្រោះដូច្នោះ ការនៅក្នុងបដិរូបទេសៈនោះ ទើបត្រាស់ថា "ជាមង្គល" ព្រោះជាបច្ច័យនៃសម្បត្តិទាំងនោះ ។

ភាពជាអ្នកប្រារព្ធគុណព្រះពុទ្ធ ព្រះបច្ចេកពុទ្ធ និងព្រះខីណាស្រពសន្សំកុសលទុកក្នុងជាតិដែលកន្លងមកហើយ ឈ្មោះថា **ភាពជាអ្នកធ្វើបុណ្យទុកក្នុងកាលមុន** ។ សូម្បីភាពជាអ្នកធ្វើបុណ្យទុកក្នុងកាលមុននោះ ក៏ជាមង្គល ។ ព្រោះហេតុអ្វី? អធិប្បាយថា ភាពជាអ្នកធ្វើបុណ្យទុកក្នុងកាលមុន រមែងឲ្យសម្រេចជាព្រះអរហត្ត កាលចប់គាថាសូម្បី ៤ បទ ដែលសំដែងចំពោះព្រះភក្ត្ររបស់ព្រះពុទ្ធ និងព្រះបច្ចេកពុទ្ធ ឬដែលបានស្តាប់ចំពោះព្រះភក្ត្ររបស់ព្រះពុទ្ធ ឬសាវ័ករបស់ព្រះពុទ្ធ ។ ក៏មនុស្សណាសាងបារមីទុក មានកុសលមូលដ៏ច្រើនមកអំពីមុន មនុស្សនោះ ធ្វើវិបស្សនាឲ្យកើតហើយ រមែងសម្រេចធម៌ជាទីអស់អាសវៈ ដោយកុសលមូលនោះឯង ដូចព្រះមហាកប្បិនៈ និងព្រះអគ្គមហេសី ។ ព្រោះហេតុនោះ ព្រះមានព្រះភាគទើបត្រាស់ថា "ភាពជាអ្នកធ្វើបុណ្យទុកក្នុងកាលមុនជាមង្គល" ។

បុគ្គលខ្លះក្នុងលោកនេះ រមែងធ្វើខ្លួនជាអ្នកទ្រុស្តសីលហើយ ឲ្យតាំងនៅក្នុងសីល ខ្លួនដែលមិនមានសទ្ធា ឲ្យតាំងនៅក្នុងសទ្ធាសម្បទា ខ្លួនកំណាញ់ ឲ្យតាំងនៅក្នុងចាគសម្បទា ។ ការតម្កល់ខ្លួនដូចពោលមកនេះឈ្មោះថា **តាំងខ្លួនទុកប្រពៃ** ។ ការតាំងខ្លួនប្រពៃនេះ ហៅថា **អត្ត-សម្មាបណិធិ** ។ អត្តសម្មាបណិធិនេះឯង ជាមង្គល ។ ព្រោះហេតុអ្វី? ព្រោះជាហេតុលះពៀរដែលប្រព្រឹត្តទៅក្នុងបច្ចុប្បន្ន និងក្នុងខាងមុខ និងបានទទួលអានិសង្សផ្សេងៗ ។

ព្រះមានព្រះភាគត្រាស់មង្គលនៃគាថានេះទុក ៣ មង្គល គឺ ការនៅក្នុងបដិរូបទេស: ១ ភាពជាអ្នកធ្វើបុណ្យទុកក្នុងកាលមុន ១ និងការតាំងខ្លួនទុកដោយប្រពៃ ១ ដោយប្រការដូច្នេះ ។ ក៏សេចក្ដីមង្គលទាំងនោះជាមង្គល ក៏បានបង្ហាញទុកក្នុងមង្គលនោះៗ ឯងហើយ ។

ចប់សេចក្ដីពណ៌នាគាថានេះថា បដិរូបទេសវាសោ ច

## ពណ៌នាគាថាថា ពហុសច្ចញ្ច

ឥឡូវនេះ នឹងពណ៌នាបទក្នុងគាថានេះថា **ពាហុសច្ចញ្ច** ជាដើម ដូចតទៅនេះ សេចក្ដីថា ភាពជាពហុស្សូត ឈ្មោះថា **ពាហុសច្ចៈ** ។ ភាពឆ្លាតក្នុងការងារគ្រប់យ៉ាង ឈ្មោះថា **សិល្បៈ** ។ វិន័យផ្លូវកាយវាចាចិត្ត ឈ្មោះថា **វិន័យ** ។ បទថា **សុសិក្ខិតោ** ប្រែថា ដែលគេសិក្សាហើយដោយល្អ ។ បទថា **សុភាសិតា** ប្រែថា ដែលគេពោលដោយល្អហើយ ។ ស័ព្ទថា **យា** សំដែងសេចក្ដីមិនពិតប្រាកដ ។ ពាក្យដែលថ្លែងចេញតាមវាចា ឈ្មោះថា **វាចា** ។ ពាក្យដ៏សេស មានន័យដូចដែលពោលហើយនោះឯង ។ នេះជាការពណ៌នាបទក្នុងគាថាថា **ពាហុសច្ចញ្ច** ជាដើមនេះ ។

ចំណែកការពណ៌នាសេចក្ដី គប្បីជ្រាបដូច្នេះ ។ ភាពជាអ្នកទ្រទ្រង់ទុកនូវសត្ថុសាសន៍ ដែលទ្រង់ពណ៌នាទុក ដោយន័យជាដើមយ៉ាងនេះថា ជាអ្នកទ្រទ្រង់សុតៈ សន្សំសុតៈ និងថា ភិក្ខុរូបខ្លះក្នុងធម្មវិន័យនេះ មានសុតៈច្រើន គឺ សុតៈ គេយ្យៈ វេយ្យាករណៈ ជាដើម ឈ្មោះថា **ភាពជាពហុស្សូត** ។ ភាពជាពហុស្សូតនោះ ត្រាស់ថា **ជាមង្គល** ព្រោះជាហេតុ

លះអកុសល និងចម្រើនកុសល និងព្រោះជាហេតុធ្វើឲ្យជាក់ច្បាស់បរមត្ថ-សច្ចៈតាមលំដាប់ ។ សមពិតដូចដែលព្រះមានព្រះភាគត្រាស់ទុកដូច្នេះថា

> ម្នាលភិក្ខុទាំងឡាយ អរិយសាវកអ្នកស្តាប់ហើយ រមែងលះអកុសល ចម្រើនកុសល រមែងលះវត្ថុដែលមានទោស ចម្រើនវត្ថុដែលមិនមានទោស រក្សាខ្លួនឲ្យបរិសុទ្ធ ដូច្នេះ ។ ទ្រង់ត្រាស់តទៅទៀតថា ៖
>
> រមែងពិចារណាអត្ថនៃធម៌ទាំងឡាយ ដែលទ្រទ្រង់ចាំទុកនូវធម៌ទាំងឡាយ រមែងអត់ធន់ក្នុងការសម្លឹងពិនិត្យរបស់លោកអ្នកពិចារណាអត្ថ កាលអត់ធន់ដល់ការសម្លឹងពិនិត្យធម៌ហើយ ឆន្ទៈរមែងកើត កាលឆន្ទៈកើតហើយ រមែងឧស្សាហៈ កាលឧស្សាហៈ រមែងពិចារណា កាលពិចារណា រមែងតាំងសេចក្តីព្យាយាម កាលតាំងសេចក្តីនូវព្យាយាម រមែងធ្វើឲ្យជាក់ច្បាស់នូវបរមត្ថសច្ចៈ ដោយកាយ (នាមកាយ) និងរមែងចាក់ធ្លុះដោយបញ្ញា ដូច្នេះ ។

មួយវិញទៀត សុតពាហុសច្ចៈ (ភាពជាពហុស្សូត) របស់គ្រហស្ថណា មិនមានទោស ការនោះ ក៏គប្បីជ្រាបថា ជាមង្គល ព្រោះនាំមកនូវប្រយោជន៍សុខក្នុងលោកទាំងពីរ ។

សិល្បៈរបស់គ្រហស្ថ និងសិល្បៈរបស់បព្វជិត ឈ្មោះថា **សិល្បៈ** ។ បណ្តាសិល្បៈទាំង ២ នោះ កិច្ចកម្ម មានការងាររបស់ជាងកែវមណី ជាងមាសជាដើម ដែលវៀរចាកការធ្វើអន្តរាយជីវិតសត្វដទៃ វៀរចាកអកុសល ឈ្មោះថា សិល្បៈរបស់គ្រហស្ថ ។ សិល្បៈរបស់គ្រហស្ថនោះ ឈ្មោះថា ជាមង្គល ព្រោះនាំមកនូវប្រយោជន៍ក្នុងលោកនេះ ។

ការចាត់ចែងធ្វើសមណបរិក្ខារ មានការប៉ះ និងការដេរចីវរជាដើម ដែលព្រះមានព្រះភាគទ្រង់សរសើរទុកក្នុងទីនោះ ៗ ដោយន័យជាដើមថា "ម្នាលភិក្ខុទាំងឡាយ កិច្ចគួរធ្វើណាៗ របស់សព្រហ្មចារី មិនថាខ្ពស់ទាបយ៉ាងណា ភិក្ខុជាអ្នកឧស្សាហៈក្នុងកិច្ចដែលគួរធ្វើនោះៗ" និងដែលត្រាស់ថា "ជានាថករណធម៌ (ធម៌ធ្វើជាទីពឹង)" ឈ្មោះថា សិល្បៈរបស់បព្វជិត ។ សិល្បៈរបស់បព្វជិតនោះ គប្បីជ្រាបថា ជាមង្គល ព្រោះនាំមកនូវប្រយោជន៍

សុខក្នុងលោកទាំង ២ ដល់ខ្លួនឯង និងដល់អ្នកដទៃៗ ។

វិន័យរបស់គ្រហស្ថ និងវិន័យរបស់បព្វជិត ឈ្មោះថា **វិន័យ** ។ បណ្ដាវិន័យទាំង ២ នោះ ការវៀរចាកអកុសលកម្មបថ ១០ ឈ្មោះថា **វិន័យរបស់គ្រហស្ថ** ។ វិន័យរបស់គ្រហស្ថនោះ គ្រហស្ថសិក្សាល្អហើយក្នុងវិន័យនោះ ឈ្មោះថា ជាមង្គល ព្រោះនាំមកនូវប្រយោជន៍សុខក្នុងលោកទាំង ២ ដោយមិនត្រូវសង្កិលេស (សេចក្ដីសៅហ្មង) និងដោយការកំណត់គុណ គឺ អាចារ: ។

ការមិនត្រូវអាបត្តិ ៧ កង ឈ្មោះថា **វិន័យរបស់បព្វជិត** ។ សូម្បីវិន័យរបស់បព្វជិតនោះ ដែលបព្វជិតសិក្សាល្អហើយ ដោយន័យដូចពោលមកហើយ ។ ឬបារិសុទ្ធ ។ សីល ៤ ឈ្មោះថា វិន័យរបស់បព្វជិត ។ វិន័យរបស់បព្វជិតនោះ ដែលបព្វជិតសិក្សាល្អហើយ សិក្សាដោយការតាំងនៅក្នុងចតុប្បារិសុទ្ធិសីលនោះ នឹងសម្រេចព្រះអរហត្តបាន គប្បីជ្រាបថាជាមង្គល ព្រោះជាហេតុប្រសព្វសុខទាំងលោកិយ: ទាំងលោកុត្តរ: ។

វាចាដែលវៀរចាកទោស មានមុសាវាទជាដើម ឈ្មោះថា **វាចា-**

សុភាសិត ។ ដូចព្រះមានព្រះភាគត្រាស់ទុកថា "ម្នាលភិក្ខុទាំងឡាយ វាចាប្រកបដោយអង្គ ៤ ជាវាចាសុភាសិត" ។ ឬថា វាចាដែលមិនរាយមាយក៏ឈ្មោះថា វាចាសុភាសិត ។ ដូចដែលព្រះមានព្រះភាគត្រាស់ទុកថា ៖

សប្បុរសទាំងពោលថា វាចាសុភាសិតជាវាចាខ្ពង់ខ្ពស់
ជាប្រការទី ១ ។ បុគ្គលគប្បីពោលតែធម៌ មិនគប្បី
ពោលមិនមែនជាធម៌ ជាប្រការទី ២ ។ គប្បីពោល
តែពាក្យគួរស្រឡាញ់ មិនគប្បីពោលពាក្យដែលមិនគួរ
ស្រឡាញ់ ជាប្រការទី ៣ ។ ពោលតែពាក្យសច្ចៈ មិន
គប្បីពោលពាក្យឡេះឡោះ ជាប្រការទី ៤ ។

សូម្បីវាចាសុភាសិតនេះ ក៏គប្បីជ្រាបថា "ជាមង្គល" ព្រោះនាំមកនូវប្រយោជន៍សុខក្នុងលោកទាំង ២ តែព្រោះវាចាសុភាសិតនេះ ទាក់ទងក្នុងវិន័យ ដូច្នោះ សូម្បីមិនសង្គ្រោះវាចាសុភាសិតនេះទុកដោយវិន័យស័ព្ទក៏គប្បីជ្រាបថា ជាវិន័យនោះឯង ។ បើដូច្នោះ វាចា មានការសំដែងធម៌ជាដើមដល់អ្នកដទៃ គប្បីជ្រាបថា ជាវាចាសុភាសិត ក្នុងទីនេះ ដោយការ

ស្តាក់ស្មើរចិត្តឬ? ។ ពិតហើយ វាចាសុភាសិតត្រាស់ថា ជាមង្គល ក៏ព្រោះជាហេតុប្រសព្វសុខក្នុងលោកទាំង ២ និងព្រះនិព្វានរបស់សត្វទាំងឡាយ ក៏ដូចជាការនៅក្នុងបដិរូបទេសៈ ។ ព្រះវង្គីសត្ថេរពោលទុកថា ៖

ព្រះពុទ្ធត្រាស់ព្រះវាចាណា ដ៏ក្សេម ដើម្បីលុះព្រះនិព្វាន

ដើម្បីធ្វើទីបំផុតទុក្ខ ព្រះវាចានោះឯង ជាកំពូលនៃវាចា

ទាំងឡាយ ។

ព្រះសម្ពុទ្ធត្រាស់មង្គលនៃគាថានេះទុក ៤ មង្គល គឺ ពាហុសច្ចៈ ១ សិល្បៈ ១ វិន័យដែលសិក្សាល្អហើយ ១ និងវាចាសុភាសិត ១ ដោយប្រការដូច្នេះ ។ ក៏សេចក្តីនៃមង្គលនោះ ក៏បានអធិប្បាយទុកក្នុងមង្គលនោះៗ ដូច្នេះ ។

ចប់សេចក្តីពណ៌នាគាថាថា ពាហុសច្ចញ្ច ជាដើម

## ពណ៌នាគាថាថា មាតាបិតុឧបដ្ឋានំ

ឥឡូវនេះ នឹងពណ៌នាបទក្នុងគាថានេះថា **មាតាបិតុឧបដ្ឋានំ** ជាដើម ដូចតទៅនេះ ។ មាតាផង បិតាផង ហេតុនោះទើបឈ្មោះថា **មាតាបិតា** ។ បទថា **ឧបដ្ឋានំ** ប្រែថា ការទំនុកបម្រុង ។ បុត្រទាំងឡាយផង ភរិយាទាំងឡាយផង ហេតុនោះទើបឈ្មោះថា **បុត្តភរិយា** ។ ការសង្គ្រោះ ឈ្មោះថា **សង្គហៈ** ។ ការងារ គឺ កិច្ចកម្ម មិនច្របូកច្របល់ ឈ្មោះថា **ការងារមិនច្របូកច្របល់** ការងារទាំងឡាយនោះឯង ឈ្មោះថា **កម្មន្តា** ។ ពាក្យដ៏សេស មានន័យដូចដែលពោលមកហើយនោះឯង ។ នេះជាការពណ៌នាបទ ។

ចំណែកការពណ៌នាសេចក្តី គប្បីជ្រាបដូច្នេះ ។ ស្ត្រីអ្នកញុំាងបុត្រឲ្យកើត ហៅឈ្មោះថា **មាតា បិតា** ក៏ដូច្នេះ ។ ការធ្វើឧបការៈដោយការលាងជើង គក់ច្របាច់ ដុសជម្រះ ផ្ងូតទឹក និងដោយការបង្អោនបច្ច័យ ៤ ឈ្មោះថា **ការទំនុកបម្រុង** ។ ក្នុងការទំនុកបម្រុងនោះ ព្រោះហេតុដែលមាតាបិតាមានឧបការៈច្រើន ប្រាថ្នាប្រយោជន៍ អនុគ្រោះបុត្រទាំងឡាយ

មាតាបិតាពួកណា ឃើញបុត្រទាំងឡាយលេងខាងក្រៅ ដើរមកមានខ្លួនប្រឡាក់ធូលី ក៏ជូតធូលីឲ្យ ថើបបុត្រ ថ្នាក់ថ្នម ញុំាងនូវសេចក្តីស្រឡាញ់មេត្តាដល់បុត្រ បុត្រទាំងឡាយប្រើសីសៈទូលមាតាបិតារហូត ១០០ ឆ្នាំ ក៏មិនអាចនឹងធ្វើបដិការៈសងគុណមាតាបិតានោះបាន ។ ព្រោះហេតុដែលមាតាបិតានោះជាអ្នកថែរក្សាចិញ្ចឹម សំដែងលោកនេះ សម្មតិថា ជាព្រហ្ម សម្មតិថា ជាបុព្វាចារ្យ ដូច្នោះ ការទំនុកបម្រុងមាតាបិតានោះ រមែងនាំមកនូវការសរសើរក្នុងលោកនេះ និងលះលោកនេះទៅហើយ ក៏នឹងនាំមកនូវសុខក្នុងសួគ៌ ។ ព្រោះហេតុនោះ ទើបត្រាស់ថា "ជាមង្គល" សមដូចដែលព្រះមានព្រះភាគត្រាស់ថា ៖

មាតាបិតា លោកហៅថាព្រហ្ម ថាបុព្វាចារ្យ ជាអាហុ-
ណេយ្យបុគ្គលរបស់បុត្រ ជាអ្នកអនុគ្រោះបុត្រ ព្រោះ
ដូច្នោះ បណ្ឌិតគប្បីថ្វាយបង្គំ និងគប្បីធ្វើសក្ការៈមាតា
បិតានោះ ដោយបាយ ទឹក សំពត់ ទីដេក ការគក់
ប្របាច់ ការងូតទឹកឲ្យ និងលាងជើង ។ ព្រោះការ

ការប្រណិប័តន៍ មាតាបិតានោះ បណ្ឌិតទាំងឡាយទើប
សរសើរគេក្នុងលោកនេះ គេលះលោកទៅហើយ រមែង
រីករាយក្នុងសួគ៌ ។

ន័យម្យ៉ាងទៀត កិច្ចកម្ម ៥ យ៉ាង មានការចិញ្ចឹមថែរក្សាលោក ជួយធ្វើកិច្ចការរបស់លោក និងការរក្សាវង្សត្រកូលជាដើម ឈ្មោះថា ការទំនុកបម្រុង ។ ការទំនុកបម្រុងនោះ គប្បីជ្រាបថា ជាមង្គល ព្រោះជាហេតុនៃប្រយោជន៍សុខក្នុងបច្ចុប្បន្ន ៥ យ៉ាង មានការហាមមិនឲ្យធ្វើបាបជាដើម ។ សមពិតដូចព្រះមានព្រះភាគទ្រង់ត្រាស់ដូច្នេះថា ៖

ម្នាលគហបតិបុត្រ ទិសខាងមុខ គឺ មាតាបិតា ដែលបុត្រ
គប្បីទំនុកបម្រុងដោយស្ថាន ៥ គឺ យើង ដែលលោកបាន
ចិញ្ចឹមមកហើយ នឹងចិញ្ចឹមលោកវិញ នឹងជួយធ្វើកិច្ចការ
របស់លោក នឹងរក្សាវង្សត្រកូល នឹងបដិបត្តិខ្លួនឲ្យសមជា
ទាយាទ ម្យ៉ាងទៀត ពេលលោកធ្វើកាលៈហើយ (ស្លាប់)
និងធ្វើបុណ្យឧទ្ទិសទៅឲ្យលោក ។ ម្នាលគហបតិបុត្រ ទិស

ទិសខាងមុខ គឺ មាតាបិតា ដែលបុត្រគប្បីទំនុកបម្រុង
ដោយស្ថាន ៥ នេះហើយ ក៏រមែងអនុគ្រោះបុត្រដោយ
ស្ថាន ៥ គឺ ហាមបុត្រពីអំពើអាក្រក់ ឲ្យបុត្រតាំងនៅ
ក្នុងសេចក្ដីល្អ ឲ្យសិក្សាសិល្បៈ រកភរិយាដែលសមគួរ
ឲ្យ ប្រគល់ទ្រព្យមត៌កឲ្យ ក្នុងវេលាសមគួរ ។

មួយវិញទៀត អ្នកណាទំនុកបម្រុងមាតាបិតា ដោយឲ្យកើតសេចក្ដីជ្រះថ្លាក្នុងវត្ថុទាំង ៣ (ព្រះរតនត្រ័យ) ដោយឲ្យដល់ព្រមដោយសីល ដោយការបព្វជា បុគ្គលនេះជាកំពូលនៃអ្នកទំនុកបម្រុងមាតាបិតា ។ ការទំនុកបម្រុងមាតាបិតារបស់បុគ្គលនោះ ជាការតបជំនួសឧបការគុណដែលមាតាបិតាធ្វើមកហើយ ត្រាស់ថា ជាមង្គល ព្រោះជាបទដ្ឋាននៃប្រយោជន៍ទាំងឡាយ ទាំងបច្ចុប្បន្ន ទាំងលោកខាងមុខដ៏ច្រើន ។

ទាំងបុត្រទាំងធីតាដែលកើតអំពីខ្លួន ក៏រាប់ថា បុត្រនោះឯង ក្នុងបទថា **បុត្តទារស្ស** នេះ ។ បទថា **ទារ:** បានដល់ ភរិយា ២០ ពួក ពួកណាមួយ ។ បុត្រ និងភរិយា ឈ្មោះថា **បុត្តទារ:** ។ បទថា **សង្គហោ**

(ការសង្គ្រោះ) បានដល់ ការធ្វើឧបការៈដោយការលើកសរសើរជាដើម ។ ការធ្វើឧបការៈនោះ គប្បីជ្រាបថា ជាមង្គល ព្រោះជាហេតុនៃប្រយោជន៍សុខក្នុងបច្ចុប្បន្ន មានភាពជាអ្នកចាត់ចែងការងារល្អជាដើម ។ ពិតហើយ ព្រះមានព្រះភាគទ្រង់សង្គ្រោះ បុត្រភរិយា ដែលទ្រង់លើកឡើងសំដែងក្នុងទីនេះថា ទិសខាងក្រោយ គប្បីជ្រាបថា គឺ បុត្រភរិយា ទុកដោយភរិយា ស័ព្ទ ទើបត្រាស់ទុកដូច្នេះថា ៖

ម្នាលគហបតិបុត្រ ទិសខាងក្រោយ គឺ ភរិយា ដែលស្វាមីគប្បីទំនុកបម្រុងដោយស្ថាន ៥ គឺ ដោយការលើកសរសើរ ដោយការមិនមើលងាយ ដោយការមិនក្បត់ចិត្ត ដោយការប្រគល់ភាពជាធំឲ្យ ដោយការប្រគល់គ្រឿងប្រដាប់ឲ្យ ម្នាលគហបតិបុត្រ ទិសខាងក្រោយ គឺ ភរិយា ដែលស្វាមីទំនុកបម្រុងដោយស្ថាន ៥ ទាំងនេះហើយ រមែងអនុគ្រោះស្វាមីដោយស្ថាន ៥ គឺ ចាត់ចែងការងារល្អ សង្គ្រោះអ្នកជិតខាង មិនក្បត់ចិត្ត រក្សាទ្រព្យដែលស្វាមីរកបានមក ឧស្សាហៈមិន

ខ្ជិលច្រអូសក្នុងកិច្ចគ្រប់យ៉ាង ។

ឬ មានន័យម្យ៉ាងទៀតដូច្នេះ បទថា សង្គហោ (សង្គ្រោះ) បានដល់ ការសង្គ្រោះដោយការឲ្យទាន បិយវាចា (និយាយគួរឲ្យស្រឡាញ់) អត្ថចរិយា (ការបំពេញប្រយោជន៍ដែលជាធម៌) ។ ដូចម្តេច? គឺ ការឲ្យស្បៀងអាហារក្នុងថ្ងៃឧបោសថ ការឲ្យមើលនក្ខត្តឫក្សក្នុងថ្ងៃនក្ខត្តឫក្ស ធ្វើមង្គលក្នុងថ្ងៃមង្គល ការឲ្យឱវាទទូន្មានក្នុងប្រយោជន៍ទាំងឡាយ ដែលប្រព្រឹត្តទៅក្នុងបច្ចុប្បន្ន និងប្រព្រឹត្តទៅក្នុងបរលោក ។ ការសង្គ្រោះនោះ គប្បីជ្រាបថា ជាមង្គល ព្រោះជាហេតុនៃប្រយោជន៍ក្នុងបច្ចុប្បន្ន និងជាហេតុនៃប្រយោជន៍ក្នុងកាលជាអនាគត និងព្រោះជាហេតុដែលសូម្បីទេវតាទាំងឡាយគប្បីថ្វាយបង្គំ ។ ដូចដែលសក្កទេវរាជត្រាស់ទុកថា ៖

នែ៎! មាតលី គ្រហស្ថណា ធ្វើបុណ្យ មានសីល ជាឧបាសក

ចិញ្ចឹមភរិយាដោយធម៌ យើងរមែងនមស្ការគហបតីនោះឯង ។

ការងារទាំងឡាយ មានកសិកម្ម (ធ្វើស្រែ) គោរក្ខកម្ម (ចិញ្ចឹមគោ) និងពាណិជ្ជកម្ម (ទិញលក់) ជាដើម វៀរចាកការៈច្របូកច្របល់ មានការ

កន្លងវេលា ការធ្វើមិនសមគួរ និងការទម្រន់ជាដើម ព្រោះជាអ្នកស្គាល់កាល ព្រោះជាអ្នកធ្វើសមគួរ ព្រោះជាអ្នកមិនខ្ជិលច្រអូស និងព្រោះមិនគប្បីដល់នូវសេចក្តីអន្តរាយ ហេតុដល់ព្រមដោយសេចក្តីឧស្សាហ៍ព្យាយាម ឈ្មោះថា **ការងារមិនច្របូកច្របល់** ។ ការងារមិនច្របូកច្របល់នោះដែលបុគ្គលប្រកបបានយ៉ាងនេះ ក៏ព្រោះខ្លួន បុត្រភរិយា ឬទាសៈ និងកម្មករ ជាអ្នកឆ្លាត ត្រាស់ថា "ជាមង្គល" ព្រោះជាហេតុឲ្យបាននូវទ្រព្យស្រូវអង្ករ និងសេចក្តីចម្រើនក្នុងបច្ចុប្បន្ន ។ សមដូចដែលព្រះមានព្រះ-ភាគត្រាស់ទុកដូច្នេះថា ៖

អ្នកមានធុរៈ ធ្វើសមគួរ ព្យាយាម រមែងបានទ្រព្យ ។

និងថា

អ្នកពេញចិត្តដេកពេលថ្ងៃ ខ្ជិលច្រអូសក្នុងពេលយប់
ស្រវឹងជាប្រចាំ ជាអ្នកលេង គ្រប់គ្រងផ្ទះមិនបាន ។
ប្រយោជន៍ទាំងឡាយ រមែងកន្លងពួកកំលោះដែលលះ
បង់ការងារចោល ដោយអាងថា ត្រជាក់ពេក ក្តៅពេក

ល្ងាចហើយ ។ បុគ្គលណាមិនសំគាល់នូវត្រជាក់ និងក្តៅ ឲ្យក្រៃលែងជាងស្មៅ ធ្វើកិច្ចរបស់កូនប្រុស បុគ្គលនោះ រមែងមិនសាបសូន្យចាកសេចក្តីសុខ ។

និងថា

កាលបុគ្គលរួបរួមភោគទ្រព្យ ដូចមេឃ្មុំរួបរួមទឹក ភោគ- ទ្រព្យ រមែងសន្សំជាគំនរ ដូចដំបូកដែលកណ្តៀរកពូនឡើង ដូច្នោះ ។ យ៉ាងនេះជាដើម ។

ព្រះមានព្រះភាគត្រាស់មង្គលនៃគាថានេះទុក ៤ មង្គល គឺ ការទំនុកបម្រុងមាតា ១ ការទំនុកបម្រុងបិតា ១ ការសង្គ្រោះបុត្រភរិយា ១ និងការងារមិនច្របូកច្របល់ ១ ឬ ៥ មង្គល ព្រោះការចែកសង្គ្រោះបុត្រ និងភរិយាចេញជា ២ ។ ឬ ៣ មង្គល ព្រោះរួមការទំនុកបម្រុងមាតាបិតាក៏ដូចគ្នា ។ ក៏មង្គលទាំងនោះ ជាមង្គល បានអធិប្បាយទុកក្នុងមង្គលនោះៗហើយ ។

ចប់សេចក្តីពណ៌នាគាថាថា មាតាបិតុឧបដ្ឋានំ

## ពណ៌នាគាថាថា ទានញ្ច

ឥឡូវនេះ នឹងពណ៌នាបទក្នុងគាថានេះថា **ទានញ្ច** ជាដើម ដូចតទៅនេះ ។ ឈ្មោះថា **ទាន** ព្រោះគេឲ្យដោយវត្ថុនេះ លោកអធិប្បាយថា គេប្រគល់ទ្រព្យដែលខ្លួនមានឲ្យដល់អ្នកដទៃ ។ ការប្រព្រឹត្តធម៌ ឬការប្រព្រឹត្តដែលមិនប្រាសចាកធម៌ ឈ្មោះថា **ធម្មចរិយា** ។ ឈ្មោះថា **ញាតិ** ព្រោះនរណាៗ ក៏ដឹងថា បុគ្គលនេះ (នៅក្នុងវង្ស) របស់យើង ។ (ការងារ) មិនមានទោស ឈ្មោះថា **អនវជ្ជៈ** លោកអធិប្បាយថា នរណាៗ និន្ទាមិនបាន តិះដៀលមិនបាន ។ ពាក្យដ៏សេស មានន័យដូចដែលពោលមកហើយទាំងអស់នោះឯង ។ នេះជាការពណ៌នាបទ ។

ចំណែកការពណ៌នាសេចក្តី គប្បីជ្រាបដូច្នេះ ។ ចេតនាដែលហេតុបរិច្ចាគទានវត្ថុ ១០ មានបាយជាដើម ដែលមានការត្រេកអរជាខាងដើម ឆ្ពោះ (ចំពោះ) អ្នកដទៃ ឬការមិនលោភដែលប្រកបដោយចាគចេតនានោះ ឈ្មោះថា **ទាន** ។ ពិតហើយ បុគ្គលរមែងប្រគល់ឲ្យវត្ថុនោះដល់អ្នកដទៃ ដោយសេចក្តីមិនលោភ ។ ព្រោះហេតុនោះ ខ្ញុំទើបពោលថា “ឈ្មោះថា

ទាន ព្រោះគេឲ្យទានដោយវត្ថុនេះ" ។ ទាននោះ ត្រាស់ថា "ជាមង្គល" ព្រោះជាហេតុប្រសព្វផលវិសេសដែលប្រព្រឹត្តទៅក្នុងបច្ចុប្បន្ន និងប្រព្រឹត្តទៅក្នុងបរលោក មានភាពជាអ្នកដែលជនដ៏ច្រើនស្រឡាញ់ និងពេញចិត្តជាដើម ។ ក្នុងរឿងទាននេះ គប្បីរឭកដល់សូត្រទាំងឡាយជាដើមយ៉ាងនេះថា សីហសេនាបតី ជាទាយក ជាទានបតី រមែងជាទីស្រឡាញ់ពេញចិត្តរបស់ជនដ៏ច្រើន ។

ន័យម្យ៉ាងទៀត ឈ្មោះថា **ទាន** មាន ២ គឺ **អាមិសទាន** និង **ធម្មទាន** ក្នុងទាន ២ នោះ អាមិសទាន បានពោលមកហើយ ។ ចំណែកការសំដែងធម៌ ដែលព្រះសម្មាសម្ពុទ្ធប្រកាសហើយ ដែលជាហេតុអស់ទុក្ខ និងនាំមកនូវសុខក្នុងលោកនេះ និងបរលោក ព្រោះនឹងឲ្យប្រយោជន៍ដល់អ្នកដទៃ ឈ្មោះថា **ធម្មទាន** ។ ម្យ៉ាងទៀត បណ្តាទានទាំង ២ នេះ ធម្មទានតែម្យ៉ាងប៉ុណ្ណោះ ជាទានដ៏ប្រសើរ ។ ដូចព្រះមានព្រះភាគត្រាស់ទុកថា ៖

ការឲ្យធម៌ ឈ្នះការឲ្យទាំងពួង រសនៃធម៌ ឈ្នះអស់រស

ទាំងពួង សេចក្តីត្រេកអរក្នុងធម៌ ឈ្នះសេចក្តីត្រេកអរ

*ទាំងពួង ការអស់តណ្ហា ឈ្នះទុក្ខទាំងពួង ។*

*ក្នុងសូត្រ និងគាថានោះ ទ្រង់ត្រាស់អាមិសទានជាមង្គលប៉ុណ្ណោះ ចំណែកធម្មទានត្រាស់ថា "ជាមង្គល" ព្រោះជាបទដ្ឋាននៃគុណទាំងឡាយមានភាពជាអ្នកចាក់ធ្លុះអត្ថជាដើម ។ សមដូចដែលព្រះមានព្រះភាគត្រាស់ទុកដូច្នេះថា ៖*

*ម្នាលភិក្ខុទាំងឡាយ ភិក្ខុសំដែងធម៌ តាមដែលស្តាប់មក តាមដែលរៀនមក ដោយពិស្តារ ដល់អ្នកដទៃៗ ដោយប្រការណាៗ ភិក្ខុនោះ រមែងជាអ្នកចាក់ធ្លុះអត្ថ និងចាក់ធ្លុះធម៌ ក្នុងធម៌នោះ ដោយប្រការនោះៗ ដូច្នេះជាដើម ។*

*ការប្រព្រឹត្តកុសលកម្មបថ ១០ ឈ្មោះថា* ***ធម្មចរិយា*** *ដូចព្រះមាន-ព្រះភាគត្រាស់ទុកជាដើមយ៉ាងនេះថា "ព្រាហ្មណ៍គហបតីទាំងឡាយ ការប្រព្រឹត្តធម៌ និងការប្រព្រឹត្តស្មើផ្លូវកាយ មាន ៣ យ៉ាង" ។ ការប្រព្រឹត្តធម៌នោះ គប្បីជ្រាបថា* ***ជាមង្គល*** *ព្រោះជាហេតុចូលដល់សួគ៌ទេវលោក ។ សមពិតដូចដែលព្រះមានព្រះភាគត្រាស់ទុកដូច្នេះថា "ព្រាហ្មណ៍គហបតីទាំង*

ឡាយ ព្រោះហេតុដែលប្រព្រឹត្តធម៌ ប្រព្រឹត្តស្មើ សត្វពួកខ្លះ ក្នុងលោកនេះ ខាងមុខអំពីស្លាប់ព្រោះកាយបែកធ្លាយ រមែងចូលដល់សុគតិ សួគ៌ទេវលោក ដូច្នេះ ។

ជនអ្នកជាប់ទាក់ទងខាងមាតា ឬខាងបិតា រហូត ៧ ជួរត្រកូលឈ្មោះថា **ញាតិ** ។ ការសង្គ្រោះញាតិទាំងនោះ ដែលត្រូវសេចក្តីវិនាសភោគ: ត្រូវសេចក្តីវិនាសព្រោះជំងឺគ្របសង្កត់ ហើយមករកខ្លួន ដោយអាហារ គ្រឿងស្លៀកដណ្តប់ និងបាយជាដើមតាមកម្លាំង ទ្រង់ត្រាស់ថា "**ជាមង្គល**" ព្រោះជាហេតុប្រសព្វផលវិសេស ក្នុងបច្ចុប្បន្នមានការសរសើរជាដើម និងបរលោក រមែងទៅកាន់សុគតិជាដើម ។ កិច្ចកម្មសុចរិតផ្លូវកាយ វាចា ចិត្ត មានការសមាទានអង្គឧបោសថ ការធ្វើសេចក្តីខ្វល់ខ្វាយការធ្វើចំការ និងដាំដើមឈើ និងសាងស្ពានជាដើម ឈ្មោះថា **ការងារមិនមានទោស** ។ ការងារមិនមានទោសទាំងនោះ ត្រាស់ថា "ជាមង្គល" ព្រោះជាហេតុឲ្យប្រសព្វប្រយោជន៍សុខច្រើនប្រការ ។ គប្បីរឭកដល់ព្រះសូត្រទាំងឡាយ មានជាដើមយ៉ាងនេះថា វិសាខា ស្ត្រី ឬបុរសពួកខ្លះក្នុង

សាសនានេះ កាន់យកឧបោសថប្រកបដោយអង្គ ៨ ប្រការ ខាងមុខអំពីស្លាប់ព្រោះការបែកធ្លាយ គប្បីចូលដល់ភាពជាសំឡាញ់របស់ទេវតាជាន់ចាតុម្មហារាជិកាណា ប្រការនោះក៏ជាឋានៈប្រព្រឹត្តទៅបាន ។

ព្រះមានព្រះភាគត្រាស់មង្គលនៃគាថានេះទុក ៤ មង្គល គឺ ទាន ១ ធម្មចរិយា ១ ការសង្គ្រោះញាតិ ១ ការងារមិនមានទោស ១ ដោយប្រការដូច្នេះ ។ ក៏មង្គលទាំងនោះ ក៏បានអធិប្បាយទុកក្នុងមង្គលនោះៗ ហើយនោះឯង ។

ចប់សេចក្តីពណ៌នាគាថានេះថា ទានញ្ច

## ពណ៌នាគាថាថា អារតី

ឥឡូវនេះ នឹងពណ៌នាក្នុងគាថានេះថា **អារតី វិរតី** ជាដើម ដូចតទៅនេះ ។ ការលះបង់ ឈ្មោះថា **អារតិ** ការវៀរចាក ឈ្មោះថា **វិរតិ** ម្យ៉ាងវិញទៀត សត្វទាំងឡាយរមែងវៀរចាកដោយចេតនានោះ ហេតុនោះ ចេតនា ទើបឈ្មោះថា **វិរតិ** ។ បទថា **បាបា (ចាកបាប)** បានដល់ ចាកអកុសល ។ ឈ្មោះថា **មជ្ជៈ** ព្រោះអត្ថថា ជាទីតាំងនៃសេចក្ដីស្រវឹង ។ ការផឹកមជ្ជៈ ឈ្មោះថា **មជ្ជបានៈ** ។ សង្រួមចាកមជ្ជបានៈនោះ ។ ការប្រុងប្រយ័ត្នឈ្មោះថា **ការសង្រួម** ។ ការមិនប្រមាទ ឈ្មោះថា **អប្បមាទៈ** ។ បទថា **ធម្មេសុ (ក្នុងធម៌ទាំងឡាយ)** បានដល់ ក្នុងកុសលទាំងឡាយ ។ ពាក្យដ៏សេស មានន័យដូចពោលហើយនោះឯង នេះជាការពណ៌នាបទ ។

ចំណែកការពណ៌នាសេចក្ដី គប្បីជ្រាបដូច្នេះ ។ ការមិនត្រេកអរផ្លូវចិត្តតែម្យ៉ាង របស់បុគ្គលអ្នកឃើញទោសក្នុងបាប ឈ្មោះថា **អារតិ** ។ ការវៀរចាកផ្លូវកាយវាចា ដោយកម្ម និងទ្វារ ឈ្មោះថា **វិរតិ** ។

ក៏ធម្មតា វិរតិនេះមាន ៣ គឺ **សម្បត្តវិរតិ ១ សមាទានវិរតិ ១**

**សមុច្ឆេទវិរតិ** ១ ។ បណ្ដាវិរតិទាំង ៣ នោះ វិរតិចេតនាវៀរចាកវត្ថុដែលប្រសព្វរបស់កុលបុត្រ ដោយន័យជាដើមយ៉ាងនេះថា ការដែលយើងនឹងសម្លាប់សត្វ និងលួចទ្រព្យ ជាដើមនេះ មិនសមគួរដល់យើងឡើយ ក៏ព្រោះអាស្រ័យជាតិត្រកូល និងគោត្ររបស់ខ្លួន វិរតិចេតនាវៀរចាកនេះឈ្មោះថា **សម្បត្តវិរតិ** ។ កុលបុត្តមិនធ្វើបាប មានបាណាតិបាតជាដើម តាំងអំពីប្រព្រឹត្តវិរតិណា វិរតិនោះ ប្រព្រឹត្តទៅដោយសមាទានសិក្ខាបទ ឈ្មោះថា **សមាទានវិរតិ** ។ ភ័យពៀរ ៥ របស់ព្រះអរិយសាវ័កស្ងប់ទៅ តាំងពីប្រព្រឹត្តវិរតិណា វិរតិនោះប្រកបដោយអរិយមគ្គ ឈ្មោះថា **សមុច្ឆេទវិរតិ** ។ អកុសលណា ដែលឈ្មោះថា **បាប** មាន ៤ យ៉ាង ពោល គឺ កម្មកិលេស ដែលព្រះមានព្រះភាគត្រាស់ទុកពិស្ដារយ៉ាងនេះថា “គហបតីបុត្ត កម្មកិលេស គឺ បាណាតិបាត កម្មកិលេស គឺ អទិន្នាទាន ។ល។ កម្មកិលេស គឺ មុសាវាទ” ដូច្នេះ ហើយទ្រង់រួបរួមទុកដោយគាថាយ៉ាងនេះថា ៖

លោកពោលកម្មកិលេស ៤ គឺ បាណាតិបាត អទិន្នាទាន

មុសាវាទ និងការល្មើសកិរិយារបស់អ្នកដទៃ បណ្ឌិតទាំងឡាយរមែងមិនសរសើរឡើយ ។

គប្បីវៀរចាកបាបអកុសលនោះ ។ ការលះបង់ ការវៀរចាកសូម្បីទាំងអស់នោះ ត្រាស់ថា “ជាមង្គល” ព្រោះជាហេតុបានទទួលផលវិសេសច្រើនប្រការ មានការលះបង់ពៀរវេរាក្នុងបច្ចុប្បន្ន និងប្រព្រឹត្តទៅក្នុងបរលោកជាដើម ។ ក៏ក្នុងសេចក្តីនេះ គប្បីព្រួកដល់ព្រះសូត្រទាំងឡាយដោយន័យជាដើមថា “ម្នាលគហបតីបុត្ត អរិយសាវកវៀរដាច់ខាតចាកបាណាតិបាតហើយ” ។

និងពណ៌នា **ការសង្រួមចាកការផឹកគ្រឿងស្រវឹង** ។ ពាក្យនេះជាឈ្មោះរបស់ចេតនាវៀរចាកទីតាំងនៃសេចក្តីប្រមាទ គឺ ការផឹកគ្រឿងស្រវឹង គឺ សុរា និងមេរ័យ ដែលពោលទុកមុនហើយ ។ ក៏ព្រោះហេតុដែលអ្នកផឹកទឹកស្រវឹង រមែងមិនដឹងអត្ថ មិនដឹងធម៌ រមែងធ្វើអន្តរាយដល់មាតា ធ្វើអន្តរាយដល់បិតា សូម្បីដល់ព្រះពុទ្ធ ព្រះបច្ចេកពុទ្ធ និងសាវករបស់ព្រះតថាគត រមែងប្រសព្វការតិះដៀលក្នុងភពបច្ចុប្បន្ន ប្រសព្វទុគ្គតិ

ក្នុងភពខាងមុខ និងប្រសព្វភាពជាអ្នកឆ្កួតក្នុងភពតៗ ទៅ ។ ចំណែកការសង្រួមចាកការផឹកទឹកស្រវឹង រមែងរម្ងាប់ទោសទាំងនោះ និងការដល់ព្រមដោយគុណ ដែលផ្ទុយគ្នានឹងទោសនោះ ។ ដូច្នោះ ការសង្រួមចាកការផឹកទឹកស្រវឹងនេះ គប្បីជ្រាបថា ជាមង្គល ។

ការនៅមិនប្រាសចាកសតិក្នុងកុសលធម៌ទាំងឡាយ ដោយអត្ថ គប្បីជ្រាបថា ជាបដិបក្ខនឹងសេចក្ដីប្រមាទ ដែលលោកពោលទុកក្នុងបាលីថា ការធ្វើដោយមិនគោរព ការធ្វើដោយមិនតជាប់គ្នា ការធ្វើមិនមុតមាំ ការប្រព្រឹត្តធូរថយ ការលះបង់ឆន្ទៈ ការដាក់ធុរៈ ការមិនសេព ការមិនចម្រើន ការមិនធ្វើឲ្យច្រើន ការមិនតាំងចិត្ត ការមិនប្រកបរឿយៗ ការធ្វេសប្រហែសក្នុងការអប់រំកុសលធម៌ទាំងឡាយ សេចក្ដីប្រមាទ សេចក្ដីធ្វេសប្រហែស ភាពជាអ្នកប្រមាទបែបនេះណា ហៅថា "ប្រមាទ" ឈ្មោះថា **សេចក្ដីមិនប្រមាទ** ក្នុងកុសលទាំងឡាយ ។ ការមិនប្រមាទក្នុងកុសលធម៌នោះ ទ្រង់ត្រាស់ថា "ជាមង្គល" ព្រោះជាហេតុប្រសព្វកុសលច្រើនប្រការ និងព្រោះជាហេតុសម្រេចអមតធម៌ ។ ក្នុងសេចក្ដីនោះ គប្បីរឭកដល់ពាក្យទូន្មាន

របស់ព្រះសាស្តាជាដើមយ៉ាងនេះថា "បុគ្គលមិនប្រមាទ បុគ្គលមានសេចក្តីព្យាយាម" ដូច្នេះ និង "សេចក្តីមិនប្រមាទជាដើមអមតបទ" ដូច្នេះ ។

ព្រះមានព្រះភាគត្រាស់មង្គលនៃគាថានេះទុក ៣ មង្គល គឺ ការវៀរចាកបាប ១ ការសង្រួមចាកការផឹកទឹកស្រវឹង ១ ការមិនប្រមាទក្នុងកុសលធម៌ទាំងឡាយ ១ ដោយប្រការដូច្នេះ ។ ក៏មង្គលទាំងនោះ ជាមង្គល ក៏បានអធិប្បាយក្នុងមង្គលនោះៗ ហើយនោះឯង ។

ចប់សេចក្តីពណ៌នាគាថាថា អារតី

## ពណ៌នាគាថាថា គារវោ ច

ឥឡូវនេះ នឹងពណ៌នាបទក្នុងគាថានេះថា **គារវោ ច** ជាដើមដូចតទៅនេះ ។ បទថា **គារវោ (សេចក្តីគោរព)** បានដល់ ភាពជាអ្នកធ្ងន់ ។ បទថា **និវាតោ (ភាពទន់ភ្លន់)** បានដល់ ការប្រព្រឹត្តទន់ភ្លន់ ។ បទថា **សន្តុដ្ឋិ** ប្រែថា សេចក្តីសន្តោស ។ ការដឹងឧបការៈគុណដែលលោកធ្វើទុក ឈ្មោះថា **កតញ្ញុតា** ។ បទថា **កាលេន** ប្រែថា ខណៈ សម័យ ។ ការស្តាប់ធម៌ ឈ្មោះថា **ធម្មស្សវនៈ** ។ ពាក្យដ៏សេសមានន័យដូចដែលពោលមកហើយនោះឯង នេះជាការពណ៌នាបទ ។

ចំណែកការពណ៌នាសេចក្តី គប្បីជ្រាបដូច្នេះ ។ សេចក្តីគោរព ការធ្វើសេចក្តីគោរព ភាពជាអ្នកមានសេចក្តីគោរព តាមសមគួរ ក្នុងព្រះពុទ្ធ ព្រះបច្ចេកពុទ្ធ ព្រះសាវ័ករបស់ព្រះតថាគត អាចារ្យ ឧបជ្ឈាយ៍ មាតាបិតា បងប្រុស បងស្រីជាដើម ជាអ្នកប្រកបសេចក្តីគោរព ឈ្មោះថា **គារវៈ** ។ គារវៈនោះ ព្រោះជាហេតុនៃការទៅកាន់សុគតិជាដើម ដូចដែលត្រាស់ទុកថា ៖

បុគ្គលធ្វើសេចក្តីគោរពបុគ្គលដែលគួរគោរព សក្ការៈបុគ្គលដែលគួរសក្ការៈ រាប់អានបុគ្គលដែលគួររាប់អាន បូជាបុគ្គលដែលគួរបូជា ។ ព្រោះកម្មនោះ ដែលខ្លួនធ្វើបរិបូណ៌ហើយយ៉ាងនេះ សមាទានហើយយ៉ាងនេះ ខាងមុខពីស្លាប់ព្រោះកាយបែកធ្លាយ គេរមែងចូលដល់សុគតិសួគ៌ទេវលោក ។ បើគេមិនចូលដល់សុគតិសួគ៌ទេវលោកទេ ប្រសិនបើគេមកកើតជាមនុស្ស ក៏នឹងជាបុគ្គលមានវង្សត្រកូលខ្ពង់ខ្ពស់ក្នុងប្រទេសដែលត្រឡប់មកកើត ដូច្នេះ ។

និងដូចដែលត្រាស់ទុកថា ៖

ម្នាលភិក្ខុទាំងឡាយ ធម៌ដែលជាទីតាំងនៃសេចក្តីមិនសាបសូន្យ ៧ ប្រការទាំងនេះ ៧ ប្រការដូចម្តេច គឺ ភាពជាអ្នកមានសេចក្តីគោរពក្នុងព្រះសាស្តា ដូច្នេះជាដើម ដូច្នោះ ទើបត្រាស់ថា "ជាមង្គល" ។

ភាពជាអ្នកមានចិត្តទាប ភាពជាអ្នកមានការប្រព្រឹត្តមិនឃ្មើសឃ្មង

ឈ្មោះថា **ការបន្ទាបខ្លួន** ។ បុគ្គលប្រកបដោយភាពជាអ្នកបន្ទាបខ្លួនណា កម្ចាត់មានះបាន កម្ចាត់សេចក្តីក្រអឺតក្រទមបាន មានខ្លួនដូចជាសំពត់ជូតជើង ស្មើដោយគោឧសភៈបាក់ស្នែង និងស្មើដោយពស់ដែលត្រូវដកពិសចេញហើយ រមែងជាអ្នកល្អិតល្អន់ ទន់ភ្លន់ផូរផង់ប្រកបដោយសេចក្តីសុខ ភាពជាអ្នកបន្ទាបខ្លួននេះ ជានិវាតៈ និវាតៈនោះ ត្រាស់ថា "ជាមង្គល" ព្រោះជាហេតុបាននូវគុណ មានយសជាដើម ។ មម្យ៉ាងទៀត ត្រាស់ទុកថា "បុគ្គលមានការបន្ទាបខ្លួន មិនក្រអឺតប្រទម បុគ្គលនោះ រមែងបានយស" ដូច្នេះ ជាដើម ។

សេចក្តីសន្តោសដោយបច្ច័យតាមមានតាមបាន ឈ្មោះថា **សន្តោស** ។ សន្តោសនោះមាន ១២ យ៉ាង គឺ ក្នុងចីវរ ៣ យ៉ាង គឺ យថាលាភ-សន្តោស (សន្តោសតាមដែលបាន) យថាពលសន្តោស (សន្តោសតាមកម្លាំង) យថាសារុប្បសន្តោស (សន្តោសតាមសមគួរ) ។ ក្នុងបិណ្ឌបាតជាដើមក៏ដូចគ្នា ។

នឹងពណ៌នាប្រភេទនៃសន្តោសនោះ ដូច្នេះ ។ ភិក្ខុក្នុងព្រះធម្មវិន័យ

នេះ បានចីវរល្អ ឬមិនល្អ ភិក្ខុនោះក៏ញុំាងអត្តភាពឲ្យប្រព្រឹត្តទៅដោយចីវរនោះប៉ុណ្ណោះ មិនប្រាថ្នាចីវរនោះ កាលបានក៏មិនទទួល នេះឈ្មោះថា យ-ថាលាភសន្តោស ក្នុងចីវររបស់ភិក្ខុនោះ ។

ម្យ៉ាងវិញទៀត ភិក្ខុអាពាធកាលគ្រងចីវរធ្ងន់ រមែងត្រូវគមខ្នង ឬលំបាក លោកទើបប្តូរចីវរនោះជាមួយភិក្ខុដែលស្រឡាញ់គ្នា ញុំាងអត្តភាពឲ្យប្រព្រឹត្តទៅដោយចីវរស្រាលនោះ ក៏នៅជាអ្នកសន្តោស នេះឈ្មោះថា យថាពលសន្តោស ក្នុងចីវររបស់ភិក្ខុនោះ ។

ភិក្ខុមួយរូបទៀត ជាអ្នកបានបច្ច័យដ៏ប្រណីត លោកបានចីវរបណ្តាចីវរសាច់ល្អជាដើមណាមួយ ដែលមានតម្លៃច្រើន គិតថា ចីវរនេះសមគួរដល់ព្រះថេរៈ ភិក្ខុបួសយូរ និងភិក្ខុជាពហុស្សូត ទើបថ្វាយដល់ភិក្ខុទាំងនោះ ខ្លួនឯងក៏លើកយកសំពត់ដ៏សេសអំពីគំនរសម្រាម ឬអំពីទីដទៃណាៗ ធ្វើសង្ឃាដិគ្រង ក៏នៅជាអ្នកសន្តោសដូចគ្នា នេះឈ្មោះថា យថាសារុប្ប-សន្តោស ក្នុងចីវររបស់ភិក្ខុនោះ ។

មួយទៀត ភិក្ខុក្នុងធម្មវិន័យនេះ បានបិណ្ឌបាត ថោកទាប ឬប្រណីត

ញុំាងអត្តភាពឲ្យប្រព្រឹត្តទៅដោយបិណ្ឌបាតនោះ មិនបំណាងបិណ្ឌបាតដទៃ ។ សូម្បីបានក៏មិនទទួល នេះឈ្មោះថា **យថាលាភសន្តោស** ក្នុងបិណ្ឌបាតរបស់ភិក្ខុនោះ ។

មួយទៀត ភិក្ខុអាពាធឆាន់បិណ្ឌបាតស្មោហ្មង រោគនឹងកម្រើកធ្ងន់ឡើង លោកទើបថ្វាយបិណ្ឌបាតនោះដល់ភិក្ខុដែលត្រូវគ្នា ឆាន់ទឹកដោះថ្លាទឹកឃ្មុំ និងទឹកដោះស្រស់ជាដើម ពីដៃភិក្ខុនោះ ហើយធ្វើសមណធម៌ ក៏នៅជាអ្នកសន្តោស នេះឈ្មោះថា **យថាពលសន្តោស** ក្នុងបិណ្ឌបាតរបស់ភិក្ខុនោះ ។

ភិក្ខុមួយរូបទៀត បានបិណ្ឌបាតដ៏ប្រណីត លោកគិតថា បិណ្ឌបាតនេះសមគួរដល់ព្រះថេរៈ ដែលបួសយូរ និងសូម្បីដល់សព្រហ្មចារីដទៃ អ្នកវៀរបិណ្ឌបាតដ៏ប្រណីតចេញ ក៏ញុំាងអត្តភាពឲ្យប្រព្រឹត្តទៅមិនបាន ទើបបានថ្វាយដល់ភិក្ខុទាំងនោះ ខ្លួនឯងត្រាច់បិណ្ឌបាត សូម្បីឆាន់អាហារដែលលាយគ្នា ក៏នៅជាអ្នកសន្តោស នេះឈ្មោះថា **យថាសារុប្បសន្តោស** ក្នុងបិណ្ឌបាតរបស់ភិក្ខុនោះ ។

មួយទៀត សេនាសនៈមានដល់ភិក្ខុក្នុងធម្មវិន័យនេះ លោកក៏សន្តោស ដោយសេនាសនៈនោះឯង មិនព្រមទទួលសេនាសនៈដទៃសូម្បីល្អជាងដែល កើតមានដល់ខ្លួនទៀត នេះឈ្មោះថា **យថាលាភសន្តោស** ក្នុងសេនាសនៈ របស់ភិក្ខុនោះ ។

មួយទៀត ភិក្ខុអាពាធនៅក្នុងសេនាសនៈដែលហប់ខ្យល់ រមែងនឹង ទុរន់ទុរាខ្លាំងឡើង ដោយរោគប្រមាត់ជាដើម លោកនឹងថ្វាយសេនាសនៈ ដល់ភិក្ខុដែលពេញចិត្តគ្នា ហើយនៅក្នុងសេនាសនៈដែលត្រជាក់ មានខ្យល់ ដែលសមគួរដល់ភិក្ខុនោះ ហើយសូម្បីធ្វើសមណធម៌ ក៏នៅជាអ្នកសន្តោស នេះឈ្មោះថា **យថាពលសន្តោស** ក្នុងសេនាសនៈរបស់ភិក្ខុនោះ ។

ភិក្ខុមួយរូបទៀត មិនព្រមទទួលសេនាសនៈដែលល្អសូម្បីមានដល់ ខ្លួន គិតថា សេនាសនៈល្អជាទីតាំងនៃសេចក្តីប្រមាទ កាលភិក្ខុអង្គុយក្នុង សេនាសនៈនោះ ថីនមិទ្ធៈរមែងគ្របសង្កត់ កាលលក់ហើយក្រោកឡើង មកទៀត កាមវិតក្កៈរមែងកើតឡើង លោកទើបបដិសេធសេនាសនៈនោះ នៅក្នុងទីដែលមានពន្លឺ គល់ឈើ និងកុដិប្រក់ដោយស្លឹកឈើស្ងួតយ៉ាង

ណាមួយ ក៏នៅជាអ្នកសន្តោស នេះឈ្មោះថា **យថាសារុប្បសន្តោស** ក្នុងសេនាសនៈរបស់ភិក្ខុ ។

មួយទៀត ភិក្ខុក្នុងធម្មវិន័យនេះ បានភេសជ្ជៈមិនថា ផ្លែសម៉ ឬកន្ទួតព្រៃ លោកក៏ញ៉ាំងអត្តភាពឲ្យប្រព្រឹត្តទៅដោយភេសជ្ជៈនោះ មិនប្រាថ្នាភេសជ្ជៈដទៃ មានទឹកដោះថ្លា ទឹកឃ្មុំ ទឹកអំពៅជាដើមដែលបានហើយ សូម្បីកាលបានក៏មិនទទួល នេះឈ្មោះថា **យថាលាភសន្តោស** ក្នុងគិលានប្បច្ច័យរបស់ភិក្ខុនោះ ។

មួយទៀត ភិក្ខុអាពាធ ត្រូវការប្រេង តែបានទឹកអំពៅ លោកក៏ថ្វាយទឹកអំពៅនោះដល់ភិក្ខុដែលជាសំឡាញ់ តែត្រូវការថ្នាំដោយប្រេងពីដៃរបស់ភិក្ខុនោះ សូម្បីធ្វើសមណធម៌ ក៏នៅជាអ្នកសន្តោស នេះឈ្មោះថា **យថាពលសន្តោស** ក្នុងគិលានប្បច្ច័យរបស់ភិក្ខុនោះ ។

ភិក្ខុមួយរូបទៀត ដាក់សម៉ត្រាំជាមួយមូត្រស្អុយចុះក្នុងភាជនៈមួយ ដាក់របស់មានរសជាតិផ្អែម ៤ យ៉ាង ចុះក្នុងភាជនៈមួយ កាលត្រូវភិក្ខុជាមិត្តប្រាប់ថា "លោកត្រូវការវត្ថុណា ក៏កាន់យកចុះ" ប្រសិនបើ អាពាធ

របស់ភិក្ខុនោះស្ងប់ដោយថ្នាំត្រាំទឹកមូត្រស្អុយ និងរសជាតិផ្អែមទាំង ២ នោះណាមួយសោត ដូច្នោះ លោកគិតថា ធម្មតាថា ថ្នាំត្រាំដោយមូត្រស្អុយព្រះពុទ្ធជាដើមសរសើរហើយ និងព្រះពុទ្ធត្រាស់ថា បព្វជិតអាស្រ័យមូត្រស្អុយជាភេសជ្ជៈ គប្បីធ្វើសេចក្តីឧស្សាហៈក្នុងមូត្រស្អុយជាភេសជ្ជៈនោះរហូតអស់ជីវិត បដិសេធរបស់មានរសផ្អែមជាភេសជ្ជៈ ៤ យ៉ាង សូម្បីធ្វើភេសជ្ជៈដោយសម៉ត្រាំទឹកមូត្រស្អុយ ក៏ជាអ្នកសន្តោសយ៉ាងក្រៃលែងនេះឈ្មោះថា យថាសារុប្បសន្តោស ក្នុងគិលានប្បច្ច័យរបស់ភិក្ខុនោះ ។

សន្តោសសូម្បីទាំងអស់នោះ មានប្រភេទដូច្នេះ ក៏ហៅថា សន្តុដ្ឋី ។ សន្តុដ្ឋីនោះ គប្បីជ្រាបថា "ជាមង្គល" ព្រោះជាហេតុលះបង់បាបធម៌ទាំងឡាយ មានការប្រាថ្នាហួសព្រំដែន ការប្រាថ្នាច្រើន និងការប្រាថ្នាលាមកជាដើម ព្រោះជាហេតុនៃសុគតិ ព្រោះជាគ្រឿងអប់រំអរិយមគ្គ និងព្រោះជាហេតុនៃភាពជាអ្នករស់នៅបានសប្បាយក្នុងទិសទាំង ៤ ។ ដូចដែលព្រះមានព្រះភាគត្រាស់ទុកថា ៖

បុគ្គលសន្តោសដោយបច្ច័យតាមមានតាមបាន រមែងជាអ្នក

នៅសប្បាយក្នុងទិសទាំង ៤ និងមិនមានបដិឃៈឡើយ

ដូច្នេះជាដើម ។

ការដឹងឧបការៈគុណដែលបុគ្គលណាមួយធ្វើមកហើយ មិនថាតិច ឬច្រើន ដោយការរឭករឿយៗ ឈ្មោះថា **កតញ្ញុតា** ។ មួយទៀត បុណ្យទាំងឡាយនោះឯង មានឧបការៈច្រើនដល់សត្វទាំងឡាយ ព្រោះការពារទុក្ខ មានទុក្ខក្នុងនរកជាដើមបាន ។ ដូច្នោះ ការរឭកដល់ឧបការៈរបស់បុណ្យសូម្បីទាំងនោះ ក៏គប្បីជ្រាបថា ជាកតញ្ញុតា ។ កតញ្ញុតានោះ ទ្រង់ត្រាស់ថា ជាមង្គល ព្រោះជាហេតុប្រសព្វផលវិសេសមានប្រការផ្សេងៗ ដែលសប្បុរសទាំងឡាយគប្បីសរសើរជាដើម ។ ទាំងព្រះដ៏មានព្រះភាគក៏ត្រាស់ទុកថា "ម្នាលភិក្ខុទាំងឡាយ បុគ្គល ២ ពួកទាំងនេះ រកបានដោយក្រក្នុងលោក បុគ្គល ២ ពួក ដូចម្ដេច គឺ បុព្វការី ១ កតញ្ញូកតវេទី ។

ការស្ដាប់ធម៌ ដើម្បីបន្ទោរបង់វិតក្កៈ មានកាមវិតក្កៈជាដើម ក្នុងកាលដែលចិត្តប្រកបដោយឧទ្ធច្ចៈ ឬក្នុងកាលដែលចិត្តត្រូវវិតក្កៈទាំងឡាយមានកាមវិតក្កៈជាដើមណាមួយគ្របសង្កត់ ឈ្មោះថា **ការស្ដាប់ធម៌តាមកាល** ។

អាចារ្យពួកមួយពោលថា "ការស្តាប់ធម៌រាល់ៗ ៥ ថ្ងៃ ឈ្មោះថា ការស្តាប់ធម៌តាមកាល" ដូចដែលលោកពោលថា "ព្រះអនុរុទ្ធៈ ក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ពួកខ្ញុំព្រះអង្គអង្គុយប្រជុំសន្ទនាគ្នាដោយធម្មីកថា មួយយប់ទល់ភ្លឺ រាល់ៗ ៥ ថ្ងៃ ។

មួយទៀត ក្នុងកាលណា ភិក្ខុចូលរកកល្យាណមិត្រហើយ អាចស្តាប់ធម៌បន្ទោរបង់សេចក្តីសង្ស័យរបស់ខ្លួនចេញបាន ការស្តាប់ធម៌សូម្បីកាលនោះ ក៏គប្បីជ្រាបថា ការស្តាប់ធម៌តាមកាល ដូចដែលព្រះមានព្រះភាគត្រាស់ទុកថា "ភិក្ខុចូលទៅរកកល្យាណមិត្រទាំងនោះ សាកសួរដេញដោលរហូតអស់កាល តាមកាល" ។ ការស្តាប់ធម៌តាមកាលនោះ គប្បីជ្រាបថាជាមង្គល ព្រោះជាហេតុប្រសព្វផលវិសេសច្រើនប្រការ មានការលះនីវរណៈបាន មានអានិសង្ស ៤ និងសម្រេចធម៌ជាទីអស់ទៅនៃអាសវៈជាដើម ។ សមពិតដូចដែលព្រះមានព្រះភាគត្រាស់ទុកថា ៖

ម្នាលភិក្ខុទាំងឡាយ ក្នុងសម័យណា អរិយសាវ័កដាក់ចិត្តធ្វើឲ្យជាប្រយោជន៍ រួបរួមគ្រប់យ៉ាងទុកដោយចិត្ត

ផ្ទៀងត្រចៀកស្តាប់ធម៌ ក្នុងសម័យនោះ នីវរណៈ ៥ របស់អរិយសាវកនោះ រមែងមិនមាន ។

និងថា

ម្នាលភិក្ខុទាំងឡាយ គប្បីប្រាថ្នាអានិសង្ស ៤ ប្រការ នៃធម៌ទាំងឡាយដែលធ្លាប់ស្តាប់ ។ល។ ដែលចាក់ធ្លុះ ដោយល្អហើយ ។

និងថា

ម្នាលភិក្ខុទាំងឡាយ ធម៌ទាំង ៤ នេះ ដែលអប់រំដោយល្អ ដំណើរការដោយល្អ រហូតកាល តាមកាល រមែងឲ្យដល់ធម៌ជាទីអស់អាសវៈដោយលំដាប់ ធម៌ ៤ ប្រការដូចម្តេច គឺ ការស្តាប់ធម៌តាមកាល យ៉ាងនេះជាដើម ។

ព្រះមានព្រះភាគត្រាស់មង្គលនៃគាថានេះទុក ៥ មង្គល គឺ សេចក្តីគោរព ១ ការបន្ទាបខ្លួន ១ សន្តោស ១ កតញ្ញុតា ១ និងការស្តាប់ធម៌តាមកាល ១ ដោយប្រការដូច្នេះ ។ មង្គលទាំងនោះ ក៏បានអធិប្បាយទុក

*ក្នុងមណ្ឌលនោះៗ ហើយ នោះឯង ។*

ចប់សេចក្តីពណ៌នាគាថានេះថា ការពោ ៥

## ពណ៌នាគាថាថា ខន្តី ច

ឥឡូវនេះ នឹងពណ៌នាបទក្នុងគាថានេះថា **ខន្តិ ច** ជាដើមដូចតទៅនេះ សេចក្តីអត់ធន់ ឈ្មោះថា **ខន្តិ** ។ ឈ្មោះថា **សុវចៈ** ព្រោះមានសេចក្តីថា ងាយ ព្រោះជាអ្នកកាន់យកដោយខាងស្តាំ (គោរព) កម្មរបស់បុគ្គលប្រដៅងាយ ឈ្មោះថា សោវចស្សៈ ភាពនៃកម្មរបស់បុគ្គលប្រដៅងាយ ឈ្មោះថា **សោវចស្សតា** ។ ឈ្មោះថា **សមណៈ** ព្រោះស្ងប់កិលេសទាំងឡាយបាន ។ បទថា **ទស្សនំ (ការឃើញ)** បានដល់ ការសម្លឹងមើល ។ ការសន្ទនាធម៌ ឈ្មោះថា **ធម្មសាកច្ឆា** ។ ពាក្យដ៏សេស មានន័យដូចដែលពោលហើយនោះឯង ។ នេះជាការពណ៌នាបទ ។

ចំណែកការពណ៌នាអត្ថ គប្បីជ្រាបដូច្នេះ ។ អធិវាសនខន្តិ ឈ្មោះថា **ខន្តិ** ភិក្ខុអ្នកប្រកបដោយខន្តិនោះឯង រមែងមិនមានអាការខុសប្រក្រតីដូចអ្នកដែលមិនបានឮបុគ្គលដែលជេរដោយអក្កោសវត្ថុ ១០ និងដូចអ្នកដែលមិនបានឃើញបុគ្គលដែលបៀតបៀនដោយការសម្លាប់ និងការចងជាដើម ដូចខន្តិវាទីតាបស ដូច្នោះ ។ ដូចដែលព្រះមានព្រះភាគត្រាស់ថា ៖

សមណៈអ្នកសំដែងខន្តិ មានមកហើយក្នុងអតីតកាល
ព្រះរាជាដែនកាសីទ្រង់បានទម្លាយសមណៈអ្នកតាំងនៅ
ក្នុងខន្តិនោះឯង ។

ឬរមែងដាក់ចិត្តថា គេធ្វើល្អហើយ ព្រោះមិនមានការខុសក្រៃលែងជាងនោះទៀត ដូចព្រះបុណ្ណត្ថេរៈ ដូច្នោះ ។ ដូចលោកក្រាបទូលថា ៖

បពិត្រព្រះអង្គដ៏ចម្រើន បើអ្នកស្រុកសុនាបរន្តៈ នឹងជេរ
នឹងបរិភាស ខ្ញុំព្រះអង្គសោត ក្នុងកាលនោះ ខ្ញុំព្រះអង្គ
នឹងធ្វើទុកក្នុងចិត្តថា អ្នកស្រុកសុនាបរន្តៈទាំងនេះ ជាអ្នក
ចម្រើនហ្ន៎ អ្នកស្រុកសុនាបរន្តៈទាំងនេះ ជាអ្នកចម្រើន
ដោយល្អហ្ន៎ មនុស្សទាំងនេះមិនវាយខ្ញុំព្រះអង្គដោយដៃ
ដូច្នេះជាដើម ។

និងកាលភិក្ខុប្រកបដោយខន្តិនោះឯង រមែងជាអ្នកដែលឥសីទាំងឡាយក៏គប្បីសរសើរ ។ ដូចសរភង្គឥសីពោលទុកថា ៖

បុគ្គលសម្លាប់សេចក្តីក្រោធបានហើយ រមែងមិនសោកសៅ

កុងកាលណាៗ ឥសីទាំងឡាយរមែងសរសើរការលះបង់

សេចក្តីលប់គុណ បុគ្គលគួរអត់ធន់នឹងពាក្យគ្រោតគ្រាត

ដែលមនុស្សទាំងឡាយពោលហើយ សប្បុរសទាំងឡាយ

សរសើរខន្តិនោះថា ប្រសើបំផុត ។

រមែងជាអ្នកដែលទេវតាទាំងឡាយគប្បីសរសើរ ។ ដូចដែលសក្កទេវរាជត្រាស់ទុកថា ៖

បុគ្គលណាជាអ្នករឹងមាំ អត់អន់ចំពោះមនុស្សទន់ខ្សោយ

សប្បុរសទាំងឡាយសរសើរខន្តិនោះរបស់បុគ្គលនោះថា

ជាកំពូល បុគ្គលទន់ខ្សោយរមែងត្រូវអត់ធន់ជាប្រចាំ ។

រមែងជាបុគ្គលដែលព្រះពុទ្ធទាំងឡាយក៏គប្បីសរសើរ ។ ដូចដែលព្រះមានព្រះភាគត្រាស់ទុកថា ៖

បុគ្គលណាមិនក្រោធ អត់ទ្រាំការជេរ ការសម្លាប់ និង

ការចងបាន តថាគតហៅបុគ្គលនោះ ដែលមានខន្តិជា

កម្លាំង មានកម្លាំងនោះឯង ថាជាព្រាហ្មណ៍ ។

ក៏ខន្តិនោះឯង គប្បីជ្រាបថា "ជាមង្គល" ព្រោះជាហេតុប្រសព្វគុណទាំងនោះ និងគុណដទៃៗ ដែលទ្រង់សរសើរក្នុងទីនេះ ។

កាលត្រូវសព្រហ្មចារីទូន្មានដោយធម៌ ក៏មិនមានសេចក្ដីរាយមាយរវើរវាយ ឬគិតដល់គុណ និងទោស ដាក់សេចក្ដីអើពើ សេចក្ដីគោរព និងមិនមានការបណ្ដែតបណ្ដោយចិត្ត ហើយបន្លឺវាចាថា "សាធុៗ" ដូច្នេះ ឈ្មោះថា **សោវចស្សតា (ការប្រដៅងាយ)** ។ សោវចស្សតានោះ ត្រាស់ថា "ជាមង្គល" ព្រោះជាហេតុបានឱវាទ និងអនុសាសនី អំពីសម្នាក់សព្រហ្មចារីទាំងឡាយ និងព្រោះជាហេតុលះទោស និងសម្រេចគុណ ។

ការចូលទៅរកការទំនុកបម្រុង រឭក ការស្ដាប់ និងការឃើញនូវបព្វជិតទាំងឡាយអ្នកស្ងប់កិលេសហើយ អប់រំកាយ វាចា ចិត្ត និងបញ្ញា ប្រកបដោយសេចក្ដីអត់ធន់ និងដោយសេចក្ដីស្ងប់ប្រណីត ឈ្មោះថា **ការឃើញសមណៈ** ។ ការឃើញសមណៈសូម្បីទាំងអស់នោះ លោកពោលថា "ទស្សនៈ" ដោយទេសនាយ៉ាងទាប ។ ការឃើញសមណៈនោះ គប្បីជ្រាបថា ជាមង្គល ។ ព្រោះហេតុអ្វី? ព្រោះមានឧបការៈច្រើន ។ ពិតណាស់

ព្រះមានព្រះភាគត្រាស់ទុកជាដើមថា “ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា ការឃើញភិក្ខុទាំងនោះ មានឧបការច្រើន” ។ ព្រោះបុណ្យណា កុល-បុត្រអ្នកត្រូវការប្រយោជន៍ ឃើញភិក្ខុទាំងឡាយអ្នកមានសីលមកដល់ទ្វារផ្ទះ បើថាទេយ្យធម៌មាន ក៏គប្បីបង្អោនថ្វាយដោយទេយ្យធម៌ តាមកម្លាំងប្រសិនបើមិនមានទេ ក៏គប្បីថ្វាយបង្គំដោយបញ្ចង្គប្រតិស្ឋាន ។ សូម្បីមិនអាចថ្វាយបង្គំដោយបញ្ចង្គប្រតិស្ឋាន ក៏គប្បីផ្គងអញ្ជលីនមស្ការ កាលបើមិនអាច ក៏គប្បីមានចិត្តជូរផង់ មើលដោយចក្ខុដែលគួរស្រឡាញ់ ។ ដោយបុណ្យដែលមានការក្រឡេកមើលជាមូលយ៉ាងនេះ រោគ ឬសេចក្តីក្តៅក្រហាយ ភាពព្រិល ឬស្រវាំងមិនមានក្នុងភ្នែក រហូតអស់ច្រើនពាន់ជាតិចក្ខុទាំងពីរក៏នឹងថ្លាស្អាត មានសិរី មានវណ្ណៈ ៥ ដូចទ្វារផ្ទះកែវមណីដែលបើកក្នុងរតនៈវិមាន គេនឹងបានសម្បត្តិក្នុងទេវតា និងមនុស្សប្រមាណ ១០០.០០០ កប្ប ។ កាលដែលគេកើតជាមនុស្ស ក៏ជាមនុស្សមានបញ្ញាគប្បីសោយវិបាកសម្បត្តិបែបនេះ ក៏ដោយបុណ្យដែលសម្រេចមកអំពីការឃើញសមណៈ ដែលគេប្រព្រឹត្តមកដោយល្អ មិនគួរអស្ចារ្យឡើយ សូម្បី

សត្វតិរច្ឆាន បណ្ឌិតទាំងឡាយក៏ពណ៌នាផលសម្បត្តិនៃការឃើញសមណៈ ដែលត្រឹមតែធ្វើសទ្ធាឲ្យកើតហើយ តែម្យ៉ាងទុកយ៉ាងនេះ ក្នុងបាលីប្រទេស ណា បាលីប្រទេសនោះថា ៖

សត្វទីទុយក្អែកមូល អាស្រ័យនៅវេទិយកបព៌ត

អស់កាលយូរ សត្វទីទុយនេះសុខពិតហ្ន៎ ឃើញព្រះពុទ្ធ

ទ្រង់ជាបុគ្គលដ៏ប្រសើរ ដែលស្តេចក្រោកឡើងពីព្រឹក ។

ទីទុយនោះធ្វើចិត្តឲ្យជ្រះថ្លាក្នុងតថាគត និងភិក្ខុសង្ឃ

ដ៏ប្រសើរបំផុត មិនទៅកាន់ទុគ្គតិអស់មួយសែនកប្ប

កាលចុតិចាកទេវលោក ត្រូវកុសលកម្មដាស់តឿនហើយ

និងជាព្រះពុទ្ធមានអនន្តញ្ញាណ ប្រាកដព្រះនាមថា សោ-

មនស្សៈ ដូច្នេះ ។

ក្នុងវេលាព្រលប់ ឬក្នុងវេលាព្រលឹម ភិក្ខុខាងព្រះសូត្រ ២ រូប រមែងសន្ទនាព្រះសូត្រ ខាងព្រះវិន័យធរ ក៏សន្ទនាព្រះវិន័យ ចំណែកខាង ព្រះអភិធម្ម ក៏សន្ទនាព្រះអភិធម្មជាមួយគ្នា ឬសន្ទនាគ្នាក្នុងកាលនោះ ៗ

ដើម្បីជម្រះចិត្តដែលត្រូវសេចក្ដីវិលប្រអូស សេចក្ដីពាយមាយ និងសេចក្ដីសង្ស័យដែលនាំទៅ កាលសន្ទនាតាមកាលនេះ ឈ្មោះថា **ការសន្ទនាធម៌តាមកាល** ។ ការសន្ទនាធម៌តាមកាលនោះ ត្រាស់ថា "ជាមង្គល" ព្រោះជាហេតុនៃគុណទាំងឡាយ មានការឈ្លាសក្នុងអាគម គឺ និកាយទាំង ៥ ជាដើមនោះឯង ។

ព្រះមានព្រះភាគត្រាស់មង្គលនៃគាថានេះទុក ៤ មង្គល គឺ សេចក្ដីអត់ធន់ ១ ភាពជាអ្នកប្រដៅងាយ ១ ការឃើញសមណៈ ១ និងការសន្ទនាធម៌តាមកាល ១ ដោយប្រការដូច្នេះ ។ ក៏មង្គលទាំងនោះ បានអធិប្បាយទុកក្នុងមង្គលនោះៗ ហើយ ។

ចប់សេចក្ដីពណ៌នាគាថានេះថា ១ដ្ឋិ ៨

## ពណ៌នាគាថាថា តបោ ច

ឥឡូវនេះ នឹងពណ៌នាបទក្នុងគាថានេះថា **តបោ ច** ជាដើម ដូចតទៅនេះ ។ ឈ្មោះថា **តបៈ** ព្រោះដុតបាបធម៌ ។ ការប្រព្រឹត្តដូចព្រហ្ម ឬការប្រព្រឹត្តរបស់ព្រហ្ម ឈ្មោះថា **ព្រហ្មចរិយៈ** ។ លោកអធិប្បាយថា ការប្រព្រឹត្តដ៏ប្រសើរ ។ ការឃើញអរិយសច្ចៈទាំងឡាយ ឈ្មោះថា **អរិយសច្ចាន ទស្សនំ** ។ អាចារ្យពួកខ្លះពោលថា **អរិយសច្ចានិ ទស្សនំ** ដូច្នេះក៏មាន ពាក្យនោះមិនត្រឹមត្រូវ ។ ឈ្មោះថា **និព្វាន** ព្រោះចេញចាកវានៈ តណ្ហាគ្រឿងចង ការធ្វើឲ្យជាក់ច្បាស់ ឈ្មោះថា **សច្ឆិកិរិយា** ។ ការធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វាន ឈ្មោះថា **និព្វានសច្ឆិកិរិយា** ។ ពាក្យដ៏សេសមានន័យដូចដែលពោលមកហើយនោះឯង នេះជាការពណ៌នាបទ ។

ចំណែកការពណ៌នាសេចក្តី គប្បីជ្រាបដូច្នេះ ឥន្ទ្រិយសំវរៈ ឈ្មោះថា **តបៈ** ព្រោះដុតអភិជ្ឈា និងទោមនស្សជាដើម ឬសេចក្តីព្យាយាម ឈ្មោះថា **តបៈ** ព្រោះដុតសេចក្តីខ្ជិលច្រអូស បុគ្គលអ្នកប្រកបដោយតបៈនោះ លោកហៅថា **អាតាបី** តបៈនេះ គប្បីជ្រាបថា "ជាមង្គល" ព្រោះជាហេតុ

លះអភិជ្ឈាជាដើម និងបានឈានជាដើម ។

ឈ្មោះថា *ព្រហ្មចរិយៈ* ជាឈ្មោះរបស់ មេថុនវិរតិ សមណធម៌ សាសនា និង មគ្គ ។ ពិតហើយ មេថុនវិរតិ លោកហៅថា ព្រហ្មចរិយៈ បានក្នុងប្រយោគជាដើមថា *អព្រហ្មចរិយំ បហាយ ព្រហ្មចារី ហោតិ* លះអព្រហ្មចរិយៈ ជាព្រហ្មចារី ។ សមណធម៌ ហៅថា ព្រហ្មចរិយៈ បានក្នុងប្រយោគជាដើមយ៉ាងនេះថា *ភគវតិ នោ អាវុសោ ព្រហ្មចរិយំ វុស្សតិ* អ្នកមានអាយុ យើងប្រព្រឹត្តសមណធម៌ ក្នុងសាសនារបស់ព្រះមានព្រះ-ភាគ ។

សាសនា ហៅថា ព្រហ្មចរិយៈ បានក្នុងប្រយោគជាដើមយ៉ាងនេះថា *ន តាវាហំ បាបិម បរិនិព្វាយិស្សាមិ យាវ មេ ឥទំ ព្រហ្មចរិយំ ន ឥទ្ធញ្ចេវ ភវិស្សតិ ផីតញ្ច វិត្ថារិកំ ពាហុជញ្ញំ* មារមានបាប ដរាបណាសាសនារបស់តថាគត នៅមិនទាន់តាំងមាំ ចម្រើនដល់បរិស័ទផងគ្នាទេ តថាគតក៏មិនទាន់បរិនិព្វានត្រឹមនោះ ។

មគ្គ ហៅថា ព្រហ្មចរិយៈ បានក្នុងប្រយោគជាដើមយ៉ាងនេះថា

**អយមេវ ខោ ភិក្ខវេ អរិយោ អដ្ឋង្គិកោ មគ្គោ ព្រហ្មចរិយំ ។ សេ-យ្យថីទំ សម្មាទិដ្ឋិ** ម្នាលភិក្ខុទាំងឡាយ អរិយមគ្គមានអង្គ ៨ គឺ សម្មា-ទិដ្ឋិជាដើម ជាព្រហ្មចរិយៈ តែក្នុងទីនេះ ព្រហ្មចរិយៈសូម្បីគ្រប់យ៉ាង ក៏រមែងគួរ ព្រោះមគ្គ លោកសង្គ្រោះដោយអរិយសច្ចទស្សនៈ ខាងមុខហើយ ។ ក៏ព្រហ្មចរិយៈនោះ គប្បីជ្រាបថា "ជាមង្គល" ព្រោះជាហេតុប្រសព្វផលវិសេសច្រើនប្រការ ។

ការឃើញមគ្គ ដោយត្រាស់ដឹងអរិយសច្ចៈ ៤ ដែលពោលទុកហើយក្នុងកុមារបញ្ហា ឈ្មោះថា **អរិយសច្ចានទស្សនៈ** ។ អរិយសច្ចានទស្សនៈនោះ ត្រាស់ថា "ជាមង្គល" ព្រោះជាហេតុកន្លងទុក្ខក្នុងសង្សារវដ្ដ ។

អរហត្តផល លោកបំណងយកថា **និព្វាន** ក្នុងទីនេះ ឈ្មោះថា **និព្វានសច្ឆិកិរិយា (ការធ្វើឲ្យជាក់ច្បាស់ព្រះនិព្វាន)** ។ ពិតហើយ អរហត្ត-ផលនោះ លោកពោលថា "និព្វាន" ព្រោះចេញចាកតណ្ហា ដែលគេដឹងថា **វាន:** ព្រោះចងទុកក្នុងគតិ ៥ ។ ការដល់ ឬការពិចារណាព្រះនិព្វាននោះហៅថា **សច្ឆិកិរិយា** ។ តែការធ្វើឲ្យជាក់ច្បាស់ព្រះនិព្វានក្រៅពីនេះ សម្រេច

បាន ដោយការឃើញអរិយសច្ចៈ ៤ នោះឯង ព្រោះហេតុនោះ ការឃើញអរិយសច្ចៈនោះ លោកទើបមិនបំណានក្នុងទីនេះ ។ ការធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វាននោះ គប្បីជ្រាបថា ជាមង្គល ព្រោះជាហេតុនៅជាសុខក្នុងបច្ចុប្បន្នជាដើម ដោយប្រការដូច្នេះ ។

ព្រះមានព្រះភាគត្រាស់មង្គលនៃគាថានេះទុក ៤ មង្គល គឺ តបៈ ១ ព្រហ្មចរិយៈ ១ អរិយសច្ចានទស្សនៈ ១ និងនិព្វានសច្ឆិកិរិយា ១ ដោយប្រការដូច្នេះ ។ ក៏មង្គលទាំងនោះ ជាមង្គល បានអធិប្បាយទុកក្នុងមង្គលនោះៗ ឯង ។

ចប់សេចក្តីពណ៌នាគាថានេះថា តបោ ច

## ពណ៌នាគាថាថា ផុដ្ឋស្ស លោកធម្មេហិ

ឥឡូវនេះ នឹងពណ៌នាបទក្នុងគាថានេះថា **ផុដ្ឋស្ស លោកធម្មេហិ** ដូចតទៅនេះ ។ បទថា **ផុដ្ឋស្ស (អ្នកដែលត្រូវ... ប៉ះខ្ទប់ហើយ)** បានដល់ អ្នក (ត្រូវលោកធម៌) ប៉ះខ្ទប់ហើយ គឺ ពាល់ត្រូវហើយ បានដល់ដល់ព្រមហើយ ។ ធម៌ទាំងឡាយក្នុងលោក ឈ្មោះថា **លោកធម៌** ។ លោកអធិប្បាយថា ធម៌ទាំងឡាយនឹងមិនវិលត្រឡប់ ដរាបណាដែលលោកនៅប្រព្រឹត្តទៅ ។ បទថា **ចិត្តំ (ចិត្ត)** បានដល់ មនោ មានស្ស ។ បទថា **យស្ស** បានដល់ របស់ភិក្ខុថ្មី ភិក្ខុកណ្តាល ឬភិក្ខុជាថេរៈ ។ បទថា **ន កម្បតិ (មិនញាប់ញ័រ)** បានដល់ មិនញាប់ញ័រ ។ ទបថា **អសោកំ (មិនសោកសៅ)** បានដល់ គ្មានសេចក្តីសោក អ្នកមានសេចក្តីសោកដូចត្រូវសរដែលដកហើយ ។ បទថា **វិរជំ (មិនសៅហ្មង)** បានដល់ ប្រាសចាកធូលី គឺ កិលេស កម្ចាត់ធូលី គឺ កិលេសហើយ ។ បទថា **ខេមំ (ក្សេម)** បានដល់ មិនមានភ័យ គ្មានឧបទ្រវៈ ។ ពាក្យដ៏សេសមានន័យដូចបានពោលទុកហើយនោះឯង នេះជាការពណ៌នាបទ ។

ចំណែកការពណ៌នាអត្ថ គប្បីជ្រាបដូច្នេះ ចិត្តរបស់បុគ្គលណា ដែលលោកធម៌ ៨ មានលាភ មិនមានលាភ ជាដើម គ្របសង្កត់ហើយ រមែងមិនខ្វាច មិនញាប់ញ័រ ឈ្មោះថា **ចិត្តរបស់បុគ្គលដែលត្រូវលោកធម៌ពាល់ត្រូវហើយមិនញាប់ញ័រ** ចិត្តនោះរបស់បុគ្គលនោះគប្បីជ្រាបថា ជាមង្គល ព្រោះនាំមកនៅភាពជាបុគ្គលខ្ពង់ខ្ពស់លើលោក នៅធម៌ណាៗឲ្យញាប់ញ័រមិនបាន ។

សួរថា ក៏ចិត្តរបស់នរណា ត្រូវលោកធម៌ទាំងនោះប៉ះខ្ទប់ហើយមិនញាប់ញ័រ? ឆ្លើយថា ចិត្តរបស់ព្រះអរហន្តខីណាស្រព មិនមែនចិត្តរបស់នរណាដទៃ ។ ពិតហើយ ព្រះមានព្រះភាគត្រាស់ទុកដូច្នេះថា ៖

ភ្នំថ្មតាន់ រមែងមិនញាប់ញ័រដោយខ្យល់ យ៉ាងណា រូប សំឡេង ក្លិន រស ផោដ្ឋព្វៈ និងធម៌ទាំងអស់ ទាំងឥដ្ឋារម្មណ៍ ទាំងអនិដ្ឋារម្មណ៍ រមែងធ្វើចិត្តរបស់លោកដែលតាំងមាំមិនឲ្យញាប់ញ័របាន ក៏ដូច្នោះ ព្រោះថា ចិត្តរបស់លោកដែលតាំងមាំ រួចផុតហើយ រមែងឃើញការរលត់

រឿយៗ ។

ចិត្តរបស់ព្រះខីណាស្រពប៉ុណ្ណោះ ឈ្មោះថា **អសោក:** (មិនសោកសៅ) ។ ពិតហើយ ចិត្តរបស់ព្រះខីណាស្រពនោះ ឈ្មោះថា **អសោក:** ព្រោះមិនមានសេចក្តីសោក ដែលលោកពោលដោយន័យជាដើមថា សេចក្តីសោក ការសៅហ្មងចិត្ត ការក្រៀមក្រំចិត្ត ការដុតចិត្តខាងក្នុង សេចក្តីសៅហ្មងខាងក្នុង ការដែលចិត្តត្រូវសេចក្តីសោកដុតរោល ។ អាចារ្យខ្លះពោលដល់និព្វាន ពាក្យនោះ មិនភ្ជាប់សេចក្តីជាមួយបទខាងដើមៗ ។ ចិត្តរបស់ព្រះខីណាស្រពប៉ុណ្ណោះ ឈ្មោះថា **អសោក:** យ៉ាងណា ក៏ឈ្មោះថា **វិរជ: ខេម:** ដូច្នោះ ។ ពិតហើយ ចិត្តរបស់ព្រះខីណាស្រពនោះ ឈ្មោះថា **វិរជ:** ព្រោះប្រាសចាកធូលី គឺ រាគ: ទោស: មោហ: និងឈ្មោះថា **ខេម:** ព្រោះប្រាសចាកយោគ:ទាំង ៤ ។ ព្រោះថា ចិត្តទាំង ៣ យ៉ាងនោះ ដូចដែលលោកកាន់យកហើយក្នុងខណ:ចិត្តប្រព្រឹត្តទៅក្នុងអារម្មណ៍នោះៗ ដោយអាការនោះៗ ហើយអធិប្បាយ គប្បីជ្រាបថា "ជាមង្គល" ព្រោះនាំមកភាពជាអ្នកខ្ពង់ខ្ពស់ក្នុងលោក មានភាពជាអ្នកមានខន្ធដែលមិន

ប្រព្រឹត្តទៅជាដើម (មិនកើតទៀត) និងព្រោះនាំមកនូវភាពជាអាហុនេយ្យ-បុគ្គលជាដើម ។

ព្រះមានព្រះភាគត្រាស់មង្គលនៃគាថានេះទុក ៤ មង្គល គឺ ចិត្តមិនញាប់ញ័រដោយលោកធម៌ប្រាំបី ១ ចិត្តមិនសោកសៅ ១ ចិត្តប្រាសចាកធូលី គឺ កិលេស ១ ចិត្តក្សេម ១ ដោយប្រការដូច្នេះ ។ ក៏មង្គលទាំងនោះ ជាមង្គល ក៏បានអធិប្បាយទុកក្នុងមង្គលនោះឯងហើយ ។

ចប់សេចក្តីពណ៌នាគាថានេះថា ផុដ្ឋស្ស លោកធម្មេហិ

## ពណ៌នាគាថាថា ឯតាទិសានិ

ព្រះមានព្រះភាគ ត្រាស់មង្គល ៣៨ ប្រការ ដោយគាថា ១០ គាថា មាន **អសេវនា ច ពាលានំ** ការមិនសេពគប់បុគ្គលជាអាទិ៍យ៉ាងនេះហើយ ឥឡូវនេះកាលទ្រង់សរសើរមង្គល ដែលព្រះអង្គត្រាស់ទាំងនេះ ទើបបានត្រាស់គាថាចុងក្រោយថា **ឯតាទិសានិ កត្វាន** ជាដើម ។

ពណ៌នាសេចក្ដីនៃគាថាចុងក្រោយនោះ ដូច្នេះ បទថា **ឯតាទិសានិ** កាត់បទថា **ឯតានិ ឦទិសានិ** ប្រែថា ដូច្នេះ គឺ មានការមិនសេពគប់បុគ្គលពាលជាដើម មានប្រការដូចដែលតថាគតពោលមកហើយ ។ បទថា **កត្វាន** ប្រែថា ធ្វើ ។ ការពិត ពាក្យនេះមិនដទៃពីសេចក្ដីថា **កត្វាន កត្វា ករិត្វា** (ប្រែថា ធ្វើដូចគ្នា) ។ បទថា **សព្វត្ថមបរាជិតា (មិនចាលចាញ់សត្រូវក្នុងទីទាំងពួង)** សេចក្ដីថា សត្វទាំងឡាយធ្វើមង្គលដូច្នេះ ដែលសត្រូវ ៤ ប្រភេទ គឺ ខន្ធមារ កិលេសមារ អភិសង្ខារមារ និងទេវបុត្រមារ សូម្បីតែមួយប្រភេទ ក៏ធ្វើឲ្យចាលចាញ់បានក្នុងទីទាំងពួង លោកអធិប្បាយថា ញ៉ាំងមារទាំង ៤ នោះ ឲ្យចាញ់ដោយខ្លួនឯង ។ ក៏ ម អក្សរ

ក្នុងបទថា **សព្វត្ថមបរាជិតា** នេះ គប្បីជ្រាបថា ត្រឹមតែការតបទ ។

បទថា **សព្វត្ថ សោត្ថឹ គច្ឆន្តិ** (រមែងដល់នូវសួស្តីក្នុងទីគ្រប់កន្លែង) សេចក្តីថា សត្វទាំងឡាយធ្វើមង្គលដូចដែលពោលមកនេះ ជាអ្នកដែលមារទាំង ៤ ធ្វើឲ្យចាលចាញ់មិនបាន រមែងដល់នូវសេចក្តីសួស្តីក្នុងទីទាំងពួង គឺ ក្នុងលោកនេះ និងលោកខាងមុខ សូម្បីក្នុងទីឈរ និងក្នុងទីដើរជាដើម អាសវៈពួកណា ដែលធ្វើនូវសេចក្តីចង្អៀតចង្អល់ និងសេចក្តីក្តៅក្រហាយ គប្បីកើតឡើងព្រោះការសេពគប់បុគ្គលពាលជាដើម ហេតុមិនមានអាសវៈទាំងនោះ ទើបដល់សេចក្តីសួស្តី លោកអធិប្បាយថា ជាអ្នកដែលមានឧបទ្រវៈមិនរារាំង ដែលឧបសគ្គៈមិនរារាំង ក្សេម មិនមានភ័យចំពោះមុខ ។ ក៏និគ្គហិត ក្នុងប្រការនេះថា **សព្វត្ថ សោត្ថឹ គច្ឆន្តិ** នេះ គប្បីជ្រាបថា ត្រាស់ដើម្បីងាយដល់ការចងគាថា ។

ព្រះមានព្រះភាគ ទ្រង់បញ្ចប់ទេសនាដោយបទនៃគាថាថា **តំ តេសំ មង្គលមុត្តមំ** ។ ទ្រង់បញ្ចប់ដូចម្តេច? ទ្រង់បញ្ចប់ថា "ទេវបុត្រ ព្រោះហេតុដែលជនអ្នកធ្វើមង្គលដូចពោលមកនេះ រមែងដល់សេរីសួស្តីក្នុងទីទាំងពួង

យ៉ាងនេះ ដូច្នោះ លោកចូរដឹងថា មង្គលទាំង ៣៨ ប្រការ មានការមិនសេពគប់បុគ្គលពាលជាដើមនោះ ឧត្តម ប្រសើរ ខ្ពង់ខ្ពស់ជាទីបំផុតសម្រាប់ជនទាំងនោះ អ្នកធ្វើមង្គលដូចដែលពោលមកនេះ ។

ខាងចុងនៃទេសនា ដែលព្រះដ៏មានព្រះភាគទ្រង់បញ្ចប់នេះ ទេវតាមួយសែនកោដិសម្រេចជាព្រះអរហន្ត ។ ចំនួនអ្នកសម្រេចសោតាបត្តិផល សកទាគាមិផល អនាគាមិផល រាប់មិនបានឡើយ ។ លុះស្អែកឡើង ព្រះមាន-ព្រះភាគត្រាស់ហៅព្រះអានន្ទមក ត្រាស់ថា "ម្នាលអានន្ទ កាលយប់មិញទេវតាមួយអង្គចូលមកសួរមង្គលបញ្ហា គ្រានោះ តថាគតបានពោលមង្គល ៣៨ ប្រការ ដល់ទេវតានោះ ។ អានន្ទ អ្នកចូររៀនមង្គលបរិយាយនេះ លុះរៀនហើយ ចូរបង្រៀនដល់ភិក្ខុទាំងឡាយចុះ ។ ព្រះថេរៈរៀនហើយក៏បង្រៀនដល់ភិក្ខុទាំងឡាយ ។ មង្គលសូត្រនេះ អាចារ្យនាំមកតៗ គ្នាប្រព្រឹត្តទៅរហូតដល់សព្វថ្ងៃនេះ គប្បីជ្រាបថា សាសនព្រហ្មចរិយៈនេះស្ថិតស្ថេរ ចម្រើន ផ្សព្វផ្សាយទូទៅ បានចេះដឹងច្រើនគ្នា ដរាបតាំងពីទេវតា និងមនុស្ស ប្រកាសល្អហើយ ។

ដើម្បីសេចក្ដីធ្លាតឈ្លាសក្នុងការសន្សំការចេះដឹងក្នុងមង្គលនេះឯង ឥឡូវនេះ នឹងប្រកបសេចក្ដីតាំងអំពីដើមដូច្នេះ ។

សត្វទាំងឡាយអ្នកប្រាថ្នាសេចក្ដីសុខក្នុងលោកនេះ លោកខាងមុខ និងលោកុត្តរៈ គប្បីលះការសេពគប់ជាមួយបុគ្គលពាលចេញ អាស្រ័យតែបណ្ឌិត បូជាបុគ្គលដែលគួរបូជា , ឯការនៅក្នុងបដិរូបទេស និងភាពជាអ្នកធ្វើបុណ្យទុកក្នុងកាលមុនជាស់តឿនឲ្យបំពេញកុសល និងតម្កល់ខ្លួនទុកប្រពៃ , មានអត្តភាពដែលប្រដាប់ដោយពាហុសច្ចៈ សិល្បៈ និងវិន័យ ពោលសុភាសិតដែលសមគួរដល់វិន័យ , មិនទាន់លះបង់ភេទជាគ្រហស្ថត្រឹមណា ក៏ជម្រះបំណុលចាស់ដោយការទំនុកបម្រុងមាតាបិតា ត្រឹមនោះប្រកបបំណុលថ្មីដោយការសង្គ្រោះបុត្រ និងភរិយា ដល់នូវភាពស្អុកស្ដុកដោយទ្រព្យ និងស្រូវអង្ករជាដើម ដោយភាពជាអ្នកមានការងារមិនច្របូកច្របល់ ។ កាន់យកសារៈនៃភោគៈដោយទាន និងសារៈនៃជីវិតដោយការប្រព្រឹត្តធម៌ ការធ្វើប្រយោជន៍ដល់ជនជាញាតិ ដោយការសង្គ្រោះញាតិ និងប្រយោជន៍ដល់ជនដទៃៗ ដោយភាពជាអ្នកមានការងារ ដែលមិនមាន

ទោស , វៀរចាកការធ្វើអាក្រក់ចំពោះអ្នកដទៃ ដោយការវៀរចាកអំពើបាប ការធ្វើអាក្រក់ដោយខ្លួនឯង ដោយវៀរចាកការផឹកទឹកស្រវឹង ចម្រើនកុសល និងមិនប្រមាទក្នុងធម៌ទាំងឡាយ , លះភេទគ្រហស្ថដោយភាពជាអ្នកចម្រើនកុសល សូម្បីតាំងនៅក្នុងភាវៈជាបព្វជិត ក៏ញុំាងវត្តសម្បទាឲ្យសម្រេចដោយភាពគោរពក្នុងព្រះពុទ្ធ សាវករបស់ព្រះពុទ្ធ និងឧបជ្ឈា-យាចារ្យជាដើម និងដោយភាពជាអ្នកបន្ទាបខ្លួន លះសេចក្តីល្មោភក្នុងបច្ច័យដោយការសន្តោស តាំងនៅក្នុងសប្បុរិសភូមិដោយភាពជាអ្នកកតញ្ញូ លះភាពជាអ្នកមានចិត្តខ្ជិលច្រអូសក្នុងការស្តាប់ធម៌ , គ្របសង្កត់អន្តរាយគ្រប់យ៉ាងដោយខន្តិ ធ្វើខ្លួនឲ្យមានទីពឹង ដោយភាពជាអ្នកប្រដៅងាយ មើលការប្រកបវត្តបដិបត្តិ ដោយការឃើញសមណៈ បន្ទោបង់សេចក្តីសង្ស័យក្នុងធម៌ទាំងឡាយ ដែលជាទីតាំងនៃសេចក្តីសង្ស័យ ដោយការសន្ទនាធម៌ , ដល់សីលវិសុទ្ធិ ដោយតបៈ គឺ ឥន្ទ្រិយសំវរៈ ដល់ចិត្តវិសុទ្ធិ ដោយព្រហ្មចរិយៈ គឺ សមណធម៌ និងញុំាងវិសុទ្ធិ ៤ ក្រៅពីនោះ ឲ្យដល់ព្រមដល់ញាណទស្សនវិសុទ្ធិ ដែលជាបរិយាយនៃការឃើញអរិយសច្ចៈ ដោយ

បដិបទានេះ ធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វានដែលរាប់បានថា អរហត្តផល ។ កាលធ្វើឲ្យជាក់ច្បាស់ហើយ ជាអ្នកមានចិត្តមិនញាប់ញ័រដោយលោកធម៌ ៨ ដូចភ្នំសិនេរុ មិនញាប់ញ័រដោយខ្យល់ និងភ្លៀង រមែងជាអ្នកមិនសោកសៅ ប្រាសចាកធូលី គឺ កិលេស មានសេចក្ដីក្សេមដ៏ប្រណីត និងជាអ្នកមានសេចក្ដីក្សេមដ៏ប្រណីត រមែងជាអ្នកសូម្បីតែសត្រូវណាមួយ ឲ្យអន្តរាយមិនបានក្នុងទីទាំងពួង ទាំងនឹងដល់នៅសិរីសួស្ដីក្នុងទីគ្រប់កន្លែង ។ ព្រោះហេតុនោះ ព្រះមានព្រះភាគទើបត្រាស់ថា ៖

*ទេវតា និងមនុស្សទាំងឡាយធ្វើមង្គលដូច្នេះហើយ មិនមានសត្រូវក្នុងទីទាំងពួង រមែងដល់សិរីសួស្ដី ក្នុងទីគ្រប់កន្លែង នោះជាមង្គលដ៏ឧត្ដមរបស់ទេវតា និងមនុស្សទាំងនោះ ។*

ចប់សេចក្ដីពណ៌នាគាថានេះថា ឯតាទិសានិ

## ចប់អដ្ឋកថា មង្គលសូត្រ

# អដ្ឋកថា រតនសូត្រទី ៦

*(ពោលដោយរតនៈដ៏ប្រណីត)*

## ប្រយោជន៍នៃបទតាំង

*គប្បីជ្រាបវិនិច្ឆ័យក្នុង រតនសូត្រទី ៦ ដូចតទៅនេះ ៖*

*[៧] ឥឡូវនេះ ដល់លំដាប់ការពណ៌នាសេចក្តីនៃរតនសូត្រ ដែលលើកឡើងតាំងក្នុងលំដាប់តអំពីមង្គលសូត្រនោះ ដោយន័យជាដើមថា* ***យានីធ ភូតានិ*** *(ពួកភូតឯណា... ក្នុងទីនេះ) ខ្ញុំនឹងពោលប្រយោជន៍នៃការតាំងរតនសូត្រនោះទុកក្នុងទីនេះ តពីនោះ ដើម្បីសំដែងការឈានចុះកាន់សេចក្តីនៃសូត្រនេះ តាមនិទាន (វចនៈ) ដ៏បរិសុទ្ធល្អ ដូចការចុះកាន់ទឹកក្នុងស្ទឹង និងបឹងជាដើម តាមកំពង់ទឹកដែលល្អ ។*

*ប្រកាសន័យនេះថា សូត្រនេះនរណាពោល ពោលកាលណា ពោលទីណា ពោលព្រោះហេតុអ្វី ទើបធ្វើការពណ៌នាសេចក្តីនៃរតនសូត្រនេះ ។*

*ក្នុង ២ សូត្រនេះ ព្រោះហេតុដែលព្រះមានព្រះភាគទ្រង់សំដែងការរក្សាខ្លួនឯង និងការកម្ចាត់អាសវៈទាំងឡាយ ដែលមានការធ្វើមិនល្អ និង*

ការធ្វើល្អជាបច្ច័យ ដោយមង្គលសូត្រ ចំណែកសូត្រនេះ ព្រះមានព្រះភាគ ទ្រង់ឲ្យសម្រេចការរក្សាអ្នកដទៃ និងការកម្ចាត់អាសវៈទាំងឡាយ ដែលមានអមនុស្សជាដើមជាបច្ច័យ ដូច្នោះ សូត្រនេះ ទើបតាំងទុកក្នុងលំដាប់តអំពីមង្គលសូត្រនោះ ដូច្នេះឯង ។

ប្រយោជន៍នៃការតាំងរតនសូត្រនោះទុកក្នុងទីនេះមានប៉ុណ្ណោះ

## រឿងក្រុងវេសាលី

ឥឡូវនេះ ក្នុងបទថា **យេន វុត្តំ យទា យត្ថ យស្មា ចេតំ (សូត្រនេះនរណាពោល ពោលកាលណា ពោលទីណា ពោលព្រោះហេតុអ្វី)** នេះ អ្នកជំទាស់ពោលថា ក៏សូត្រនេះនរណាពោល ពោលកាលណា ពោលទីណា និងពោលព្រោះហេតុអ្វី ។ សូមអធិប្បាយដូច្នេះ ការពិត សូត្រនេះព្រះមានព្រះភាគព្រះអង្គឯងប៉ុណ្ណោះត្រាស់សំដែង មិនមែនព្រះសាវ័កជាអ្នកពោល ។ ត្រាស់កាលណា ។ ត្រាស់កាលក្រុងវេសាលីត្រូវឧបទ្រវៈទាំងឡាយ មានទុព្ភិក្ខភ័យជាដើមកើតឡើង ព្រះមានព្រះភាគ ដែលពួក

ស្តេចលិច្ឆវីទូលអារាធនាសូមស្តេចយាងពីក្រុងរាជគ្រឹះ កាលនោះ រតនសូត្រនោះ ព្រះអង្គក៏ត្រាស់ដើម្បីកម្ចាត់ឧបទ្រវៈទាំងនោះ ក្នុងក្រុងវេសាលី ។ ការវិសជ្ជនាបញ្ហាទាំងនោះ ដោយសង្ខេបមានប៉ុណ្ណេះ ។ ចំណែកសេចក្តីពិស្តារ ព្រះបុរាណាចារ្យទាំងឡាយពណ៌នាទុក តាំងពីរឿងក្រុងវេសាលីជាដើមតទៅ ។ ក្នុងរឿងនោះ ការពណ៌នានឹងមានដូចតទៅនេះ ។

ដូចបានស្តាប់មក ព្រះអគ្គមហេសីរបស់ព្រះបាទក្រុងពារាណសី ទ្រង់ព្រះគភ៌ ព្រះនាងទ្រង់ជ្រាបហើយ ក៏បានក្រាបទូលព្រះរាជាឲ្យទ្រង់ជ្រាប ។ ព្រះរាជាក៏ព្រះរាជទានគ្រឿងរក្សាព្រះគភ៌ ។ ព្រះនាងបានទទួលការរក្សាព្រះគភ៌មកយ៉ាងល្អ ក៏ស្តេចចូលកាន់ផ្ទះព្រះសូតិ ក្នុងវេលាជិតថ្ងៃកើត ។ ពួកអ្នកមានបុណ្យរមែងចេញចាកគភ៌ ក្នុងវេលារជិតភ្លឺ ។ ក៏បណ្តាអ្នកមានបុណ្យទាំងនោះ ព្រះអគ្គមហេសីអង្គនោះ ក៏ជាអ្នកមានបុណ្យមួយអង្គ ព្រោះហេតុនោះ វេលាជិតភ្លឺ ព្រះនាងក៏ប្រសូតិដុំសាច់ដូចផ្កាចំបា មានត្របកពណ៌ក្រហម ។ តពីនោះ ព្រះទេវីអង្គដទៃៗ ក៏ប្រសូត្រព្រះឱរសមានរូបដូចមាស ។ ព្រះអគ្គមហេសីប្រសូត្រដុំសាច់ ដូច្នោះ ព្រះនាងទ្រង់ត្រិះរិះ

ថា សំឡេងតិះដៀលនឹងគប្បីកើតមានដល់យើង ចំពោះព្រះភក្ត្រព្រះរាជា ព្រោះខ្លាចការតិះដៀលនោះ ទើបទ្រង់បញ្ជាឲ្យដាក់ដុំសាច់នោះចុះក្នុងភាជនៈមួយ យកភាជនៈដទៃទៀតបិទទុក ព្រះថាប់ត្រាព្រះរាជលញ្ចករហើយ ឲ្យបណ្តែតទៅតាមក្រសែទឹកទន្លេគង្គា ។ ពួកស្ត្រីបម្រើទាំងឡាយបោះចុះទៅ ទេវតាទាំងឡាយក៏ចាត់ការរក្សា ។ ទាំងយកជ័រមហាហិង្គុសរសេរលើសំពត់មាស ហើយចងទុកត្រង់ភាសនៈនោះថា ព្រះរាជឱរសធិតារបស់ព្រះអគ្គ-មហេសីនៃព្រះបាទក្រុងពារាណសី ។ តពីនោះ ភាជនៈនោះ មិនបានត្រូវភ័យ គឺ រំខាន ក៏អណ្តែតទៅតាមក្រសែទន្លេគង្គា ។

សម័យនោះ តាបសមួយរូបអាស្រ័យគ្រួសាររបស់អ្នកចិញ្ចឹមគោនៅជិតមាត់ទន្លេគង្គា ។ ពេលព្រឹក តាបសនោះក៏ចុះកាន់ទន្លេគង្គា ក្រឡេកឃើញភាជនៈនោះអណ្តែតមក ក៏កាន់យកដោយបង្សុកូលសញ្ញា ដោយគិតថា ជារបស់ដែលគេបោះបង់ចោល ។ តពីនោះ ក៏ឃើញសំពត់សរសេរអក្សរ និងព្រះរាជត្រា ក៏ស្រាយចេញឃើញដុំសាច់នោះ លុះឃើញហើយតាបសរូបនោះក៏គិតថា មុខជាសត្វកើតក្នុងគភ៌ ដូច្នោះ ទើបមិនស្អុយ ។

ក៏នាំដុំសាច់នោះទៅកាន់អាស្រម ដាក់ទុកក្នុងទីស្អាត ។ កន្លងទៅកន្លះខែ ដុំសាច់ក៏បែកជា ២ ដុំ តាបសឃើញហើយ ក៏ដាក់ទុកយ៉ាងល្អថែមទៀត ។ តពីនោះ កន្លងទៅកន្លះខែទៀត ដុំសាច់មួយដុំក៏បែកជាបញ្ចសាខា មានដៃជើង និងសីសៈ ។ តាបសឃើញហើយ ចាត់ចែងទុកដាក់យ៉ាងល្អ ។ តពីនោះ កន្លះខែទៀត ដុំសាច់មួយដុំកើតជាទារក មានរូបដូចមាស មួយដុំទៀតក៏ជាទារិកា ។ តាបសកើតសេចក្តីស្រឡាញ់ដូចជាបុត្រ ក្នុងទារកទាំង ២ នោះ ។ ទឹកដោះក៏កើតពីម្រាមមេដៃរបស់តាបសនោះ តាំងពីនោះមក តាបសបានទឹកដោះ និងអាហារមក ក៏បរិភោគអាហារ បន្តក់ទឹកដោះក្នុងមាត់របស់ទារកទាំង ២ ។ វត្ថុណាៗ ចូលទៅក្នុងពោះរបស់ទារកនោះ វត្ថុទាំងអស់នោះ ក៏នឹងឃើញដូចចូលទៅក្នុងភាជនៈធ្វើដោយកែវមណី ។ ទារកទាំង ២ នោះ មានសម្បុរថ្លាយ៉ាងនេះ ។ តែអាចារ្យពួកដទៃៗ ពោលថា សម្បុររបស់ទារកទាំង ២ នោះ ថ្លាឆ្លុះដល់គ្នានិងគ្នា ដូចត្រូវដោតអំបោះទុក ។ ទារកទាំងនោះ ទើបប្រាកដ ឈ្មោះថា លិច្ឆវី ព្រោះមិនមានសម្បុរ ឬព្រោះមានសម្បុរថ្លា ដោយប្រការដូច្នេះ ។

តាបសចិញ្ចឹមទារក វេលាព្រឹកឡើង ក៏ចូលទៅកាន់ស្រុកស្វែងរកអាហារ ពេលថ្ងៃត្រង់ក៏ត្រឡប់មកវិញ ។ អ្នកចិញ្ចឹមគោទាំងឡាយ ដឹងដល់ការខ្វល់ខ្វាយរបស់តាបសនោះ ក៏ពោលថា លោកម្ចាស់ ការចិញ្ចឹមទារក ជាកង្វល់ធំរបស់អ្នកបួស សូមលោកម្ចាស់មេត្តាឲ្យទារកដល់ពួកយើងចុះ ។ ពួកយើងនឹងជួយគ្នាចិញ្ចឹម សូមលោកម្ចាស់ធ្វើកិច្ចកម្មរបស់លោកម្ចាស់ចុះ ។ តាបសក៏ព្រមទទួល ។ ស្អែកឡើង ពួកអ្នកចិញ្ចឹមគោក៏ជួយគ្នាធ្វើផ្លូវឲ្យរាបស្មើហើយ រោយផ្កាឈើ លើកទង់ លេងភ្លេង នាំគ្នាមកកាន់អាស្រម ។ តាបសពោលថា ទារកទាំង ២ មានបុណ្យច្រើន ពួកលោកចូរចាត់ការអាវាហវិវាហដល់គ្នានិងគ្នា ឲ្យព្រះរាជាទ្រង់ត្រេកអរដោយបញ្ចគោរស ចូរជ្រើសរើសភូមិប្រទេសជួយគ្នាសាងព្រះនគរ ចូរអភិសេកព្រះកុមារនៅក្នុងទីកន្លែងនោះ ហើយប្រគល់ទារកឲ្យ ។ ពួកអ្នកចិញ្ចឹមគោទទួលពាក្យហើយ ក៏នាំទារកទៅចិញ្ចឹមថែរក្សា ។

ទារកទាំង ២ ចម្រើនធំធាត់ កាលលេងក៏លេងប្រើដៃខ្លះ ជើងខ្លះវាយពួកក្មេងតូចៗ កូនអ្នកចិញ្ចឹមគោដទៃៗ ក្នុងទីឈ្លោះគ្នា ។ ក្មេងកូន

អ្នកចិញ្ចឹមគោទាំងនោះក៏ស្រែកយំ ត្រូវមាតាបិតាសួរថា ដូចម្តេចបានយំ? ក៏ប្រាប់ថា ក្មេងដែលមិនមានឪពុកម្តាយ ដែលតាបសចិញ្ចឹមទាំងនេះ គម្រាមពួកយើង ។ តពីនោះ មាតាបិតារបស់ក្មេងទាំងនោះក៏ពោលថា ទារក ២ នាក់នេះ ចូលចិត្តគម្រាមក្មេងដទៃៗ ក៏កើតការក្តៅក្រហាយ មិនសង្គ្រោះតទៅទៀត ហើយក៏លះបង់ចេញ ។ បានឮថា តអំពីនោះមក ប្រទេសនោះ ទើបត្រូវហៅថា វជ្ជី ទំហំ ៣០០ យោជន៍ ។ គ្រានោះ ពួកអ្នកចិញ្ចឹមគោ ធ្វើព្រះរាជាឲ្យត្រេកអរហើយ ជ្រើសរើសយកប្រទេសទីនោះ សាងព្រះនគរក្នុងប្រទេសនោះ ហើយអភិសេកព្រះរាជកុមារដែលព្រះជន្មបាន ១៦ វស្សា តាំងជាព្រះរាជា ។ បានធ្វើវិវាហមង្គលជាមួយទារិការបស់ព្រះអង្គ បានដាក់កតិកាច្បាប់ទុកថា នឹងមិននាំទារិកាមកពីខាងក្រៅ និងមិនឲ្យទារិកាអំពីទីនេះ ដល់នរណាៗ ។ ដោយការនៅរួមគ្នាគ្រាដំបូងរបស់ព្រះកុមារ កុមារី នោះ ក៏កើតទារកមួយគូ (កូនភ្លោះ) ជាធិតា ១ ឱរស ១ ដោយអាការយ៉ាងនេះ ក៏កើតជាគូៗ ដល់ ១៦ ដង ។ តពីនោះ កាលទារកទាំងនោះ ចម្រើនវ័យដោយតាមលំដាប់ នគរនោះក៏មិនសមល្មម

នឹងបង្កើតអារាម ឧទ្យាន ស្ថានទីនៅ បរិវារ និងសម្បត្តិ ទើបព័ទ្ធជុំវិញព្រះនគរនោះ ដោយកំពែង ៣ ជាន់ ចន្លោះមួយគាវុត មួយៗ ។ ព្រោះនគរនោះ ត្រូវពង្រីកឲ្យធំរឿយៗ ទើបបានឈ្មោះថា **វេសាលី** នេះឯង ។

នេះរឿងក្រុងវេសាលី

## ការនិមន្តព្រះមានព្រះភាគ

ក៏ក្រុងវេសាលីនេះ កាលព្រះមានព្រះភាគស្តេចឧប្បត្តិក៏ស្តុកស្តម្ភបរិបូណ៌ ។ ព្រោះថា ក្នុងក្រុងវេសាលីនោះ មានព្រះរាជារហូតដល់ ៧.៧០៧ អង្គ ។ ព្រះយុវរាជ សេនាបតី និងភណ្ឌាគារិកជាដើម ក៏ដូចគ្នា ។ ដូចដែលលោកពោលទុកថា ៖

សម័យនោះឯង ក្រុងវេសាលី ។ រុងរឿង ស្តុកស្តម្ភ មាន
មនុស្សច្រើន មានមនុស្សកុះករ មានអាហាររកបានងាយ
មានប្រាសាទ ៧.៧០៧ ខ្នង មានស្រះពោក្ខរណី ៧.៧០៧
ស្រះ ។

សម័យតមក ក្រុងវេសាលីកើតទុព្ភិក្ខភ័យ រាំងភ្លៀង ស្រូវអន្តរាយខូចអស់ ។ មនុស្សលំបាករហូតដល់ស្លាប់ គេបោះបង់ចោលមនុស្សទាំងនោះទៅក្រៅនគរ ។ ពួកអមនុស្សធំក្លិនសាកសពមនុស្សស្លាប់ ក៏នាំគ្នាចូលទៅកាន់ព្រះនគរ ។ តពីនោះ មនុស្សក៏ស្លាប់កើនឡើង ។ ព្រោះភាពបដិកូលនោះ អហិវាតករោគក៏កើតដល់សត្វទាំងឡាយ ។ មនុស្សក្នុងក្រុងវេសាលីត្រូវភ័យ ៣ យ៉ាង គឺ ទុព្ភិក្ខភ័យ អមនុស្សភ័យ និងរោគភ័យបៀតបៀន ក៏ចូលទៅគាល់ព្រះរាជា ក្រាបទូលថា "បពិត្រព្រះតេជ: កើតភ័យ ៣ យ៉ាង ក្នុងព្រះនគរនេះហើយ បពិត្រព្រះអង្គ កាលពីមុននេះរាប់បាន ៧ ជួររាជត្រកូល មិនធ្លាប់កើតភ័យដូច្នេះឡើយ ប្រហែលជាព្រះអង្គទ្រង់មិនតាំងនៅក្នុងធម៌ ឥឡូវនេះ ភ័យនោះទើបកើតឡើង" ។ ព្រះរាជាទ្រង់ប្រជុំស្តេចលិច្ឆវីគ្រប់អង្គក្នុងទីរាជការត្រាស់ថា សូមគ្រប់ព្រះអង្គពិចារណាឡើងវិញ នូវប្រការដែលយើងមិនបានតាំងនៅក្នុងធម៌ចុះ ។ ស្តេចលិច្ឆវីទាំងនោះ ពិចារណាឡើងវិញដល់ប្រពៃណីគ្រប់យ៉ាង ក៏ទ្រង់មិនឃើញប្រការធ្វេសប្រហែសណាៗ ។ តពីនោះ ក៏មិនឃើញទោសរបស់

ព្រះរាជា ទើបនាំគ្នាគិតថា ភ័យនេះរបស់ពួកយើងនឹងស្ងប់ទៅបាន យ៉ាងណា ។ ក្នុងទីប្រជុំនោះ ស្តេចលិច្ឆវីពួកខ្លះ ត្រាស់អាងដល់សាស្តាទាំង ៦ ថា កាលសាស្តាទាំងនេះដាក់ជើងចុះប៉ុណ្ណោះ ភ័យក៏នឹងរម្ងាប់ទៅ ។ ពួកខ្លះត្រាស់ថា បានឮថា ព្រះពុទ្ធស្តេចឧប្បត្តិហើយក្នុងលោក ព្រះមានព្រះ-ភាគអង្គនោះ ទ្រង់សំដែងធម៌ដើម្បីប្រយោជន៍ដល់សត្វទាំងពួង ទ្រង់មានឫទ្ធិច្រើន មានអានុភាពច្រើន គ្រាន់តែព្រះអង្គលើកព្រះបាទដាក់ចុះប៉ុណ្ណោះ ភ័យគ្រប់យ៉ាង ក៏នឹងរម្ងាប់ទៅ ។ ព្រោះហេតុនោះ ស្តេចលិច្ឆវីទាំងនោះ ទើបពេញព្រះទ័យត្រាស់ថា ក៏ព្រះមានព្រះភាគអង្គនោះ ឥឡូវនេះប្រថាប់នៅទីណាហ្ន៎ ពួកយើងបញ្ជូនមនុស្សទៅនិមន្ត ស្តេចមក ឬមិនមកហ្ន៎ ។ ស្តេចលិច្ឆវីពួកមួយទៀតត្រាស់ថា ធម្មតាព្រះពុទ្ធ ទ្រង់ករុណាសត្វ ហេតុអ្វីស្តេចទ្រង់មិនមក ក៏ព្រះមានព្រះភាគអង្គនោះ ពេលនេះ ប្រថាប់នៅក្រុងរាជគ្រឹះ ព្រះបាទពិម្ពិសារទ្រង់ឧបដ្ឋាក ក្រែងស្តេចមិនឲ្យព្រះអង្គមក ។ ត្រាស់ថា បើដូច្នោះ យើងនឹងទូលព្រះបាទពិម្ពិសារឲ្យទ្រង់ពេញព្រះទ័យ ហើយយាងព្រះមានព្រះភាគព្រះអង្គមក ហើយទ្រង់ប្រគល់គ្រឿងបណ្ណាការ

ដ៏ច្រើន បញ្ជូនស្ដេចលិច្ឆវី ២ ព្រះអង្គ ព្រមដោយកងកម្លាំងដ៏ធំទៅកាន់រាជសំណាក់ព្រះបាទពិម្ពិសារ ដោយត្រាស់បង្គាប់ថា សូមអ្នកទូលព្រះបាទពិម្ពិសារឲ្យពេញព្រះទ័យហើយ នាំព្រះមានព្រះភាគស្ដេចមក ។ ស្ដេចលិច្ឆវីទាំង ២ អង្គ ស្ដេចទៅ ថ្វាយគ្រឿងបណ្ណាការដល់ព្រះបាទពិម្ពិសារ ហើយថ្វាយឲ្យទ្រង់ជ្រាបរឿងរ៉ាវ ហើយទូលថា បពិត្រព្រះមហារាជ សូមព្រះអង្គទ្រង់ករុណាប្រោសមេត្តាបញ្ជូនព្រះមានព្រះភាគ ស្ដេចមកកាន់នគររបស់ខ្ញុំព្រះអង្គផងចុះ ព្រះរាជាទ្រង់មិនព្រមទទួល ត្រាស់ថា ពួកលោកចូលនិមន្តខ្លួនឯងចុះ ស្ដេចលិច្ឆវីក៏ទទួលថា ល្អហើយព្រះអង្គ ហើយចូលទៅគាល់ព្រះមានព្រះភាគ ថ្វាយបង្គំហើយ ក្រាបទូលយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន ភ័យ ៣ យ៉ាង កើតឡើងក្នុងនគររបស់ខ្ញុំព្រះអង្គ បើព្រះមានព្រះភាគ ស្ដេចគប្បីទៅសោត សិរីសួស្ដីក៏នឹងគប្បីមានដល់ពួកខ្ញុំព្រះអង្គ ។ ព្រះមានព្រះភាគទ្រង់ពិចារណាថា កាលត្រាស់រតនសូត្រក្នុងក្រុងវេសាលី ការរក្សានឹងផ្សាយទៅមួយសែនកោដិចក្រវាល ចប់សូត្រសត្វ ៨៤.០០០ នឹងត្រាស់ដឹងធម៌ ទើបទ្រង់ទទួលនិមន្ត ។ គ្រានោះ ព្រះ

បាទពិម្ពិសារទ្រង់ទទួលដំណឹងថា ព្រះមានព្រះភាគទ្រង់ទទួលនិមន្តហើយ ក៏ប្រោសឲ្យឃោសនាទៅក្នុងព្រះនគរថា ព្រះមានព្រះភាគទ្រង់ទទួលនិមន្តស្តេចទៅក្រុងវេសាលីហើយ ស្តេចចូលទៅគាល់ព្រះមានព្រះភាគ ទូលសួរថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះអង្គទ្រង់ទទួលស្តេចនឹងទៅក្រុងវេសាលីឬ ព្រះអង្គ? ។ ព្រះមានព្រះភាគត្រាស់ថា ថ្វាយព្រះពរមហាបពិត្រ ។ ព្រះបាទពិម្ពិសារទូលសួរថា បពិត្រព្រះអង្គដ៏ចម្រើន បើដូច្នោះ សូមទ្រង់មេត្តាប្រោសរង់ចាំរហូតដល់ការចាត់ចែងផ្លូវថ្វាយសិន ព្រះអង្គ ។

គ្រានោះ ព្រះបាទពិម្ពិសារ ទ្រង់ធ្វើផ្ទៃដី ៥ យោជន៍ ចន្លោះក្រុងរាជគ្រឹះ និងទន្លេគង្គា ឲ្យរៀបរយហើយ ឲ្យសាងវិហារក្នុងរវាងផ្លូវមួយយោជន៍មួយៗ ឲ្យក្រាបទូលព្រះមានព្រះភាគដល់វេលាដែលស្តេចនឹងទៅ ។ ព្រះមានព្រះភាគ មានភិក្ខុ ៥០០ អង្គ ហែហម ស្តេចយាងទៅ ។ ព្រះរាជាទ្រង់យកផ្កាឈើ ៥ ពណ៌ រោយតាមផ្លូវ ៥ យោជន៍ (កម្ពស់) ត្រឹមក្បាលជង្គង់ ឲ្យលើកទង់សំពត់ តាំងឆ្នាំងពេញដោយទឹក និងដើមចេកជាដើម ឲ្យបាំងស្វេតឆត្រ ២ ជាន់ សម្រាប់ព្រះមានព្រះភាគ ឆត្រមួយជាន់សម្រាប់

ព្រះភិក្ខុសង្ឃមួយរូប ទ្រង់ធ្វើការបូជាដោយផ្កាឈើ និងគ្រឿងក្រអូបជាដើម ព្រមដោយរាជបរិពាររបស់ព្រះអង្គ ឲ្យព្រះមានព្រះភាគប្រថាប់នៅក្នុងវិហារ មួយខ្នងៗ ថ្វាយមហាទាន ទ្រង់នាំស្តេចចុះកាន់ប្រាំងទន្លេគង្គា ៥ ថ្ងៃ ។ នៅក្នុងទីនោះ ទ្រង់ប្រដាប់ទូកដោយគ្រឿងប្រដាប់គ្រប់យ៉ាង ហើយទ្រង់បញ្ជូនសារទៅថ្វាយ ស្តេចលិច្ឆវីក្រុងវេសាលីថា ព្រះមានព្រះភាគស្តេចយាងមកហើយសូមស្តេចលិច្ឆវីគ្រប់អង្គ គាត់តែងផ្លូវថ្វាយការទទួលព្រះមាន-ព្រះភាគចុះ ។ ស្តេចលិច្ឆវីទាំងនោះ ស្របគ្នាថា និងធ្វើការបូជាឲ្យជា ២ ជង ធ្វើផែនដី ៣ យោជន៍ រវាងក្រុងវេសាលី និងទន្លេគង្គាឲ្យរៀបរាយ បាត់បែងស្វេតឆត្រ ៤ សម្រាប់ព្រះមានព្រះភាគ សម្រាប់ព្រះភិក្ខុសង្ឃមួយអង្គៗ ឆត្រ ២ ធ្វើការបូជា រង់ចាំស្តេចយាងមកកាន់ប្រាំងទន្លេគង្គា ។

គ្រានោះ ព្រះបាទពិម្ពិសារ ទ្រង់ធ្វើទូកខ្នាតធំ ២ គ្រឿង ហើយឲ្យសាងមណ្ឌបប្រដាប់ដោយកម្រងផ្កាឈើជាដើម ក្រាលពុទ្ធាសនៈធ្វើដោយរតនៈសុទ្ធក្នុងមណ្ឌបនោះ ។ ទីនោះ ព្រះមានព្រះភាគប្រថាប់លើកពុទ្ធាសនៈនោះ ។ សូម្បីភិក្ខុ ៥០០ រូប ក៏ចុះកាន់ទូក គង់តាមសមគួរ ។ ព្រះរាជា

ទ្រង់ដង្ហែព្រះមានព្រះភាគ ទ្រង់ចុះទឹកប្រមាណដល់ព្រះសូរង ក្រាបទូលថា "បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គនឹងនៅមាត់ច្រាំងទន្លេគង្គានេះឯង រហូតដល់ព្រះមានព្រះភាគស្ដេចត្រឡប់មកវិញ ហើយក៏ស្ដេចត្រឡប់ឡើងច្រាំង" ។ ទេវតារហូតដល់អកនិដ្ឋកពបាននាំគ្នាធ្វើការបូជា ។ នាគរាជទាំងឡាយ មានកម្ពលនាគ និងអស្សត្រនាគជាដើម ដែលអាស្រ័យនៅក្នុងទន្លេគង្គា ក៏នាំគ្នាធ្វើការបូជា ។ ដោយការបូជាធំយ៉ាងនេះ ព្រះមានព្រះភាគស្ដេចទៅតាមទន្លេគង្គា អស់រយៈផ្លូវចម្ងាយប្រមាណ ១ យោជន៍ ក៏ចូលដល់ដែនរបស់ពួកស្ដេចលិច្ឆវីក្រុងវេសាលី ។

តពីនោះ ពួកស្ដេចលិច្ឆវីក៏ធ្វើការបូជាទ្វេដង ដែលព្រះបាទពិម្ពិសារទ្រង់ធ្វើការបូជា ចេញទៅទទួលព្រះមានព្រះភាគដោយចុះក្នុងទឹកប្រមាណត្រឹមព្រះសូរង ។ ខណៈនោះឯង មហាមេឃក៏តាំងឡើង ពន្លឺផ្លេកបន្ទោរផ្ទៃលធ្លាត់ ព្រមទាំងបញ្ចេញសំឡេងគម្រាម គ្រហឹម គគ្រឹកគគ្រេងក្នុងទាំង ៤ ទិស ។ លំដាប់នោះ ពេលព្រះមានព្រះភាគទ្រង់ដាក់ព្រះបាទដំបូងចុះត្រង់មាត់ច្រាំងទន្លេគង្គា ភ្លៀងបោក្ខរព័ស្សក៏រោយគ្រាប់ចុះមក ។ ជនពួក

ណាត្រូវការនឹងទទឹក ជនទាំងនោះប៉ុណ្ណោះរមែងទទឹក អ្នកមិនត្រូវការទទឹក ក៏មិនទទឹក ។ ក្នុងទីគ្រប់កន្លែង ទឹករមែងហូរទៅត្រឹមខ្នងជើង ត្រឹមជង្គង់ ត្រឹមចង្កេះ ត្រឹមក សាកសពទាំងពួង ត្រូវទឹកហូរនាំចុះទៅកាន់ទន្លេគង្គា ផែនដីក៏ល្អស្អាត ។

ពួកស្តេចលិច្ឆវីយាងព្រះមានព្រះភាគប្រថាប់នៅគ្រប់ៗ មួយយោជន៍ ក្នុងរវាងផ្លូវ ថ្វាយមហាទាន ទ្រង់ធ្វើការបូជាជាទ្វេគុណ ៣ ថ្ងៃ ទើបយាង ស្តេចឆ្ពោះទៅក្រុងវេសាលី ។ កាលព្រះមានព្រះភាគស្តេចដល់ក្រុងវេសាលី សក្កទេវរាជ មានពួកទេវតាហែហម ក៏ស្តេចមកដល់ ។ ព្រោះការប្រជុំ របស់ពួកទេវតាអ្នកមានសក្តិធំ ពួកមនុស្សទើបនាំគ្នាគេចទៅចំណែកម្ខាង ។ ព្រះមានព្រះភាគ ប្រថាប់ឈរជិតទ្វារនគរ ទ្រង់ហៅព្រះអានន្ទមក ត្រាស់ ថា "អានន្ទ អ្នកចូររៀនរតនសូត្រនេះ យកគ្រឿងប្រកបពលីកម្ម និមន្តដើរ ទៅចន្លោះកំពែងទាំង ៣ ជាន់ នៃក្រុងវេសាលីជាមួយពួកស្តេចលិច្ឆវីរាជ- កុមារ ធ្វើព្រះបរិត្ត" ហើយបានត្រាស់រតនសូត្រ ។

ការវិសជ្ជនាបញ្ហាទាំងនេះថា ក៏ព្រះសូត្រនេះនរណាពោល ពោល

កាលណា ពោលទីណា និងពោលព្រោះហេតុអ្វី បុរាណាចារ្យទាំងឡាយពណ៌នាទុកពិស្តារ តាំងពីរឿងក្រុងវេសាលីជាដើម ដោយប្រការដូច្នេះ ។

គ្រានោះ ក្នុងថ្ងៃដែលព្រះមានព្រះភាគស្តេចដល់ក្រុងវេសាលីនោះឯង រតនសូត្រនេះ ដែលព្រះមានព្រះភាគត្រាស់ជិតទ្វារក្រុងវេសាលី ដើម្បីកម្ចាត់ឧបទ្រវៈទាំងនោះ ព្រះអានន្ទក៏រៀនយក កាលនឹងពោលដើម្បីប្រយោជន៍នៃការការពារគ្នា ទើបយកបាត្ររបស់ព្រះមានព្រះភាគដាក់ទឹកមក ដើរប្រោះព្រំទូទាំងព្រះនគរ ។ ពេលព្រះថេរៈពោលថា **យំកិញ្ចិ** ប៉ុណ្ណោះ ពួកអមនុស្សដែលអាស្រ័យគំនរសម្រាម និងទីជញ្ជាំងផ្ទះជាដើម ដែលមិនទាន់រត់ចេញទៅអំពីមុន ក៏នាំគ្នារត់ចេញទៅតាមផ្លូវទ្វារទាំង ៤ ។ ទ្វារទាំងឡាយក៏មិនមានទីចន្លោះ អមនុស្សពួកខ្លះ កាលមិនបានទីចន្លោះទ្វារទាំងឡាយ ក៏ទម្លាយកំពែងក្រុងរត់ចេញទៅ ។ ពេលពួកអមនុស្សនាំគ្នារត់ចេញទៅហើយ ខ្លួនពួកមនុស្សទាំងឡាយក៏ស្ងប់រោគទៅ ពួកមនុស្សទាំងឡាយ ក៏នាំគ្នាចេញមកបូជាព្រះថេរៈ ដោយផ្កាឈើ និងគ្រឿងក្រអូបជាដើមគ្រប់យ៉ាង ។ មហាជនយកគ្រឿងក្រអូបគ្រប់យ៉ាង លាបសណ្ឋាគារ

(ទីប្រជុំ) កណ្ដាលព្រះនគរ ធ្វើពិតានវិចិត្រដោយរតនៈ ប្រដាប់ដោយគ្រឿងប្រដាប់គ្រប់យ៉ាង ក្រាលពុទ្ធាសនៈត្រង់ទីនោះ ហើយយាងព្រះមានព្រះភាគមក ។

ព្រះមានព្រះភាគ ស្ដេចយាងចូលកាន់សណ្ឋាគារ ប្រថាប់លើអាសនៈដែលគេក្រាលទុកហើយ ។ ទាំងភិក្ខុសង្ឃ ពួកព្រះរាជា និងមនុស្សទាំងឡាយ អង្គុយលើអាសនៈដែលសមគួរ ។ សូម្បីសក្កទេវរាជ ក៏ប្រថាប់អង្គុយជិតនឹងទេវបរិស័ទ ក្នុងទេវលោកទាំងពីរ ទាំងទេវតាដទៃៗ ផង ។ សូម្បីព្រះអានន្ទត្ថេរ ក៏និមន្តទៅទូទាំងក្រុងវេសាលី ធ្វើអារក្ខាហើយ ក៏មកព្រមជាមួយពួកមនុស្សក្រុងវេសាលី គង់ក្នុងទីដ៏សមគួរ ។ ក្នុងទីនោះព្រះមានព្រះភាគ ក៏បានត្រាស់រតនសូត្រនោះឯងដល់មនុស្សគ្រប់គ្នា ។

ក៏មាតិកាណា ខ្ញុំបានតាំងទុកថា ខ្ញុំនឹងប្រកាសន័យនេះថា រតនសូត្រនេះ នរណាពោល ពោលកាលណា ពោលទីណា និងពោលព្រោះហេតុអ្វី មាតិកានោះដែលខ្ញុំពោលទុកពិស្ដារហើយ ដោយប្រការទាំងពួងដោយពាក្យមានប្រមាណប៉ុណ្ណេះ ។

# ពណ៌នាគាថាថា យានីធ

ឥឡូវនេះ នឹងផ្តើមពណ៌នាសេចក្តី ព្រោះខ្ញុំបានពោលទុកថា "នឹងពណ៌នាសេចក្តីនៃរតនសូត្រនោះ" តែអាចារ្យពួកមួយពោលថា ព្រះមាន-ព្រះភាគត្រាស់ ៥ គាថាដើម ដ៏សេសព្រះអានន្ទពោល វេលាធ្វើដែលព្រះបរិត្ត នឹងយ៉ាងណាក៏ដោយ ប្រយោជន៍អ្វីដល់យើងដោយគាថាតិចតួចដែលនៅមិនទាន់បានពិចារណានេះ ខ្ញុំនឹងពណ៌នាសេចក្តីនៃរតនសូត្រនេះសូម្បីដោយប្រការទាំងពួង ។

នឹងពណ៌នាគាថាដំបូងថា **យានីធ ភូតានិ** ជាដើម ។ ក្នុងគាថាដំបូងនោះ បទថា **យានិ** (ពួកណា) បានដល់ យ៉ាងណា មិនថានឹងមានសក្តិ៍តូច ឬសក្តិ៍ធំ ។ បទថា **ឥធ** (ក្នុងទីនេះ) បានដល់ ក្នុងប្រទេសនេះ ព្រះមានព្រះភាគ ត្រាស់សំដៅដល់ស្ថានទីប្រជុំក្នុងខណៈនោះ ។

ក្នុងបទថា **ភូតានិ ភូត** សព្ទ ប្រើសំដៅដល់វត្ថុដែលមានហើយបានក្នុងប្រយោគជាដើមយ៉ាងនេះថា **ភូតស្មឹ បាចិត្តិយំ** ជាអាបត្តិបាចិត្តិយ៍ព្រោះភូតគាម ។

ប្រើសំដៅដល់ **ខន្ធបញ្ចកៈ** បានក្នុងប្រយោគជាដើមយ៉ាងនេះថា **ភូតមិទំ ភិក្ខវេ សមនុបស្សថ** ម្នាលភិក្ខុទាំងឡាយ ពួកអ្នកចូរពិចារណាឃើញខន្ធបញ្ចកៈនេះ ។

ប្រើសំដៅដល់ រូប មានបឋវីជាដើម ៤ យ៉ាង បានក្នុងប្រយោគជាដើមថា **ចត្តារោ ខោ ភិក្ខុ មហាភូតា ហេតុ** ភិក្ខុ មហាភូតរូប ៤ នេះឯង ជាហេតុ ។

ប្រើសំដៅដល់ ព្រះខីណាស្រព បានក្នុងប្រយោគជាដើមថា **យោ ច កាលឃសោ ភូតោ** ក៏ព្រះខីណាស្រពណា ទំពាស៊ីកាលវេលា ។

ប្រើសំដៅដល់ សព្វសត្វ បានក្នុងប្រយោគជាដើមថា **សព្វេវ និក្ខិបិស្សន្តិ ភូតា លោកេ សមុស្សយំ** សព្វសត្វទឹងលះបង់រាងកាយនេះទុកក្នុងលោក ។

ប្រើសំដៅដល់ ដើមឈើជាដើម បានក្នុងប្រយោគជាដើមថា **ភូតគាមបាតព្យតាយ** ព្រោះធ្វើឲ្យវិនាសភូតគាម ។

ប្រើសំដៅដល់ ពួកសត្វខាងក្រោមទេវតាជាន់ចាតុម្មហារាជ បាន

ក្នុងប្រយោគជាដើមយ៉ាងនេះថា **ភូតំ ភូតតោ សញ្ជានាតិ** ចាំបាននូវពួកសត្វដោយភាពជាពួកសត្វ ដូច្នោះ **ភូត** សព្ទ ក្នុងទីនេះ គប្បីជ្រាបថា ប្រើក្នុងអត្ថថា អមនុស្ស ដោយមិនផ្សេងគ្នា ។

បទថា **សមាគតានិ** ប្រែថា មកប្រជុំហើយ ។ ពាក្យថា **ភុម្មានិ (នៅភាគផែនដី)** បានដល់ ដែលកើតលើផែនដី ។ សព្ទថា **វា** ប្រើក្នុងសេចក្ដីថា មិនប្រាកដ ។ ដោយ **វា** សព្ទនោះ ព្រះមានព្រះភាគទ្រង់ធ្វើវិកប្បដូច្នេះថា **យានីធ ភុម្មានិ វា ភូតានិ សមាគតានិ** (ពួកភូតឯណានៅលើផែនដី មកប្រជុំគ្នាហើយក្នុងទីនេះ) ហើយត្រាស់ថា **យានិ វ អន្តលិក្ខេ** (ឬពួកណានៅលើអាកាស) ដើម្បីទ្រង់ធ្វើវិកប្បទី ២ ទៀត ។ សេចក្ដីថា ឬសត្វពួកណា កើតហើយក្នុងអាកាស ពួកសត្វទាំងអស់នោះមកប្រជុំហើយក្នុងទីនេះ ។ ក៏ក្នុងសេចក្ដីនេះ សត្វទាំងឡាយដែលកើតហើយ មានហើយ តាំងពីទេវតាជាន់យាមា រហូតដល់ជាន់អកនិដ្ឋៈ គប្បីជ្រាបថា មានហើយ (កើតហើយ) ក្នុងអាកាស ព្រោះជាសត្វដែលកើតក្នុងវិមានដែលប្រាកដក្នុងអាកាស ។ សត្វទាំងឡាយខាងក្រោមនោះ និង

តាំងពីបាតភ្នំសិនេរុ រហូតដល់ពួកដែលស្ថិតនៅក្នុងដើមឈើ និងវល្លិ៍ជាដើម និងពួកដែលកើតហើយ មានហើយលើផែនដី សត្វទាំងអស់នោះគប្បីជ្រាបថា សត្វកើតលើផែនដី ព្រោះជាសត្វដែលកើតត្រង់ផែនដី និងត្រង់ដើមឈើ វល្លិ៍ និងភ្នំជាដើម ដែលទាក់ទងជាមួយផែនដី ។

ព្រះមានព្រះភាគ ដើម្បីទ្រង់កំណត់ពួកសត្វអមនុស្សគ្រប់ពួក ដោយ ២ បទថា **កុម្មានិ វា យានិ វ អន្តលិក្ខេ** (ឬពួកភូតឯណានៅលើផែនដី ឬនៅអាកាស) ហើយទ្រង់កំណត់សំដែងដោយបទមួយទៀត ត្រាស់ថា **សព្វេវ ភូតា សុមនា ភវន្តុ** (សូមពួកភូតទាំងអស់ ចូរមានចិត្តល្អ) ។ បទថា **សព្វេ** (ទាំងអស់) បានដល់ មិនមានសល់ឡើយ ។ បទថា **ឯវ** ចុះ ក្នុងអត្ថថា អវធារណៈ (ហាមសេចក្ដីឯទៀត) អធិប្បាយថា មិនវៀរសូម្បីតែម្នាក់ ។ ពាក្យថា **ភូតា** (ពួកភូត) បានដល់ ពួកអមនុស្ស ។ បទថា **សុមនា ភវន្តុ** (ចូរមានចិត្តល្អ) បានដល់ អ្នកមានចិត្តនៅជាសុខ គឺថា ចូរជាអ្នកមានបីតិសោមនុស្ស ។ បទថា **អថោបិ** ជានិបាតទាំង ២ បទ ចុះក្នុងអត្ថ គឺ ការកាន់យកពាក្យ (ប្រយោគ) ដើម្បីប្រកបទុកក្នុង

កិច្ច គឺ នាទីដទៃ ។ បទថា ***សក្កច្ច សុណន្តុ ភាសិតំ*** (និងចូរស្តាប់ភាសិតដោយគោរព) បានដល់ ធ្វើឲ្យជាប្រយោជន៍ ធ្វើទុកក្នុងចិត្ត រួបរួមដោយចិត្តទាំងអស់ហើយ ចូរស្តាប់ទេសនារបស់យើង ដែលនឹងនាំមកនូវទិព្វសម្បត្តិ និងលោកុត្តរសុខ ។

ក្នុងព្រះសូត្រនេះ ព្រះមានព្រះភាគទ្រង់ត្រាស់បញ្ចូលពួកភូតដោយព្រះតម្រាស់ ដែលមិនពិតប្រាកដថា ***យានីធ ភូតានិ សមាគតានិ*** (ពួកភូតឯណា មកប្រជុំគ្នាហើយក្នុងទីនេះ) ហើយទើបទ្រង់កំណត់ជា ២ ចំណែកទៀតថា ***ភុម្មានិ វា យានិ វ អន្តលិក្ខេ*** (ពួកភូតឯណា នៅលើផែនដី ឬលើអាកាស) តពីនោះ ក៏ត្រាស់រួមទៀតថា ***សព្វេវ ភូតា*** (ពួកភូតទាំងអស់) ទ្រង់ប្រកបសត្វទុកក្នុងអាសយសម្បត្តិ ដោយព្រះតម្រាស់នេះថា ***សុមនា ភវន្តុ*** (ចូរមានចិត្តល្អ) ទ្រង់ប្រកបសត្វក្នុងប្រយោគសម្បត្តិ ដោយព្រះតម្រាស់នេះថា ***សក្កច្ចំ សុណន្តុ ភាសិតំ*** (ចូរស្តាប់ភាសិតដោយគោរព) ទ្រង់ប្រកបសត្វទុកក្នុងសម្បត្តិ គឺ យោនិសោមនសិការ និងក្នុងសម្បត្តិ គឺ ការយោសនាអំពីអ្នកដទៃ ក៏ដូចគ្នា ទ្រង់ប្រកបសត្វទុកក្នុងសម្បត្តិ គឺ

ការតាំងខ្លួនទុកដោយប្រពៃ និងការចូលទៅរកសប្បុរស និងក្នុងសម្បត្តិ គឺ ហេតុនៃសមាធិ និងបញ្ញាក៏ដូចគ្នា ទើបទ្រង់បញ្ចប់ព្រះគាថា ។

## ពណ៌នាគាថាថា តស្មា ហិ

នឹងពោលគាថាទី ២ ថា **តស្មា ហិ ភូតា** ជាដើម ។ ក្នុងគាថានោះ ។ បទថា **តស្មា** (ព្រោះដូច្នោះ) ជាពាក្យពោលដល់ហេតុ ។ បទថា **ភូតា** ជាពាក្យអញ្ជើញ ។ បទថា **និសាមេថ (អ្នកទាំងឡាយចូរតាំងចិត្តស្តាប់)** បានដល់ ចូរស្តាប់ ។ បទថា **សព្វេ (ទាំងអស់)** បានដល់មិនមានសេសសល់ ។ លោកអធិប្បាយទុកដូចម្តេច? លោកអធិប្បាយថា ព្រោះហេតុដែលអ្នកទាំងឡាយ លះទិព្វយសស្ថាន និងការព្រមព្រៀងនៃគ្រឿងឧបភោគបរិភោគក្នុងទិព្វយសស្ថាននោះ មកប្រជុំក្នុងទីនេះ ដើម្បីស្តាប់ធម៌ មិនមែនដើម្បីការមើលការរាំ ការច្រៀងជាដើម ដូច្នោះ សូមអ្នកទាំងឡាយដែលជាភូតទាំងអស់ តាំងចិត្តស្តាប់ធម៌ ។

ម្យ៉ាងទៀត ដោយព្រះតម្រាស់ថា **សុមនា ភវន្តុ សក្កច្ចំ សុណន្តុ** (ចូរមានចិត្តល្អ ចូរស្តាប់ដោយគោរព) ព្រះមានព្រះភាគទ្រង់ជ្រាបថា ភូត

ទាំងនោះមានចិត្តល្អ នឹងប្រាថ្នាស្ដាប់ដោយគោរព ទើបត្រាស់ថា ព្រោះហេតុដែលអ្នកទាំងឡាយ ប្រកបដោយភាពជាអ្នកមានចិត្តល្អ ដោយអត្តសម្មាបណិធិ យោនិសោមនសិការ និងអាសយសុទ្ធិ ដោយភាពជាអ្នកប្រាថ្នាស្ដាប់ដោយគោរព និងដោយបយោគសុទ្ធិ ព្រោះជាបទដ្ឋាននៃការចូលទៅសេពគប់សប្បុរស និងការឃោសនាអំពីអ្នកដទៃ ដូច្នោះ សូមភូតទាំងឡាយតាំងចិត្តស្ដាប់ចុះ ។

ម្យ៉ាងទៀត បទណា ត្រាស់ថា **ភាសិតំ (ភាសិត)** ចុងគាថាដើមទ្រង់អាងបទនោះជាតួហេតុ ទើបត្រាស់ថា ព្រោះហេតុថាធម្មតាភាសិតរបស់តថាគត រកបានដោយលំបាកក្រៃលែង ព្រោះខណៈដែលវៀរចាកអខណៈទាំងពួង រកបានដោយលំបាក និងមានអានិសង្សដ៏ច្រើន ព្រោះប្រព្រឹត្តទៅដោយព្រះបញ្ញាគុណ និងព្រះករុណាគុណ ទាំងតថាគតក៏បំណងនឹងពោលភាសិតនោះ ទើបបានត្រាស់ថា **សុណន្តុ ភាសិតំ (ចូរស្ដាប់ភាសិត)** ដូច្នោះ សូមភូតទាំងឡាយគ្រប់គ្នាតាំងចិត្តស្ដាប់ចុះ ។ ព្រះតម្រាស់នេះ គឺ ទ្រង់អធិប្បាយដោយបទនៃគាថានេះ ។

ព្រះមានព្រះភាគ កាលទ្រង់លើកហេតុនេះយ៉ាងនេះ ទ្រង់ប្រកប ភូតទាំងឡាយទុកក្នុងការតាំងចិត្តស្តាប់ភាសិតរបស់ព្រះអង្គ ទើបទ្រង់ផ្តើម ត្រាស់ភាសិតដែលគប្បីតាំងចិត្តស្តាប់ថា **មេត្តំ ករោថ មានុសិយា បជាយ (ចូរធ្វើសេចក្តីមេត្តាក្នុងពួកប្រជាដែលជាមនុស្ស)** ។ ភាសិតនោះមានអត្ថ ថា ប្រជាជនពួកមនុស្សណា ត្រូវឧបទ្រវៈទាំង ៣ បៀតបៀនហើយ សូម អ្នកទាំងឡាយចូរចូលទៅតាំងមេត្តា នូវភាពជាមិត្រ ការមានអធ្យាស្រ័យ ញុំាងប្រយោជន៍ដល់ប្រជាជនពួកមនុស្សនោះចុះ ។ អាចារ្យពួកខ្លះពោល ថា **មានុសិកំ បជំ** ពាក្យនោះមិនត្រូវ ព្រោះភូតដែលនៅលើផែនដីមិន កើត ។ អាចារ្យពួកខ្លះទៀតពណ៌នាសេចក្តីណា សេចក្តីសូម្បីនោះ ក៏មិន ត្រូវ ។ ចំណែកក្នុងទីនេះមានអធិប្បាយថា យើងមិនពោលដោយកម្លាំង គឺ ភាពជាធំថា ជាពុទ្ធៈ ប៉ុន្តែថា វត្ថុណាជាប្រយោជន៍ដល់ពួកអ្នក និង ដល់ប្រជាជនពួកមនុស្សនេះ យើងនឹងពោលវត្ថុនោះថា សូមពួកលោកចូរ ធ្វើសេចក្តីមេត្តាដល់ប្រជាជនពួកមនុស្សចុះ ។

ក្នុងប្រការនេះ មេត្តារបស់ជនទាំងនេះអ្នកធ្វើសេចក្តីមេត្តា គប្បីជ្រាប

ថា ជាប្រយោជន៍ធំទូលាយ ដោយព្រះសូត្រទាំងឡាយជាដើមយ៉ាងនេះថា

រាជឥសីពួកណា ទ្រង់ឈ្នះផែនដីដែលបរិបូរដោយពួកសត្វ
ត្រាច់ចរបូជាយញ្ញ អស្សមេធៈ បរិសមេធៈ សម្មាបាសៈ
វាជបេយ្យៈ និងនិរគ្គឡៈ ។ រាជឥសីទាំងនោះ មិនបាន
សោយផល សូម្បីតែចំណែកទី ១៦ នៃមេត្តាចិត្តដែលអប់រំ
ល្អហើយ ។ បើបុគ្គលមានចិត្តមិនគិតប្រទូសក្នុងសត្វ សូម្បី
តែមួយ ប្រព្រឹត្តមេត្តា រមែងជាអ្នកឈ្លាសដោយចិត្តនោះ ។
អរិយជនមានចិត្តអាណិតសត្វមានជីវិតគ្រប់ជំពូក ឈ្មោះថា
ប្រកបបុណ្យដ៏ច្រើន ដូច្នេះ ។

និងដោយអានិសង្ស ១១ ប្រការ ។

មេត្តា គប្បីជ្រាបថាមានប្រយោជន៍ដ៏ធំ សូម្បីដល់សត្វទាំងឡាយ
ដែលគេធ្វើសេចក្តីមេត្តា ដោយព្រះសូត្រជាដើមយ៉ាងនេះថា ៖

ទេវតានុកម្បិតោ បោសោ  សទា ភទ្រានិ បស្សតិ
បុគ្គលដែលទេវតាអនុគ្រោះហើយ រមែងប្រសព្វសេចក្តី

ចម្រើនគ្រប់កាល ។

ព្រះមានព្រះភាគ កាលទ្រង់សំដែងថា មេត្តាមានប្រយោជន៍ដ៏ធំដល់បុគ្គលសូម្បីទាំងពីរចំណែកយ៉ាងនេះ ទើបត្រាស់ថា **ធ្វើសេចក្តីមេត្តាក្នុងពួកប្រជាដែលជាមនុស្ស** ឥឡូវនេះ កាលនឹងទ្រង់សំដែងសូម្បីឧបការៈទើបត្រាស់ថា ៖

ទិវា ច រត្តោ ច ហរន្តិ យេ ពលឹ

តស្មា ហិ នេ រក្ខថ អប្បមត្តា ។

មនុស្សពួកណា រមែងនាំពលីកម្មទៅទាំងថ្ងៃ និងយប់

ព្រោះដូច្នោះ អ្នកទាំងឡាយចូរកុំប្រមាទ ជួយរក្សាពួក

មនុស្សទាំងនោះ ។

ភាសិតនោះ មានសេចក្តីថា មនុស្សពួកណាសាងទេវតាសូម្បីដោយភាពជាគំនូរ និងគូសដោយដើមឈើជាដើម ហើយចូលទៅកាន់រុក្ខចេតិយជាដើម ធ្វើពលីកម្មបូជាក្នុងវេលាថ្ងៃ និងធ្វើពលីកម្មក្នុងវេលាយប់ ថ្ងៃខាងនោចជាដើម ឧទ្ទិសទេវតាទាំងឡាយ ឬថ្វាយទានសលាកភត្តជាអាទិ៍ ធ្វើ

ពលីកម្មឧទ្ទិសដល់អារក្ខទេវតា សូម្បីដោយការឧទ្ទិសបត្តិទាន (ឲ្យចំណែកបុណ្យ) ដល់ព្រហ្ម និងទេវតាទាំងឡាយ និងធ្វើពលិកម្មក្នុងវេលាយប់ដោយការលើកឆត្រ តាំងប្រទីប កម្រងផ្កា និងចាត់ចែងឲ្យមានការស្តាប់ធម៌រហូតអស់រាត្រីជាដើម ហើយឧទ្ទិសបត្តិទានមយៈ មនុស្សទាំងនោះពួកអ្នកនឹងមិនគប្បីរក្សាដូចម្តេចបាន ។ ព្រោះហេតុដែលមនុស្សពួកណាធ្វើពលីកម្មឧទ្ទិសដល់ពួកអ្នក ទាំងថ្ងៃ ទាំងយប់យ៉ាងនេះ ដូច្នោះ ពួកអ្នកចូររក្សាមនុស្សពួកនោះចុះ ។ អធិប្បាយថា ដូច្នោះ ពួកអ្នកចូរឃុំគ្រងរក្សាមនុស្សពួកនោះ គឺ ជាអ្នកមិនប្រមាទ ធ្វើភាពជាអ្នកកតញ្ញូនោះទុកក្នុងដួងចិត្ត ព្រួកដល់រឿយៗ ចូរនាំវត្ថុដែលមិនជាប្រយោជន៍ដល់ពួកគេចេញទៅ ចូរនាំចូលតែវត្ថុដែលជាប្រយោជន៍ សូម្បីព្រោះហេតុធ្វើពលីកម្មនោះ ។

## ពណ៌នាគាថាថា យំកិញ្ចិ

ព្រះមានព្រះភាគ គ្រាទ្រង់សំដែងថា មនុស្សមានឧបការៈក្នុងទេវតាទាំងឡាយយ៉ាងនេះហើយ ទើបទ្រង់ផ្តើមការប្រកបសច្ចវចនៈ ដោយន័យ

ថា **យំកិញ្ចិ វិត្តំ** (ទ្រព្យជាគ្រឿងរីករាយណាមួយ) ដូច្នេះជាដើម ដើម្បីទ្រង់រម្ងាប់ឧបទ្រវៈរបស់មនុស្សទាំងនោះ និងដើម្បីការស្តាប់ធម៌របស់ទេវតានិងមនុស្សទាំងឡាយ ដោយការប្រកាសគុណរបស់ព្រះរតនត្រ័យ មានព្រះពុទ្ធជាដើម ។ ក្នុងសច្ចវាចានោះ បទថា **យំកិញ្ចិ** (**យ៉ាងណាមួយ**) សេចក្តីថា លោកកាន់យកមិនមានសល់ ដោយការកំណត់ទុក គឺ វត្ថុណាមួយដែលគួរធ្វើការផ្លាស់ប្តូរបានក្នុងទីនោះៗ ។ បទថា **វិត្តំ** (ទ្រព្យជាគ្រឿងរីករាយចិត្ត) បានដល់ ទ្រព្យ ។ ពិតណាស់ ទ្រព្យនោះ ឈ្មោះថា ទ្រព្យជាគ្រឿងរីករាយចិត្ត ព្រោះឲ្យកើតសេចក្តីរីករាយចិត្ត ។ ទ្រង់សំដែងមនុស្សលោកដោយពាក្យថា **ក្នុងលោកនេះ** ទ្រង់ក៏សំដែងលោកដ៏សេសក្រៅពីមនុស្សលោកនោះ ដោយពាក្យថា **ក្នុងលោកដទៃ** ដោយ ២ បទនោះ គប្បីជ្រាបថា ក៏មានសេចក្តីដល់នាគ និងសុបណ្ណជាដើមដ៏សេស វៀរមនុស្សនិងសួគ៌ទាំងឡាយ ព្រោះកាលព្រមនឹងកាន់យកលោកទាំងពួង វៀរមនុស្សទាំងឡាយ ក៏បានត្រាស់ទុកខាងមុខថា **ក្នុងសួគ៌** ។

ទ្រព្យជាគ្រឿងរីករាយចិត្តឯណា សម្រាប់មនុស្ស ដែលជាទ្រព្យប្រើ

ផ្ទាស់ប្តូរ និងប្រើជាគ្រឿងប្រដាប់ គ្រឿងបរិភោគ (ប្រើប្រាស់) មានមាស ប្រាក់ កែវមុក្តា កែវមណី កែវពិទូរ្យ កែវប្រពាឡ ត្បូងទទឹម និងកែវ ច្រើនយ៉ាង និងទ្រព្យជាគ្រឿងរីករាយចិត្តឯណា សម្រាប់នាគ និងគ្រុឌ ជាដើម ដែលឧប្បត្តិក្នុងភពទាំងឡាយ ដ៏ធំច្រើនរយយោជន៍ក្នុងវិមានរតនៈ នៅលើផែនដី ដែលក្រាលដោយខ្សាច់កែវមុក្តា និងកែវមណី ។ ទ្រព្យជា គ្រឿងរីករាយចិត្តនោះ ក៏ជាការសំដែងហើយដោយបទទាំងពីរនេះ ដោយ ប្រការដូច្នេះ ។

បទថា **សគ្គេសុ វា** (ក្នុងសួគ៌) បានដល់ ទេវលោកដែលជាកាមា-វចរៈ និងរូបាវចរៈ ។ ទេវលោកទាំងនោះ ឈ្មោះថា **សួគ៌** ព្រោះដំណើរ ទៅ គឺ ដល់បានដោយកម្មដ៏ល្អ ។ ម្យ៉ាងទៀត ឈ្មោះថា **សួគ៌** ព្រោះ មានអារម្មណ៍ល្អពិសេស ។ បទថា **យំ** (ណា) បានដល់ ដែលមានម្ចាស់ របស់ ឬមិនមានម្ចាស់របស់ណា ។ ពាក្យថា **រតនំ** (រតនៈ) បានដល់ ឈ្មោះថា រតនៈ ព្រោះនាំឲ្យកើត ឲ្យបម្រើននូវសេចក្តីត្រេកអរ ។ បទថា **រតនៈ** នេះ ជាឈ្មោះរបស់វត្ថុគ្រប់យ៉ាងដែលធ្វើឲ្យស្អាត មានតម្លៃច្រើន

ប្អឹងមិនបាន ឃើញលំបាក និងជារបស់បរិភោគប្រើប្រាស់របស់សត្វអ្នក មិនថោកថយ ដូចដែលលោកពោលទុកថា ៖

របស់ដែលធ្វើឲ្យគេកោតក្រែង មានតម្លៃច្រើន ប្អឹងមិនបាន
ឃើញបានលំបាក ជាគ្រឿងប្រើប្រាស់របស់សត្វអ្នកមិន
ថោកថយ ព្រោះហេតុនោះ ទើបហៅថា រតនៈ ។

បទថា បណីតំ (ដ៏ប្រណីត) បានដល់ ខ្ពង់ខ្ពស់ ប្រសើរជាទីបំផុត មិនតិចតួច គួរីករាយ ។ រតនៈណាក្នុងសួគ៌ទាំងឡាយ ចាប់តាំងពីវិមានសុធម្មសភា វិជយន្តប្រាសាទដែលជារតនៈ សុទ្ធតែមានទំហំច្រើនរយយោជន៍ មានម្ចាស់របស់ និងរតនៈណាដែលទាក់ទងនៅក្នុងវិមានដែលសូន្យទទេ ក្នុងសត្វទាំងឡាយដែលធ្វើអបាយប៉ុណ្ណោះឲ្យពេញ ព្រោះមិនមែនជាសម័យដែលព្រះពុទ្ធស្តេចឧប្បត្តិ មិនមានម្ចាស់របស់ ឬថា រតនៈសូម្បីដទៃណាដែលអាស្រ័យនៅក្នុងផែនដី មហាសមុទ្រ និងភ្នំហិមពាន្តជាដើម មិនមានម្ចាស់របស់ ។ រតនៈនោះ ក៏ទ្រង់សំដែងហើយ ដោយបទនៃគាថានេះដោយប្រការដូច្នេះ ។

ស័ព្ទថា ន ក្នុងបទគាថាថា **ន នោ សមំ អត្ថិ តថាគតេន** (ដែលស្មើដោយព្រះតថាគត មិនមានឡើយ) ចុះក្នុងអត្ថបដិសេធ ។ ស័ព្ទថា **នោ** ចុះក្នុងអត្ថហាមសេចក្តីដទៃ ។ បទថា **សមំ** (ស្មើ) បានដល់ ប្រៀបធៀប ។ បទថា **អត្ថិ** ប្រែថា មាន ។ បទថា **តថាគតេន** (ដោយព្រះតថាគត) បានដល់ ដោយព្រះពុទ្ធ ។ លោកអធិប្បាយយ៉ាងណា? អធិប្បាយទុកដូច្នេះ ទ្រព្យជាគ្រឿងរីករាយចិត្ត និងរតនៈនោះ រតនៈសូម្បីតែមួយ ដែលស្មើដោយពុទ្ធរតនៈមិនមានឡើយ ។ ពិតហើយ ទ្រព្យជាគ្រឿងរីករាយចិត្តណា ឈ្មោះថា រតនៈ ព្រោះអត្ថថា ធ្វើឲ្យកើតសេចក្តីកោតក្រែង ទ្រព្យជាគ្រឿងរីករាយចិត្តនោះ គឺអ្វី គឺ ចក្ររតន៍ និងមណីរតន៍របស់ស្តេចចក្រពត្តិ តែកាលកើតឡើងហើយ មហាជនមិនធ្វើសេចក្តីគោរពកោតក្រែងក្នុងទីដទៃ នរណាៗ កាន់យកផ្កាឈើ និងគ្រឿងក្រអូបជាដើមហើយ នឹងមិនទៅស្ថានទីរបស់យក្ស និងស្ថានទីរបស់ភូត ជនសូម្បីគ្រប់រូប នឹងធ្វើការគោរពកោតក្រែងបូជាចំពោះចក្ររតន៍ និងមណីរតន៍ប៉ុណ្ណោះ ប្រាថ្នាពរនោះៗ និងពរខ្លះដែលប្រាថ្នាហើយ គេក៏សម្រេចផលបាន រតនៈ

សូម្បីនោះ ស្មើដោយពុទ្ធរតនៈរមែងមិនមាន ។

ប្រសិនបើ ទ្រព្យជាគ្រឿងរីករាយចិត្ត ឈ្មោះថា **រតនៈ** ព្រោះអត្ថថា ធ្វើឲ្យកើតសេចក្តីគោរពកោតក្រែង ព្រះតថាគតប៉ុណ្ណោះ ឈ្មោះថា **រតនៈ** ។ ពិតហើយ កាលព្រះតថាគតស្តេចទ្រង់ឧប្បត្តិហើយ ទេវតា និងមនុស្ស អ្នកមានសក្តិធំ គ្រប់ពួកក្រុម ទេវតា និងមនុស្សទាំងនោះ រមែងមិនធ្វើសេចក្តីគោរពកោតក្រែងក្នុងរតនៈដទៃ រមែងមិនបូជារតនៈដទៃៗ ។ ពិតហើយ សហម្បតីព្រហ្ម ក៏បូជាព្រះតថាគត ដោយកម្រងរតនៈប៉ុនភ្នំសិនេរុ ។ ម្យ៉ាងទៀត ទេវតាពួកដទៃ និងមនុស្សទាំងឡាយ មានព្រះបាទពិម្ពិសារ ព្រះបាទកោសល និងអនាថបិណ្ឌិកៈជាដើម ក៏បូជាតាមកម្លាំង ។ ព្រះបាទអសោកមហារាជទ្រង់លះព្រះរាជទ្រព្យ ៩៦ កោដិ ទ្រង់សាងវិហារ ៨៤.០០០ ខ្នង ទូទាំងជម្ពូទ្វីប ឧទ្ទិសថ្វាយព្រះមានព្រះភាគ សូម្បីស្តេចបរិនិព្វានហើយ ។ នឹងចាំបាច់ពោលថ្វីដល់ពួកអ្នកដែលគោរពកោតក្រែងដទៃទៀត ។ ម្យ៉ាងទៀត ការធ្វើសេចក្តីគោរពកោតក្រែង ឧទ្ទិសស្ថានទីប្រសូត្រ ទីត្រាស់ដឹង ទីប្រកាសព្រះធម្មចក្ក និងស្ថានទីបរិនិព្វាន ឬព្រះ

ចេតិយ គឺ ព្រះបដិមា របស់ព្រះកស្សបៈសម្មាសម្ពុទ្ធសូម្បីបរិនិព្វាន ក៏ប្រព្រឹត្តទៅដូចរបស់ព្រះមានព្រះភាគ ។ រតនៈដែលស្មើដោយព្រះតថាគតសូម្បីព្រោះអត្ថថា ធ្វើឲ្យកើតសេចក្ដីគោរពកោតក្រែង រមែងមិនមានដោយប្រការដូច្នេះ ។

ទ្រព្យជាគ្រឿងរីករាយចិត្ត សូម្បីនោះ ឈ្មោះថា រតនៈ ព្រោះអត្ថថា មានតម្លៃច្រើន ក៏ដូចគ្នា ។ ទ្រព្យជាគ្រឿងរីករាយចិត្តនោះ គឺអ្វី? គឺសំពត់ដែនកាសី ។ ដូចព្រះមានព្រះភាគត្រាស់ទុកថា ម្នាលភិក្ខុទាំងឡាយសំពត់ដែនកាសីសូម្បីចាស់ក៏នៅមានពណ៌ស្រស់ មានសម្ផស្សស្រួលស្បាយនិងមានតម្លៃច្រើន ។ ទ្រព្យជាគ្រឿងរីករាយចិត្តនោះ ស្មើដោយពុទ្ធរតនៈរមែងមិនមាន ។ ប្រសិនបើទ្រព្យជាគ្រឿងរីករាយចិត្ត ឈ្មោះថា រតនៈព្រោះអត្ថថា មានតម្លៃច្រើន ព្រះតថាគតប៉ុណ្ណោះ ឈ្មោះថា រតនៈ ។ពិតហើយ ព្រះតថាគតទ្រង់ទទួលសូម្បីបង្សុកូលចីវររបស់ជនពួកណា ទាននោះរបស់ជនទាំងនោះ រមែងមានផលច្រើន មានអានិសង្សច្រើន ដូចទានរបស់ព្រះបាទអសោកមហារាជ ទាំងនេះ ក៏ព្រោះព្រះតថាគតនោះទ្រង់

គុណដ៏ធំ ។ ដោយពាក្យពោលដល់ប្រការដែលព្រះតថាគតទ្រទ្រង់គុណដ៏ធំយ៉ាងនេះ គប្បីជ្រាបបទនៃព្រះសូត្រដែលសាធកៈមិនមានទោស ក្នុងសេចក្តីនេះដូច្នេះថា ៖

តថាគតនោះ ទទួលចីវរ បិណ្ឌបាត សេនាសនៈ និងគិលានប្បច្ច័យភេសជ្ជបរិក្ខាររបស់ជនពួកណា ទាននោះរបស់ជនទាំងនោះ រមែងមានផលច្រើន មានអានិសង្សច្រើន តថាគតពោលដូច្នេះ ក៏ព្រោះតថាគតនោះជាអ្នកទ្រទ្រង់គុណដ៏ធំ ម្នាលភិក្ខុទាំងឡាយ ប្រៀបដូចសំពត់ដែនកាសីនោះ មានតម្លៃច្រើន យ៉ាងណា តថាគតពោលថា បុគ្គលនេះក៏មានឧបមាដូច្នោះ ។

រតនៈស្មើដោយព្រះតថាគត សូម្បីព្រោះអត្ថថា មានតម្លៃច្រើន រមែងមិនមាន ដោយប្រការដូច្នេះ ។

ទ្រព្យជាគ្រឿងរីករាយចិត្ត ណា ឈ្មោះថា រតនៈ ព្រោះអត្ថថា ប្រឹងមិនបាន ក៏ដូចគ្នា ។ ទ្រព្យជាគ្រឿងរីករាយចិត្តនោះ គឺអ្វី គឺ ចក្ករតន៍

របស់ព្រះចៅចក្រពត្តិ មានដុំជាមណីឥន្ទនិល មានកាំជារតនៈ ៧.០០០ មានកង់ជាកែវប្រពាឡ មានទី.តជាមាសពណ៌ក្រហម កើតឡើង មានកាំមួយៗ ផុកកាំ ១០ ពេលប៉ះនឹងខ្យល់ក៏ធ្វើសំឡេង ដូចជាសំឡេងតន្ត្រីប្រកបដោយអង្គ ៥ ដែលអ្នកជំនាញលេងហើយ , ទាំង ២ ខាងរបស់ដុំ មានមុខដូចជារាជសីហ៍ ខាងក្នុងកង់មានប្រហោង មិនមានអ្នកធ្វើ ឬអ្នកឲ្យធ្វើ គឺ តាំងឡើងពីឧតុមានកម្មជាបច្ច័យ ដែលព្រះរាជាទ្រង់បំពេញចក្កពត្តិវត្ត ១០ ប្រការហើយ ថ្ងៃឧបោសថ ១៥ កើត ទ្រង់ជម្រះព្រះកេសហើយ ទ្រង់កាន់ឧបោសថ ស្តេចឡើងលើព្រះមហាប្រាសាទ ទ្រង់ជម្រះសីល ប្រថាប់អង្គុយ និងទតឃើញចក្ករតន៍ប្រាកដឡើង ដូចព្រះច័ន្ទពេញបូរមី និងព្រះអាទិត្យ និងទ្រង់បានឮសំឡេងមកពីចម្ងាយតាំងពី ១២ យោជន៍ ឃើញពន្លឺចាំងមកពណ៌លឿងទុំពីចម្ងាយ ៣ យោជន៍ ដែលមហាជនក្រឡេកមើល និងនាំគ្នាភ្ញាក់ផ្អើលថា ប្រហែលជាព្រះច័ន្ទ ឬព្រះអាទិត្យដួងទី ២ កើតឡើងហើយ រសាត់មកលើព្រះនគរ មិនខ្ពស់ពេកមិនទាបពេក មកតាមទិសខាងកើត ដល់ខាងក្នុងព្រះរាជនិវេសន៍ហើយ ឈប់

*នៅដូចរថបាក់ក្ងោ ក្នុងទីដែលមហាជនគួរបូជាដោយគ្រឿងក្រអូប និងផ្កា ឈើជាដើម ។*

*ហត្ថិរតនៈ (ដំរីកែវ) ក៏កើតឡើងតពីចក្ករតន៍នោះឯង គឺ ដំរីស សុទ្ធ ជើងក្រហម មានកម្លាំង ៧ ដំរីសារ មានឫទ្ធិ៍ ទៅតាមផ្លូវអាកាស បាន មកពីត្រកូលដំរីឧបោសថក៏មាន ពីត្រកូលដំរីឆទ្ទន្ត បើមកពីត្រកូល ឧបោសថ ក៏ជាបងរបស់ដំរីទាំងអស់ បើមកពីត្រកូលឆទ្ទន្ត ក៏ជាប្អូនរបស់ ដំរីទាំងអស់ មានការសិក្សាដែលសិក្សាហើយ ហ្វឹកហាត់ហើយ ដំរីនោះ នាំបរិស័ទប្រមាណ ១២ យោជន៍ ដើរទូទាំងជម្ពូទ្វីប ទៅហើយប្រឡប់មក វិញឯង មុនអាហារព្រឹកនោះឯង ។*

*អស្សរតនៈ (សេះកែវ) ក៏កើតបន្តពីហត្ថិរតន៍នោះឯង គឺ សេះស សុទ្ធ ជើងក្រហម សីសៈខ្មៅ មានសក់ដូចស្មៅជំណោកទន្សាយ មកពីត្រកូល ស្ដេចសេះវលាហកៈ ។ ក្នុងប្រការនេះ ពាក្យដ៏សេសក៏ដូចគ្នានឹងហត្ថិរតន៍ នោះឯង ។*

*មណីរតនៈ (មណីកែវ) ក៏កើតតពីអស្សរតន៍នោះ មណីនោះជា*

កែវពិទូរ្យ ស្អាតដោយធម្មជាតិ មានប្រាំបីជ្រុង ច្នៃយ៉ាងល្អ ដោយប្រវែង ស្មើនឹងដុំនៃចក្រ មកពីវេបុល្លបព៌ត មណីនោះ យាមងងឹតសូម្បីប្រកប ដោយអង្គ ៤ បើដាក់លើកំពូលទង់របស់ព្រះរាជា ក៏បញ្ចេញពន្លឺភ្លឺបានមួយ យោជន៍ , ដោយពន្លឺនោះ ពួកមនុស្សសម្គាល់ថាជាពេលថ្ងៃ ក៏ប្រកបការងារ មើលឃើញដោយហោចទៅសូម្បីទាំងស្រមោចខ្មៅស្រមោចក្រហម ។

**ឥត្ថីរតនៈ (ស្ត្រីកែវ)** ក៏កើតបន្ទាប់ពីមណីរតន៍សូម្បីនោះ គឺ ស្ត្រី ដែលជាព្រះអគ្គមហេសីដោយប្រក្រតី ឬមកអំពីឧត្តរកុរុទ្វីប ឬមកពីរាជ ត្រកូលមទ្ទរាជ វៀរចាកទោស ៦ មានកម្ពស់មិនខ្ពស់ពេកជាដើម កន្លង វណ្ណៈរបស់មនុស្ស តែមិនដល់វណ្ណៈជាទិព្វ ដែលសម្រាប់ព្រះរាជា នឹង មានកាយក្តៅកាលយាមត្រជាក់ នឹងមានកាយត្រជាក់កាលយាមក្តៅ មាន សម្ផស្សដូចសំឡីដែលគេប្ញិចហើយ ៧ ដង ក្លិនចន្ទក៏ផ្សាយចេញអំពីកាយ ក្លិនឧប្បលក៏ផ្សាយចេញអំពីមាត់ និងជាបុគ្គលប្រកបដោយគុណសម្បត្តិដ៏ ច្រើន មានការភ្ញាក់មុនជាដើម ។

**គហបតិរតនៈ (គហបតិកែវ)** ក៏កើតតពីឥត្ថីរតនៈនោះ គឺ សេដ្ឋី

អ្នកធ្វើការងារដោយប្រក្រតីរបស់ព្រះរាជា នៅពេលនិងចក្ករតន៍កើតឡើង ក៏ប្រាកដទិព្វចក្ខុ ឃើញរណ្តៅទ្រព្យបានប្រមាណមួយយោជន៍ដោយជុំវិញ ទាំងដែលមានម្ចាស់ ទាំងដែលមិនមានម្ចាស់ ក៏ចូលទៅគាល់ព្រះរាជា ទូលបវារណាថា "បពិត្រព្រះសម្មតិទេព សូមព្រះអង្គទ្រង់មេត្តាប្រោសដាក់ព្រះរាជការៈកិច្ចចុះ ខ្ញុំព្រះអង្គនឹងធ្វើកិច្ចដែលគួរធ្វើទាក់ទងជាមួយទ្រព្យសម្បត្តិរបស់ព្រះអង្គផ្ទាល់ ព្រះអង្គ" ។

**បរិនាយករតនៈ (បរិនាយកកែវ)** ក៏កើតតពីគហបតិរតនៈនោះឯង គឺ ដោយប្រក្រតីជេដ្ឋរាជឱរសរបស់ព្រះរាជា ពេលចក្ករតន៍កើតឡើង ក៏ជាអ្នកប្រកបដោយបញ្ញាធ្លាតឈ្លាសដ៏ប្រសើរ អាចកំណត់ដឹងចិត្តបរិស័ទប្រមាណ ១២ យោជន៍ ដោយចិត្តខ្លួន ហើយធ្វើការនិគ្គហៈដាក់ទោស និងបគ្គហៈលើកសរសើរ ។ បរិនាយកនោះ ក៏ចូលគាល់ព្រះរាជា បវារណាថា "បពិត្រព្រះសម្មតិទេព សូមព្រះអង្គទ្រង់ប្រោសដាក់រាជការៈចុះ ខ្ញុំព្រះអង្គនឹងបរិហាររាជការដែនដីរបស់ព្រះអង្គឯង ព្រះអង្គ" ។ ឬក៏ថា ទ្រព្យជាទីរីករាយចិត្តឯណា បែបនោះ ឈ្មោះថា **រតនៈ** ព្រោះអត្ថថា ថ្លឹងមិន

បាន ទ្រព្យជាគ្រឿងរីករាយចិត្តដទៃណា មិនអាចពិនិត្យពិចារណាវាយតម្លៃបានថា មានតម្លៃមួយរយ មួយពាន់ ឬមួយកោដិ ។ ក្នុងទ្រព្យជាគ្រឿងរីករាយចិត្តនោះ សូម្បីរតនៈត្រឹមតែមួយ ដែលស្មើដោយពុទ្ធរតនៈ មិនមានឡើយ ប្រសិនបើទ្រព្យជាគ្រឿងរីករាយចិត្ត ឈ្មោះថា រតនៈ ព្រោះអត្ថថា ប្រឹងមិនបាន ព្រះតថាគតប៉ុណ្ណោះ ឈ្មោះថា **រតនៈ** ។ ពិតហើយ ព្រះតថាគត នរណាៗ ក៏មិនអាចពិនិត្យពិចារណាដោយសីល ដោយសមាធិ ឬដោយបណ្ដាបញ្ញាជាដើមណាមួយ ហើយកំណត់ថា ទ្រង់មានព្រះគុណប៉ុណ្ណេះ ទ្រង់ស្មើ ឬប្រៀបធៀបជាមួយបុគ្គលនេះ ។ រតនៈ ស្មើដោយព្រះតថាគត សូម្បីព្រោះអត្ថថា ប្រឹងមិនបាន មិនមានឡើយ ដោយប្រការដូច្នេះ ។

ទ្រព្យជាគ្រឿងជារីករាយចិត្តណា ឈ្មោះថា **រតនៈ** ព្រោះអត្ថថា ឃើញបានលំបាក ក៏ដូចគ្នា ។ ទ្រព្យជាគ្រឿងរីករាយចិត្តនេះ ក៏គឺ ប្រាកដបានលំបាក បានដល់ ស្ដេចចក្រពត្តិ និងរតនៈ ៧ ប្រការ មានចក្ករតន៍ជាដើម របស់ស្ដេចចក្រពត្តិនោះ រតនៈនោះ ដែលស្មើដោយពុទ្ធរតនៈមិន

មាន ៗ ប្រសិនបើទ្រព្យជាគ្រឿងរីករាយចិត្ត ឈ្មោះថា រតនៈ ព្រោះអត្ថថា ឃើញបានលំបាកសោត ព្រះតថាគតប៉ុណ្ណោះ ឈ្មោះថា រតនៈ ៗ ភាពជារតនៈរបស់ព្រះចៅចក្រពត្តិជាដើម នឹងឃើញបានលំបាកមកអំពីណា ៗ ពិតហើយ រតនៈទាំងនោះ រមែងកើតឡើងដ៏ច្រើនក្នុងកប្បមួយប៉ុណ្ណោះ តែព្រោះហេតុដែលលោកត្រូវសាបសូន្យចាកព្រះតថាគតរាប់បានដោយអសង្ខេយ្យកប្ប ដូច្នោះ ព្រះតថាគតប៉ុណ្ណោះ ឈ្មោះថា ឃើញបានលំបាក ព្រោះកើតឡើងគ្រាខ្លះ ៗ សមដូចដែលព្រះមានព្រះភាគត្រាស់ទុកក្នុងសម័យបរិនិព្វាន ដូច្នេះថា ៖

ម្នាលអានន្ទ ទេវតាទាំងឡាយពោលទោសថា ពួកយើងនាំគ្នាមកអំពីចម្ងាយ បំណងនឹងគាល់ព្រះតថាគត ព្រោះព្រះតថាគតអរហន្តសម្មាសម្ពុទ្ធ ស្តេចឧប្បត្តិឡើងក្នុងលោកក្នុងគ្រាខ្លះ ថ្ងៃនេះឯង យាមខាងចុងនៃរាត្រី ព្រះតថាគតក៏ស្តេចនឹងបរិនិព្វាន តែភិក្ខុអ្នកមានសក្តិធំរូបនេះ ឈរបាំងព្រះភក្ត្រព្រះមានព្រះភាគហើយ ពួកយើង មិនបាន

ឱកាសនឹងគាល់ព្រះមានព្រះភាគក្នុងកាលចុងក្រោយ ។

រតនៈដែលស្មើដោយព្រះតថាគត សូម្បីព្រោះអត្ថថា ឃើញបានលំបាក រមែងមានដោយប្រការដូច្នេះ ។

ទ្រព្យជាគ្រឿងរីករាយចិត្តសូម្បីនោះណា ឈ្មោះថា រតនៈ ព្រោះអត្ថថា ជាគ្រឿងបរិភោគប្រើប្រាស់របស់សត្វអ្នកមិនថោកថយ ក៏ដូចគ្នា ។ ទ្រព្យជាគ្រឿងរីករាយចិត្តនោះ គឺអ្វី គឺ ចក្ករតន៍ជាដើម របស់ស្តេចចក្រ-ពត្តិ ។ ពិតហើយ រតនៈនោះ មិនមែនកើតឡើងដើម្បីជាគ្រឿងបរិភោគសូម្បីដោយការយល់សប្តិរបស់បុរសថោកថយ អ្នកមានត្រកូលទាប ដូចមនុស្សចណ្ឌាល ជាងតម្បាញ ព្រាន ជាងរថ និងមនុស្សស្មូមទានជាដើម ដែលមានទ្រព្យទាំងសែនកោដិក្តី នៅលើមហាប្រាសាទ ៧ ជាន់ក្តី តែជាគ្រឿងបរិភោគរបស់សត្វដែលមិនថោកថយ ព្រោះកើតឡើងដើម្បីជាគ្រឿងបរិភោគរបស់ព្រះរាជាមហាក្សត្រិយ៍ជាឧភតោសុជាតិ បំពេញចក្រពត្តិវត្ត ១០ ប្រការបរិបូណ៌ សូម្បីរតនៈនោះ ដែលស្មើនឹងព្រះពុទ្ធរតនៈ មិនមានឡើយ ។ ក៏ប្រសិនបើទ្រព្យជាគ្រឿងរីករាយចិត្ត ឈ្មោះថា រតនៈ ព្រោះ

អត្ថថា ជាគ្រឿងបរិភោគរបស់សត្វអ្នកមិនថោកថយសោត ព្រះតថាគត ប៉ុណ្ណោះ ឈ្មោះថា រតនៈ ។ ពិតហើយ ព្រះតថាគត មិនមែនជាគ្រឿង បរិភោគ សូម្បីដោយការយល់សប្តិរបស់គ្រូទាំង ៦ មានបូរណកស្សបៈ ជាដើម ដែលសម្មតិគ្នាថាជាសត្វថោកទាប អ្នកមិនដល់ព្រមដោយឧបនិ- ស្ស័យ មានទស្សនៈវិបរិត និងរបស់សត្វពួកដទៃបែបនោះក្នុងលោក ។ តែជាគ្រឿងបរិភោគរបស់ពួកបុគ្គលដល់ព្រមដោយឧបនិស្ស័យ អ្នកអាច សម្រេចព្រះអរហត្ត កាលចប់គាថាសូម្បី ៤ បទ អ្នកមានញាណទស្សនៈ កម្ចាត់បង់កិលេស មានព្រះពាហិយទារុចីរិយៈជាដើម និងរបស់ព្រះមហា សាវ័កទាំងឡាយដទៃៗ អ្នកជាបុត្ររបស់ត្រកូលធំៗ ពិតហើយ ពួកសត្វ អ្នកមិនថោកទាបទាំងនោះ កាលញ៉ាំងទស្សនានុត្តរិយៈ សវនានុត្តរិយៈ និង បារិចរិយានុត្តរិយៈជាដើមឲ្យសម្រេច ឈ្មោះថា បរិភោគប្រើប្រាស់ព្រះ តថាគត ។ រតនៈដែលស្មើដោយព្រះតថាគត សូម្បីព្រោះអត្ថថា ជាគ្រឿង បរិភោគរបស់សត្វអ្នកមិនថោកទាប មិនមានឡើយ ដោយប្រការដូច្នេះ ។

ទ្រព្យជាគ្រឿងរីករាយចិត្តនោះណា ដោយមិនវិសេស ក៏ឈ្មោះថា

រតនៈ ព្រោះអត្ថថា ឲ្យកើតសេចក្ដីរីករាយ ទ្រព្យជាទីរីករាយនៃចិត្តនោះ គឺអ្វី គឺ ចក្ករតន៍របស់ស្ដេចចក្រពត្តិ ។ ពិតហើយ ស្ដេចចក្រពត្តិទ្រង់ឃើញចក្ករតន៍នោះហើយ ក៏ទ្រង់ពេញព្រះទ័យ ចក្ករតន៍នោះ នាំសេចក្ដីរីករាយមកឲ្យដល់ព្រះរាជា សូម្បីដោយប្រការដូច្នេះ ។

ម្យ៉ាងវិញទៀត ស្ដេចចក្រពត្តិ ទ្រង់ចាប់ព្រះសុវណ្ណភិង្ការ (កំសៀវមាស) ដោយព្រះហស្តឆ្វេង ទ្រង់ចាប់ចក្ករតន៍ដោយព្រះហស្តស្ដាំ ទ្រង់មានព្រះរាជឱង្ការថា ចក្ករតន៍ចូរវិលទៅ ចក្ករតន៍ចូរមានជ័យជម្នះ ។ តពីនោះ ចក្ករតន៍ក៏បញ្ចេញសំឡេងដ៏ពីរោះដូចតូរ្យតន្ត្រីប្រកបដោយអង្គ ៥ ឆ្ពោះទៅកាន់ទិសបូព៌ា ។ ស្ដេចចក្រពត្តិទ្រង់លើកចតុរង្គសេនា ប្រមាណ ១២ យោជន៍ ជាប់តាមទៅ ទ្រង់ទទួលគ្រឿងបណ្ណាការអំពីដៃពួកអ្នកកាន់គ្រឿងបណ្ណាការ មានផ្កាឈើ ផ្លែឈើ និងទំពាំងជាដើម ត្រង់ដើមឈើទាំងឡាយមិនខ្ពស់ពេក មិនទាបពេក អំពីចំណែកក្រោមនៃដើមឈើខ្ពស់ និងអំពីចំណែកខាងលើនៃដើមទាប ហើយនាំមកថ្វាយដោយអនុភាពរបស់ចក្ករតន៍ ទ្រង់អនុគ្រោះព្រះរាជាដែលធ្លាប់ជាបដិបក្ខ ដែលមកគាល់ដោយ

សេចក្តីគោរពជាដើម យ៉ាងនេះថា "សូមទ្រង់ស្តេចមកចុះ ព្រះមហារាជ" ដូច្នេះ ដោយន័យថា "មិនគួរសម្លាប់សត្វមានជីវិត" ដូច្នេះជាដើម ទើបស្តេចទៅ ។ ក៏ក្នុងទីណា ព្រះរាជាមានព្រះរាជបំណងនឹងសោយ ឬបំណងនឹងផ្ទុំពេលថ្ងៃ ក្នុងទីនោះ ចក្ករតន៍ក៏នឹងចុះពីអាកាសហើយឈប់ស្ងៀម ដូចបាក់ភ្ញៅ នៅត្រង់ផែនដីដែលរាបស្មើ សមគួរដល់កិច្ចគ្រប់យ៉ាង មានកិច្ចទាក់ទងនឹងទឹកជាដើម កាលព្រះរាជាកើតចិត្តគិតនឹងស្តេចទៅទៀត ចក្ករតន៍ក៏ធ្វើសំឡេងដោយន័យមុននោះឯង ទើបវិលទៅ ។ ចំណែកបរិស័ទ (ក្បួនទ័ព) ប្រមាណ ១២ យោជន៍ បានឮសំឡេងនោះ ក៏នាំគ្នាហោះទៅ ។ ចក្ករតន៍ចុះកាន់មហាសមុទ្រ នាទិសបូព៌ាដោយលំដាប់ កាលចក្ករតន៍នោះចុះកាន់សមុទ្រ ទឹកក៏ញែកទៅប្រមាណ ១ យោជន៍ នៅនឹងដូចធ្វើនូវភក្តីភាពចំពោះព្រះរាជា ។ មហាជនក៏កាន់យករតនៈទាំង ៧ តាមសេចក្តីត្រូវការ ។ ព្រះរាជាទ្រង់ចាប់សុវណ្ណភិង្ការទៀត ទ្រង់ប្រោះព្រំដោយទឹកថា រាជកិច្ចរបស់យើងដំណើរចាប់ផ្តើមអំពីនេះទៅ ដូច្នេះហើយ ស្តេចទើបត្រឡប់វិញ ។ កងទ័ពនៅខាងមុខ ចក្ករតន៍នៅខាងក្រោយ ព្រះរាជានៅ

ត្រង់កណ្ដាល ។ ទឹកក៏ពេញឡើងត្រង់ស្ថានទីដែលចក្ករតន៍ចេញទៅ ។ ចក្ករតន៍ក៏ទៅតាមសមុទ្រតាមទិសទក្សិណ ទិសបស្ចិម និងទិសឧត្តរ ដោយឧបាយនេះឯង ។

ចក្ករតន៍វិលទៅរហូត ៤ ទិស យ៉ាងនេះហើយ ក៏ឡើងកាន់អាកាសប្រមាណ ៣០០ យោជន៍ ។ ព្រះរាជាប្រថាប់ឈរលើចក្ករតន៍នោះ ទ្រង់យកជ័យជម្នះដោយអនុភាពចក្ករតន៍ ទ្រង់បានត្រួតត្រាមួយចក្រវាឡ ដែលប្រដាប់ដោយទ្វីបធំ ៤ ទ្វីប និងទ្វីបតូច ២.០០០ ដូចបឹងឈូកបុណ្ឌរិកដែលរីកហើយ យ៉ាងនេះគឺ បុព្វវិទេហទ្វីប ប្រដាប់ដោយទ្វីបតូច ៥០០ មានបរិមណ្ឌល ៧.០០០ យោជន៍ , ឧត្តរកុរុទ្វីប ក៏ដូចគ្នា មានបរិមណ្ឌល ៨.០០០ យោជន៍ , អបរគោយានទ្វីប មានបរិមណ្ឌល ៧.០០០ យោជន៍ ដូចគ្នា និងជម្ពូទ្វីប មានបរិមណ្ឌល ១.០០០ យោជន៍ ។ ស្ដេចចក្រពត្តិអង្គនោះទ្រង់កំពុងត្រួតមើលយ៉ាងនេះ ក៏ទ្រង់កើតសេចក្ដីត្រេកអរមិនមែនតិចឡើយ ចក្ករតន៍នោះ ឲ្យកើតសេចក្ដីរីករាយដល់ព្រះរាជា សូម្បីដោយប្រការដូច្នេះ ។ ចក្ករតន៍សូម្បីនោះ ដែលស្មើដោយព្រះពុទ្ធរតនៈ មិនមាន

ឡើយ ។ ឈ្មោះថា **រតនៈ** ព្រោះអត្ថថា ឲ្យកើតសេចក្ដីរីករាយ តែព្រះតថាគតប៉ុណ្ណោះ ឈ្មោះថា រតនៈ ចក្ករតន៍នឹងធ្វើអ្វីបាន ។

ពិតហើយ សេចក្ដីត្រេកអរក្នុងចក្រពត្តិ ដែលរតនៈសូម្បីគ្រប់យ៉ាងមានចក្ករតន៍ជាដើមឲ្យកើត ក៏មិនចូលដល់ការរាប់ខ្ទះ ចំរៀកខ្ទះ ចំណែកនៃចំរៀកខ្ទះ នៃសេចក្ដីត្រេកអរដែលជាទិព្វណា ព្រះតថាគតទ្រង់ធ្វើឲ្យកើតសេចក្ដីត្រេកអរក្នុងបឋមឈាន ទុតិយឈាន តតិយឈាន ចតុត្ថ-ឈាន និងបញ្ចមឈាន សេចក្ដីត្រេកអរក្នុងអាកាសានញ្ចាយតនឈាន វិញ្ញាណញ្ចាយតនឈាន អាកិញ្ចញ្ញាយតនឈាន និងនេវសញ្ញានាសញ្ញា-យតនឈាន សេចក្ដីត្រេកអរក្នុងសោតាបត្តិមគ្គ សោតាបត្តិផល សក-ទាគាមិមគ្គ សកទាគាមិផល អនាគាមិមគ្គ អនាគាមិផល អរហត្តមគ្គ និងអរហត្តផល ដល់ទេវតា និងមនុស្សទាំងឡាយ រាប់ចំនួនមិនបាន អ្នកទទួលឱវាទរបស់ព្រះអង្គ គឺ ក្រៃលែងជាង ប្រណីតជាង ក្នុងសេចក្ដីត្រេកអរសូម្បីនោះ ។ រតនៈស្មើដោយព្រះតថាគត សូម្បីព្រោះអត្ថថា ឲ្យកើតសេចក្ដីត្រេកអរ មិនមានដោយប្រការដូច្នេះ ។

មួយយ៉ាងទៀត ធម្មតារតនៈនេះមាន ២ យ៉ាង គឺ **សវិញ្ញាណករតនៈ** និង **អវិញ្ញាណករតនៈ** បណ្ដារតនៈទាំង ២ នោះ **អវិញ្ញាណករតនៈ** បាន ដល់ ចក្ករតន៍ និងមណីរតន៍ ឬក៏រតនៈសូម្បីដទៃណា មានមាស និងប្រាក់ ជាដើម ដែលជាប់ដោយអនិន្ទ្រិយ៍ ។ **សវិញ្ញាណករតនៈ** បានដល់ រតនៈ មានហត្ថិរតន៍ជាដើម មានបរិនាយករតន៍ជាទីបំផុត ឬក៏ថា រតនៈសូម្បី ដទៃណា ដែលជាប់ដោយឥន្ទ្រិយ៍ ។ ក្នុងរតនៈទាំង ២ យ៉ាង សវិញ្ញា-ណករតនៈ ពោលថា ប្រសើរជាង ក្នុងប្រការនេះ ។ ព្រោះហេតុអ្វី? ព្រោះហេតុថា រតនៈ មានមាស ប្រាក់ កែវមណី កែវមុក្តាជាដើម ត្រូវ នាំចូលទៅប្រើជាគ្រឿងប្រដាប់របស់ហត្ថីរតន៍ជាដើម ដែលជាសវិញ្ញាណ-ករតនៈនោះឯង ។

សូម្បីសវិញ្ញាណករតនៈ ក៏មាន ២ យ៉ាង គឺ រតនៈដែលជាសត្វ តិរច្ឆាន និងរតនៈដែលជាមនុស្ស ។ បណ្ដាសវិញ្ញាណករតនៈ ២ យ៉ាង នោះ រតនៈដែលជាមនុស្ស ប្រសើរជាង ។ ព្រោះហេតុអ្វី? ព្រោះថា រតនៈដែលសត្វតិរច្ឆាន រមែងជាពាហនៈរបស់រតនៈដែលជាមនុស្ស ។ សូម្បី

មនុស្សដែលជារតនៈ ក៏មាន ២ យ៉ាង គឺ ឥត្ថីរតនៈ និងបុរិសរតនៈ ។ បណ្តាមនុស្សរតនៈទាំង ២ នោះ បុរិសរតនៈ ពោលថា ប្រសើរជាង ។ ព្រោះហេតុអ្វី? ព្រោះហេតុថា ឥត្ថីរតនៈ ចូលដល់ភាពជាបរិចារិការបស់បុរិសរតនៈ ។ សូម្បីបុរិសរតនៈក៏មាន ២ គឺ **អគារិករតនៈ** និង **អនាគារិករតនៈ** ។ បណ្តាបុរិសរតនៈទាំង ២ នោះ ។ អនាគារិករតនៈ ពោលថា ប្រសើរជាង ។ ព្រោះហេតុអ្វី? ព្រោះហេតុថា ក្នុងអនាគារិករតនៈ សូម្បីស្តេចចក្រពត្តិដ៏ប្រសើរ ក៏នៅថ្វាយបង្គំអនាគារិករតនៈ អ្នកប្រកបដោយគុណ មានសីលជាដើម ដោយបញ្ចង្គប្រតិស្ឋាន ទំនុកបម្រុង អង្គុយជិត ប្រសព្វសម្បត្តិដែលជាទិព្វ និងមនុស្ស សម្រេចនិព្វានសម្បត្តិក្នុងទីបំផុត ។

សូម្បី **អនាគារិករតនៈ** ក៏មាន ២ យ៉ាង គឺ **អរិយរតនៈ** និង **បុថុជ្ជនរតនៈ** ។ សូម្បី **អរិយរតនៈ** ក៏មាន ២ យ៉ាង គឺ **សេក្ខរតនៈ** និង **អសេក្ខរតនៈ** ។ សូម្បី **អសេក្ខរតនៈ** ក៏មាន ២ យ៉ាង គឺ **សុក្ខវិបស្សករតនៈ** និង **សមថយានិករតនៈ** ។

*សូម្បី សមថយានិករតនៈ* ក៏មាន ២ យ៉ាង គឺ ដែលសម្រេចជាសាវកបារមី និងមិនសម្រេច ។

បណ្ដាសមថយានិករតនៈទាំង ២ នោះ សមថយានិករតនៈដែលសម្រេចសាវកបារមី ប្រសើរជាង ព្រោះហេតុអ្វី? ព្រោះហេតុថា មានគុណច្រើន ។ បច្ចេកពុទ្ធរតនៈ ពោលថា ប្រសើរជាង សូម្បីសាវកបារមីរតនៈ ។ ព្រោះហេតុអ្វី? ព្រោះហេតុថា មានគុណច្រើន ។ ព្រះសាវកច្រើនរយ សូម្បីព្រះសារីបុត្រ ព្រះមហាមោគ្គល្លាន ក៏មិនដល់ការរាប់ មិនដល់នូវចំរៀក មិនដល់ចំណែកនៃចំរៀក សូម្បីចំណែកនៃរយនូវគុណទាំងឡាយរបស់ព្រះបច្ចេកពុទ្ធមួយព្រះអង្គ ។

*សម្មាសម្ពុទ្ធរតនៈ* ពោលថា ប្រសើរជាង សូម្បីព្រះបច្ចេកពុទ្ធរតនៈ ព្រោះហេតុអ្វី? ព្រោះហេតុថា មានគុណច្រើន ។ ប្រសិនបើព្រះបច្ចេកពុទ្ធទាំងឡាយ គង់ប្រថាប់ពត់ភ្នែនទូទាំងជម្ពូទ្វីប ក៏មិនដល់ការរាប់ មិនដល់នូវចំរៀក មិនដល់ចំណែកនៃចំរៀកក្នុងព្រះគុណទាំងឡាយរបស់ព្រះសម្មាសម្ពុទ្ធមួយព្រះអង្គ ។ សមដូចដែលព្រះសម្មាសម្ពុទ្ធត្រាស់

ទុកដូច្នេះថា "ម្នាលភិក្ខុទាំងឡាយ សត្វទាំងឡាយមិនមានជើងក្តី ។ល។ ព្រះតថាគត អ្នកប្រាជ្ញបានពោលថា ប្រសើរជាងសត្វទាំងនោះជាដើម" ។ **រតនៈ** ដែលស្មើដោយព្រះតថាគត មិនមានឡើយ ដោយបរិយាយយ៉ាងនេះ ដោយប្រការដូច្នេះ ។ ព្រោះហេតុនោះ ព្រះមានព្រះភាគទើបត្រាស់ថា **ន នោ សមំ អត្ថិ តថាគតេន (រតនៈដែលស្មើដោយព្រះតថាគតមិនមានឡើយ)** ។

ព្រះមានព្រះភាគ លុះត្រាស់ភាពនៃព្រះពុទ្ធរតនៈ ដែលរតនៈដទៃៗប្រៀបស្មើមិនបានយ៉ាងនេះហើយ ឥឡូវនេះ ដើម្បីរម្ងាប់ឧបទ្រវៈ ដែលកើតដល់សត្វទាំងនោះ ទ្រង់មិនអាស្រ័យជាតិ ទ្រង់មិនអាស្រ័យគោត្រ ទ្រង់មិនអាស្រ័យភាពជាកុលបុត្រ ទ្រង់មិនអាស្រ័យភាពជាអ្នកមានវណ្ណៈស្អាតជាដើម តែទ្រង់អាស្រ័យភាពជាព្រះពុទ្ធរតនៈ ដែលមិនមានអ្វីប្រៀបស្មើបានដោយគុណទាំងឡាយ មានសីលក្ខន្ធ និងសមាធិក្ខន្ធជាដើម ក្នុងលោកមានអវិចីជាដើម មានភវគ្គព្រហ្មជាទីបំផុត ទើបទ្រង់ប្រកបសច្ចវចនៈថា **ឥទម្បិ ពុទ្ធេ រតនំ បណីតំ ឯតេន សច្ចេន សុវត្ថិ ហោតុ (រតនៈ**

គឺ ព្រះពុទ្ធនេះឯង ជារតនៈដ៏ឧត្តម ដោយពាក្យសច្ចៈនេះ សូមសិរីសួស្តីចូរមាន) ដូច្នេះ ។

សច្ចៈវាចានោះ មានសេចក្តីដូច្នេះថា ភាពនៃព្រះពុទ្ធមិនមាននរណាប្រៀបស្មើបាន ដោយគុណទាំងឡាយនោះៗ ជាមួយទ្រព្យជាគ្រឿងរីករាយចិត្ត ឬរតនៈគ្រប់យ៉ាងដែលមាននៅក្នុងលោកនេះ ឬលោកដទៃ ឬក្នុងសួគ៌ទាំងឡាយ សូម្បីនេះ ឈ្មោះថា ជារតនៈដ៏ប្រណីតក្នុងព្រះពុទ្ធ ។ ប្រសិនបើថា ប្រការនេះជាសច្ចៈ បើដូច្នេះ ដោយសច្ចៈនេះ សូមសិរីសួស្តីចូរមាន សូមវត្ថុដែលល្អស្អាតទាំងឡាយចូរមាន ការមិនមានរោគ ការប្រាសចាកឧបទ្រវៈ ចូរមានដល់សត្វទាំងនេះ ។ ក៏ក្នុងសេចក្តីនេះ គប្បីជ្រាបថា រតនៈដ៏ប្រណីត បានដល់ ភាពជារតនៈដ៏ប្រណីត គឺ ភាវៈនៃព្រះពុទ្ធជារតនៈដ៏ប្រណីត ដូចសេចក្តីថា ព្រោះជាខ្លួន ឬព្រោះជាប់ទាក់ទងជាមួយខ្លួននេះ ដូចក្នុងប្រយោគជាដើមថា ម្នាលអានន្ទ ចក្ខុនេះឯងសូន្យចាកខ្លួន ឬសូន្យចាកវត្ថុជារបស់ខ្លួន ។ ពិតហើយ ក្រៅពីនេះ ចក្ខុក៏ជាការបដិសេធមិនបានថាខ្លួន ឬចាកវត្ថុជារបស់ខ្លួន ដូច្នោះ ។ ដែលពិត ដោយ

ប្រការក្រៅពីនេះ ព្រះពុទ្ធក៏មិនគប្បីសម្រេចជារតនៈ ព្រោះថា រតនៈមិនមាននៅក្នុងវត្ថុណា វត្ថុនោះក៏រមែងមិនសម្រេចជារតនៈ ។ តែថា រតនៈដែលជាប់ពាក់ព័ន្ធដោយវិធីណាៗ ក៏ដោយ ដែលរាប់ថាជាប្រយោជន៍ មានបុគ្គលធ្វើសេចក្ដីគោរពកោតក្រែងជាដើម មាននៅក្នុងវត្ថុណា ព្រោះហេតុនៃវត្ថុនោះ លោកបំណាងយកជារតនៈ ទើបបញ្ញត្តិថា **រតនៈ** ដូច្នោះ ព្រះពុទ្ធទើបសម្រេចថា **រតនៈ** ព្រោះរតនៈនោះមានហើយ ។ ន័យម្យ៉ាងទៀត បទថា **ឥទម្បិ ពុទ្ធេ រតនំ បណីតំ** (**រតនៈ គឺ ព្រះពុទ្ធនេះឯង ជារតនៈដ៏ឧត្ដម**) គប្បីជ្រាបសេចក្ដីយ៉ាងនេះថា ព្រះពុទ្ធជារតនៈ ដោយប្រការដូច្នេះ ។ លុះព្រះមានព្រះភាគត្រាស់គាថានេះ សិរីសួស្ដីក៏កើតមានដល់រាជត្រកូល ភ័យក៏រម្ងាប់ទៅ ។ ពួកអមនុស្សក្នុងសែនកោដិចក្រវាឡ ក៏នាំគ្នាបង្អោនទទួលព្រះពុទ្ធអាជ្ញា នៃព្រះគាថានេះ ។

## ពណ៌នាគាថាថា ខយំ វិរាគំ

ព្រះមានព្រះភាគ កាលត្រាស់សច្ចវចនៈ ដោយពុទ្ធគុណយ៉ាងនេះហើយ ឥឡូវនេះ ទើបទ្រង់ផ្ដើមត្រាស់ថា **ខយំ វិរាគំ** (ព្រះសក្យមុនីមាន

ព្រះទ័យតម្កល់មាំ (ទ្រង់សម្រេចធម៌ណា) **ជាទីក្ស័យទៅនៃកិលេស ជាទីប្រាសចាករាគៈ** ជាដើម ដោយគុណ គឺ ព្រះនិព្វានធម៌ ។ ក្នុងបទនោះ ព្រោះកិលេសទាំងឡាយ មានរាគៈជាដើមអស់ទៅហើយ ឬអស់ទៅដោយជុំវិញហើយ ព្រោះធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វាន ឬព្រោះហេតុដែលព្រះនិព្វាននោះ ជាការរលត់ដែលមិនកើត និងការអស់ទៅនៃកិលេសទាំងឡាយមានរាគៈជាដើមទាំងនោះ ដោយការប្រសព្វ និងដោយអារម្មណ៍ ឬព្រោះហេតុដែលបុគ្គលធ្វើឲ្យជាក់ច្បាស់ព្រះនិព្វាននោះហើយ កិលេសទាំងឡាយមានរាគៈជាដើម ក៏ប្រាសចេញទៅ ប្រាសចាកទៅ ត្រូវកម្ចាត់ទៅ ដោយបរិបូណ៌ ដូច្នោះ ព្រះនិព្វាន លោកទើបហៅថា **ជាទីអស់កិលេស** ថា **ប្រាសចាករាគៈ** ។ តែព្រោះហេតុដែលព្រះនិព្វាននោះ ការកើតមិនប្រាកដ សេចក្តីវិនាសមិនប្រាកដ ភាពនៃចិត្តប្រែប្រួលមិនមាន ដូច្នោះ ព្រះនិព្វាននោះ លោកទើបវិគ្រោះថា មិនកើត មិនចាស់ មិនស្លាប់ ហៅថា **អមតៈ** ។ តែក្នុងទីនេះ លោកហៅថា **បណីត** ព្រោះអត្ថថា ខ្ពង់ខ្ពស់ និងព្រោះអត្ថថា មិនក្តៅក្រហាយ ។ បទថា **យទជ្ឈគា** (សម្រេច) បានដល់ ដល់

ប្រសព្វ បានធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វានណា ដោយកម្លាំងញាណរបស់ខ្លួន ។ បទថា **សក្យមុនី (ព្រះសក្យមុនី)** បានដល់ ឈ្មោះថា សក្យៈ ព្រោះទ្រង់ជាឱរសរបស់សក្យត្រកូល ឈ្មោះថា **មុនី** ព្រោះប្រកបដោយមោនេយ្យធម៌ មុនី គឺ សក្យៈ ឈ្មោះថា **ព្រះសក្យមុនី** ។ បទថា **សមាហិតោ (មានព្រះហឫទ័យតម្កល់មាំ)** បានដល់ អ្នកមានចិត្តតាំងមាំ ហើយដោយសមាធិជាអរិយមគ្គ ។ បទថា **ន តេន ធម្មេន សមត្ថិ កិញ្ចិ (វត្ថុណាៗ ដែលស្មើដោយព្រះធម៌នោះមិនមាន)** សេចក្តីថា ធម្មជាតិណាៗ ដែលស្មើដោយព្រះធម៌ ដែលព្រះសក្យមុនីទ្រង់សម្រេចហើយ មាននាមថា **ខយៈ (ជាទីអស់កិលេស)** ជាដើមនោះ មិនមាន ។ ព្រោះដូច្នោះ សូម្បីក្នុងព្រះសូត្រដទៃ ព្រះមានព្រះភាគក៏ត្រាស់ទុកជាដើមថា “ម្នាលភិក្ខុទាំងឡាយ ធម៌ទាំងឡាយ ទាំងជាសង្ខតៈ ទាំងជាអសង្ខតៈ មានប្រមាណប៉ុនណា វិរាគធម៌ អ្នកប្រាជ្ញពោលថា ជាកំពូលនៃធម៌ទាំងនោះ” ។

ព្រះមានព្រះភាគ កាលត្រាស់និព្វានធម៌ ដែលធម៌ដទៃៗ ប្រៀបស្មើមិនបានយ៉ាងនេះហើយ ឥឡូវនេះ ដើម្បីរម្ងាប់ឧបទ្រវៈដែលកើតដល់

សត្វទាំងនោះ ទ្រង់អាស្រ័យរតនៈ គឺ និព្វានធម៌ មិនមានធម៌ដទៃស្មើដូច ដោយគុណទាំងឡាយ គឺ ធម៌ជាទីអស់កិលេស ប្រាសចាកកិលេស ជាអមតធម៌ និងធម៌ដ៏ប្រណីត ទើបទ្រង់ប្រកបសច្ចវចនៈថា **សូម្បីនេះ ក៏ជារតនៈដ៏ប្រណីតក្នុងព្រះធម៌ ដោយពាក្យសច្ចៈនេះ សូមសិរីសួស្តីចូរកើតមាន)** ។ អត្ថនៃសច្ចវចនៈនោះ គប្បីជ្រាបតាមន័យដែលពោលមកហើយក្នុងគាថាខាងដើមនោះឯង ។ ពួកអមនុស្សក្នុងសែនកោដិចក្រវាឡ ក៏នាំគ្នាទទួលពុទ្ធអាជ្ញានៃព្រះគាថានេះឯង ។

## ពណ៌នាគាថាថា យម្ពុទ្ធសេដ្ឋោ

ព្រះមានព្រះភាគ លុះត្រាស់សច្ចវចនៈ ដោយគុណនៃនិព្វានធម៌យ៉ាងនេះហើយ ឥឡូវនេះ ទើបទ្រង់ផ្តើមត្រាស់ដោយគុណរបស់មគ្គធម៌ថា **យម្ពុទ្ធសេដ្ឋោ** (ព្រះពុទ្ធជាបុគ្គលប្រសើរបំផុត...ឯណា) ជាដើម ។ ក្នុងបទនោះ ឈ្មោះថា **ព្រះពុទ្ធ** ដោយន័យជាដើមថា ត្រាស់ដឹងសច្ចៈទាំងឡាយ ។ ឈ្មោះថា **ជាបុគ្គលប្រសើរបំផុត** ព្រោះជាអ្នកខ្ពស់បំផុត និងគួរសរសើរ ។ ឈ្មោះថា **ពុទ្ធសេដ្ឋៈ** ព្រោះជាអ្នកត្រាស់ដឹង ជាបុគ្គល

ខ្ពង់ខ្ពស់បំផុត និងគួរសរសើរ ។ ន័យម្យ៉ាងទៀត ឈ្មោះថា **ព្រះពុទ្ធជាបុគ្គលប្រសើរបំផុត** ព្រោះជាអ្នកប្រសើរបំផុត ក្នុងពុទ្ធៈទាំងឡាយដែលហៅថា អនុពុទ្ធៈ បច្ចេកពុទ្ធៈ និងសុតពុទ្ធៈ ។ ព្រះពុទ្ធជាបុគ្គលប្រសើរបំផុតអង្គនោះ ទ្រង់ប្រសើរ ទ្រង់សរសើរ ប្រកាសនូវសមាធិធម៌ណាទុកក្នុងបាលីនោះៗ ដោយន័យជាដើមថា បណ្ដាផ្លូវទាំងឡាយ មគ្គមានអង្គ ៨ ជាផ្លូវដ៏ក្សេមដើម្បីសម្រេចព្រះនិព្វាន និងថា ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសំដែងសមាធិដែលជាអរិយៈ ដែលមានហេតុ មានគ្រឿងប្រកបដល់អ្នកទាំងឡាយ ។ បទថា **សុចឹ (ស្អាត)** បានដល់ ស្អាតផូរផង់ដោយសព្វគ្រប់ ព្រោះធ្វើការកាត់មន្ទិល គឺ កិលេសបានជាសមុច្ឆេទ ។ បទថា **សមាធិមានន្តរិកញ្ញមាហុ (អ្នកប្រាជ្ញទាំងឡាយពោលសមាធិណាថា ឲ្យផលដោយលំដាប់)** សេចក្ដីថា បណ្ឌិតទាំងឡាយ ពោលនូវសមាធិណាថា អនន្តរិកសមាធិ (សមាធិកើតក្នុងលំដាប់) ព្រោះឲ្យផលពិតក្នុងលំដាប់ការបដិបត្តិរបស់ខ្លួន ។ អន្តរាយណាៗ ដែលរារាំងផលនៃអនន្តរិកសមាធិនោះ កាលសមាធិដែលជាតួមគ្គ កើតឡើងហើយ មិនមាន ។ ដូចដែលពោល

ទុកថា ៖

ក៏បុគ្គលនេះ គប្បីជាអ្នកបដិបត្តិដើម្បីធ្វើឲ្យជាក់ច្បាស់នូវសោតាបត្តិផល និងសូម្បីជាវេលាដែលកប្បឆេះ កប្បក៏មិនគប្បីឆេះ ដរាបណាបុគ្គលនេះនៅមាន នៅមិនទាន់ធ្វើឲ្យជាក់ច្បាស់សោតាបត្តិផល បុគ្គលនេះហៅថា ឋិតកប្បី (អ្នកមានកប្បតាំងនៅ) ។ បុគ្គលដែលដល់ព្រមដោយមគ្គទាំងអស់ ក៏ជាឋិតកប្បី ។

បទថា សមាធិនា តេន សមោ ន វិជ្ជតិ សេចក្ដីថា រូបាវចរសមាធិ ឬអរូបាវចរសមាធិណាៗ ដែលស្មើដោយអនន្តរិកសមាធិដ៏ស្អាតដែលព្រះពុទ្ធជាបុគ្គលប្រសើរបំផុត សរសើរហើយនោះៗ មិនមានឡើយ ។ ព្រោះហេតុអ្វី? ព្រោះសត្វសូម្បីកើតក្នុងព្រហ្មលោកនោះៗ ព្រោះអប់រំសមាធិទាំងនោះហើយ ក៏នៅមានការកើតក្នុងអបាយភូមិ មាននរកជាដើមទៀតបាន និងព្រោះព្រះអរិយបុគ្គលលះបង់ការកើតគ្រប់យ៉ាងដាច់ជាសមុច្ឆេទ ព្រោះអប់រំសមាធិដែលជាគូព្រះអរហត្តនេះឯង ។ ព្រោះដូច្នោះ សូម្បីក្នុង

សូត្រដទៃ ព្រះមានព្រះភាគក៏ត្រាស់ទុកថា ៖

ម្នាលភិក្ខុទាំងឡាយ ធម៌ទាំងឡាយដែលសង្ខតៈ (ដែលបច្ច័យតាក់តែង) មានប្រមាណត្រឹមណា អរិយមគ្គមានអង្គ ៨ អ្នកប្រាជ្ញពោលថា ជាកំពូលនៃសង្ខតធម៌ទាំងនោះ ។

ព្រះមានព្រះភាគ កាលត្រាស់អនន្តរិកសមាធិ ដែលសមាធិដទៃៗប្រៀបស្មើមិនបានយ៉ាងនេះហើយ ឥឡូវនេះ ទ្រង់អាស្រ័យរតនៈ គឺ មគ្គធម៌ដែលរតនៈដទៃប្រៀបស្មើមិនបាន ដោយន័យមុននោះឯង ទើបទ្រង់ប្រកបសច្ចវចនៈថា សូម្បីនេះ ក៏ជារតនៈដ៏ប្រណីតក្នុងព្រះធម៌ ដោយពាក្យសច្ចៈនេះ សូមសិរីសួស្តីចូរកើតមាន ។ អត្ថនៃសច្ចវចនៈនោះ គប្បីជ្រាបដោយន័យដែលពោលមកហើយនោះឯង ។ ពួកអមនុស្សក្នុងសែនកោដិចក្រវាឡនាំគ្នាទទួលពុទ្ធអាជ្ញានៃព្រះគាថានេះឯង ។

## ពណ៌នាគាថាថា យេ បុគ្គលា

ព្រះមានព្រះភាគ លុះត្រាស់សច្ចវចនៈ សូម្បីដោយគុណនៃមគ្គធម៌

យ៉ាងនេះហើយ ឥឡូវនេះ ទើបទ្រង់ផ្ដើមត្រាស់សូម្បីដោយសង្ឃគុណថា **យេ បុគ្គលា** (បុគ្គលពួកណា) ជាដើម ។ ក្នុងបទនោះ ពាក្យថា **យេ** (ពួកណា) ជានិទ្ទេសមិនពិតប្រាកដ ។ បទថា **បុគ្គលា** (បុគ្គល) បានដល់សត្វទាំងឡាយ ។ ស័ព្ទថា **អដ្ឋ** (៨) ជាការកំណត់ចំនួនសត្វទាំងនោះ ។ ពិតហើយ សត្វទាំងនោះ មាន ៨ គឺ អ្នកបដិបត្តិ (មគ្គ) ៤ អ្នកតាំងនៅក្នុងផល ៤ ។ បទថា **សតំ បសដ្ឋា** (ដែលសប្បុរសទាំងឡាយសរសើរហើយ) បានដល់ ដែលសប្បុរស គឺ ព្រះពុទ្ធ ព្រះបច្ចេកពុទ្ធ ព្រះសាវក ទេវតា និងមនុស្សពួកដទៃសរសើរហើយ ។ ព្រោះហេតុអ្វី? ព្រោះប្រកបដោយគុណ មានសីលដែលកើតរួមគ្នាជាដើម ។ ពិតណាស់ គុណទាំងឡាយរបស់សប្បុរសទាំងនោះ មានសីល និងសមាធិជាដើមកើតរួមគ្នា ដូចពណ៌ និងក្លិនជាដើម ដែលកើតរួមគ្នារបស់ផ្កាចំប៉ា និងផ្កាពិកុលជាដើម ។ ព្រោះហេតុនោះ បុគ្គលទាំងនោះ ទើបជាទីស្រឡាញ់ ជាទីពេញចិត្ត គួរសរសើររបស់សប្បុរសទាំងឡាយ ដូចផ្កាឈើទាំងឡាយ ដែលព្រមដោយពណ៌ និងក្លិនជាដើម ជាទីស្រឡាញ់ ជាទីពេញចិត្ត គួរសរសើរ របស់

ទេវតា និងមនុស្សទាំងឡាយ ។ ព្រោះហេតុនោះ ព្រះមានព្រះភាគទើបត្រាស់ថា **យេ បុគ្គលា អដ្ឋ សតំ បសដ្ឋា** (បុគ្គលពួកណា ៨ ជំពូក... ដែលសប្បុរសទាំងឡាយសរសើរហើយ) ។

ន័យម្យ៉ាងទៀត បទថា **យេ** (ណា) ជានិទ្ទេសមិនប្រាកដ ។ បទថា **បុគ្គលា** (បុគ្គល) បានដល់ សត្វទាំងឡាយ ។ ពាក្យថា **អដ្ឋសតំ** (១០៨) ជាការកំណត់ចំនួនសត្វទាំងនោះ ។ ពិតហើយ សត្វទាំងនោះបានដល់ ព្រះសោតាបន្ន ៣ ពួក គឺ ឯកពិជី កោលំកោលៈ និងសត្តក្ខត្តុបរមៈ ។ ព្រះសកទាគាមី ៣ ពួក ដែលសម្រេចផលក្នុងកាមភព រូបភព និងអរូបភព ។ ព្រះសោតាបន្ន និងព្រះសកទាគាមីទាំងអស់នោះមាន ២៤ ពួក ដោយបដិបទា ៤ ។ ព្រះអនាគាមីក្នុងទេវតាជាន់អវិហាមាន ៥ ពួក គឺ អន្តរាបរិនិព្វាយី ឧបហច្ចបរិនិព្វាយី សសង្ខារបរិនិព្វាយី អសង្ខារបរិនិព្វាយី ឧទ្ធំសោតោអកនិដ្ឋគាមិ ។ ព្រះអនាគាមីក្នុងទេវតាជាន់អតប្បា សុទស្សា សុទស្សី ក៏មានជាន់នីមួយៗ ៥ ពួកដូចគ្នា ។ ចំណែកក្នុងទេវតាជាន់អកនិដ្ឋ មាន ៤ ពួក វៀរឧទ្ធំសោតោអកនិដ្ឋគាមី រួមព្រះ

អនាគាមីមាន ២៤ ពួក ។ ព្រះអរហន្ត មាន ២ ពួក គឺ សុក្ខវិបស្សក: និងសមថយានិក: ។ ព្រះអរិយបុគ្គលអ្នកតាំងនៅក្នុងមគ្គ មាន ៤ ពួក រួមជាព្រះអរិយបុគ្គល ៥៤ ពួក ។ ព្រះអរិយបុគ្គលទាំងអស់នោះ គុណដោយ ២ ពួក គឺ ចំណែកសទ្ធាធុរ: និងចំណែកបញ្ញាធុរ: រួមជា ១០៨ ពួក ។ បទដ៏សេស មានន័យដូចពោលមកហើយនោះឯង ។

បទថា **ចត្តារិ ឯតានិ យុគានិ ហោន្តិ** (៤ គូ) សេចក្តីថា បុគ្គលដែលទ្រង់លើកឡើងកាន់ឧទ្ទេសទុកដោយពិស្តារថា ព្រះអរិយបុគ្គលទាំងអស់នោះ មាន ៨ ពួកក្តី ១០៨ ពួកក្តី ពោលដោយសង្ខេប អ្នកតាំងនៅក្នុងសោតាបត្តិមគ្គ អ្នកតាំងនៅក្នុងសោតាបត្តិផល រួមជា ១ គូ ។ យ៉ាងនេះ រហូតដល់ភិក្ខុតាំងនៅក្នុងអរហត្តមគ្គ ភិក្ខុតាំងនៅក្នុងអរហត្តផល រួមជាគូ ១ រួមទាំងអស់ជា ៤ គូ ។ បទថា **តេ** (ទាំងនោះ) ក្នុងបទថា **តេ ទក្ខិណេយ្យា** (បុគ្គលទាំងនោះ... គួរដល់ទក្ខិណាទាន) ជាសព្វនិទ្ទេស អធិប្បាយកំណត់ពិតប្រាកដ ចំពោះបទឧទ្ទេសដែលលើកឡើងតាំងទុកមិនពិតប្រាកដក្នុងកាលមុន ។ បុគ្គលដែលព្រះមានព្រះភាគត្រាស់ទុក ដោយ

ពិស្ដារថា មាន ៨ ពួក ឬ ១០៨ ពួក ដោយសង្ខេបថា មាន ៤ គូ សូម្បីទាំងអស់ រមែងគួរដល់ទក្ខិណា ព្រោះហេតុនោះ ទើបឈ្មោះថា ទក្ខិ-ណេយ្យ: ។ ទេយ្យធម៌ ដែលបុគ្គលជឿកម្ម និងផលនៃកម្ម មិនមានការនឹកថា ភិក្ខុរូបនេះនឹងធ្វើកិច្ចកម្មជាទេព្យ ឬទូតកម្ម ដូច្នេះជាដើម ហើយប្រគេន ឈ្មោះថា **ទក្ខិណា** ។ បុគ្គលដែលប្រកបដោយគុណ មានសីលជាដើម និងបុគ្គលទាំងនេះ ឈ្មោះថា រមែងគួរដល់ទក្ខិណានោះ ព្រោះហេតុនោះ ព្រះមានព្រះភាគទើបត្រាស់ថា **តេ ទក្ខិណេយ្យា** (បុគ្គលទាំងនោះ... គួរដល់ទក្ខិណាទាន) ។

បទថា **សុគតស្ស សាវកា** (ជាសាវករបស់ព្រះសុគត) សេចក្ដីថា ព្រះមានព្រះភាគ ឈ្មោះថា **ព្រះសុគត** ព្រោះទ្រង់ប្រកបដោយការយាងទៅស្អាត ព្រោះស្ដេចយាងទៅកាន់ស្ថានទីដ៏ស្អាត ព្រោះស្ដេចយាងទៅដោយល្អ និងព្រោះត្រាស់ល្អ ។ ជាសាវករបស់ព្រះសុគតអង្គនោះ ។ លោកទាំងអស់នោះ ឈ្មោះថា **សាវក** ព្រោះស្ដាប់តម្រាស់ ។ បុគ្គលដទៃ ៗ សូម្បីស្ដាប់ក៏ពិត តែគេស្ដាប់ហើយ ក៏មិនធ្វើកិច្ចដែលគួរធ្វើ ។

ចំណែកព្រះសាវកទាំងនេះ ស្តាប់ហើយ ធ្វើកិច្ចដែលគួរធ្វើ គឺ បដិបត្តិធម៌ សមគួរដល់ធម៌ សម្រេចមគ្គផល ព្រោះដូច្នោះ លោកទាំងនេះ ទើបត្រាស់ហៅថា សាវក ។

បទថា ឯតេសុ ទិន្នានិ មហប្ផលានិ (ទានទាំងឡាយដែលគេថ្វាយក្នុងបុគ្គលទាំងនោះ រមែងមានផលច្រើន) សេចក្តីថា ទានទាំងឡាយសូម្បីតិចតួច ដែលថ្វាយក្នុងសាវករបស់ព្រះតថាគតទាំងនោះ ឈ្មោះថា មានផលច្រើន ព្រោះជាទានដែលចូលដល់ភាពជាទក្ខិណាបរិសុទ្ធិចំណែកខាងបដិគ្គាហកៈ ។ ព្រោះដូច្នោះ ព្រះមានព្រះភាគទើបត្រាស់ទុក សូម្បីក្នុងសូត្រដទៃថា ៖

ម្នាលភិក្ខុទាំងឡាយ សង្ឃទាំងឡាយក្តី គណៈទាំងឡាយក្តី មានប្រមាណត្រឹមណា សង្ឃសាវករបស់តថាគត អ្នកប្រាជ្ញពោលថា ជាកំពូលនៃសង្ឃ និងគណៈទាំងនោះ គឺនរណា គឺ គូនៃបុរស ៤ បុរសបុគ្គល ៨ នេះ ជាសង្ឃរបស់សាវករបស់ព្រះដ៏មានព្រះភាគ ។បេ។ ក៏រមែងបាន

ផលដ៏ប្រសើរ ។

ព្រះមានព្រះភាគ លុះត្រាស់គុណរបស់សង្ឃរតនៈដែលជាអ្នកតាំងនៅក្នុងមគ្គ និងជាអ្នកដែលតាំងនៅក្នុងផលយ៉ាងនេះហើយ ឥឡូវនេះ ទ្រង់អាស្រ័យគុណនោះឯង ទើបទ្រង់ប្រកបសច្ចវចនៈថា **សូម្បីនេះក៏ជារតនៈដ៏ប្រណីតក្នុងព្រះសង្ឃ** ។ អត្ថនៃសច្ចវចនៈនោះ ក៏គប្បីជ្រាបតាមន័យដែលពោលហើយនោះឯង ។ ពួកអមនុស្សក្នុងសែនកោដិចក្រវាល បាននាំគ្នាទទួលពុទ្ធអាជ្ញានៃព្រះគាថាសូម្បីនេះ ។

## ពណ៌នាគាថាថា យេ សុប្បយុត្តា

ព្រះមានព្រះភាគ គ្រាត្រាស់សច្ចវចនៈដោយគុណរបស់សង្ឃរតនៈដោយកិច្ចអ្នកតាំងនៅក្នុងមគ្គ និងផល យ៉ាងនេះហើយ ឥឡូវនេះ ទើបផ្តើមត្រាស់ដោយគុណរបស់ព្រះខីណាសវបុគ្គលទាំងឡាយ អ្នកសោយសុខក្នុងផលសមាបត្តិពួកខ្លះ តពីបទមុននោះថា **យេ សុប្បយុត្តា** (ព្រះអរិយ-បុគ្គលពួកណា ក្នុងសាសនារបស់ព្រះពុទ្ធគោតម) ប្រកបល្អហើយ ជាដើម ។ ក្នុងបទនោះ បទថា **យេ** (ពួកណា) ជាបទឧទ្ទេសដែលមិនប្រាកដ ។ បទ

ថា *សុប្បយុត្តា* ប្រែថា ប្រកបល្អហើយ អធិប្បាយថា លះអនេសនៈ (ការស្វែងរកដែលមិនសមគួរ) ទាំងឡាយចេញហើយ អាស្រ័យការចិញ្ចឹមជីវិតដ៏បរិសុទ្ធ ផ្ដើមប្រកបខ្លួនទុកក្នុងវិបស្សនា ។ ន័យម្យ៉ាងទៀត បទថា **សុប្បយុត្តា (ប្រកបល្អហើយ)** បានដល់ ប្រកបដោយកាយបយោគ និងវិចីបយោគដ៏បរិសុទ្ធល្អ ។ ទ្រង់សំដែងសីលក្ខន្ធរបស់ព្រះខីណាសវបុគ្គលទាំងនោះ ដោយពាក្យថា **ប្រកបល្អហើយ** នោះ ។ បទថា **មនសា ទឡ្ហេន (មានចិត្តតម្កល់មាំ)** បានដល់ មានចិត្តដ៏ធ្ងន់ ។ អធិប្បាយថា ដោយចិត្តដែលប្រកបដោយសមាធិដែលតាំងមាំ ។ ទ្រង់សំដែងសមាធិខន្ធរបស់ព្រះខីណាសវបុគ្គលទាំងនោះ ដោយពាក្យថា **មានចិត្តតាំងមាំ** នោះ ។ បទថា **និក្កាមិនោ (មិនមានសេចក្តីអាល័យ)** បានដល់ ជាអ្នកមិនអាល័យក្នុងកាយ និងជីវិត មានសេចក្តីព្យាយាមចេញចាកកិលេសទាំងពួង ជាបុគ្គលអ្នកមានបញ្ញាជាធុរៈធ្វើហើយដោយសេចក្តីព្យាយាម ។ ទ្រង់សំដែងបញ្ញាក្ខន្ធដែលប្រកបដោយសេចក្តីព្យាយាម របស់ព្រះខីណាសវបុគ្គលនោះ ដោយពាក្យថា **មិនមានសេចក្តីអាល័យ** នោះ ។

បទថា **គោតមសាសនម្ហិ (ក្នុងសាសនារបស់ព្រះពុទ្ធគោតម)** បានដល់ ក្នុងសាសនារបស់ព្រះតថាគត ដែលមានព្រះនាមថា គោតម ដោយព្រះគោត្រនោះឯង ។ ដោយពាក្យថា **ក្នុងសាសនារបស់ព្រះពុទ្ធគោតម** នោះ ទ្រង់សំដែងថា ពួកអ្នកក្រៅសាសនានេះ អ្នកធ្វើតបៈដើម្បីទេវតា ដោយប្រការផ្សេងៗ ក៏មិនមានសេចក្តីព្យាយាមចេញចាកកិលេសទាំងឡាយ ព្រោះមិនមានគុណ មានការប្រកបយ៉ាងល្អជាដើម ។ បទថា **តេ (ទាំងនោះ)** ជាពាក្យអធិប្បាយឧទ្ទេសដែលតាំងទុកមុន ។ ក្នុងបទថា **បត្តិបត្តា (សម្រេចព្រះអរហត្តដែលគួរសម្រេច)** នេះ គុណគួរសម្រេច ហេតុនោះទើបឈ្មោះថា **បត្តិ (គុណដែលគួរសម្រេច)** ដែលបុគ្គលសម្រេចព្រះអរហត្ត ដែលគួរសម្រេចហើយ និងជាបុគ្គលក្សេមចាកយោគៈដោយសព្វគ្រប់ ឈ្មោះថា **សម្រេចព្រះអរហត្តដែលគួរសម្រេច)** ។ ពាក្យនេះ ជាឈ្មោះរបស់ព្រះអរហត្តផល ។ អ្នកសម្រេចគុណ (អរហត្ត) ដែលគួរសម្រេចនោះ ហេតុនោះ ទើបឈ្មោះថា **បត្តិបត្តា** ។ បទថា **អមតំ** បានដល់ ព្រះនិព្វាន ។ បទថា **វិគយ្ហ (ចូលដល់)** បានដល់ ចូលដល់ដោយអារម្មណ៍ ។ បទថា

**លទ្ធា** ប្រែថា បានហើយ ។ បទថា **មុធា (ទទេ)** បានដល់ ដោយមិនមានតម្លៃ គឺ សូម្បីធ្វើតម្លៃត្រឹមតែមួយកាកណិក ។ បទថា **និព្វុតឹ (ការរលត់កិលេស)** បានដល់ ផលសមាបត្តិ ដែលរម្ងាប់សេចក្តីក្រវល់ក្រវាយដោយអំណាចលះកិលេសចេញហើយ ។ បទថា **ភុញ្ជមានា** ប្រែថា សោយហើយ ។ លោកអធិប្បាយទុកយ៉ាងណា? លោកអធិប្បាយថា ជនពួកណា ក្នុងសាសនារបស់ព្រះគោតមនេះ ឈ្មោះថា ប្រកបល្អហើយ ព្រោះដល់ព្រមដោយសីល ឈ្មោះថា មានចិត្តធ្ងន់ (តាំងមាំ) ព្រោះដល់ព្រមដោយសមាធិ ឈ្មោះថា គ្មានសេចក្តីអាល័យ ព្រោះដល់ព្រមដោយបញ្ញា ជនទាំងនោះ ក៏ចូលដល់អមតៈដោយសម្មាបដិបទានេះ ជាអ្នកបានទទេៗ សោយការរលត់ ដែលបានឈ្មោះថា ផលសមាបត្តិ ឈ្មោះថា ជាអ្នកបានសម្រេចគុណដែលគួរសម្រេច ។

ព្រះមានព្រះភាគ កាលត្រាស់គុណរបស់សង្ឃរតនៈ ដោយអំណាចព្រះខីណាសវបុគ្គលអ្នកសោយសុខ ដែលកើតពីផលសមាបត្តិយ៉ាងនេះហើយ ឥឡូវនេះ ទ្រង់អាស្រ័យគុណនោះឯង ទើបទ្រង់ប្រកបសច្ចវចនៈថា **សូម្បី**

នេះ ក៏ជារតនៈដ៏ប្រណីតក្នុងព្រះសង្ឃ ។ អត្ថនៃសច្ចវចនៈនោះ គប្បីជ្រាប តាមន័យពោលមកហើយនោះឯង ។ ពួកអមនុស្សក្នុងសែនកោដិចក្រវាល ក៏នាំគ្នាទទួលពុទ្ធអាជ្ញានៃព្រះគាថាសូម្បីនេះឯង ។

## ពណ៌នាគាថាថា យថិន្ទខីលោ

ព្រះមានព្រះភាគ កាលត្រាស់សច្ចវចនៈ មានសង្ឃរតនៈជាទីតាំង ដោយគុណនៃខីណាសវបុគ្គលយ៉ាងនេះហើយ ឥឡូវនេះ ទ្រង់ផ្តើមត្រាស់ ដោយគុណរបស់ព្រះសោតាបន្ន ដែលប្រច័ក្សដល់បុគ្គលដ៏ច្រើនទាំងនោះថា **យថិន្ទខីលោ (សសរខឿន... យ៉ាងណា)** ជាដើម ។ ក្នុងបទនោះ បទថា **យថា (យ៉ាងណា)** ជាពាក្យឧបមា ។ បទថា **ឥន្ទខីលោ (សសរខឿន)** នេះ ជាឈ្មោះរបស់សសរឈើខ្លឹមដែលគេកប់ក្នុងដី ៨ ហត្ថ ឬ ១០ ហត្ថ ខាងក្នុងធរណីទ្វារ ដើម្បីការពារទ្វារព្រះនគរ ។ បទថា **បឋវឹ** ប្រែថា ផែនដី ។ បទថា **សិតោ** បានដល់ ចូលទៅកប់ខាងក្នុង ។ បទថា **សិយា** ប្រែថា គប្បីជា ។ បទថា **ចតុព្ភិ វាតេហិ (ដោយខ្យល់ ៤ ទិស)** បាន ដល់ ដោយខ្យល់ដែលបក់មកពី ៤ ទិស ។ បទថា **អសម្បកម្បិយោ (មិន

ញាប់ញ័រ) បានដល់ មិនអាចឲ្យញ័រ ឬកម្រើកបាន ។ បទថា **តថូបមំ** (ឧបមាក៏ដូច្នោះ) បានដល់ ដូចយ៉ាងនោះ ។ បទថា **សប្បុរិសំ** (សប្បុរស) បានដល់ បុរសខ្ពង់ខ្ពស់ ។ បទថា **វទាមិ** ប្រែថា ពោល ។ បទថា **យោ អរិយសច្ចានិ អវេច្ច បស្សតិ** (បុគ្គលណាឃើញអរិយសច្ចៈទាំងឡាយ) បានដល់ បុគ្គលណាឃើញអរិយសច្ចៈ ៤ ដោយបញ្ញា ។ ក្នុងបទនោះ អរិយសច្ចៈទាំងឡាយ គប្បីជ្រាបតាមន័យដែលពោលទុកហើយក្នុងកុមារ-បញ្ហា និងគម្ពីរវិសុទ្ធិមគ្គនោះឯង ។

ចំណែកសេចក្តីសង្ខេបក្នុងប្រការនេះ មានដូច្នេះ ឧបមាដូចសសរខឿនដែលកប់ជាប់ដី ព្រោះមានឫសជ្រៅ ក៏មិនគប្បីញាប់ញ័រដោយខ្យល់ទាំង ៤ ទិស យ៉ាងណា សប្បុរសណាឃើញអរិយសច្ចៈ តថាគតហៅសប្បុរសសូម្បីនេះ ក៏ដូចឧបមានោះដូចគ្នា ។ ព្រោះហេតុអ្វី? ព្រោះថា សប្បុរសសូម្បីនោះ ជាអ្នកមិនញាប់ញ័រដោយខ្យល់ គឺ វាទៈរបស់តិរ្ថិយទាំងពួង គឺ នរណាៗ ក៏មិនអាចឲ្យញ័រ ឬកម្រើកចាកទស្សនៈនោះបាន ដូចសសរខឿនមិនញាប់ញ័រដោយខ្យល់បក់មកអំពីទិសទាំង ៤ ដូច្នោះ ។

ព្រោះដូច្នោះ ព្រះមានព្រះភាគទើបត្រាស់ទុកសូម្បីក្នុងសូត្រដទៃថា ៖

ម្នាលភិក្ខុទាំងឡាយ សសរដែក ឬសសរខឿនបោះជ្រៅ ត្រូវកប់យ៉ាងល្អ មិនញាប់ញ័រ សូម្បីខ្យល់ភ្លៀងខ្លាំងបក់មកអំពីទិសបូព៌ា ។ ក៏មិនធ្វើសសរនោះឲ្យញាប់ញ័រ មិនគប្បីធ្វើសសរនោះឲ្យរង្គើ មិនគប្បីធ្វើសសរនោះឲ្យកម្រើក សូម្បីខ្យល់ភ្លៀងខ្លាំងបក់មកអំពីទិសបច្ឆិម ។ ទិសទក្សិណ ទិសឧត្តរ ក៏មិនគប្បីធ្វើសសរនោះឲ្យញាប់ញ័រ មិនគប្បីធ្វើសសរនោះឲ្យរង្គើ មិនគប្បីធ្វើសសរនោះឲ្យកម្រើកបាន ។ ព្រោះហេតុអ្វី ព្រោះកប់ចុះជ្រៅ ព្រោះសសរខឿនគេកប់ទុកល្អហើយ យ៉ាងណា ។ ម្នាលភិក្ខុទាំងឡាយ សមណៈ ឬព្រាហ្មណ៍ពួកណាមួយ រមែងដឹងតាមសេចក្តីពិតថា នេះទុក្ខ ។ល។ នេះទុក្ខនិរោធគាមិនីបដិបទា សមណៈ ឬព្រាហ្មណ៍ពួកនោះ រមែងមិនសម្លឹងមើល (អជ្ឈាស្រ័យ) របស់សមណៈ ឬព្រាហ្មណ៍ដទៃថា បុគ្គលនេះ កាលដឹង កាលឃើញ ក៏

*ឃើញយ៉ាងនេះពិត សេចក្តីនោះមានព្រោះហេតុណា ម្នាល ភិក្ខុទាំងឡាយ ក៏ព្រោះអរិយសច្ច ៤ សមណៈ ឬព្រាហ្មណ៍ នោះឃើញល្អហើយ ក៏ដូច្នោះដូចគ្នា ។*

*ព្រះមានព្រះភាគ កាលត្រាស់គុណរបស់សង្ឃរតនៈដោយអំណាច ព្រះសោតបន្ន ដែលប្រចក្សដល់បុគ្គលជាច្រើនយ៉ាងនេះហើយ ឥឡូវនេះ ទ្រង់អាស្រ័យគុណនោះឯង ទើបទ្រង់ប្រកបសច្ចវចនៈថា **សូម្បីនេះ ក៏ជារតនៈដ៏ប្រណីតក្នុងព្រះសង្ឃ** ។ អត្ថរបស់សច្ចវចនៈនោះ គប្បីជ្រាបតាមន័យដែលពោលមកហើយនោះឯង ។ ពួកអមនុស្សក្នុងសែនកោដិចក្រវាល ក៏នាំគ្នាទទួលពុទ្ធអាជ្ញានៃព្រះគាថាសូម្បីនេះ ។*

## ពណ៌នាគាថាថា យេ អរិយសច្ចានិ

*ព្រះមានព្រះភាគ គ្រាត្រាស់សច្ចវចនៈ ដែលមានសង្ឃរតនៈជាទីតាំងដោយគុណរបស់ព្រះសេតាបន្ន ដោយមិនប្លែកគ្នាយ៉ាងនេះហើយ ឥឡូវនេះ ទើបទ្រង់ផ្តើមត្រាស់ថា **យេ អរិយសច្ចានិ** (ព្រះសោតាបន្នពួកណាធ្វើឲ្យជាក់ច្បាស់អរិយសច្ចៈ) ជាដើម ដោយគុណរបស់ព្រះសោតាបន្នដែល*

ជាសត្តក្ខត្តុបរមៈ អ្នកទាបបំផុតរបស់ព្រះសោតាបន្នទាំងអស់ ក្នុងបណ្ដា ព្រះសោតាបន្ន ៣ ប្រភេទ គឺ ឯកពិជី កោលំកោលៈ សត្តក្ខត្តុបរមៈ ដូចដែលត្រាស់ទុកថា ៖

បុគ្គលខ្លះក្នុងព្រះសាសនានេះ រមែងឈ្មោះថាសោតាបន្ន ព្រោះអស់សំយោជនៈ ៣ សោតាបន្ននោះ កើតឡើងក្នុង ភពមួយប៉ុណ្ណោះ ក៏ធ្វើទីបំផុតទុក្ខ នេះឈ្មោះថា ឯកពិជី សោតាបន្នអន្ទោល ២ ឬ ៣ ត្រកូល ក៏ដូចគ្នា រមែងធ្វើ ទីបំផុតទុក្ខបាន នេះឈ្មោះថា កោលំកោលៈ សោតាបន្ន នៅវិលវល់កើតស្លាប់នៅក្នុងទេវតា និងមនុស្ស ៧ ជង ក៏ដូចគ្នា រមែងធ្វើទីបំផុតទុក្ខបាន នេះឈ្មោះថា សត្តក្ខត្តុ-បរមៈ ។

ក្នុងបទនោះ បទថា យេ អរិយសច្ចានិ (ព្រះសោតាបន្នពួកណា ...អរិយសច្ច) នេះ មានន័យដូចដែលពោលមកហើយនោះឯង ។ បទថា វិភាវយន្តិ (ធ្វើឲ្យជាក់ច្បាស់) បានដល់ កម្ចាត់សេចក្ដីងងឹត គឺ កិលេស

ដែលបិទបាំងសច្ចៈហើយ ធ្វើឲ្យជាក់ច្បាស់ប្រាកដដល់ខ្លួន ដោយពន្លឺនៃបញ្ញា ។ បទថា **គម្ភីរបញ្ញេន** (ដែលព្រះសាស្តាអ្នកមានបញ្ញាជ្រាលជ្រៅ) បានដល់ ព្រះមានព្រះភាគ ទ្រង់មានបញ្ញាដ៏ធំ ដែលនរណាៗ សូម្បីក្នុងលោកនេះ ព្រមទាំងទេវលោកបាននូវបញ្ញា ដែលជាព្រះបញ្ញារកប្រមាណមិនបាន លោកអធិប្បាយថា ទ្រង់ជាសព្វញ្ញូ ។

បទថា **សុទេសិតានិ** (ទ្រង់សំដែងល្អហើយ) បានដល់ ទ្រង់សំដែងដោយល្អ ដោយន័យនោះៗ មានសមាសន័យ (សង្ខេប) ព្យាសន័យ (ពិស្តារ) សាកលយន័យ (សេចក្តីទាំងអស់) វេកលយន័យ (សេចក្តីចំណែកខ្លះ) ជាដើម ។ បទថា **កិញ្ចាបិ តេ ហោន្តិ កុសប្បមត្តា** (**សូម្បីថា ព្រះសោ-តាបន្នពួកនោះ និងជាអ្នកប្រមាទយ៉ាងខ្លាំងក្លា**) សេចក្តីថា បុគ្គលទាំងឡាយដែលអប់រំអរិយសច្ចហើយនោះ អាស្រ័យឋានៈនៃសេចក្តីប្រមាទ មានភាពជាទេវរាជ និងជាស្តេចចក្រពត្តិជាដើម ជាអ្នកប្រមាទខ្លាំងក្លាក៏ពិត តែនាមនិងរូបណាគប្បីតាំងនៅ ព្រោះវិញ្ញាណដែលសោតាបត្តិមគ្គញ្ញាណតាក់តែងរលត់ទៅហើយ កើតក្នុងសង្សារវដ្តដែលមានខាងដើមខាងចុងមិនដឹងហើយ

ដល់ ៧ ភព ក៏មិនកាន់យកភពជាទី ៨ ព្រោះនាម និងរូបនោះរលត់ទៅ ព្រោះតាំងនៅមិនបាន តែក្នុងភពទី ៧ នោះឯង ក៏នឹងផ្តើមវិបស្សនា ហើយសម្រេចព្រះអរហត្ត ។

ព្រះមានព្រះភាគ ត្រាត្រាស់គុណរបស់សង្ឃរតនៈ ដោយអំណាចព្រះសោតាបន្នសត្តក្ខត្តុបរមៈ យ៉ាងនេះហើយ ឥឡូវនេះ ទ្រង់អាស្រ័យគុណនោះឯង ទ្រង់ប្រកបសច្ចវចនៈថា **សូម្បីនេះ ក៏ជារតនៈដ៏ប្រណីតក្នុងព្រះសង្ឃ** ។ អត្ថនៃសច្ចវចនៈនោះ គប្បីជ្រាបតាមន័យដែលពោលមកហើយអំពីមុននោះឯង ។ ពួកអមនុស្សក្នុងសែនកោដិចក្រវាល ក៏នាំគ្នាទទួលពុទ្ធអាជ្ញានៃព្រះគាថានេះឯង ។

## ពណ៌នាគាថាថា សហាវស្ស

ព្រះមានព្រះភាគ កាលត្រាស់សច្ចវចនៈ មានសង្ឃរតនៈជាទីតាំងដោយគុណ គឺ ការមិនកាន់យកភពទី ៨ របស់ព្រះសោតាបន្នជាសត្តក្ខត្តុបរមៈយ៉ាងនេះហើយ ឥឡូវនេះ ទើបផ្តើមត្រាស់ថា **សហាវស្ស** (ព្រមជាមួយ... របស់ព្រះសោតាបន្ននោះ) ជាដើម ដោយគុណរបស់ព្រះសោ-

តាបន្នជាសត្តក្ខត្តុបរមៈនោះឯង សូម្បីទឹងនៅកាន់ភព ៧ ទៀត ដែលផ្សេង ពីបុគ្គលដទៃៗ ដែលនៅលះការកាន់យកភពមិនបាន ។ ក្នុងបទនោះ បទថា **សហាវ** ប្រែថា ព្រមជាមួយ... តែម្យ៉ាង ។ បទថា **អស្ស** (នោះ) បានដល់ របស់ព្រះសោតាបន្នពួកណាមួយ ដែលត្រាស់ថា ព្រះសោតាបន្ន ពួកនោះ មិនកាន់យកភពទី ៨ ។ បទថា **ទស្សនសម្បទាយ** (ដោយ **ទស្សនសម្បទា**) បានដល់ ដោយការដល់ព្រមនៃសោតាបត្តិមគ្គ ។ ពិត ហើយ សោតាបត្តិមគ្គឃើញព្រះនិព្វានហើយ លោកទើបហៅថា **ទស្សនៈ** ព្រោះឃើញព្រះនិព្វានមុនធម៌ទាំងពួង ដោយការដល់ព្រមនៃកិច្ចដែលគួរ ធ្វើ ។ ការប្រាកដនៃសោតាបត្តិមគ្គនោះនៅក្នុងខ្លួន ឈ្មោះថា **ទស្សន-សម្បទា** ។ ព្រមដោយទស្សនសម្បទានោះឯង ។ ស័ព្ទថា **សុ** ក្នុងបទថា **តយស្សុ ធម្មា ជហិតា ភវន្តិ** នេះ ជានិបាត ចុះក្នុងអត្ថត្រឹមតែធ្វើបទឲ្យ ពេញ ដូចក្នុងប្រយោគជាដើមថា **ឥទំ សុ មេ សារីបុត្ត មហាវិកដ្ឋភោ-ជនស្មឹ ហោតិ** សារីបុត្រនេះឯង មានវត្តក្នុងការឆាន់អាហារបែបមហាវិកដ្ឋ របស់តថាគត ។ ក្នុងសេចក្ដីនេះ មានអត្ថយ៉ាងនេះថា ព្រោះហេតុថា ធម៌

៣ (សំយោជនៈខាងក្រោម ៣) ដែលសោតាបន្នលះបានហើយ ជាការលះហើយ ព្រមដោយទស្សនសម្បទារបស់ព្រះសោតាបន្ននោះ ។

ឥឡូវនេះ ដើម្បីទ្រង់សំដែងធម៌ដែលព្រះសោតាបន្នលះបានហើយ ទើបត្រាស់ថា **សក្កាយទិដ្ឋិ វិចិកិច្ឆិតញ្ច សីលព្វតំ វាបិ យទត្ថិ កិញ្ចិ (សក្កាយទិដ្ឋិ វិចិកិច្ឆា សីលព្វតបរាមាស ណាមួយមានហើយ)** ក្នុងធម៌ ៣ យ៉ាងនោះ កាលកាយនៅមាន ទិដ្ឋិមានវត្ថុ ២០ ក្នុងកាយ ដែលហៅថា ឧបាទានក្ខន្ធ ៥ ដែលមាន ឈ្មោះថា **សក្កាយទិដ្ឋិ** ។ ឬថា កាលកាយនៅមាន ទិដ្ឋិ (ការឃើញ) ក្នុងកាយនោះ សូម្បីព្រោះហេតុនោះ ឈ្មោះថា **សក្កាយទិដ្ឋិ** អធិប្បាយថា ទិដ្ឋិដែលមាននៅក្នុងកាយ តាមដែលបានពោលហើយ ។ ឬទិដ្ឋិ (ការឃើញ) ក្នុងកាយដែលមាននោះឯង សូម្បីព្រោះហេតុនោះ ឈ្មោះថា **សក្កាយទិដ្ឋិ** អធិប្បាយថា ទិដ្ឋិក្នុងកាយតាមដែលពោលមក ដែលមានហើយ ដែលប្រព្រឹត្តទៅយ៉ាងនេះថា អត្តា ពោលគឺរូបជាដើម ។ ទិដ្ឋិទាំងពួង ព្រះសោតាបន្នលះបង់ហើយ ព្រោះលះសក្កាយ-ទិដ្ឋិនោះបានហើយ ។ ព្រោះថា សក្កាយទិដ្ឋិនោះជាឫសគល់របស់ធម៌ គឺ

កិលេសនោះឯង ។ បញ្ញា លោកហៅថា ចិកិច្ឆតៈ ព្រោះរម្ងាប់ព្យាធិ គឺកិលេសទាំងពួង ។ បញ្ញាចិកិច្ឆិតៈ (បញ្ញាកែខ្វែ) នោះ ទៅប្រាសហើយចាកវត្ថុនេះ ឬវត្ថុនេះទៅប្រាសហើយចាកបញ្ញាចិកិច្ឆិតៈនោះ ហេតុនោះទើបឈ្មោះថា វិចិកិច្ឆិតៈ ។ ពាក្យនេះ ជាឈ្មោះរបស់សេចក្ដីសង្ស័យដែលមានវត្ថុ ៨ ដែលទ្រង់ត្រាស់ទុកដោយន័យជាដើមថា សង្ស័យក្នុងព្រះសាស្ដា ។ សេចក្ដីសង្ស័យសូម្បីទាំងអស់ ជាការលះបានហើយ ក៏ព្រោះលះវិចិកិច្ឆានោះបានហើយ ។ ពិតហើយ សេចក្ដីសង្ស័យនោះជាឫសគល់របស់កិលេសទាំងនោះ ។ សីលច្រើនយ៉ាង មានគោសីល (សីលគោ) កុក្កុរវត្ត (សីលសុនខ) ជាដើម និងវត្ត មានគោវត្ត និងកុក្កុរវត្តជាដើមដែលមានក្នុងបាលីប្រទេសជាដើមយ៉ាងនេះថា សមណព្រាហ្មណ៍ខាងក្រៅព្រះសាសនានេះ កាន់យកសេចក្ដីបរិសុទ្ធដោយសីល បរិសុទ្ធិដោយវត្តហៅថា សីលវត្ត ។ តបៈដើម្បីទេវតា មានការអាក្រាតកាយ និងការមានសីសៈត្រងោលជាដើម សូម្បីគ្រប់យ៉ាង ជាការលះបានហើយ ក៏ព្រោះលះសីលវត្តនោះ ។ ពិតហើយ សីលវត្តនោះ ជាឫសគល់របស់តបៈនោះ

ព្រោះហេតុនោះឯង ព្រះមានព្រះភាគ ទើបត្រាស់ទុកចុងគាថាទាំងអស់ថា **យទត្ថិ កិញ្ចិ (ណាមួយមានហើយ)** គប្បីជ្រាបថា បណ្តាសំយោជនៈខាងក្រោម ៣ នោះ សក្កាយទិដ្ឋិ នឹងលះបានក៏ដោយការដល់ព្រមដោយការឃើញទុក្ខ វិចិកិច្ឆា នឹងលះបានក៏ព្រោះដល់ព្រមដោយការឃើញសមុទ័យ សីលព្វតៈ (បរាមាស) នឹងលះបានក៏ព្រោះដល់ព្រមដោយការឃើញមគ្គ និងការឃើញព្រះនិព្វាន ។

## ពណ៌នាគាថាថា ចតូហាបាយេហិ

ព្រះមានព្រះភាគ កាលទ្រង់សំដែងការលះកិលេសវដ្តរបស់ព្រះសោ-តាបន្ននោះយ៉ាងនេះហើយ ឥឡូវនេះ កាលកិលេសវដ្តៈនោះមាន វិបាកវដ្តៈណាគប្បីមាន កាលទ្រង់សំដែងការលះវិបាកវដ្តៈសូម្បីនោះ ព្រោះលះកិលេស-វដ្តៈនោះបាន ទើបត្រាស់ថា **ចតូហបាយេហិ ច វិប្បយុត្តោ (ព្រះសោតាបន្នជាអ្នករួចផុតហើយចាកអបាយទាំង ៤)** ក្នុងពាក្យនោះ ឈ្មោះថា អបាយមាន ៤ គឺ និរយៈ តិរច្ឆាន ប្រេតវិស័យ និងអសុរកាយ អធិប្បាយថា ព្រះសោតាបន្ន សូម្បីនៅកាន់ ៧ ភព ក៏រួចផុតចាកអបាយទាំង ៤ នោះ ។

ព្រះមានព្រះភាគ កាលទ្រង់សំដែងការលះវិបាកវដ្តៈរបស់ព្រះសោ-
តាបន្ននោះយ៉ាងនេះហើយ ឥឡូវនេះ កម្មវដ្តៈណា ជាឫសគល់របស់វិបាក-
វដ្តៈនេះ កាលទ្រង់សំដែងការលះកម្មវដ្តៈសូម្បីនោះ ទើបត្រាស់ថា **ឆ
ចាភិឋានានិ អភព្វោ កាតុំ (មិនអាចនឹងធ្វើអភិដ្ឋាន ៦)** ។ ក្នុងបទនោះ
បទថា **អភិដ្ឋានានិ (អភិដ្ឋាន)** បានដល់ ឋានៈដែលគ្រោតគ្រាត ។ ព្រះ
សោតាបន្ននោះ ប្រព្រឹត្តទៅមិនបាន គឺ មិនធ្វើអភិដ្ឋាន ៦ នោះ ។ ក៏
អភិដ្ឋានទាំងនោះ គប្បីជ្រាបថា កម្ម គឺ មាតុឃាត (សម្លាប់មាតា) បិតុ-
ឃាត (សម្លាប់បិតា) អរហន្តឃាត (សម្លាប់ព្រះអរហន្ត) លោហិតុប្បាទ
(ធ្វើលោហិតរបស់ព្រះពុទ្ធឲ្យពុះពងឡើង) សង្ឃភេទ (ធ្វើសង្ឃឲ្យបែកគ្នា)
អញ្ញសត្ថារុទ្ទេស (រាប់អានសាសនាដទៃ គឺ ចូល) ដែលព្រះមានព្រះភាគ
ត្រាស់ទុកក្នុងឯកនិបាត អង្គុត្តរនិកាយ ដោយន័យជាដើមថា "ម្នាលភិក្ខុ
ទាំងឡាយ បុគ្គលអ្នកដល់ព្រមដោយទិដ្ឋិ (សម្មាទិដ្ឋិ) នឹងគប្បីផ្តាច់ជីវិត
របស់មាតា នោះមិនមែនជាឋានៈ មិនមែនជាឱកាស ដែលនឹងគប្បីមាន ។
ពិតហើយ អរិយសាវកអ្នកដល់ព្រមដោយទិដ្ឋិ មិនគប្បីផ្តាច់បង់ជីវិតសូម្បី

ស្រមោចខ្មៅស្រមោចក្រហមក៏ពិត សូម្បីយ៉ាងនោះ អភិដ្ឋាន ៦ នោះ ព្រះមានព្រះភាគត្រាស់ទុក ក៏ដើម្បីតិះដៀលភាវៈនៃបុថុជ្ជន ។ ពិតហើយ បុថុជ្ជនរមែងធ្វើសូម្បីអភិដ្ឋាន ដែលមានទោសច្រើនយ៉ាងនេះបាន ក៏ព្រោះមិនដល់ព្រមដោយទិដ្ឋិ ចំណែកព្រះសោតាបន្នអ្នកដល់ព្រមដោយទិដ្ឋិ មិនគួរនឹងធ្វើអភិដ្ឋានទាំងនោះ ។ ចំណែកការប្រើ អភព្វសព្ទ ក្នុងទីនេះ ក៏ដើម្បីសំដែងថា ព្រះសោតាបន្នមិនធ្វើ (អភិដ្ឋាន ៦) សូម្បីក្នុងភពដទៃ ។ សេចក្តីពិត សូម្បីក្នុងភពដទៃ ព្រះសោតាបន្នមិនដឹងថា ខ្លួនជាអរិយសាវក ដោយធម្មតានោះឯង ក៏មិនធ្វើបាប ៦ យ៉ាងនោះ ឬធ្វើពៀរ ៥ យ៉ាង មានបាណាតិបាតជាដើម ឬដល់ឋានៈ ៦ ព្រមទាំងការកាន់យកសាសនាដទៃ អាចារ្យពួកខ្លះសំដៅយក ហើយពោលថា **អភិដ្ឋាន ៦** ដូច្នេះក៏មាន ។ ក៏ក្នុងរឿងនេះ មានព្រះអរិយសាវក និងក្មេងអ្នកស្រុកដែលចាប់ត្រីងាប់ជាដើម ជាឧបមា ។

ព្រះមានព្រះភាគ កាលត្រាស់គុណរបស់អរិយសាវកសូម្បីនៅកាន់យកភព ៧ ជាសង្ឃរតនៈ ដោយគុណដែលប្លែកពីបុគ្គលដទៃៗ ដែលនៅ

មិនទាន់លះបង់ភពបានយ៉ាងនេះហើយ ឥឡូវនេះ ទ្រង់អាស្រ័យគុណនោះឯង ទើបទ្រង់ប្រកបសច្ចវចនៈថា សូម្បីនោះ ក៏ជារតនៈដ៏ប្រណីតក្នុងសង្ឃរតនៈ ។ អត្ថនៃសច្ចវចនៈនោះ គប្បីជ្រាបដោយន័យដូចពោលហើយនោះឯង ។ ពួកអមនុស្សក្នុងសែនកោដិចក្រវាល ក៏នាំគ្នាទទួលពុទ្ធអាជ្ញានៃព្រះគាថានេះឯង ។

## ពណ៌នាគាថាថា កិញ្ចាបិ សោ

ព្រះមានព្រះភាគ គ្រាត្រាស់សច្ចវចនៈ មានសង្ឃរតនៈជាទីតាំងដោយគុណរបស់ព្រះសោតាបន្ន សូម្បីនៅកាន់យក ៧ ភព ដែលពិសេសជាងពួកបុគ្គលដទៃ ដែលនៅលះការកាន់យកភពមិនបាន យ៉ាងនេះហើយ ឥឡូវនេះ ព្រះសោតាបន្នអ្នកដល់ព្រមដោយទស្សនៈ មិនមែនមិនធ្វើអភិដ្ឋាន ៦ តែម្យ៉ាងក៏ទេ ទាំងមិនធ្វើបាបកម្មសូម្បីតិចតួចអ្វីៗ ហើយបិទបាំងបាបកម្មនោះផង ដូច្នោះ ទើបទ្រង់ផ្ដើមត្រាស់ដោយគុណព្រះសោតាបន្នអ្នកដល់ព្រមដោយទស្សនៈ សូម្បីនៅមានសេចក្ដីប្រមាទ ក៏មិនមានការបិទបាំងកម្មដែលធ្វើមកហើយថា **កិញ្ចាបិ សោ កម្មំ ករោតិ បាបកំ** (សូម្បី

ថា ព្រះសោតាបន្នទោះនៅធ្វើបាបកម្ម) ។

ព្រះតម្រាស់នោះមានសេចក្តីដូច្នេះ សូម្បីថា ព្រះសោតាបន្ននោះ ដល់ព្រមដោយទស្សនៈ នៅមានការប្រមាទដោយភ្លេចសតិ វៀរសិក្ខាបទ ដែលជាលោកវជ្ជៈ ដែលព្រះមានព្រះភាគទ្រង់សំដៅដល់ការគិតកន្លងល្មើស ក៏ត្រាស់ទុកថា សិក្ខាបទណា តថាគតបញ្ញត្តិដល់សាវកទាំងឡាយ រមែង មិនកន្លងល្មើសសិក្ខាបទនោះរបស់តថាគត សូម្បីព្រោះហេតុនៃជីវិត ដូច្នេះ រមែងធ្វើបាបកម្មយ៉ាងដទៃតាមផ្លូវកាយ ដែលព្រះពុទ្ធទ្រង់វៀស ពោល គឺ ការកន្លងល្មើសសិក្ខាបទដែលបណ្ណត្តិវជ្ជៈ មានកុដិការសិក្ខាបទ និង សហសេយ្យសិក្ខាបទជាដើមក្តី ធ្វើបាបកម្មផ្លូវវាចា មានបង្រៀនធម៌ដល់ អនុបសម្បន្ន ថាព្រមគ្នា សំដែងធម៌ដល់មាតុគ្រាមលើសពី ៥-៦ ពាក្យ ការនិយាយរាយរាយ និយាយពាក្យគ្រោតគ្រាតជាដើមក្តី ធ្វើបាបកម្មផ្លូវ ចិត្ត មិនថាក្នុងទីណាៗ គឺ ការធ្វើឲ្យកើតលោភៈ ទោសៈ ការត្រេកអរ ក្នុងមាសជាដើម ការមិនពិចារណាជាដើម ក្នុងការបរិភោគចីវរជាអាទិ៍ក្តី ព្រះសោតាបន្ននោះ ក៏មិនអាចបិទបាំងបាបកម្មនោះ គឺ ព្រះសោតាបន្ននោះ

ដឹងថា កម្មនេះមិនគួរ មិនគួរធ្វើ ក៏មិនបិទបាំងបាបកម្មនោះ សូម្បីតែមួយ ជង ក្នុងពេលភ្លាមៗ នោះឯង ក៏ធ្វើឲ្យប្រាកដ (បើកចំហរ) ក្នុងព្រះសាស្តា ឬក្នុងសព្រហ្មចារីដែលជាវិញ្ញូជន រមែងទទួល ឬរវាំងប្រការដែលគួររវាំង យ៉ាងនេះថា "ខ្ញុំនឹងមិនធ្វើទៀត" ។ ព្រោះហេតុអ្វី? ព្រោះថា ព្រះមាន-ព្រះភាគត្រាស់ដល់ព្រះសោតបន្ន ដែលឃើញបទ គឺ ព្រះនិព្វានហើយ មិនអាចបិទបាំងបាបកម្ម អធិប្បាយថា ព្រះមានព្រះភាគត្រាស់ដល់បុគ្គលដែលឃើញបទ គឺ ព្រះនិព្វាន អ្នកដល់ព្រមដោយទស្សនៈ មិនអាចធ្វើបាបកម្ម សូម្បីបែបនោះ ហើយបិទបាំងបាបកម្មនោះទុក ។ ត្រាស់ទុកយ៉ាងណា? ត្រាស់ទុកថា ៖

> ម្នាលភិក្ខុទាំងឡាយ កុមារតូចនៅខ្ចីដេកផ្ងារ យកដៃជើង
> ប៉ះលើរងើកភ្លើង រមែងដកត្រឡប់យ៉ាងលឿន យ៉ាងណា
> ម្នាលភិក្ខុទាំងឡាយ សូម្បីថា ព្រះសោតាបន្នត្រូវអាបត្តិ
> បែបនោះ ការចេញចាកអាបត្តិបែបនោះ រមែងប្រាកដ ។
> ក្នុងទីនោះឯង ព្រះសោតាបន្នរមែងប្រញាប់សំដែង បើក

ចំហរ ធ្វើឲ្យងាយ ក្នុងព្រះសាស្ដា ឬក្នុងមិត្រព្រហ្មចារី ដែលជាវិញ្ញូជន កាលសំដែងចេញហើយក៏សង្រួមរវាំងតទៅ នេះជាធម្មតារបស់បុគ្គលដែលដល់ព្រមដោយទិដ្ឋិ ក៏ដូច្នោះដូចគ្នា ។

ព្រះមានព្រះភាគ លុះទ្រង់ត្រាស់គុណរបស់សង្ឃរតនៈដោយគុណរបស់ព្រះសោតាបន្ន សូម្បីនៅដោយសេចក្ដីប្រមាទ តែក៏ដល់ព្រមដោយទស្សនៈ មិនមានការបិទបាំងបាបកម្មដែលធ្វើហើយ យ៉ាងនេះហើយ ឥឡូវនេះ ទ្រង់អាស្រ័យគុណនេះឯង ទើបទ្រង់ប្រកបសច្ចវចនៈថា **សូម្បីនេះក៏ជារតនៈដ៏ប្រណីតក្នុងសង្ឃ** ។ សេចក្ដីរបស់សច្ចវចនៈនោះ គប្បីជ្រាបតាមន័យដែលពោលហើយនោះឯង ។ ពួកអមនុស្សក្នុងសែនកោដិចក្រវាល ក៏នាំគ្នាទទួលពុទ្ធអាជ្ញានៃព្រះគាថានេះឯង ។

## ពណ៌នាគាថាថា វនប្បគុម្ពេ

ព្រះមានព្រះភាគ កាលត្រាស់សច្ចវចនៈ មានសង្ឃរតនៈជាទីតាំងដោយប្រការនៃគុណនោះ ៗ របស់បុគ្គលទាំងឡាយ ដែលទាក់ទងនៅក្នុង

ព្រះសង្ឃ យ៉ាងនេះហើយ ឥឡូវនេះ ទ្រង់អាស្រ័យព្រះបរិយត្តិធម៌ ដែល ព្រះមានព្រះភាគកាលទ្រង់សំដែងគុណព្រះរតនត្រ័យ ក៏ទ្រង់សំដែងយ៉ាង សង្ខេបក្នុងទីនេះ និងទ្រង់សំដែងទុកពិស្តារក្នុងទីដទៃ ទើបទ្រង់ផ្តើមសច្ច-វចនៈ មានព្រះពុទ្ធរតនៈជាទីតាំងទៀតថា **វនប្បគុម្ពេ យថា ផុស្សិតគ្គេ** **(គុម្ពឈើក្នុងព្រៃ ខាងចុងមានផ្ការីកស្រស់ល្អ)** ។ ក្នុងសច្ចវចនៈនោះ ពួក ដើមឈើដែលកំណត់ដោយទីកន្លែងដែលនៅប្រចាំក្នុងទីជិត ឈ្មោះថា **ព្រៃ** ។ គុម្ពឈើដែលលូតលាស់ដោយឫស ខ្លឹម មែក និងស្លឹក ឈ្មោះថា **គុម្ព** **ឈើ** ។ គុម្ពឈើដែលរីកលូតលាស់ល្អនៃព្រៃ ឬក្នុងព្រៃ ឈ្មោះថា **គុម្ព** **ឈើក្នុងព្រៃ** ។ គុម្ពឈើដែលរីកលូតលាស់ក្នុងព្រៃនោះ លោកហៅថា **វនប្បគុម្ពេ** ដូច្នោះ ក៏ហៅបានថា ដូចក្នុងប្រយោគជាដើមថា **អត្ថិ សវិ-** **តក្កសវិចារេ , អត្ថិ អវិតក្កវិចារមត្តេ , សុខេ ទុក្ខេ ជីវេ** ។ មានវិតក្កៈ មានវិចារៈក៏មាន មិនមានវិតក្កៈមានវិចារៈក៏មាន ។ សុខ ទុក្ខ ជីវៈ (ជាទី ៧) ។ បទថា **យថា (យ៉ាងណា)** ជាពាក្យឧបមា ។ ចុងនៃគុម្ព ឈើនោះរីកហើយ ហេតុនោះ គុម្ពឈើនោះឈ្មោះថា **មានចុងរីកហើយ** ។

អធិប្បាយថា ផ្កាឈើដែលកើតឯង ត្រង់មែកធំតូចគ្រប់មែក ។ ផ្កាឈើនោះ លោកពោលថា "មានចុងដែលរីកហើយ" តាមន័យដែលពោលមកពីមុននោះឯង ។ បទថា **គិម្ហានមាសេ បឋមស្មឹ គិម្ហេ (ក្នុងខាងដើមខែគិម្ហៈ នៃរដូវគិម្ហន្តៈ)** សេចក្តីថា ក្នុងខែមួយនៃខែក្នុងគិម្ហហន្តរដូវ ៤ ខែ ។ បើនឹងសួរថា ក្នុងខែណា? ឆ្លើយថា ក្នុងគិម្ហន្តរដូវ ដើមខែ ។ អធិប្បាយថា ក្នុងខែចិត្រមាស (ខែ ៥) ។ ពិតហើយ ខែចិត្រមាសនោះ លោកហៅថា ដើមខែនៃគិម្ហន្តរដូវ និងថា វស្សានរដូវ ។ ពាក្យក្រៅពីនោះ ប្រាកដជាក់ច្បាស់ដោយអត្ថនៃបទទាំងនោះហើយ ។

ចំណែកសេចក្តីរួមក្នុងពាក្យនេះមានដូច្នេះថា គុម្ពឈើដែលរីកលូតលាស់ល្អ មានឈ្មោះហៅថា គុម្ពឈើជំទង់ ចុងមែកមានផ្ការីកពាសពេញរមែងល្អស្អាតក្រៃលែង ក្នុងព្រៃ ត្រង់ដងព្រៃដោយដើមឈើច្រើនប្រភេទ ក្នុងវស្សន្តរដូវៗ ដែលមានឈ្មោះថា ខាងដើមខែនៃគិម្ហន្តរដូវ យ៉ាងណា ព្រះមានព្រះភាគ មិនមែនទ្រង់សំដែងព្រោះឃើញដល់លាភ មិនមែនទ្រង់សំដែងព្រោះឃើញដល់សក្ការៈជាដើម តែមានព្រះហឫទ័យមហាករុណា ឲ្យ

ទ្រង់វិតទំតែម្យ៉ាង ទ្រង់បានសំដែងព្រះបរិយត្តិធម៌ដ៏ប្រសើរ ដែលឈ្មោះ ថា មានឧបមាដូច្នោះ ព្រោះល្អយ៉ាងក្រៃលែងដោយផ្កាឈើ គឺ ប្រភេទនៃអត្ថច្រើនប្រការ មានខន្ធ អាយតនៈជាដើមក៏មាន មានសតិប្បដ្ឋាន និងសម្មប្បធានជាដើមក៏មាន មានសីលក្ខន្ធ សមាធិខន្ធជាដើមក៏មាន ឈ្មោះថា ឲ្យដល់ព្រះនិព្វាន ព្រោះសំដែងមគ្គដែលឲ្យដល់ព្រះនិព្វាន ដើម្បីជាប្រយោជន៍ក្រៃលែងដល់សត្វទាំងឡាយ ដូច្នោះដូចគ្នា ។ ចំណែកក្នុងបទថា **បរមំ ហិតាយ** **(ដើម្បីប្រយោជន៍ក្រៃលែង)** នេះ លោកចុះនិគ្គហិតក៏ដើម្បីស្រួលដល់ការចងគាថា ។ ចំណែកអត្ថមានដូច្នេះថា ទ្រង់បានសំដែងដើម្បីប្រយោជន៍ក្រៃលែង គឺ ដើម្បីព្រះនិព្វាន ។

ព្រះមានព្រះភាគ កាលត្រាស់ព្រះបរិយត្តិដែលដូចគុម្ពឈើល្អក្នុងព្រៃ ដែលចុងខែមកចេញផ្ការីកពាសពេញយ៉ាងនេះហើយ ឥឡូវនេះ ទ្រង់អាស្រ័យព្រះបរិយត្តិធម៌នោះឯង ទើបទ្រង់ប្រកបសច្ចវចនៈ ដែលមានពុទ្ធរតនៈជាទីតាំងថា **សូម្បីនេះ ក៏ជារតនៈដ៏ប្រណីតក្នុងព្រះពុទ្ធ** ។ សេចក្តីនៃសច្ចវចនៈនោះ គប្បីជ្រាបតាមន័យដែលពោលមកហើយនោះឯង ។ តែ

គប្បីប្រកបសេចក្តីតែមួយ យ៉ាងនេះថា គុណជាត ពោលគឺ ព្រះបរិយត្តិ-ធម៌ មានប្រការតាមដែលពោលមកហើយសូម្បីនេះ ក៏ជារតនៈដ៏ប្រណីតក្នុងព្រះពុទ្ធ ។ ពួកអមនុស្សក្នុងសែនកោដិចក្រវាល ក៏នាំគ្នាទទួលអាជ្ញានៃព្រះគាថានេះឯង ។

## ពណ៌នាគាថាថា វរោ វរញ្ញូ

ព្រះមានព្រះភាគ លុះត្រាស់សច្ចវចនៈ ដែលមានពុទ្ធរតនៈជាទីតាំងដោយបរិយត្តិធម៌យ៉ាងនេះហើយ ឥឡូវនេះ ទើបទ្រង់ផ្តើមត្រាស់ដោយលោកុត្តរធម៌ថា *វរោ វរញ្ញូ* (ព្រះពុទ្ធដ៏ប្រសើរ ទ្រង់ដឹងធម៌ដ៏ប្រសើរ) ក្នុងបទនោះ បទថា *វរោ* (ដ៏ប្រសើរ) សេចក្តីថា ព្រះពុទ្ធ ដែលបុគ្គលអ្នកមានអធ្យាស្រ័យបង្អោនចិត្តទៅដ៏ប្រណីតប្រាថ្នាថា ឱហ្ន៎ សូម្បីយើងក៏នឹងជាដូច្នេះ ឬព្រះពុទ្ធដ៏ប្រសើរ ខ្ពង់ខ្ពស់ ប្រសើរបំផុត ព្រោះប្រកបដោយគុណដ៏ប្រសើរ ។ បទថា *វរញ្ញូ* (ទ្រង់ដឹងធម៌ដ៏ប្រសើរ) បានដល់ទ្រង់ដឹងព្រះនិព្វាន ។ ពិតហើយ ព្រះនិព្វាន ឈ្មោះថា ប្រសើរ ព្រោះអត្ថថា ខ្ពង់ខ្ពស់ជាងធម៌ទាំងពួង ។ ក៏ព្រះពុទ្ធអង្គនោះ ត្រាស់ដឹងជាក់នូវ

ព្រះនិព្វាននោះ ត្រង់គល់ពោធិព្រឹក្ស ដោយព្រះអង្គឯង ។ បទថា **វរទោ** **(ប្រទានធម៌ដ៏ប្រសើរ)** សេចក្តីថា ប្រទានធម៌ដ៏ប្រសើរដែលជាចំណែកនៃការត្រាស់ដឹង និងជាចំណែកអប់រំបារមីដល់សាវកទាំងឡាយ មានព្រះបញ្ចវគ្គិយ ព្រះភទ្ទវគ្គិយ និងជដិលជាដើម និងដល់ទេវតា និងមនុស្សដទៃៗ ។ បទថា **វរាហរោ (ទ្រង់នាំមកនូវធម៌ដ៏ប្រសើរ)** បានដល់ ដែលហៅថា ទ្រង់នាំមកនូវធម៌ដ៏ប្រសើរ ព្រោះទ្រង់នាំមកនៅមគ្គដ៏ប្រសើរ ។ ពិតហើយ ព្រះមានព្រះភាគព្រះអង្គនោះ ទ្រង់បំពេញបារមី ៣០ ទស មកតាំងពីព្រះពុទ្ធ ព្រះនាមទីបង្ករ ទ្រង់នាំមកនូវមគ្គដ៏ប្រសើរពីបូរាណ ដែលព្រះសម្មាសម្ពុទ្ធទាំងឡាយ ព្រះអង្គមុនៗ ទ្រង់ដំណើរមកហើយ ។ ព្រោះហេតុនោះ ព្រះអង្គទើបត្រូវហៅថា ទ្រង់នាំមកនូវមគ្គដ៏ប្រសើរ ។

មួយទៀត ព្រះពុទ្ធ ឈ្មោះថា ប្រសើរ ព្រោះទ្រង់បានព្រះសព្វញ្ញុ-តញ្ញាណ ។ ឈ្មោះថា ដឹងធម៌ដ៏ប្រសើរ ព្រោះទ្រង់ធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វាន ឈ្មោះថា ប្រទានធម៌ប្រសើរ ព្រោះប្រទានវិមុត្តិសុខដល់សត្វទាំងឡាយ ។ ឈ្មោះថា នាំមកនូវមគ្គដ៏ប្រសើរ ព្រោះទ្រង់នាំមកនូវបដិបទា

ដ៏ខ្ពង់ខ្ពស់បំផុត ។ ឈ្មោះថា កំពូល ព្រោះមិនមានគុណណាៗ ដែលក្រៃលែងជាងលោកុត្តរគុណទាំងនោះឡើយ ។

មានន័យដទៃទៀតថា ឈ្មោះថា **ទ្រង់ប្រសើរ** ព្រោះទ្រង់បរិបូណ៌ដោយអធិដ្ឋានធម៌ គឺ ឧបសមៈ (សេចក្ដីស្ងប់រម្ងាប់) ។ ឈ្មោះថា **ទ្រង់ដឹងធម៌ដ៏ប្រសើរ** ព្រោះទ្រង់បរិបូណ៌ដោយអធិដ្ឋានធម៌ គឺ បញ្ញា (សេចក្ដីដឹងជុំវិញ) ។ ឈ្មោះថា **ប្រទានធម៌ដ៏ប្រសើរ** ព្រោះបរិបូណ៌ដោយអធិដ្ឋានធម៌ គឺ ចាគៈ (ការលះ) ។ ឈ្មោះថា **នាំមកនូវធម៌ដ៏ប្រសើរ** ព្រោះទ្រង់បរិបូណ៌ដោយអធិដ្ឋានធម៌ គឺ សច្ចៈ (សេចក្ដីពិត) ។ ទ្រង់នាំមកនូវសច្ចៈ គឺ មគ្គដ៏ប្រសើរ ។ មួយវិញទៀត ឈ្មោះថា **ទ្រង់ប្រសើរ** ព្រោះទ្រង់សន្សំបុណ្យ ។ ឈ្មោះថា **ទ្រង់ដឹងធម៌ដ៏ប្រសើរ** ក៏ព្រោះទ្រង់សន្សំបញ្ញា ឈ្មោះថា **ទ្រង់ប្រទានធម៌ដ៏ប្រសើរ** ព្រោះទ្រង់ប្រគល់ឧបាយនៃបុណ្យ និងបញ្ញានោះ ដល់អ្នកត្រូវការភាពជាព្រះពុទ្ធ ។ ឈ្មោះថា **ទ្រង់នាំមកនូវធម៌ដ៏ប្រសើរ** ព្រោះនាំមកនូវឧបាយនៃបុណ្យ និងបញ្ញានោះ ដល់អ្នកត្រូវការភាពជាព្រះបច្ចេកពុទ្ធ ។ ឈ្មោះថា **កំពូល** ព្រោះមិនមាន

អ្នកស្មើដូចក្នុងធម៌នោះៗ ឬព្រោះជាអ្នកមិនមានអាចារ្យ តែក៏ត្រឡប់ជាអាចារ្យរបស់បុគ្គលដទៃៗ ដោយព្រះអង្គឯង ទ្រង់បានសំដែងធម៌ដ៏ប្រសើរ ព្រោះទ្រង់សំដែងធម៌ដ៏ប្រសើរ ដែលប្រកបដោយគុណ មានធម៌ដែលត្រាស់ល្អហើយជាដើម ដើម្បីផលនោះ ដល់អ្នកត្រូវការជាសាវ័ក ។ ពាក្យដ៏សេស មានន័យដូចដែលពោលមកហើយនោះឯង ។

ព្រះមានព្រះភាគ គ្រាត្រាស់គុណរបស់ព្រះអង្គដោយលោកុត្តរធម៌ ៩ ប្រការ យ៉ាងនេះហើយ ឥឡូវនេះ ទ្រង់អាស្រ័យគុណនោះឯង ទើបទ្រង់ប្រកបសច្ចវចនៈ ដែលមានព្រះពុទ្ធរតនៈជាទីតាំងថា **សូម្បីនេះ ក៏ជារតនៈដ៏ប្រណីតក្នុងព្រះពុទ្ធ** ។ អត្ថរបស់សច្ចវចនៈនោះ គប្បីជ្រាបតាមន័យដូចពោលហើយនោះឯង ។ តែគប្បីប្រកបសេចក្ដីតែម្យ៉ាងយ៉ាងនេះថា ព្រះពុទ្ធអង្គនោះ បានត្រាស់ដឹងលោកុត្តរធម៌ដ៏ប្រសើរណាផង បានប្រទានលោកុត្តរធម៌ណាផង ទ្រង់នាំមកនូវលោកុត្តរធម៌ណាផង ទ្រង់បានសំដែងលោកុត្តរធម៌ណាផង សូម្បីនេះ ក៏ជារតនៈដ៏ប្រណីតក្នុងព្រះពុទ្ធអង្គនោះ ។ ពួកអមនុស្សក្នុងសែនកោដិចក្រវាល ក៏ទទួលពុទ្ធអាជ្ញានៃព្រះគាថានេះ ។

## ពណ៌នាគាថាថា ខីណំ

ព្រះមានព្រះភាគ ទ្រង់អាស្រ័យបរិយត្តិធម៌ និងលោកុត្តរធម៌ហើយ ត្រាស់សច្ចវចនៈ ដែលមានព្រះពុទ្ធរតនៈជាទីតាំង ដោយ ២ គាថាយ៉ាង នេះហើយ ឥឡូវនេះ ទ្រង់អាស្រ័យគុណ គឺ ការសម្រេចអនុបាទិសេស-និព្វាន របស់ព្រះសាវកទាំងឡាយដែលបានស្តាប់បរិយត្តិធម៌ និងបដិបត្តិ តាមការដែលបានស្តាប់មក បានសម្រេចលោកុត្តរធម៌ទាំង ៩ ប្រការ ទើប ទ្រង់ផ្តើមត្រាស់សច្ចវចនៈ មានសង្ឃរតនៈជាទីតាំងទៀតថា **ខីណំ បុរាណំ** (កម្មចាស់របស់ព្រះអរិយសាវកពួកណាអស់ហើយ) ក្នុងសច្ចវចនៈនោះ បទ ថា **ខីណំ** (អស់ហើយ) បានដល់ អស់ ឬដកចេញបានដោយសមុច្ឆេទ ។ បទថា **បុរាណំ** ប្រែថា ចាស់ ។ បទថា **នវំ** (ថ្មី) បានដល់ ក្នុងឥឡូវ នេះ ដែលកំពុងប្រព្រឹត្តទៅ (បច្ចុប្បន្ន) ។ បទថា **នត្ថិ សម្ភវំ** (កម្មកើត ឡើងថ្មី... រមែងមិនមាន) បានដល់ ការប្រាកដ (កើតថ្មី) រមែងមិនមាន ។ បទថា **វិរត្តចិត្តា** (មានចិត្តមិនមានតម្រេក) បានដល់ មានចិត្តប្រាសចាក រាគៈ ។ បទថា **អាយតិកេ ភវស្មឹ** (ក្នុងភពតទៅ) បានដល់ ក្នុងភពថ្មី

ក្នុងអនាគតកាល ។ បទថា **តេ (ទាំងនោះ)** បានដល់ ភិក្ខុជាខីណាស្រព ដែលអស់កម្មភពចាស់ មិនមានកម្មភពថ្មី និងមានចិត្តប្រាសចាកតម្រេក ក្នុងភពតទៅ ។ បទថា **ខីណពីជា (មានពូជអស់ទៅហើយ)** បានដល់ អ្នកមានពូជត្រូវដកចេញហើយ ។ បទថា **អវិរុឡ្ហិឆន្ទា (មានសេចក្ដីពេញចិត្តដុះមិនបាន)** បានដល់ អ្នកវៀរចាកឆន្ទៈដែលដុះឡើង (កើត) បាន ។ បទថា **និព្វន្តិ (និព្វាន)** បានដល់ រលត់ស្និទ្ធ ។ បទថា **ធីរា (ជាអ្នកមានបញ្ញា)** បានដល់ អ្នកដល់ព្រមដោយបញ្ញា ឈ្មោះ ធិតិ ។ បទថា **យថាយម្បទីបោ** ប្រែថា ដូចដួងប្រទីបនេះ ។

លោកអធិប្បាយទុកយ៉ាងណា? លោកអធិប្បាយទុកថា កម្មណា របស់សត្វទាំងឡាយ កើតហើយរលត់ទៅ ជាកម្មចាស់ ជាអតីតកាល រមែងមិនទាន់អស់ទៅ ព្រោះអាចនាំមកនូវបដិសន្ធិ ព្រោះលះសិនេហៈ គឺតណ្ហាមិនទាន់បាន កម្មចាស់នោះ របស់ភិក្ខុខីណាស្រពពួកណា ឈ្មោះថាអស់ទៅ ក៏ព្រោះមិនអាចឲ្យវិបាកតទៅ ដូចពូជដែលភ្លើងឆេះហើយ ព្រោះសិនេហៈ គឺ តណ្ហា រីងស្ងួតទៅដោយព្រះអរហត្តមគ្គ និងកម្មណារបស់

ភិក្ខុជាខីណាស្រពពួកណា ដែលប្រព្រឹត្តទៅក្នុងបច្ចុប្បន្ន ដោយអំណាចពុទ្ធបូជាជាដើម ហៅថា កម្មថ្មី ។ ក៏កម្មថ្មីនោះ របស់ភិក្ខុជាខីណាស្រពពួកណា ក៏មិនកកពបាន ព្រោះមិនឲ្យផលតទៅទៀត ដូចផ្កានៃដើមឈើដែលមានឫសដាច់ហើយ ព្រោះលះតណ្ហាបាននោះឯង ។

មួយទៀត ភិក្ខុជាខីណាស្រព មិនមានចិត្តត្រេកអរក្នុងភពតទៅ ព្រោះលះតណ្ហាបាននោះឯង ភិក្ខុជាខីណាស្រពទាំងនោះ ឈ្មោះថា មានពូជអស់ហើយ ព្រោះបដិសន្ធិវិញ្ញាណដែលលោកពោលទុកក្នុងពាក្យនេះថា កម្ម ឈ្មោះថា ជាស្រែ , វិញ្ញាណ ឈ្មោះថា ជាពូជ ការអស់ទៅព្រោះអស់កម្មនោះឯង ។ ឆន្ទៈឯណា រមែងនាំឲ្យកើត ពោលគឺ កពថ្មីដែលមានហើយអំពីមុន ។ ភិក្ខុជាខីណាស្រពទាំងឡាយ ឈ្មោះថា មានឆន្ទៈមិនដុះតទៅទៀត ព្រោះមិនកើតក្នុងវេលាចុតិដូចពីមុន ព្រោះឆន្ទៈនោះ លះបានហើយ ព្រោះសមុទ័យនោះឯង ឈ្មោះថា អ្នកប្រាជ្ញ ព្រោះដល់ព្រមដោយធិតិប្បញ្ញា រមែងរលត់ដូចប្រទីបរលត់ទៅ ដូច្នោះ ។ ព្រោះវិញ្ញាណរលត់ទៅ រមែងកន្លងផ្លូវនៃបញ្ញត្តិជាដើមយ៉ាងនេះថា មានរូប ឬ

មិនមានរូប ទៀត ។

បានឮថា បណ្ដាប្រទីបច្រើនដួង ដែលគេតាំងទុកដើម្បីបូជាទេវតាប្រចាំក្នុងក្រុងសម័យនោះ ប្រទីបមួយដួងរលត់ទៅ ព្រះមានព្រះភាគកាលទ្រង់បង្ហាញប្រទីបដួងនោះ ទើបត្រាស់ថា "ដូចប្រទីបដួងនេះ" ។

ព្រះមានព្រះភាគ លុះត្រាស់គុណ គឺ ការសម្រេចអនុបាទិសេសនិព្វានរបស់ព្រះខីណាស្រពដែលស្ដាប់បរិយត្តិធម៌ ដែលត្រាស់ដោយ ២ គាថាមុននោះ ទាំងបដិបត្តិតាមបរិយត្តិដែលស្ដាប់ហើយ សម្រេចលោកុត្តរធម៌ទាំង ៩ ប្រការយ៉ាងនេះហើយ ឥឡូវនេះ ទ្រង់អាស្រ័យគុណនោះឯង កាលទ្រង់ប្រកបសច្ចវចនៈ មានសង្ឃរតនៈជាទីតាំង ទើបទ្រង់បញ្ចប់ទេសនាថា **សូម្បីនេះ ក៏ជារតនៈដ៏ប្រណីតក្នុងព្រះសង្ឃ ។** អត្ថនៃសច្ចវចនៈនោះ គប្បីជ្រាបតាមន័យដែលពោលហើយនោះឯង ។ តែគប្បីប្រកបសេចក្ដីតែម្យ៉ាងយ៉ាងនេះថា គុណជាត ពោលគឺ ព្រះនិព្វាន របស់ព្រះខីណាស្រព ដោយប្រការតាមដែលពោលមកហើយសូម្បីនេះ ក៏ជារតនៈដ៏ប្រណីតក្នុងសង្ឃរតនៈ ។ ពួកអមនុស្សក្នុងសែនកោដិចក្រវាល ក៏នាំគ្នា

ទទួលអាជ្ញានៃព្រះគាថានេះឯង ។

ក្នុងវេលាចប់ទេសនា សិរីសួស្តីក៏មានដល់រាជត្រកូល ។ ឧបទ្រវៈទាំងពួងក៏ស្ងប់រម្ងាប់ទៅ ។ សត្វ ៨៤.០០០ ក៏បានត្រាស់ដឹងធម៌ ។

## ពណ៌នា ៣ គាថាថា យានីធ ជាដើម

គ្រានោះ សក្កទេវរាជទ្រង់ត្រិះរិះថា ព្រះមានព្រះភាគទ្រង់អាស្រ័យគុណព្រះរតនត្រ័យ ប្រកបសច្ចវចនៈ ទ្រង់ធ្វើសិរីសួស្តីដល់ពួកអ្នកនគរ ។ សូម្បីយើង ក៏គប្បីពោលខ្លះដោយអាស្រ័យគុណព្រះរតនត្រ័យ ដើម្បីសិរីសួស្តីដល់ពួកអ្នកនគរ ដូច្នេះហើយ ទើបត្រាស់ ៣ គាថាចុងក្រោយថា **យានីធ ភូតានិ** (ពួកភូតឯណា... ក្នុងទីនេះ) ជាដើម ។ ក្នុង ៣ គាថានោះ ព្រោះហេតុជាព្រះពុទ្ធ លោកហៅថា តថាគត ព្រោះស្តេចមក ដូចដែលមនុស្សទាំងឡាយត្រូវខ្វល់ខ្វាយនាំគ្នាមក ដើម្បីប្រយោជន៍ដល់លោក ។ ព្រោះស្តេចទៅ ដូចមនុស្សទាំងនោះគប្បីទៅ ។ ព្រោះទ្រង់ដឹងទូទៅ ដូចពួកមនុស្សទាំងនោះនឹងគប្បីដឹងទូទៅ ។ ព្រោះទ្រង់ដឹង ដូចពួកមនុស្សទាំងនោះគប្បីដឹង ។ ព្រោះទ្រង់ប្រសព្វវត្ថុដែលមានយ៉ាងនោះ ។ មួយទៀត

ព្រោះហេតុដែលព្រះពុទ្ធព្រះអង្គនោះ ដែលទេវតា និងមនុស្សទាំងឡាយ បូជាយ៉ាងលើសលប់ ដោយផ្កាឈើ និងគ្រឿងក្រអូបជាដើម ដែលកើតខាងក្រៅ ជាឧបការៈ និងដែលកើតក្នុងខ្លួន មានការបដិបត្តិធម៌សមគួរដល់ធម៌ជាដើម ដូច្នោះ សក្កទេវរាជ ទ្រង់ប្រមូលទេវបរិស័ទទាំងអស់រួមទាំងព្រះអង្គ ហើយត្រាស់ថា **តថាគតំ ទេវមនុស្សបូជិតំ ពុទ្ធំ នមស្សាម សុវត្ថិ ហោតុ** (ពួកខ្ញុំព្រះអង្គ សូមនមស្ការព្រះតថាគតជាព្រះពុទ្ធ ដែលទេវតា និងមនុស្សបូជាហើយ សូមឲ្យសិរីសួស្តីចូរមាន) ។

មួយទៀត ព្រោះហេតុក្នុងព្រះធម៌ មគ្គធម៌ដំណើរទៅហើយ ដូចដែលព្រះពុទ្ធកាលទ្រង់ដកឡើងនូវធម៌ដែលជាបក្ខពួកកិលេស គប្បីដំណើរទៅ ដោយកម្លាំងសមថវិបស្សនា ដែលជាធម៌គូគ្នានោះ ហេតុនោះ លោកទើបហៅថា តថាគត , សូម្បីនិព្វានធម៌ ដែលព្រះពុទ្ធជាដើមទ្រង់សម្រេចគឺ ចាក់ធ្លុះហើយដោយព្រះបញ្ញា ដល់ព្រមដើម្បីកម្ចាត់ទុក្ខទាំងពួងនោះ ដូច្នោះ លោកទើបហៅ តថាគត ។ មួយទៀត ព្រោះហេតុដែលព្រះសង្ឃដំណើរទៅហើយ ដូចដែលលោកបដិបត្តិដើម្បីប្រយោជន៍ដល់ខ្លួន គប្បីប្រព្រឹត្ត

ទៅដោយមគ្គនោះៗ ហេតុនោះ លោកទើបហៅថា តថាគត ។ ដូច្នោះ សូម្បីក្នុង ២ គាថាដ៏សេស សក្កទេវរាជទើបត្រាស់ថា "ពួកខ្ញុំព្រះអង្គសូមថ្វាយបង្គំតថាគតធម៌ សូមសិរីសួស្តីចូរមាន ពួកខ្ញុំព្រះអង្គសូមថ្វាយបង្គំតថាគតធម៌ សូមសិរីសួស្តីចូរមាន " ដូច្នេះ ។ ពាក្យដ៏សេស មានន័យដូចពោលហើយទាំងនោះ ។

សក្កទេវរាជ កាលត្រាស់ ៣ គាថានេះ យ៉ាងនេះហើយ ទ្រង់ធ្វើប្រទក្សិណព្រះមានព្រះភាគ ស្តេចព្រមទាំងទេវបរិស័ទ ក៏ទៅកាន់ទេវបុរី ។ ចំណែកព្រះមានព្រះភាគ ទ្រង់សំដែងរតនសូត្រនោះឯង សូម្បីក្នុងថ្ងៃទី ២ សត្វ ៨៤.០០០ ក៏បានត្រាស់ដឹងធម៌ ។ ទ្រង់សំដែងយ៉ាងនេះរហូតដល់ ៧ ថ្ងៃ ។ ការត្រាស់ដឹងធម៌ ក៏មានយ៉ាងនោះឯងគ្រប់ៗ ថ្ងៃ ។ ព្រះមានព្រះភាគ ប្រថាប់នៅក្រុងវេសាលីកន្លះខែហើយ ទើបទ្រង់ប្រាប់ដល់ស្តេចលិច្ឆវីថា នឹងត្រឡប់ បន្ទាប់ពីនោះ ពួកស្តេចលិច្ឆវី ក៏យាងព្រះមានព្រះភាគឆ្ពោះទៅកាន់ប្រាំងទន្លេគង្គា ដោយសក្ការៈជាទ្វិគុណ ៣ ថ្ងៃទៀត ។ ពួកស្តេចនាគដែលនៅក្នុងទន្លេគង្គា គិតគ្នាថា ពួកមនុស្សបានធ្វើ

សក្ការៈដល់ព្រះតថាគតមុន ពួកយើងនឹងមិននាំគ្នាធ្វើខ្លះទេឬ ទើបសាងទូកជាច្រើន ធ្វើដោយមាស ប្រាក់ និងកែវមណី ក្រាលបល្ល័ង្កធ្វើដោយមាសប្រាក់ និងកែវមណី ធ្វើទឹកឲ្យដេរដាសដោយផ្កាឈូក ៥ ពណ៌ ទូលអង្វរព្រះមានព្រះភាគថា "បពិត្រព្រះអង្គ សូមព្រះអង្គទ្រង់អនុគ្រោះដល់ពួកខ្ញុំព្រះអង្គផងចុះ" ។ ព្រះមានព្រះភាគទ្រង់ទទួល ស្តេចឡើងកាន់ (ចុះ) ទូកកែវ ចំណែកភិក្ខុ ៥០០ រូប ក៏ឡើងកាន់ (ចុះ) ទូក ៥០០ មួយអង្គទូក ១ ។ ពួកស្តេចនាគ យាងព្រះមានព្រះភាគព្រមទាំងភិក្ខុសង្ឃទៅកាន់ពិភពនាគ ។ ឮថា ក្នុងទីនោះ ព្រះមានព្រះភាគទ្រង់សំដែងធម៌ដល់នាគបរិស័ទ រហូតរាត្រីជិតភ្លឺ ។ ថ្ងៃទី ២ ពួកនាគនាំគ្នាថ្វាយមហាទាន ដោយរបស់ទំពារ របស់ឆាន់ដែលជាទិព្វ ។ ព្រះមានព្រះភាគ ទ្រង់អនុមោទនាស្តេចចេញចាកពិភពនាគ ។

ពួកភុម្មទេវតានាំគ្នាគិតថា ពួកមនុស្ស នឹងនាគនាំគ្នាធ្វើសក្ការៈព្រះតថាគត ពួកយើងនឹងមិននាំគ្នាធ្វើទេឬ? ទើបនាំគ្នាយកឆ័ត្រជំតូច គុម្ពឈើដ៏ស្រស់ក្នុងព្រៃ ដើមឈើ និងភ្នំ ។ ដោយឧបាយនោះឯង សក្ការៈវិសេស

ខ្នាតធំ ក៏បានកើតឡើងដរាបដល់ភពរបស់អកនិដ្ឋព្រហ្ម ។ សូម្បីព្រះបាទពិម្ពិសារ ក៏ទ្រង់បានធ្វើជាទ្វេគុណ ជាងសក្ការៈដែលពួកស្តេចលិច្ឆវីទ្រង់ធ្វើកាលព្រះមានព្រះភាគស្តេចមក ទ្រង់យាងព្រះមានព្រះភាគមកដល់ក្រុងរាជគ្រឹះដោយប្រើវេលា ៥ ថ្ងៃ ដោយន័យដូចពោលមកហើយនោះឯង ។

លុះព្រះមានព្រះភាគ ស្តេចដល់ក្រុងរាជគ្រឹះហើយ ខាងក្រោយកត្តពួកភិក្ខុដែលអង្គុយប្រជុំគ្នាក្នុងសាលាមូល និយាយក្នុងរវាងគ្នានិងគ្នាយ៉ាងនេះថា "ឱហ្ន៎ អានុភាពរបស់ព្រះមានព្រះភាគ ដែលភូមិភាគ ៨ យោជន៍ទាំងចំណែកត្រើយអាយ និងចំណែកត្រើយនាយនៃទន្លេគង្គា ត្រូវបានធ្វើទីមិនរាបស្មើឲ្យរាបស្មើ ហើយរោយខ្សាច់ គ្របដណ្តប់ដោយផ្កាឈើទាំងឡាយ សូម្បីទន្លេគង្គាប្រមាណមួយយោជន៍ ក៏ដេរដាសដោយផ្កាឈូកគ្រប់ពណ៌ ឆ័ត្រតូចធំត្រូវលើកឡើងដរាបដល់ភពរបស់អកនិដ្ឋព្រហ្ម" ។ ព្រះមានព្រះភាគទ្រង់ជ្រាបរឿងនោះហើយ ស្តេចចេញចាកព្រះគន្ធកុដិទៅកាន់សាលាមូល ដោយបាដិហារិយដែលសមគួរក្នុងខណៈនោះ ប្រថាប់គង់លើពុទ្ធាសនៈដ៏ប្រសើរ ដែលគេក្រាលទុកក្នុងសាលាមូល ។ លុះប្រថាប់គង់

ហើយ ព្រះមានព្រះភាគត្រាស់ហៅភិក្ខុទាំងឡាយថា "ម្នាលភិក្ខុទាំងឡាយ ឥឡូវនេះ ពួកអ្នកអង្គុយប្រជុំនិយាយគ្នាដោយរឿងអ្វី" ។ ភិក្ខុទាំងឡាយក៏ក្រាបទូលរឿងទាំងអស់ ។ ព្រះមានព្រះភាគបានត្រាស់ដូច្នេះថា "ម្នាលភិក្ខុទាំងឡាយ បូជាវិសេសនេះ មិនបានកើតឡើងព្រោះពុទ្ធានុភាពរបស់តថាគត ទាំងមិនមែនព្រោះអានុភាពរបស់នាគ ទេវតា និងព្រហ្ម ដែលពិតកើតឡើងព្រោះអានុភាពនៃការបរិច្ចាគតិចតួច អំពីកាលមុនមកនោះឯង" ។ ពួកភិក្ខុទើបក្រាបទូលថា "បពិត្រព្រះអង្គដ៏ចម្រើន ពួកខ្ញុំព្រះអង្គ មិនដឹងការបរិច្ចាគតិចតួចនោះឡើយ សូមព្រះមានព្រះភាគ ប្រោសត្រាស់ប្រាប់ដល់ពួកខ្ញុំព្រះអង្គ ឲ្យពួកខ្ញុំព្រះអង្គដឹងនូវការបរិច្ចាគតិចតួចនោះផងចុះ" ។

ព្រះមានព្រះភាគទើបត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ រឿងធ្លាប់មានមកហើយ ក្នុងក្រុងតក្កសិលា មានព្រាហ្មណ៍ម្នាក់ ឈ្មោះ **សង្ខ:** ។ គេមានបុត្រ ឈ្មោះ **សុសិមមាណព** ។ មាណពនោះ មានអាយុ ១៦ ឆ្នាំ ដោយវ័យ ថ្ងៃមួយចូលទៅរកបិតា ថ្វាយបង្គំហើយ ឈរក្នុងទីកន្លែងដ៏សមគួរមួយ ។ ពេលនោះ បិតាសួរគេថា "មានអ្វី សុសិម:កូន ?" គេ

ឆ្លើយថា "កូនប្រាថ្នាទៅក្រុងពារាណសីដើម្បីរៀនសិល្បៈ ពុក" ព្រាហ្មណ៍ពោលថា "សុសិមៈ បើដូច្នោះ ពុកមានសំឡាញ់ជាព្រាហ្មណ៍ឈ្មោះឯណោះ កូនចូលទៅរកគេរៀនចុះ" ហើយប្រគល់ទ្រព្យឲ្យ ១.០០០ កហាបណៈ ។ សុសិមមាណពនោះទទួលទ្រព្យហើយ ក៏ថ្វាយបង្គំលាមាតាបិតា ដើរផ្លូវទៅកាន់ក្រុងពារាណសីដោយលំដាប់ ចូលទៅរកអាចារ្យប្រកបដោយកាតទន់ភ្លន់ ថ្វាយបង្គំហើយប្រាប់ពីខ្លួន ។ អាចារ្យដឹងថាជាកូនរបស់សំឡាញ់ ក៏ព្រមទទួលមាណព បានធ្វើការទទួលគ្រប់យ៉ាងដោយល្អ ។ មាណពនោះ កាលប្រាសចាកសេចក្ដីនឿយហត់ក្នុងការដើរផ្លូវឆ្ងាយហើយ ក៏ដាក់កហាបណៈ ១.០០០ នោះ ជិតជើងអាចារ្យ សូមឱកាសរៀនសិល្បៈ អាចារ្យក៏បើកឱកាសឲ្យរៀន ។

គេរៀនបានរហ័ស និងរៀនបានច្រើន ទាំងចាំទុកសិល្បៈដែលរៀននោះបានមិនសាបសូន្យ ដូចខ្លាញ់ដែលដាក់ក្នុងភាជនៈមាស គេរៀនសិល្បៈដែលគួររៀនដល់ ១២ ឆ្នាំ ឲ្យសម្រេចទៅបានដោយ ២-៣ ខែប៉ុណ្ណោះ ។ គេធ្វើការស្វាធ្យាយឃើញតែខាងដើម និងកណ្ដាលប៉ុណ្ណោះ មិនឃើញខាង

ចុង ទើបចូលរកអាចារ្យ សួរថា "លោកអាចារ្យ ខ្ញុំឃើញតែខាងដើម និងខាងកណ្ដាលរបស់សិល្បៈនេះប៉ុណ្ណោះ មិនបានឃើញខាងចុងឡើយ?" អាចារ្យក៏ពោលថា "យើងក៏ឃើញយ៉ាងនោះដូចគ្នាដែរ បាអើយ" ។ គេទើបសួរថា "លោកអាចារ្យ បើដូច្នោះ នរណាហ្ន៎ ដឹងខាងចុងរបស់សិល្បៈនេះ?" អាចារ្យពោលថា "បាអើយ នៅព្រៃឥសិបតនៈ មានឥសីច្រើនអង្គ ឥសីទាំងនោះគង់ដឹង ។ គេប្រាប់ថា "លោកអាចារ្យ ខ្ញុំនឹងចូលទៅសួរឥសីទាំងនោះឯង" ។ អាចារ្យក៏ឆ្លើយថា "ទៅសួរតាមសប្បាយចុះ បា" ។ គេក៏ចូលទៅកាន់ព្រៃឥសិបតនៈ ចូលទៅរកព្រះបច្ចេកពុទ្ធទាំងឡាយ សួរថា "លោកម្ចាស់ដ៏ចម្រើន លោកម្ចាស់ដឹងខាងចុងនៃសិល្បៈខ្លះទេ? ព្រះបច្ចេក-ពុទ្ធត្រាស់ថា "អើ យើងដឹង" ។ គេក៏អង្វរថា "សូមមេត្តាប្រោសឲ្យខ្ញុំបានសិក្សាខាងចុងនៃសិល្បៈនោះផងចុះ" ។ ព្រះបច្ចេកពុទ្ធត្រាស់ថា "បើដូច្នោះ ចូរបួសសិនចុះ អ្នកមិនមែនជាអ្នកបួស សិក្សាមិនបានឡើយ" ។ គេទទួលពាក្យថា "ប្រពៃហើយលោកម្ចាស់ មេត្តាឲ្យខ្ញុំបួសចុះ លោកម្ចាស់ចូរធ្វើតែការដែលលោកម្ចាស់ប្រាថ្នាចុះ ហើយឲ្យខ្ញុំសិក្សាខាងចុងនៃសិល្បៈនោះ

ជាការស្រេច" ។ ព្រះបច្ចេកពុទ្ធទាំងនោះ ឲ្យគេបួសហើយ ក៏មិនអាចប្រកបគេទុកក្នុងកម្មដ្ឋាន ឲ្យសិក្សាបានតែអភិសមាចារ ដោយន័យជាដើមថា លោកគប្បីស្លៀកយ៉ាងនេះ គប្បីដណ្តប់យ៉ាងនេះ ។ គេសិក្សានៅក្នុងប្រការនោះ តែព្រោះជាអ្នកដល់ព្រមដោយឧបនិស្ស័យ មិនយូរប៉ុន្មានក៏ត្រាស់ដឹងបច្ចេកពោធិញ្ញាណ ។ ព្រះសុសិម:ដល់នូវលាភយសដ៏ប្រសើរព្រមទាំងបរិវារ ក៏ប្រាកដទូទៅក្នុងក្រុងពារាណសីថា "សុសិម:បានត្រាស់ជាព្រះបច្ចេកពុទ្ធ" តែមិនយូរប៉ុន្មាន លោកក៏បរិនិព្វាន ព្រោះបានធ្វើកម្មដែលជាហេតុឲ្យអាយុខ្លី ។ ព្រះបច្ចេកពុទ្ធទាំងឡាយ និងពួកមហាជននាំគ្នាធ្វើឈាបនកិច្ចសរីរ:របស់លោក រក្សាធាតុ សាងព្រះស្តូបទុកជិតទ្វារនគរ ។

ចំណែកសង្ខព្រាហ្មណ៍ គិតថា កូនរបស់យើងទៅយូរហើយ នៅមិនទាន់ដឹងដំណឹងតិចតួចរបស់គេឡើយ បំណងនឹងជួបកូន ទើបចេញពីតក្កសិលា ដើរផ្លូវទៅតាមលំដាប់ក៏ដល់ក្រុងពារាណសី ឃើញពួកមហាជនប្រជុំគ្នា គិតថា ក្នុងពួកជនដ៏ច្រើន ត្រឹមតែម្នាក់គង់នឹងដឹងដំណឹងតិចតួច

អំពីកូនរបស់យើងដោយពិត ទើបចូលទៅកាន់ទីជំនុំជន សួរថា មាណព សុសិមៈមកក្នុងទីនេះ មានឃើញទេ លោកដឹងដំណឹងកូនរបស់យើងខ្លះដែរទេ? ជនទាំងនោះពោលថា ព្រាហ្មណ៍ ពួកយើងដឹង លោករៀនចប់ត្រៃវេទក្នុងសំណាក់ព្រាហ្មណ៍ក្នុងព្រះនគរនេះហើយ ក៏បួសក្នុងសំណាក់របស់ព្រះបច្ចេកពុទ្ធទាំងឡាយ បានត្រាស់ជាព្រះបច្ចេកពុទ្ធ បរិនិព្វានដោយអនុបាទិសេសនិព្វានធាតុទៅហើយ នេះព្រះស្តូប យើងសាងទុកសម្រាប់លោក ។ សន្ទព្រាហ្មណ៍នោះយកដៃទះផែនដី យំរៀបរាប់ត្រង់លានព្រះចេតិយនោះ ដកស្មៅ និងយកសំពត់ដណ្តប់គ្រប នាំខ្សាច់ទៅរោយត្រង់លានព្រះចេតិយព្រះបច្ចេកពុទ្ធ នាំយកទឹកក្នុងក្អមប្រោះព្រំទីដីដោយជុំវិញ ធ្វើការបូជាដោយផ្កាឈើ យកសំពត់ដណ្តប់លើកឡើងធ្វើជាទង់ ចងឆ័ត្រធ្វើជាម្លប់ទុកលើស្តូបហើយ ក៏ត្រឡប់ទៅ ។

ព្រះមានព្រះភាគ លុះទ្រង់សំដែងរឿងអតីតយ៉ាងនេះហើយ កាលទ្រង់ភ្ជាប់ជាតកនោះនឹងបច្ចុប្បន្ន ទើបត្រាស់ធម៌ដល់ភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ ពួកអ្នកគប្បីមានការគិតថា អ្នកដទៃជាសន្ទព្រាហ្មណ៍ក្នុង

សម័យនោះដោយពិត តែពួកអ្នកមិនគប្បីឃើញយ៉ាងនេះ ក៏សម័យនោះ តថាគតនេះឯង ជាសទ្ធព្រាហ្មណ៍ តថាគតជកស្មៅត្រង់លានព្រះចេតិយ របស់សុសិមបច្ចេកពុទ្ធ ដោយផលកម្មរបស់តថាគតនោះ ជនទាំងឡាយ ទើបធ្វើផ្លូវ ៨ យោជន៍ ឲ្យប្រាសចាកគល់ឈើ និងបន្លា ធ្វើផែនដីឲ្យ រាបស្មើស្អាត ។ តថាគតរោយជីខ្សាច់ត្រង់លានព្រះចេតិយ ព្រះសុសិម បច្ចេកពុទ្ធនោះ ដោយផលកម្មរបស់តថាគតនោះ ជនទាំងឡាយទើបរោយ ជីខ្សាច់ត្រង់ផ្លូវ ៨ យោជន៍ ។ តថាគតធ្វើការបូជាត្រង់ព្រះស្តូបនោះ ដោយផ្កាឈើ ដោយផលកម្មរបស់តថាគតនោះ ជនទាំងឡាយ ទើបបាន ក្រាលនូវផ្កាឈើច្រើនប្រភេទទាំងលើគោក ទាំងខាងក្នុងទឹក ក្នុងផ្លូវ ៩ យោជន៍ ។ តថាគតប្រោះព្រំផែនដីដោយទឹកក្នុងក្អម ត្រង់ព្រះស្តូបនោះ ដោយផលកម្មរបស់តថាគតនោះ ភ្លៀងបោក្ខរណី ទើបបង្អុរចុះត្រង់ក្រុង វេសាលី ។ តថាគតលើកទង់សំពត់ និងបង់ឆត្រត្រង់ចេតិយនោះ ដោយ ផលកម្មរបស់តថាគត ជនទាំងឡាយ ទើបលើកទង់សំពត់ និងឆត្រតូច ធំ រហូតដល់កពអកនិដ្ឋ ។ ម្នាលភិក្ខុទាំងឡាយ ដូច្នោះ បូជាវិសេសនេះ

មិនមែនកើតឡើងព្រោះពុទ្ធានុភាព មិនមែនព្រោះអានុភាពរបស់នាគ ទេវតា និងព្រហ្មទេ ដែលពិត បានកើតឡើងព្រោះអនុភាពនៃការបរិច្ចាគតិចតួច អំពីកាលមុនមកនោះឯង ។ ចប់ធម្មកថា បានត្រាស់ព្រះគាថានេះថា ៖

បើបុគ្គលគប្បីឃើញសុខដ៏ធំ ព្រោះលះសុខល្មមប្រមាណ
សោត អ្នកមានបញ្ញាកាលឃើញសុខដ៏ធំ គប្បីលះសុខ
ល្មម ប្រមាណចេញ ដូច្នេះ ។

ចប់អដ្ឋកថា រតនសូត្រទី ៦

# អដ្ឋកថា តិរោកុឌ្ឌសូត្រទី ៧

(ការឱ្យចំណែកបុណ្យដល់អ្នកស្លាប់ទៅហើយ)

## *ប្រយោជន៍នៃការតាំងព្រះសូត្រ*

[៨] *ឥឡូវនេះ ដល់លំដាប់នៃការពណ៌នាសេចក្តីតិរោកុឌ្ឌសូត្រ ដែលលើកឡើងតាំង តាមលំដាប់បន្ទាប់ពីរតនសូត្រដោយន័យថា **តិរោកុឌ្ឌេសុ តិដ្ឋន្តិ** (ពួកប្រេត... ឈរនៅខាងក្រៅជញ្ជាំងផ្ទះ) ជាដើម នឹងពោលអំពីប្រយោជន៍នៃការតាំងតិរោកុឌ្ឌសូត្រនោះទុកក្នុងទីនេះ ទើបនឹងធ្វើការពណ៌នាសេចក្តី ។*

*ក្នុងសេចក្តីនោះ សេចក្តីពិត តិរោកុឌ្ឌសូត្រនេះ សូម្បីព្រះមានព្រះភាគ ក៏មិនបានត្រាស់តាមលំដាប់នេះ តែក៏ទ្រង់សំដែងដល់ការបដិបត្តិកុសលកម្មនេះ ដោយប្រការផ្សេងៗ ទុកមុនព្រះសូត្រនេះ ព្រោះហេតុនៃបុគ្គលប្រមាទក្នុងការបដិបត្តិកុសលកម្មនោះ កាលកើតក្នុងឋានៈសូម្បីដ៏សៅហ្មងជាងនរក និងកំណើតសត្វតិរច្ឆាន ក៏រមែងកើតក្នុងពួកប្រេតនោះ*

ឯង ដូច្នោះ ព្រះមានព្រះភាគទើបត្រាស់រតនសូត្រ ដើម្បីសំដែងថា បុគ្គល មិនគួរប្រមាទក្នុងការបដិបត្តិកុសលកម្មនោះ និងដើម្បីរម្ងាប់ឧបទ្ទវៈនៃក្រុង វេសាលី ដែលពួកភូតឯណាបៀតបៀនហើយ ឬត្រាស់ដើម្បីសំដែងថា ក្នុងពួកភូតទាំងនោះ មានភូតពួកខ្លះមានរូបបែបនោះ គប្បីជ្រាបប្រយោជន៍ នៃការតាំងតិរោកុឌ្ឍសូត្រនេះ ក្នុងទីនេះ ។

## កថាអនុមោទនា

ក៏ព្រោះការពណ៌នាអត្ថរបស់ តិរោកុឌ្ឍសូត្រនោះ ដែលខ្ញុំប្រកាស ធ្វើព្រះសូត្រនោះទាំងអស់ថា តិរោកុឌ្ឍសូត្រ អ្នកណាប្រកាស ប្រកាសក្នុង ទីណា ប្រកាសកាលណា ប្រកាសព្រោះហេតុអ្វី តាមលំដាប់ ទើបជាការ ដែលធ្វើទុកល្អហើយ ដូច្នោះ ខ្ញុំនឹងធ្វើការពណ៌នាសេចក្ដីនោះ យ៉ាងនោះ ដូចគ្នា ។

បទថា តិរោកុឌ្ឍសូត្រនេះ នរណាប្រកាស ប្រកាសក្នុងទីណា ប្រកាសកាលណា និងប្រកាសព្រោះហេតុអ្វី សូមអធិប្បាយដូច្នេះ តិរោ-កុឌ្ឍសូត្រ ព្រះមានព្រះភាគទ្រង់ប្រកាស ក៏តិរោកុឌ្ឍសូត្រនោះឯង ទ្រង់បាន

ប្រកាស ដើម្បីទ្រង់អនុមោទនាដល់ព្រះបាទមគធរដ្ឋ ក្នុងថ្ងៃព្រឹកឡើងក្នុងក្រុងរាជគ្រឹះ ដើម្បីធ្វើសេចក្ដីនេះឲ្យជាក់ច្បាស់ គួរពោលរឿងទុកឲ្យពិស្ដារក្នុងប្រការនេះ ដូច្នេះ ។

ក្នុងកប្បទី ៩២ រាប់អំពីកប្បនេះ មាននគរឈ្មោះកាសី ក្នុងនគរនោះ មានព្រះរាជាព្រះនាមថា **ជយសេន** ព្រះទេវីរបស់ព្រះរាជានោះ ព្រះនាមថា **សិរិមា** ។ ព្រះពោធិសត្វ ព្រះនាមថា **បុស្ស:** កើតក្នុងគភ៌របស់ព្រះនាង ត្រាស់ដឹងសម្មាសម្ពោធិញ្ញាណតាមលំដាប់ ។ ព្រះបាទជយសេនទ្រង់ទឹករឭកដល់ព្រះរតនត្រ័យជារបស់ព្រះអង្គថា ឱរសរបស់យើងចេញបួស បានត្រាស់ជាព្រះពុទ្ធ ព្រះពុទ្ធក៏ជារបស់យើង ព្រះធម៌ក៏ជារបស់យើង ព្រះសង្ឃក៏ជារបស់យើង ទ្រង់ឧបដ្ឋាកដោយព្រះអង្គឯង គ្រប់វេលាមិនព្រមប្រទានឱកាសដល់បុគ្គលដទៃៗ ។

បងប្អូនរបស់ព្រះមានព្រះភាគ ដែលមានមាតាផ្សេងគ្នា ៣ ព្រះអង្គនាំគ្នាត្រិះរិះថា ធម្មតាព្រះពុទ្ធទាំងឡាយ រមែងស្ដេចឧប្បត្តិឡើងដើម្បីជាប្រយោជន៍ដល់សត្វទាំងពួង មិនមែនដើម្បីប្រយោជន៍ដល់សត្វតែម្នាក់ទេ

តែព្រះបិតារបស់យើង ទ្រង់មិនប្រទានឱកាសដល់ពួកយើង និងអ្នកដទៃៗ ឡើយ យើងនឹងបានការឧបដ្ឋាកព្រះមានព្រះភាគយ៉ាងណាហ្ន៎ ព្រះរាជឱរស ទាំងនោះ ទើបដាក់ព្រះហឫទ័យថា ចាំយើងនឹងធ្វើឧបាយខ្លះ ។ ទាំង ៣ ព្រះអង្គ ទើបឲ្យមេស្រុកជាយដែន ធ្វើការបះបោរ ។ បន្ទាប់មក ព្រះរាជា ទ្រង់ជ្រាបដំណឹងថា ស្រុកទល់ដែនក្បត់ ទើបទ្រង់បញ្ជាព្រះឱរសទាំង ៣ ព្រះអង្គ ចេញទៅបង្ក្រាបជនក្បត់ ។ ព្រះរាជាឱរសទាំងនោះ បង្ក្រាបអំពើ ក្បត់ស្រេចហើយ ក៏ស្ដេចត្រឡប់ ព្រះរាជាទ្រង់ពេញព្រះទ័យ ទ្រង់ព្រះ រាជទានពរថា “បា ប្រាថ្នាវត្ថុណា ក៏ចូរទទួលវត្ថុនោះ” ។ ព្រះរាជឱរស ទាំង ៣ ព្រះអង្គ ក្រាបទូលថា “ខ្ញុំព្រះអង្គប្រាថ្នាឧបដ្ឋាកព្រះមានព្រះភាគ ជាម្ចាស់” ។ ព្រះរាជាត្រាស់ថា “វៀរពរប្រការនេះចេញ សូមទទួលពរ ដទៃវិញចុះ” ។ ព្រះរាជឱរសក្រាបទូលថា “ពួកខ្ញុំព្រះអង្គ មិនប្រាថ្នាពរ យ៉ាងដទៃទេ ព្រះអង្គ” ។ ព្រះរាជាត្រាស់ថា “បើដូច្នោះ បាចូរកំណត់ វេលាមក ហើយទទួលទៅ” ។ ព្រះរាជឱរសទូលសូម ៧ ឆ្នាំ ។ ព្រះរាជា មិនព្រះរាជទាន ។ ព្រះរាជឱរសទើបទូលសូមចុះយ៉ាងនេះ គឺ ៦ ឆ្នាំ ៥

ឆ្នាំ ៤ ឆ្នាំ ៣ ឆ្នាំ ២ ឆ្នាំ ១ ឆ្នាំ ៧ ខែ ៦ ខែ ៥ ខែ ៤ ខែ រហូតដល់ ៣ ខែ ។ ព្រះរាជាទើបប្រទានថា ទទួលបាន ។

ព្រះរាជឱរសទាំងនោះ បានទទួលព្រះរាជទានពរហើយ ក៏ទ្រង់រីករាយយ៉ាងខ្លាំង ចូលគាល់ព្រះមានព្រះភាគ ថ្វាយបង្គំហើយក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ពួកខ្ញុំព្រះអង្គបំណងនឹងឧបដ្ឋាកព្រះមានព្រះមានអស់ត្រៃមាស សូមព្រះមានព្រះភាគ ទ្រង់ប្រោសទទួលចាំវស្សាអស់ត្រៃ-មាសនេះដល់ខ្ញុំព្រះអង្គផងចុះ ព្រះអង្គ ។ ព្រះមានព្រះភាគក៏ទ្រង់ទទួលដោយអាការតុណ្ហីភាព ។ តពីនោះ ព្រះរាជឱរសទាំង ៣ ព្រះអង្គ ក៏បញ្ជូនហត្ថលេខា ទៅចែកដល់ក្មាក់ងាររក្សាសួយក្នុងជនបទរបស់ព្រះអង្គថា យើងនឹងឧបដ្ឋាកព្រះមានព្រះភាគអស់ត្រៃមាសនេះ ។ អ្នកចូរចាត់គ្រឿងប្រកបក្នុងការឧបដ្ឋាកព្រះមានព្រះភាគទុកឲ្យដល់ព្រមគ្រប់ប្រការ ។ ទើបសាងព្រះវិហារជាដើមទៅ ។ ក្មាក់ងារអ្នករក្សាសួយនោះ ចាត់ការគ្រប់យ៉ាងហើយ ក៏បញ្ជូនសៀវភៅរាយការឲ្យទ្រង់ជ្រាប ។ ព្រះរាជឱរសទាំងនោះ ក៏ទ្រង់ស្លៀកដណ្ដប់សំពត់កាសាយៈ ទ្រង់ឧបដ្ឋាកព្រះមានព្រះ-

ភាគដោយគោរព ដោយបុរសវេយ្យាវច្ចករ ២.៥០០ នាក់ យាងស្តេចមក កាន់ជនបទ បង្អោនថ្វាយព្រះវិហារ អារាធនាទ្រង់នៅចាំវស្សា ។

បុត្រគហបតីម្នាក់ ជាក្នាក់ងារដែលរក្សាឃ្លាំងរបស់ព្រះរាជឱរស ទាំងនោះ ព្រមទាំងភរិយា ជាអ្នកមានបសាទសទ្ធា គេបានថ្វាយទានវត្ត ដល់ព្រះសង្ឃមានព្រះពុទ្ធជាប្រធានដោយគោរព ។ ក្នាក់ងាររក្សាដែល រក្សាសួយក្នុងជនបទ នាំបុត្រគហបតីនោះ ឲ្យធ្វើការថ្វាយទានដោយគោរព ព្រមទាំងបុរសអ្នកស្រុកជនបទប្រមាណ ១១.០០០ នាក់ ។ បណ្តាអ្នក ទាំងនោះ អ្នកស្រុកជនបទពួកខ្លះ មានចិត្តត្រូវឥស្សាមច្ឆរិយៈគ្របសង្កត់ ពួកគេក៏នាំគ្នាអន្តរាយដល់ទាន បរិភោគទេយ្យធម៌ដោយខ្លួនឯងខ្លះ ឲ្យដល់ ពួកកូនៗ ខ្លះ និងយកភ្លើងដុតរោងអាហារ ។ លុះបវារណាចេញវស្សា ព្រះរាជឱរសទាំងឡាយ ក៏ទ្រង់ធ្វើសក្ការៈធំក្រៃលែងចំពោះព្រះមានព្រះភាគ តាមព្រះមានព្រះភាគចូលគាល់ព្រះរាជបិតា ។ ព្រះមានព្រះភាគស្តេចទៅ ក្នុងទីនោះហើយ ក៏បរិនិព្វាន ។ ព្រះរាជា ព្រះរាជឱរស ក្នាក់ងាររក្សា សួយក្នុងជនបទ និងក្នាក់ងាររក្សាឃ្លាំង ។ ធ្វើកាលៈទៅតាមលំដាប់ ក៏

កើតក្នុងសួគ៌ព្រមទាំងបរិស័ទជាបរិវារ ។ ពួកជនដែលមានចិត្តត្រូវឥស្សាមច្ឆរិយគ្របសង្កត់ ក៏នាំគ្នាទៅកើតក្នុងនរកទាំងឡាយ កាលមនុស្ស ២ ពួកនោះ ចាកសួគ៌ចូលដល់សួគ៌ ចាកនរកចូលដល់នរក ដោយអាការយ៉ាងនេះ កប្បក៏កន្លងទៅ ៩២ កប្ប ។

តមក ក្នុងភទ្ទកប្បនេះ កាលព្រះពុទ្ធព្រះនាម **កស្សបៈ** ជនដែលមានចិត្តត្រូវឥស្សាមច្ឆរិយៈគ្របសង្កត់នោះ ក៏កើតជាប្រេត ។ គ្រានោះមនុស្សទាំងឡាយ ថ្វាយទាន ឧទ្ទិសដើម្បីប្រយោជន៍ដល់ពួកប្រេតដែលជាញាតិរបស់ខ្លួនថា **សូមទាននេះ ចូរមានដល់ពួកញាតិរបស់យើង** ។ ប្រេតទាំងនោះ ក៏បានសម្បត្តិ ។ ខណៈនោះ ប្រេតសូម្បីពួកនេះឃើញដូច្នោះ ក៏ទៅគាល់ព្រះមានព្រះភាគកស្សបៈ ទូលសួរថា បពិត្រព្រះអង្គដ៏ចម្រើន ធ្វើដូចម្ដេចហ្ន៎ ពួកខ្ញុំព្រះអង្គទើបនឹងបានសម្បត្តិបែបនោះខ្លះ ព្រះអង្គ? ព្រះមានព្រះភាគត្រាស់ថា ឥឡូវនេះ ពួកអ្នកនៅមិនទាន់បានទេ តែថា ក្នុងអនាគត នឹងមានព្រះពុទ្ធព្រះនាមថា គោតម ក្នុងកាលនៃព្រះមានព្រះភាគអង្គនោះ នឹងមានព្រះរាជាព្រះនាមថា ពិម្ពិសារ ស្ដេចជាញាតិរបស់ពួកអ្នក

រាប់តាំងពីនេះទៅ ៩២ កប្ប ទ្រង់នឹងថ្វាយទានដល់ព្រះពុទ្ធឧទ្ទិសចំណែកកុសលដល់ពួកអ្នក គ្រានោះ ពួកអ្នកនឹងបាន ។ ឮថា កាលមានព្រះពុទ្ធតម្រាស់យ៉ាងនេះហើយ ព្រះពុទ្ធតម្រាស់នោះ បានប្រាកដដល់ប្រេតទាំងនោះ ហាក់ដូចជាត្រាស់ថា ពួកអ្នកនឹងបានក្នុងថ្ងៃស្អែក ។

តមក កាលកន្លងទៅមួយពុទ្ធន្តរ ព្រះមានព្រះភាគរបស់ពួកយើងស្តេចឧប្បត្តិឡើងក្នុងលោក ។ ព្រះរាជឱរសទាំង ៣ អង្គនោះ ក៏ចុតិចាកទេវលោកព្រមទាំងបុរស ២.៥០០ នាក់ ទៅកើតក្នុងត្រកូលព្រាហ្មណ៍ទាំងឡាយក្នុងដែនមគធៈ បួសជាឥសី បានជាជដិល ៣ នាក់ បងប្អូននៅនឹងគយាសីសប្រទេស ។ ឯអ្នករក្សាសួយក្នុងជនបទ បានជាព្រះបាទពិម្ពិសារ បុត្រគហបតីដែលជាមេរក្សាឃ្លាំង បានជា មហាសេដ្ឋីឈ្មោះវិសាខៈ ភរិយារបស់គេបានជាធីតារបស់សេដ្ឋីឈ្មោះ ធម្មទិន្នា បរិស័ទដ៏សេស កើតជារាជបរិវាររបស់ព្រះបាទពិម្ពិសារទាំងអស់ ។

ព្រះមានព្រះភាគរបស់ពួកយើង ស្តេចកើតឡើងក្នុងលោក កន្លងទៅ ៧ សប្តាហ៍ ក៏ស្តេចមកប្រថាប់នៅក្រុងពារាណសី ដោយលំដាប់ ទ្រង់

ប្រកាសព្រះធម្មចក្រប្រោសភិក្ខុបញ្ចវគ្គីយ៍ជាដើម រហូតដល់ទ្រង់ណែនាំជដិល ៣ នាក់បងប្អូន ដែលមានបរិវារ ២.៥០០[១] ទើបស្ដេចយាងទៅកាន់ក្រុងរាជគ្រឹះ ។ នៅក្នុងក្រុងរាជគ្រឹះនោះ ទ្រង់ប្រោសព្រះបាទពិម្ពិសារ ដែលស្ដេចចូលទៅគាល់ក្នុងថ្ងៃនោះឯង ឲ្យតាំងនៅក្នុងសោតាបត្តិផលព្រមទាំងព្រាហ្មណ៍ និងគហបតីអ្នកស្រុកមគធ: ១១ នហុត ។ កាលនោះ ព្រះ-មានព្រះភាគទ្រង់ទទួលនិមន្តព្រះបាទពិម្ពិសារ ដើម្បីសោយភត្តាហារក្នុងថ្ងៃស្អែក លុះព្រឹកឡើង ដែលសក្កទេវរាជញុំាងស្ដេច ឲ្យទ្រង់សរសើរ (ព្រះមានព្រះភាគ) ដោយគាថាទាំងឡាយ ជាដើមយ៉ាងនេះថា ៖

ព្រះដ៏មានព្រះភាគ មានព្រះឆវីស្មើដោយដុំមាសសិង្គី
ទ្រង់ហ្វឹកហាត់ឥន្ទ្រីយ៍ហើយ ទ្រង់ផុតវិសេសហើយ
ស្ដេចចូលកាន់នគររាជគ្រឹះ ព្រមដោយព្រះបុរាណ-
ជដិលទាំងឡាយ អ្នកហ្វឹកហាត់ឥន្ទ្រីយ៍ហើយ ជាអ្នក
ផុតវិសេសហើយ ដូច្នេះ ។

---

១ អដ្ឋកថាបេតវត្ថុ មាន ១.០០០ នាក់ ។

ស្ដេចចូលកាន់ក្រុងរាជគ្រឹះ ទ្រង់ទទួលមហាទានក្នុងព្រះរាជនិវេសន៍ របស់ព្រះបាទពិម្ពិសារ ។ ប្រេតទាំងនោះ ឈរហែហមដោយសង្ឃឹមថា ឥឡូវនេះ ព្រះរាជាទ្រង់នឹងឧទ្ទិសទានដល់ពួកយើង ឥឡូវនេះ ទ្រង់នឹង ឧទ្ទិសទានដល់ពួកយើង ។

ចំណែកព្រះបាទពិម្ពិសារថ្វាយទានហើយ ទ្រង់ត្រិះរិះថា ព្រះមាន-ព្រះភាគនឹងគង់ប្រថាប់នៅក្នុងទីណាហ្ន៎ ទ្រង់រំពឹងដល់រឿងដែលប្រថាប់នៅ របស់ព្រះមានព្រះភាគប៉ុណ្ណោះ ទ្រង់មិនបានឧទ្ទិសទាននោះ ដល់នរណាៗ ប្រេតទាំងឡាយអស់សង្ឃឹម ពេលកណ្ដាលយប់ ទើបនាំគ្នាធ្វើជាសំឡេង ប្លែកៗ គួរឲ្យខ្លាចយ៉ាងក្រៃលែងក្នុងព្រះរាជនិវេសន៍ ។ ព្រះរាជាទ្រង់ដល់ នូវភាពភ័យខ្លាច លុះភ្លឺឡើង បានក្រាបទូលព្រះមានព្រះភាគថា បពិត្រ ព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គបានឮសំឡេងដូច្នេះ ហេតុការណ៍អ្វី នឹងមាន ដល់ខ្ញុំព្រះអង្គ ព្រះអង្គ ។

ព្រះមានព្រះភាគត្រាស់ថា ថ្វាយព្រះពរ មហាបពិត្រ ទ្រង់កុំខ្លាច ឡើយ នឹងមិនមានវត្ថុអាក្រក់អ្វី ៗ ដល់មហាបពិត្រទេ តែថា ពួកញាតិ

ចាស់ៗ របស់មហាបពិត្រ កើតជាប្រេតមាន ប្រេតទាំងនោះត្រាច់ទៅអស់មួយពុទ្ធន្តរ មានសេចក្ដីសង្ឃឹមចំពោះមហាបពិត្រថា ទ្រង់នឹងថ្វាយទានចំពោះព្រះពុទ្ធ ហើយនឹងឧទ្ទិសចំណែកបុណ្យដល់ពួកគេ កាលពីថ្ងៃម្សិលមហាបពិត្រមិនបានឧទ្ទិសចំណែកបុណ្យដល់ប្រេតទាំងនោះ ប្រេតទាំងនោះអស់សង្ឃឹម ទើបនាំគ្នាធ្វើសំឡេងប្លែកៗ ដូច្នោះ ។

ព្រះបាទពិម្ពិសារក្រាបទូលថា ឥឡូវនេះ កាលខ្ញុំព្រះអង្គថ្វាយទានពួកគេក៏គួរបានឬ ព្រះអង្គ ។

ព្រះមានព្រះភាគត្រាស់ថា ថ្វាយព្រះពរ មហាបពិត្រ ។

ព្រះបាទពិម្ពិសារក្រាលទូលថា បើដូច្នោះ សូមព្រះមានព្រះភាគប្រោសមេត្តាទទួលនិមន្តសោយភត្តាហារព្រឹកថ្ងៃនេះ របស់ខ្ញុំព្រះអង្គផងចុះព្រះអង្គ ខ្ញុំព្រះអង្គនឹងឧទ្ទិសទានដល់ប្រេតទាំងនោះ ។ ព្រះមានព្រះភាគទ្រង់ទទួល ។ ព្រះរាជាស្ដេចចូលខាងក្នុងព្រះរាជនិវេសន៍ ចាត់ចែងមហាទានហើយ ឲ្យក្រាបទូលវេលាភត្តាហារចំពោះមានព្រះភាគ ។ ព្រះមាន-ព្រះភាគស្ដេចចូលខាងក្នុងព្រះរាជនិវេសន៍ ប្រថាប់លើពុទ្ធាសនៈដែលគេ

ចាត់ចែងទុក ព្រមដោយភិក្ខុសង្ឃ ។

ប្រេតទាំងនោះ នាំគ្នាទៅឈរត្រង់ខាងក្រៅជញ្ជាំងផ្ទះជាដើម ដោយសង្ឃឹមថា ថ្ងៃនេះពួកយើងគង់បានអ្វីបរិភោគខ្លះ ។ ព្រះមានព្រះភាគទ្រង់បានធ្វើដោយអាការដែលប្រេតពួកនោះ ឲ្យប្រាកដដល់ព្រះរាជា ។

ព្រះរាជាទ្រង់ថ្វាយទឹកទក្ខិណោទកឧទ្ទិសថា **សូមទាននេះ ចូលមានដល់ពួកញាតិរបស់យើង** ។ រំពេចនោះឯង ស្រះបោក្ខរណីដេរដាសដោយផ្កាឈូក ក៏កើតឡើងដល់ប្រេតទាំងនោះ ។ ប្រេតទាំងនោះក៏មុជ និងផឹកក្នុងស្រះបោក្ខរណីនោះ រម្ងាប់សេចក្តីក្រវល់ក្រវាយ សេចក្តីលំបាក និងបាត់សេចក្តីស្រេកឃ្លានបាន ហើយមានសម្បុរដូចមាស ។

លំដាប់នោះ ព្រះរាជាទ្រង់ថ្វាយបាយយាគូ របស់ទំពា របស់ធាន់ហើយឧទ្ទិស ។ រំពេចនោះឯង បាយយាគូ របស់ទំពារ និងរបស់ស៊ីដែលជាទិព្វ ក៏កើតឡើងដល់ប្រេតទាំងនោះ ។ ប្រេតទាំងនោះ ក៏នាំគ្នាបរិភោគរបស់ទិព្វទាំងនោះ មានឥន្ទ្រិយ៍ផូរផង់ ។

លំដាប់នោះ ព្រះរាជាទ្រង់ថ្វាយសំពត់ និងសេនាសនៈ ឧទ្ទិស គ្រឿង

អលង្ការផ្សេងៗ មានសំពត់ទិព្វ យានទិព្វ ប្រាសាទទិព្វ គ្រឿងក្រាលទិព្វ និងទីដេកទិព្វជាដើម ក៏កើតឡើងដល់ប្រេតទាំងនោះ ។ សម្បត្តិសួម្បីទាំងនោះរបស់ប្រេតពួកនោះ ប្រាកដគ្រប់យ៉ាងដោយប្រការណា ព្រះមានព្រះ-ភាគក៏ទ្រង់អធិដ្ឋាន (ឲ្យព្រះរាជាទ្រង់ឃើញ) ដោយប្រការនោះ ។ ព្រះរាជាទ្រង់ពេញព្រះហឫទ័យក្រៃលែង ។ តអំពីនោះ ព្រះមានព្រះភាគទ្រង់សោយស្រេចហើយ ទ្រង់បានហាមកត្តាហារហើយ ទើបត្រាស់ព្រះគាថាទាំងនេះថា **តិរោកុឌ្ឌេសុ តិដ្ឋន្តិ** (ពួកប្រេត... ឈរនៅទីខាងក្រៅជញ្ជាំងផ្ទះ) ជាដើម ដើម្បីទ្រង់អនុមោទនាដល់ព្រះបាទមគធរដ្ឋ ។

ដោយពាក្យមានប្រមាណប៉ុណ្ណោះ មាតិកានេះថា ដែលខ្ញុំប្រកាសធ្វើព្រះសូត្រនោះទាំងអស់ថា តិរោកុឌ្ឌសូត្រ អ្នកណាប្រកាស ប្រកាសក្នុងទីណា ប្រកាសកាលណា ប្រកាសព្រោះហេតុអ្វី (តាមលំដាប់) ក៏ជាការពោលហើយដោយសង្ខេប និងដោយពិស្តារ ។

## ពណ៌នាគាថាទី ១

ឥឡូវនេះ នឹងពណ៌នាសេចក្តីនៃតិរោកុឌ្ឌសូត្រនេះ តាមលំដាប់ត

ទៅ គឺ ទីនពណ៌នាសេចក្តីក្នុងគាថាដំបូងមុន ។ ចំណែកខាងក្រៅនៃជញ្ជាំងទាំងឡាយ ហៅថា **តិរោកុឌ្ឌៈ** ។ បទថា **តិដ្ឋន្តិ (ឈរ)** ជាពាក្យពោលដល់ឥរិយាបថឈរ ព្រោះហាមឥរិយាបថអន្ទ្រយជាដើម ។ ព្រោះហេតុនោះ ព្រះមានព្រះភាគ ទើបត្រាស់ដល់ពួកប្រេតដែលឈរនៅក្នុងទីចំណែកដទៃរបស់ជញ្ជាំងផ្ទះទុក សូម្បីក្នុងទីនេះថា **តិរោកុឌ្ឌេសុ តិដ្ឋន្តិ (ឈរនៅខាងក្រៅជញ្ជាំងផ្ទះ)** ដូចដែលលោកពោលដល់អ្នកសំដែងឫទ្ធិផ្សេងៗ ដែលទៅឈរនៅក្នុងចំណែកនៃកំពែង និងចំណែកដទៃនៃភ្នំថា ទៅខាងក្រៅកំពែង ក្រៅភ្នំ មិនទើសទាក់ ដូច្នោះ ។ ក្នុងបទថា **សន្ធិសិង្ឃាដកេសុ ច** នោះ ផ្លូវបែកជា ៤ ឬសូម្បីទីតនៃផ្ទះ ដែលតជញ្ជាំង និងស៊ុបន្ទួច លោកហៅថា **សន្ធិ** ។ ផ្លូវបែកជា ៣ លោកហៅថា **សិង្ឃាដកៈ** ។ ព្រះមានព្រះភាគទ្រង់ធ្វើពាក្យនោះទុកដូចគ្នា ភ្ជាប់ជាមួយពាក្យដើម ទើបត្រាស់ថា **សន្ធិសិង្ឃាដកេសុ ច** ។ បទថា **ទ្វារពាហាសុ តិដ្ឋន្តិ (ឈរនៅជិតទ្វារផ្ទះ)** បានដល់ ឈរអែបទ្វារស្រុក ទ្វារព្រះនគរ និងទ្វារផ្ទះ ។ ផ្ទះញាតិពីមុនក្តី ផ្ទះរបស់ខ្លួនដែលធ្លាប់គ្រប់គ្រងជាម្ចាស់ក្តី ឈ្មោះថា ផ្ទះ

របស់ខ្លួន ។ ក្នុងបទថា **អាគន្ត្វាន សកំ ឃរំ** (មកកាន់ផ្ទះរបស់ខ្លួន) ។ ព្រោះហេតុដែលពួកប្រេតទាំងនោះ នាំគ្នាមកដោយគិតថា ជាផ្ទះរបស់ខ្លួន ដូច្នោះ ព្រះមានព្រះភាគ ទើបត្រាស់ដល់ផ្ទះទាំងពីរនោះថា "មកកាន់ផ្ទះរបស់ខ្លួន" ។

## ពណ៌នាគាថាទី ២

ព្រះមានព្រះភាគ កាលទ្រង់សំដែងដល់ព្រះរាជា ដល់ប្រេតជាច្រើន ដែលមកកាន់ព្រះនិវេសន៍របស់ព្រះបាទពិម្ពិសារ ដែលជាផ្ទះរបស់ញាតិអំពីមុន សូម្បីខ្លួនមិនធ្លាប់គ្រប់គ្រងមកអំពីមុន ដោយសម្គាល់ថា ជាផ្ទះរបស់ខ្លួន ឈរនៅខាងក្រៅជញ្ជាំងផ្ទះ ត្រង់ផ្លូវបែកជា ៤ និងផ្លូវបែកជា ៣ និងទ្វារស្រុក សោយផលនៃឥស្សា និងសេចក្តីកំណាញ់ ពួកខ្លះមានពុកមាត់ និងសក់វែង មុខខ្មៅ មានអវយវៈធំតូចមិនគ្រប់ រូបរាងស្គាំងស្គម ស្បែកគគ្រើម ខ្មៅ ដូចដើមត្នោតត្រូវភ្លើងព្រៃឆេះឈរនៅក្នុងទីនោះៗ ពួកខ្លះមានខ្លួនត្រូវអណ្តាតភ្លើងដែលឆេះតាំងអំពីពោះចេញតាមមាត់ ដូចឈើពួតភ្លើងដែលពួតគ្នា ព្រោះសេចក្តីស្រេកឃ្លានឆេះរោលហើយ ពួកខ្លះមិនបាន

រសជាតទៅក្រៅអំពីរស គឺ សេចក្តីស្រេកឃ្លាន ព្រោះកាលបានទឹក និងបាយ ក៏មិនអាចបរិភោគបានតាមត្រូវការ ព្រោះមានរន្ធបំពង់កតូចប៉ុនគូថម្ជុល និងព្រោះមានពោះធំដូចភ្នំ ពួកខ្លះមានរាងកាយមិនគួរមើល ប្លែកៗ និងគួរខ្លាចក្រៃលែង បានទឹកខ្ទុះឈាម ខ្ទុះខួរឆ្អឹងជាដើម ដែលហូរចេញពីដំបៅបួសដែលបែកធ្លាយនៃគ្នានិងគ្នា ឬរបស់សត្វដទៃ ក្រេបជញ្ជក់ដូចទឹកអម្រឹត ទើបត្រាស់ថា ៖

ពួកប្រេតមកកាន់ផ្ទះរបស់ខ្លួន ឈរនៅខាងក្រៅជញ្ជាំង
ផ្ទះខ្លះ ឈរនៅត្រង់ផ្លូវបែកជា ៤ និងផ្លូវបែកជា ៣ ខ្លះ
ឈរនៅជិតទ្វារផ្ទះខ្លះ ។

កាលទ្រង់សំដែងនូវកម្ម ដែលប្រេតទាំងនោះធ្វើមកហើយ ជាទារុណកម្ម ទើបត្រាស់គាថាទី ២ ថា **បហូតេ អន្នបានម្ហិ** (កាលបាយ និងទឹក... **មានដ៏ច្រើន**) ជាដើម ។

បណ្តាបទទាំងនោះ បទថា **បហូតេ** (ដ៏ច្រើន) បានដល់ មិនតិច ។ លោកអធិប្បាយថា ច្រើន គឺ តាមសេចក្តីត្រូវការ ។ យក ព ជា ប

បានក្នុងប្រយោគជាដើមថា **ពហុ សន្តោ ន ភរតិ** (អ្នកមានទ្រព្យច្រើន ក៏មិនចិញ្ចឹមបីបាច់) ។ តែអាចារ្យពួកខ្លះសូត្រថា **ពហូតេ** ក៏មាន **ពហូកេ** ក៏មាន ។ បាឋៈទាំងនោះ ជាបាឋៈដែលសរសេរដោយសេចក្តីក្ងាំងក្ងាត់ ។ បាយផង ទឹកផង ឈ្មោះថា បាយនិងទឹក របស់ទំពារស៊ីផង របស់ស៊ីផង ឈ្មោះថា របស់ទំពារ និងរបស់ស៊ី ។ ព្រះមានព្រះភាគទ្រង់សំដែងអាហារ ៤ យ៉ាង គឺ របស់ស៊ី របស់ផឹក របស់ទំពារ និងរបស់លិទ្ធភក្ស ដោយពាក្យនេះ ។ បទថា **ឧបដ្ឋិតេ** ប្រែថា ដែលគេចូលតាំងទុក ។ លោកអធិប្បាយថា ចាត់ចែង តុបតែង រួបរួម ។ បទថា **ន តេសំ កោចិ សរតិ សត្តានំ** (ញាតិណាៗ របស់ប្រេតទាំងនោះ ក៏រឭកមិនបាន ព្រោះកម្មរបស់សត្វទាំងឡាយជាបច្ច័យ) សេចក្តីថា កាលសត្វទាំងនោះកើតក្នុងបិត្តិវិស័យ នរណាៗ មិនថា មាតាបិតា ឬបុត្រ ក៏មិនរឭកដល់ ។ ព្រោះហេតុអ្វី? **ព្រោះកម្មរបស់សត្វបច្ច័យ** គឺ ព្រោះកម្ម គឺ សេចក្តីកំណាញ់ ដែលខ្លួនធ្វើ មានការមិនឲ្យ និងបដិសេធការឲ្យជាដើមជាបច្ច័យ ព្រោះថា កម្មរបស់សត្វទាំងនោះ មិនឲ្យញាតិរឭកដល់ ។

## ពណ៌នាគាថាទី ៣

ព្រះមានព្រះភាគ កាលទ្រង់សំដែងដល់ការមិនមានត្រឹមតែការរឭកដល់ពួកញាតិរបស់ខ្លួន របស់ពួកប្រេតទាំងនោះ ដែលមានសេចក្តីសង្ឃឹមចំពោះញាតិទាំងឡាយថា កាលបាយ និងទឹកជាដើម សូម្បីមិនមែនតិចដែលពួកញាតិចូលទៅតាំងទុក (ក្នុងសង្ឃ) គួរញាតិទាំងឡាយនឹងគប្បីឲ្យអ្វីៗ ឧទ្ទិសចំពោះពួកយើងខ្លះ ដូច្នេះ ព្រោះកម្មដែលប្រេតទាំងនោះធ្វើហើយ ឲ្យផលដុតរោលក្រៃលែងជាបច្ច័យយ៉ាងនេះ ទើបត្រាស់ថា ៖

*កាលបាយ និងទឹក របស់ទំពារ របស់ស៊ីដ៏ច្រើន ដែល*
*គេចូលទៅតាំងទុក ញាតិណាៗ របស់សត្វទាំងនោះ ក៏*
*រឭកមិនបាន ព្រោះកម្មរបស់សត្វទាំងឡាយជាបច្ច័យ ។*

កាលទ្រង់សរសើរទាន ដែលព្រះរាជាថ្វាយឧទ្ទិសចំពោះញាតិទាំងឡាយរបស់ព្រះរាជាដែលកើតក្នុងបិត្តិវិស័យ (កើតជាប្រេត) ទៀត ទើបត្រាស់ព្រះគាថាទី ៣ ថា **ឯវំ ទទន្តិ ញាតីនំ** (ជនទាំងនោះរមែងឲ្យ... ដើម្បីញាតិទាំងឡាយយ៉ាងនេះ) ជាដើម ។

បណ្តាបទទាំងនោះ បទថា **ឯវំ** ជាពាក្យឧបមា ។ បទថា **ឯវំ** នោះ សម្ព័ន្ធអត្ថ ២ ន័យ គឺ ៖

១.ជនពួកណាមានសេចក្តីករុណា ជនពួកនោះរមែងឲ្យបាយ និងទឹកជាដើមដើម្បីញាតិទាំងឡាយ កាលញាតិណាៗ សូម្បីព្រេកមិនបាន ព្រោះកម្មរបស់សត្វទាំងនោះជាបច្ច័យយ៉ាងនេះ ។

២.ថ្វាយព្រះពរ ជនពួកណាមានសេចក្តីករុណា ជនពួកនោះ រមែងឲ្យបាយ និងទឹកដ៏ស្អាត ប្រណីត ជាកប្បិយ: (របស់គួរ) តាមកាល ដើម្បីញាតិទាំងឡាយ ដូចដែលមហាបពិត្រថ្វាយទាន ដូច្នោះ ។

បណ្តាបទទាំងនោះ បទថា **ទទន្តិ** (រមែងឲ្យ) បានដល់ ឲ្យ ឧទ្ទិសបង្អោនឲ្យ ។ បទថា **ញាតីនំ** (ដើម្បីញាតិទាំងឡាយ) បានដល់ បុគ្គលដែលជាប់ទាក់ទងខាងមាតា និងខាងបិតា ។ បទថា **យេ** (ពួកណា) បានដល់ ពួកណាមួយ មិនថា បុត្រ ធិតា ឬបងប្អូន ។ បទថា **ហោន្តិ** ប្រែថា រមែងជា ។ បទថា **អនុកម្បកា** (ជាអ្នកអនុគ្រោះ) បានដល់ អ្នកបំណងនូវប្រយោជន៍ គឺ អ្នកស្វែងរកប្រយោជន៍ ។ បទថា **សុចឹ** (ដែល

ស្អាត) បានដល់ គ្មានមន្ទិល គួរសរសើរ រីករាយ ជាធម៌ បានមកដោយធម៌ ។ បទថា **បណីតំ** (ប្រណីត) បានដល់ ខ្ពង់ខ្ពស់ ប្រសើរបំផុត ។ បទថា **កាលេន** (តាមកាល) បានដល់ តាមកាលដែលពួកប្រេតជាញាតិមកឈរខាងក្រៅជញ្ជាំងផ្ទះជាដើម ។ បទថា **កប្បិយំ** (ដែលសមគួរ) បានដល់ គួរ សមគួរ សមគួរបរិភោគរបស់ព្រះអរិយៈទាំងឡាយ ។ បទថា **បានភោជនំ** (បាយ និងទឹក) បានដល់ បាយផង ទឹកផង ឈ្មោះថា បាយ និងទឹក ។ ក្នុងទីនេះ លោកបំណងយកទេយ្យធម៌គ្រប់យ៉ាង ដោយយកបាយ និងទឹកឡើងមកជាប្រធាន ។

## ពណ៌នាគាថាទី ៤ សម្ព័ន្ធជាមួយគាថាទី ៣

ព្រះមានព្រះភាគ កាលទ្រង់សរសើរបាយ និងទឹក ដែលព្រះបាទមគធៈទ្រង់ថ្វាយដើម្បីអនុគ្រោះពួកញាតិដែលជាប្រេត យ៉ាងនេះ ទើបត្រាស់ថា ៖

ជនពួកណាមានសេចក្តីករុណា ជនពួកនោះ រមែងឲ្យបាយ<br>និងទឹកដ៏ស្អាត ប្រណីត ជារបស់គួរតាមកាលយ៉ាងនេះ ។

កាលទ្រង់សំដែងនូវទានដែលឲ្យហើយ ដែលឲ្យដើម្បីញាតិទាំងនោះទៀត ទើបត្រាស់កន្លះគាថាទី ៤ ខាងដើម ថា ឥទំ វោ ញាតីនំ ហោតុ (សូមទាននេះឯង ចូរមានដល់ញាតិទាំងឡាយ) ជាដើម ។ គប្បីសម្ពន្ធសេចក្តីជាមួយកន្លះគាថាខាងដើមនៃគាថាទី ៣ ថា

ជនពួកណាមានសេចក្តីករុណា ជនពួកនោះរមែងឲ្យបាយ
និងទឹក យ៉ាងនេះថា សូមទាននេះ ចូរមានដល់ញាតិទាំង
ឡាយ សូមញាតិទាំងឡាយ ចូរមានសេចក្តីសុខចុះ ។

ព្រោះហេតុនោះ អាការដែលគប្បីឲ្យ គឺ ទ្រង់ធ្វើហើយដោយ ឯវំសព្ទ ដែលមានអត្ថថា អាការ ក្នុងពាក្យនេះថា ជនទាំងនោះរមែងឲ្យដោយអាការយ៉ាងនេះថា សូមទាននេះឯង ចូរមានដល់ញាតិទាំងឡាយ មិនមែនដោយអាការយ៉ាងដទៃ ។

បណ្តាបទទាំងនោះ បទថា ឥទំ (នេះ) ជាពាក្យសំដែងដល់ទេយ្យធម៌ ។ បទថា វោ ជានិបាតតែម្យ៉ាង មិនមែនឆដ្ឋីវិភត្តិ ដូចក្នុងប្រយោគជាដើមយ៉ាងនេះថា កច្ចិ បន វោ អនុរុទ្ធា សមគ្គា សម្មោទមានា និងថា

*យេហិ នោ អរិយា ។ បទថា ញាតីនំ ហោតុ (ចូរមានដល់ញាតិទាំងឡាយ) សេចក្ដីថា ចូរមានដល់ញាតិទាំងឡាយដែលកើតក្នុងបិត្តិវិស័យ ។ បទថា សុខិតា ហោន្តុ ញាតយោ (សូមញាតិទាំងឡាយ ចូរមានសេចក្ដីសុខចុះ) សេចក្ដីថា សូមពួកញាតិដែលចូលដល់បិត្តិវិស័យទាំងនោះ ចូរជាអ្នកបាន ដោយផលទាននេះ មានសេចក្ដីសុខចុះ ។*

## ពណ៌នាវគ្គខាងចុងរបស់គាថាទី ៤

## សម្ព័ន្ធជាមួយវគ្គខាងដើមរបស់គាថាទី ៥

*ព្រះមានព្រះភាគ កាលទ្រង់សំដែងនូវទានដែលញាតិ គប្បីឲ្យដល់ញាតិទាំងឡាយដែលចូលដល់បិត្តិវិស័យ ទើបត្រាស់ថា សូមទាននេះឯង ចូរមានដល់ញាតិទាំងឡាយ សូមញាតិទាំងឡាយចូរមានសេចក្ដីសុខ ដូច្នេះ ព្រោះហេតុដែលព្រះមានព្រះភាគត្រាស់ថា សូមទាននេះឯង ចូរមានដល់ញាតិទាំងឡាយ កម្មដែលបុគ្គលម្នាក់ធ្វើហើយ រមែងមិនឲ្យផលដល់បុគ្គលម្នាក់ទៀត តែវត្ថុនោះ ដែលញាតិឧទ្ទិសឲ្យយ៉ាងនោះឯង រមែងជាបច្ច័យដល់កុសលកម្មរបស់ញាតិទាំងឡាយ ។ ដូច្នោះ កាលទ្រង់សំដែងដល់កុសល-*

កម្ម ដែលឲ្យកើតផលទាន់ពេលដល់ញាតិទាំងឡាយ ព្រោះវត្ថុនោះៗ ឯង ទៀត ទើបត្រាស់កន្លះនៃគាថាទី ៤ ខាងក្រោយថា **តេ ច តត្ថ** (ចំណែក **ពួកប្រេតដែលជាញាតិទាំងនោះ... ក្នុងទីឲ្យទាន)** និងកន្លះនៃគាថាទី ៥ ខាង ដើមថា **បហូតេ អន្នបានម្ហិ (ក្នុងបាយ និងទឹកដ៏ច្រើន)** ។

កន្លះខាងដើម និងកន្លះខាងចុងនៃគាថាទាំងនោះ មានអត្ថថា លោក អធិប្បាយទុកថា ប្រេតដែលជាញាតិទាំងនោះ មកដោយជុំវិញ មករួមគ្នា ប្រជុំនៅក្នុងទីកន្លែងមួយ ក្នុងទីដែលញាតិឲ្យទាននោះ ។ លោកអធិប្បាយ ទុកថា ប្រេតទាំងនោះ មកដោយជុំវិញ មករួមគ្នា មកព្រមគ្នា ដើម្បី សេចក្តីត្រូវការ យ៉ាងនេះថា ញាតិទាំងឡាយរបស់យើង និងឧទ្ទិសទាន នេះ ដើម្បីប្រយោជន៍ដល់យើងទាំងឡាយ ។ បទថា **ពហូតេ អន្នបានម្ហិ (ក្នុងបាយ និងទឹកដ៏ច្រើន)** សេចក្តីថា ក្នុងបាយ និងទឹកជាច្រើន ដែលញាតិ ឧទ្ទិសឲ្យដើម្បីខ្លួន ។ បទថា **សក្កច្ចំ អនុមោទរេ (រមែងអនុមោទនាដោយ គោរព)** សេចក្តីថា ប្រេតទាំងនោះជឿផលកម្ម មិនលះសេចក្តីកោតក្រែង មានចិត្តមិនញាប់ញ័រ រមែងត្រេកអរអនុមោទនា កើតបីតិ និងសោមនស្ស

ថា ទាននេះចូរមានផល ដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខ ដល់យើងទាំងឡាយ ។

## ពណ៌នាវគ្គខាងចុងរបស់គាថាទី ៥ សម្ព័ន្ធជាមួយវគ្គខាងដើមរបស់គាថាទី ៦

ព្រះមានព្រះភាគ កាលទ្រង់សំដែងដល់កុសលកម្មឲ្យផល កើតទាន់ពេលដល់ញាតិទាំងឡាយ ដែលចូលដល់បិត្តិវិស័យ យ៉ាងនេះ ទើបត្រាស់ថា ៖

ចំណែកពួកប្រេតដែលជាញាតិទាំងនោះ មកព្រមគ្នាហើយ
ជួបជុំក្នុងទីឲ្យទាន រមែងអនុមោទនាដោយគោរព ក្នុងបាយ
និងទឹកដ៏ច្រើននោះ ។

កាលទ្រង់សំដែងអាការរីករាយ ប្រារព្ធញាតិទាំងឡាយរបស់ប្រេតទាំងនោះ បានសោយផលនៃកុសលកម្មដែលកើតឡើងព្រោះអាស្រ័យពួកញាតិទៀត ទើបត្រាស់កន្លះនៃគាថាទី ៥ ខាងក្រោយថា **ចិរំ ជីវន្តុ (ចូរមានជីវិតយឺនយូរ)** និងកន្លះនៃគាថាទី ៦ ខាងដើមថា **អម្ហាកញ្ច កតា បូជា**

(ទាំងការបូជា ដែលញាតិជាទាយកក៏បានធ្វើដល់ពួកយើងហើយ) ។

កន្ទុះខាងចុង និងកន្ទុះខាងដើមនៃគាថាទាំងនោះ មានសេចក្តីថា បទថា ចិរំ ជីវន្តុ (ចូរមានជីវិតយឺនយូរ) បានដល់ មានជីវិតនៅយូរ មានអាយុវែង ។ បទថា នោ ញាតី ប្រែថា ញាតិទាំងឡាយរបស់ពួកយើង ។ បទថា យេសំ ហេតុ (ព្រោះហេតុនៃញាតិពួកណា) បានដល់ ព្រោះអាស្រ័យញាតិពួកណា ព្រោះហេតុនៃញាតិពួកណា ។ បទថា លភាម្ហសេ ប្រែថា បាន ។ ពួកប្រេតពោលអាងសម្បត្តិដែលខ្លួនបានក្នុងខណៈនោះ ។

ពិតណាស់ ទក្ខិណារមែងសម្រេចផល គឺ ឲ្យកើតផលក្នុងខណៈនោះបាន ក៏ដោយអង្គ ៣ គឺ ព្រោះការអនុមោទនាដោយខ្លួនឯងរបស់ប្រេតទាំងឡាយ ១ ដោយការឧទ្ទិសរបស់ទាយកទាំងឡាយ ១ ដោយការដល់ព្រមនៃទក្ខិណេយ្យបុគ្គល ១ ។

បណ្តាអង្គទាំង ៣ នោះ ទាយកទាំងឡាយជាហេតុពិសេស ព្រោះហេតុនោះ ប្រេតទាំងឡាយទើបពោលថា រមែងបានព្រោះហេតុនៃញាតិពួក

ណា ។ បទថា **អម្ហាកញ្ច កតា បូជា (ទាំងការបូជា ដែលញាតិអ្នកជាទាយកក៏បានធ្វើដល់ពួកយើងហើយ)** សេចក្តីថា និងញាតិទាំងឡាយដែលឧទ្ទិសទាននេះ យ៉ាងនេះថា សូមទាននេះ ចូរមានដល់ញាតិទាំងឡាយរបស់យើង ដូច្នេះ ឈ្មោះថា ធ្វើការបូជាពួកយើងហើយ ។ បទថា **ទាយកា ច អនិប្ផលា (និងទាយកទាំងឡាយរមែងមិនគ្មានផល)** សេចក្តីថា កម្មដែលសម្រេចមកអំពីការបរិច្ចាគ ដែលទាយកធ្វើហើយក្នុងសន្តានណា ទាយកទាំងឡាយ ឈ្មោះថា មិនឥតផល ក៏ព្រោះកម្មនោះឲ្យផលក្នុងសន្តាននោះប៉ុណ្ណោះ ។ ក្នុងបទនេះ អ្នកជំទាស់ពោលថា ញាតិទាំងឡាយដែលចូលដល់បិត្តិវិស័យ រមែងបានប៉ុណ្ណោះឬ? ឬថា សូម្បីបុគ្គលដទៃៗ ក៏បាន ។ សូមអធិប្បាយដូច្នេះ ព្រះមានព្រះភាគ ត្រូវព្រាហ្មណ៍ឈ្មោះជាណុស្សោណិទូលសួរហើយ ទ្រង់ក៏បានព្យាករណ៍សេចក្តីនេះទុកដូច្នេះថា ក្នុងសេចក្តីនេះតថាគតនឹងគប្បីពោលពាក្យអ្វី ។ សមដូចដែលព្រះសង្គីតិកាចារ្យពោលទុកដូច្នេះថា ជាណុស្សោណិព្រាហ្មណ៍ទូលសួរថា ៖

បពិត្រព្រះគោតម ពួកខ្ញុំម្ចាស់ឈ្មោះថាព្រាហ្មណ៍ រមែង

ឲ្យទាន រមែងធ្វើការជឿថា ទាននេះនឹងសម្រេចផលដល់ប្រេតទាំងឡាយដែលជាញាតិសាលោហិត ប្រេតទាំងឡាយដែលជាញាតិសាហិត នឹងបរិភោគទាននេះ ។ បពិត្រព្រះគោតម ទាននោះ នឹងសម្រេចផលដល់ប្រេតទាំងឡាយដែលជាញាតិសាលោហិតខ្លះទេ ប្រេតទាំងឡាយដែលជាញាតិសាលោហិត និងបរិភោគទាននោះបានខ្លះទេ ។

ព្រះមានព្រះភាគត្រាស់តបថា ៖

ព្រាហ្មណ៍ នឹងសម្រេចផលក្នុងទីជាឋានៈ មិនសម្រេចផលក្នុងទីដែលជាអឋានៈ ។

ជាណុស្សោណិព្រាហ្មណ៍ទូលសួរថា ៖

បពិត្រព្រះគោតម ទីយ៉ាងណាជាឋានៈ ទីយ៉ាងណាជាអឋានៈ ។

ព្រះមានព្រះភាគត្រាស់តបថា ៖

ម្នាលព្រាហ្មណ៍ បុគ្គលពួកខ្លះក្នុងលោកនេះ ធ្វើបាណា-

តិបាត ។ល។ ជាមិច្ឆាទិដ្ឋិ ខាងមុខអំពីស្លាប់ព្រោះកាយបែកធ្លាយ គេរមែងចូលដល់នរក ។ អាហារណារបស់ពួកសត្វនរក គេរមែងញុំាងជីវិតឲ្យប្រព្រឹត្តទៅក្នុងនរកនោះ ដោយអាហារនោះ គេក៏តាំងនៅបានក្នុងនរកនោះដោយអាហារនោះ ។

ម្នាលព្រាហ្មណ៍ ទាននោះរមែងមិនសម្រេចផលដល់សត្វដែលតាំងនៅក្នុងនរកណា នរកនោះឯង ឈ្មោះថាអឋាន: ។

ម្នាលព្រាហ្មណ៍ បុគ្គលពួកខ្លះក្នុងលោកនេះ ធ្វើបាណាតិបាត ។ល។ ជាមិច្ឆាទិដ្ឋិ ខាងមុខអំពីស្លាប់ ព្រោះកាយបែកធ្លាយ គេចូលដល់កំណើតសត្វតិរច្ឆាន ។ អាហារឯណារបស់ពួកសត្វដែលកើតក្នុងកំណើតតិរច្ឆាន គេរមែងញុំាងជីវិតឲ្យប្រព្រឹត្តទៅក្នុងកំណើតសត្វតិរច្ឆាននោះ ដោយអាហារនោះ រមែងតាំងនៅបានក្នុងកំណើតសត្វតិរិច្ឆាននោះ

ដោយអាហារនោះ ។

ម្នាលព្រាហ្មណ៍ ទាននោះ រមែងមិនសម្រេចផលដល់សត្វតាំងនៅក្នុងកំណើតសត្វតិរច្ឆានណា កំណើតសត្វតិរច្ឆាននោះឯង ឈ្មោះថា អឋានៈ ។

ម្នាលព្រាហ្មណ៍ បុគ្គលពួកខ្លះក្នុងលោកនេះ វៀរចាកបាណាតិបាត ។ល។ ជាសម្មាទិដ្ឋិ ខាងមុខអំពីស្លាប់ព្រោះកាយបែកធ្លាយ គេរមែងចូលដល់ភាពជាសំឡាញ់របស់មនុស្ស ។ល។ ដល់នូវភាពជាសំឡាញ់របស់ពួកទេវតា អាហារណារបស់ពួកទេវតា គេញុំាងជីវិតឲ្យប្រព្រឹត្តទៅក្នុងទេវលោកនោះ ដោយអាហារនោះ គេតាំងនៅបានក្នុងទេវលោកនោះ ដោយអាហារនោះ ។

ម្នាលព្រាហ្មណ៍ ទាននោះ រមែងមិនសម្រេចផលដល់សត្វដែលតាំងនៅក្នុងទេវលោកណា ទេវលោកនេះឯងក៏ឈ្មោះថា អឋានៈ ។

ម្នាលព្រាហ្មណ៍ តែថា បុគ្គលក្នុងលោកនេះ ធ្វើបាណាតិបាត ។បេ។ ជាមិច្ឆាទិដ្ឋិ ខាងមុខអំពីស្លាប់ទៅ ព្រោះកាយបែកធ្លាយ គេក៏រមែងចូលដល់បិត្តិវិស័យ ។ អាហារណារបស់ពួកសត្វដែលចូលដល់បិត្តិវិស័យ គេរមែងញុំាងជីវិតឲ្យប្រព្រឹត្តទៅក្នុងបិត្តិវិស័យនោះ ដោយអាហារនោះ គេតាំងនៅបានក្នុងបិត្តិវិស័យនោះ ដោយអាហារនោះ ។ ក៏ឬថា ពួកមិត្រសំឡាញ់ ឬពួកញាតិសាលោហិត បង្អោនទានណាពីមនុស្សលោកនេះទៅឲ្យដល់គេ គេរមែងញុំាងជីវិតឲ្យប្រព្រឹត្តទៅក្នុងបិត្តិវិស័យនោះ ដោយទាននោះ គេរស់នៅបានក្នុងបិត្តិវិស័យនោះ ដោយទាននោះ ។ ម្នាលព្រាហ្មណ៍ ទាននោះឯង រមែងសម្រេចផលដល់សត្វអ្នកតាំងនៅក្នុងបិត្តិវិស័យណា បិត្តិវិស័យនេះឯង ឈ្មោះថា ឋានៈ ។

ជាណុស្សោណិព្រាហ្មណ៍ទូលសួរថា ៖

បពិត្រព្រះគោតម ប្រសិនបើប្រេតដែលជាញាតិសា-
លោហិតមិនចូលដល់ឋានៈនោះ នរណាហ្ន៎នឹងបរិភោគទាន
នោះ ។

ព្រះមានព្រះភាគត្រាស់តបថា ៖

ម្នាលព្រាហ្មណ៍ ពួកប្រេតដែលជាញាតិសាលោហិត
សូម្បីពួកដទៃរបស់គេដែលចូលដល់ឋានៈនោះ បរិភោគ
ទាននោះឯង ។

ជាណុស្សោណិព្រាហ្មណ៍ទូលសួរថា ៖

បពិត្រព្រះគោតម ទាំងប្រេតដែលជាញាតិសាលោ-
ហិតអ្នកនោះ ក៏មិនចូលដល់ឋានៈនោះ ទាំងពួកប្រេតដែល
ជាញាតិសាលោហិតសូម្បីពួកដទៃរបស់គេ ក៏មិនចូលដល់
ឋានៈនោះ នរណាហ្ន៎នឹងបរិភោគទាននោះ ។

ព្រះមានព្រះភាគត្រាស់តបថា ៖

ម្នាលព្រាហ្មណ៍ ឋានៈដែលនឹងគប្បីវៀរចាកពួកញាតិ

សាលោហិតអ្នកស្លាប់ទៅហើយអស់កាលយូរ ដូច្នេះ មិន
មែនជាឋានៈ មិនមែនឱកាសដែលនឹងមានបាន ប៉ុន្តែថាសូម្បី
ទាយកអ្នកឲ្យ រមែងមិនមែនថា គ្មានផលទេ ព្រាហ្មណ៍ ។

ពណ៌នាវគ្គខាងចុងរបស់គាថាទី ៦

សម្ព័ន្ធជាមួយគាថាទី ៧

ព្រះមានព្រះភាគ កាលទ្រង់សរសើរ ព្រោះអាស្រ័យសម្បត្តិរបស់ពួកញាតិក្នុងជាតិមុនរបស់ព្រះបាទមគធរដ្ឋ ដែលចូលដល់បិត្តិវិស័យ ទើបទ្រង់សំដែងថា សូមថ្វាយព្រះពរ ព្រះញាតិរបស់មហាបពិត្រទាំងនេះរីករាយនាំគ្នាសរសើរក្នុងទានសម្បទានេះ ទើបត្រាស់ថា ៖

ពួកប្រេតនាំគ្នារីករាយថា ពួកយើងបានសម្បត្តិ ព្រោះ
ហេតុនៃញាតិពួកណា សូមញាតិទាំងនោះរបស់ពួកយើងចូរ
មានជីវិតរស់នៅអស់កាលយូរ ទាំងការបូជាដែលញាតិជា
ទាយកក៏បានធ្វើដល់ពួកយើងហើយ ទាំងទាយកទាំងឡាយ
អ្នកឲ្យក៏មានផល ដូច្នេះ ។

លុះទ្រង់សំដែងការមិនមានហេតុ ដែលឲ្យបានសម្បត្តិយ៉ាងដទៃ មានកសិកម្ម និងគោរក្ខកម្មជាដើម របស់ពួកប្រេតដែលចូលដល់បិត្តិវិស័យទាំងនោះ និងការដែលពួកប្រេតទាំងនោះ ញ៉ាំងជីវិតឲ្យប្រព្រឹត្តទៅដោយទាន ដែលញាតិឲ្យអំពីមនុស្សលោកនេះ ទើបត្រាស់កន្លះនៃគាថាក្រោយទី ៦ ថា **ន ហិ តត្ថ កសិ អត្ថិ (ក៏ក្នុងបិត្តិវិស័យនោះមិនមានកសិកម្ម)** និងគាថាទី ៧ នេះថា **វណិជ្ជា តាទិស (ការលក់ដូរច្នោះ)** ជាដើម ។

ក្នុងគាថានោះ មានសេចក្តីពណ៌នាដូច្នេះ សូមថ្វាយព្រះពរ ក៏ក្នុងបិត្តិវិស័យនោះ មិនមានកសិកម្មណាដែលពួកប្រេតទាំងនោះ នឹងអាស្រ័យហើយបានសម្បត្តិ ។ បទថា **គោរក្ខេត្ថ ន វិជ្ជតិ (មិនមានគោរក្ខកម្មក្នុងបិត្តិវិស័យនោះ)** សេចក្តីថា មិនមែនមានកសិកម្មតែម្យ៉ាងប៉ុណ្ណោះទេ ក្នុងបិត្តិវិស័យនោះ ក៏មិនមានសូម្បីតែគោរក្ខកម្ម ដែលពួកប្រេតទាំងនោះនឹងអាស្រ័យ ហើយបានសម្បត្តិ ។ បទថា **វណិជ្ជា តាទិសី នត្ថិ (មិនមានការជួញដូរ)** សេចក្តីថា មិនមានការលក់ដូរ ដែលនឹងជាហេតុឲ្យបានសម្បត្តិរបស់ពួកប្រេតទាំងនោះ ។ បទថា **ហិរញ្ញេន កយាកយំ (ការ**

ទិញដូរដោយប្រាក់) សេចក្តីថា ក្នុងបិត្តិវិស័យនោះ មិនមានសូម្បីតែការទិញដូរដោយប្រាក់ ដែលជាហេតុឲ្យបានសម្បត្តិរបស់ពួកប្រេតទាំងនោះ ។

បទថា **ឥតោ ទិន្នេន យាបេន្តិ បេតា កាលកតា តហឹ** (អ្នកធ្វើកាលកិរិយាទៅហើយ រមែងញុំាងអត្តភាពឲ្យប្រព្រឹត្តទៅក្នុងបិត្តិវិស័យនោះ ដោយទានដែលញាតិឲ្យហើយអំពីមនុស្សនេះ) សេចក្តីថា តែពួកប្រេតរមែងញុំាងជីវិតឲ្យប្រព្រឹត្តទៅ ញុំាងអត្តភាពឲ្យប្រព្រឹត្តទៅ ដោយទានដែលពួកញាតិ ឬមិត្រសំឡាញ់ឲ្យទៅអំពីមនុស្សលោកនេះតែម្យ៉ាង ។ បទថា **បេតា** (លះទៅហើយ) បានដល់ ពួកសត្វដែលចូលដល់បិត្តិវិស័យ ។ បទថា **កាលគតា** បានដល់ ទៅតាមវេលាស្លាប់របស់ខ្លួន ។ ម្យ៉ាងទៀត បាលីថា **កាលកតា** អធិប្បាយថា ធ្វើកាលៈ ធ្វើមរណៈ ។ បទថា **តហឹ** បានដល់ ក្នុងបិត្តិវិស័យនោះ ។

## ពណ៌នាតីរគាថា គាថា ទី ៨ និងគាថាទី ៩

ព្រះមានព្រះភាគ កាលត្រាស់ថា អ្នកធ្វើកាលកិរិយាលះលោកនេះទៅហើយ រមែងញុំាងអត្តភាពឲ្យប្រព្រឹត្តទៅក្នុងបិត្តិវិស័យនោះ ដោយទាន

ដែលពួកញាតិមិត្រឲ្យហើយអំពីមនុស្សលោកនេះ យ៉ាងនេះហើយ ឥឡូវនេះ កាលទ្រង់ប្រកាសសេចក្តីនោះ ដោយការឧបមាទាំងឡាយ ទើបត្រាស់ ២ គាថានេះថា **ឧន្នតេ ឧទកំ វុដ្ឋំ** (ទឹកធ្លាក់ចុះពីទីទួល) ជាដើម ។

គាថានោះ មានសេចក្តីថា ទឹកដែលមេឃឲ្យធ្លាក់ចុះលើទីទួល លើដីគោក លើភូមិភាគទីខ្ពស់ រមែងហូរចុះកាន់ទីទាប គឺ ហូរទៅដល់ភូមិភាគទីទាប យ៉ាងណា ទានដែលញាតិមិត្រឲ្យអំពីមនុស្សលោកនេះ រមែងសម្រេចផល អធិប្បាយថា បង្កើតផល ប្រាកដផល ដល់ពួកប្រេតដូច្នោះដូចគ្នា ។ ពិតហើយ លោកនៃប្រេត ឈ្មោះថា ឋាន:ជាទីតាំងនៃសេចក្តីសម្រេចផលទាន ដូចទីទំនាប ជាឋាន:ដែលឃាំងទឹកដែលហូរមក ។ ដូចដែលត្រាស់ទុកថា ម្នាលព្រាហ្មណ៍ ទាននោះ រមែងសម្រេចផលដល់សត្វដែលតាំងនៅក្នុងបិត្តិវិស័យណា បិត្តិវិស័យនោះឯង ជាឋាន: ដូច្នេះ ដូចជាទឹកដែលហូរមកប្រជុំត្រង់ក្បាលទឹក ញកភ្នំ ប្រឡាយធំ ជង់អូរ បឹងជាទន្លេធំ រមែងញុំាងសាគរឲ្យពេញប្រៀប យ៉ាងណា ទានដែលញាតិមិត្រឲ្យទៅអំពីលោកនេះ រមែងសម្រេចផលដល់ពួកប្រេត តាមន័យដូចពោល

មកហើយ ដូច្នោះ ។

## ពណ៌នាគាថាទី ១០

ព្រះមានព្រះភាគ លុះទ្រង់ប្រកាសសេចក្ដីនេះថា អ្នកធ្វើកាលកិរិយាទៅហើយ រមែងញ៉ាំងអត្តភាពឲ្យប្រព្រឹត្តទៅក្នុងបិត្តិវិស័យនោះដោយទានដែលញាតិមិត្រឲ្យទៅអំពីមនុស្សលោកនេះ ដូច្នេះ ដោយឧបមានេះហើយ កាលទ្រង់សំដែងទៀតថា ព្រោះហេតុដែលពួកប្រេតទាំងនោះ សង្ឃឹមថាពួកយើងនឹងបានអ្វីៗ អំពីមនុស្សលោកនេះ សូម្បីនាំគ្នាមកដល់ផ្ទះញាតិហើយ ក៏មិនអាចនឹងស្រែកសូមថា សូមលោកទាំងឡាយឲ្យរបស់ឈ្មោះនេះដល់ពួកយើងចុះ ដូច្នោះ កុលបុត្រ កាលរឭកដល់វត្ថុដែលគួររឭកទាំងនេះ គប្បីឲ្យទក្ខិណា ដើម្បីពួកប្រេតទាំងនោះ ទើបត្រាស់គាថានេះថា **អទាសិ មេ (លោកបានឲ្យវត្ថុនេះដល់យើង)** ជាដើម ។

គាថានោះ មានសេចក្ដីថា កុលបុត្រកាលរឭកគ្រប់យ៉ាង យ៉ាងនេះថា លោកបានឲ្យទ្រព្យ ឬធញ្ញាហារឈ្មោះនេះដល់យើង លោកបានព្យាយាមដោយខ្លួនឯង បានធ្វើកិច្ចឈ្មោះនេះដល់យើង អ្នកឯណោះជាញាតិ

ព្រោះជាប់ទាក់ទងខាងមាតា ឬខាងបិតារបស់យើង អ្នកនោះជាមិត្រ ព្រោះអាចជួយដោយសេចក្តីស្រឡាញ់ និងអ្នកឯណោះជាមិត្រធ្លាប់លេងធូលីជាមួយគ្នានឹងយើង ដូច្នេះ គប្បីឲ្យទក្ខិណា គប្បីឲ្យទានដល់គេដែលស្លាប់ទៅហើយ ។

មានបាឋ:ដទៃទៀតថា *បេតានំ ទក្ខិណា ទជ្ជា (គប្បីឲ្យទក្ខិណាដល់ពួកប្រេត)* ។ បាឋ:នោះមានសេចក្តីថា ឈ្មោះថា គប្បីឲ្យ ព្រោះជារបស់ដែលគប្បីឲ្យ ។ របស់ដែលគប្បីឲ្យនោះ គឺអ្វី ក៏គឺទក្ខិណាដើម្បីអ្នកដែលស្លាប់ទៅហើយ ។ ដែលកុលបុត្រកាលរឭកដល់កិច្ចដែលលោកធ្វើមកអំពីមុន ដោយន័យថា លោកបានឲ្យវត្ថុនេះដល់យើងដូច្នេះជាដើមអធិប្បាយថា អ្នកតាមរឭកដល់ហើយ ។ ពាក្យនេះគប្បីជ្រាបថា ជាបឋមាវិភត្តិ ចុះក្នុងអត្ថថា បំណង ជាតតិយាវិភត្តិ ។

## ពណ៌នាគាថាទី ១១

ព្រះមានព្រះភាគ កាលទ្រង់សំដែងអនុស្សរណវត្ថុ ដែលជាហេតុក្នុងការឲ្យនូវទក្ខិណាដើម្បីពួកប្រេតទាំងឡាយយ៉ាងនេះ ទើបត្រាស់ថា ៖

បុគ្គលកាលរឭកដល់ឧបការៈដែលលោកធ្វើមកអំពី

មុនថា លោកបានឲ្យវត្ថុនេះដល់យើង បានធ្វើកិច្ចនេះដល់

យើង បានជាញាតិមិត្ររបស់យើង គប្បីឲ្យទក្ខិណាដល់

លោកដែលស្លាប់ទៅហើយ ។

ទ្រង់សំដែងបន្តទៀតថា ជនពួកណា មានការយំ និងសោកសៅជាដើមនៅខាងមុខ ព្រោះសេចក្តីស្លាប់របស់ញាតិ ឈ្មោះថា រមែងមិនឲ្យអ្វីៗ ដើម្បីប្រយោជន៍ដល់ញាតិទាំងនោះ ។ ការយំ និងការសោកសៅជាដើមនោះ របស់ជនទាំងនោះ មានតែការធ្វើខ្លួនឲ្យក្តៅក្រហាយតែម្យ៉ាងប៉ុណ្ណោះ រមែងមិនញុំាងប្រយោជន៍អ្វីៗ ឲ្យសម្រេចដល់អ្នកស្លាប់ទៅហើយ ទើបត្រាស់គាថានេះថា ន ហិ រុណ្ណំ វា (ការយំ... ក៏មិនគួរធ្វើ) ជាដើម ។

បណ្តាបទទាំងនោះ បទថា រុណ្ណំ (ការយំ) បានដល់ ការយំ កិរិយាយំ ការដែលទឹកភ្នែកធ្លាក់ចុះ ទ្រង់សំដែងការលំបាកកាយដោយបទនេះ ។ បទថា សោកោ (សេចក្តីសោក) បានដល់ សេចក្តីសោក សេចក្តីសោកសៅ ។ ទ្រង់សំដែងសេចក្តីលំបាកចិត្តដោយបទនេះ ។ បទថា យាវញ្ញា

*(យ៉ាងដទៃៗ)* បានដល់ ឬថា ក្រៅពីការយំសោកណា ។ បទថា ***បរិទេវនា (ការយំរៀបរាប់)*** បានដល់ ការយំរឿយៗ ការយំរៀបរាប់ដល់គុណ ដោយន័យថា ឱ! កូនតូចតែមួយជាទីស្រឡាញ់ ជាទីពេញចិត្ត នៅឯណា ដូច្នេះជាដើម របស់បុគ្គលដែលត្រូវសេចក្ដីវិនាសញាតិប៉ះពាល់ហើយ ។ ទ្រង់សំដែងសេចក្ដីលំបាកវាចាដោយបទនេះ ។

## ពណ៌នាគាថាទី ១២

ព្រះមានព្រះភាគ លុះទ្រង់សំដែងការយំជាដើម មិនជាប្រយោជន៍ថា ការយំ ការសោកសៅ ឬការយំយ៉ាងដទៃសូម្បីទាំងអស់ មិនមានប្រយោជន៍ដល់អ្នកស្លាប់ទៅហើយ ដែលពិត មានតែធ្វើខ្លួនឲ្យក្ដៅក្រហាយតែម្យ៉ាងប៉ុណ្ណោះ ញាតិទាំងឡាយក៏គង់នៅយ៉ាងនោះ ដូច្នេះហើយ កាលទ្រង់សំដែងដល់ទក្ខិណាដែលព្រះបាទមគធរដ្ឋទ្រង់ថ្វាយហើយ ប្រកបដោយប្រយោជន៍ទៀត ទើបត្រាស់គាថានេះថា ***អយញ្ច ខោ ទក្ខិណា (ទក្ខិណានេះឯង)*** ដូច្នេះជាដើម ។

គាថានោះ មានសេចក្ដីថា សូមថ្វាយព្រះពរ ទក្ខិណានេះឯង មហា

បពិត្រ ថ្វាយឧទ្ទិសដល់ពួកញាតិរបស់មហាបពិត្រក្នុងថ្ងៃនេះ ព្រោះហេតុដែលព្រះសង្ឃជាស្រែបុណ្យដ៏កំពូលរបស់លោក ដូច្នោះ ទក្ខិណានោះ ជាទក្ខិណាដែលទ្រង់តាំងទុកល្អហើយក្នុងព្រះសង្ឃ ទើបសម្រេចផល លោកអធិប្បាយថា សម្រេចផល ដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខ ដល់បេត-ជនអស់កាលយូរ ។ ក៏បទថា **ឧបកប្បតិ (រមែងសម្រេច)** បានដល់សម្រេចផលដោយឋានៈ គឺ សម្រេចផលក្នុងខណៈនោះទាន់ពេល មិនយូរឡើយ គឺ ប្រាកដទាន់ពេល ទើបត្រាស់ថា "ក៏សេចក្តីនោះប្រាកដច្បាស់ចំពោះព្រះតថាគតដោយឋានៈ" យ៉ាងណា ទក្ខិណាដែលសម្រេចផលឲ្យទាន់ពេល សូម្បីក្នុងទីនេះ ទើបត្រាស់ថា "សម្រេចផលដោយឋានៈ" ដូច្នោះ ។ ឋានៈណា ត្រាស់ទុកថា "ព្រាហ្មណ៍ ទាននោះ រមែងសម្រេចផលដល់សត្វដែលតាំងនៅក្នុងបិត្តិវិស័យណា បិត្តិវិស័យនោះឯង ជាឋានៈ" ដូច្នេះ ។ ទក្ខិណាដែលសម្រេចផលក្នុងឋានៈនោះ ផ្សេងដោយប្រភេទ មានឧប្បជ្ជិបា-សិកប្រេត (ប្រេតអ្នកស្រេកឃ្លាន) វន្តាសាប្រេត បរទត្តូបជីវិតប្រេត (ប្រេតអាស្រ័យការឲ្យរបស់បុគ្គលដទៃ) និងនិជ្ឈាមតណ្ហិកប្រេតជាដើម ក៏ត្រាស់ថា

រមែងសម្រេចផលដោយឋានៈ ដូចអ្នកឲ្យកហាបណៈ ក្នុងលោកគេហៅថា រមែងឲ្យដោយកហាបណៈ ដូច្នោះ ។ តែក្នុងអត្ថវិកប្បនេះ បទថា **ឧបកប្បតិ** (រមែងសម្រេច) បានដល់ ប្រាកដផល លោកអធិប្បាយថា បង្កើតផល ។

ពណ៌នាគាថាទី ១៣

ព្រះមានព្រះភាគ កាលទ្រង់សំដែងដល់ទក្ខិណា ដែលព្រះរាជាថ្វាយហើយ មានប្រយោជន៍យ៉ាងនេះ ទើបត្រាស់ថា ៖

*ក៏ទក្ខិណានេះឯង មហាបពិត្រថ្វាយហើយ ចូលទៅ*
*តាំងទុកល្អហើយក្នុងព្រះសង្ឃ រមែងសម្រេចផលដោយ*
*ឋានៈ រមែងប្រយោជន៍ដល់ប្រេតអស់កាលយូរ ដូច្នេះ ។*

ព្រោះហេតុដែលញាតិធម៌ ដែលព្រះរាជាទ្រង់បានថ្វាយទក្ខិណានេះ ទ្រង់ធ្វើកិច្ចដែលពួកញាតិគួរធ្វើដល់ពួកញាតិ ទ្រង់ធ្វើឲ្យប្រាកដដល់ជនដ៏ច្រើន ឬទ្រង់លើកជាតួយ៉ាងថា ញាតិធម៌ សូម្បីលោកទាំងឡាយក៏គប្បីបំពេញ ដោយការធ្វើកិច្ចដែលពួកញាតិគប្បីធ្វើចំពោះពួកញាតិយ៉ាងនោះដូចគ្នា មិនគប្បីធ្វើខ្លួនឲ្យក្តៅក្រហាយព្រោះការយំជាដើម ដែលគ្មានប្រយោជន៍

ការបូជាពួកប្រេត ដែលព្រះរាជាអ្នកទ្រង់ញ៉ាំងពួកប្រេតទាំងនោះឲ្យបានទិព្វ-សម្បត្តិ ទ្រង់ធ្វើហើយយ៉ាងឱឡារិក ជាមួយកម្លាំងរបស់ភិក្ខុទាំងឡាយ ដែលព្រះរាជា ទ្រង់អង្គាសភិក្ខុសង្ឃមានព្រះពុទ្ធជាប្រធានឲ្យឆ្អែតស្កប់-ស្កល់ ដោយបាយ និងទឹកជាដើម ឈ្មោះថា ទ្រង់ផ្ដើមឲ្យហើយ ដោយបុណ្យមិនមែនតិច ដែលព្រះរាជាទ្រង់ញ៉ាំងចាគចេតនា មានគុណ គឺ ការអនុគ្រោះជាដើម ជាបរិវារឲ្យកើត ក៏ទ្រង់ប្រសព្វហើយ ដូច្នោះ កាលស្ដេចញ៉ាំងព្រះរាជាឲ្យទ្រង់រីករាយដោយគុណតាមសេចក្ដីពិតទាំងនោះទៀត ទើបទ្រង់បញ្ចប់ទេសនា ដោយព្រះគាថានេះថា ៖

ញាតិធម៌ទាំងនោះ គឺ ទ្រង់សំដែងហើយ ការបូជា
អ្នកដែលស្លាប់ទៅហើយ ក៏ទ្រង់ធ្វើយ៉ាងឱឡារិក កម្លាំង
របស់ភិក្ខុទាំងឡាយ ក៏ទ្រង់ផ្ដើមឲ្យហើយ បុណ្យមិនមែន
តិច ព្រះអង្គទ្រង់ខ្វល់ខ្វាយហើយ ។

ន័យម្យ៉ាងទៀត ព្រះមានព្រះភាគទ្រង់ណែនាំព្រះរាជាដោយធម្មីកថា ដោយបទគាថានេះថា សោ ញាតិ ធម្មោ ច អយំ និទស្សិតោ (ញាតិ

**ទាំងអស់នោះ ក៏ទ្រង់សំដែងហើយ)** ។ ពិតហើយ ការសំដែងញាតិធម៌នេះឯង ជាការបង្ហាញរឿយៗ ក្នុងប្រការនេះ ។ ទ្រង់ណែនាំដោយគាថានេះថា **បេតាន បូជា ច កតា ឧឡារា (ការបូជាអ្នកស្លាប់ទៅហើយ ក៏ទ្រង់ធ្វើយ៉ាងឧឡារ)** ។ ពិតហើយ ការសរសើរថា **យ៉ាងឧឡារ** ក៏ជាការណែនាំដោយការបូជារឿយៗ ក្នុងប្រការនេះ ។ ទ្រង់ឲ្យអាចហានដោយបទគាថានេះថា **ពលញ្ច ភិក្ខូនមនុប្បទិន្នំ (កម្លាំងរបស់ភិក្ខុទាំងឡាយក៏ទ្រង់បំពេញឲ្យហើយ)** ។ ពិតណាស់ ការបំពេញកម្លាំងដល់ភិក្ខុទាំងឡាយក៏ជាទានយ៉ាងនេះ (ទានមប៉្យាង) ក្នុងសេចក្តីនេះ ។ ពាក្យថា **ទ្រង់បំពេញកម្លាំងឲ្យ** ជាការដាស់ឲ្យអាចហាន ដោយការបន្ថែមឧស្សាហៈដល់ព្រះរាជានោះ ។ ទ្រង់ឲ្យរីករាយដោយបទគាថានេះថា **តុម្ហេហិ បុញ្ញំ បសុតំ អនប្បកំ (បុណ្យមិនមែនតិច ព្រះអង្គទ្រង់ខ្វល់ខ្វាយហើយ)** ។ ពិតហើយ ការរឭកដល់ការប្រសព្វបុណ្យនោះឯង គប្បីជ្រាបថា ជាការឲ្យកើតសេចក្តីរីករាយ ព្រោះញុំាងសេចក្តីរីករាយឲ្យកើតឡើង ដោយការពណ៌នាគុណតាមដែលសេចក្តីពិតដល់ព្រះរាជាក្នុងប្រការនេះ ។

ចប់ទេសនា ការសម្រេចធម៌បានមានដល់សត្វ ៨៤.០០០ ដែលសង្វេគព្រោះការពណ៌នាទោសនៃការចូលដល់បិត្តិវិស័យ ហើយតាំងសេចក្តីព្យាយាមដោយឧបាយ ។ សូម្បីថ្ងៃស្អែកឡើង ព្រះមានព្រះភាគ ក៏ទ្រង់សំដែងតិរោកុឌ្ឌសូត្រនេះឯង ដល់ទេវតា និងមនុស្សទាំងឡាយ ។ ការត្រាស់ដឹងធម៌យ៉ាងនោះ បានមានដល់ទៅ ៧ ថ្ងៃ ដោយប្រការដូច្នេះ ។

ចប់អដ្ឋកថា តិរោកុឌ្ឌសូត្រទី ៧

# អដ្ឋកថា និធិកណ្ឌសូត្រទី ៨

( ហេតុតាំងព្រះសូត្រ )

គប្បីជ្រាបវិនិច្ឆ័យក្នុង និធិកណ្ឌសូត្រទី ៨ ដូចតទៅនេះ ៖

[៩] និធិកណ្ឌសូត្រ ខ្ញុំលើកឡើងតាំងដោយន័យថា និធឹ និធេតិ បុរិសោ (បុរសរមែងកប់កំណប់ទ្រព្យ) ជាដើម តលំដាប់ពីតិរោកុឌ្ឌសូត្រឥឡូវនេះ ខ្ញុំនឹងពោលហេតុតាំង និងនឹងសំដែងហេតុកើតរឿងនៃនិធិកណ្ឌសូត្រទុកក្នុងទីនេះ ទើបធ្វើការពណ៌នាសេចក្តីនៃនិធិកណ្ឌសូត្រនោះ ៗ

បណ្តាហេតុទាំង ២ នោះ ក្នុងទីនេះ គប្បីជ្រាបហេតុតាំងនិធិកណ្ឌសូត្រនោះមុនយ៉ាងនេះ ។ ពិតហើយ និធិកណ្ឌសូត្រនេះ ព្រះមានព្រះភាគសូម្បីមិនបានត្រាស់ទុកតាមលំដាប់នេះ ព្រោះហេតុជាសូត្រគូនៃតិរោកុឌ្ឌ-សូត្រដែលត្រាស់ទុកហើយ ព្រោះជារឿងអនុមោទនា ដូច្នោះ ខ្ញុំទើបលើកឡើងតាំងទុកក្នុងទីនេះ ។ ឬថា គប្បីជ្រាបថា កាលខ្ញុំសំដែងវិបត្តិរបស់ពពួកជនដែលប្រាសចាកបុណ្យ ដោយតិរោកុឌ្ឌសូត្រហើយ ទើបលើកយកនិធិកណ្ឌសូត្រនេះតាំងទុកក្នុងទីនេះ ក៏ដើម្បីសំដែងសម្បត្តិរបស់ពពួកជន

ដែលធ្វើបុណ្យទុក ដោយសូត្រនេះ ។ ហេតុតាំងនិធិកណ្ឌសូត្រនោះ ទុកក្នុងទីនេះមានប៉ុណ្ណេះ ។

## ហេតុកើតព្រះសូត្រ

និធិកណ្ឌសូត្រនោះ មានហេតុកើតដូច្នេះ ។

បានឮថា ក្នុងក្រុងសាវត្ថី កុដុម្ពិកម្នាក់ ស្តុកស្តម្ភ មានទ្រព្យច្រើន មានភោគៈច្រើន ទាំងគេក៏ជាមនុស្សមានបសាទសទ្ធា មានចិត្តប្រាសចាកមន្ទិល គឺ សេចក្តីកំណាញ់ នៅគ្រប់គ្រងផ្ទះ ។ ថ្ងៃមួយ គេថ្វាយទានដល់ព្រះភិក្ខុសង្ឃមានព្រះពុទ្ធជាប្រធាន ។ សម័យនោះ ព្រះរាជាមានព្រះរាជបំណងនឹងជួប ទើបទ្រង់បញ្ជារាជបុរសម្នាក់ទៅកាន់សំណាក់គេ ដោយព្រះរាជតម្រាស់បង្គាប់ថា នាយចូរទៅនាំកុដុម្ពីឈ្មោះនេះមក រាជបុរសនោះទៅនិយាយជាមួយកុដុម្ពីនោះថា គហបតី ព្រះរាជាកោះហៅលោក ។ កុដុម្ពិកមានចិត្តប្រកបដោយគុណ មានសទ្ធាជាដើម កំពុងអង្គៀសភិក្ខុសង្ឃមានព្រះពុទ្ធជាប្រធាន ទើបពោលថា ទៅមុនចុះរាជបុរស ខ្ញុំនឹងទៅតាមក្រោយ ខ្ញុំកប់កំណប់ទ្រព្យក្នុងខណៈនេះសិន ។ ព្រះមានព្រះភាគ សោយស្រេច

ហើយ ដើម្បីនឹងទ្រង់សំដែងបុញ្ញសម្បទាថា និធិដោយបរមត្ថ ទើបបាន ត្រាស់ព្រះគាថាទាំងនេះថា **និធឹ និធេតិ បុរិសោ** (បុរសរមែងកប់កំណប់ទ្រព្យ) ជាដើម ដើម្បីអនុមោទនាដល់កុដុម្ពីនោះ ។ និធិកណ្ឌសូត្រនោះ មានហេតុកើតឡើងដូចពោលមកនេះ ។

ខ្ញុំពោលហេតុតាំង និងសំដែងហេតុកើតរបស់
និធិកណ្ឌសូត្រទុកក្នុងទីនេះហើយ នឹងធ្វើការពណ៌នា
សេចក្តីរបស់និធិកណ្ឌសូត្រនោះ ដូចតទៅនេះ ។

## ពណ៌នាគាថាទី ១

បណ្តាបទទាំងនោះ បទថា **និធឹ និធេតិ បុរិសោ** (បុរសរមែងកប់កំណប់ទ្រព្យ) សេចក្តីថា ឈ្មោះថា និធិ មាន ៤ គឺ **ថាវរនិធិ ជង្គមនិធិ អង្គសមនិធិ អនុគាមិកនិធិ** ។ បណ្តានិធិ ៤ នោះ ទ្រព្យដែលនៅលើផែនដីក្តី ទ្រព្យដែលនៅក្នុងអាកាសក្តី ប្រាក់ក្តី មាសក្តី ស្រែក្តី ដីភូមិក្តី ឬក៏ទ្រព្យបែបនោះសូម្បីដទៃណា ដែលមិនឃ្លាតចាកទីដោយខ្លួនឯង ឈ្មោះថា ថាវរៈ (តាំងនៅ) កំណប់ទ្រព្យនេះ ឈ្មោះថា **ថាវរនិធិ** ។

ទាសស្រី ទាសប្រុស ដំរី គោ សេះ លា ពពែ កេះ មាន់ ជ្រូក ឬក៏ទ្រព្យបែបនោះសូម្បីដទៃណា ដែលកម្រើកបានដោយខ្លួនឯង ឈ្មោះថា ជង្គមៈ (កម្រើកបាន) កំណប់ទ្រព្យនេះ ឈ្មោះថា **ជង្គមនិធិ** ។ ពាហុ-សច្ចៈ (ភាពជាពហុស្សូត) ដែលជាអ្នកបង្កើតការងារ បង្កើតសិល្បៈ ទីតាំងនៃវិជ្ជាការ ឬក៏ថា ពហុសច្ចៈបែបនោះសូម្បីដទៃណា ដែលសិក្សាហើយសិក្សាទៀត ជំនាញជាប់ខ្លួនប្រៀបដូចជាអវយវៈធំតូច ឈ្មោះថា អង្គសមៈ (ស្មើដោយអវយវៈ) កំណប់ទ្រព្យនេះ ឈ្មោះថា **អង្គសមនិធិ** ។ បុណ្យដែលសម្រេចដោយទាន ដែលសម្រេចដោយសីល ដែលសម្រេចដោយភាវនា ដែលសម្រេចដោយការស្តាប់ធម៌ ដែលសម្រេចដោយការសំដែងធម៌ ឬក៏បុណ្យបែបនោះសូម្បីដទៃណា ជាប់ដោយផលដែលគួរប្រាថ្នាដូចដើរជាប់ទៅតាមក្នុងទីនោះៗ ឈ្មោះថា អនុគាមិកៈ (ជាប់តាមទៅបាន) កំណត់ទ្រព្យនេះ ឈ្មោះថា **អនុគាមិកៈ** ។ ចំណែកក្នុងទីនេះ ទ្រង់ប្រាថ្នាយក **ថាវរនិធិ** ។

បទថា **និធេតិ (រមែងកប់)** បានដល់ តាំងទុក កប់ទុក រក្សាទុក ។

បទថា **បុរិសោ (បុរស)** បានដល់ មនុស្ស ។ បុរសក្តី ស្ត្រីក្តី ខ្ទើយក្តី រមែងកប់កំណប់ទ្រព្យបានក៏ពិត តែក្នុងទីនេះ ក៏ទ្រង់ធ្វើទេសនាដោយបុរសជាសំខាន់ តែពោលដោយអត្ថ គប្បីឃើញថា ទ្រង់ប្រមូលបុគ្គលសូម្បីទាំងនោះទុកក្នុងទីនេះ ។ បទថា **គម្ភីរេ ឱទកន្តិកេ (ក្នុងទីជ្រៅមានទឹកជាទីបំផុត)** សេចក្តីថា ដែលឈ្មោះថា ទីជ្រៅ ព្រោះអត្ថថា ត្រូវស្ទួងចុះ ឈ្មោះថា **មានទឹកជាទីបំផុត** ព្រោះជ្រៅរហូតដល់ទឹកជាទីបំផុត ។ ទីជ្រៅ តែមិនមានទឹកជាទីបំផុតក៏មាន ដូចអណ្តូងជ្រៅមួយជួរបុរសដែលឈរលើទីដីខ្ពស់ ។ ដែលមានទឹកជាទីបំផុត តែមិនជ្រៅក៏មាន ដូចអណ្តូងមានជម្រៅមួយហស្តក្តី ពីរហស្តក្តី ត្រង់ទីគល់ឈើ ។ ទីជ្រៅ ទាំងដែលមានទឹកជាទីបំផុតក៏មាន ដូចអណ្តូងដែលគេជីកនៅត្រង់ទីខ្ពស់រហូតមានទឹកហូរចេញមកនៅក្នុងទីនោះ ។ បទថា **គម្ភីរេ ឱទកន្តិកេ** នេះ ត្រាស់សំដៅដល់ទីជ្រៅ និងមានទឹកជាទីបំផុតនោះ ។

បទថា **អត្ថេ កិច្ចេ សមុប្បន្នេ (កាលកិច្ចដែលចាំបាច់កើតឡើង)** សេចក្តីថា ឈ្មោះថា ចាំបាច់ ព្រោះមិនប្រាសចាកប្រយោជន៍ ។ លោក

អធិប្បាយថា នាំមកនូវប្រយោជន៍ នាំមកនូវសេចក្តីចម្រើន ។ ឈ្មោះថា កិច្ច ព្រោះគួរធ្វើ ។ លោកអធិប្បាយថា ករណីណាមួយ ។ កិច្ចដែលកើតឡើងហើយនោះឯង ឈ្មោះថា កើតឡើង ។ លោកអធិប្បាយថា ដែលតាំងឡើងហើយព្រោះជាកិច្ចគួរធ្វើ ។ កាលកិច្ចដែលជាប្រយោជន៍នោះកើតឡើងហើយ ។ បទថា **អត្ថាយ មេ ភវិស្សតិ (ទ្រព្យនេះនឹងជាប្រយោជន៍ដល់យើង)** នេះ ជាការសំដែងដល់ប្រយោជន៍នៃការកប់កំណប់ទ្រព្យ ។ ពិតហើយ បុរសនោះកប់កំណប់ទ្រព្យទុក ក៏ដើម្បីប្រយោជន៍យ៉ាងនេះថា កាលករណីខ្លះដែលនាំមកនូវប្រយោជន៍កើតឡើង កំណប់ទ្រព្យនឹងជាប្រយោជន៍ដល់យើង នឹងមាន ដើម្បីការសម្រេចនៃកិច្ចរបស់យើងនោះ ។ ជាការពិត សេចក្តីសម្រេចនៃកិច្ចនោះឯង គប្បីជ្រាបថាជាប្រយោជន៍របស់កំណប់ទ្រព្យនោះ កាលកិច្ចកើតឡើង ។

## ពណ៌នាគាថាទី ២

ព្រះមានព្រះភាគ លុះទ្រង់សំដែងប្រយោជន៍នៃការកប់កំណប់ទ្រព្យយ៉ាងនេះ កាលទ្រង់សំដែងសេចក្តីប្រាថ្នានៃការប្រសព្វប្រយោជន៍ ឥឡូវ

នេះ ដើម្បីទ្រង់សំដែងសេចក្ដីប្រាថ្នានៃការលះបង់ចេញនៅវត្ថុដែលមិនជាប្រយោជន៍ ទើបត្រាស់ថា ៖

កំណប់ទ្រព្យនេះ នឹងជាប្រយោជន៍ដល់យើង ដើម្បី
ផុតចាករាជភ័យកាលយើងពោលប្រទូស្តខ្លះ ដើម្បីផុត
ចាកចោរ កាលយើងត្រូវចោរប្រៀតបៀនខ្លះ ដើម្បីដោះ
បំណុលខ្លះ ក្នុងគ្រាទុរ្ភិក្ខភ័យខ្លះ ក្នុងគ្រាទល់ក្រខ្លះ ។

គាថានោះ គប្បីប្រកបសេចក្ដីតាមកំណើតស័ព្ទ ជាមួយបទទាំង ២ ថា *ភវិស្សតិ បមោក្ខាយ* (នឹងជួយដោះបំណុល) ដែលត្រាស់ក្នុងពាក្យនេះថា *អត្ថាយ មេ ភវិស្សតិ* (នឹងជាប្រយោជន៍ដល់យើង) និងថា *ឥណស្ស វា បមោក្ខាយ* (ដើម្បីដោះបំណុលខ្លះ) ទើបនឹងជ្រាបសេចក្ដីបាន ។

ក្នុងបទនោះ ប្រកបសេចក្ដីយ៉ាងនេះថា បុរសកប់កំណប់ទ្រព្យ មិនមែនដោយបំណងថា នឹងជាប្រយោជន៍ដល់យើងតែម្យ៉ាងប៉ុណ្ណោះទេ ។ ក៏មានអ្វីទៀតហ្ន៎? ក៏គឺ បុរសកប់កំណប់ទ្រព្យ ក៏ដោយបំណងថា នឹងជួយដោះបំណុលឲ្យផុតចាករាជភ័យ ដែលត្រូវពួកសត្រូវ ពួកបច្ចាមិត្រពោល

ប្រទូស្ត ដោយន័យយ៉ាងនេះថា អ្នកនេះជាចោរខ្លះ ជាបុរសក្បត់ប្រពន្ធខ្លះ រត់គេចពន្ធខ្លះ ដូច្នេះជាដើម នឹងជួយដោះយើងឲ្យផុតចាកចោរភ័យដែលត្រូវពួកចោរបៀតបៀន ព្រោះការលួចទ្រព្យដោយវិធីកាត់ទីតជាដើមខ្លះ ដោយការចាប់ជម្រិតខ្លះថា ឯងចូរឲ្យមាស និងប្រាក់ប៉ុណ្ណេះៗ ខ្លះ ។ ម្ចាស់បំណុលនឹងទារបំណុលយើង ក៏នឹងជួយដោះយើងឲ្យរួចផុតពីបំណុលដែលម្ចាស់បំណុលទាំងនោះទារខ្លះ ។ សម័យដែលកើតទុរ្ភិក្ខភ័យ ស្រូវអន្តរវិនាស អាហាររកបានលំបាក ក្នុងសម័យនោះ នឹងញ៉ាំងអត្តភាពឲ្យប្រព្រឹត្តទៅដោយទ្រព្យតិចតួច ធ្វើមិនបានងាយ កំណប់ទ្រព្យទាំងនោះនឹងជួយយើងបានក្នុងគ្រាទុរ្ភិក្ខភ័យនោះបាន ដូច្នេះខ្លះ ។ នឹងជួយយើងបានក្នុងគ្រាលំបាកដែលកើតពីអគ្គិភ័យ ឧទកភ័យ ទាយាទមិនជាទីស្រឡាញ់ដូច្នេះខ្លះ ។

ព្រះមានព្រះភាគ គ្រាទ្រង់សំដែងប្រយោជន៍នៃការរក្សាទ្រព្យ ២ យ៉ាង ដោយ ២ គាថា គឺ បំណងនឹងជួបប្រយោជន៍ និងបំណងដែលវៀរចាកវត្ថុដែលមិនមែនជាប្រយោជន៍យ៉ាងនេះហើយ ឥឡូវនេះ កាលនឹង

ត្រាស់ការញ៉ាំងប្រយោជន៍សូម្បីទាំង ២ នោះឯងដល់កុដុម្ពីនោះ ទើបត្រាស់ថា ឯតទត្ថាយ លោកស្មឹ និធិ នាម និធិយ្យតិ (កំណប់ទ្រព្យដែលគេកប់ទុកក្នុងលោក ក៏ដើម្បីប្រយោជន៍យ៉ាងនេះ) ។

គាថានោះមានអត្ថថា ប្រយោជន៍ឯណា គឺ ការប្រសព្វប្រយោជន៍និងការវៀរចាកវត្ថុដែលមិនមែនជាប្រយោជន៍ ទ្រង់សំដែងទុកដោយន័យជាដើមយ៉ាងនេះថា នឹងជាប្រយោជន៍ដល់យើង និងថា នឹងផុតពីរាជភ័យកាលយើងត្រូវគេពោលប្រទូស្តខ្ចះ ។ ធម្មតាកំណប់ទ្រព្យ មានមាសប្រាក់ជាដើមណាមួយ គេកប់ទុក តាំងទុក រក្សាទុក ក្នុងឱកាសលោកនេះ ក៏ដើម្បីប្រយោជន៍នោះ គឺ ដើម្បីធ្វើកិច្ចទាំងនោះឲ្យសម្រេចទៅបាន ។

## ពណ្ណនាគាថាទី ៣

ឥឡូវនេះ ព្រោះហេតុដែលកំណប់ទ្រព្យនោះ សូម្បីគេកប់ទុកល្អហើយយ៉ាងនេះ រមែងឲ្យសម្រេចប្រយោជន៍តាមប្រាថ្នាដល់អ្នកមានបុណ្យទាំងនោះបាន មិនសម្រេចប្រយោជន៍ដល់បុគ្គលពួកដទៃ ដូច្នោះ កាលទ្រង់សំដែងប្រយោជន៍នោះ ទើបត្រាស់ថា ៖

កំណាប់ទ្រព្យដែលគេកប់ទុកល្អហើយ ក្នុងទីដ៏ជ្រៅ
មានទឹកជាទីបំផុតប៉ុណ្ណោះ កំណាប់ទ្រព្យ រមែងសម្រេច
ប្រយោជន៍ដល់គេបានទាំង អស់ក្នុងគ្រប់កាលតែម្យ៉ាង
មិនបានឡើយ ។

គាថានោះមានសេចក្ដីថា សូម្បីកំណាប់ទ្រព្យនោះ គេកប់ទុកយ៉ាងល្អដល់ម្ល៉ោះ លោកអធិប្បាយថា សូម្បីគេជីករណ្ដៅរក្សាទុកដ៏ល្អយ៉ាងនោះ ។ គេកប់ទុកល្អយ៉ាងណា? គេកប់ទុកក្នុងទីជ្រៅមានទឹកជាទីបំផុត លោកអធិប្បាយថា ល្អយ៉ាងនោះដែលរាប់បានថា កប់ទុកក្នុងទីជ្រៅបំផុតរហូតដល់ទឹក ។ បទថា **ន សព្វោ សព្វទាយេវ តស្ស តំ ឧបកប្បតិ** (កំណាប់ទ្រព្យ រកសម្រេចដល់គេបានទាំងអស់ ក្នុងកាលទាំងពួងមិនបាន) សេចក្ដីថា កំណាប់ទ្រព្យរមែងមិនសម្រេចប្រយោជន៍ មិនសម្រេចផលសូម្បីទាំងអស់ ដល់បុរសដែលកប់ទុកបានគ្រប់កាល លោកអធិប្បាយថា មិនអាចធ្វើកិច្ចតាមដែលពោលមកហើយ ។ តើអ្វីហ្ន៎? គឺថា គ្រាខ្លះក៏សម្រេចប្រយោជន៍ គ្រាខ្លះក៏មិនសម្រេចប្រយោជន៍ឡើយ ។ សព្ទថា តំ ក្នុងគាថា

នោះ គប្បីឃើញថា ជានិបាតចុះក្នុងអត្ថនៃបទបូរណៈ (ធ្វើបទឲ្យពេញ) ដូចក្នុងប្រយោគជាដើមយ៉ាងនេះថា **យថា តំ អប្បមត្តស្ស អាតាបិនោ** ។ ឬថា លោកធ្វើលិង្គ (ភេទស័ព្ទ) ឲ្យផ្សេងគ្នា កាលគួរនឹងពោលថា **សោ** ក៏ពោលថា **តំ** ។ ពិតហើយ កាលពោលយ៉ាងនោះ សេចក្តីនោះក៏ដឹងបានស្រួល ។

## ពណ៌នាគាថាទី ៤ និងទី ៥

ព្រះមានព្រះភាគកាលត្រាស់ថា កំណប់ទ្រព្យ រមែងរកសម្រេចប្រយោជន៍ដល់គេបានក្នុងគ្រប់កាលទាំងពួងមិនបាន យ៉ាងនេះ ឥឡូវនេះ កាលនឹងទ្រង់សំដែងហេតុដែលមិនសម្រេចប្រយោជន៍នោះ ទើបត្រាស់ថា

**ព្រោះកំណប់ទ្រព្យឃ្លាតចាកកន្លែងទៅខ្លះ ការចាំ**
**របស់គេឃ្លៀងឃ្លាតទៅខ្លះ ពួកនាគនាំយកទៅខ្លះ ពួក**
**យក្សនាំយកទៅខ្លះ ពួកទាយាទមិនជាទីស្រឡាញ់នាំយក**
**ទៅកាលគេមិនឃើញខ្លះ ។**

គាថានោះមានសេចក្តីថា កំណប់ទ្រព្យនោះ ឃ្លាតចាកទីដែលគេកប់

ទុកល្អហើយ គឺ សូម្បីមិនមានចេតនាក៏ទៅទីដទៃបាន ព្រោះម្ចាស់របស់អស់បុណ្យខ្លះ ។ បទថា **សញ្ញា វាស្ស វិមុយ្ហតិ (ការចាំរបស់គេឃ្លៀងឃ្លាតទៅខ្លះ)** សេចក្ដីថា គេចាំមិនបានដល់ទីកន្លែងកប់កំណប់ទ្រព្យទុកខ្លះ ពួកនាគប្ដូរទីកន្លែងកំណប់ទ្រព្យ ព្រោះការអស់បុណ្យរបស់គេជាស់តឿនហើយ នាំយកទៅទីដទៃខ្លះ ។ ពួកយក្សនាំយកទៅតាមសេចក្ដីពេញចិត្តខ្លះ។ ពួកទាយាទអ្នកទទួលមត៌ក ដែលមិនជាទីស្រឡាញ់ជីកផែនដីកាន់យកកំណប់ទ្រព្យនោះទៅ ពេលគេមិនឃើញខ្លះ ។ កំណប់ទ្រព្យនោះ មិនសម្រេចប្រយោជន៍ដល់គេ ព្រោះហេតុមានការឃ្លាតចាកទីជាដើមនោះឯងដោយប្រការដូច្នេះ ។

ព្រះមានព្រះភាគ កាលត្រាស់ហេតុដែលមិនឲ្យសម្រេចប្រយោជន៍ដែលលោកសម្មតិ មានការឃ្លាតចាកទីជាដើម យ៉ាងនេះហើយ ឥឡូវនេះកាលទ្រង់សំដែងហេតុ ដែលគេដឹងថា ការអស់បុណ្យយ៉ាងណាមួយដែលជាមូលហេតុសូម្បីទាំងនោះ ទើបត្រាស់ថា **យទា បុញ្ញក្ខយោ ហោតិ សព្វ-មេតំ វិនស្សតិ (ក្នុងវេលាដែលគេអស់បុណ្យ កំណប់ទ្រព្យទាំងអស់នោះ**

វមែងវិនាសទៅ) ។

គាថានោះមានសេចក្តីថា សម័យណា បុណ្យដែលធ្វើភោគសម្បត្តិឲ្យសម្រេច អស់ទៅ ក៏នឹងធ្វើវត្ថុដែលមិនមែនបុណ្យ ដែលប្រព្រឹត្តទៅដើម្បីសេចក្តីវិនាសនៃភោគសម្បត្តិ មានឱកាសតាំងនៅ សម័យនោះ ធនជាតណា មានប្រាក់ និងមាសជាដើម ដែលបុគ្គលកប់កំណាប់ទ្រព្យទុកហើយ ធនជាតទាំងអស់នោះ ក៏វិនាសអស់ទៅដែរ ។

## ពណ៌នាគាថាទី ៦

ព្រះមានព្រះភាគ គ្រាត្រាស់ដល់កំណាប់ទ្រព្យដែលសូម្បីបុគ្គលកប់ទុកហើយដោយសេចក្តីប្រាថ្នានោះៗ តែក៏មិនសម្រេចប្រយោជន៍តាមដែលប្រាថ្នា ដល់លោកសម្មតិក៏ត្រូវមានការវិនាសទៅជាធម្មតា ដោយប្រការផ្សេងៗ យ៉ាងនេះហើយ ឥឡូវនេះ ដើម្បីទ្រង់សំដែងបុញ្ញសម្បទានោះថាជាកំណាប់ទ្រព្យដោយបរមត្ថ កាលទ្រង់សំដែងនិធិកណ្ឌសូត្រនេះ ដែលទ្រង់ផ្តើមដើម្បីអនុមោទនាដល់កុដុម្ពីនោះ ទើបត្រាស់ថា ៖

កំណាប់ទ្រព្យរបស់បុគ្គលណា នឹងជាស្ត្រីក៏ដោយ បុរស

កំដោយ កប់ទុកល្អហើយដោយទាន សីល សញ្ញមៈ

និងទមៈ ។

បណ្តាបទទាំងនោះ បទថា **ទានំ** (ទាន) គប្បីកាន់យកតាមន័យដែលពោលទុកហើយក្នុងមង្គលប្រការថា **ទានញ្ច ធម្មចរិយា** នោះ ។ បទថា **សីលំ** (សីល) បានដល់ ការមិនកន្លងល្មើសផ្លូវកាយ និងវាចា គឺសីល ៥ សីល ៨ សីល ១០ និងបាតិមោក្ខសំវរសីលជាដើម ។ សីលគ្រប់យ៉ាងលោកថា សីល ក្នុងទីនេះ ។ ពាក្យថា **សញ្ញមោ** (សញ្ញមៈ) បានដល់ ការសង្រួម ឈ្មោះថា សញ្ញមៈ លោកអធិប្បាយថា ការហាមចិត្តទៅក្នុងអារម្មណ៍ផ្សេងៗ ពាក្យនេះ ជាឈ្មោះរបស់ សមាធិ ។ បុគ្គលប្រកបហើយដោយសញ្ញមៈ លោកហៅថា អ្នកសង្រួមដ៏ខ្ពង់ខ្ពស់ ក្នុងបាលីនេះថា **ហត្ថសញ្ញតោ បាទសញ្ញតោ វាចាសញ្ញតោ សញ្ញតុត្តមោ** (អ្នកសង្រួមដៃ សង្រួមជើង សង្រួមវាចា ឈ្មោះថា អ្នកសង្រួមដ៏ខ្ពង់ខ្ពស់) ។ អាចារ្យពួកមួយពោលថា សេចក្តីសង្រួម ឈ្មោះ សញ្ញមៈ លោកអធិប្បាយថា ការសង្រួម ពាក្យនេះ ជាឈ្មោះរបស់ឥន្ទ្រិយសំវរៈ ។ ការហ្វឹកហាត់ ឈ្មោះ

ថា **ទមៈ** លោកអធិប្បាយថា ការស្ងប់កិលេស ពាក្យនេះ ជាឈ្មោះរបស់ បញ្ញា ។ ពិតហើយ បញ្ញា ក្នុងបាលីកន្លែងខ្លះហៅថា បញ្ញា ដូចប្រយោគ ជាដើមយ៉ាងនេះថា **សុស្សូសំ លភតេ បញ្ញំ** (អ្នកស្តាប់ដោយល្អ រមែងបាន នូវបញ្ញា) កន្លែងខ្លះលោកហៅថា ធម្មៈ ក្នុងប្រយោគជាដើមយ៉ាងនេះថា **សច្ចំ ធម្មោ ធិតិ ចាគោ** (សច្ចៈ ធម្មៈ ធិតិ ចាគៈ) ។ កន្លែងខ្លះទៀត លោកហៅថា ទមៈ ក្នុងប្រយោគជាដើមយ៉ាងនេះថា **យទិ សច្ចា ទមា ចាគា ខន្ត្យា ភិយ្យោធ វិជ្ជតិ** (ប្រសិនបើ ហេតុនៃការបានកេរ្តិ៍ឈ្មោះក្រៃ លែងទៅជាងសច្ចៈ ហេតុនៃការបានបញ្ញាក្រៃលែងទៅជាងទមៈ ហេតុនៃ ការចងមិត្រក្រៃលែងជាចាគៈ ហេតុនៃការបានលោកិយលោកុត្តរទ្រព្យក្រៃ លែងជាងខន្តិ មាននៅក្នុងលោកនេះសោត) ។

បណ្ឌិតដឹងទានយ៉ាងនេះហើយ គប្បីប្រមូលមកជ្រាបនូវអត្ថនៃគាថា នេះ យ៉ាងនេះថា កំណប់ទ្រព្យដែលសម្រេចដោយបុណ្យរបស់បុគ្គលណា ជាស្ត្រីក៏ដោយ បុរសក៏ដោយ គេនឹងយកធម្មៈទាំង ៤ នេះ គឺ ទាន សីល សញ្ញមៈ ទមៈ ដែលកប់ទុកល្អហើយ ដោយការធ្វើធម៌ទាំង ៤ មានទាន

ជាដើមទាំងនោះទុកដោយល្អក្នុងចិត្តសន្តានតែម្យ៉ាង ឬក្នុងវត្ថុមានចេតិយជាដើម ដូចកំណាប់ទ្រព្យដែលសម្រេចដោយធនជាត គេក៏យកមាស ប្រាក់ មុក្តា មណី កប់ទុក ដោយការប្រើប្រាស់មាសប្រាក់ជាដើមទាំងនោះ ចុះក្នុងទីជាមួយគ្នា ដូច្នោះ ។

## ពណ៌នាគាថាទី ៧

ព្រះមានព្រះភាគ លុះទ្រង់សំដែងបុញ្ញសម្បទាជាកំណាប់ទ្រព្យដោយបរមត្ថ ដោយគាថានេះថា ***យស្ស ទានេន*** (កំណាប់ទ្រព្យរបស់បុគ្គលណា... កប់ទុកល្អហើយដោយទាន) ជាដើមយ៉ាងនេះហើយ ឥឡូវនេះ កាលទ្រង់សំដែងទីដែលគេកប់កំណាប់ទ្រព្យនោះ ដែលជាការកប់ដោយល្អ ទើបត្រាស់ថា ៖

ក្នុងចេតិយក្តី ក្នុងសង្ឃក្តី ក្នុងបុគ្គលក្តី ក្នុង
ភ្ញៀវក្តី ក្នុងមាតាក្តី ក្នុងបិតាក្តី ក្នុងបងប្រុសក្តី ។

ក្នុងគាថានោះ ឈ្មោះថា ***ចេតិយ*** ព្រោះគួរបង្កើត ។ លោកអធិប្បាយថា គួរបូជា ។ ឈ្មោះថា ចេតិយ ព្រោះវិចិត្រហើយ ។ ចេតិយ

នោះមាន ៣ យ៉ាង គឺ **បរិភោគចេតិយ ឧទ្ទិសកចេតិយ ធាតុចេតិយ** ។

បណ្តាចេតិយទាំង ៣ នោះ ព្រះពោធិព្រឹក្ស ឈ្មោះថា **បរិភោគ-ចេតិយ** , ព្រះពុទ្ធបដិមា ឈ្មោះថា **ឧទ្ទិសកចេតិយ** , ព្រះស្តូបដែលមានទីតម្កល់ព្រះធាតុ ឈ្មោះថា **ធាតុកចេតិយ** ។

បទថា **សង្ឃេ (សង្ឃ)** បានដល់ បុគ្គលណាមួយ ក្នុងពួកសង្ឃដែលមានព្រះពុទ្ធជាព្រះប្រធាន ។ បទថា **បុគ្គលេ (បុគ្គល)** បានដល់ បុគ្គលណាមួយក្នុងពួកគ្រហស្ថ និងបព្វជិតជាដើម ។ ឈ្មោះថា **អតិថិ (ភ្ញៀវ)** ព្រោះគេមិនមានតិថី គឺ មកក្នុងថ្ងៃណាក៏បាន ។ ពាក្យនេះ ជាឈ្មោះរបស់ភ្ញៀវដែលមកក្នុងខណៈនោះ ។ ពាក្យដ៏សេស មានន័យដូចបានពោលហើយនោះឯង ។

បណ្ឌិតស្គាល់ចេតិយជាដើមយ៉ាងនេះហើយ ឥឡូវនេះ គប្បីប្រមូលមកជ្រាបអត្ថនៃគាថានេះ យ៉ាងនេះ ។ កំណប់ទ្រព្យណា ដែលត្រាស់ថា "កប់ល្អហើយ" កំណប់ទ្រព្យនោះ ដែលគេកប់ទុកក្នុងវត្ថុទាំងនេះ រមែងឈ្មោះថា កប់ទុកល្អហើយ ។ ព្រោះហេតុអ្វី? ព្រោះអាចឲ្យផលដែលគួរ

ប្រាថ្នាបានអស់កាលយូរ ។ ពិតណាស់ ជនទាំងឡាយថ្វាយក្នុងព្រះចេតិយ សូម្បីតិចតួច រមែងជាអ្នកបានផលដែលគួរប្រាថ្នាអស់កាលយូរ ។ ដូចដែលត្រាស់ទុកថា ៖

យើងថ្វាយផ្កាមួយទង ក៏នឹងមិនស្គាល់ទុគ្គតិរហូត

អស់ ៨០ កោដិកប្ប នេះជាផលនៃការថ្វាយផ្កា ។

និងថា ៖

បើបុគ្គលគប្បីឃើញសុខដ៏ធំ គប្បីលះសុខល្មម

ប្រមាណចេញ ។

គប្បីជ្រាបការចែកផលទាន សូម្បីក្នុងវត្ថុមានព្រះសង្ឃជាដើម តាមន័យដែលពោលទុកហើយក្នុងទក្ខិណាវិសុទ្ធិសូត្រ និងវេលាមសូត្រជាដើម ដោយប្រការដូច្នេះ ។ មួយទៀត ទ្រង់សំដែងការប្រព្រឹត្តទៅ និងសេចក្តីចម្រើនផលនៃទានក្នុងវត្ថុ មានចេតិយជាដើម ដោយប្រការណា ក៏គប្បីប្រារព្ធគុណនោះៗ ក្នុងទីទាំងពួង តាមការប្រកបហើយ ទើបបានជ្រាបការប្រព្រឹត្តទៅ និងការចម្រើនផល នៃសីលដែលជាចារិតសីល និងវារិតសីល

នៃសញ្ញមៈ ចំណែកដែលជាពុទ្ធានុស្សតិជាដើម និងនៃទមៈ ចំណែកខាង វិបស្សនា មនសិការ និងការពិចារណាវត្ថុនោះ ដោយប្រការដូច្នោះ ។

## ពណ៌នាគាថាទី ៨

ព្រះមានព្រះភាគ កាលទ្រង់សំដែងវត្ថុ មានព្រះចេតិយជាដើម នៃកំណប់ទ្រព្យដែលសម្រេចដោយបុណ្យ ដែលគេកប់ទុកដោយទានជា ដើម យ៉ាងនេះហើយ ឥឡូវនេះ កាលនឹងទ្រង់សំដែងសេចក្ដីផ្សេងគ្នារបស់កំណប់ទ្រព្យ ដែលបុគ្គលកប់ចុះក្នុងវត្ថុទាំងនោះ អំពីកំណប់ទ្រព្យដែលកប់ក្នុងទីជ្រៅមានទឹកជាទីបំផុត ទើបត្រាស់ថា ៖

កំណប់ទ្រព្យនោះ ឈ្មោះថាគេកប់ល្អហើយ
នរណាៗ លួចយកមិនបាន ជារបស់ជាប់តាមខ្លួន
ទៅបាន បណ្ដាភោគៈដែលចាំ ត្រូវលះបង់ទៅ គេ
ក៏នាំកំណប់ទ្រព្យ គឺ បុណ្យនោះទៅបាន ។

ក្នុងគាថានោះ ព្រះមានព្រះភាគទ្រង់សំដែងកំណប់ទ្រព្យដែលកប់ទុកល្អហើយ ដោយទានជាដើមនោះ ដោយបទដើមថា កំណប់ទ្រព្យនោះ

ឈ្មោះថា គេកប់ទុកល្អហើយ ។ បទថា **អជេយ្យោ** (**នរណាក៏ដណ្តើមមិនបាន**) បានដល់ អ្នកដទៃៗ មិនអាចច្បាំងហើយដណ្តើមយកទៅបាន ។ បាឋៈថា **អច្ចេយ្យោ** ក៏មាន ។ អធិប្បាយថា ដែលនរណាៗ មិនគប្បីឈ្នះ ។ មិនគួរឈ្នះ គឺ អ្នកត្រូវការប្រយោជន៍សុខ គួរធ្វើដោយខ្លួនឯង ។ ក៏ក្នុងបាឋៈនេះ ប្រកបសេចក្តីថា "កំណប់ទ្រព្យនេះ នរណាៗ ដណ្តើមមិនបាន" ហើយសំដែងពាក្យសួរទៀតថា "ព្រោះហេតុអ្វី" ទើបសម្ព័ន្ធសេចក្តីថា ព្រោះហេតុកំណប់ទ្រព្យដែលកប់ទុកល្អហើយ នឹងជាប់ទៅតាមបាន ។ តែកំណប់ទ្រព្យដែលកប់ទុកល្អហើយដោយប្រការក្រៅនេះ ជារបស់ដែលនរណាៗ ឈ្នះមិនបាន ក៏លោកពោលទុកហើយ ។ ពិតហើយ កំណប់ទ្រព្យនោះ ដែលកប់ទុកល្អហើយ ដែលនរណាៗ យកឈ្នះមិនបាន គឺ មិនមាននរណាយកឈ្នះបានឡើយ ។ កំណប់ទ្រព្យឈ្មោះថា **អនុគាមិក** ព្រោះជាប់តាមទៅបាន ។ អធិប្បាយថា មិនលះបុគ្គលសូម្បីកំពុងទៅបរលោកដោយការឲ្យផលក្នុងភពនោះៗ ។

បានឮថា បទថា **បហាយ គមនីយេសុ ឯតំ អាទាយ គច្ឆតិ** (បណ្ឌិ

ភោគៈដែលត្រូវនាំយកទៅ គេក៏នាំកំណប់ទ្រព្យ (គឺបុណ្យ) នោះ ទៅបាន) នេះ មានសេចក្ដីយ៉ាងនេះថា ពេលមរណកាលប្រាកដឡើង បណ្ដាភោគៈទាំងឡាយដែលត្រូវលះទៅ គេក៏នាំយកកំណប់ទ្រព្យនោះទៅបរលោក ។ សេចក្ដីនោះមិនត្រូវ ។ ព្រោះហេតុអ្វី? ព្រោះភោគៈទាំងឡាយនាំទៅមិនបាន ។ ពិតហើយ ភោគៈនោះៗ ដែលអ្នកត្រូវស្លាប់គប្បីលះបង់ចោលទាំងអស់ យកទៅតាមមិនបានឡើយ តែគតិវិសេសនោះៗ (ដែលអ្នកត្រូវស្លាប់) ក៏នាំយកទៅបាន ។ ព្រោះហេតុដែលគប្បីមានយ៉ាងនេះសោត ក៏គប្បីពោលបានថា បណ្ដាគតិវិសេសទាំងឡាយ ដែលចាំបាច់ត្រូវលះភោគៈទាំងឡាយទៅ ។ ដូច្នោះ ទើបគប្បីជ្រាបសេចក្ដីក្នុងប្រការនេះយ៉ាងនេះ ។ កាលភោគៈទាំងឡាយ ត្រូវលះបង់បុគ្គលអ្នកត្រូវស្លាប់ទៅ ដោយប្រការជាដើមយ៉ាងនេះថា "កំណប់ទ្រព្យឃ្លាតចាកទីខ្លះ" មច្ចៈ (អ្នកត្រូវស្លាប់) ក៏នាំយកទៅបានតែកំណប់ទ្រព្យ គឺ បុណ្យ ។ ព្រោះថា កំណប់ គឺ បុណ្យនោះ មិនលះមច្ចៈនោះ ព្រោះជាទ្រព្យជាប់តាមទៅបាន ។

ក្នុងគាថានោះ អាចារ្យពួកខ្លះពោលថា ក្នុងបទថា **គមនីយេសុ** នេះ

គប្បីមានសេចក្តីថា **គន្តព្វេសុ** មិនមែនសេចក្តីថា **គច្ឆន្តេសុ** ពាក្យនោះមិនគប្បីកាន់យកត្រឹមតែមួយជ្រុងប៉ុណ្ណោះទេ ។ ដូចក្នុងពាក្យថា **អរិយា និយ្យានិកា** នេះ មានសេចក្តីថា **និយ្យន្តា** មិនមែនមានសេចក្តីថា **និយ្យាតព្វា** យ៉ាងណា សូម្បីក្នុងទីនេះ ក៏មានសេចក្តីថា **គច្ឆន្តេសុ** ។ មិនមែនមានសេចក្តីថា **គន្តព្វេសុ** ក៏ដូច្នោះ ។

ម្យ៉ាងទៀត ព្រោះហេតុដែលបុគ្គលនេះ ប្រាថ្នានឹងឲ្យដល់នរណាៗ ក្នុងវេលានឹងស្លាប់ ក៏ចាប់កាន់ភោគៈឲ្យទៅមិនបាន ដូច្នោះ ភោគៈទាំងនោះ ដែលគេត្រូវលះទៅតាមផ្លូវកាយជាមុន ជាខាងក្រោយ ទើបត្រូវលះតាមផ្លូវចិត្តទាំងអស់សង្សឹម លោកអធិប្បាយថា គប្បីកន្លងហើយទៅ ។ ព្រោះដូច្នោះ ទើបគួរឃើញសេចក្តីក្នុងប្រការនេះ យ៉ាងនេះថា បណ្តាភោគៈទាំងឡាយដែលចាំបាច់ត្រូវលះតាមផ្លូវកាយមុន ជាខាងក្រោយ ទើបត្រូវលះទៅតាមផ្លូវចិត្ត ។ ក្នុងសេចក្តីខាងដើម ជាសត្តមីវិភត្តិ ចុះក្នុងនិទ្ធារណៈថា បណ្តាភោគៈទាំងឡាយដែលចាំបាច់ត្រូវលះបង់ គេក៏នាំភោគៈ គឺ បុញ្ញនិធិនោះតែម្យ៉ាងប៉ុណ្ណោះ ចេញពីភោគៈទាំងឡាយ ហើយនាំទៅ ។

ក្នុងសេចក្តីខាងក្រោយ ជាសត្តមីវិភត្តិ ចុះក្នុងការលក្ខណ: ដោយការ: ថា ក៏ដោយការ:នៃភោគ:ទាំងឡាយជាប់តាមទៅ ក៏រមែងកំណត់ការ: គឺ កំណប់ទ្រព្យនោះនាំទៅជាមួយបាន ។

## ពណ៌នាគាថាទី ៩

ព្រះមានព្រះភាគ កាលទ្រង់សំដែងសេចក្តីផ្សេងគ្នារបស់បុញ្ញនិធិនេះ ចាកកំណប់ទ្រព្យដែលគេកប់ទុកក្នុងទីជ្រៅ មានទឹកជាទីបំផុត កាលទ្រង់ញ៉ាំងឧស្សាហ:ឲ្យកើតឡើងដល់ទេវតា និងមនុស្សទាំងឡាយក្នុងបុញ្ញនិធិនោះ ដោយការពណ៌នាគុណបុញ្ញនិធិ ដែលទ្រង់សំដែងដោយព្រះអង្គទៀត ដូចឈ្មួញលក់ទំនិញដ៏ឱឡារ ញ៉ាំងឧស្សាហ:ឲ្យកើតដល់អ្នកទិញ ដោយការពណ៌នាគុណនៃទំនិញរបស់ខ្លួន ដូច្នោះ ទើបត្រាស់ថា ៖

កំណប់ទ្រព្យ គឺ បុណ្យ មិនសាធារណ:ដល់
ជនដទៃ ចោរក៏លួចទៅមិនបាន បុញ្ញនិធិណាជាប់
តាមខ្លួនទៅបាន អ្នកប្រាជ្ញគប្បីធ្វើបុញ្ញនោះចុះ ។

បណ្តាបទទាំងនោះ បទថា អសាធារណមញ្ញេសំ ប្រែថា មិនជា

សាធារណៈដល់ជនដទៃ ។ ម អក្សរ ធ្វើបទសន្ធិ ដូចក្នុងប្រយោគជាដើមថា **អទុក្ខមសុខាយ វេទនាយ សម្បយុត្តា (ប្រកបដោយវេទនាដែលមិនមែនទុក្ខមិនមែនសុខ)** ។ **និធិ** ដែលចោរទាំងឡាយលួចយកទៅមិនបាន ឈ្មោះថា **អចោរាហរណោ** ។ អធិប្បាយថា រមែងជានិធិដែលចោរទាំងឡាយលួចទៅមិនបាន ឈ្មោះថា **និធិ** ព្រោះគេកប់ទុក ។ ព្រះមានព្រះភាគ កាលទ្រង់ពណ៌នាគុណរបស់បុញ្ញនិធិនោះ ដោយ ២ បទដើម យ៉ាងនេះហើយ បន្ទាប់មក ក៏ទ្រង់ញ៉ាំងឧស្សាហៈឲ្យកើតក្នុងបុញ្ញនិធិនោះ ដោយ ២ បទក្រោយ ទើបត្រាស់ថា **បុញ្ញនិធិណា ជាប់តាមខ្លួនទៅបាន អ្នកប្រាជ្ញគប្បីធ្វើបុញ្ញនិធិនោះ** ។

គាថានោះមានអត្ថថា ព្រោះធម្មតាបុញ្ញនិធិ មិនជាសាធារណៈដល់ជនដទៃ និងជានិធិដែលចោរលួចមិនបាន ។ តែក៏មិនមែននិធិដែលមិនសាធារណៈ និងចោរលួចទៅមិនបានតែម្យ៉ាងប៉ុណ្ណោះទេ ដោយពិត និធិនោះ រមែងជាប់ទៅតាមខ្លួនបាន ដែលត្រាស់ទុកថា “កំណប់ទ្រព្យនោះគេកប់ទុកល្អហើយ នរណាៗ ដណ្តើមយកមិនបាន ជារបស់ជាប់តាមខ្លួន

បាន ក៏ព្រោះកំណប់ទ្រព្យនោះ ឈ្មោះថា បុញ្ញនិធិនោះឯង ដូច្នោះ អ្នកប្រាជ្ញ គឺ បុគ្គលអ្នកដល់ព្រមដោយពុទ្ធិសេចក្តីដឹង ដល់ព្រមដោយធិតិ គឺបញ្ញា គប្បីបំពេញបុណ្យទាំងឡាយ ។

ពណ្ណនាគាថាទី ១០

ព្រះមានព្រះភាគ កាលទ្រង់ញ៉ាំងឧស្សាហៈឲ្យកើតដល់ទេវតា និងមនុស្សទាំងឡាយ ក្នុងបុញ្ញនិធិ ដោយការពណ៌នាគុណយ៉ាងនេះហើយ ឥឡូវនេះ ជនពួកណាឧស្សាហៈហើយ ធ្វើឧស្សាហៈនោះឲ្យសម្រេចផល ដោយការធ្វើបុញ្ញនិធិ បុញ្ញនិធិរបស់ជនទាំងនោះ រមែងឲ្យផលយ៉ាងណា កាលទ្រង់សំដែងផលនោះដោយសង្ខេប ទើបត្រាស់ថា បុញ្ញនិធិនោះឲ្យផលដែលគួរប្រាថ្នាគ្រប់យ៉ាង ដល់ទេវតា និងមនុស្សទាំងឡាយ ។

ឥឡូវនេះ ព្រោះហេតុដែលបុញ្ញនិធិ ជាប់ដោយសេចក្តីប្រាថ្នា ជាគ្រឿងឲ្យវត្ថុតាមប្រាថ្នា ទើបនឹងវៀរសេចក្តីប្រាថ្នាចេញមិនបាន ដូចដែលត្រាស់ទុកថា ៖

ម្នាលគហបតីទាំងឡាយ បើអ្នកប្រព្រឹត្តធម៌ ប្រព្រឹត្តស្មើ

គប្បីប្រាថ្នាថា ឱហ្ន៎ ខាងមុខអំពីសេចក្ដីស្លាប់ទៅ ព្រោះ
កាយបែកធ្លាយ យើងគប្បីចូលដល់ភាពជាសំឡាញ់របស់
ពួកក្សត្រិយ៍មហាសាល ប្រការដែលគេសង្ឃឹមថា ខាង
មុខអំពីសេចក្ដីស្លាប់ ព្រោះកាយបែកធ្លាយ យើងគប្បី
ចូលដល់ភាពជាសំឡាញ់របស់ពួកក្សត្រិយ៍មហាសាល ក៏
ជាឋានៈប្រព្រឹត្តទៅបាន ។ សេចក្ដីនោះ ព្រោះហេតុអ្វី ។
ក៏ព្រោះបុគ្គលនោះ ជាអ្នកប្រព្រឹត្តធម៌ ប្រព្រឹត្តស្មើ យ៉ាង
នោះ ។ល។ គេធ្វើឲ្យជាក់ច្បាស់ចេតោវិមុត្តិ បញ្ញាវិមុត្តិ
ដែលរកអាសវៈមិនបាន ដោយបញ្ញាដ៏ក្រៃលែងឯង ក្នុង
បច្ចុប្បន្ន គេចូលដល់ហើយ ។ សេចក្ដីនោះ ព្រោះហេតុ
អ្វី ។ ក៏ព្រោះគេជាអ្នកប្រព្រឹត្តធម៌ ប្រព្រឹត្តស្មើ ។

ពិតហើយ ព្រះមានព្រះភាគត្រាស់ថា ៖

ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងធម្មវិន័យនេះ រមែងជា
អ្នកប្រកបដោយ សទ្ធា ប្រកបដោយសីល សុត្តៈ ចាគៈ

បញ្ញា ភិក្ខុនោះប្រាថ្នាយ៉ាងនេះថា ឱហ្ន៎ ខាងមុខអំពីការស្លាប់ទៅ ព្រោះកាយបែកធ្លាយ យើងគប្បីចូលដល់ភាពជាសំឡាញ់របស់ពួកក្សត្រិយ៍មហាសាល ។ ភិក្ខុនោះតាំងចិត្តនោះ អធិដ្ឋានចិត្តនោះ ចម្រើនចិត្តនោះ ។ សង្ខារ (បច្ច័យជាគ្រឿងតាក់តែង) និងវិហារធម៌ (គ្រឿងនៅ) ទាំងនោះ ដែលភិក្ខុនោះចម្រើនឲ្យច្រើនយ៉ាងនេះ ធ្វើឲ្យច្រើនយ៉ាងនេះ រមែងប្រព្រឹត្តទៅដើម្បីកើតក្នុងទីនោះឯង ដូច្នេះជាដើម ។

ព្រោះដូច្នោះ លុះទ្រង់សំដែងបរិយាយនៃសេចក្តីសង្ឃឹមយ៉ាងនោះ សេចក្តីប្រាថ្នាដែលមានអធិដ្ឋានភាវនា ដោយការតាំងចិត្តជាបរិក្ខារ ហេតុក្នុងបុញ្ញនិធិនោះ ឲ្យផលដែលគួរប្រាថ្នាគ្រប់យ៉ាងនោះ ទើបត្រាស់ថា ៖

ទេវតា និងមនុស្ស ប្រាថ្នាណាស់នូវឥដ្ឋផលណាៗ ឥដ្ឋផលទាំងអស់នោះៗ ដែលបុគ្គលរមែងបានដោយបុញ្ញនិធិនោះ ។

ពណ៌នាគាថាទី ១១

ឥឡូវនេះ ព្រះមានព្រះភាគ កាលទ្រង់សំដែងដល់ឥដ្ឋផលទាំងពួង នោះ ដែលបុគ្គលបានដោយបុញ្ញនិធិនោះៗ ទើបត្រាស់ព្រះគាថា ជាដើម យ៉ាងនេះថា សុវណ្ណតា សុសរតា (មានវណ្ណៈល្អ មានសំឡេងពីរោះ) ។

បណ្ដាគាថាទាំងនោះ នឹងវិនិច្ឆ័យក្នុងគាថាទី ១ មុន ការមានពណ៌សម្បុរល្អ ការមានពណ៌ស្បែកស្រដៀងមាស ឈ្មោះថា ភាពជាអ្នកមានវណ្ណៈល្អ ភាពជាអ្នកមានវណ្ណៈល្អសូម្បីនោះ បុគ្គលរមែងបានដោយបុញ្ញ-និធិនោះ ដូចដែលត្រាស់ទុកថា ៖

ម្នាលភិក្ខុទាំងឡាយ ជាតិមុន ភពមុន កំណើតមុន តថាគតកើតជាមនុស្សពីមុន ជាអ្នកមិនក្រោធ មិនច្រើនដោយសេចក្ដីចង្អៀតចង្អល់ចិត្ត សូម្បីត្រូវគេពោលច្រើនៗ ក៏សង្កត់ចិត្ត មិនក្រោធ មិនព្យាបាទ មិនប្រើកម្លាំង មិនធ្វើសេចក្ដីកម្រើក ទោសៈ និងការមិនមានហេតុបច្ច័យឲ្យប្រាកដ ទាំងជាអ្នកឲ្យសំពត់ក្រាល សំពត់ដណ្ដប់សាច់ល្អិត សំពត់សំបកឈើសាច់ល្អិត សំពត់

ដែលមានសាច់ល្អិត សំពត់ថ្មីសាច់ល្អិត សំពត់កម្ពល សាច់ល្អិត យ៉ាងណា ។ តថាគតនោះ ព្រោះការធ្វើ និងសន្សំកម្មនោះ ។លៗ តថាគតនោះ ចុតិចាកភាព នោះហើយ ទើបមកកាន់ភាពជាយ៉ាងនេះ រមែងបាន មហាបុរិសលក្ខណៈនេះ គឺ ជាអ្នកមានវណ្ណៈដូចមាស មានសម្បុរស្រដៀងមាស ។

ភាពជាអ្នកមានសំឡេងដូចព្រហ្ម ភាពជាអ្នកនិយាយសំឡេង ដូចសត្វករវិក ឈ្មោះថា ភាពជាអ្នកមានសំឡេងពីរោះ ភាពជាអ្នកមានសំឡេងពីរោះនោះ ដែលបុគ្គលរមែងបានក៏ដោយបុញ្ញនិធិនេះ ដូចដែលត្រាស់ទុកថា ៖

ម្នាលភិក្ខុទាំងឡាយ ជាតិមុន ភពមុន កំណើតមុន តថាគតកើតជាមនុស្សពីមុន លះវាចាគ្រោតគ្រាត វៀរ ជាច់ខាតចាកវាចាគ្រោតគ្រាត ។ ពោលតែវាចាមិនមាន ទោស សប្បាយត្រចៀក គួរស្រឡាញ់ ពេញចិត្ត ជា

វាចាអ្នកក្រុង ជនជាច្រើនស្រឡាញ់រាប់អាន ពេញចិត្ត

យ៉ាងណា ។ តថាគតនោះ ព្រោះការធ្វើ និងការសន្សំ

កម្មនោះ ។ល។ តថាគតនោះ ចុតិចាកភពនោះហើយ

ទើបមកកាន់ភាពជាយ៉ាងនេះ រមែងបាននូវមហាបុរិស

លក្ខណៈ ២ យ៉ាងនេះ គឺ ជាអ្នកមានជីវ្ហាធំ មានសំឡេង

ដូចព្រហ្ម និយាយសំឡេងដូចសត្វករវិក ។

បទថា សុសណ្ឋានា (ការមានទ្រង់ទ្រាយល្អ) បានដល់ ការមាន ទ្រង់ទ្រាយសមសួន លោកអធិប្បាយថា ការតាំងនៅនៃអវយវៈធំតូចក្នុង ទីដែលគួរពេញ និងមូលក្លំ ដោយភាពជាអវយវៈពេញ និងមូលក្លំ ដូច ដែលត្រាស់ទុកថា ៖

ម្នាលភិក្ខុទាំងឡាយ ជាតិមុន ភពមុន កំណើតមុន

តថាគតកើតជាមនុស្សពីមុន ប្រាថ្នាប្រយោជន៍ ប្រាថ្នា

សេចក្តីចម្រើន ប្រាថ្នាសេចក្តីសុខ ប្រាថ្នាសេចក្តីក្សេម

ប្រាសចាកយោគៈ ដល់ជនដ៏ច្រើន គប្បីញ៉ាំងជនទាំង

នេះឲ្យចម្រើនដោយសទ្ធា សីលៈ សុតៈ ចាគៈ បញ្ញា គប្បីឲ្យចម្រើនដោយទ្រព្យ និងធញ្ញជាតិ ដោយស្រែ ចំការ ទីដី ដោយសត្វជើង ២ ជើង ៤ ដោយបុត្រ ភរិយា ដោយទាសកម្មករ ដោយញាតិមិត្រ ពួកពង្ស យ៉ាងណា តថាគតនោះ ព្រោះការធ្វើ និងសន្សំកម្មនោះ ។បេ។ តថាគតនោះ ចុតិចាកភពនោះ មកកាន់ភាពជា យ៉ាងនេះ រមែងបានមហាបុរិសលក្ខណៈ ៣ ទាំងនេះ គឺ មានព្រះកាយពាក់កណ្ដាលលើដូចសីហៈ មានចន្លោះ ព្រះអង្សៈ (គឺព្រះខរៈ) ល្អ និងមានព្រះអង្គៈមូលក្លំស្មើ ដូច្នេះជាដើម ។

បទនៃព្រះសូត្រទាំងឡាយ ដែលធ្វើឲ្យបានសម្រេចដោយបុញ្ញនិធិនេះ សូម្បីក្នុងដទៃក្រៅពីនេះ ក៏គប្បីនាំមកអំពីទីនោះៗ ពោលដោយន័យនេះ ។ តែព្រោះខ្លាចពិស្ដារហួសពេក ទើបបាន (ពោល) សង្ខេបទុកឥឡូវនេះ ខ្ញុំនឹងធ្វើការពណ៌នាបទដ៏សេស ។

ទូទាំងរឿងរ៉ាវគប្បីជ្រាបថា រូប ក្នុងបទថា **សុរូបតា** (ការមានរូបស្អាត) នេះ ។ ដូចក្នុងប្រយោគជាដើមយ៉ាងនេះថា សភាពដែលអាកាសហែហម រមែងរាប់ថា រូប នោះឯង ។ សភាពដែលរូបនោះល្អ ឈ្មោះថា ការមានរូបស្អាត លោកអធិប្បាយថា មិនវែងពេក មិនខ្លីពេក មិនធាត់ពេក មិនស្គមពេក មិនខ្មៅពេក មិនសពេក ។ បទថា **អាធិបច្ចំ** ប្រែថា ភាពជាធំ អធិប្បាយថា ជាប្រធាន ព្រោះជាក្សត្រិយ៍មហាសាលជាដើម ។ បទថា **បរិវារោ** (ការមានបរិវារ) បានដល់ ចំពោះគ្រហស្ថ សម្បត្តិ គឺជនរបស់ខ្លួន និងជនដោយជុំវិញ ចំពោះបព្វជិត សម្បត្តិ គឺ បរិស័ទ ។ ភាពជាធំ និងការមានបរិវារ ឈ្មោះថា **ភាពជាធំ និងមានបរិវារ** ។ ក៏បណ្ដាឥដ្ឋផលទាំងនោះ គប្បីជ្រាបថា ភាពដែលដល់ព្រមនៃសរីរៈ ត្រាស់ដោយភាពជាអ្នកមានវណ្ណៈស្អាតជាដើម សម្បត្តិ គឺ ភោគៈ ត្រាស់ដោយភាពជាធំ សម្បត្តិ គឺ ជនរបស់ខ្លួន និងជនដោយជុំវិញ ត្រាស់ដោយភាពជាបរិវារ ។ ដោយបទថា **សព្វមេតេន លព្ភតិ** (ឥដ្ឋផលទាំងអស់នោះដែលបុគ្គលរមែងបានដោយបុញ្ញនិធិនេះ) ព្រះមានព្រះភាគទ្រង់សំដែងថា

ក្នុងពាក្យដែលត្រាស់ថា "ទេវតា និងមនុស្សទាំងឡាយប្រាថ្នាផលណា ៗ ផលនោះៗ ទាំងអស់ ដែលបុគ្គលរមែងបានដោយបុញ្ញនិធិទាំងអស់នោះ ឥដ្ឋផល មានវណ្ណៈស្អាតជាដើម ដែលត្រាស់ទុកផ្ទេកដំបូងមុននេះ គប្បីជ្រាបថា ឥដ្ឋផលទាំងអស់នោះ បុគ្គលរមែងបានដោយបុញ្ញនិធិនេះ" ។

## ពណ៌នាគាថាទី ១២

ព្រះមានព្រះភាគ កាលទ្រង់សំដែងសម្បត្តិរបស់ទេវតា និងមនុស្សដែលទាបជាងសម្បត្តិ គឺ ភាពជាព្រះរាជា ដែលបុគ្គលគប្បីបានដោយបុញ្ញានុភាព ដោយគាថាយ៉ាងនេះហើយ ឥឡូវនេះ កាលទ្រង់សំដែងសម្បត្តិ គឺ ភាពជាព្រះរាជាទាំង ២ នោះ ទើបត្រាស់គាថានេះថា ៖

ភាពជាព្រះរាជាគ្រប់គ្រងប្រទេស ភាពជាធំ (គឺ
ចក្រពត្តិរាជ) សុខរបស់ស្តេចចក្រពត្តិដែលគួរស្រឡាញ់
សូម្បីភាពជាព្រះរាជានៃទេវតាក្នុងពួកទិព្វ ឥដ្ឋផលទាំង
អស់នោះ ដែលបុគ្គលរមែងបានដោយបុញ្ញនិធិនេះ ។

បណ្តាបទទាំងនោះ បទថា បទេសរជ្ជំ (ភាពជាព្រះរាជានៃប្រទេស)

បានដល់ ភាពជាព្រះរាជា នៃប្រទេស (ផែនដី) ក្នុងប្រទេសមួយៗ សូម្បីតែទ្វីបមួយក៏មិនដល់ទាំងអស់ ។ ភាពជាព្រះរាជាជាធំ ឈ្មោះថា **ភាពជាធំ** ទ្រង់សំដែងភាពជាស្តេចចក្រពត្តិនៃទ្វីប ដោយពាក្យនេះ ។ សុខរបស់ស្តេចចក្រពត្តិ ឈ្មោះថា **ចក្រពត្តិសុខ** ។ បទថា **បិយំ** (គួរស្រឡាញ់) បានដល់ គួរប្រាថ្នា គួរស្រឡាញ់ គួរពេញចិត្ត ។ ទ្រង់សំដែងភាពជាស្តេចចក្រពត្តិ មានមហាសមុទ្រទាំង ៤ ជាដែន ដោយពាក្យនេះ ។ ភាពជាព្រះរាជាក្នុងពួកទេវតា ឈ្មោះថា **ភាពជាព្រះរាជានៃភព** ។ ដែលទ្រង់សំដែងភាពជាព្រះរាជានៃទេវតារបស់មនុស្សទាំងឡាយ មានព្រះបាទមន្ធាតុជាដើម ដោយពាក្យនេះ ។ ដោយបទថា **អបិ ទិព្វេសុ** (ក្នុងពពួកទិព្វ) នេះ ទ្រង់សំដែងភាពជាព្រះរាជានៃទេវតារបស់មនុស្សទាំងឡាយ សូម្បីដែលកើតក្នុងពពួកទិព្វទាំងឡាយ ដែលគេដឹងថា ទិព្វ ព្រោះមានក្នុងភពទិព្វ ។ ដោយបទថា **សព្វមេតេន លព្ភតិ (ឥដ្ឋផលទាំងអស់នោះ បុគ្គលរមែងបានដោយបុញ្ញនិធិនេះ)** ទ្រង់សំដែងថា "ទេវតា និងមនុស្សទាំងឡាយប្រាថ្នាផលណាៗ ផលនោះៗ ទាំងអស់នោះ ដែលបុគ្គលរមែងបានដោយ

បុញ្ញនិធិនោះ ឥដ្ឋផលមានភាព ជាព្រះរាជាប្រទេសរាជជាដើម ដែលត្រាស់

ពណ៌នាគាថាទី ១៣

ព្រះមានព្រះភាគ លុះទ្រង់សំដែងសម្បត្តិ គឺ ភាពជាព្រះរាជារបស់ទេវតា និងមនុស្ស ដែលបុគ្គលគប្បីបានដោយបុញ្ញានុភាព ដោយគាថាយ៉ាងនេះហើយ ឥឡូវនេះ កាលទ្រង់ធ្វើសម្បត្តិដែលត្រាស់ដោយ ២ គាថាទុកខាងមុខដោយសង្ខេប នឹងទ្រង់សំដែងសម្បត្តិដែលត្រាស់ដោយ ២ គាថាទុកខាងមុខដោយសង្ខេប នឹងទ្រង់សំដែងសម្បត្តិ គឺ ព្រះនិព្វាន ទើបត្រាស់គាថានេះថា ៖

*សម្បត្តិរបស់មនុស្ស សេចក្តីត្រេកអរណា*
*ក្នុងទេវលោក និងសម្បត្តិ គឺ ព្រះនិព្វានណា ឥដ្ឋ-*
*ផលនោះ ដែលបុគ្គលបានដោយបុញ្ញនិធិនេះ ។*

ពណ៌នាបទរបស់គាថានោះ មានដូច្នេះ ឈ្មោះថា **មានុសី** ព្រោះរបស់នេះមានហើយដល់មនុស្សទាំងឡាយ មានុសីនុ៎ះឯង ឈ្មោះ មានុសិកា ។ ការដល់ព្រម ឈ្មោះថា **សម្បត្តិ** ។ លោករបស់ទេវតាទាំងឡាយ

ឈ្មោះថា **ទេវលោក** ។ ក្នុងទេវលោកនោះ ។ បទថា **យា** (ណា) ជាការកាន់យកមិនមានចំណែកសល់ ។ ឈ្មោះថា **រតិ** ព្រោះត្រេកអរដោយសម្បត្តិដែលកើតខាងក្នុង ឬជាគ្រឿងឧបករណ៍ខាងក្រៅ ។ ពាក្យនេះជាឈ្មោះនៃសេចក្ដីសុខ និងវត្ថុគ្រឿងឲ្យមានសេចក្ដីសុខ ។ បទថា **យា** (ណា) ជាពាក្យសំដែងសេចក្ដីមិនពិតប្រាកដ ។ ច ស័ព្ទ មានអត្ថដូចគ្នានឹងសម្បត្តិទាំងពួង ។ ព្រះនិព្វាននោះឯង ឈ្មោះថា **សម្បត្តិ** **គឺ** **ព្រះនិព្វាន** ។

ក៏ការពណ៌នាអត្ថ មានដូច្នេះ ដោយបទថា សុវណ្ណតា (ការមានវណ្ណៈល្អ) ជាដើម សម្បត្តិ និងសេចក្ដីត្រេកអរនោះណា ត្រាស់ថា **មានុស្សិកា ច សម្បត្តិ ទេវលោកេ ច យា រតិ** (សម្បត្តិរបស់មនុស្ស និងសេចក្ដីត្រេកអរណាក្នុងលោក) ។ សម្បត្តិ និងសេចក្ដីត្រេកអរទាំងអស់នោះ និងសម្បត្តិ គឺ ព្រះនិព្វាន ដែលបុគ្គលគប្បីបានដោយចំណែកជាព្រះអរិយបុគ្គល ដែលមានសទ្ធានុសារីជាដើម ឥដ្ឋផលដូចពោលមកនេះ ទ្រង់ត្រាស់ចំណែកទី ៣ គប្បីជ្រាបថា ឥដ្ឋផលទាំងអស់នោះ ដែលបុគ្គលរមែង

បានព្រោះបុញ្ញនិធិនេះ ។

ន័យម្យ៉ាងទៀត សម្បត្តិរបស់មនុស្សឯណា ដែលមិនបានត្រាស់ទុកមុន ដោយឥដ្ឋផលមានភាពមានវណ្ណៈល្អជាដើម និងផ្សេងដោយភាពជាអ្នកឆ្លាតឈ្លាសជាដើម ដែលលោកសំដែងទុកដោយន័យយ៉ាងនេះថា ជាអ្នកអាចហ៊ាន មានសតិ ការនៅប្រព្រឹត្តព្រហ្មចរិយៈក្នុងព្រះធម្មវិន័យនេះជាដើម សម្បត្តិដែលជារបស់មនុស្ស និងសេចក្តីត្រេកអរក្នុងឈានជាដើមក្នុងទេវលោកយ៉ាងដទៃណា និងនិព្វានសម្បត្តិ មានប្រការដូចពោលមកហើយឯណា ឥដ្ឋផលដូចពោលមកនេះ ត្រាស់ទុកជាចំណែកទី ៣ គប្បីជ្រាបថា ឥដ្ឋផលទាំងអស់នោះ ដែលបុគ្គលរមែងបានដោយបុញ្ញនិធិ ។ គប្បីជ្រាបការពណ៌នាសេចក្តីក្នុងប្រការនេះ ដោយប្រការដូច្នេះ ។

## ពណ៌នាគាថាទី ១៤

ព្រះមានព្រះភាគ កាលទ្រង់សំដែងដល់និព្វានសម្បត្តិ ដែលគប្បីបានដោយបុញ្ញានុភាព និងដែលគប្បីបានសម្រេចភាពជាព្រះអរិយបុគ្គលជាសទ្ធានុសារីជាដើម ដោយគាថានេះយ៉ាងហើយ ឥឡូវនេះ កាលទ្រង់

សំដែងនិព្វាននោះ និងឧបាយនៃនិព្វាននោះ ដែលគប្បីសម្រេចដោយភាព
ជាអ្នកជំនាញក្នុងវិជ្ជា ៣ និងឧភតោភាគវិមុត្តិ ទើបត្រាស់គាថានេះថា ៖

កាលដែលបុគ្គលអាស្រ័យសម្បទា គឺ មិត្រហើយ
បើប្រកបដោយឧបាយបញ្ញា ជាអ្នកជំនាញក្នុងវិជ្ជា និង
វិមុត្តិ ឥដ្ឋផលទាំងនោះ ដែលបុគ្គលរមែងបាន ក៏ព្រោះ
បុញ្ញនិធិ ។

ពណ៌នាបទរបស់គាថានោះ មានដូច្នេះថា ឈ្មោះថា សម្បទា ព្រោះ
ជាគ្រឿងសម្រេចផល គឺ ដល់ភាពចម្រើននៃគុណ , សម្បទា គឺ មិត្រ
ឈ្មោះថា មិត្តសម្បទា ។ ដែលជាមិត្រសម្បទានោះ ។ បទថា **អាគម្ម**
ប្រែថា អាស្រ័យ ។ បទថា **យោនិសោ** ប្រែថា ដោយឧបាយ ។ បទថា
**បយុញ្ជតោ** (ប្រកប) បានដល់ ប្រកបដោយសេចក្តីព្យាយាម ។ ឈ្មោះ
ថា **វិជ្ជា** ព្រោះជាគ្រឿងដឹងច្បាស់ ។ ឈ្មោះថា **វិមុត្តិ** ព្រោះជាគ្រឿង
រួចផុត ឬរួចផុតឯង ។ ទាំងវិជ្ជាទាំងវិមុត្តិ ឈ្មោះថា វិជ្ជា និងវិមុត្តិ ។
ភាពជាអ្នកជំនាញក្នុងវិជ្ជា និងវិមុត្តិ ឈ្មោះថា **វិជ្ជាវិមុត្តិវសីភាវៈ** ។

ចំណែកការពណ៌នាអត្ថ មានដូចតទៅនេះ

បទថា **មិត្តសម្បទមាគម្ម** (អាស្រ័យសម្បទា គឺ មិត្រ) សេចក្ដីថា កាលដែលបុគ្គលអាស្រ័យព្រះសាស្ដា ឬសព្រហ្មចារីដែលជាទីតាំងនៃសេចក្ដីគោរពចំពោះលោកណាមួយ ទទួលឱវាទ និងអនុសាសនីអំពីលោកហើយ ប្រកបដោយឧបាយនៃបញ្ញា ដោយការបដិបត្តិតាមដែលលោកទូន្មាន ជាអ្នកជំនាញក្នុងវិជ្ជា ៣ មានបុព្វេនិវាសញ្ញាណជាដើម និងក្នុងវិមុត្តិដែលផ្សេងដោយសមាបត្តិ ៨ និងព្រះនិព្វាន ដែលមកយ៉ាងនេះថា ក្នុងធម៌ទាំងនោះ វិមុត្តិ គឺអ្វី គឺ ការរួចផុតដ៏ក្រៃលែងនៃចិត្ត និងនិព្វាន ដូច្នេះ ដោយភាពជាអ្នកមិនយឺតយូរដោយប្រការនោះៗ នេះណា ផលដែលទ្រង់ត្រាស់ជាចំណែកទី ៤ សូម្បីនេះ គប្បីជ្រាបថា ឥដ្ឋផលទាំងអស់នោះ ដែលបុគ្គលរមែងបានដោយបុញ្ញនិធិ ។

## ពណ៌នាគាថាទី ១៥

ព្រះមានព្រះភាគ លុះទ្រង់សម្ដែងនិព្វានសម្បត្តិដែលគប្បីបាន ដោយអានុភាពរបស់បុណ្យដែលជាចំណែកនៃភាពជាជំនាញក្នុងវិជ្ជា និងវិមុត្តិ ដែល

ពោលមកពីមុនហើយ ដែលគប្បីសម្រេចសូម្បីដោយអំណាចនៃត្រៃវិជ្ជា និង ឧភតោភាគវិមុត្តិដោយគាថានេះ យ៉ាងនេះហើយ ឥឡូវនេះ ព្រោះហេតុដែល លោកសំដៅដល់ភាពជាអ្នកសម្រេចភាពជំនាញក្នុងវិជ្ជា និងវិមុត្តិ សូម្បី ជាអ្នកមានវិជ្ជា ៣ និងរួចផុតហើយដោយចំណែកទាំង ២ (គឺចេតោវិមុត្តិ និងបញ្ញាវិមុត្តិ) ពួកលោកទាំងអស់នោះ មិនមែនបានសេចក្ដីសម្រេចនៃ គុណ មានបដិសម្ភិទាជាដើម តែសេចក្ដីចម្រើននៃគុណ មានបដិសម្ភិទា ជាដើម ដែលបុគ្គលរមែងបានដោយបុញ្ញសម្បទានេះ ដោយប្រការនោះៗ ព្រោះជាបទដ្ឋាននៃសេចក្ដីចម្រើននូវគុណនោះ ដូច្នោះ កាលទ្រង់សំដែង សេចក្ដីចម្រើននូវគុណសូម្បីនោះ ទើបត្រាស់គាថានេះថា ៖

បដិសម្ភិទា វិមោក្ខ សាវកបារមី បច្ចេកពោធិ

និងពុទ្ធិភូមិឯណា ឥដ្ឋផលទាំងអស់នោះ ដែលបុគ្គល

រមែងបានដោយបុញ្ញនិធិនេះ ។

ព្រោះហេតុថា បញ្ញាណា ដែលដល់នូវការបែកធ្លាយក្នុងធម៌ អត្ថ និរុត្តិ និងបដិភាណ លោកហៅថា បដិសម្ភិទា វិមោក្ខ ៨ ទាំងនេះណា

ដោយន័យថា អ្នកមានរូប រមែងឃើញរូបជាដើម ។ សាវកបារមីនេះណា ដែលឲ្យសម្រេចសាវកសម្បត្តិ ដែលព្រះសាវកទាំងឡាយរបស់ព្រះមាន-ព្រះភាគ គប្បីសម្រេច ។ បច្ចេកពោធិណា ដែលឲ្យសម្រេចជាសយម្ភូ និងពុទ្ធភូមិណា ដែលឲ្យសម្រេចភាពជាបុគ្គលខ្ពង់ខ្ពស់លើសពួសត្វ ដែលគេធ្វើហើយដោយប្រពៃ ។ ឥដ្ឋផលដែលត្រាស់ជាចំណែកទី ៥ នេះ គប្បីជ្រាបថា ឥដ្ឋផលទាំងអស់នោះ ដែលបុគ្គលរមែងបានដោយបុញ្ញនិធិនេះ ។

## ពណ៌នាគាថាទី ១៦

ព្រះមានព្រះភាគ កាលទ្រង់សំដែងផលដែលត្រាស់ទុកថា ទេវតានិងមនុស្សទាំងឡាយ ប្រាថ្នាឥដ្ឋផលណាៗ ឥដ្ឋផលទាំងអស់នោះ ដែលបុគ្គលរមែងបានដោយបុញ្ញនិធិនេះ ជាផ្នែកៗ ដោយគាថា ៥ គាថាទាំងនោះ យ៉ាងនេះហើយ ឥឡូវនេះ កាលទ្រង់សរសើរបុញ្ញសម្បទា ដែលគេដឹងមកថា ជានិធិដែលឲ្យផលដែលគួរប្រាថ្នាគ្រប់យ៉ាងនេះ ទើបទ្រង់បញ្ចប់ទេសនាដោយគាថានេះថា ៖

បុញ្ញសម្បទានេះ មានប្រយោជន៍ច្រើនយ៉ាងនេះ ព្រោះ

ដូច្នោះ បណ្ឌិតអ្នកមានបញ្ញា ទើបសរសើរភាពជាអ្នកធ្វើ
បុណ្យទុកហើយ ។

ពណ៌នាបទនៃគាថានោះ ដូច្នេះ ។ បទថា **ឯវំ** (យ៉ាងនេះ) ជាពាក្យសំដែងភាពដែលកន្លងហើយ ។ ឈ្មោះថា **មហត្ថិកា** ព្រោះមានប្រយោជន៍ច្រើន ។ លោកអធិប្បាយថា ប្រព្រឹត្តទៅដើម្បីប្រយោជន៍ដ៏ធំ ។ បាឋៈថា **មហិទ្ធិកា** ដូច្នេះក៏មាន ។ បទថា **ឯសា** (នេះ) ជាពាក្យឧទ្ទេស (សំនួរ) ។ លើកបុញ្ញសម្បទា ដែលត្រាស់តាំងអំពីដើម ពីពាក្យនេះថា **យស្ស ទានេន សីលេន** (កំណប់ទ្រព្យរបស់បុគ្គលណា... កប់ទុកល្អហើយដោយទាន សីល) រហូតដល់បទថា **កយិរាថ ធីរោ បុញ្ញានិ** (អ្នកប្រាជ្ញគប្បីធ្វើបុញ្ញនិធិនោះ) ដោយបទឧទ្ទេសនោះ ។ ស័ព្ទថា **យទិទំ** ជានិបាតចុះក្នុងអត្ថថា ធ្វើឲ្យព្រមគ្នា ។ ដើម្បីទ្រង់អធិប្បាយថា ឧទ្ទេសដែលទ្រង់លើកឡើងថា **ឯសា** ទើបទ្រង់ធ្វើឲ្យព្រមគ្នាថា **យា ឯសា** ដោយស័ព្ទនិបាតថា **យទិទំ** នោះ ។ ការដល់ព្រមនៃបុណ្យទាំងឡាយ ឈ្មោះថា **បុញ្ញសម្បទា** ។ បទថា **តស្មា** (ព្រោះដូច្នោះ) ជាពាក្យសំដែងហេតុ ។

បទថា **ធីរ** បានដល់ អ្នកមានបញ្ញា ។ បទថា **បសំសន្តិ** ប្រែថា សរសើរ ។ បទថា **បណ្ឌិតា (បណ្ឌិត)** បានដល់ អ្នកដល់ព្រមដោយបញ្ញា ។ បទថា **កតបុញ្ញតំ** ប្រែថា ភាពជាអ្នកធ្វើបុណ្យទុកហើយ ។

ចំណែកការពណ៌នាអត្ថមានដូច្នេះថា ព្រះមានព្រះភាគ កាលទ្រង់សរសើរបុញ្ញនិធិ ភាពជាអ្នកមានវណ្ណៈស្រស់ស្អាតជាដើម មានពុទ្ធភូមិជាទីបំផុត ដែលល្មមបុគ្គលនឹងគប្បីសម្រេចបាន ដោយអានុភាពនៃសម្បទាដូច្នេះហើយ ឥឡូវនេះ កាលទ្រង់ប្រមូលសំដែងតាមប្រការនោះៗ ឯង លុះទ្រង់លើកយកបុញ្ញសម្បទាតាមប្រការដែលពោលហើយ មានប្រយោជន៍ច្រើន ដោយពាក្យនោះឯង ទើបត្រាស់ថា ប្រការដែលបុញ្ញសម្បទា ដែលឈ្មោះថា មានប្រយោជន៍ច្រើន ព្រោះនាំមកនូវប្រយោជន៍ធំយ៉ាងនេះ ដែលតថាគតសំដែងដោយន័យថា **យស្ស ទានេន សីលេន** យ៉ាងនេះជាដើម ព្រោះដូច្នោះ បណ្ឌិតអ្នកមានបញ្ញាដូចតថាគត ទើបសរសើរបុគ្គលអ្នកធ្វើបុណ្យទុកហើយ ដែលមានអាការ និងវោហារ គឺ ខន្ធច្រើន ដោយពាក្យដែលពោលក្នុងទីនេះថា **និធិ** មិនសាធារណៈដល់ជនដទៃៗ ដែលចោរលួច

យកទៅមិនបានជាដើម និងដែលមិនបានពោលទុក (ក្នុងទីនេះ) ថា "ម្នាល ភិក្ខុទាំងឡាយ ពួកអ្នកកុំខ្លាចបុណ្យឡើយ ពាក្យថា បុណ្យ ជាឈ្មោះរបស់សេចក្តីសុខ ដូច្នេះជាដើម ដោយគុណតាមសេចក្តីពិត ព្រោះមិនខ្ជិលច្រអូសក្នុងការសាំដែងធម៌ ដែលនាំមកនូវប្រយោជន៍សុខដល់សត្វទាំងឡាយ មិនមែនសរសើរព្រោះយល់ដល់បក្ខពួករបស់ខ្លួន" ។

ចប់ទេសនា ឧបាសកនោះ ក៏តាំងនៅក្នុងសោតាបត្តិផលព្រមដោយជនជាច្រើន និងគេក៏ចូលគាល់ព្រះបាទបសេនទិកោសល ក្រាបទូលសេចក្តីនោះ ។ ព្រះរាជាទ្រង់ត្រេកអរដ៏ក្រៃលែង ទ្រង់សរសើរថា "សាធុ គហបតី សាធុ គហបតី លោកកប់កំណប់ទ្រព្យ ដែលសូម្បីយើងក៏នាំទៅមិនបាន" ទ្រង់បានធ្វើការបូជាដ៏ច្រើនដល់ឧបាសកនោះឯង ។

ចប់អដ្ឋកថា និធិកណ្ឌសូត្រទី ៨

# អដ្ឋកថា មេត្តសូត្រទី ៩

## ពោលដោយការផ្សាយមេត្តាក្នុងសត្វទាំងពួង

## ( ប្រយោជន៍នៃការតាំងសូត្រ )

*គប្បីជ្រាបវិនិច្ឆ័យក្នុង មេត្តសូត្រទី ៩ ដូចតទៅនេះ ៖*

[១០] *ឥឡូវនេះ ដល់លំដាប់ពណ៌នាសេចក្ដីរបស់មេត្តសូត្រ ដែលតាំងទុកក្នុងលំដាប់បន្ទាប់ពីនិធិកណ្ឌសូត្រ ។ ក្នុងទីនេះ ខ្ញុំនឹងពោលដល់ប្រយោជន៍នៃការតាំងមេត្តសូត្រនោះ តពីនោះ គប្បីជ្រាបការអធិប្បាយបទទាំងនេះថា មេត្តសូត្រនោះនរណាពោល ពោលកាលណា ពោលក្នុងទីណា និងពោលព្រោះហេតុអ្វី ខ្ញុំជម្រះនិទានហើយ ទើបនឹងធ្វើការពណ៌នាអត្ថរបស់មេត្តសូត្រនោះ ។*

*ក្នុងមេត្តសូត្រនោះ ព្រោះហេតុដែលត្រាស់បុញ្ញសម្បទា មានទានសីលជាដើម ដោយនិធិកណ្ឌសូត្រ ។ កាលបុគ្គលធ្វើមេត្តាក្នុងសត្វទាំងឡាយ បុញ្ញសម្បទានោះរមែងមានផលច្រើន រហូតដល់អាចធ្វើឲ្យសម្រេចពុទ្ធភូមិបាន ដូច្នោះ ខ្ញុំទើបលើកយកមេត្តសូត្រឡើងតាំងទុកក្នុងទីនេះ ដើម្បី*

សំដែងថា មេត្តាជាឧបការៈដល់បុញ្ញសម្បទានោះ ឬព្រោះហេតុដែលខ្ញុំត្រា សំដែងកម្មដ្ឋានដែលអាចលះរាគៈ ដោយទូតីវ្យាការ សម្រាប់ជនទាំងឡាយ អ្នករាប់អានព្រះពុទ្ធសាសនាដោយសរណៈហើយ តាំងនៅក្នុងសីលដោយ សិក្ខាបទទាំងឡាយ និងអាចលះមោហៈ ដោយកុមារបញ្ហា ទើបសំដែងថា ការប្រព្រឹត្តសរណៈជាដើមនោះ ជាមង្គល និងរក្សាខ្លួនឯងដោយមង្គលសូត្រ សំដែងការរក្សាអ្នកដទៃដែលសមគួរដល់មង្គលនោះ ដោយរតនសូត្រ សំដែង ការឃើញពួកភូតខ្លះ ក្នុងបណ្តាភូតទាំងឡាយដែលពោលទុកក្នុងរតនសូត្រ និងការវិបត្តិរបស់ពួកជនដែលប្រមាទក្នុងបុញ្ញសម្បត្តិ ដូចដែលពោលហើយ ដោយតិរោកុឌ្ឌសូត្រ និងសំដែងសម្បត្តិដែលជាបដិបក្ខចំពោះវិបត្តិ ដែល ពោលទុកក្នុងតិរោកុឌ្ឌសូត្រ ដោយនិធិកណ្ឌសូត្រ តែមិនទាន់បានសំដែង កម្មដ្ឋានដែលអាចលះទោសៈ ដូច្នោះ ដើម្បីសំដែងកម្មដ្ឋានដែលអាចលះ ទោសៈនោះ ខ្ញុំនឹងលើកយកមេត្តសូត្រនេះ ឡើងតាំងទុកក្នុងទីនេះ ។ បើ ដូច្នោះ ខុទ្ទកបាឋៈ ទើបបរិបូណ៌ដោយល្អ ប្រការដែលពោលមកនេះ ជា ប្រយោជន៍នៃការតាំងមេត្តសូត្រនោះទុកក្នុងទីនេះ ។

## ការជម្រះនិទាន

ឥឡូវនេះ ខ្ញុំនឹងលើកយកមាតិកានេះទុកថា ៖

គប្បីជ្រាបការអធិប្បាយបទទាំងនេះថា មេត្តសូត្រនេះ

នរណាពោល ពោលកាលណា ពោលក្នុងទីណា និង

ពោលព្រោះហេតុអ្វី ខ្ញុំជម្រះនិទានហើយ ទើបធ្វើការ

ពណ៌នាសេចក្តីរបស់មេត្តសូត្រនោះ ដូច្នេះ ។

ក្នុងមាតិកានេះ គប្បីជ្រាបការអធិប្បាយបទទាំងនេះ និងការជម្រះនិទានដោយសង្ខេបយ៉ាងនេះមុនថា មេត្តសូត្រនេះ ព្រះមានព្រះភាគត្រាស់ដោយព្រះអង្គឯង សាវ័កជាដើមមិនបានពោល ។ ប៉ុន្តែថា កាលណាភិក្ខុទាំងឡាយត្រូវទេវតាទាំងឡាយរំខាននៅជិតភ្នំហិមពាន្ត ទើបនាំគ្នាមកគាល់ព្រះមានព្រះភាគ កាលនោះ ព្រះមានព្រះភាគទើបត្រាស់មេត្តសូត្រនោះ ដើម្បីការពារ និងដើម្បីជាកម្មដ្ឋានសម្រាប់ភិក្ខុទាំងនោះ ។

ចំណែកដោយពិស្តារ គប្បីជ្រាបយ៉ាងនេះ ៖

សម័យមួយ ជិតតិបីចូលវស្សា ព្រះមានព្រះភាគប្រថាប់នៅក្នុងក្រុង

សាវត្ថី ។ សម័យនោះ ភិក្ខុទាំងឡាយជាច្រើន ចាកចេញពីប្រទេសចំនួនច្រើនទទួលកម្មដ្ឋានក្នុងសំណាក់ព្រះមានព្រះភាគ ប្រាថ្នានឹងចូលចាំវស្សាក្នុងទីនោះៗ ទើបចូលគាល់ព្រះមានព្រះភាគ បានឮថា សម័យនោះ ព្រះមានព្រះភាគត្រាស់កម្មដ្ឋានទាំងឡាយដែលអនុកូលដល់ចរិតចំនួន ៨៤.០០០ ប្រភេទដោយន័យនេះ គឺ អសុភកម្មដ្ឋាន ១១ យ៉ាង គឺ អសុភដែលមានវិញ្ញាណ និងមិនមានវិញ្ញាណ សម្រាប់បុគ្គលរាគចរិត ។ កម្មដ្ឋាន មានមេត្តាកម្មដ្ឋានជាដើម សម្រាប់បុគ្គលទោសចរិត ។ កម្មដ្ឋាន មានមរណស្សតិកម្មដ្ឋានជាដើម សម្រាប់បុគ្គលមោហចរិត ។ កម្មដ្ឋាន មានពុទ្ធានុស្សតិកម្មដ្ឋានជាដើម សម្រាប់បុគ្គលសទ្ធាចរិត ។ កម្មដ្ឋាន មានចតុធាតុវវត្ថានកម្មដ្ឋានជាដើម សម្រាប់បុគ្គលពុទ្ធិចរិត ។

លំដាប់នោះ ភិក្ខុប្រមាណ ៥០០ រូប រៀនកម្មដ្ឋានក្នុងសំណាក់ព្រះមានព្រះភាគ កំពុងស្វែងរកសេនាសនៈដែលជាទីសប្បាយ និងគោចរគ្រាម ដើរទៅតាមលំដាប់ បានជួបភ្នំ មានផែនថ្មស្រដៀងមណី ពណ៌ក្រម៉ៅ ប្រដាប់ដោយដងព្រៃពណ៌ខៀវ មានម្លប់ត្រជាក់ មានភូមិភាគពេញ

ទៅដោយខ្សាច់ដូចផែនប្រាក់មុក្តា ខ្យល់សមុទ្របក់មកគួរជាទីរីករាយ ជាប់ផ្ទៃជាមួយព្រៃហិមពាន្ត ក្នុងបច្ចន្តប្រទេស ។ ភិក្ខុទាំងនោះ ស្នាក់នៅមួយយប់ក្នុងទីនោះ កាលរាត្រីជិតភ្លឺធ្វើសរីរៈកិច្ចស្រេចហើយ ក៏នាំគ្នាចូលទៅបណ្ឌិបាតនៅក្នុងស្រុកមួយកន្លែងជិតទីនោះឯង ។ ពួកអ្នកស្រុកប្រកបដោយត្រកូល ១.០០០ អាស្រ័យនៅជាមួយគ្នាក្នុងស្រុកនោះ មនុស្សទាំងឡាយមានបសាទសទ្ធា ពួកគេគ្រាន់តែឃើញភិក្ខុទាំងឡាយប៉ុណ្ណោះ ក៏កើតបីតិសោមនស្ស ព្រោះការឃើញបព្វជិតក្នុងបច្ចន្តប្រទេស រកបានដោយកម្រនិមន្តភិក្ខុទាំងនោះឲ្យឆាន់ហើយ ក៏អង្វរថា បពិត្រលោកម្ចាស់ សូមលោកម្ចាស់នៅក្នុងទីនេះរហូតអស់ត្រៃមាសចុះ ហើយនាំគ្នាសាងកុដិសម្រាប់ធ្វើសេចក្តីព្យាយាម ៥០០ ខ្នង ចាត់ចែងគ្រឿងឧបការៈគ្រប់យ៉ាង មានគ្រែតាំង ឆ្នាំងទឹកឆាន់ ទឹកប្រើប្រាស់ជាដើមនៅក្នុងទីនោះ ។

ស្អែកឡើង ភិក្ខុទាំងឡាយចូលទៅបិណ្ឌបាតនៅក្នុងស្រុកតំបន់ដទៃទៀត ។ ក្នុងស្រុកសូម្បីនោះ មនុស្សទាំងឡាយ ក៏ទំនុកបម្រុងយ៉ាងនោះដូចគ្នា ហើយសូមអង្វរឲ្យនៅចាំវស្សា ។ ភិក្ខុទាំងឡាយទទួលនិមន្តដោយ

មិនមានការសង្ស័យថា "កាលមិនមានអន្តរាយ" ទើបនាំគ្នាចូលទៅកាន់ដង ព្រៃនោះ ជាអ្នកប្រារព្ធសេចក្តីព្យាយាមអស់ទាំងថ្ងៃទាំងយប់ វាយរគាំង ប្រាប់យាម ជាអ្នកច្រើនដោយយោនិសោមនសិការ ទើបចូលទៅអង្គុយ ត្រង់គល់ឈើ ។ រុក្ខទេវតាទាំងឡាយ ត្រូវតេជៈរបស់ភិក្ខុអ្នកមានសីល កម្ចាត់តេជៈចេញហើយ ក៏ចុះចាកវិមានរៀងៗ ខ្លួន នាំពួកកូនៗ ចុះចេញ ទៅដោយប្រញាប់ ប្រៀបដូចកាលព្រះរាជា ឬរាជមហាមាត្យ ទៅកាន់ទី នៅរបស់អ្នកស្រុក កាន់យកឱកាសដែលទំនេរក្នុងផ្ទះទាំងឡាយរបស់ពួក អ្នកស្រុក ពួកអ្នកស្រុកក៏ត្រូវចេញចាកស្រុកទៅនៅទីដទៃ ក៏បានតែសម្លឹង មើលពីចម្ងាយ ដោយសង្ឃឹមថា កាលណាហ្ន៎ លោកទើបនឹងចេញទៅ យ៉ាងណា ទេវតាទាំងឡាយត្រូវលះបង់ចោលវិមានរៀងៗ ខ្លួន ប្រញាប់ ប្រញាល់ចេញទៅ បានតែសម្លឹងមើលអំពីទីឆ្ងាយ ដោយសង្ឃឹមថា កាល ណាហ្ន៎ លោកទើបនឹងចេញទៅ ក៏ដូច្នោះដូចគ្នា ។ តពីនោះ ទេវតា ទាំងឡាយក៏ផ្តើមគិតគ្នាយ៉ាងនេះថា ភិក្ខុទាំងឡាយចូលវស្សាដំបូងហើយ នឹងនៅរហូតអស់ត្រៃមាសមែនពិត តែពួកយើងមិនអាចនឹងនាំពួកក្មេងនៅ

យ៉ាងលំបាកបានយូរៗ ឡើយ ណ្ហើយចុះ ពួកយើងនឹងសំដែងអារម្មណ៍ដែលគួរខ្លាចដល់ភិក្ខុទាំងឡាយ ។ ទេវតាទាំងនោះ ទើបនិម្មិតរូបយក្សដែលគួរខ្លាចឈរនៅចំពោះមុខ វេលាភិក្ខុទាំងឡាយធ្វើសមណធម៌ពេលយប់ និងធ្វើសំឡេងដែលគួរខ្លាច ព្រោះឃើញរូបទាំងនោះ និងបានឮសំឡេងនោះ បេះដូងរបស់ភិក្ខុទាំងឡាយក៏ញាប់ញ័រ ភិក្ខុទាំងនោះមានសម្បុរស្លេកស្លាំង និងកើតជារោគស្គមលឿង ។ ព្រោះហេតុនោះ ភិក្ខុទាំងនោះ ទើបមិនអាចធ្វើចិត្តឲ្យមានអារម្មណ៍តែមួយបាន កាលចិត្តមិនអាចមានអារម្មណ៍តែមួយហើយ ព្រោះសេចក្ដីភ័យខ្លាចរឿយៗ សតិរបស់ភិក្ខុទាំងនោះ ក៏ភ្លេចភ្លាំងទៅ តពីនោះ អារម្មណ៍ដែលអាក្រក់ ក៏ប្រាកដដល់ភិក្ខុទាំងនោះដែលមានសតិភ្លេចភ្លាំងហើយ ខួរក្បាលរបស់ភិក្ខុទាំងនោះ ក៏ដូចត្រូវក្លិនអាក្រក់នោះបៀតបៀន រោគឈឺសីសៈក៏កើតខ្លាំងឡើង ។ ភិក្ខុទាំងនោះ ក៏មិនព្រមប្រាប់រឿងនោះដល់គ្នានឹងគ្នា ។

តមកថ្ងៃមួយ កាលភិក្ខុគ្រប់រូបប្រជុំគ្នាក្នុងវេលាទំនុកបម្រុងព្រះ-សង្ឃត្ថេរ ព្រះសង្ឃត្ថេរក៏សួរថា អ្នកមានអាយុ កាលពួកលោកចូលទៅ

កាន់ដងព្រៃនេះ ពណ៌សម្បុរបរិសុទ្ធផូរផង់ដ៏លើសលុប ២-៣ ថ្ងៃនេះ ទាំងឥន្ទ្រិយ៍ក៏ផូរផង់ តែឥឡូវនេះ ក្នុងពេលនេះ ពួកលោកស្គមស្លេកស្លាំង កើតរោគស្គមលឿង ក្នុងទីនៅរបស់ពួកលោកមិនសប្បាយឬ? លំដាប់នោះ ភិក្ខុមួយរូបពោលថា បពិត្រលោកម្ចាស់ ពេលយប់ខ្ញុំបានឃើញ និងបានឮអារម្មណ៍ដែលគួរខ្លាចយ៉ាងនេះៗ ជុំតែក្លិនដូច្នេះ ព្រោះហេតុនោះ ចិត្តរបស់ពួកខ្ញុំទើបមិនតាំងមាំជាសមាធិ ។ ភិក្ខុទាំងនោះគ្រប់រូប ទើបនាំគ្នាប្រាប់រឿងនោះ ដោយឧបាយនេះដូចគ្នា ។ ព្រះសង្ឃត្ថេរពោលថា អ្នកមានអាយុ ព្រះមានព្រះភាគទ្រង់បញ្ញត្តិការចូលវស្សាទុក ២ យ៉ាង ក៏សេនាសនៈនេះ មិនជាទីសប្បាយដល់ពួកលោក មកអ្នកមានអាយុ ពួកយើងនឹងនាំគ្នាទៅគាល់ព្រះមានព្រះភាគ ទូលសួរដល់សេនាសនៈដែលជាទីសប្បាយដទៃៗ ភិក្ខុទាំងនោះទទួលពាក្យរបស់ព្រះថេរៈថា សាធុ លោកម្ចាស់ គ្រប់រូបក៏ទុកដាក់សេនាសនៈ កាន់បាត្រចីវរមិនប្រាប់លានរណាៗ ក្នុងត្រកូលទាំងឡាយ ព្រោះភាពជាអ្នកមិនជាប់នៅក្នុងត្រកូលទាំងឡាយ នាំគ្នាចារិកទៅកាន់ក្រុងសាវត្ថី ក៏ដល់ក្រុងសាវត្ថីតាមលំដាប់ហើយ ក៏នាំគ្នាចូលទៅ

គាល់ព្រះមានព្រះភាគ ។

ព្រះមានព្រះភាគទ្រង់ឃើញភិក្ខុទាំងនោះ ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតបញ្ញត្តិសិក្ខាបទទុកថា ភិក្ខុមិនគប្បីត្រាច់ចារិកទៅខាងក្នុងវស្សា ហេតុអ្វីពួកអ្នកទើបចារិកមកកាន់ទីនេះ ។ ភិក្ខុទាំងនោះ ទើបក្រាបទូលរឿងទាំងអស់នោះចំពោះព្រះមានព្រះភាគ ។ ព្រះមានព្រះភាគទ្រង់ពិចារណា ក៏ទ្រង់មិនឃើញសេនាសនៈដែលជាទីសប្បាយដទៃសម្រាប់ពួកភិក្ខុទាំងនោះ ទូទាំងជម្ពូទ្វីប ដោយទីបំផុត សូម្បីត្រឹមតែតាំងមានជើងបួន ដូច្នោះ ទើបត្រាស់នឹងភិក្ខុទាំងនោះថា ម្នាលភិក្ខុទាំងឡាយ សេនាសនៈជាទីសប្បាយដទៃសម្រាប់ពួកអ្នកមិនមានទេ ពួកអ្នកនៅក្នុងទីនោះៗ ឯងនឹងសម្រេចធម៌ជាទីអស់អាសវៈ ទៅចុះភិក្ខុទាំងឡាយ ពួកអ្នកចូលទៅអាស្រ័យសេនាសនៈនោះៗ ចុះ ប្រសិនបើ ពួកអ្នកប្រាថ្នាការមិនមានភ័យអំពីទេវតាទាំងឡាយ ក៏ចូរនាំគ្នារៀនព្រះបរិត្តនេះ ។ ព្រោះថា ព្រះបរិត្តនេះនឹងជាគ្រឿងការពារ និងជាកម្មដ្ឋានសម្រាប់ពួកអ្នក ដូច្នេះ ហើយទើបត្រាស់ព្រះសូត្រនេះ ។

តែអាចារ្យពួកខ្លះពោលថា ព្រះមានព្រះភាគត្រាស់ព្រះតម្រាស់នេះ ថា ទៅចុះភិក្ខុទាំងឡាយ ពួកអ្នកចូរទៅអាស្រ័យសេនាសនៈនោះៗ នៅមួយជាគ្នាចុះ ហើយទើបត្រាស់ថា ដំណាលថា ភិក្ខុអ្នកនៅព្រៃគួរតែដឹងនិងបរិហារ ។ បរិហារយ៉ាងណា? បរិហារយ៉ាងនេះ គឺ ផ្សាយមេត្តា ២ វេលា គឺ ធ្វើវេលាល្ងាច និងព្រឹក ធ្វើព្រះបរិត្ត ២ វេលា ចម្រើនអសុភ ២ វេលា ចម្រើនមរណានុស្សតិ ២ វេលា រឭកដល់មហាសង្វេគវត្ថុទាំង ៨ ២ វេលា គឺ ជាតិ ជរា ព្យាធិ មរណៈ អបាយទុក្ខ ៤ ឈ្មោះមហាសង្វេគវត្ថុ ៨ ។ មួយទៀត ជាតិ ជរា ព្យាធិ មរណៈ ៤ អបាយទុក្ខជាទី ៥ ទុក្ខមានវដ្ដៈជាមូលក្នុងអតីត ១ ទុក្ខមានវដ្ដៈជាមូលក្នុងអនាគត ១ ទុក្ខមានការស្វែងរកអាហារជាមូលក្នុងបច្ចុប្បន្ន ១ ។ ព្រះមានព្រះភាគ កាលទ្រង់ប្រាប់ការបរិហារយ៉ាងនេះហើយ ទើបបានត្រាស់ព្រះសូត្រនេះដើម្បីជាមេត្តា ដើម្បីជាព្រះបរិត្ត និងដើម្បីឈានដែលជាបាទនៃវិបស្សនាដល់ភិក្ខុទាំងឡាយនោះ ។ គប្បីជ្រាបការអធិប្បាយបទទាំងនេះថា មេត្តសូត្រនេះ នរណាពោល ពោលកាលណា ពោលក្នុងទីណា និងពោល

ព្រោះហេតុអ្វី និងការជម្រះនិទាន សូមឱ្យជោយពិស្តារដោយប្រការដូច្នេះ ។

មាតិកានោះណា ខ្ញុំតាំងទុកថា គប្បីជ្រាបការអធិប្បាយបទទាំងនេះថា មេត្តសូត្រនេះ នរណាពោល ពោលកាលណា ពោលក្នុងទីណា និងពោលព្រោះហេតុអ្វី ខ្ញុំជម្រះនិទានហើយ មាតិកានោះ ដែលខ្ញុំពោលពិស្តារហើយ ដោយអាការទាំងពួង ដោយកថាមានប្រមាណត្រឹមប៉ុណ្ណេះ ។

## ពណ៌នាគាថាទី ១

ឥឡូវនេះ នឹងផ្តើមពណ៌នាអត្ថនៃព្រះសូត្រនោះ ដែលធ្វើការជម្រះនិទានហើយយ៉ាងនេះ ព្រោះខ្ញុំពោលទុកថា ទើបនឹងធ្វើការពណ៌នាសេចក្តីមេត្តសូត្រនេះ ដូច្នេះ ។ ក្នុងគាថានោះ នឹងផ្តើមពណ៌នាបទនៃគាថាទី ១ នេះថាករណីយមត្ថកុសលេន (អ្នកឈ្លាសក្នុងប្រយោជន៍គប្បីធ្វើ) មុនដូច្នេះ ។ បទថា ករណីយំ (គប្បីធ្វើ) បានដល់ គួរធ្វើ អធិប្បាយថា គួរដល់ការធ្វើ ។ បដិបទា ឈ្មោះថា ប្រយោជន៍ ឬប្រយោជន៍ដល់ខ្លួនយ៉ាងណាមួយ ប្រយោជន៍ទាំងអស់នោះ លោកហៅថា ប្រយោជន៍ ព្រោះជាទីតាំងនៃសេចក្តីស្ងប់ ។ ឈ្មោះថា ជាទីតាំងនៃសេចក្តីស្ងប់ ព្រោះ

បុគ្គលគប្បីចូលដល់ ។ នូវបុគ្គលអ្នកឈ្លាសក្នុងទីតាំងនៃសេចក្ដីស្ងប់ ។ ឈ្មោះថា **អ្នកឈ្លាសក្នុងប្រយោជន៍** លោកអធិប្បាយថា ជាអ្នកឆ្លាតឈ្លាសក្នុងប្រយោជន៍ ។ បទថា **យំ** ជាបឋមាវិភត្តិ សំដែងការមិនពិតប្រាកដ ។ បទថា **តំ** ជាទុតិយាវិភត្តិសំដែងការពិតប្រាកដ ។ ឬថា បទថា **យំ តំ** សូម្បីទាំង ២ ជាបឋមាវិភត្តិ ។ បទថា **សន្តំ បទំ** ជាទុតិយាវិភត្តិ ។ បណ្ដាពាក្យទាំង ២ នោះ ដែលឈ្មោះថា **ស្ងប់** ព្រោះជាលក្ខណៈ ។ ដែលមានឈ្មោះថា **បទ** ព្រោះដែលបុគ្គលគប្បីសម្រេច ពាក្យនេះជាឈ្មោះរបស់ព្រះនិព្វាន ។ បទថា **អភិសមេច្ច** ប្រែថា បន្ទាបង់ហើយ ។ នរណាមែងអាច ហេតុនោះ អ្នកនោះឈ្មោះថា **សក្កោ** (អ្នកអាច) ។ លោកអធិប្បាយថា អ្នកអាច អ្នកអាចហ៊ាន ។ បទថា **ឧជុ** (ត្រង់) បានដល់អ្នកប្រកបដោយការទៀងត្រង់ ។ អ្នកណាត្រង់ដោយល្អ ហេតុនោះ អ្នកនោះឈ្មោះថា **សុហុជូ** (អ្នកត្រង់ដោយល្អ) ។ សេចក្ដីថា ការទូន្មានងាយមាននៅក្នុងបុគ្គលនោះ ហេតុនោះ បុគ្គលនោះឈ្មោះថា **សុវចោ** (អ្នកប្រដៅងាយ) ។ បទថា **អស្ស** ប្រែថា គប្បីមាន គប្បីជា ។ បទថា **មុទុ** (ទន់

ភូន់) បានដល់ អ្នកប្រកបដោយភាពទន់ភ្លន់ ។ បុគ្គលណាមិនមានការប្រកាន់ខ្លួនប្រដៅក្រ ហេតុនោះ បុគ្គលនោះឈ្មោះថា **អនតិមានី** (មិនមានអតិមាន:) ។

ចំណែកការពណ៌នាអត្ថក្នុងទីគាថាទី ១ នេះដូច្នេះ ។

នីងវិនិច្ឆ័យក្នុងបទថា **ករណីយមត្ថកុសលេន យន្តំ សន្តំ បទំ អភិសមេច្ច** (កុលបុត្រអ្នកប្រាថ្នានីងលុះបទដ៏ស្ងប់ គប្បីធ្វើកិច្ចនោះណាកិច្ចនោះ ដែលកុលបុត្រអ្នកឈ្លាសក្នុងប្រយោជន៍ គប្បីធ្វើ) នេះជាមុន ។ **ករណីយ:** (វត្ថុដែលគប្បីធ្វើ) ក៏មាន **អករណីយ:** (វត្ថុដែលមិនគប្បីធ្វើ) ក៏មាន ។ ក្នុង ២ យ៉ាងនោះ ដោយសង្ខេប សិក្ខា ៣ ឈ្មោះថា **ករណីយ:** ។ សីលវិបត្តិ ទិដ្ឋិវិបត្តិ អាចារវិបត្តិ អាជីវវិបត្តិ ដូចពោលមកយ៉ាងនេះជាដើម ឈ្មោះថា **អករណីយ:** ។ មួយទៀត អត្ថកោសលក៏មាន អនត្ថកោសលក៏មាន ។ ក្នុង ២ យ៉ាងនោះ បុគ្គលណាបួសក្នុងព្រះសាសនានេះ មិនប្រកបខ្លួនទុកដោយល្អ ជាអ្នកមានសីលដាច់ អាស្រ័យអានេសនា (ការស្វែងរកមិនសមគួរ) ២១ យ៉ាង ចិញ្ចឹមជីវិតខុស គឺ ១

ឲ្យដើមឫស្សី ២.ឲ្យផ្កាឈើ ៣.ឲ្យស្លឹកឈើ ៤.ឲ្យផ្លែឈើ ៥.ឲ្យឈើជម្រះធ្មេញ ៦.ឲ្យទឹកលាងមុខ (មាត់) ៧. ឲ្យទឹកងូត ៨.ឲ្យម្សៅលាបខ្លួន ៩.ឲ្យដីដុសខ្លួន ១០.បញ្ជោរ ១១.និយាយពិតលាយពាក្យកុហក ១២.ចិញ្ចឹមកូនឲ្យគេ ១៣.ទទួលបម្រើគ្រហស្ថ ១៤.ធ្វើខ្លួនជាពេទ្យ ១៥.ធ្វើខ្លួនជាទូត ១៦. ទទួលបញ្ជូនដំណឹងគ្រហស្ថ ១៧.ឲ្យរបស់ដើម្បីប្រាថ្នាផលដល់ខ្លួន ១៨.ផ្លាស់ប្តូរ ១៩.ជាហោមើលផែនដី ២០.ជាហោមើលឫក្ស ២១.ជាហោមើលលក្ខណៈ ។ និងប្រព្រឹត្តអគោចរ ៦ គឺ ១.ស្រីពេស្យា ២.ស្រីមេម៉ាយ ៣.ស្រីសាវកែ ៤.ខ្ទើយ ៥.ភិក្ខុនី ៦.រោងស្រា ។ ស្និទ្ធស្នាលជាមួយព្រះរាជា មហាមាត្យរបស់ព្រះរាជា តិរ្ថិយ សាវកតិរ្ថិយ ដោយការស្និទ្ធស្នាលជាមួយគ្រហស្ថ ដែលមិនសមគួរ សេពគប់ ចូលជិត ចំពោះត្រកូលដែលមិនមានសទ្ធា មិនដូចជាអណ្តូងទឹក ជេរ និងបរិភាស ប្រាថ្នាតែវត្ថុដែលមិនមានប្រយោជន៍ មិនមានសេចក្តីចម្រើន មិនមានសេចក្តីសុខ មិនប្រាសចាកយោគៈ ដល់ភិក្ខុ ភិក្ខុនី ឧបាសក ឧបាសិកា ។ បុគ្គលនេះឈ្មោះថា **អ្នកឆ្លាតក្នុងវត្ថុដែលមិនមានប្រយោជន៍** ។

មួយទៀត បុគ្គលណាបួសក្នុងព្រះសាសនានេះ ប្រកបខ្លួនដោយប្រពៃ លះអនេសនា ប្រាថ្នាតាំងនៅក្នុងចតុបារិសុទ្ធិសីល បំពេញបាតិមោក្ខសំវរសីលដោយសទ្ធាជាសំខាន់ បំពេញឥន្ទ្រិយសំវរសីលដោយសតិជាសំខាន់ បំពេញអាជីវបារិសុទ្ធិសីលដោយការព្យាយាមជាសំខាន់ បំពេញការសេពបច្ច័យដោយបញ្ញាជាសំខាន់ បុគ្គលនេះ ឈ្មោះថា **អ្នកឆ្លាតក្នុងប្រយោជន៍** ។

មួយទៀត បុគ្គលណាជម្រះបាតិមោក្ខសំវរសីល ដោយជំរះអាបត្តិ ៧ កង , ជម្រះឥន្ទ្រិយសំវរសីល ដោយមិនឲ្យអភិជ្ឈាជាដើម កើតក្នុងអារម្មណ៍ដែលប៉ះខ្ទប់ក្នុងទ្វារ ៦ , ជម្រះអាជីវបារិសុទ្ធិសីល ដោយវៀរអនេសនា និងសេពតែបច្ច័យដែលវិញ្ញូជនសរសើរ ដែលព្រះពុទ្ធ និងសាវករបស់ព្រះពុទ្ធសរសើរ , ជម្រះការសេពបច្ច័យ ដោយការពិចារណាបច្ច័យតាមដែលពោល និងជម្រះសម្បជញ្ញៈ ដោយការពិចារណាចំពោះសាត្ថកសម្បជញ្ញៈជាដើម ក្នុងការប្តូរឥរិយាបថទាំង ៤ ។ សូម្បីបុគ្គលនេះ ក៏ឈ្មោះថា **អ្នកឆ្លាតក្នុងប្រយោជន៍** ។

មួយទៀត បុគ្គលណាដឹងថា សំពត់ស្មោកគ្រោកអាស្រ័យទឹកអំបិល ក៏ធ្វើឲ្យស្អាតបាន កញ្ចក់អាស្រ័យផេះក៏ធ្វើឲ្យស្អាតបាន មាសអាស្រ័យភ្លើងដុតក៏ធ្វើឲ្យបរិសុទ្ធបាន យ៉ាងណា សីលអាស្រ័យញាណក៏បរិសុទ្ធបាន ដូច្នោះ ហើយជម្រះដោយទឹក គឺ ញាណ ក៏ធ្វើសីលឲ្យបរិសុទ្ធបាន ។ ប្រៀបដូចសត្វត្រដៀវរិចរក្សាពង សត្វចាមរីរក្សាកន្ទុយ ស្ត្រីមានបុត្រតែមួយរក្សាបុត្រមួយដែលគួរស្រឡាញ់ បុរសមានភ្នែកតែម្ខាងរក្សាភ្នែកម្ខាងនោះទុក យ៉ាងណា បុគ្គលមិនប្រមាទក៏រក្សាសីលក្ខន្ធរបស់ខ្លួន ក៏ដូច្នោះ គេពិចារណាអង្គសីលទាំងល្ងាចព្រឹក ក៏មិនឃើញទោសសូម្បីមានប្រមាណតិចតួច ។ សូម្បីបុគ្គលនេះ ក៏ឈ្មោះថា **អ្នកឆ្លាតក្នុងប្រយោជន៍** ។

មួយទៀត បុគ្គលណាតាំងនៅក្នុងសីល ដែលមិនធ្វើសេចក្តីក្តៅក្រហាយ រមែងផ្គងបដិបទាជាគ្រឿងគ្របសង្កត់កិលេស កាលផ្គងបដិបទានោះហើយ រមែងធ្វើបរិកម្មក្នុងកសិណ លុះធ្វើបរិកម្មក្នុងកសិណហើយ រមែងញុំាងសមាបត្តិទាំងឡាយឲ្យកើត ។ សូម្បីបុគ្គលនេះ ក៏ឈ្មោះថា **អ្នកឈ្លាសក្នុងប្រយោជន៍** ។

មួយទៀត បុគ្គលណាចេញចាកសមាបត្តិ ពិចារណាសង្ខារទាំងឡាយ រមែងសម្រេចព្រះអរហត្ត បុគ្គលនេះជាកំពូលនៃអ្នកឆ្លាតក្នុងប្រយោជន៍ ។ ជនទាំងឡាយឯណា ជាអ្នកឆ្លាតក្នុងប្រយោជន៍ដែលលោកសរសើរហើយ ដោយត្រឹមតែនៅក្នុងសីល ដែលមិនធ្វើសេចក្តីក្តៅក្រហាយ ឬដោយត្រឹមតែផ្គងបដិបទាជាគ្រឿងគ្របសង្កត់កិលេស ជនទាំងនោះ លោកបំណងថា **អ្នកឆ្លាតក្នុងប្រយោជន៍** ក្នុងអត្ថនេះ ។ និងភិក្ខុទាំងនោះ ក៏ជាយ៉ាងនោះ ។ ព្រោះហេតុនោះ ព្រះមានព្រះភាគទ្រង់សំដៅដល់ភិក្ខុទាំងនោះ ទើបត្រាស់ដោយទេសនាជាបុគ្គលាធិដ្ឋានយ៉ាងនេះថា **ករណីយត្ថកុសលេន (ដែលជាអ្នកឆ្លាតក្នុងប្រយោជន៍ គប្បីធ្វើ)** ដូច្នេះ ។

តពីនោះ កាលភិក្ខុទាំងនោះកើតសេចក្តីសង្ស័យថា កិច្ចអ្វីដែលត្រូវធ្វើ ព្រះមានព្រះភាគទើបត្រាស់ថា **យន្តំ សន្តំ បទំ អភិសមេច្ច (កុលបុត្រអ្នកប្រាថ្នានឹងសម្រេចបទដ៏ស្ងប់ គប្បីធ្វើកិច្ចនោះ)** ។ ក្នុងបទនេះមានអធិប្បាយដូច្នេះ ។ ព្រះពុទ្ធ និងព្រះអនុពុទ្ធទាំងឡាយ សរសើរកិច្ចដែលបុគ្គលប្រាថ្នានឹងសម្រេចសន្តិបទ គឺ បទនៃព្រះនិព្វាន ដោយការ

ចាក់ធ្លុះហើយ គប្បីធ្វើ ។ ក៏ក្នុងបទនេះ គប្បីជ្រាបថា បទថា **យំ** (ណា) ខ្ញុំពោលទុកខាងដើមបទគាថានេះហើយ រមែងប្រព្រឹត្តទៅដោយអធិការថា **ករណីយំ** (គប្បីធ្វើ) គឺ **តំ សន្តំ បទំ អភិសមេច្ច** (សម្រេចបទដ៏ស្ងប់នោះ) តែព្រោះហេតុដែលអត្ថនេះ មានបាឋៈត្រូវបំពេញពាក្យដ៏សេស ។ ដូច្នោះ ខ្ញុំទើបពោលថា **វិហរិតុកាមេន** (អ្នកប្រាថ្នានឹង... នៅ) ។

ន័យម្យ៉ាងទៀត ក្នុងបទនេះគប្បីជ្រាបអធិប្បាយយ៉ាងនេះថា បទថា **សន្តំ បទំ អភិសមេច្ច** (សម្រេចបទដ៏ស្ងប់) រមែងប្រព្រឹត្តទៅដោយអធិការថា កិច្ចឯណា ដែលបុគ្គលប្រាថ្នានឹងដឹងបទ គឺ ព្រះនិព្វានថា ស្ងប់ ដូច្នេះ ដោយលោកិយប្បញ្ញា ព្រោះបានស្តាប់មកជាដើម នឹងសម្រេចបទ គឺ ព្រះនិព្វាននោះ គប្បីធ្វើ ។ ន័យម្យ៉ាងទៀត កាលត្រាស់ថា **អ្នកឆ្លាតក្នុងប្រយោជន៍គប្បីធ្វើ** កាលភិក្ខុទាំងឡាយនាំគ្នាគិតថា ហេតុអ្វី ទើបទ្រង់ត្រាស់ថា **សម្រេចបទដ៏ស្ងប់** ។ ន័យនោះគប្បីជ្រាបអធិប្បាយដូច្នេះ កិច្ចណា ដែលបុគ្គលអ្នកដឹងបទដ៏ស្ងប់ដោយលោកិយប្បញ្ញាហើយ គប្បីធ្វើ គប្បីប្រកបកិច្ចនោះ លោកអធិប្បាយថា កិច្ចនោះគួរដល់ការធ្វើទាំង

អស់នោះឯង ។

សួរថា កិច្ចនោះ គឺអ្វី? ឆ្លើយថា កិច្ចអ្វីដទៃគប្បីមាន ក្រៅពីឧបាយសម្រេចបទ គឺ និព្វាននោះ ។ កិច្ចនោះ ខ្ញុំពោលទុកហើយដោយបទខាងដើម ដែលសំដែងសិក្ខា ៣ ព្រោះអត្ថថា គួរដល់ការធ្វើក៏ពិត តែក្នុងការពណ៌នាអត្ថនៃពាក្យនោះ ខ្ញុំក៏បានពោលទុកហើយថា **ករណី** ក៏មាន **អករណី** ក៏មាន ។ ក្នុង ២ យ៉ាងនោះ ដោយសង្ខេប សិក្ខា ៣ ឈ្មោះថា ករណី ។ តែព្រោះទ្រង់សំដែងទុកដោយសង្ខេបពេក បណ្ដាភិក្ខុទាំងនោះ ភិក្ខុពួកខ្លះក៏ដឹង ពួកខ្លះក៏មិនដឹង ។ តពីនោះ កាលត្រាស់កិច្ចដោយចំពោះយ៉ាងក្រៃលែងដល់ភិក្ខុអ្នកនៅព្រៃគួរធ្វើ ឲ្យពិស្ដារ ដើម្បីឲ្យពួកភិក្ខុដែលមិនដឹងបានដឹង ទើបត្រាស់កន្លះគាថានេះមុនថា **សក្កោ ឧជូ ច សុហុជូ ច សុវចោ ចស្ស មុទុ អនតិមានី** (កុលបុត្រនោះ គប្បីជាអ្នកអាចហ៊ាន ត្រង់ និងត្រង់ដោយល្អ គប្បីជាអ្នកប្រដៅងាយ ទន់ភ្លន់ មិនមានអតិមាន:) ។

លោកអធិប្បាយទុកយ៉ាងណា ? លោកអធិប្បាយថា ភិក្ខុអ្នកនៅ

ព្រៃ ប្រាថ្នានឹងសម្រេចសន្តិបទ ឬសម្រេចសន្តិបទនោះដោយលោកិយ-
បញ្ញាហើយ បដិបត្តិដើម្បីសម្រេចសន្តិបទនោះ មិនអាស្រ័យក្នុងកាយ
និងជីវិត ព្រោះប្រកបដោយបធានិយង្គៈប្រការទី ២ និងប្រការទី ៤ គប្បី
ជាអ្នកអាចបដិបត្តិដើម្បីចាក់ធ្លុះសច្ចៈ ករណីយកិច្ចដែលគួរគប្បីធ្វើណាៗ
នោះ មិនថាខ្ពស់ទាបរបស់សព្រហ្មចារី ក្នុងការបរិកម្មកសិណ សមាទាន
វត្តជាដើម និងក្នុងការប្រដាប់បាត្រចីវរជាដើមរបស់ខ្លួន ក៏គប្បីអាច គប្បី
ឧស្សាហ៍ មិនខ្ជិលច្រអូស អាចក្នុងករណីយកិច្ចទាំងនោះ និងក្នុងកិច្ច
យ៉ាងដទៃ ក៏ដូច្នោះដូចគ្នា ។ សូម្បីកាលជាអ្នកអាច ក៏គប្បីជាអ្នកត្រង់
ព្រោះការប្រកបដោយបធានិយង្គៈប្រការទី ៣ ។ សូម្បីកាលជាអ្នកត្រង់
ក៏គប្បីជាអ្នកត្រង់ដោយល្អ ដោយភាពជាអ្នកត្រង់មួយគ្រា ឬជាអ្នកត្រង់
ក្នុងវេលានៅជាកំលោះ គឺ មិនសន្ដោសធ្វើឲ្យបរិបូណ៌រឿយៗ រហូតអស់
ជីវិត ។ ឬថា ឈ្មោះថា **ឧជុ** (ត្រង់) ព្រោះធ្វើដោយសេចក្ដីមិនអួតអាង
ឈ្មោះថា **សុហុជូ** (ត្រង់ដោយល្អ) ព្រោះមិនមានមាយា ឬថា ឈ្មោះថា
ត្រង់ ព្រោះលះការវៀចដោយកាយ និងវាចា ឈ្មោះថា **ត្រង់ដោយល្អ** ព្រោះ

លះការវៀចផ្លូវចិត្ត ឬឈ្មោះថា **ត្រង់** ព្រោះមិនអួតគុណដែលមិនមានពិត ។ គប្បីឈ្មោះថា **ជាអ្នកត្រង់ និងត្រង់ដោយល្អ** ដោយអារម្មណូបនិជ្ឈាន និងលក្ខណូបនិជ្ឈាន ដោយសិក្ខាប្រការទី ២-៣ និងដោយបយោគសុទ្ធិ និងអាសយសុទ្ធិ ដោយប្រការដូច្នេះ ។

ភិក្ខុមិនមែនជាអ្នកត្រង់ និងត្រង់ដោយល្អតែម៉្យាងនោះទេ ដែលពិតគប្បីជា**អ្នកប្រដៅងាយ** ទៀតផង ។ ក៏បុគ្គលណា ត្រូវលោកពោលប្រដៅថា "លោកមិនគួរធ្វើប្រការនេះ" ក៏និយាយថា "លោកឃើញអ្វី លោកបានឮអ្វី លោកជាអ្វីនឹងយើងទើបនិយាយ ជាឧបជ្ឈាយ៍ អាចារ្យ ជាមិត្រឬ?" ឬបៀតបៀនលោកនោះដោយការនៅស្ងៀម ឬព្រមទទួលហើយមិនធ្វើតាម បុគ្គលនោះឈ្មោះថា នៅឆ្ងាយពីការសម្រេចគុណវិសេស ។ ឯបុគ្គលណា ត្រូវលោកឲ្យឱវាទ ក៏ពោលថា "សាធុ លោកម្ចាស់ លោកនិយាយល្អហើយ ដែលឈ្មោះថាទោសរបស់ខ្លួនជារបស់ឃើញបានលំបាក លោកឃើញខ្ញុំជាយ៉ាងនេះ អនុគ្រោះទូន្មានប្រដៅទៀតចុះ ខ្ញុំមិនបានទទួលឱវាទអំពីសំណាក់លោកយូរហើយ នឹងបដិបត្តិតាមដែលលោកទូន្មាន បុគ្គល

នោះឈ្មោះថា នៅមិនឆ្ងាយពីការសម្រេចគុណវិសេស ។ ព្រោះដូច្នោះ បុគ្គលទទួលពាក្យរបស់អ្នកដទៃ ហើយធ្វើយ៉ាងនេះ គប្បីឈ្មោះថា ជាអ្នកប្រដៅងាយ ។

មួយទៀត ជាអ្នកប្រដៅងាយយ៉ាងណា ក៏គប្បីជាអ្នកទន់ភ្លន់យ៉ាងនោះ ។ បទថា **មុទុ (ទន់ភ្លន់)** សេចក្តីថា ភិក្ខុត្រូវពួកគ្រហស្ថប្រើជាទូតទទួល និងបញ្ជូនដំណឹងជាដើម ក៏មិនធ្វើការទន់ភ្លន់ក្នុងកិច្ចនោះ ជាអ្នកព្រងើយកន្តើយ គប្បីជាអ្នកទន់ភ្លន់ក្នុងវត្តបដិបត្តិ និងព្រហ្មចារ្យទាំងអស់ អត់ធន់ដល់ការមិនត្រូវទទួលប្រើក្នុងកិច្ចនោះ ដូចមាសដែលជាងតាក់តែងល្អហើយ ។ម្យ៉ាងទៀត បទថា **មុទុ (ទន់ភ្លន់)** បានដល់ ជាអ្នកមិនមានមុខស្រពាប់ស្រពោន គឺ ជាអ្នកមានមុខស្រស់ស្រាយ ចរចាតែពាក្យដែលឲ្យកើតសេចក្តីសុខ ក្រោកទទួលភ្ញៀវ គប្បីជាអ្នកដែលគប់រកបាននៅសេចក្តីសុខដូចកំពង់ទឹកល្អ មិនមែនត្រឹមតែជាអ្នកទន់ភ្លន់តែម្យ៉ាងនោះទេ គប្បីជាអ្នកមិនមាន **អតិមានះ** (មើលងាយគេ) ផង ។ មិនគប្បីមើលងាយអ្នកដទៃដោយវត្ថុនៃការមើលងាយ មានជាតិ និងគោត្រជាដើម គប្បី

មានចិត្តស្មើដូចជាក្មេងចណ្ឌាល ដូចព្រះសារីបុត្រថេរៈ ដូច្នោះ ។

## ពណ៌នាគាថាទី ២

ព្រះមានព្រះភាគ កាលត្រាស់ករណីយកិច្ចខ្លះដោយចំពោះ ដ៏ក្រៃលែងរបស់ភិក្ខុអ្នកនៅព្រៃ ដែលប្រាថ្នានឹងសម្រេចសន្តិបទ ឬបដិបត្តិដើម្បីសម្រេចសន្តិបទនោះ យ៉ាងនេះហើយ ទ្រង់មានព្រះពុទ្ធបំណងនឹងត្រាស់ឲ្យក្រៃលែងឡើងទៀតថា ទើបត្រាស់គាថាទី ២ ថា ***សន្តុស្សកោ ច (ជាអ្នកសន្តោស)*** ជាដើម ។

ក្នុងគាថាទី ២ នោះ ភិក្ខុឈ្មោះថា ***អ្នកសន្តោស*** ព្រោះសន្តោសដោយសន្តោស ១២ យ៉ាង មានប្រភេទដូចពោលទុកហើយក្នុងមង្គលសូត្រនេះថា ***សន្តុដ្ឋី ច កតញ្ញុតា (សេចក្តីសន្តោស ការដឹងគុណ)*** នេះ ។ ន័យម្យ៉ាងទៀត ភិក្ខុណារមែងត្រេកអរ ព្រោះហេតុនោះ ភិក្ខុនោះឈ្មោះថា ***តុស្សកៈ (អ្នកត្រេកអរ)*** ភិក្ខុត្រេកអរក្នុងរបស់ខ្លួនឯង អ្នកត្រេកអរក្នុងរបស់ដែលមាន អ្នកត្រេកអរដោយអាការស្មើ ហេតុនោះ ទើបឈ្មោះថា ***សន្តុស្សកៈ (អ្នកសន្តោស)*** ។ ក្នុងលក្ខណៈ ៣ យ៉ាងនោះ បច្ច័យ ៤

ដែលលោកលើកឡើងសំដែងក្នុងពាងឧបសម្បទាយ៉ាងនេះថា **បិណ្ឌិយាលោបភោជនំ និស្សាយ** (អាស្រ័យភោជន គឺ ដុំបាយដែលរកបានដោយកម្លាំងស្មង) ជាដើម ខ្លួនក៏ទទួលទុកហើយ ឈ្មោះថា **របស់ខ្លួន**

ភិក្ខុមិនសំដែងអាការខុសប្រក្រតីក្នុងវេលាទទួល និងក្នុងវេលាបរិភោគ ញុំាងអត្តភាពឲ្យប្រព្រឹត្តទៅដោយបច្ច័យរបស់ខ្លួននោះ ល្អក្តី មិនល្អក្តី ដែលគេថ្វាយដោយគោរព និងមិនគោរពក្តី ហៅថា **អ្នកត្រេកអរក្នុងរបស់ខ្លួន** ។

របស់ណាបានមកហើយ មានដល់ខ្លួន របស់នោះឈ្មោះថា **មានហើយ** ។ ភិក្ខុត្រេកអរក្នុងរបស់មានហើយនោះឯង មិនប្រាថ្នារបស់ក្រៅពីនោះ លះភាពជាអ្នកប្រាថ្នាលើសច្រើន ហៅថា **អ្នកត្រេកអរក្នុងរបស់ដែលមានហើយ** ។

ការលះសេចក្តីពេញចិត្តទាស់ចិត្ត ក្នុងឥដ្ឋារម្មណ៍ និងអនិដ្ឋារម្មណ៍ ឈ្មោះថា **ប្រព្រឹត្តស្មើ** ។ ភិក្ខុត្រេកអរក្នុងអារម្មណ៍ទាំងពួងដោយអាការស្មើនោះ ហៅថា **អ្នកត្រេកអរក្នុងអាការស្មើ** ។

ឈ្មោះថា **ចិញ្ចឹមងាយ** ព្រោះគេចិញ្ចឹមបានដោយងាយ ។ លោកអធិប្បាយថា អ្នកដែលគេចិញ្ចឹមងាយ ។ ក៏ភិក្ខុណា កាលមនុស្សយកបាត្រដាក់ពេញដោយបាយស្រូវសាលី សាច់ និងបបរជាដើមថ្វាយហើយ សំដែងនូវការៈងាកមុខចេញ និងទាស់ចិត្ត និយាយថា "ពួកលោកឲ្យអ្វី" មើលងាយបិណ្ឌបាតនោះចំពោះមុខគេ ឲ្យដល់សាមណេរ និងគ្រហស្ថជាដើម ភិក្ខុនោះ ឈ្មោះថា ជាអ្នកដែលគេចិញ្ចឹមលំបាក ។ មនុស្សទាំងឡាយឃើញភិក្ខុនោះហើយ ក៏ដើរចេញពីចម្ងាយ ដោយពោលថា "ភិក្ខុចិញ្ចឹមលំបាក នរណាក៏មិនអាចចិញ្ចឹមបាន" ។ ចំណែកភិក្ខុណាបានរបស់ថោក-ទាប ឬប្រណីតណាមួយ តិច ឬច្រើន មានចិត្តល្អ ទឹកមុខថ្លូវថង់ ញុំាងអត្តភាពឲ្យប្រព្រឹត្តទៅ ភិក្ខុនោះ ឈ្មោះថា អ្នកចិញ្ចឹមងាយ ។ មនុស្សទាំងឡាយឃើញភិក្ខុនោះ ក៏បានការស្និទ្ធស្នាលយ៉ាងក្រៃលែង នឹងប្ដេជ្ញាទទួលចិញ្ចឹមថា "លោកម្ចាស់របស់យើង ចិញ្ចឹមងាយ រមែងត្រេកអរក្នុងបច្ច័យតាមមានតាមបាន យើងនឹងចិញ្ចឹមលោក" ។ ភិក្ខុបែបនេះ លោកបំណងថា ជាអ្នកចិញ្ចឹមងាយ ក្នុងទីនេះ ។

កិច្ចរបស់ភិក្ខុតិច ហេតុនោះ ភិក្ខុនោះឈ្មោះថា **អប្បកិច្ចៈ (អ្នកមានកិច្ចតិច)** មិនមែនអ្នកខ្វល់ខ្វាយដោយកិច្ចច្រើនយ៉ាង ដូចជាសប្បាយក្នុងការងារ សប្បាយក្នុងការជជែកគ្នា សប្បាយក្នុងការប្រឡូកប្រឡំជាដើមម្យ៉ាងទៀត ជាអ្នកវៀរកិច្ច មានការកសាង ការបរិភោគរបស់សង្ឃ ការទូន្មានសាមណេរ និងញោមវត្តជាដើម ទូទាំងវិហារ ។ លោកអធិប្បាយថា ធ្វើការកោរសក់ កាត់ក្រចក ដុតបាត្រ ធ្វើចីវរជាដើមរបស់ខ្លួន ក្រៅពីកិច្ច គឺ សមណធម៌ ។

ការប្រព្រឹត្តរបស់ភិក្ខុនោះស្រាល ហេតុនោះ ភិក្ខុនោះ ឈ្មោះថា **សល្លហុកវុត្តិ (អ្នកមានការប្រព្រឹត្តស្រាល)** ។ ភិក្ខុអ្នកមានបរិក្ខារច្រើនរូបខ្លះ វេលាចេញដើរផ្លូវ ក៏ឲ្យមហាជនយកបាត្រ ចីវរ គ្រឿងក្រាល ប្រេងទឹកអំពៅជាដើម ដ៏ច្រើនទូលលើសីសៈ លី កណ្តៀតជាដើមចេញទៅយ៉ាងណា ភិក្ខុណា មិនដូច្នោះ រមែងជាអ្នកមានបរិក្ខារតិច រក្សាត្រឹមតែសមណបរិក្ខារ ៨ មានបាត្រចីវរជាដើមប៉ុណ្ណោះ វេលាដើរផ្លូវ ក៏ទៅតាមផ្លូវ ដូចជាបក្សីមានតែស្លាប (ហើរទៅ) ភិក្ខុបែបនោះ លោកបំណងថា

ជាអ្នកមានការប្រព្រឹត្តស្រោល ក្នុងទីនេះ ។ ឥន្ទ្រិយទាំងឡាយរបស់ភិក្ខុនោះ ស្ងប់ ហេតុនោះ ភិក្ខុនោះ ឈ្មោះថា **សន្តិន្ទ្រិយ (អ្នកមានឥន្ទ្រិយស្ងប់)** ។ លោកអធិប្បាយថា អ្នកមានឥន្ទ្រិយមិនរាយមាយ ដោយអំណាចរាគៈជាដើម ក្នុងឥដ្ឋារម្មណ៍ជាអាទិ៍ ។ បទថា **និបកោ (អ្នកមានបញ្ញា)** បានដល់ បុគ្គលជាវិញ្ញូជន អ្នកដឹងច្បាស់ មានបញ្ញា អធិប្បាយថា អ្នកប្រកបដោយបញ្ញាជាគ្រឿងតាមរក្សាសីល ដោយបញ្ញាជាគ្រឿងពិចារណាបច្ច័យ ៤ មានចីវរជាដើម និងដោយបញ្ញាកំណត់ដឹងសប្បាយៈ ៧ យ៉ាង មានអាវាសជាទីសប្បាយៈជាដើម ។

អ្នកមិនឃ្នើសឃ្នង ហេតុនោះ ទើបឈ្មោះថា **អប្បគព្ភៈ (អ្នកមិនឃ្នើសឃ្នង)** ។ អធិប្បាយថា វៀរចាកការឃ្នើសឃ្នងផ្លូវកាយ ៨ ស្ថាន វៀរចាកការឃ្នើសឃ្នងផ្លូវវាចា ៤ ស្ថាន និងវៀរចាកការឃ្នើសឃ្នងផ្លូវចិត្តច្រើនស្ថាន ។

ការធ្វើមិនសមគួរផ្លូវកាយ ក្នុងសង្ឃ គណៈ បុគ្គល រោងឆាន់ រោងភ្លើង កំពង់ងូតទឹក ផ្លូវបិណ្ឌបាត និងការចូលកាន់ចន្លោះស្រុក ឈ្មោះ

ថា ការឃ្មើសឃ្មងផ្លូវកាយ ៨ ស្ថាន គឺ ជាដើមយ៉ាងនេះថា ភិក្ខុរូបខ្លះ ក្នុងសាសនានេះ អង្គុយឱបជង្គង់ ឬយកជើងទាក់ជើង (គងទាក់ខ្វា) ក្នុងកណ្តាលសង្ឃ ក្នុងកណ្តាលគណៈ ក្នុងទីប្រជុំបរិស័ទ ៤ ក៏ដូចគ្នា ក្នុងបុគ្គលអ្នកចាស់ជាង ក៏ដូចគ្នា ។ ចំណែកក្នុងរោងឆាន់ មិនឲ្យអាសនៈដល់ភិក្ខុចាស់ជាង ហាមអាសនៈភិក្ខុថ្មី ក្នុងរោងភ្លើងក៏ដូចគ្នា ក៏ក្នុងរោងភ្លើងនោះ ភិក្ខុមិនសូមឱកាសភិក្ខុដែលចាស់ជាង ធ្វើការដុតភ្លើងជាដើម ។ ចំណែកក្នុងកំពង់ទឹក លោកពោលពាក្យនេះថា មិនត្រូវប្រកាន់ថា កំលោះចាស់ គប្បីផ្ងូតទឹកបានតាមលំដាប់លំដោយរបស់អ្នកមកដល់ គេមិនកាន់យកពាក្យនោះ មកក្រោយ ក៏ចុះទឹក បៀតបៀនគ្នាភិក្ខុចាស់ និងភិក្ខុថ្មី ។ ចំណែកក្នុងផ្លូវភិក្ខាចារ គេសម្រុកទៅខាងមុខៗ យកដៃគៀសភិក្ខុចាស់ដើម្បីប្រាថ្នាអាសនៈដ៏ប្រសើរ ទឹកដ៏ប្រសើរ និងអាហារដ៏ប្រសើរ ។ ក្នុងការចូលទៅកាន់ចន្លោះស្រុក ក៏មានជាដើមយ៉ាងនេះថា គេចូលទៅមុនភិក្ខុចាស់ ធ្វើការលេងផ្លូវកាយ (ប្រឡែងលេង) ជាមួយភិក្ខុកំលោះ ។

ការបញ្ចេញវាចាមិនសមគួរ ក្នុងសង្ឃ គណៈ បុគ្គល និងចន្លោះ

ស្រុក ឈ្មោះថា ឃ្នងផ្លូវវាចា ៤ ស្ថាន គឺ ជាដើមយ៉ាងនេះថា ភិក្ខុរូប ខ្លះក្នុងសាសនានេះ មិនសូមឱកាសក្នុងកណ្តាលសង្ឃ ហើយពោលធម៌ ។ ក្នុងគណៈ ក្នុងបុគ្គលអ្នកចាស់ជាង ដូចដែលលោកពោលមកហើយ ក៏ដូច គ្នា ។ ក្នុងទីនោះ លោកត្រូវមនុស្សទាំងឡាយសួរបញ្ហា មិនសូមឱកាស ភិក្ខុចាស់ជាង ក៏ឆ្លើយបញ្ហា ។ ចំណែកក្នុងចន្លោះស្រុក ក៏ពោលជាដើម យ៉ាងនេះថា "មានអ្វីក្នុងស្រុកនោះ ដាំបាយ ឬរបស់ទំពារ ឬរបស់ស៊ី លោកនឹងឲ្យអ្វីដល់យើង ថ្ងៃនេះយើងនឹងទំពារ នឹងស៊ីអ្វី នឹងផឹកអ្វី" ។

សូម្បីការមិនដល់ការល្មើសផ្លូវកាយ និងវាចា ក្នុងឋានៈនោះៗ តែ ក៏មានវិតក្កៈដែលមិនមានសមគួរមានប្រការផ្សេងៗ មានការវិតក្កៈតាមផ្លូវ ចិត្ត ឈ្មោះថា ការឃ្លើសឃ្នងផ្លូវចិត្ត មានច្រើនស្ថាន ។

បទថា កុលេសុ អននុគិទ្ធោ (មិនជាប់ក្នុងត្រកូលទាំងឡាយ) សេចក្តីថា ភិក្ខុចូលទៅរកត្រកូលណា មិនជាប់ដោយសេចក្តីប្រាថ្នាក្នុងបច្ច័យ ឬដោយការស្និទ្ធស្នាលជាមួយគ្រហស្ថ ដែលមិនសមគួរក្នុងត្រកូលទាំងនោះ លោកអធិប្បាយថា មិនសោកសៅរួមផង មិនរីករាយរួមផង ។ មិនសុខ

ផង បើត្រកូលទាំងនោះជួបសុខ ។ មិនទុក្ខផង បើត្រកូលទាំងនោះជួប ទុក្ខ ឬបើករណីយកិច្ចទាំងឡាយដែលគួរធ្វើកើតឡើង ក៏មិនចូលប្រកប ដោយខ្លួនឯង ។ ក៏បទណាថា អស្ស (គប្បីជា) ដែលត្រាស់ទុកក្នុងបទ នេះថា សុវចោ អស្ស (គប្បីជាអ្នកប្រដៅងាយ) នៃគាថានេះ បទនោះ គប្បីប្រកបចូលជាមួយគ្រប់ៗ បទ យ៉ាងនេះថា សន្តុស្សកោ ច អស្ស សុភរោ ច អស្ស (គប្បីជាអ្នកសន្តោស គប្បីជាអ្នកចិញ្ចឹមងាយ) ។

## ពណ៌នាគាថាទី ៣

ព្រះមានព្រះភាគ កាលត្រាស់ប្រាប់ករណីសូម្បីក្រៃលែងជាងនោះ ដោយចំពោះដល់ភិក្ខុអ្នកនៅព្រៃ ដែលប្រាថ្នាសន្តិបទ យ៉ាងនេះហើយ ឥឡូវ នេះ ទ្រង់មានព្រះពុទ្ធបំណងនឹងត្រាស់ប្រាប់អករណី ទើបត្រាស់កន្លះ គាថាទៀតថា ន ច ខុទ្ទំ សមាចរេ កិញ្ចិ យេន វិញ្ញូ បរេ ឧបវ-ទេយ្យុំ (វិញ្ញូជនតិះដៀលជនទាំងឡាយដទៃបាន ដោយកម្មដែលតិចតួច ឯណា សូម្បីកម្មណាៗ ត្រឹមតែតិចតួចនោះ ក៏មិនគប្បីប្រព្រឹត្ត) ។

កន្លះគាថានោះ មានអត្ថដូច្នេះ ភិក្ខុកាលធ្វើករណីយ៉ាងនេះ ក៏

មិនគប្បីប្រព្រឹត្តកាយទុច្ចរិត វចីទុច្ចរិត មនោទុច្ចរិត ដែលហៅថា **ខុទ្ទៈ (កម្មតិចតួច)** គឺ លាមក ។ មិនគប្បីប្រព្រឹត្តកម្មតិចតួចនោះផង និងកាលមិនប្រព្រឹត្ត មិនមែនប្រព្រឹត្តតែកម្មគ្រោតគ្រាតតែម្យ៉ាងប៉ុណ្ណោះទេ សូម្បីកម្មតិចតួចណាៗ ក៏មិនគប្បីប្រព្រឹត្ត លោកអធិប្បាយថា មិនគប្បីប្រព្រឹត្តកម្មលាមកទាំងតិច ទាំងតូច ។

តពីនោះ ព្រះមានព្រះភាគ ទ្រង់សំដែងទោសដែលឃើញបានឯងក្នុងការប្រព្រឹត្តកម្មលាមកនោះថា **វិញ្ញូជនតិះដៀលជនទាំងឡាយពួកដទៃបានដោយកម្មណា** ។ ក្នុងពាក្យនេះ ព្រោះហេតុដែលមិនមែនជាវិញ្ញូជនក៏មិនជាប្រមាណ ។ ព្រោះអវិញ្ញូជនទាំងនោះ នៅធ្វើកម្មមិនមានទោសឬមានទោស មានទោសតិច ឬច្រើន ។ ចំណែកវិញ្ញូជនប៉ុណ្ណោះ ទើបយកជាប្រមាណបាន ។ ព្រោះថា វិញ្ញូជនទាំងនោះ ពិចារណាសព្វគ្រប់ហើយ រមែងតិះដៀលបុគ្គលដែលគួរតិះដៀល , សរសើរបុគ្គលដែលគួរសរសើរ ដូច្នោះ ទើបត្រាស់ថា វិញ្ញូជនតិះដៀលជនពួកដទៃបាន ។

ព្រះមានព្រះភាគកាលត្រាស់ឧបចារៈនៃកម្មដ្ឋាន មានករណី និង

អករណីី ដោយចំពោះដ៏ក្រៃលែង ដល់ភិក្ខុអ្នកនៅព្រៃ ដែលប្រាថ្នានឹងសម្រេចសន្តិបទហើយ ឬបំណងនឹងបដិបត្តិដើម្បីសម្រេចសន្តិបទនោះ និងដល់ពួកភិក្ខុអ្នកប្រាថ្នានឹងទទួលកម្មដ្ឋានសូម្បីគ្រប់រូប ដោយលើកយកភិក្ខុអ្នកនៅព្រៃជាសំខាន់ ដោយពីរគាថាកន្លះនេះ យ៉ាងនេះហើយ ឥឡូវនេះទើបទ្រង់ផ្តើមត្រាស់មេត្តកថា ដោយន័យថា **សុខិនោ វា ខេមិនោ ហោន្តុ (ចូរជាអ្នកមានទូវសេចក្តីសុខ មានសេចក្តីក្សេម)** ជាដើម ដើម្បីជាបរិត្តកម្ចាត់ភ័យអំពីទេវតាទាំងនោះ និងដើម្បីជាកម្មដ្ឋានដោយអាស្រ័យឈានជាបាទនៃវិបស្សនា ដល់ភិក្ខុទាំងនោះ ។

បណ្តាបទទាំងនោះ បទថា **សុខនោ (អ្នកមានសេចក្តីសុខ)** បានដល់ អ្នកព្រមព្រៀងដោយសុខ ។ បទថា **ខេមិនោ** ប្រែថា ជាអ្នកមានសេចក្តីក្សេម ។ លោកអធិប្បាយថា អ្នកមិនមានភ័យ មិនមានឧបទ្ទវៈ ។ បទថា **សព្វេ (ទាំងពួង)** បានដល់ មិនមានសេសសល់ ។ បទថា **សត្តា (សត្វ)** បានដល់ សត្វមានជីវិត ។ បទថា **សុខិតត្តា (មានខ្លួនដល់នូវសេចក្តីសុខ)** បានដល់ អ្នកមានចិត្តដល់នូវសេចក្តីសុខ ។ ក៏ក្នុងពាក្យនេះ

គប្បីជ្រាបថា ឈ្មោះថា អ្នកមានសេចក្តីសុខ ដោយសុខផ្លូវកាយ ។ ឈ្មោះថា មានខ្លួនដល់នូវសេចក្តីសុខ ដោយសុខផ្លូវចិត្ត ។ ឈ្មោះថា មានសេចក្តីក្សេម សូម្បីដោយសុខទាំង ២ នោះ ឬដោយការប្រាសចាកភ័យនិងឧបទ្រវៈទាំងពួង ។ ក៏ហេតុអ្វី ទើបត្រាស់យ៉ាងនេះ? ក៏ដើម្បីសំដែងអាការនៃមេត្តាភាវនា ។ ដូច្នោះឯង ទើបគួរបម្រើនមេត្តាថា **សូមសត្វទាំងឡាយ ចូរមានសេចក្តីសុខ** ដូច្នេះខ្លះ ថា **ចូរមានសេចក្តីក្សេម** ដូច្នេះខ្លះ **ចូរជាអ្នកមានខ្លួនដល់នូវសេចក្តីសុខ** ដូច្នេះខ្លះ ។

## ពណ៌នាគាថាទី ៤

ព្រះមានព្រះភាគ កាលទ្រង់សំដែងមេត្តាភាវនា ដោយសង្ខេប តាំងពីឧបចារៈរហូតដល់អប្បនាជាទីបំផុត យ៉ាងនេះហើយ ឥឡូវនេះ ដើម្បីទ្រង់សំដែងមេត្តាភាវនានោះដោយពិស្តារ ទើបត្រាស់ ២ គាថាថា **យេកេចិ** (ពួកណាមួយ) ជាដើម ។ម្យ៉ាងទៀត ព្រោះហេតុដែលចិត្តត្រូវសន្សំនៅក្នុងអារម្មណ៍ដែលនៅក្រាស់ (ក្នុងអារម្មណ៍បុថុជ្ជន) រមែងមិនឈប់នៅក្នុងអារម្មណ៍តែមួយដែលជាខាងដើមប៉ុណ្ណោះ តែងនឹងស្ទុះទៅតាមប្រភេទ

អារម្មណ៍ដោយលំដាប់ ដូច្នោះ ទើបត្រាស់ ២ គាថាថា **យេកេចិ** ជាដើម ដើម្បីចិត្តដែលស្ទុះជាប់តាមទៅ ហើយឈប់នៅក្នុងអារម្មណ៍ដែលជាប្រភេទ នៃទុកៈ (ពួក ២) នៃសត្វ និងតិកៈ (ពួក ៣) នៃសត្វ មាន **តសថាវរទុកៈ** ជាដើម ។ ម្យ៉ាងទៀត ព្រោះហេតុដែលអារម្មណ៍ណា របស់បុគ្គលណា ជាអារម្មណ៍ដែលប្រាកដជាក់ច្បាស់ហើយ ចិត្តរបស់បុគ្គលនោះ រមែងតាំង នៅជាសុខក្នុងអារម្មណ៍នោះ ដូច្នោះ អារម្មណ៍ណារបស់ភិក្ខុរូបណា ក្នុង បណ្ដាភិក្ខុទាំងនោះ ប្រាកដច្បាស់ហើយ ព្រះមានព្រះភាគមាន ព្រះពុទ្ធ-បំណងនឹងឲ្យចិត្តរបស់ភិក្ខុរូបនោះ តាំងនៅក្នុងអារម្មណ៍នោះ ទើបត្រាស់ ២ គាថានេះថា **យេកេចិ** ជាដើម ដែលសំដែងសេចក្ដីផ្សេងគ្នានៃអារម្មណ៍ ជាទុកៈ និងតិកៈមាន **តសថាវរទុកៈ** ជាដើម ។

ពិតហើយ ក្នុង ២ គាថានោះ ព្រះមានព្រះភាគទ្រង់សំដែងទុកៈ (ពួក ២ នៃសត្វ) ៤ ទុកៈ គឺ **តសថាវរទុកៈ** ពួក ២ នៃសត្វអ្នកតក់ស្លុត និងអ្នកមាំមួន **ទិដ្ឋាទិដ្ឋទុកៈ** ពួក ២ នៃសត្វអ្នកដែលខ្លួនឃើញ ហើយ និងអ្នកដែលខ្លួនមិនទាន់ឃើញ **ទូរសន្តិកទុកៈ** ពួក ២ នៃសត្វអ្នក

នៅទីឆ្ងាយ និងអ្នកនៅទីជិត **ភូតសម្ភវេសីទុក:** ពួក ២ នៃសត្វអ្នកកើតហើយ និងអ្នកដែលស្វែងរកទីកើត , និងទ្រង់សំដែងតិក: (ពួក ៣ នៃសត្វ) ៣ តិក: គឺ **ទីឃរស្សមជ្ឈិមតិក:** ពួក ៣ នៃសត្វអ្នកមានអត្តភាពវែង ខ្លី និងកណ្តាល , **មហន្តាណុកមជ្ឈិមតិក:** ពួក ៣ នៃសត្វអ្នកមានអត្តភាពធំ តូច និងកណ្តាល , **ថូលាណុកមជ្ឈិមតិក:** ពួក ៣ នៃសត្វអ្នកមានអត្តភាពស្គម ធាត់ និងកណ្តាល ដោយមជ្ឈិមបទដែលជាទីកើតប្រយោជន៍ក្នុង ៣ តិក: និងអណុកថូលបទ ជាទីកើតប្រយោជន៍ក្នុង ២ តិក: ដោយបទ ៦ បទ មានទីឃបទជាដើម ។ បណ្តាបទទាំងនោះ បទថា **យេកេចិ (ពួកណាមួយ)** ជាបទសំដែងថា មិនមានចំណែកសេសសល់ឡើយ ។ ពួកសត្វដែលកើតហើយ គឺ **សត្វមានបាណ: (មានជីវិត)** ឈ្មោះថា **បាណភូត: (សត្វមានជីវិត)** ។ មយ៉ាងទៀត សត្វទាំងឡាយរមែងដកដង្ហើម ហេតុនោះ ទើបឈ្មោះថា **បាណ: (សត្វមានខ្យល់ដកដង្ហើម)** ។ ទ្រង់កាន់យកបញ្ចវោការសត្វ ដែលទាក់ទងនឹងអស្សាស-បស្សាស: (ខ្យល់ដកដង្ហើមចេញចូល) ដោយបទនេះ ។ សត្វទាំងឡាយ

រមែងកើត ហេតុនោះ ទើបឈ្មោះថា **ភូត** ។ ទ្រង់កាន់យកឯកវោការសត្វ និងចតុវោការសត្វ ដោយបទនេះ ។ បទថា **អត្ថិ** ប្រែថា មាន គឺ មានព្រម ។

ព្រះមានព្រះភាគ គ្រាទ្រង់សំដែងសត្វទាំងពួង ដែលទ្រង់សង្គ្រោះដោយទុកៈ និងតិកៈរួមគ្នា ដោយបទថា **យេកេចិ បាណភូតត្ថិ (សត្វមានជីវិតទាំងឡាយ ពួកណាមួយ... មានហើយ)** នេះ យ៉ាងនេះហើយ ឥឡូវនេះ ទ្រង់សង្គ្រោះសត្វសូម្បីទាំងអស់នោះ សំដែងដោយទុកៈនេះថា **តសា វា ថាវរា វា អនវសេសា (នៅជាអ្នកតក់ស្លុត ឬជាអ្នកមាំមួន មិនមានសេសសល់)** ។

ក្នុងទុកៈនេះ សត្វទាំងឡាយតក់ស្លុត ហេតុនោះ ទើបឈ្មោះថា **តសា (អ្នកតក់ស្លុត)** ។ ពាក្យនេះ ជាឈ្មោះរបស់សត្វទាំងឡាយអ្នកមានតណ្ហា និងមានភ័យ ។ សត្វទាំងឡាយរមែងមាំមួន ហេតុនោះ ទើបឈ្មោះថា **ថាវរា (អ្នកមាំមួន)** ពាក្យនេះ ជាឈ្មោះរបស់ព្រះអរហន្តទាំងឡាយអ្នកលះតណ្ហា និងភ័យបានហើយ ។ ចំណែកដ៏សេសរបស់សត្វពួកនោះ

មិនមាន ហេតុនោះ ទើបឈ្មោះថា **អនវសេសា (មិនមានសេសសល់)** លោកអធិប្បាយថា សូម្បីគ្រប់ពួកសត្វ ។ ក៏ពាក្យណាត្រាស់ទុកខាងចុង នៃគាថាទី ២ ពាក្យនោះ គប្បីភ្ជាប់ជាមួយទុក: និងតិក:ទាំងអស់ ។ បទថា **យេកេចិ បាណភូតត្ថិ (សត្វមានជីវិតទាំងឡាយ ពួកណាមួយ... មានហើយ)** សេចក្តីថា សត្វទាំងឡាយដែលតក់ស្លុតក្តី ដែលមាំមួនក្តី មិនមានសេសសល់ សូម្បីសត្វទាំងអស់នេះ ចូរជាអ្នកមានខ្លួនដល់នូវសេចក្តីសុខ ។ សូម្បីសត្វទាំងអស់ពួកនេះដែលកើតហើយក្តី ស្វែងរកទីកើតក្តី ចូរអ្នកមានខ្លួនដល់នូវសេចក្តីសុខចុះ ដោយប្រការដូច្នេះ ។

បណ្តាបទទាំង ៦ មាន **ទីឃា វា** ជាដើម ដែលសំដែងតិក: ៣ ពួក មាន **ទីឃរស្សមជ្ឈិមតិក:** ជាដើម ។ បទថា **ទីឃា (វែង)** បានដល់ សត្វមានអត្តភាពវែង មាននាគ ត្រី សត្វទន្សេងជាដើម ។ ពិតហើយ សូម្បីអត្តភាពរបស់នាគទាំងឡាយក្នុងមហាសមុទ្រ ក៏វែងច្រើនរយព្យាម ។ អត្តភាពរបស់ត្រី និងទន្សេងជាដើម ក៏មានវែងច្រើនយោជន៍ ។ បទថា **មហន្តា (ធំ)** បានដល់ សត្វមានអត្តភាពធំ ក្នុងទឹកក៏មានត្រី និងអណ្តើក

ជាដើម លើគោកក៏មានស្តេចដំរីជាដើម ក្នុងពពួកអមនុស្ស ក៏មានទានព (អសុរ) ជាដើម និងត្រាស់ថា "រាហូ" ជាកំពូលនៃសត្វដែលមានអត្តភាពទាំងឡាយ ។ ពិតហើយ អត្តភាពរបស់រាហូនោះ កម្ពស់ ៤.៨០០ យោជន៍ ប្រវែងដៃ ១.២០០ យោជន៍ ចន្លោះចិញ្ចើម ៥០ យោជន៍ ចន្លោះម្រាមដៃក៏ដូចគ្នា បាតដៃ ២០០ យោជន៍ ។ បទថា **មជ្ឈិមា (កណ្តាល)** បានដល់ អត្តភាពរបស់សេះ គោ ក្របី ជ្រូកជាដើម ។ បទថា **រស្សកា (ខ្លី)** បានដល់ សត្វទាំងឡាយមានខ្នាតទាប ត្រង់កណ្តាលវែង ត្រង់កណ្តាលធាត់ មានមនុស្សតឿជាដើម ក្នុងជាតិនោះៗ ។ បទថា **អណុកា (តូច)** បានដល់ សត្វទាំងឡាយដែលមានអត្តភាពល្អិត ដែលកើតនៅក្នុងទឹកជាដើម មិនជាអារម្មណ៍របស់មំសចក្ខុ ជាវិស័យរបស់ទិព្វចក្ខុ ឬសត្វតូចៗ មានសុចជាដើម ។ មួយទៀត សត្វពួកណាមានខ្នាតទាប ត្រង់កណ្តាលធំ និងត្រង់កណ្តាលធាត់ ក្នុងជាតិនោះៗ សត្វទាំងនោះ គប្បីជ្រាបថា តូច ។ បទថា **ថូលា (ធាត់)** បានដល់ សត្វទាំងឡាយ មានអត្តភាពមូល មានត្រី អណ្តើក គ្រុំ ខ្យង ជាដើម ។

## ពណ៌នាគាថាទី ៥

ព្រះដ៏មានព្រះភាគ ទ្រង់សម្តែងសត្វទាំងឡាយមិនមានសេសសល់ដោយតិក: ៣ យ៉ាងនេះហើយ ឥឡូវនេះ ទ្រង់សង្គ្រោះសត្វទាំងនោះដោយទុក: ៣ ទុក:ថា **ទិដ្ឋា វា យេ ច អទិដ្ឋា (ពួកណាដែលយើងឃើញហើយ ឬមិនបានឃើញ)** ជាដើម ។

បណ្តាបទទាំងនោះ បទថា **ទិដ្ឋា (ដែលយើងឃើញហើយ)** បានដល់ សត្វពួកណាធ្លាប់ឃើញហើយ ដែលមកប្រាកដដល់ភ្នែករបស់ខ្លួន ។ បទថា **អទិដ្ឋា (មិនបានឃើញ)** បានដល់ សត្វពួកណាស្ថិតនៅក្នុងសមុទ្រដទៃ ភ្នំដទៃ និងចក្រវាឡដទៃជាដើម ។ តែព្រះមានព្រះភាគទ្រង់សំដែងសត្វដទៃនៅឆ្ងាយ និងជិតចំពោះអត្តភាពរបស់ខ្លួន ដោយទុក:នេះថា **យេ ច ទូរេ វសន្តិ អវិទូរេ (ពួកណានៅក្នុងទីឆ្ងាយ ឬក្នុងទីជិត)** ។ សត្វទាំងនោះ គប្បីជ្រាបដោយសត្វមានជើង ២ និងសត្វមិនមានជើងជាដើម ។ ក៏ពួកសត្វដែលស្ថិតនៅក្នុងកាយរបស់ខ្លួន ហៅថា នៅជិត ពួកសត្វដែលនៅក្រៅកាយ ហៅថា នៅឆ្ងាយ ។ មួយទៀត ពួកសត្វដែលនៅក្នុងឧបចារ:

ហៅថា នៅជិត ។ ដែលនៅខាងក្រៅឧបចារៈ ហៅថា នៅឆ្ងាយ ។ ដែលនៅក្នុងព្រះវិហារ តាមជនបទ ទ្វីប ចក្រវាឡ ហៅថា នៅជិត , ដែលនៅក្នុងចក្រវាឡដទៃ ហៅថា នៅឆ្ងាយ ។

បទថា **ភូតា (កើតហើយ)** បានដល់ កើតហើយ បង្កើតហើយ ។ ព្រះខីណាស្រពពួកណាកើតហើយនោះឯង មិនរាប់ថានឹងកើតទៀត ពាក្យនោះ ជាឈ្មោះរបស់ព្រះខីណាស្រពទាំងនោះ ។ សត្វពួកណា ស្វែងរកទីកើត ហេតុនោះ សត្វពួកនោះ ឈ្មោះថា **សម្ភវេសី** ។ ពាក្យនេះជាឈ្មោះរបស់ព្រះសេក្ខៈ និងបុថុជ្ជនទាំងឡាយ ដែលកំពុងស្វែងរកទីកើតក្នុងអនាគត ព្រោះនៅលះភព និងសំយោជនៈនៅមិនទាន់បាន ។ ន័យម្យ៉ាងទៀត បណ្តាកំណើត ៤ ពួក សត្វដែលជាអណ្ឌជៈកើតនៅក្នុងពង និងជលាពុជៈកើតនៅក្នុងគភ៌ ដែលនៅមិនទាន់ទម្លាយសំបកពង និងប្រសូតចេញមកដរាបណា ដរាបនោះ ក៏ឈ្មោះថា **សម្ភវេសី** ។ ដែលទម្លាយសំបកពង និងប្រសូតចេញមកខាងក្រៅ ក៏ឈ្មោះថា **ភូតៈ** ។ ពួកសត្វដែលជាសំសេទជៈ និងឱបបាតិកៈ ឈ្មោះថា **សម្ភវេសី** ក្នុងខណៈបឋម-

ចិត្ត តាំងពីទុតិយខណៈចិត្តទៅ ឈ្មោះថា **ភូត** ។ ឬសត្វទាំងឡាយ កើតដោយឥរិយាបថណា នៅមិនទាន់ផ្លាស់ឥរិយាបថ ពីឥរិយាបថនោះដរាបណា ដរាបនោះនៅឈ្មោះថា **សម្ភវេសី** បន្ទាប់ពីនោះ ឈ្មោះថា **ភូត** ។

## ពណ៌នាគាថាទី ៦

ព្រះដ៏មានព្រះភាគ គ្រាទ្រង់សំដែងមេត្តាភាវនាក្នុងសត្វទាំងឡាយដោយប្រាថ្នាឲ្យចូលដល់ប្រយោជន៍សុខចំពោះភិក្ខុទាំងនោះ ដោយប្រការផ្សេងៗ ដោយ ២ គាថាកន្លះថា **សុខិនោ វា (ជាអ្នកមានសុខ)** ជាដើមយ៉ាងនេះហើយ ឥឡូវនេះ កាលទ្រង់សំដែងមេត្តាភាវនានោះ សូម្បីដោយបំណងឲ្យចេញចាកវត្ថុដែលមិនជាប្រយោជន៍ និងទុក្ខ ទើបត្រាស់ថា **ន បរោ បរំ និកុព្វេថ (សត្វដទៃមិនគប្បីគម្រាមកំហែងសត្វដទៃ)** ។ នេះជាបាឋៈចាស់ តែបច្ចុប្បន្នសូត្រថា **បរំ ហិ** ដូច្នេះក៏មាន បាឋៈនេះ មិនល្អ ។

បណ្តាបទទាំងនោះ បទថា **បរោ (សត្វដទៃ)** បានដល់ ជនដទៃ ។ បទថា **បរំ (សត្វដទៃ)** បានដល់ នូវជនដទៃ ។ បទថា **ន និកុព្វេថ (មិន**

គប្បីគម្រាមកំហែង) បានដល់ មិនកម្ចាត់ ។ បទថា **នាតិមញ្ញេថ** (មិនគប្បីមើលងាយ) បានដល់ មិនគប្បីមើលងាយ ។ បទថា **កត្ថចិ** (ក្នុងទីណាៗ) បានដល់ ក្នុងឱកាសណាៗ គឺ ក្នុងស្រុក ឬក្នុងតំបន់នៃស្រុក កណ្តាលញាតិ ឬកណ្តាលបុគ្គល ដូច្នេះជាដើម ។ បទថា **នំ** ប្រែថា នោះ ។ បទថា **កិញ្ចិ** (នរណាៗ) បានដល់ បុគ្គលណាមួយ គឺ ក្សត្រ ឬព្រាហ្មណ៍ គ្រហស្ថ ឬបព្វជិត ដែលដល់នូវសុខ ឬដល់នូវទុក្ខ ដូច្នេះជាដើម ។ បទថា **ព្យារោសនា បដិឃសញ្ញា** (ព្រោះសេចក្តីក្រោធ និងគំនុំ) បានដល់ ព្រោះសេចក្តីក្រោធ ដោយកាយវិការ និងវចីវិការ និងព្រោះគំនុំដោយមនោវិការ ។ ព្រោះកាលនឹងគួរត្រាស់ថា **ព្យារោសនាយ បដិឃសញ្ញាយ** តែក៏ត្រាស់ហៅថា **ព្យារោសនា បដិឃសញ្ញា** ដូចកាលគួរនឹងត្រាស់ថា **សម្មទញ្ញាយ វិមុត្តា** តែក៏ត្រាស់ថា **សម្មទញ្ញា វិមុត្តា** និងដូចកាលគួរនឹងត្រាស់ថា **អនុបុព្វសិក្ខាយ អនុបុព្វកិរិយាយ អនុបុព្វបដិបទាយ** តែក៏ត្រាស់ថា **អនុបុព្វសិក្ខា អនុបុព្វកិរិយា អនុបុព្វបដិបទា អញ្ញារាធនា** ដូច្នោះ ។ បទថា **នាញ្ញមញ្ញស្ស ទុក្ខមិច្ឆេយ្យ** ប្រែថា មិន

គប្បីប្រាថ្នាទុក្ខដល់គ្នានឹងគ្នា ។ លោកអធិប្បាយទុកយ៉ាងណា? លោកអធិប្បាយទុកថា មិនមែនចម្រើនមេត្តាដោយមនសិការជាដើមថា សូមសត្វទាំងឡាយចូរមានសេចក្តីសុខ មានសេចក្តីក្សេមចុះ ដូច្នេះតែម្យ៉ាង ដែលពិត គប្បីមនសិការយ៉ាងនេះថា ឱហ្ន៎ បុគ្គលដទៃមិនថានរណាៗ មិនគប្បីគម្រាមបុគ្គលដទៃៗ ឡើយ ដោយកិរិយាកោង មានការកុហកបោកបញ្ឆោតជាដើម មិនគប្បីមើលងាយបុគ្គលដទៃមិនថានរណាៗ មិនថាក្នុងប្រទេសណាៗ ដោយវត្ថុនៃមានះ ៩ យ៉ាង មានជាតិជាដើម និងមិនគប្បីប្រាថ្នាទុក្ខដល់គ្នានឹងគ្នា ព្រោះសេចក្តីក្រោធ ឬព្រោះការចងគំនុំ ដូច្នេះថែមទៀតផង ។

## ពណ៌នាគាថាទី ៧

ព្រះមានព្រះភាគ លុះទ្រង់សំដែងមេត្តាភាវនា ដោយអត្ថ ដោយពុទ្ធបំណាងឲ្យចេញចាកវត្ថុដែលមិនជាប្រយោជន៍ និងទុក្ខ យ៉ាងនេះហើយឥឡូវនេះ កាលទ្រង់សំដែងមេត្តាភាវនានោះឯងដោយឧបមា ទើបត្រាស់ថា **មាតា យថា និយំ បុត្តំ** (មាតាថ្នមបុត្ររបស់ខ្លួន... យ៉ាងណា) ជាដើម ។

គាថានោះមានសេចក្ដីថា មាតាគប្បីរក្សាបុត្ររបស់ខ្លួន គឺ បុត្រដែលកើតអំពីខ្លួន កើតពីទ្រូង គប្បីថ្នាក់ថ្នមបុត្រនោះ ដែលមានតែមួយប៉ុណ្ណោះ ដោយអាយុ គឺ រមែងលះបង់សូម្បីអាយុរបស់ខ្លួន ដើម្បីរក្សាបុត្រនោះ រារាំងហាមទុក្ខដែលមកដល់បុត្រនោះ យ៉ាងណា ភិក្ខុគប្បីធ្វើចិត្តដែលប្រកបដោយមេត្តានេះឲ្យចម្រើន គឺ ឲ្យកើតរឿយៗ ឲ្យផ្សាយទៅនិងញុំាងមេត្តាភាវនានោះឲ្យចម្រើនមិនមានប្រមាណ ដោយកាន់យកសត្វមិនមានប្រមាណជាអារម្មណ៍ ឬដោយផ្សាយទៅមិនមានសេសសល់ សូម្បីតែសត្វមួយ ដូច្នោះ ។

## ពណ៌នាគាថាទី ៨

ព្រះមានព្រះភាគ លុះទ្រង់សំដែងមេត្តាភាវនាដោយអាការទាំងពួងយ៉ាងនេះហើយ ឥឡូវនេះ កាលទ្រង់សំដែងការចម្រើនមេត្តាភាវនានោះឯងទើបត្រាស់ថា មេត្តញ្ច សព្វលោកស្មិ (មេត្តា... ក្នុងលោកទាំងពួង) ជាដើម ។

ក្នុងគាថានោះ ឈ្មោះថា មិត្រ ព្រោះស្រឡាញ់ និងរក្សា អធិប្បាយ

ថា ព្រួយបារម្ភ ព្រោះមានអធ្យាស្រ័យបំណងប្រយោជន៍ដ៏ចម្រើន និងរក្សាឲ្យផុតចាកការមកដល់នូវវត្ថុដែលមិនជាប្រយោជន៍ ។ ការមានមិត្រឈ្មោះថា **មេត្តា** ។ បទថា **សព្វលោកស្មឹ (ក្នុងលោកទាំងពួង)** បានដល់ក្នុងសត្វលោកមិនមានសល់ ។ មានក្នុងចិត្ត ហេតុនោះ ទើបឈ្មោះថា **មានសៈ** ។ ក៏បទថា **មានសំ (មានក្នុងចិត្ត)** នោះ លោកពោលយ៉ាងនេះ ក៏ព្រោះប្រកបជាមួយចិត្ត ។ បទថា **ភាវយេ** ប្រែថា គប្បីចម្រើន ។ ប្រមាណនៃមានសៈនោះ មិនមាន ហេតុនោះទើបឈ្មោះថា **អបរិមាណ (មិនមានប្រមាណ)** ។ លោកពោលយ៉ាងនេះ ក៏ព្រោះមេត្តាដែលមានសត្វមិនមានប្រមាណជាអារម្មណ៍ ។ បទថា **ឧទ្ធំ** ប្រែថា ខាងលើ ។ ទ្រង់កាន់យកអរូបភពដោយបទនោះ ។ បទថា **អធោ** ប្រែថា ខាងក្រោម ទ្រង់កាន់យកកាមភពដោយបទនោះ ។ បទថា **តិរិយំ** ប្រែថា ខាងទទឹង ទ្រង់កាន់យករូបភពដោយបទនោះ ។ បទថា **អសម្ពាធំ (ដែលមិនចង្អៀត)** បានដល់ វៀរចាកសេចក្តីចង្អៀត ។ លោកអធិប្បាយថា មានព្រំដែនផ្សេងគ្នា (មិនមានព្រំដែន) ។ សត្រូវ លោកហៅឈ្មោះថា ព្រំដែន អធិប្បាយថា

ប្រព្រឹត្តទៅក្នុងព្រំដែននោះ ។ បទថា **អវេរំ (មិនមានពៀរ)** បានដល់ វៀរចាកពៀរ អធិប្បាយថា វៀរចាកការប្រកាន់ចេតនាចងពៀរ សូម្បីក្នុងចន្លោះៗ ។ បទថា **អសបត្តំ (មិនមានសត្រូវ)** បានដល់ ប្រាសចាកសត្រូវ ។ ពិតហើយ បុគ្គលអ្នកនៅដោយមេត្តា រមែងជាទីស្រឡាញ់របស់មនុស្ស ជាទីស្រឡាញ់របស់អមនុស្ស ។ សត្រូវណាៗ របស់គេរមែងមិនមាន ។ ព្រោះហេតុនោះ មានសៈ (វត្ថុដែលមានក្នុងចិត្ត) របស់គេនោះ លោកទើបហៅថា មិនមានសត្រូវ ព្រោះប្រាសចាកសត្រូវ ។ ក៏ពាក្យថា សត្រូវ សត្រូវ នោះ ជាពាក្យដោយបរិយាយ ។ ការពណ៌នាសេចក្តីតាមបទ មានប៉ុណ្ណោះ ។

ចំណែកការសំដែងសេចក្តីដែលបំណង ក្នុងទីនេះមានដូច្នេះ ៖

គប្បីផ្សាយមេត្តាដែលត្រាស់ទុកថា **ឯវម្បិ សព្វភូតេសុ មានសំភាវយេ អបរិមាណំ (គប្បីចម្រើនមេត្តាមានក្នុងចិត្តមិនមានប្រមាណ ក្នុងសត្វទាំងឡាយ សូម្បីដូច្នោះ)** ដូច្នេះ ផ្សាយមេត្តាដែលមានក្នុងចិត្តមិនមានប្រមាណ ឲ្យសម្រេចដល់ការចម្រើនលូតលាស់បរិបូណ៌ក្នុងលោកទាំងពួង ។

តើដូចម្តេច? គឺ ផ្សាយមេត្តានោះមិនមានសេសសល់ ទាំងខាងលើ ខាងក្រោម ខាងទទឹង គឺ ខាងលើក៏តាំងអំពីភវគ្គព្រហ្មចុះមក ខាងក្រោមតាំងពីអវិចីនរកឡើងទៅ ខាងទទឹង គឺ ទិសដ៏សេស ឬខាងលើ ក៏បានដល់អរូបធាតុ ខាងកណ្តាលក៏បានដល់កាមធាតុ ខាងទទឹងក៏បានដល់រូបធាតុ ។ កាលចម្រើនមេត្តាយ៉ាងនេះ ធ្វើមិនឲ្យមានសេចក្តីចង្អៀត មិនឲ្យមានពៀរ និងមិនឲ្យមានសត្រូវ ។ គប្បីចម្រើនមេត្តានោះ ដោយប្រការដែលមិនមានសេចក្តីចង្អៀតចង្អល់ មិនមានពៀរ និងមិនមានសត្រូវ ។ ឬថា មេត្តានោះដល់ភាវនាសម្បទា ជាគុណ ឈ្មោះថា មិនចង្អៀត ព្រោះជាឱកាសលោកទាំងពួង (គឺ ៣១ ភូមិ) ជាគុណ ឈ្មោះថា មិនមានពៀរ ព្រោះកម្ចាត់អាឃាតរបស់ខ្លួនក្នុងសត្វដទៃ ជាគុណ ឈ្មោះថា មិនមានសត្រូវ ព្រោះកម្ចាត់អាឃាតរបស់សត្វដទៃក្នុងខ្លួន ក៏គប្បីចម្រើនផ្សាយមេត្តាដែលមានក្នុងចិត្តនោះ ដែលមិនចង្អៀត មិនមានពៀរ មិនមានសត្រូវ មិនមានប្រមាណក្នុងលោកទាំងពួង ដោយកំណត់ទិសទាំង ៣ គឺ ខាងលើ ខាងក្រោម និងខាងទទឹង ។

## ពណ៌នាគាថាទី ៥

ព្រះមានព្រះភាគ កាលទ្រង់សំដែងការចម្រើនមេត្តាភាវនាយ៉ាងនេះហើយ ឥឡូវនេះ កាលទ្រង់សំដែងការមិនមានឥរិយាបថពិតប្រាកដរបស់អ្នកប្រកបរឿយៗ ក្នុងការចម្រើនមេត្តានោះហើយ ទើបត្រាស់ថា **ទិដ្ឋំ ចរំ ។បេ។ អធិដ្ឋេយ្យ (ឈរក្តី ដើរក្តី ។ល។ ក៏គប្បីតាំងសតិ)** ដូច្នេះ ។

គាថានោះមានសេចក្តីថា អ្នកចម្រើនមេត្តា កាលចម្រើនមេត្តាមានក្នុងចិត្តនេះយ៉ាងនេះ មិនចាំបាច់កំណត់ឥរិយាបថ ដូចក្នុងបាលីថា អង្គុយពត់ភ្នែន តាំងកាយឲ្យត្រង់ ដូច្នេះជាដើម កាលធ្វើការបន្ទោបង់ ដោយការចុករោយព្រោះឥរិយាបថណាមួយ តាមសប្បាយ នឹងឈរ ឬដើរ អង្គុយ ឬដេក ក៏ជាអ្នកប្រាសចាកសេចក្តីងោកងក់ ត្រឹមណា ក៏គប្បីតាំងសតិក្នុងមេត្តានោះ ទុកត្រឹមនោះ ។

ន័យម្យ៉ាងទៀត ព្រះមានព្រះភាគ កាលទ្រង់សំដែងការចម្រើនមេត្តាភាវនា យ៉ាងនេះហើយ ឥឡូវនេះ កាលទ្រង់សំដែងភាពជាអ្នកជំនាញ ទើបត្រាស់ថា **តិដ្ឋំ ចរំ (ឈរក្តី ដើរក្តី)** ជាដើម ។ ពិតហើយ អ្នកជំនាញ

ហើយ ប្រាថ្នានឹងតាំងសតិក្នុងមេត្តាឈានដោយឥរិយាបថណា នឹងឈរ ឬដើរ នឹងអង្គុយ ឬដេក ក៏បាន ។ ន័យមួយទៀត អ្នកជំនាញ នឹងឈរ ឬដើរ នឹងអង្គុយ ឬដេក ព្រោះហេតុនោះ ការឈរជាដើម រមែងមិនធ្វើអន្តរាយដល់បុគ្គលនោះ ។ មួយទៀត អ្នកជំនាញ ប្រាថ្នានឹងតាំងសតិទុកក្នុងមេត្តាឈាននេះត្រឹមណា ក៏ជាអ្នកប្រាសចាកការងោកងក់ ទើបតាំងសតិទុកបានត្រឹមនោះ ។ ការយឺតយូរក្នុងមេត្តាឈាននោះ របស់អ្នកនោះ រមែងមិនមាន ។ ព្រោះហេតុនោះ ទើបត្រាស់ថា "នឹងឈរ ឬដើរ អង្គុយ ឬដេក ក៏ជាអ្នកប្រាសចាកការងោកងក់ត្រឹមណា ក៏គប្បីតាំងសតិនោះទុកត្រឹមនោះ" ។

គាថានោះមានអធិប្បាយដូច្នេះ បុគ្គលអ្នកជំនាញគប្បីចម្រើនមេត្តាដែលទ្រង់ត្រាស់ទុកថា **មេត្តញ្ច សព្វលោកស្មឹ មានសំ ភាវយេ (គប្បីចម្រើនមេត្តាមានក្នុងចិត្តក្នុងលោកទាំងពួង)** ដោយប្រការដែលអ្នកជំនាញមិនចាំបាច់អើពើដោយឥរិយាបថ បណ្តាឥរិយាបថ មានឈរជាដើម ក៏ប្រាថ្នានឹងតាំងសតិក្នុងមេត្តាឈាននោះ ត្រឹមណា ជាអ្នកប្រាសចាកសេចក្តី

ងោកង៉ុយហើយ ក៏គប្បីតាំងសតិនោះទុកត្រឹមនោះ ។

ព្រះមានព្រះភាគ កាលទ្រង់សំដែងភាពជាអ្នកជំនាញនៅក្នុងមេត្តា-ភាវនា យ៉ាងនេះ ទ្រង់ប្រកបភិក្ខុទុកក្នុងមេត្តាវិហារ (ការនៅដោយមេត្តា) នោះថា **ឯតំ សតឹ អធិដ្ឋេយ្យ (គប្បីតាំងសតិនោះទុក)** ឥឡូវនេះ កាលទ្រង់សរសើរការនៅនោះ ទើបត្រាស់ថា **ព្រហ្មមេត្តំ វិហារំ ឥធមាហុ (អ្នកប្រាជ្ញទាំងឡាយហៅការនៅនេះថា ជាព្រហ្មវិហារក្នុងសាសនានេះ)** ។

គាថានោះ មានអត្ថថា ការនៅដោយមេត្តាណា ដែលទ្រង់សរសើរផ្តើមពីព្រះពុទ្ធត្រាស់ថា **សុខិនោ វា ខេមិនោ វា ហោន្តុ (ចូរជាអ្នកមានសេចក្តីសុខ ឬមានសេចក្តីក្សេម)** រហូតដល់ព្រះពុទ្ធត្រាស់ថា **ឯតំ សតឹ អធិដ្ឋេយ្យ (គប្បីតាំងសតិនោះទុកត្រឹមនោះ)** ។ អ្នកប្រាជ្ញទាំងឡាយពោលការនៅដោយមេត្តានោះថា **ព្រហ្មវិហារ (ការនៅដូចព្រហ្ម)** ពោលការនៅដោយមេត្តានោះថា **សេដ្ឋវិហារ (ការនៅដ៏ប្រសើរ)** ក្នុងព្រះសាសនា គឺ ក្នុងធម្មវិន័យ របស់ព្រះអរិយនេះ ព្រោះមិនមានទោសក្នុងការនៅដូចជាទិព្វ នៅដូចព្រហ្ម នៅដូចព្រះអរិយៈ និងនៅដោយឥរិយាបថទាំង ៤

និងការនៅដោយមេត្តានោះ ធ្វើប្រយោជន៍ដល់ខ្លួន និងដល់អ្នកដទៃ ។ ព្រោះហេតុនៃសេចក្តីស្ងប់ជាប់តគ្នា មិនត្រូវជ្រៀតជ្រែក ដូច្នោះ អ្នកចម្រើនមេត្តា ឈរក្តី ដើរក្តី អង្គុយក្តី ដេកក្តី កាលមិនទាន់ងោកងក់ត្រឹមណា ក៏គប្បីតាំងសតិនោះទុកត្រឹមនោះ ។

## ការពណ៌នាគាថាទី ១០

ព្រះមានព្រះភាគ កាលទ្រង់សំដែងមេត្តាភាវនាប្រការផ្សេងៗ ដល់ភិក្ខុទាំងនោះ យ៉ាងនេះហើយ ឥឡូវនេះ ព្រោះហេតុដែលមេត្តានៅជិតអត្តទិដ្ឋិ (ការឃើញថាជាខ្លួន) ព្រោះមានសត្វជាអារម្មណ៍ ដូច្នោះ លុះទ្រង់សំដែងការសម្រេចអរិយភូមិ ធ្វើមេត្តាឈាននោះៗ ឯងឲ្យជាបាទដល់ភិក្ខុទាំងនោះ ដោយហាមការប្រកាន់ដោយទិដ្ឋិនាំមុខ ទើបទ្រង់បញ្ចប់ទេសនាដោយគាថានេះថា **ទិដ្ឋិញ្ច អនុបគ្គម្ម (មិនចូលដល់ទិដ្ឋិ)** ជាដើម ។

គាថានោះ មានអត្ថថា ការនៅដោយមេត្តាឈានណា ដែលទ្រង់សរសើរទុកថា "អ្នកប្រាជ្ញទាំងឡាយពោលការនៅនោះថា ជាព្រហ្មវិហារក្នុងធម្មវិន័យនេះ" អ្នកចម្រើនមេត្តា ចេញចាកការនៅដោយមេត្តានោះហើយ

កំណត់នាមធម៌ មានវិតក្ក វិចារៈជាដើម ក្នុងទីនោះ និងរូបធម៌តាមការកំណត់ (នាម) ធម៌ទាំងនោះជាដើម និងដោយការកំណត់នាមរូប ក៏មិនប្រកាន់ដោយទិដ្ឋិយ៉ាងនេះថា នេះជាគំនរសង្ខារសុទ្ធ បុគ្គលរមែងប្រកាន់មិនបានថា សត្វក្នុងសង្ខារនេះ ដូច្នេះ ជាអ្នកមានសីល ដោយលោកុត្តរ-សីលតាមលំដាប់ ដល់ព្រមដោយទស្សនៈ ដែលគេដឹងថា ជាសម្មាទិដ្ឋិក្នុងសោតាបត្តិមគ្គ ដែលប្រកបដោយលោកុត្តរសីល តពីនោះ ក៏នាំចេញកម្ចាត់ រម្ងាប់ការរោកង៉ុយក្នុងកាមទាំងឡាយ គឺ កិលេសកាមដែលមិនទាន់លះបាន ដោយធ្វើឲ្យស្រាលស្តើងដោយសកទាគាមិមគ្គ និងអនាគា-មិមគ្គ និងដោយការលះមិនឲ្យមានសេសសល់ឡើយ ក៏រមែងមិនចូលដល់ការដេកក្នុងគភ៌មាតាទៀត គឺ មិនត្រូវដេកក្នុងគភ៌ទៀតដោយពិត បានដល់កើតក្នុងពួកទេវតាជាន់សុទ្ធាវាសទាំងឡាយ សម្រេចព្រះអរហត្ត ហើយបរិនិព្វានក្នុងជាន់សុទ្ធាវាសនោះឯង ។

ព្រះមានព្រះភាគ កាលទ្រង់បញ្ចប់ទេសនាយ៉ាងនេះហើយ ត្រាស់ចំពោះភិក្ខុទាំងនោះថា "ទៅចុះភិក្ខុទាំងឡាយ ពួកអ្នកចូរនៅក្នុងដងព្រៃ

នោះ និងចូរគោះគោំងក្នុងថ្ងៃធម្មស្សវនៈ ៨ ថ្ងៃ ក្នុងខែ ហើយចូរស្វាធ្យាយព្រះសូត្រនេះ ចូរធ្វើធម្មកថា ពោលធម៌ សន្ទនាធម៌ អនុមោទនាគ្នា ចូរសេព ចូរចម្រើន ធ្វើឲ្យច្រើននូវកម្មដ្ឋាននេះឯង ពួកអមនុស្សទាំងនោះ នឹងមិនសំដែងអារម្មណ៍គួរភ័យខ្លាចនោះ នឹងជាអ្នកប្រាថ្នាល្អ ប្រាថ្នានូវប្រយោជន៍ដល់ពួកអ្នកដោយពិត" ។ ភិក្ខុទាំងនោះទទួលព្រះតម្រាស់ហើយក្រោកចាកអាសនៈ ក្រាបថ្វាយបង្គំព្រះមានព្រះភាគ ហើយធ្វើប្រទក្សិណទៅកាន់ដងព្រៃនោះ ហើយធ្វើតាមដែលទ្រង់ទូន្មានគ្រប់ប្រការ ។ ទេវតាទាំងឡាយកើតបីតិសោមនស្សថា លោកម្ចាស់ទាំងឡាយ នាំសេចក្តីសុខនាំប្រយោជន៍មកឲ្យពួកយើង ក៏នាំគ្នារក្សា បោសសំអាតសេនាសនៈចាត់ចែងទឹកក្តៅ គក់ប្របាច់ខ្នង ប្របាច់ជើង ទុកដាក់ និងរក្សាទុក ។ ភិក្ខុសូម្បីទាំងនោះ ក៏នាំគ្នាចម្រើនមេត្តានោះ ធ្វើមេត្តានោះឲ្យជាបាទ ចម្រើនវិបស្សនា ក៏សម្រេចព្រះអរហត្តដែលជាផលដ៏វិសេស ខាងក្នុងត្រៃមាសនោះឯងគ្រប់ៗ រូប បវារណាដោយវិសុទ្ធិបវារណាក្នុងថ្ងៃមហាបវារណានោះឯង ។

ព្រះតថាគតទ្រង់ជាម្ចាស់នៃធម៌ អ្នកទ្រង់ឈ្លាសក្នុងប្រយោជន៍ ត្រាស់ករណីមេត្តសូត្រ ដែលមានប្រយោជន៍ដោយប្រការដូច្នេះ ។

ភិក្ខុទាំងឡាយ អ្នកមានបញ្ញាបរិបូរ បានទទួលសេចក្តីស្ងប់នៃហឫទ័យក្រៃលែង ក៏សម្រេចសន្តិបទ ។

ព្រោះដូច្នោះ វិញ្ញូជនប្រាថ្នាសម្រេចសន្តិបទដែលជាអមតៈ ដ៏អស្ចារ្យ ដែលព្រះអរិយៈស្រឡាញ់ហើយ ក៏គប្បីធ្វើករណីយកិច្ចដែលមានប្រយោជន៍ ផ្សេងដោយសីល សមាធិ បញ្ញាដែលគ្មានមន្ទិល ជាប់តគ្នាមិនដាច់ខ្សែចុះ ។

ចប់អដ្ឋកថា មេត្តសូត្រទី ៩

# និគមគាថា

*ដោយកថាមានប្រមាណប៉ុណ្ណោះ ខ្ញុំនឹងពោលពាក្យណាទុកថា ៖*

*ខ្ញុំសូមមនស្ការព្រះរតនត្រ័យដ៏ប្រសើរខ្ពង់ខ្ពស់ ជាវត្ថុ*

*ដែលគួរនមស្ការហើយ នឹងតែងអដ្ឋកថានៃខុទ្ទកបាឋៈខ្លះ ។*

*ក្នុងពាក្យនោះ ដែលខ្ញុំបានតែងអដ្ឋកថានៃខុទ្ទកបាឋៈ ៩ ប្រភេទ គឺ ១.សរណៈ ២.សិក្ខាបទ ៣.ទ្វត្តឹង្សាការ ៤.កុមារបញ្ហា ៥.មង្គលសូត្រ ៦.រតនសូត្រ ៧.តិរោកុឌ្ឌសូត្រ ៨.និធិកណ្ឌសូត្រ និង ៩.មេត្តសូត្រ ។ ព្រោះហេតុនោះ ខ្ញុំទើបពោលពាក្យថា ៖*

*ខ្ញុំបំណងនឹងឲ្យព្រះសទ្ធម្មតាំងមាំ ទើបតែងអដ្ឋកថា*

*នៃខុទ្ទកបាឋៈនេះ ប្រសព្វកុសលឯណា ។ សូមជននេះ*

*ចូរឆាប់សម្រេចសេចក្តីចម្រើន លូតលាស់ បរិបូណ៌ក្នុង*

*ធម៌ ដែលព្រះអរិយៈប្រកាសហើយ ដោយអនុភាពនៃ*

*កុសលនោះ ។*

*អដ្ឋកថានៃខុទ្ទកបាឋៈ ឈ្មោះបរមត្ថជោតិកានេះ រចនាដោយព្រះថេរៈ*

ដែលគ្រូទាំងឡាយថ្វាយនាមថា **ពុទ្ធឃោសៈ** អ្នកប្រដាប់ដោយគុណ គឺសេចក្ដីបរិសុទ្ធយ៉ាងក្រៃលែង ការជឿ ការដឹង និងសេចក្ដីព្យាយាម ដែលគុណសមុទ័យ គឺ សីល អាចារៈ អាជវៈ និងមទ្ទវៈជាដើមបណ្ដាលហើយ អ្នកអាចឈានចុះកាន់ព្រៃ គឺ លទ្ធិខ្លួន និងលទ្ធិដទៃ ប្រកបដោយការដឹងការឈ្លាស អ្នកមានប្រភាព គឺ អំណាចនៃញាណដែលមិនមានអ្វីរារាំងក្នុងសត្ថុសាសន៍ ដែលផ្សេងដោយព្រះត្រៃបិដក បរិយត្តិធម៌ ព្រមទាំងអដ្ឋកថា ប្រកបដោយលម្អនៃវចនៈដ៏ពីរោះ ឱឡារិក ដែលថ្លែងបានងាយនិងញុំាងសម្បត្តិ គឺ ករណៈឲ្យកើតហើយដោយមហាវេយ្យាករណ៍ ជាអ្នកមានវាទៈត្រឹមត្រូវ បែកធ្លាយ មានវាទៈដ៏ប្រសើរ ជាមហាកវី ជាអ្នកមានសេចក្ដីបរិសុទ្ធ និងសេចក្ដីដឹងទូលំទូលាយ ជាអលង្ការនៃវង្សរបស់ព្រះថេរៈទាំងឡាយអ្នកនៅក្នុងមហាវិហារ ជាប្រទីបនៃថេរវង្ស (ថេរវាទ) ដែលមានការដឹងមុតមាំល្អហើយក្នុងធម៌ដ៏ក្រៃលែងរបស់មនុស្ស ដែលប្រដាប់ដោយគុណ ផ្សេងដោយអភិញ្ញា ៦ និងបដិសម្ភិទាជាដើម ។

**តាវ តិដ្ឋតុ លោកស្មឹ លោកនិត្ថរណេសិនំ**

*ទស្សេន្តី កុលបុត្តានំ        នយំ សីលាទិសុទ្ធិយា*

*យាវ ពុទ្ធោតិ នាមម្បិ      សុទ្ធចិត្តស្ស តាទិនោ*

*លោកម្ហិ លោកជេដ្ឋស្ស    បវត្តតិ មហេសិនោ ។*

*(គម្ពីរបរមត្ថជោតិកា) ដែលសំដែងន័យនៃវិសុទ្ធិជាដើម ដល់កុល-បុត្រទាំងឡាយ ដែលស្វែងរកការចេញចាកលោក ចូរតាំងនៅក្នុងលោកដរាបស្មើ សូម្បីព្រះនាមថាពុទ្ធៈនៃភិក្ខុអ្នកមានចិត្តបរិសុទ្ធ អ្នកមុតមាំ អ្នកចម្រើនបំផុតនៃលោក ដែលទ្រង់ស្វែងរកព្រះគុណដ៏ធំក្រៃលែង ឲ្យប្រព្រឹត្តទៅហើយក្នុងលោកចុះ ។*

ចប់អដ្ឋកថា ខុទ្ទកបាឋៈ

នៃ

អដ្ឋកថាខុទ្ទកនិកាយ ឈ្មោះថា បរមត្ថជោតិកា

# រាយនាមសប្បុរសជន
# ចូលរួមកសាងគម្ពីរអដ្ឋកថា

-លោកគ្រូអគ្គបណ្ឌិត .............................. $ 2.000 USA

-ឧបាសក តាំង សុជល ឧបាសិកា ឡុង កេង ព្រមទាំងបុត្ត និងចៅ $ 200 USA

-ឧបាសិកា តាំង ស៊ីថា ព្រមទាំងស្វាមី និងបុត្ត ......... $ 100 USA

-ឧបាសិកា តាំង ដល្យា ព្រមទាំងស្វាមី និងបុត្ត ......... $ 100 USA

-កុមារី តាំង សុមាវតី ......................................... $ 100 USA

-ឧបាសិកា រូច លាង ព្រមទាំងបុត្ត .............................. $ 100 AUS


នត្ថិ សន្តិ បរំ សុខំ
ព្រះរាជាណាចក្រកម្ពុជា